គ្រួមជំនួញនៃទស្សៀមធម្លាប់
COMMISSION DES MOEURS & COUTUMES

ភាសិតសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៥ ខែកក្កដា លេខ ៧
1953
ព.ស. ២៤៩៦ – គ.ស. ១៩៥៣



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
– សង្គហធម៌	ព្រះជាឡាត់នត្តមលិទ្ធសុង-ស៊ីវ	៤៨៣
– កឋិនកថា (តមក)	ព្រះមហានត្តមវិជ្ជា កែ-អឿន	៤៩៨
– ប្រវត្តិព្រះអភិធម្ម	ឃុនសិរីមេធីស្រី-អ៊ូ	៥០៥
ផ្នែកអក្សរសាស្ត្រ		
– ការបណ្តុះនិស្ស័យ (តមក)	ព្រះមហានត្តមវិជ្ជា ប៊ឹង-ប៉ម	៥០៨
– រឿងសាមកុក (តមក)	នកញ៉ា នូ-កន	៥១៥
– រឿងអារ៉ាក្សថ្លែងរឿងម្តែប្រាំ (តមក)	លោក ភ័យ-ប៊ុក	៥២៤
– រឿងចិញ្ចៀនទិព្យ (តមក)	អ្នកស្រីសារីយ៉ាន	៥៣៣
– រឿងប៉ូលនិងវីស៊ីនី (តមក)	លោក ផេង-ជ្រឿ	៥៣៩
– សកម្មភាពនៃក្រមជំនុំទំនៀមទម្លាប់ខ្មែរ (ល្បែងទាញព្រ័ត្រ)	លោក ចាប-ពិន	៥៤៤
– ទិដ្ឋានុគតិ	លោក ផែន-វ័ន ក្រសួងបឋមសិក្សា សៀមរាប	៥៥១
កំណត់ទឹងប្រវត្តិការណ៍		
–សុន្ទរកថាបណ្ឌិតម៉ាល៉ាឡាសេកេរៈថ្លែងក្នុងសមាជសាកលលើកទី ២ នៃពុទ្ធសាសនា	(តមក) ពុទ្ធសាសនបណ្ឌិត្យ	៥៥៦

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដារ ១៨.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE		Pages
—Sangahadharma	*Brah Balat Uttamalikhit Song-Sieu*	483
— Kathinakatha (suite)..... ...	*Brah Maha Ker-œrun*	498
— Abhidhamma	*M. Srey-ou*...	505
PARTIE LITTERAIRE		
— Education morale (suite)....	*Brah Maha Peung-Pam*.	508
— Histoire de SAMŒOK (suite)..	*Oknha Nou-Kan*	515
— Les vingt cinq récits du Mauvais Génie (suite)	*M. Ray-Buc*	524
— La bague magique (suite)....	*Mme SARIS-YANN*.....	533
— Paul et Virginie (suite)	*M. Phéng-Chrieu*	539
— Activité de la Commission des Mœurs et Coutumes (Jeu de corde).....	*M. Chap-Pin*	544
— Ditthânugati.....	*M. Phen-Von, Enseignement Primaire Siemreap*.....	551
NOTES ET CHRONIQUES		
— Discours du Dr. MALALASEKERA au 2e Congrès Mondial Bouddhique (suite)	*Institut Bouddhique*	556

Prix d'abonnement annuel comprenant 12 numéros : 192$00

ព្រះបាទ្បាត់ឧត្តមលិខិត សុង-ស៊ីរ៉ វត្តលង្កា ភ្នំពេញ

ទេសនាដាក់វិប្បទេសកម្ពុជា ៣លើកថ្ងៃ ៧កេច ខែដាំល្អ ឆ្នាំជូតសំរឹទ្ធិស័ក
ព.ស. ២៤៩១ (គ.ស. ១៩៤៧)

ឥមោ តស្សុ ភាគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ អាត្មាភាពសូមសំដែង អំពីសង្គហធម៌ ដែលមានក្នុងសុត្តន្តបិដក គម្ពីរទីឃនិកាយ ជាដីកវគ្គ ដូចសេចក្តីតទៅនេះ:-

កិច្ចប្តូរបាយសម្រាប់សង្គ្រោះ ឬក៏សេចស្រង់គ្នាទឹងគ្នាឲ្យមានក្តីស្នេហាទៅវិញទៅមក កុំឲ្យបែកបាក់គ្នា ហៅថា សង្គហធម៌ (ឬថា បិយករណធម៌) ជាគ្រឿងធ្វើនូវសេចក្តីស្រឡាញ់), មាន ៤ យ៉ាង ដូចព្រះគាថាមួយកន្លែង ក្នុងសង្គារលោវាទសូត្រថា:-

ទានញ្ច បិយវាជ្ជញ្ច អត្ថចរិយា ច យា ឥធ
សមានត្តតា ច ធម្មេសុ តត្ថ តត្ថ យថារហំ
ឯតេ ខោ សង្គហា លោកេ រថស្សាណីវ យាយតោ
ឯតេ ច សង្គហា នាស្សុ ន មាតា បុត្តការណា
លភេថ មានំ បូជំ វា បិតា វា បុត្តការណា ។

*សេចក្តីថា: ធម៌សម្រាប់សង្គ្រោះមនុស្សក្នុងលោកនេះ មាន ៤ យ៉ាង គឺ: ការឲ្យទាន ១, ពោលពាក្យពីពោះ ១, កិរិយាប្រព្រឹត្តអំពើ

ឲ្យជាប្រយោជន៍ ១, ភាពជាអ្នកតាំងខ្លួនឲ្យស្មោះស្ម័ ១, ធម៌តាំងប៉ុណ្ណេះ
នេះ រមែងប្រព្រឹត្តទៅក្នុងលោកដូចប្រែកខប់នៃរវេះ ។ អធិប្បាយថា
រវេះកាលបើមានប្រែកខប់ ទើបអាចប្រព្រឹត្តទៅ បើមិនមានទេក៏មិនអាច
ប្រព្រឹត្តទៅបានឡើយ ដូចម្តេចមិញ, សត្វលោក កាលបើមាន
សង្គហធម៌តាំង ៤ នេះ ទើបប្រព្រឹត្តទៅបាន បើមិនមានទេក៏មិនអាច
ប្រព្រឹត្តទៅបានដូច្នោះឯង ។ បើសង្គហធម៌ប៉ុណ្ណេះមិនមានហើយ មាតាក្តី
បិតាក្តី ក៏មិនបាននូវការបូជា ឬសេចក្តីរាប់អានអំពីបុត្រចៅខ្លួនឡើយ ។

១.— ការឲ្យទាន .— ទាននោះចែកចេញជា ២ យ៉ាង គឺ: សា-
ធារណទាន ១ អសាធារណទាន ១ ។ ឲ្យចំណែរបូបុគ្គលម្នាក់ៗ ដូចជា
មាតាបិតាឲ្យអាហារ, ឲ្យគ្រឿងប្រដាប់ស្លៀកពាក់, ឲ្យទ្រព្យសម្បត្តិធ្វើ
ដើមទុនដល់បុត្រធីតា ឬក៏បុត្រធីតាដែលមានឆ្នូរសម្បែងហើយ បាន
ជូនភោជនាហារគ្រឿងស្លៀកពាក់ដល់មាតាបិតាដែលចាស់ជរា, យ៉ាង
នេះហៅថា អសាធារណទាន ។ ឥស្សរជន ឬអ្នកមានទ្រព្យសម្បត្តិ
ជាអ្នកមានចិត្តផ្សាយមេត្តា អាណិតអាសូរដល់មហាជនហើយលះបង់
ទ្រព្យសម្បត្តិ ជួលគេឲ្យលើកថ្ម, ដីកត្រែក, ធ្វើស្ពាន ដើម្បីជាផ្លូវ
គមនាគមន៍ទៅមកបានស្រួល ឬដាំដើមឈើ, ដីកស្រះ, ដីកអណ្តូង,
សង់សាលាដើម្បីជាទីសំណាក់អាស្រ័យដល់មនុស្សអាគន្តុកៈ ឬទំនុក
បុរុងធ្វើផ្ទះពេទ្យ, សាលាបង្រៀនជាទីឲ្យចំណេះវិជ្ជាដល់កុមារកុមារី,

យ៉ាងនេះហៅថា សាធារណទាន ព្រោះឲ្យមិនចំពោះបុគ្គលម្នាក់ៗ; នេះជាសង្គហធម៌ទី ១ ។

២.— ការពោលពាក្យពីពោះ នោះអធិប្បាយថា អ្នកឲ្យបើគ្រាន់តែឲ្យប៉ុណ្ណោះ ប៉ុន្តែមិនបានពោលពាក្យពីពោះគួរឲ្យចាប់ចិត្តផងទេ, វត្ថុដែលឲ្យនោះ បើទុកជាច្រើនយ៉ាងណា ក៏ច្បាកដជាតិច, បើពោលពាក្យពីពោះគួរឲ្យចាប់ចិត្តផង, ទ័ស្តុការដែលឲ្យនោះសូម្បីតិចតួចសោះក៏ច្បាកដជាក់ដូចជាច្រើន ព្រោះធ្វើឲ្យកើតសេចក្តីស្រឡាញ់ពេញចិត្ត, ដូចកាសិតបុរាណថា: "ប្រហុកអំបិលក៏ដោយចុះឲ្យតែចានកណ្តាប់មាស"; ព្រោះហេតុនោះ បានជាព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ចាត់ការពោលពាក្យពីពោះ ថាជាសង្គហធម៌ទី ២ ។

៣.— កិរិយាប្រព្រឹត្តិអំពើឲ្យជាប្រយោជន៍ អធិប្បាយថា អ្នកឲ្យបើប្រសិនជាឲ្យហើយនិយាយពីពោះផង ដែលជាគុណចាប់ចិត្តចង់មេត្រីទុកបានយ៉ាងសិទ្ធហើយ, ប៉ុន្តែបើជាមនុស្សចេះតែមើលបំណាំគ្នាទៅវិញទៅមក មិនប្រព្រឹត្តប្រយោជន៍ដល់គ្នានឹងគ្នា គឺថាមិនហុចប្រយោជន៍ឲ្យ មិនច្បាប់ឧបាយឲ្យកើតប្រយោជន៍ គ្រាន់តែឲ្យរបស់នឹងនិយាយពីពោះប៉ុណ្ណោះ ការស្និទ្ធនោះក៏នឹងសាបសូន្យទៅវិញដោយងាយ ។ ព្រោះហេតុនោះ ការប្រព្រឹត្តិអំពើជាប្រយោជន៍នេះ ចាត់ជាសង្គហធម៌ទី ៣ ។

๔.—ភាពជាអ្នកតាំងខ្លួនឲ្យស្មោះស្មើ នោះអធិប្បាយថា អ្នកឲ្យសូម្បីឲ្យហើយ និយាយពាក្យពីរោះ ត្រមតាំងជួយខ្វល់ខ្វាយធ្វើប្រយោជន៍ឲ្យដល់គ្នានឹងគ្នាហើយ តែបើមិនចេះរៀបចំខ្លួនឲ្យសមតាមយសសក្តិ ឬមិនស្គាល់ធំ, តូច, ខ្ពស់, ទាប ជាអ្នកប្រកាន់មានៈមើលងាយគេ; សេចក្តីរាប់អានគ្នាក៏នឹងសាបសូន្យទៅវិញ ។ លុះតែអាស្រ័យនូវសេចក្តីស្មោះស្មើ តាំងខ្លួនឲ្យសមតាមយសសក្តិផង, ទើបសេចក្តីរាប់អាននោះនឹងមានកំឡាំងអាចតាំងនៅយូរអង្វែងទៅបាន ។ នេះចាត់ជាសង្គហធម៌គំរប់ ๔ ។

សព្វសត្វតាំងអស់ក្នុងលោកគួរមានសង្គហធម៌ សង្គ្រោះដល់គ្នានឹងគ្នាទៅវិញទៅមកតាមជាន់តាមថ្នាក់ ទើបចក្រតាំងគួ គឺពុទ្ធចក្រ នឹងអាណាចក្រលោកវត្តនធម៌ នឹងសន្តិសុខបានដោយស្រួល ។

ឯបុគ្គលដែលត្រូវមានសង្គហធម៌សង្គ្រោះគ្នានឹងគ្នានោះ មាន ๖ ពួក, ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់និពន្ធជាបទព្រះគាថារៀបរៀបនឹងទិសតាំង ๖ ដូច្នេះថា:-

មាតាបិតា ទិសា បុព្វា អាចរិយា ទក្ខិណា ទិសា
បុត្តទារា ទិសា បច្ឆា មិត្តាមច្ចា ច ឧត្តរា
ទាសកម្មករា เหដ្ឋา ឧទ្ធំ សមណព្រាហ្មណា
ឯតា ទិសា ឥមស្សេយ្យ អលមត្តោ កុលេ គិហី ។

សេចក្តីថា: មាតាបិតាទុកជាទិសខាងកើត, គ្រូបាអាចារ្យទុកជាទិសខាងត្បូង, បុត្រកំសាទុកជាទិសខាងលិច, មិត្រសំឡាញ់ទុកជាទិសខាងជើង, ខាសកម្មករទុកជាទិសខាងក្រោម, សមណព្រាហ្មណ៍ទុកជាទិសខាងលើ, គ្រហស្ថកុងត្រកូលដែលមានសមត្ថភាព ចិញ្ចឹមបុត្រកំសា ហើយនៅគ្រប់គ្រងផ្ទះសំបែង គប្បីនមស្សការនូវបុគ្គលទាំង ៦ ឃ្លាយមានមាតាបិតាជាដើមដែលទុកដូចជាទិសនោះៗ ចុះ ។

សេចក្តីអធិប្បាយ

មាតាបិតាទុកជាទិសខាងកើត បុត្រធីតាគប្បីមានសង្គហធម៌ប្រតិបត្តិចំពោះមាតាបិតាដោយស្ថាន ៥ យ៉ាងគឺ:

๑ - កូនត្រូវតាំងចិត្តថា អាត្មាអញនេះ គឺមាតាបិតាបានចិញ្ចឹមមក ហើយ អាត្មាអញត្រូវចិញ្ចឹមលោកវិញ ។

๒- កូនត្រូវតាំងចិត្តថា កាលបើមាតាបិតាមានកិច្ចវល់ នោះអាត្មាអញត្រូវបញ្ឈប់ការងាររបស់ខ្លួនទុកសិន ហើយត្រូវធ្វើកិច្ចការវល់របស់មាតាបិតាវិញ ។

๓- កូនត្រូវតាំងចិត្តថា អាត្មាអញត្រូវដំកល់វង្សត្រកូលមាតាបិតា ទុកឲ្យល្អមិនឲ្យវិនាស គឺថានឹងមិនញុំាងទ្រព្យសម្បត្តិរបស់មាតាបិតាឲ្យវិនាសដោយការឥតប្រយោជន៍ នឹងសង្គ្រោះមាតាបិតាឲ្យផុតអំពីវង្សដែលមិនប្រកបដោយធម៌ ហើយឲ្យតាំងនៅក្នុងវង្សដែលប្រកបដោយ

ធម៌, នឹងមិនផ្តាច់បង់នូវការកុសលចាំងឡាយមានសលាកកត្តជាដើមដែលមាតាបិតាបានប្រព្រឹត្តធ្វើតាមគន្លងត្រូវល្អមកហើយ ។

៤– កូនត្រូវតាំងចិត្តថា អាត្មាអញនឹងតាំងគំនិតមារយាទឲ្យល្អ ឲ្យជាទីពេញចិត្តនៃមាតាបិតា ឲ្យជាមនុស្សគួរមាតាបិតាប្រគល់ទ្រព្យសម្បត្តិកេរ្តិ៍ដំណែលឲ្យ ។

៥– កូនត្រូវតាំងចិត្តថា កាលបើមាតាបិតាធ្វើកាលកិរិយាហើយ អាត្មាអញត្រូវធ្វើទក្ខិណាទាន ឧទ្ទិសចំណែកផលបុណ្យជូនដល់មាតាបិតារឿយៗ ។

ចំណែកខាងមាតាបិតាត្រូវអនុគ្រោះបុត្រធីតាដោយស្ថាន៥យ៉ាងគឺ:

១– ហាមឃាត់កូនមិនឲ្យធ្វើកម្មអាក្រក់មានឃាត់កូនមិនឲ្យសម្លាប់សត្វ លួចទ្រព្យគេជាដើម ។

២– ឲ្យកូនដំកល់នៅក្នុងកម្មជាកុសល មានទានឹងសីលជាដើម ។

៣– ឲ្យកូនសិក្សារៀនសិល្បសាស្ត្រចំណេះវិជ្ជាដែលគួរសៀនមានអក្សរឹងលេខជាដើម ។

៤– រៀបចំកូនឲ្យមានភរិយា ឬ ស្វាមីតាមសមគួរដល់ត្រកូលនឹងទ្រព្យសម្បត្តិ ។

៥– ឲ្យទ្រព្យសម្បត្តិដល់កូនក្នុងសម័យពីរយ៉ាងគឺ: និច្ចសម័យ១, កាលសម័យ ១, និច្ចសម័យនោះគឺ ឲ្យទ្រព្យសម្បត្តិរឿយៗ ដើម្បីឲ្យកូន

ចាយប្រើតាមការគួរ ឬ ឲ្យដើម្បីឲ្យធ្វើកុសលណាមួយ; កាលសម័យនោះ គឺឲ្យក្នុងកាលដែលបានរៀបចំឲ្យកូនមានភរិយាស្វាមីហើយ ឬ ឲ្យក្នុងកាលដែលខ្លួនដឹងនឹងដល់ទីវិមរណភាព ។

គ្រូបាអាចារ្យទុកជាទិសខាងត្បូង សិស្សត្រូវប្រតិបត្តិដោយស្មានន័យដ៏គឺ:-

១- ដោយកិរិយាធ្វើនូវបច្ចុគ្គមនាការគ្រាកឡើងទទួល គឺថាបើសិស្សកំពុងអង្គុយនៅក្នុងទីណាមួយ ដែលមិនមានបុគ្គលជាធំជាងគ្រូអាចារ្យទេ កាលបើបានឃើញគ្រូអាចារ្យមកកាន់ទីនោះ ត្រូវសិស្សក្រោកឈរឡើង, បើលោកមានគ្រឿងបរិក្ខារអ្វី ត្រូវទទួលយកមកអំពីលោកដោយអើតើ ត្រូវរកទឹកលាងជើង, រកកំណាត់ជូតជើងរួចត្រូវបាត់ចែងទីអាសនៈដើម្បីលោក, លុះលោកអង្គុយហើយ សឹមខ្លួនអង្គុយជាខាងក្រោយ ។

កាលបើលោកក្រោកលាខ្លួនទៅ ត្រូវធ្វើអនុគ្គមនាការ គឺក្រោកជូនលោកទៅ បើយ៉ាងដូចណាស់ត្រឹមមាត់ទ្វារក្រៅ ។

២- ដោយកិរិយាចូលទៅបំរើគ្រូអាចារ្យក្នុង ១ ថ្ងៃ ៣ ដងគឺ វេលាព្រឹកម្តង, ថ្ងៃត្រង់ម្តង, ល្ងាចម្តង ។

៣- ដោយកំរិយាផ្ទៀងស្តាប់ពាក្យនៃគ្រូអាចារ្យ ដែលលោកពោលខ្ចាន់ប្រែនប្រែដោយល្អ ។

៤- ដោយការបំភ្លើតូចៗ មានឲ្យឈើសូន្យនឹងគំលុបមុខជាដើម ។

៥- ដោយកិរិយារៀនទូរសិល្បសាស្ត្រ ចំណេះវិជ្ជាអំពីគ្រូអាចារ្យ ដោយគោរព គឺរៀនម្តងៗ តាមសមគួរដល់កំលាំងប្រាជ្ញានៃខ្លួនហើយ ស្វាធ្យាយទន្ទេញដរាបដល់ចាំ ដល់ចូលចិត្ត ។

ចំណែកគ្រូចារ្យអាចារ្យត្រូវអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាង គឺ:

១- ទូន្មានប្រៀនប្រដៅសិស្សដោយល្អ គឺទូន្មានប្រៀនប្រដៅឲ្យសិស្សចេះរៀបចំតរិយាបថទាំង ៤ គឺដេក, ដើរ, ឈរ, អង្គុយ ឲ្យរៀបរយ ព្រមទាំងប្រដៅមិនឲ្យសេពគប់នឹងជាបមិត្តឲ្យសេពគប់តែនឹងភ្លស្យាណមិត្ត ។

២- បង្ហាត់បង្រៀនសិស្សដោយល្អ គឺបង្ហាត់បង្រៀនដោយត្រូវតាមអត្ថនឹងព្យញ្ជន: នឹងរបៀបពាក្យរបៀបសេចក្តីឲ្យសិស្សចាំចូលត្រឹមចិត្ត ។

៣- បង្ហាញសិល្បសាស្ត្រចំណេះវិជ្ជាដល់សិស្ស ដោយមិនលាក់ទុក គឺថាបើខ្លួនចេះប៉ុន្មាន ចង់ឲ្យសិស្សចេះប៉ុណ្ណោះដែរ ។

៤- ពោលពាក្យលើកសរសើរសិស្ស ដែលមានសិល្បសាស្ត្រចំណេះវិជ្ជា នឹងកិរិយាមារយាទល្អពិតនោះ ឲ្យច្បាស់ប្រាកដដល់មិត្តនឹងអាមាត្យ ។

៥– ធ្វើទុរ្វសេចក្តីការពាររក្សាសិស្ស ក្នុងទិសទាំងឡាយ គឺថាឲ្យសិស្សរៀនសិល្បសាស្ត្រចំណេះវិជ្ជា មិនឲ្យទើសទាល់ក្នុងវេលាដែលសិស្សនៅក្នុងទិសនោះៗ ។

ភរិយាទុកជាទិសខាងលិច ស្វាមីគប្បីអនុគ្រោះដោយស្ថាន ៥ យ៉ាង គឺ:

១– ដោយសេចក្តីកាប់អាងដោយសំដីដ៏ទន់ផ្អែមទៅកភរិយា ។

២– ដោយភរិយាមិនបៀតបៀន មិនមើលងាយភរិយាដូចជាសកម្មករ ។

៣– ដោយភរិយាមិនប្រព្រឹត្តកន្ទួចិត្តភរិយា ។

៤– ដោយភរិយាប្រគល់ទុរ្វឥស្សរិយៈ គឺការៈជាដំក្នុងការចាត់ចែងម្ហូបចំណីឲ្យជាប់មុខទៅភរិយា ។

៥– ដោយភរិយាផ្គត់ផ្គង់ទុរ្វគ្រឿងប្រដាប់ដល់ភរិយា តាមសមគួរដល់សម្បត្តិរបស់ខ្លួន ។

ចំណែកភរិយាត្រូវប្រតិបត្តិស្វាមីដោយស្ថាន ៥ យ៉ាងគឺ:

១– ចាត់ចែងការងារមានការចំអិនទុរ្វអាហារជាដើម ដោយផ្ចិតផ្ចង់,

២– សង្គ្រោះដល់ជនជាញាតិរបស់ស្វាមី ទំាងញាតិរបស់ខ្លួនដោយស្មោះស្ម័ ។

៣– ចេះថែរក្សាទុកជាក់ទុរ្វទ្រព្យសម្បត្តិ ដែលស្វាមីរកបានមកហើយ ។

៤- មិនប្រព្រឹត្តកន្ទួងចិត្តស្វាមី ។

៥- ជាស្រីឈ្លាសប្រសប់ក្នុងកិច្ចការទាំងឡាយ មានការចាត់ចែងនូវបចរនទឹងចាំយជាដើម ឥតខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង ហើយអាចញុំាងកិច្ចទាំងនោះឲ្យសម្រេចបាន ។

មិត្រសំឡាញ់ទុកជាទិសខាងជើង កុលបុត្រគប្បីទំនុកបម្រុងដោយស្ថាន៥យ៉ាង គឺ :

១- ដោយកិរិយាឲ្យទ្រព្យរបស់ដែលគួរឲ្យដល់មិត្រ ។

២- ដោយកិរិយាពោលពាក្យពីពេះពៅរកមិត្រ ។

៣- ដោយកិរិយាប្រព្រឹត្តិធ្វើនូវប្រយោជន៍ឲ្យកើតដល់មិត្រ ។

៤- ដោយភាវៈជាអ្នកមានខ្នូននឹងចិត្តស្មើដោយមិត្រ ។

៥- ដោយភាវៈមិនភ្លែងពោលឲ្យឃ្លាតចាកសេចក្តីពិតដល់មិត្រ ។

ចំណែកខាងមិត្រសំឡាញ់ត្រូវអនុគ្រោះកុលបុត្រ ដោយស្ថាន៥យ៉ាង គឺ :

១- ដួយរក្សាមិត្រដែលបានជាភ្ញាំងភ្លាត់ធ្លុះប្រហែស ។

២- ដួយថែរក្សាទ្រព្យសម្បត្តិរបស់មិត្រដែលមិត្របានជាភ្ញាំងភ្លាត់ធ្លុះប្រហែស ។

៣- កាលបើមិត្រមានសេចក្តីកិតក័យ ក៏អាចជាទីពឹងអាស្រ័យដល់មិត្របាន ។

๔- មិនលះបង់ចោលមិត្តក្នុងគ្រាលដែលមិត្តមានការត្រូវ ។

๕- ស្រឡាញ់រាប់អានកូនចៅផៅពង្សរបស់មិត្ត ។

ទាសកម្មករទុកជាទិសខាងក្រោម ចៅហ្វាយនាយគប្បីទំនុកបំរុងដោយស្ថាន ๕ យ៉ាង គឺ:

๑- ដោយកិរិយាចាត់ចែងនូវការងារឲ្យធ្វើតាមសមគួរដល់កំលាំងនៃទាសកម្មករ គឺថាដាក់ការងារឲ្យធ្វើតាមការ សម្រាប់ប្រុសស្រីចាស់ក្មេង ។

๒- ដោយកិរិយាធ្វើនូវកត្តាហារនឹងឈ្នួល ឬ បំណាច់រង្វាន់តាមសមគួរដល់ទំនងដែលត្រូវឲ្យ ។

๓- ដោយកិរិយាព្យាបាលក្សាថែទាំទាសកម្មករ ក្នុងកាលដែលមានជម្ងឺ ហើយមិនបៀតបៀនឲ្យធ្វើការងារអ្វីឡើយ ។

๔- ដោយកិរិយាចែករំលែកនូវរបស់ដែលមានសន្សាំញ៉ែតកាលឲ្យទាសកម្មកបរិភោគ ។

๕- ដោយកិរិយាបើកឱកាសឲ្យឈប់ធ្វើការក្នុងនិច្ចសម័យ គឺថាកាលបើទាសកម្មកធ្វើការនឿយហត់ពេញ ๑ ថ្ងៃ ក៏ឲ្យឈប់សម្រាកកំលាំងខ្លះ ។ ឲ្យឈប់ធ្វើការក្នុងកាលសម័យ គឺថាបើដល់កំណត់ថ្ងៃនក្ខត្តឫក្សមានថ្ងៃចូលឆ្នាំជាដើម ក៏បើកឲ្យឈប់ធ្វើការ ។

ចំណែកខាងជាវត្រាំវនិធមនុស្សដែលធ្វើការឈ្នួល ត្រូវយកចិត្តទុកដាក់បំពេញបំបានចៅហ្វាយនាយរបស់ខ្លួនដោយស្ថាន ๕ យ៉ាង គឺ:

១- គ្រែកទៀងធ្វើការងារមុនចៅហ្វាយនាយ ។

២- ឈប់ធ្វើការងារគ្រែយចៅហ្វាយនាយ ។

៣- មិនលួចទ្រព្យរបស់ចៅហ្វាយនាយ យកតែរបស់ដែលចៅហ្វាយនាយឲ្យ ។

៤- ធ្វើការងាររបស់ចៅហ្វាយនាយ ដោយពិនិត្យពិចារណាផ្តន់ផ្តង់អស់ពីចិត្ត តតមានគិតកាញ់គ្នេរ ។

៥- យកការងាររបស់ចៅហ្វាយនាយ ទៅពោលសរសើរកេរ្តិ៍ឯីនោះៗ ។

សមណព្រាហ្មណ៍ទុកជាទិសខាងលើ កុលបុត្រជាគ្រហស្ថគប្បីប្រតិបត្តិផ្តន់ផ្តង់ដោយឋានៈ ៥ យ៉ាង គឺ:

៥- ដោយកាយកម្មប្រកបដោយមេត្តា គឺថាធ្វើនូវកិច្ចដោយកាយមានទៅនិមន្តលោកទំនងទទួលយកនូវតម្រងទឹក ទៅត្រងទឹកប្រគេនលោកទំនងតក់ច្រចាច់ជាដើម ដោយសេចក្តីរាប់អានដ៏ស្មោះត្រង់ ។

៦ ដោយវចីកម្មប្រកបដោយមេត្តា គឺថាធ្វើនូវកិច្ចដោយវាចា មានពោលពាក្យដាស់តឿនអ្នកឯទៀត ឲ្យធ្វើទានដល់សមណព្រាហ្មណ៍ទំនងបន្ទូលសួរសុខទុក្ខកេរ្តិ៍កាលដែលស្តាប់ធម៌ទេសនាចប់ ទំនងធ្វើនូវបដិសណ្ឋារៈដោយសំដីរាក់ទាក់ជាដើម ដោយសេចក្តីរាប់អានដ៏ស្មោះត្រង់ ។

៣- ដោយមនោកម្មប្រកបដោយមេត្តា គឺថាធ្វើទ្វារកិច្ចដោយចិត្ត មានគិតថា ព្រះថេរៈតំាងឡាយដែលលោកតែងនិមន្តមកកាន់ត្រកូលរបស់យើង សូមឲ្យលោកបានសេចក្តីសុខសប្បាយជាដើម ដោយសេចក្តីពប់អានដ៏ស្មោះត្រង់អស់ពីចិត្ត ។

៤- ដោយកាយៈជាអ្នកមានទ្វារដុះមិនបិទ គឺថាជាអ្នកទស្សាហ៍ធ្វើទានដល់សមណព្រាហ្មណ៍ កាលបើឃើញសមណព្រាហ្មណ៍មកដល់ហើយ ក៏ឲ្យទានដោយមិនពោលគ្មញ្ញាត្តែរំពោះរបស់ដែលមាននោះថាជាគ្មានវិញឡើយ ។

៥- ដោយកិរិយាឲ្យនូវអាមិសៈ គឺឲ្យនូវខាទនីយភោជនីយាហារដល់សមណព្រាហ្មណ៍ ។

ចំណែកខាងសមណព្រាហ្មណ៍ ត្រូវអនុគ្រោះកុលបុត្រដោយស្ថាន ៦ យ៉ាង គឺ:

១- ហាមឃាត់កុលបុត្រមិនឲ្យធ្វើកម្មអាក្រក់ មានឃាត់មិនឲ្យសំឡាប់សត្វនឹងមិនឲ្យលួចទ្រព្យគេជាដើម ។

២- ឲ្យកុលបុត្រដំកល់នៅក្នុងកុសល មានទានឹងសីលជាដើម។

៣- អនុគ្រោះកុលបុត្រដោយកល្យាណចិត្ត គឺតាំងចិត្តផ្សាយមេត្តាធម៌ដល់កុលបុត្រតំាងឡាយថា ឲ្យបានសេចក្តីសុខ កុំបីមានទុក្ខ, សោក, រោគ, ភ័យអ្វីឡើយ ។

៤- ឲ្យកុលបុត្របានស្តាប់នូវធម៌ដែលមិនធ្លាប់បានស្តាប់ ។

៥- ញ៉ាំងធម៌ដែលកុលបុត្រធ្លាប់បានស្តាប់ហើយ ឲ្យផូរផង់ល្អ គឺថាធ្លាប់ពន្យល់សេចក្តីនៃធម៌នោះ ឲ្យច្បាស់លាស់ធ្លាកដឡើង តាតែកុលបុត្រនោះលែងមានសេចក្តីសង្ស័យ ។

៦- ធ្លាប់ផ្សះផ្សាគិដល់កុលបុត្រ មានធ្លាប់ឲ្យដឹងដូច្នេះថា បុគ្គលដែលបានទៅកើតកន្លែងនោះ ព្រោះអំណាចនៃកុសលមានសីល ៥ នឹងកុសលកម្មបថ ១០ ជាដើម ។

កាលបើបុគ្គលទាំង ៦ ពួកគឺ: មាតាបិតានឹងបុត្រធីតា គ្រូចារ្យ នឹងសិស្សានុសិស្ស, ភរិយានឹងស្វាមី, មិត្រសំឡាញ់នឹងកុលបុត្រ, ទាសកម្មករនឹងចៅហ្វាយនាយ, សមណព្រាហ្មណ៍នឹងកុលបុត្រ បានប្រតិបត្តិត្រូវតាមស្ថានដែលខ្លួនត្រូវប្រតិបត្តិ ត្រូវអនុគ្រោះទៅវិញទៅមកដូច្នេះហើយ បុគ្គលទាំងនោះ ឈ្មោះថាបិទបាំងនូវភ័យអន្តរាយ មិនឲ្យកើតឡើងបាន ជាបុគ្គលមានកេរ្តិ៍ឈ្មោះល្អក្នុងលោកទាំងពីរ គឺលោកនេះនឹងលោកខាងមុខ រមែងបាននូវកេរ្តិ៍ឈ្មោះយសសក្តិ ចំរើនដោយសុខគាត អនាម័យដ៏ល្អ ។

សង្គហធម៌ទាំង ៤ នេះ-បើបុគ្គលណាបានប្រតិបត្តិដោយប្រពៃហើយ កេរ្តិ៍ឈ្មោះរបស់បុគ្គលនោះនឹងផ្សុសផ្សុសឡើងក្នុងលោក ផ្សាយទូទៅនូវទិន្នន័យ ដោយឈ្មួយឈ្មប់ត្រង់ទិស ជនភាគច្រើនតែងដើរត្រសង់ស្រង់តាមក្នុងចូលទៅទួលស្គាល់បុគ្គលនោះជានាយចៅហ្វាយជាមិត្រសំឡាញ់ ប្រៀប

ដូចបុប្ផជាតិដែលមានក្នុងក្រអូបឆើត ជាទីកើតតម្រេកនៃកមរជាតិ
ពាំងឡាយ មានកន្ទុំជាដើមដូច្នោះដែរ ។

ន័យមួយទៀតព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងថា:

យស្មា ច សង្គហោ ឯតេ សមវេក្ខន្តិ បណ្ឌិតា
តស្មា មហត្តំ បប្បោន្តិ បាសំសា ច ភវន្តិ តេ ។

សេចក្តីថា អ្នកប្រាជ្ញពាំងឡាយ លោកបានប្រតិបត្តិធ្វើនូវសង្គ-
ហធម៌ពាំង ៤ នេះដោយប្រពៃ ព្រោះហេតុនោះបានជាលោកបានដល់
នូវភាវៈជាធំ ព្រមពាំងបាននូវសេចក្តីសរសើរអំពីប្រជុំជនផងទៀត ។

សំដែងមកអំពីសង្គហធម៌ ក៏សន្និដ្ឋានថាចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

ដោយអានុភាពនៃធម្មទេសនា សូមទេវតាពាំងមួយក្បឿនលោកជាតុ
រក្សាព្រះប្រិយមហាក្សត្រកម្ពុជាធិបតី ព្រមពាំងព្រះពជវង្សានុវង្ស សូម
ទ្រង់ប្រសិទ្ធដោយចតុព្វិធពរ រុងរឿងដោយសតិបញ្ញា បរិហារវចនា
កម្ពុជរដ្ឋឲ្យដល់នូវទុគ្គមគតិ ដោយមុហុត្តកាល ។

ពាំងសូមពុទ្ធបរិស័ទពាំងឡាយគ្រប់ជាន់ ដែលបានប្រតិបត្តិតាម
សាសនវិធី ក្រោមអធិបតេយ្យនៃព្រះសម្មាសម្ពុទ្ធ ឲ្យចំរើនដោយ
សុខកាត អនាម័យដ៏ល្អ ដើម្បីជាពលរដ្ឋប្រកបកិច្ចសាសនា ក្នុងហាន
បានមគ្គាកិសម័យទៅហោង ។

ចប់

រៀបរៀងទេសនា បុច្ឆា-វិសជ្ជនា

ព្រះមហាឧត្តមវិជ្ជា កែ-អឿន រ៉ិនយប្បញ្ញោ
វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង
ព្រះទេពសត្ថា សួរ-ហាយ ពិនិត្យកែសម្រួល

(តមក)

– កន្តេ មហាថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! រឿងនេះបើតាមគម្ពីរវិនយាលង្ការដីកា លោកកែថា បដិគ្គហណកិច្ចំ នត្ថិ ទាយកេន បរិវៃ ទិន្នេ សង្ឃស្ស បិត្តេន សម្បដិច្ឆនមត្តមេវ បមាណំ ហោតិ កិច្ចដៃលត្រូវទទួល (ដោយកាយ ឬដោយវាចា) មិនមានទេ កាលបើទាយកវៃប្រគេនចីវរមក យកតែត្រង់ការទទួលដោយចិត្តរបស់សង្ឃប៉ុណ្ណោះជាប្រមាណ; ឯវិ តុណ្ហីភាវេន សម្បដិច្ឆនមត្តមេវ ហោតិ កាលបើដូច្នេះ ការទទួលគឺគ្រាន់តែទទួលដោយតុណ្ហីភាពក៏បានហើយ ។ បពិត្រព្រះមហាថេរ! ការទទួលសំពត់កឋិនរបស់សង្ឃ ដោយន័យដូចបានវិសជ្ជនាមកនេះ សូមមានជ្រាប ។

១២– សាធុ សាធុ អនុត្តរៈ: ម្នាលអនុត្តរ! ប្រស្នាដៃលលោកម្ចាស់វិសជ្ជនាមកនេះ ត្រឹមត្រូវតាមគម្ពីរដីកាហើយ ខ្ញុំនឹងសួរតទៅទៀត ។

អើអនុត្តរៈ! មានពាក្យខ្លះគេនិយាយថាបួសជាលោកសង្ឃហើយ មិនត្រូវខ្វល់ខ្វាយប្រៀបប្រជ្រុយឲ្យគេធ្វើកបិនទានចំពោះខ្លួនទេ ត្រូវតែទុបាសក ទុបាសិកាធ្វើដោយសទ្ធាចិត្តគេទើបគួរ តើពាក្យដែលគេថានេះគួរស្តាប់យកជាទិដ្ឋានុគតិបានដែរឬទេ សូមលោកម្ចាស់សំដែងសេចក្តីនេះញែកឲ្យស្រឡះទៅមើល ។

កន្តេ ថេរៈ: បពិត្រព្រះមហាថេរដ៏ចំរើន! ពាក្យដែលគេថានោះក៏គួរស្តាប់គួរយកខ្លះ ព្រោះព្រះសម្មាសម្ពុទ្ធបានទ្រង់ប្រកាសហាមក្នុងអនុត្តាការ ២៤ ប្រការ មានក្នុងកបិនក្ខន្ធក:ឯណោះដោយពិត គឺសេចក្តីថាតិមិត្តកពេជ កិកុឯណាធ្វើទិមិត្តប្រៀបប្រជ្រុយនិយាយរកថាយកថា សំពត់នេះសាច់ស្រាស់សាច់ល្អិតល្អគួរធ្វើកបិនបាន ហើយថាយកនោះនាំមកថ្វាយ យ៉ាងនេះស្រាលមិនឡើងជាកបិនប្រការ ១ បរិកប្បាកពេជ កិកុឯណាភ្លែងនិយាយបរិយាយអានិសង្សកបិន ហើយយោសនាឲ្យកបិនកើតឡើង យ៉ាងនេះស្រាលមិនឡើងប្រការ ១ តារិកាលិពេជ កិកុទៅខ្ចីសំពត់គេយកមកស្រាលកបិន យ៉ាងនេះមិនឡើងជាកថិនប្រការ ១ មួយទៀតបើកិកុសាមណេរទៅយោសនាសូមថាយកមិនមែនជាញាតិ មិនមែនជាបវារណា យ៉ាងនេះស្រាលមិនឡើងជាកបិនប្រការ ១ បើកិកុទៅយោសនាសូមសំពត់អំពីញាតិ មានមាតាបិតាខ្លួនជាដើម ទោះឲ្យកើតជាកបិនឡើងក្តី ទឹងមានទោសដោយវិញ្ញត្តិសិក្ខាបទនោះឥតអង្គីមាន តែថា

មិនគួរដល់កបិន ព្រោះថាកបិននេះកើតឯងដូចសំពត់ចិញ្ចៀរសេយ្យាពស្តើ
អណ្តែតត្រសែតធ្លាក់ពីកណ្តាលអាកាស មកកន្លងកណ្តាលជំនុំសង្ឃគួរ
ដោយពុទ្ធានុញ្ញាត មួយទៀតកិរិយាទៅសូមចីវរអំពីញាតិមានមាតាបិតាជា
ដើម ហើយទើបឲ្យកើតជាកបិន ឃើញថាគួរដល់សង្ឃអាវាសជាមួយ
គ្នាក្តី ឬឲ្យសង្ឃកន្លងអាវាសដទៃក្តី សេចក្តីនេះនឹងមានបទហាមក៏ទេ តែ
កិរិយានោះអាចការពារអាបត្តិ ៥ ប្រការ ក៏ឥតអង្គឹមាន ជានៃតែអានិសង្ស
កន្លងបរលោកប៉ុណ្ណោះឯង; បពិត្រព្រះមហាវេរៈ! ខ្ញុំព្រះករុណាវិសជ្ជនា
មកដោយសេចក្តីសង្ខេបតែប៉ុណ្ណេះ សូមទានជ្រាប ។

១៣- សាធុ សាធុ អនុត្តរៈ: ម្នាលអនុត្តរៈ! ប្រស្នាដែល
លោកម្ចាស់វិសជ្ជនាមកត្រូវពិតជ្រាកដហើយ តែបើតាមគំនិតរបស់ខ្ញុំ
យល់ឃើញថា ធ្វើជាអ្នកបួសហើយ មិនត្រូវមានកង្វល់ធំធ្វើអាមិស-
ទានទៀតទេ ដូចយ៉ាងកបិននេះ ក៏ពាក់ព័ន្ធលកន្លងអាមិសទានដែរ
ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងក្នុងមហាបរិនិព្វានសូត្រថា "ម្នាលកិរិយាំ-
ឡាយ! អ្នកចាំឆ្លាយកុំខ្វល់ខ្វាយនឹងអាមិសបូជាឡើយ ត្រូវអ្នកខំប្រឹង
ប្រែងកន្លងបដិបត្តិបូជា គឺសេចក្តីប្រតិបត្តិកន្លងសីល - សមាធ - បញ្ញាឲ្យជា
ប្រយោជន៍របស់ខ្លួនចុះ ឯអាមិសបូជាឬអាមិសទានខុកមុខជាវឲ្យគ្រែហស្ត
គេឆ្លើចុះ" ខ្ញុំបានឃើញព្រះពុទ្ធតម្រាស់នេះហើយ បានជាយល់ថា អ្នក
បួសមិនត្រូវរវល់នឹងអាមិសទានឬអាមិសបូជាឡើយ; អើអនុត្តរៈ! រឿង
នេះ អ្នកយល់ឃើញដូចម្តេចទៅវិញ? សូមអ្នកវិសជ្ជនាមកមើល! ។

– កិញ្ចាបិ មហាថេរៈ បតិ្តព្រះមហាថេរ! រឿងដែលព្រះសម្ម-
សម្ពុទ្ធទ្រង់សំដែងក្នុងមហាបទានសូត្រ ក៏មែនពិតហើយ តែរឿងនេះ
ដោយព្រះសម្ពុទ្ធក្រែងទៅអនាគតកាល ពួកបព្វជិតអ្នកបួសខាំងឡាយ
មិនយកចិត្តទុកជាក់ក្នុងបដិបត្តិបូជា ដឹកនាំគ្រហស្ថខាំងឡាយឲ្យធ្វើតែអា
មិសបូជា ដើរអង្គាសយោសនាថាយកថាយកាធ្វើតែអាមិសបូជា អំពើ
នេះមិនអាចញ៉ាំងព្រះពុទ្ធសាសនាឲ្យចំរើនរុងរឿង សូម្បីតែ ១ អង្គុលី
ឡើយ ព្រោះហេតុនោះហើយបានជាទ្រង់សំដែងឃាត់បព្វជិតមិនឲ្យ
ខ្វល់ខ្វាយក្នុងអាមិសបូជា ឲ្យខំខ្វល់ខ្វាយតែក្នុងបដិបត្តិបូជា ទើបអាច
ញ៉ាំងព្រះពុទ្ធសាសនាឲ្យចំរើនរុងរឿង អស់កាលជាអង្វែងទៅ ។

ម្យ៉ាងទៀតអ្នកបួសដែលគ្មានកង្វល់នឹងកឋិនទាន មកពីគ្មានបស់
អ្វីនឹងធ្វើ ឬគ្មានសទ្ធានឹងគ្មានចំនងនឹងត្រូវធ្វើ បើមានលាភសក្ការៈដែល
កើតឡើង ឬបានមកដោយធម៌ គួរតែធ្វើ ព្រោះកឋិនទាននេះព្រះ
សម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យសហធម្មិកចំនួន ៥ គឺ កិក្ខុ កិក្ខុនី សិក្ខមានា
សាមណេរ សាមណេរី ធ្វើបាន ព្រោះការបវារិយាគទាន បានឈ្មោះថា
ជាកិច្ចលេមច្ចរិយៈដែលជាកិលេសត្រូវតែលះ បុគ្គលដែលមានភាពជា
ប្បុជ្ជនទៅឡើយ ឈ្មោះថានៅក្នុងអំណាចក្លេស គឺភគៈ ទោសៈ មោហៈ
ទំនឹមច្ឆរិយធម៌ជាដើម តែងដុតកេលរាលជាធម្មតា, សមតាមធម្មទេសនា
ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងក្នុងអាទិត្តសូត្រថា

អាទិត្តស្មឹ អគារស្មឹ យំ ឥហរតិ ភាជនំ
តំ តស្ស ហោតិ អត្ថាយ នោ ច យំ តត្ត ទយ្ហតិ,
ឯវមាទិត្តកោ លោកោ ជរាយ មរណេន ច
ឥហរេថេវ ទានេន ទិន្នំ ហោតិ សុឥហរិតំ ។

សេចក្តីថា: "កាលបើផ្ទះត្រូវភ្លើងឆាបឆេះ ជនម្ចាស់ផ្ទះតែងដកយកនូវទ្រព្យសម្បត្តិ មានភាជន: (ជាដើម) ចេញអំពីផ្ទះ, ទ្រព្យណាដែលគេដកយកចេញផុត ភ្លើងឆេះមិនបាន ទ្រព្យនោះរមែងបានទៅជាប្រយោជន៍របស់គេតទៅ យ៉ាងណាមិញ សត្វលោកដែលត្រូវភ្លើងគឺជរានឹងមរណៈឆាបឆេះ គួរប្រញាប់ដកយកចេញឲ្យផុតអំពីផ្ទះគឺរាងកាយដោយការឲ្យទាន ព្រោះថាទានដែលគេឲ្យហើយនោះឯង ឈ្មោះថាបានដកយកទុកដោយល្អ មិនឲ្យភ្លើងឆេះបាន យ៉ាងនោះដែរ"; បពិត្រព្រះមហាវេរដ៏ចំរើន! ខ្ញុំព្រះករុណាបានវិសជ្ជនាមកអំពីរឿងនេះ អស់សេចក្តីតែប៉ុណ្ណេះ សូមទានជ្រាប ។

១៤- កស្សបោ អនុត្តរ: ម្នាលអនុត្តរ! លោកម្ចាស់ប៉ុនប្រសប់មែន ចេះវិសជ្ជនាមកស្តាប់បានដោយងាយ ខ្ញុំនឹងលើកប្រស្នាដទៃសួរតទៅទៀត ។ អើលោកម្ចាស់! ចុះពាយកម្ចាស់កបិនបាន វេរដូចម្តេចទើបទៅជាសង្ឃទាន? បើត្រូវការវេរបស់ផ្សេងៗ ចំពោះតែកុអកខ្ទួល

គ្រាលកបិនដោយឡែកផង តើត្រូវប្រតិបត្តិដូចម្តេច? សូមលោកម្ចាស់ មេត្តាអធិប្បាយឲ្យសព្វគ្រប់មកមើល ។

– បពិត្រព្រះមហាថេរ! សំពត់សម្រាប់គ្រាលកបិន ជារបស់កប់ បញ្ចូលក្នុងសង្ឃភាន ត្រូវវេរតាមបាលីដែលថ្លាប់វេរថា ឥមំ ទុស្សំ កបិនបិរំ ភិក្ខុសង្ឃស្ស ទេម ។ ទុតិយម្បិ, តតិយម្បិ ។ "យើងខ្ញុំតាំងឡាយសូមវេរទូរសំពត់នេះ ជាចីវរដើម្បីកបិនចំពោះកិក្ខុ-សង្ឃ ។ អស់ពារៈពីរដងផង, អស់ពារៈបីដងផង" ។ ឯគ្រឿងបរិក្ខារ សម្រាប់ប្រគេនចំពោះលោកអ្នកគ្រាលកបិនតែ ១ រូបនោះ ឲ្យវេរថា យេនម្ហាកំ កបិនំ គហិតំ កបិនាធិស្ឋាឡិ តស្សេវ ទេម ។ ទុតិយម្បិ, តតិយម្បិ ។ "កបិនរបស់យើងខ្ញុំតាំងឡាយ ដែល លោកម្ចាស់អង្គណាកាន់យកហើយ យើងខ្ញុំតាំងឡាយ សូមវេរទូរគ្រឿង បរិក្ខារកបិនតាំងឡាយនេះ ប្រគេនលោកម្ចាស់នោះឯង ។ អស់ពារៈពីរ ដងផង, អស់ពារៈបីដងផង" ។ តែក្នុងអដ្ឋកថា អធិប្បាយថា បើទា-យកវេរថា "យេនម្ហាកំ ។ល។ តស្សេវ ទេម" យ៉ាងនេះហើយ សង្ឃមិនជាឥស្សរៈធំលើបរិក្ខារតាំងនោះទេ ព្រោះហេតុនោះបើទាយក ចង់បានផលានិសង្សច្រើន ត្រូវវេរឲ្យជារបស់សង្ឃ គួរវេរដោយឡែក តាមបាលីដែលថ្លាប់វេរវៀងៗមក ប្តូនឹងវេរឲ្យខ្លីដោយមិនបាច់រៀបរាប់ ឈ្មោះរបស់គ្រប់មុខ គ្រាន់តែថារបស់នេះៗ យ៉ាងនេះក៏គួរដូចបាលីថា

ติមាធิ មយំ ภន្តេ វិត្តធิ ភិក្ខុសង្ឃស្ស ធិយ្យាទេម ។
“បពិត្រលោកម្ចាស់ពាំនឡាយដ៏ចំរើន! យើងខ្ញុំពាំនឡាយសូមវេរទ្រព្យ
របស់ពាំនឡាយនេះចំពោះព្រះភិក្ខុសង្ឃ” ។ បើវេរយ៉ាងនេះទើប
របស់ពាំនោះមានអំណាចទូទៅដល់សង្ឃពាំងអស់ ពាំងអានិសង្សរបស់
ទាយកជាម្ចាស់ទានក៏ច្បាន់ច្រើន, បពិត្រព្រះមហាវេរ! ខ្ញុំព្រះករុណា
ច្បាន់វិសជ្ជនាមកអំពីប្រស្នានេះអស់សេចក្តីតែប៉ុណ្ណេះ សូមទានជ្រាប ។

๑๙– សាធុ សាធុ សុន្ទរំ ខោ អនុត្តរ: ម្នាលអនុត្តរ! ប្រស្នា
ដែលលោកម្ចាស់វិសជ្ជនាមកត្រឹមត្រូវល្អហើយ, បពិត្រសប្បុរសពាំនពួន!
បើលោកអ្នកមានសេចក្តីគាប់ចិត្តប្រែបណា គប្បីប្រព្រឹត្តតាមកាន់យកប្រែប
នោះចុះ ព្រោះលោកម្ចាស់អនុត្តរដែលវិសជ្ជនាមក តាមតែច្បាប់ដែល
មានមកក្នុងអដ្ឋកថាកបិន្ទកៈប៉ុណ្ណេះឯង; ឥតោ បរំ បន្ទាប់អំពីនេះទៅ
ខ្ញុំនឹងសួរលោកម្ចាស់តទៅទៀត ។ អើអនុត្តរ! ចុះកាលបើទាយកវេរ
សំពត់កបិនដល់សង្ឃរួចហើយ តើជំនុំសង្ឃត្រូវប្រគល់សំពត់កបិនឲ្យ
ទៅភិក្ខុអ្នកគ្រាលដោយវិធីដូចម្តេចទៅ? ។

(មានត)

ប្រវត្តិព្រះអភិធម្ម

ឃុនសិរីមេធី ស្រី-អ្ងួ ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

ពាក្យថា "អភិធម្ម" ប្រែថា "ធម៌ដ៏ប្រសើរ" ឬប្រែថា "ធម៌ជាធំ ក្រៃលែងជាងធម៌ទាំងឡាយ" មាន ៧ គម្ពីរ គឺ:

១ – ធម្មសង្គណី,

២ – វិភង្គ,

៣ – ធាតុកថា,

៤ – បុគ្គលប្បញ្ញត្តិ,

៥ – កថាវត្ថុ,

៦ – យមក:,

៧ - បដ្ឋាន ឬ មហាបដ្ឋាន ។

ទាំង ៧ គម្ពីរនេះ ហៅថា "អភិធម្ម" ។

ពាក្យថា "អភិធម្មត្ថសង្គហ:" គឺការប្រមូលសេចក្តីនៃព្រះអភិធម្មមកប្រមូលខ្លុកដោយចំប្លែញ ។

ពាក្យថា "បរមត្ថ" គឺសេចក្តីដ៏ក្រៃលែងក្នុងគម្ពីរព្រះអភិធម្មនោះ ។ ព្រះអភិធម្មនោះ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងចំពោះពួកទេវតា ក្នុងតាវត្តិង្សទេវលោក មានទេវបុត្រមួយអង្គឈ្មោះជាពុទ្ធមាតាជាប្រធាន ដូចមានបាលីអាគតដ្ឋានថា :-

បារិប្ផត្តកមូលម្ហិ បណ្ឌុកម្ពលនាមកេ
សិលាសនេ សន្និសិន្នោ អាទិច្ចោវ យុគន្ធរេ
មាគរំ បមុខំ កត្វា តស្សុ បញ្ញាយ តេជសា
អភិធម្មកថាមគ្គំ ទេវានំ សម្បវត្តយិ ។

ប្រែថា: "ព្រះបរមសាស្តាទ្រង់គង់លើសិលាសនៈឈ្មោះបណ្ឌុកម្ពល ក្រោមដើមបារិច្ឆត្តកព្រឹក្ស ទ្រង់មានព្រះឆព្ពណ្ណរង្សីដ៏រុងរឿងដូចព្រះអាទិត្យស្ថិតនៅលើកំពូលភ្នំយុគន្ធរ ទ្រង់សំដែងកថាមគ្គ គឺព្រះអភិធម្ម ទៅតាមសន្តានសត្វទេវបុត្តជាពុទ្ធមាតាជាប្រធាន ដោយតេជានុភាពដល់ពួកនៃបញ្ញាបារមីនោះ" ។

ព្រះមហាសារីបុត្តបានទទួលស្តាប់អំពីព្រះទស្សនៃព្រះសាស្តា ជាដំបូង ក្នុងវេលាចន្លួនាហិមវន្តប្បទេសក្បែរស្រះអនោតត្ត ក្នុងទុកាសដែលព្រះអង្គមកសោយព្រះក្រយាហារ ។ ព្រះសារីបុត្តបានទៅបំរើក្នុងទីនោះ ហើយលោកនាំមកសំដែងដល់តក្ខុចំនួន ៥០០ រូបជាដំបូង ទើបមានការសិក្សាសូត្រវៀនជាបន្តបន្ទាប់គ្នាមក ។

ព្រះអភិធម្មជាពុទ្ធវចនៈដោយពិត ដូចមានចារឹកក្នុងគម្ពីរអដ្ឋសាលិនីថា: អភិធម្មោ នាមេស សព្ពញ្ញុតពុទ្ធានំ យេវ វិសយោ ន អញ្ញេសំ វិសយោ "ព្រះអភិធម្មនេះជាវិស័យនៃព្រះសព្វញ្ញុពុទ្ធទាំងឡាយតែម្យ៉ាង មិនមែនជាវិស័យនៃជនដទៃទាំងសំដែងបានទេ" ។

ការសិក្សាព្រះអភិធម្ម មានប្រយោជន៍ធំធេ្ងលាយណាស់ ព្រោះវាមេបទ ឬ ជាគោលនៃធម៌ទាំង៤ឡាយទូទៅដូចមានពាក្យជាដើមថា: បណ្តាធម៌ទាំង ៨៤,០០០ ព្រះធម្មក្ខន្ធ កាលបើរួបរួមចុះប្រកេទនៃតិកមាតិកាបានដល់ធម៌ ៣ ប្រការគឺកុសលធម៌, អកុសលធម៌, អព្យាកតធម៌, ហើយការសិក្សាព្រះអភិធម្មនោះនឹងមានផលច្រើន ទៅជាអ្នកមានបញ្ញាតាំងអំពីជាតិនេះ នឹងបានជាបញ្ញាចារមើទៅជាតិខាងមុខទៀត ទាំងជាហេតុឲ្យប្រតិបត្តិមគ្គទាំង ៤ ប្រការ មិនខុសចាកផ្លូវផង ។

ចប់

យោពនរូបសម្បន្នោ វិសាលកុលសម្ភវោ
វិជ្ជាហីនោ ន សោភតិ ធិគន្ធា តីរកិំសុកា

ប្រុសនៅក្មេងរូបល្អឆើត ទាំងបានមកកើតត្រកូលខ្ពស់
តែហីនវិជ្ជាក៏គ្មានយស ឥតរុងរឿងស្រស់ក្នុងសង្គម ។
ដូចជាផ្កាចាក្របាមប្រាស ត្រកាលតែពណ៌មិនឱគ្គម
ព្រោះគ្មានក្លិនក្តៅបគ្គរមនោរម្យ នេះបំជាផ្កាឥតប្រយោជន៍ ។

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម
អាចារ្យសាលាចាលីវន វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង
ឃុនបណ្ឌានុក្រម ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

មនុស្សបែបនេះ ទុកដូចជាបានប្រឡាក់ប្រឡូសដោយរបស់ស្មោកគ្រោក ដែលមានក្លិនស្អុយ ដែលអ្នកដទៃត្រូវគេចខ្ជូនវត់ចេញឲ្យឆ្ងាយ ព្រោះការនៅរួមនឹងមនុស្សដែលមាននិស្ស័យមិនពប់អានអ្នកដទៃបែបនេះ ទៀតតែបង្កឲ្យកើតទុក្ខភ័យក្តៅក្រហាយឡើងដល់គ្នា . មិនជាការសុខសម្រាន្តរៀបរយបានស្រួយ ។ គប្បីចូលចិត្តចុះថាកាយ វាចា ចិត្ត ដែលអាក្រក់ឬរើងភ្នឹងមើលងាយគេ ជាគ្រឿងនិរទេសខ្លួនយើងឲ្យឃ្លាតចេញឆ្ងាយពាកមនុស្សដទៃខ្លួនៅ ។ ចំណែកកាយ វាចា ចិត្តដែលល្អវិញជាគ្រឿងប្រមូលអ្នកដទៃ ឲ្យចូលមកចងសម្ពន្ធមិត្តដិតដិតស្និទ្ធស្នាលនឹងយើង ធ្វើឲ្យយើងមានបក្សពួកមិត្តភក្តិច្រើនគ្នា ។

យើងមានចេតនាប្រាថ្នាចង់ឲ្យមនុស្សដទៃ ពប់អានយើងយ៉ាងណា មនុស្សដទៃក៏មានចេតនាចូលចិត្តឲ្យយើងពប់អានគេយ៉ាងនោះដែរ នេះជាគោលនៃសេចក្តីពិត ។ ហេតុនេះ កាលលោក - អ្នកមានការនៅរួមនឹងជាប់ទាក់ទងជាមួយមនុស្សដទៃ បើត្រូវការសេចក្តីពប់អានអំពី

មនុស្សដទៃដូចម្តេច ក៏ចូរធ្វើសេចក្តីពប់អានចំពោះមនុស្សដទៃដូច្នោះចុះ កុំឃើសឃងច្រមាថមើលងាយគ្នា ព្រោះតាលបើលោក-អ្នកមិនសំដែងសេចក្តីអត្រកប្ញការលុបគុណមើលងាយគេហើយ គេក៏នឹងមិនសំដែងសេចក្តីអត្រកប្ញការលុបគុណមើលងាយលោក-អ្នកវិញដែរ ។ ចូរព្យាយាមបណ្តុះទិស្សយ័រពប់អានអ្នកដទៃឲ្យឆ្លើងក្នុងខ្លួន តាមលក្ខណៈនៃសេចក្តីពប់អានគ្នា ៤ យ៉ាងដូចតទៅនេះ :-

១- មានកាយនឹងវាចាសុភាពរិងលំទោង.- យើងស្គាល់សេះល្អត្រង់ត្រចៀក ស្គាល់មនុស្សចិត្តខ្ពស់ត្រង់ការជួយអើពើ ស្គាល់មនុស្សល្អត្រង់ការសើច ស្គាល់តែមណីត្រង់ស្មៅ សូម្បីយើងនឹងស្គាល់មនុស្សសុភាព ក៏ត្រង់សេចក្តីសុភាពដែលគេសំដែងចេញមកតាមផ្លូវកាយនឹងវាចាដែរ ។ ពិតមែន មនុស្សសុភាពរមែងសំដែងកិរិយានឹងវាចាគួនលំទោនខន់ក្នុន់ល្អជាទីបំផុតចំពោះអ្នកដទៃ បើមនុស្សដទៃ ជាអ្នកគួចតាចអន់ខ្សោយផង ក៏នឹងតែតែសំដែងកាយវាចា ឃុំត្រង់មនុស្សអន់ខ្សោយនោះថែមទៀត ហើយសូម្បីធ្វើដូច្នោះទៅ មិនមាននរណាត្រឡប់មើល គ្មាននរណាលើកតំកើងសរសើរក៏ដោយ ក៏ឥតរវល់ដែរ ព្រោះការធ្វើល្អនោះ បំណងដើម្បីនឹងថែរក្សាសេចក្តីល្អប៉ុណ្ណោះ មិនមែនធ្វើល្អដើម្បីយកមុខ ឬដើម្បីទទួលសេចក្តីលើកដំកើងសរសើរឡើយ ពាំងកាលធ្វើសេចក្តីល្អឲ្យកើតឡើងដល់មនុស្សដទៃ ក៏មិនចាំបាច់ស្រែកហៅឲ្យគេ

មកតបស្នងខ្លួនដែរ ដរៃអំពីនោះទៅទៀត គឺឥតនឹកនាដល់អំពើដែលខ្លួនបានប្រតិបត្តិចំពោះមនុស្សដទៃឡើយ ទាំងមិនមើលអ្នកដទៃនោះដោយកន្ទុយភ្នែក ដែលហាក់ដូចជាបង្ហាញឲ្យគេដឹងថាអ្នកនោះជាកូនបំណុលត្រូវសងបំណុលខ្លួន ។ ដូច្នោះមនុស្សសុភាព ទើរមានលំអប្រាកដនៅក្នុងលោក សូម្បីស្ងាប់បាត់ទៅហើយ ក៏មិនបាត់សេចក្តីល្អដែរ ដូចជាខ្មឹមចន្ទន៍ សូម្បីត្រូវនរណារំលំផ្តួលហើយក៏នៅតែមានក្លិនក្រអូបជាប់នៅនឹងរណារនោះដែរ ។ ហេតុនេះ លោក-អ្នកចូរបណ្តុះនិស្ស័យរាប់អានគ្នាដោយសេចក្តីសុភាពចុះ ។

ចំពោះមារយាទខាងផ្លូវកាយវិញ យើងគួរសំដែងកិរិយាឲ្យសុភាពរាបសាល្អ ឲ្យសមគួរដល់បុគ្គល, ទីកន្លែងនឹងកាលសម័យ ដូចជាបានពោលទុកក្នុងឧបាយបណ្តុះនិស្ស័យទី ២ ត្រង់ "ក-កិរិយាល្អ-)" រួចហើយ មិនត្រូវសំដែងកិរិយាអាក្រក់ថោកទាប ច្របេងច្របាងរឹងត្អឹង ឬកិរិយាក្រអឺតក្រទមដទៃទៀត ចំពោះនរណាមួយឡើយ គួរប្រយ័ត្នប្រយែងដាក់កិរិយាឲ្យតាំងនៅក្នុងក្របខ័ណ្ឌដ៏ល្អ គឺសីលធម៌, សុប់សៀម, ជាក់ខ្លួន, សុភាពរៀបរយ, ទុបអរសាទរ, ករុណាប្រណី, ខ្ជួលរាក់ទាក់ដោយការអញ្ជើញ, មានសម្ងាត់វៈ: ទន់លំទោនខន់កូន ចំពោះអ្នកធំនឹងអ្នកស្មើគ្នា សូម្បីចំពោះអ្នកតូច ឬអ្នកដែលមានហានៈទាបជាង ក៏មិនគួរក្រអឺតក្រទមបើងម៉ើងឆ្មើងកន្ទ្រើង ឫយកចិត្តមុឺតដោយប្រកាន់អស្ថិមានៈដែរ ។

ចំពោះមារយាទខាងផ្លូវកាយ យើងគួរនិយាយពាក្យសំដីដែលពីរោះផ្អែមល្អែមដាយស្តាប់ស្រួលត្រចៀក ដែលអង្វរចិត្តអ្នកស្តាប់ ឲ្យមានសេចក្តីស្រឡាញ់ជាប់ចិត្តយើញសមល្មម គួរកាន់យកជាបែបយ៉ាង ព្រោះធ្វើតាមបានមិនមានទោស ជាវាចាមិនញុះឲ្យគេកើតក្រោធ ជាសំដីដឹកនាំឲ្យអ្នកស្តាប់សប្បាយរីករាយ ដូចជាបានផឹកទឹកថ្នាំដែលជាគ្រឿងធ្វើចិត្តឲ្យត្រជាក់ត្រជំ ទើងជាវាចាគួរត្រេកត្រអាលគាប់ចិត្តរបស់មនុស្សជាទៀងទៅ ។ កុំពោលពាក្យគំហកឡួកឡាវ៉ូសវ៉ាស ឬសោះកក្រោះអាក្រក់គ្រោតគ្រាត គួរអប់មាត់ឲ្យក្រអូបឈ្ងុយឈ្ងប់ទៅដោយវាចាពីរោះផ្អែមល្អែម កុំបណ្តោយឲ្យមាត់ខូចដោយពាក្យអាក្រក់គឺកុំពោលពាក្យគគ្រឹសគគ្រែសចាក់ជោត គំហក ឬពាក្យសំដីណាមួយដែលជាហេតុឲ្យមនុស្សជាទៃខឹសចិត្ត ឈឺចិត្ត ឬចង្អៀតនុំចំពោះខ្លួនឡើយ ។

ចូរចាំទុកថា អ្វីមជាងអៀម ស្មៀមជាងស្រដី (បុពណ្ណកាសិត) ។ ការនៅស្ងៀមប្រសើរជាងការធ្វើ ឬការនិយាយដោយមិនសុភាព ។ ព្រោះការធ្វើ ឬការនិយាយមិនសុភាពនោះ រមែងធ្វើឲ្យគេឈឺចិត្ត ឲ្យខូចទំនុកចិត្ត ។ ឯការធ្វើទើងការនិយាយដែលសុភាពរៀបរយវិញ ក្រៅពីធ្វើមិនឲ្យនរណាខឹសចិត្ត អន់ចិត្តឈឺចិត្តហើយ ក៏គង់ជាថ្នាំថែរក្សាទឹកចិត្តគេឲ្យត្រេកអរពេញ ស្រឡាញ់កក្តី គោរពរាប់អានពុកចិត្តបានទៀតផង ។ ហេតុនេះ លោកអ្នកចាំងឮយ ចូរសំដែង

ការិយាសុភាពតុនលំពោន ចូរពោលវាចាសុភាពផ្អែមល្ហែម ព្រមដោយ
ទឹកមុខរីករាយផូរផង់ នឹងដួងចិត្តដ៏មុតថ្លា ដូចមុខស្រស់វ៉ុងដ៏មុត ដើម្បី
កាត់បង់នូវសេចក្តីរីងរៃស្រួចឡើងបើស ច្រេងច្រាងនឹងលុបគុណ
មើលងាយមនុស្សជាទៃឲ្យវិនាសទៅ ។

២ ប្រព្រឹត្តខ្លួនស្មោះស្ម័ត្រ— មនុស្សដោយច្រើនដែលនៅរួម
គ្នាជាពួកជាគណៈ តែងចូលចិត្តបង់បានការស្មើមុខគ្នាជាដរាប ។ អ្នក
ដែលមានជាតិត្រកូលគ្រាន់បើ មានយសសក្តិ, អំណាច, ទ្រព្យសម្បត្តិ,
បរិវារ, កំឡាំងកាយ, កំឡាំងចិត្តនឹងសតិបញ្ញាឫគុណវុឌ្ឍិ រមែងមាន
សេចក្តីស្រឡាញ់ហួងហែង ថែរក្សាទុកនូវកិត្តិយសដែលជាទីស្រឡាញ់
នោះៗ មិនចង់ឲ្យនរណាមកមើលងាយត្រូវបង្អាប់ឫនបង្អោចឲ្យវិនាស
ទៅឡើយ ។ សូម្បីខ្លួនលោកអ្នកដែលជាមនុស្សម្នាក់ដូចគេ ក៏គង់តែ
មានចិត្តចង់ថែរក្សាភាពជាអ្នកស្មើមុខគ្នាដូចមនុស្សជាទៃដែរ រួបរួមទៅក៏គឺ
ចង់បានសេរីភាពពេញទីចំពោះខ្លួន មិនត្រូវឲ្យនរណាមកជិះជាន់លើ
សេរីភាពរបស់ខ្លួនឡើយ តែសូមកុំច្រឡំ! ការរក្សាសេរីភាពសមភាព
ក្នុងទីនេះត្រូវឲ្យសមគួរដល់ឋានៈរបស់ខ្លួន ដែលច្បាប់បើកឲ្យមាន មិន
មែនខ្លួនមានឋានៈគាប ហើយចង់បានភាពជាអ្នកមានមុខស្មើនឹងឋានៈ
របស់អ្នកធំទេ ។

ហេតុនេះ ទើបគួរប្រព្រឹត្តខ្លួនឲ្យស្មោះស្ម័ត្រ គឺថាឲ្យដឹងប្រមាណខ្លួន
ដំកល់ខ្លួនឲ្យស្មោះស្ម័ត្រសមសមគួរដល់ឋានៈនឹងការតាំងនៅរបស់ខ្លួន ធ្វើ

ខ្លួនឲ្យប្រពឹត្តទៅក្នុងពួកគណៈ នឹងញាតិមិត្តសំឡាញ់ដោយត្រឹមត្រូវ
ព្រោះដំរិតរបស់លោក-អ្នក ដែលនឹងបានទទួលសេចក្តីរីករាយសប្បាយ
នោះ មិនមែនទៅត្រង់ការលើកខ្លួនឯងឲ្យស្មើមនុស្សដទៃ ដោយជាតិ
ត្រកូលដ៏ខ្ពង់ខ្ពស់ ដោយអំណាចវាសនារបស់បងប្អូន ឬដោយការសំដែង
កិរិយានឹងវាចាយ៉ាងដទៃទៀតឡើយ តាមពិតទៅគឺនោត្រង់លោក-អ្នក
ចេះប្រពឹត្តខ្លួនឲ្យស្មោះស្ម័ គំកល់ខ្លួនឲ្យសមគួរ មានចិត្តជាធម៌ សំដែង
កាយវាចាឲ្យប្រកបទៅដោយការស្ងៀមភាគ ដោយសេចក្តីនុនលំទោន
ដោយសេចក្តីប្រយ័ត្នប្រយែងនឹងដោយសេចក្តីព្រមព្រៀងជាលក្ខណៈ ។
ក្នុងលោកនេះ ទីណាដែលសម្បូណ៌ទៅដោយមនុស្សលើកខ្លួន ដៀល
តួះអួតដទៃ ដោយជាតិត្រកូលថា "យើងជាមនុស្សជាន់ខ្ពស់ គេជា
មនុស្សជាន់ទាប" ព្យាយាមបែងចែកគ្នាចេញទៅជាពួកគួច។ រហូតដល់
នៅរួមគ្នាមិនបាន ទីនោះនឹងកើតមានសេចក្តីវិនាសលិចលង់ជិនហោច ។
លុះតែទីណាដែលមនុស្សមិនលើកខ្លួនសង្កត់អួតដទៃបែបនេះ ហើយព្យា-
យាមរួបរួមកំឡាំងគ្នាចូលមកជាពួកជំតែមួយដោយសាមគ្គី ទីនោះទើប
ចំរើននឹងបំតែថេរថាវរៈមាំមួនជាគួគ្នានឹងផែនដី ។ តាមពិត គោលធម្មិកឥ
សាសនានេះ ក្រៃអំពីការប្រពឹត្តិអាក្រក់ឬល្អហើយ ក៏មិនយើញមាន
ក្នុងទីណាថាសម្រាប់ជាក់ទោសឬឲ្យរង្វាន់ ដល់អ្នកដែលមានជាតិត្រកូល
ថាក់នេះថាក់នោះឡើយ ។ អ្នកនេះជាពួកយើង អ្នកនោះជាពួកគេ

នេះជាសេចក្តីចូលចិត្តរបស់មនុស្សមានន័យយ៉ាងដូច្នេះ ។ អ្នកដែលមានចំណូលយ៉ាង រមែងប្រកាន់ថា អ្នកនៅលើផែនពសុធាទាំងអស់ សុទ្ធតែជាពួកជាមួយគ្នា ។ សូមរួកសុភាសិតនេះជានិច្ចទៅ បើយើងចង់ឲ្យជាតិចំរើនរុងរឿង ។

ពួកគណៈនឹងតាំងនៅបាន ដោយអំណាចនៃភាពជាអ្នកមាននីតិធម៌ស្មើគ្នា បើមិនដូច្នោះទេ ក៏មិនអាចនឹងរក្សាសាមគ្គីធម៌ពុកបានឡើយ ។ អ្វីសោតហៅថា នីតិធម៌? បញ្ជាប់ចំលាប់ បង្គាប់នឹងគុណសម្បត្តិបែបផែនលក្ខិ ប្រពៃណី ដ៏ល្អ ដែលនិយមតៗគ្នាមកក្នុងពួកជននៃជាតិ ហៅថា នីតិធម៌ ។ លោក-អ្នកចូរកាន់នឹងធ្វើតាមនីតិធម៌របស់ពួកគណៈប្រព្រឹត្តកាយ វាចឲ្យរៀបរយស្មោះស្មើ កុំប្រព្រឹត្តបែកពួកបែកគណៈ ពាល់តែជាទីរង្គើសរបស់ពួកគណៈឬប្រជាជនឡើយ ចូរមានមតិរួមគ្នាកុំគប្រមាថប្រកាន់គ្នាដោយឥតហេតុផល ចូរចេះអនុលោមយល់ព្រមស្របគ្នាឲ្យចុះសម្រុង ធ្វើសេចក្តីចូលចិត្តឲ្យល្អក្នុងកាលឃើញផ្ទុយគ្នា ដោយសំឡឹងយកសេចក្តីស្ងប់រៀបរយ នឹងប្រយោជន៍ចំណែករួមជាសំខាន់ ។ ព្រោះមនុស្សយើង នឹងមានការប្រព្រឹត្តល្អស្មោះស្មើគ្នាបាន ក៏ដោយសារច្បាប់ចំលាប់ គឺជាមនុស្សល្អ ត្រូវនៅក្នុងច្បាប់ចំលាប់ ឯមនុស្សក្រៅច្បាប់ចំលាប់នោះ គឺមនុស្សពៃឬមនុស្សស្វាប់ ។ (មាឧត)

ឧកញ៉ាវិបុលរាជសេនា ឆ្លៀត-កន ប្រៃរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជនិឡាសបើបានអាន
ធឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

តៀវស៊ីវយល់ឃើញ — ត្រូវកំលើកទាហានប្រមាណមួយម៉ឺនហុយ នាំ ទៅតៀវទៅតាមចូឆូចំម្ងាយផ្លូវប្រហែល ១០០ សិន (៤ គ.ម) ទាន់ កងទ័ពចូឆូ ។ ក៏ឲ្យទាហានកងគ្រោយចេញតច្បាំងនឹងកងទ័ពតៀវស៊ីវ សម្លាប់ទាហាន តៀវស៊ីវស្លាប់ជាច្រើន ។ តៀវស៊ីវនឹងទៅតៀវក៏បែកទ័ពទៅ ។ តៀវស៊ីវនិយាយនឹងកាសៀងថា ដែលយើងតាមចូឆូទៅ ត្រឡប់បែកទ័ពមកគ្រានេះព្រោះមិនដឿស្តាប់ពាក្យអ្នក ។

កាសៀងនិយាយថា ឥឡូវនេះសុំឲ្យលោកលើកទ័ពតាមចូឆូទៅចុះ មុខជានឹងបានជ័យជំនះជាក្រាកដ ' បើមិនបានដូចពាក្យខ្ញុំបាទថាទេ សុំ

ឲ្យលោកគាត់ក្បាលខ្ចីបាទបុះ ។ តៀវស៊ីវបានស្តាប់ដូច្នោះ ក៏នាំទៀវ-
ពៀវលើកទ័ពទៅ តែទៀវពៀវមិនព្រម តៀវស៊ីវក៏លើកទាហានទៅតាម
ចូធួ ។ ឯចូធួដែលបានឈ្នះទ័ព ក៏មានចិត្តធ្វេសប្រហែសមិនបានលើក
ទាហានជាក្បួនទ័ព ។ លុះតៀវស៊ីវលើកទ័ពទៅទាន់ ក៏ដេញចោមរាយ
ចាក់កាប់សម្លាប់ទាហានចូធួដែលមិនទាន់ដឹងខ្លួន ។ ទាហានចូធួក៏រត់
ចាក់បែកខ្ចាត់ខ្ចាយចោលគ្រឿងសស្ត្រាវុធទឹងរនេះតាំងឡាយជាច្រើន ។
តៀវស៊ីវក៏ដេញទាហានឲ្យចូលទៅសម្លាប់ទាហានចូធួដល់ដើងកុំ ១ ខ្លួន
ឰសំឡេងទាហានស្រែកហោទីលើកំពូលកុំ ហើយលើកចុះមកជាច្រើន ។
តៀវស៊ីវយល់ថាមុខជានឹងចាញ់ ក៏នាំទាហានត្រឡប់ចូលបន្ទាយ ។
ទៀវពៀវនឹងការសៀងនាំគ្នាចេញមកទទួលតៀវស៊ីវ ចូលទៅក្នុងបន្ទាយ ។

ទៀវពៀវសួរទៅការសៀងថា កាលយើងលើកទ័ពទៅច្បាំងគ្រាមុន
នោះ ទាហានតាំងអស់កំពុងស្រុះស្រួលមានកំម្លាំង ក៏ត្រឡប់ហក់ដ័យដូច
ពាក្យអ្នកថាជាច្រើនដូច្នេះ ទាហានកំពុងនឿយហត់ អ្នកសំគាល់ថា
មុខជានឹងឈ្នះ បានជាឲ្យលើកទ័ពតាមទៅ តែឥឡូវមានដ័យដំនះដូចពាក្យ
អ្នកថាខ្វៃត ហេតុម្តេចបានជាអ្នកដឹងការនេះច្បាស់ម្ល៉ះ ? ការសៀង
ឆ្លើយថា លោកធ្វាប់ឆ្លើសឹកសង្គ្រាមមកក៏មែនហើយ តែមិនច្រើនដល់គំនិតចូធួទេ
កាលពីដំបូងចូធួលើកទ័ពទៅសំគាល់ថា យើងនឹងលើក
ទ័ពទៅតាម បានជាហាមច្រាមចាត់ទាហានឲ្យទៅការពារខាងក្រោយ

សុទ្ធតែមានថ្លៃដែរជាធំៗហានយើង ចានជាយើងបារម្ភ គ្រាក្រោយចូរឆ្លេសប្រហែសមិនបានប្រយ័ត្នការតាមរបៀបក្បួនទំនៀម ប្រញាប់ទឹងស្រួតទៅឲ្យដល់ក្រុងជានាប់ ចានជាយើងវាយបែកចានដោយងាយ ។

ខ្លាពៀវនឹងតៀវស៊ីវាក៏សរសើរគំនិតរបស់ការសៀងថា អ្នកមានជំរេះប្រាជ្ញាទឹងក្រនណាស្មើគ្មាន ។ ខ្លាពៀវនឹងតៀវស៊ីវាឆ្ងិតតែស្រឡាញ់ការសៀងលើសពីដើមហាក់ដូចជាបងប្អូន អ្នកទាំងសងខាងក៏គំនាប់លាគ្នាទៅខែត្រណរៀងខ្លួន ។

កាលទំពតៀវស៊ីវាលើកតាមទៅវាយទំពចូរឆ្លូជាន់ក្រោយនោះ ចូរឆ្លូចានឮសំឡេងធោឡោឡើង ក៏កេណ្ឌាហានប្រឹងនឹងលើកទៅជួយទទួលខាហានដែលបែកទៅនោះរត់ទៅប្រាប់ចូរឆ្លូថា កងទំពតៀវស៊ីវាលើកមកចោមវាយ ក៏ទទួលមានកងទំពមួយលើកចុះមកពីលើភ្នំ តៀវស៊ីវាខ្លាចក្រែងទំពបង្កប់ក៏នាំខាហានត្រឡប់ទៅវិញ បើកុំបានដូច្នោះប្រហែលយើងខ្ញុំតាំងឡាយនឹងស្លាប់អន្តរាយតាំងអស់គ្នា ។

ចូរឆ្លូសួរថា កងទំពនណាដែលចុះពីលើកំពូលភ្នំនោះ ។ ទទួលលីថង់លើកទំពទៅដល់ប្រទល់នឹងមុខចូរឆ្លូ លីថង់ក៏លោតចុះពីលើសេះចោះខ្លួនពីដៃចេញ ហើយដើរចូលទៅគាំនាប់ចូរឆ្លូៗ សួរថា អ្នកឯងឈ្មោះអ្វី? លីថង់ឆ្លើយជំពាបថា ខ្ញុំចានឈ្មោះលីថង់ ជាចៅហ្វាយស្រុកយ៉ាំឡាំ ចានឮកិត្តិស័ព្ទថា មហាឧបាជលើកទំពទៅប្លាំងនឹងតៀវស៊ីវា ខ្ញុំចាកក៏

លើកទ័ពមកដួយ ទទួលប្រទះនឹងកងទ័ពគៀវស៊ីវលើកតាមលោកមក គៀវស៊ីវឃើញខ្ញុំបានជាជយត្រឡប់ទៅវិញ ។ ចូឆូមានសេចក្តីត្រេកអរណាស់ ក៏តាំងលីថងជាគៀងកុងហៅ គឺនាហ្នឹងមានសេចក្តីគាប់ប្រសើរនឹងផែនដី នៅតង់ជាថៅហ្វាយស្រុកយីឡាំដដែល ហើយឲ្យលើកទាហានទៅត្រួតត្រាយាមល្បាតខាងអាណាខែត្តទិសបស្ចិម ការពារឡៅគៀនឹងគៀវស៊ីវ កុំឲ្យកងវ៉ែនមកឆ្មើងឆ្មៃរយដល់អាណាប្រជានុរាស្ត្រតាំងឡាយ ។ លីថងក៏មានសេចក្តីត្រេកអរគំនាប់លាចូឆូត្រឡប់ទៅស្រុកយីឡាំវិញ ។

ចូឆូក៏លើកទាហានបង្ក៏សទៅដល់ក្រុងហ៊ូតោ ទើបចូលទៅគាល់ព្រះចាន់ហៀនតេ ហើយក្រាបទូលថា ឥឡូវនេះ ស៊ុនសិកបានធ្វើសេចក្តីគាប់ប្រសើរណាស់ សូមឲ្យតាំងស៊ុនសិកជាឆោងឯកចៀងគុន ប្រែជាខ្នែរថា «ខុនណាងជាធំ» សម្រាប់ថ្កាប់ថ្កាមសត្រូវក្នុងស្រុកតាំងតាំង ។ ព្រះចៅហៀនតេក៏ទ្រង់ព្រះរាជទាន ។ ចូឆូទើបតែងសំបុត្រតាំងស៊ុនសិកទទឹងត្រឹងយស បញ្ជូនទៅឲ្យស៊ុនសិកឯស្រុកតាំងតាំង ហើយថាឲ្យស៊ុនសិកគិតកំចាត់ឡៅគៀវចេញឲ្យបាន ។ លុះចូឆូត្រឡប់ពីទីគំនាល់មកវិញ ត្រួតអ្នករាជការតាំងពួងបានចូលទៅគំនាប់ចូឆូជាច្រើននាក់ ។ ស៊ុនហុកដាបសួរចូឆូថា ខ្ញុំបានដឹងដំណឹងថា មហាឧបរាជបរាជ័យដល់សិកសត្រូវ មកគ្រានេះមិនបានស្រួតរូតប្រញាប់ បណ្តាយ

ឲ្យទ័ពដើរលើហែតាមធម្មតា ។ បានជាខ្ញុំបានធ្វើសំបុត្រទៅលើកស្មាតើ លោកៗតបមកថា នឹងមានដំយដំនះសឹកសត្រូវនោះតើ លោកសំគាល់ដោយហេតុអ្វី ទើបត្រូវនឹងពាក្យលោកម្ល៉ះ ។ ឫទ្ធតបថា យើងបរាជ័យនឹងតៀវស៊ីវនោះ បើនឹងគិតយកដំយដំនះវិញក៏មិនបានព្រោះសត្រូវខ្លាំងកម្លាំង ។ បើប្រឹងទៅហើយនឹងខ្ចប់ខាតខាហានជាច្រើន បានជាយើងបង្ហោតដើរឲ្យយូរ មកដល់ដែនស្រុកអាន់ពុងគួនជាចន្លោះចង្អឹត កំឲ្យតាំងបន្ទាយនៅទីនោះអែបនឹងដើងកុំ ហើយបង្គប់ខាហានខ្មុកទាំងសងខាងផ្លូវ ។ តៀវស៊ីវមិនដឹងជាកលសឹក ក៏លើកចូលមកវាយដល់បន្ទាយយើងៗ ឲ្យខាហាន ដែលបង្គប់ចេញមកខ្ចប់វាយទាំងសងខាង បានជាកងទ័ពតៀវស៊ីវបែកទៅ ។ ស៊ុនហុកបានស្តាប់សព្វសេចក្តី ក៏គ្រីក្បាលសរសើរថា គំនិតគិតរបស់មហាឧបរាជ ជំនាញស្ទូញស្ទាត់កងកលសឹកសង្គ្រាម នឹងរកអ្នកឯណាធ្ងឹមស្មើគ្មាន ។ ទទួលគុយតែចូលទៅគំនាប់ប្ញូៗសួរថា ហេតុម្តេចបានជាអ្នកឯងទើបមកតែឯងគេ? ។ គុយតែដំកបថា បានជាខ្ញុំយឺតយូរព្រោះមានខាហានអ៊ូនសៀវនាំសំបុត្រមកឯផ្ទះ និយាយហើយក៏ហូតសំបុត្រនោះទៅឲ្យឫទ្ធមើល។ ហើយក៏និយាយថា "សំបុត្រអ៊ូនសៀវថា នឹងលើកទ័ពទៅវាយកងស៊ុនចានចៅហ្វាយស្រុកចាំក់ប៉ែង សុំខាហាននឹងស្បៀងអាហារទៅជួយ បើមិនព្រមជួយដូចសេចក្តីដែលសុំទេ នឹងលើកទ័ពមកវាយយកក្រុងហ៊ូតោ"

ដូច្នេះ យើងក៏អាចដឹងគំនិតអ្នកនៅសៀវភៅចប្បាស់ គឺមុននេះអ្នកនៅសៀវភៅនឹងបើកទំព័រមកវាយស្រុកយើង. លុះដឹងថាយើងលើកទំព័រឡើងមកហើយ អ្នកនៅសៀវភៅក៏ប្រែជាសុំគាហានឥតឈប់ឈរ ដើម្បីនឹងលើកទំព័រទៅវាយកន្លះចានវិញ ដែលអ្នកនៅសៀវភៅគេលមកដូច្នេះ ជាការប្រមាថមើលងាយ. យើងចង់លើកទំព័រទៅវាយស្រុកគឺដីវាចាប់អ្នកនៅសៀវភៅសម្លាប់ចេញ តែនៅមានសេចក្តីចុះម្តង. ព្រោះគាហានយើងតិចហើយកំពុងនៅរឿយហាត់ តើអ្នកចាំងឡាយទន្លឹងយល់ឃើញដូចម្តេច? ។ គួយតែឆ្លើយថា កាលព្រះចៅហាន់គោចោទឹងព្រះចៅឈប៉ាអង្វែងធ្វើសង្គ្រាមនឹងគ្នា ព្រះចៅឈប៉ាអង្វែងខ្វាំងពូតែហើយមានសេនាគាហានច្រើន ខាងព្រះចៅហាន់គោចោមានគាហានតិច តែដំនាញស្ទាត់ស្ទាញក្នុងកលសិកគិតយកជ័យជំនះព្រះចៅឈប៉ាអង្វែងបាន សេចក្តីចាំងប៉ុន្មានលោកក៏បានជ្រាបសព្វហើយ ដែលអ្នកនៅសៀវភៅមានគាហានច្រើនក៏មែនពិតហើយ តែថាមិនស្មើប៉ុនប្រសព្វរិះគិត លោកមិនត្រេះត្រៃយឹងគាហានតិចច្រើននោះឡើយ បើលោកទៅឆ្លើការស៊ើកហើយ ខ្ញុំចាំយល់ឃើញថា លោកនឹងមានជ័យជំនះអ្នកនៅសៀវភៅ ១០ ប្រការ ឯអ្នកនៅសៀវភៅនឹងបរាជ័យដល់លោក ១៩ ប្រការ ។

ចូរឆ្លុះសួរថា យើងនឹងឈ្នះអ្នកនៅសៀវភៅ ១០ ប្រការ អ្នកនៅសៀវភៅនឹងចាញ់ ១០ ប្រការនោះដូចម្តេចខ្លះ? ចូរអ្នកនាំសេចក្តីមកអធិប្បាយឲ្យពិស្តារយើងនឹងស្តាប់ផងមើល ។

គុយតែថា លោកនឹងឈ្នះ ១០ ប្រការនោះ គឺ:

១.- លោកមិនបានគាន់ខ្លួន បើនឹងធ្វើការអ្វីៗ ព្រោះបើអ្នកតូចទឹងថាស់នឹងលោកថាខុសប្លែកវៃ លោកក៏រងើចាំស្តាប់ ។

២.- ចិត្តរបស់លោកជាអ្នកមានអធ្យាស្រ័យស្រឡាញ់ ពាប់អានមនុស្សទាំងពួង ព្រោះនឹងធ្វើកិច្ចការណាៗ ក៏តែងតាន់យកព្រះដម្រាស់ព្រះថៅហៀនតេជាប្រមាណ មនុស្សសព្វស្ថានក៏មានសេចក្តីគ្រែកអារស្រឡាញ់លោក ។

៣.- លោកនឹងនិយាយការអ្វីទៀងទាត់ . មានខ្នើអំណាចមនុស្សទាំងឡាយគោតខ្លាចជាច្រើន ។

៤.- លោកមានចិត្តសត្យពិតត្រង់ ទ្រទ្រង់សេនាគហានឲ្យមានកិត្តិយសដោយយុត្តិធម៌ សូម្បីញាតិសាលោហិតមិត្រសំឡាញ់ធ្វើខុសក៏មិនពោលប្រកាន់ទាងខុសជាត្រូវ ។

៥.- លោកនឹងគិតធ្វើការអ្វី ឃើញថាសេចក្តីនោះប្រពៃល្អទាំងចិត្តក៏ជួងផ្តើមធ្វើឲ្យបានសម្រេច ។

៦.- លោកនឹងពាប់អានស្រឡាញ់អ្នកណា ក៏ពាប់អានស្រឡាញ់ពេញដោយសុចរិតមិនមែនគិតល្បងបញ្ឆោត ។

៧.- លោកចិញ្ចឹមមនុស្សដែលនៅជិតនឹងនៅឆ្ងាយ បើល្អហើយក៏ចិញ្ចឹមស្មើគ្នា ។

៨.- លោកគិតការអ្វីជាទម្ងន់ ត្រូវគិតឲ្យឆ្អែតឆ្អន់ម៉ាំមួនទើបធ្វើ ។

៩. លោកនឹងចាប់ផ្តើមធ្វើការអ្វី ក៏ធ្វើតាមទំនៀមទម្លាប់ពីបុរាណ ។

១០.- លោកជំនាញស្ទាត់ក្នុងកលល្បិចាយនៃក្បួនពិជ័យសង្គ្រាម ទោះកំឡាំងសត្រូវខ្លាំងជាងលោកៗ ក៏គិតយកជ័យជំនះបាន ។

ឯអ្នកសៀវភៅលន់ឆ ចាញ់លោក ១០ ប្រការនោះ គឺ:

១. អ្នកសៀវភៅជាមនុស្សប្រកាន់ឥស្សរិយយស មិនចាន់ត្រូវនឹងខ្ញុំសតាមគំនិតអ្នកឯណា ។

២.- អ្នកសៀវភៅជាមនុស្សអាត្រក់ ធ្វើការលាមកដោយវៀហារ ។

៣.- អ្នកសៀវភៅនឹងនិយាយការអ្វីមិនមានអំណាចសោះ ព្រោះវាចាពោលមិនខ្ជាប់ខ្ជួនទាត់ ។

៤.- អ្នកសៀវភៅឃើញតែញាតិសន្តានបងប្អូនរបស់ខ្លួន មិនចានសន្ធយកចិត្តអ្នកដទៃ និយាយទៅតាំងខ្ញុំសតាំងត្រូវ ។

៥.- អ្នកសៀវភៅគិតការអ្វី រមែងត្រឡប់ផ្ទាស់ប្តូរយកល្អជាអាក្រក់ មិនទុកចិត្តគំនិតខ្លួន ។

៦.- អ្នកសៀវភៅនឹងចិញ្ចឹមរក្សាអ្នកឯណា មិនចានតាំងចិត្តចិញ្ចឹមជាប្រក្រតី ចំពោះមុខសរសើរថាល្អ កំបាំងមុខនិយាយបង្អាប់បង្អោនថាអាក្រក់ ។

៧.- អ្នកនៅរមែងស្រឡាញ់មនុស្សចំនុកចុកចិត្ត ដែលគិតនឹងជួយផ្តួងផ្តើម បើអ្នកឯណាក្បៀវក្បាខ្ចាំងពូកែបែរជាធ្វើព្រងើយកន្តើយ សូម្បីត្រង់ល្អសុចរិតក៏មានចិត្តគិតស្អប់ ។

៨.- អ្នកនៅរធ្វើសេចក្តីខុសផ្សេងៗ រមែងស្តាប់ពាក្យមនុស្សញុះញង់ ។

៩.- អ្នកនៅរនឹងធ្វើការអ្វី កំយកតែតាមអំពើចិត្តគំនិតរបស់ខ្លួន មិនបានធ្វើការឲ្យឆ្លាប់ខ្លួនតាមទំនៀមទម្លាប់ច្បាប់ពីបុរាណ ។

១០.- អ្នកនៅរមិនចេះមិនដឹងក្នុងកលល្បិចាយនៃក្បួនសឹកសង្គ្រាមមើលតែល្មមនឹងចិត្តមិនគិតថា សត្រូវនឹងបញ្ឆោតឲ្យចាញ់ ទោះបីនឹងឈ្នះវិញក៏មិនដឹងមិនយល់ ។

(មានត)

ត្រូវឲ្យមានបង្គាយច្រើនទើបប្រពៃ

កាលពីបុរាណកាល ព្រះឥន្ទ្រាធិរាជវាយយកបង្គាយមួយបាន ព្រោះធ្វើតាមពាក្យណែនាំព្រះគុរុ (ព្រះព្រហស្បតិ៍). ដូច ព្រោះខ្លាចព្រៃកងព្រះហិរណ្យកសិបុ ដូចនឹងព្រោះការប៉ុនប្រសប់ព្រះវិស្ណុកម្មដូច ។

ព្រោះហេតុនោះ បានជាសក្តទេវរាជប្រទានពរថា: សូមឲ្យព្រះរាជាទាំងឡាយធ្វើបង្គាយច្រើន ដើម្បីឲ្យមានដំយជាជ័យជាប ដ្បិតបុរសធ្វើដូចម្តេចឲ្យមានបង្គាយច្រើនដល់ទៅរាប់ពាន់ម៉ឺន ទើបប្រពៃ ។

ព្រះរាជាអង្គណាមិនមានបង្គាយទេ ព្រះរាជាអង្គនោះទុកដូចជានៅក្នុងអាណាចក្រគេស្រេចហើយ ដ្បិតជាពស់គ្មានចង្កូមឬដ្បិតជាដំរីមិនចុះប្រេង ។

បញ្ចតន្ត្រៈ

រឿងអាវ័ក្យថ្លែងរឿងម្លៃថ្មាំ

ហោកវ៉ាយ-ប៊ុក ក្រមការ

ប្រែពីចាវ៉ាំងមកជាខ្មែរ

(តមក)

រឿងទីដប់ប្រាំបួន

អាវក្យ៍ក្រាបបង្គំទូលថា បពិត្រមហាវាជ ! ព្រះបាទរុបទត្ត (Rûpdatt) *ទ្រង់សោយរាជសម្បត្តិ នៅនគរចិត្រកូត* (Chittrâkut) ។

មានកាលមួយថ្ងៃ ទ្រង់ស្តេចទៅបរបាញ់សត្វ ទ្រង់គង់លើអស្សតរតែមួយព្រះអង្គឯង, ទ្រង់ក៏រំងេ្វងផ្លូវ ស្តេចទៅដល់ព្រៃធំ ។ នៅក្នុងទីនោះទ្រង់ទតឃើញបឹងមួយធំ មានផ្កាឈូកដុះពាសពេញ ។ ពួកសត្វស្មាបជាច្រើនហែលច្រត់ក្នុងបឹង, ហើយនៅជុំវិញបឹងទាំងបួនទិសមានវុក្ខជាតិធំៗ ចោលមូលត្រជាក់ស្រួល ថែមទាំងមានព្រៃពាយបក់រំភើយ ។ ធ្វើឲ្យគន្ធពិជោរបុប្ផាតែអូបឈ្ងុយឈ្ងប់មកជាមួយផង ។ ដោយព្រះអាទិត្យចោលកំដៅខ្លាំងពន់ប្រមាណ ព្រះមហាក្សត្រទ្រង់ទៀបព្រួយព្រះកាយខ្សោយខ្ពុលភាព, ទ្រង់ចាន់ចង់ព្រះពាជនីនាំងពាជ័នធ៌មកឈើ, ហើយទ្រង់យកព្រះកូសាក្រាលលើផែនដី រួចទ្រង់គង់នៅទីនោះ ។ មួយមោ៉ាងក្រោយមក, មានឥន្ទ្រាដែលនៅក្នុងអាស្រមតាបស មានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ ចេញមកបេះបុប្ផា ។

ព្រះមហាក្សត្រែនិងតយល់នាងយ៉ាងណា ខ្ញុំនឹងប្រាប់ពីការដែលខ្ញុំយល់ព្រមតាមនាងនេះ ។ លុះនាងរៀបរាប់រឿងរួចហើយ ព្រះមហាក្សត្រែនិងមានព្រះបន្ទូលថា "តើខ្ញុំនៀមអ្វីក៏ផ្ទែកម្ទេះ? យើងមកកាន់ទីនេះជាក្បៀវហើយ នាងមិនមានការគួរសមអ្វីសោះចំពោះយើង" ។ នាងបានស្តាប់ព្រះបន្ទូលព្រះមហាក្សត្រ, នាងក៏ឈប់នៅទីនោះ ។ ព្រះមហាក្សត្រមានព្រះបន្ទូលតទៅទៀតថា "មានគម្ពីរពោលថា បើបុរសណាចូលមកជាក្បៀវ មកសូមពឹងពាក់អាស្រ័យនឹងគេហដ្ឋានអ្នកដទៃដែលមានវណ្ណៈខ្ពស់ បើទុកជាបុរសនោះមានវណ្ណៈទាប ឬជាខ្ញុំ, មនុស្សដែលគេនិរទេសចេញ ឬជាបច្ចាមិត្រ ឬជាអ្នកបិតុយាជ (សម្លាប់-បិតា) ក៏ត្រូវតែនាងចំពេញការណីយកិច្ចគឺការទទួលរាក់ទាក់នឹងក្បៀវនោះព្រោះក្បៀវជាវត្ថុពិសិដ្ឋ" ។

កាលព្រះមហាក្សត្រែនិងមានព្រះបន្ទូលរួចហើយ, នាងក៏ឈរស្ងៀម ។ ព្រះមហាក្សត្រែនិងបានចោលព្រះនេត្រទៅកាន់ភ្នែកនាង ។ ក្នុងពេលនោះ តាបសមកដល់ ។ ទ្រង់បានទតទៅឃើញតាបស ទ្រង់ក៏សំដែងព្រះរាជគារវភាពចំពោះតាបស ។ បានថ្វាយពរសព្វសាធុការរួចស្រែកថា "ជយោ ព្រះមហាក្សត្រ!" ហើយក្រាបបង្គំទូលសួរអំពីហេតុដែលទ្រង់យាងមកកាន់ទីនេះ ។ ទ្រង់មានព្រះបន្ទូលតបទៅតាបសថា ទ្រង់ស្តេចយាងមកបាញ់សត្វ ។

តាបសទូលថា "កិច្ចការដែលទ្រង់ប្រព្រឹត្តបែបនេះ ជាអកុសលមួយធំ ហើយគម្ពីរសំដែងថា បើបុរសណាប្រព្រឹត្តបាបអកុសល, មានមនុស្សដទៃទៀតជាច្រើននឹងសោយផលអាក្រក់នោះមិនខាន" ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលថា "សូមលោកតាអាណិតអាសូមកយើង សូមលោកតាពន្យល់យើងថាអ្វីល្អ អ្វីអាក្រក់?" ។

តាបសទូលថា "សូមទ្រង់ព្រះមេត្តាច្រើន! បាណាតិបាត ការសម្លាប់សត្វតិរច្ឆាន ដែលរស់នៅក្នុងព្រៃ, បរិភោគស្មៅ, ផឹកទឹកដោយសុខស្រួល នេះជាអកុសលបាបធំណាស់, អ្នកណាដែលការពារសត្វតិរច្ឆាន នឹងបក្សាបក្សីនេះកុំឲ្យវិនាសជីវិត ហៅថា ប្រព្រឹត្តនូវគុណធម៌ដ៏ប្រសើរ ។ មានគម្ពីរពោលថា អ្នកណាមានចិត្តសប្បុរសនឹងពួកខ្ចាច, ខ្លាយកម្ចាំង មុខជាបានទទួលផលល្អមិនខាន; ការគោរពដោយតឹងរឹងពន់ពេក មិនដល់នឹងខន្តី, ការសប្បាយដោយកាយ មិនដល់នឹងការសប្បាយក្នុងចិត្ត, ទ្រព្យសម្បត្តិ មិនដល់មិត្តភាព, សេចក្តីសុខតែយុត្តិធម៌មិនដល់ការសន្តោស ។ អ្នកណាមិនប្រមាទក្នុងការចំពេញការណ៍យកចិត្តរបស់ខ្លួនខាងសាសនាតែងបានភោគទ្រព្យ មានកិត្តិយស, បានវិជ្ជាស្រួល, កិត្តិសព្ទ ល្បីល្បាញនឹងសុទ្ធតែអំណាច, ហើយអ្នកនោះមិនចេះអួតអាងសោះឡើយ ។ អ្នកណាពេញចិត្តនឹងការិយារបស់ខ្លួនពោលតែពាក្យសច្ចៈ អ្នកនោះអាចរួចចាកទុគ្គតិទាំងពួង ព្រមទាំង

សម្រែចដល់ស្ថានដ៏ឧត្តម គឺឯកន្តបវាសីសុទ្ធ ។ តែបើអ្នកណាប្រព្រឹត្ត
យ៉ាតកម្មនូវពួកមនុស្សខោសមានសក់ក្រងជាក្បាកន្ទេល ខ្ចីនទេ
ហើយគ្មានអាវុធ ត្រូវទៅទទួលទុក្ខឯស្ថាននរក, ហើយព្រះមហាក្សត្រ
ដែលមិនបានធ្វើកុសលកម្មដល់អ្នកធ្វើបាបប្រជាពស្ត្រ ក៏ត្រូវស្តេចយាងទៅ
កាន់ទុគ្គតិកំពង់ដែរ ។ អ្នកណាបានឱតទៅដឹតព្រះអគ្គមហេសី ឬមិត្តភ័ក្តិ,
ឬស្ត្រីក្រមុំ ឬស្ត្រីដែលមានកិតិយាស ត្រូវទៅសោយទុក្ខឯនរកដែរ ។
នេះជាភាក្យដែលមានពោលទៅតម្តីរពិសិដ្ឋ" ។

ព្រះមហាក្សត្រ ទ្រង់ព្រះសណ្តាប់នូវពាក្យតាបសហើយ មានព្រះ
បន្ទូលថា: "តាំងពីនោះមកដល់ឥឡូវនេះ យើងបានប្រព្រឹត្តនូវបាប
អកុសលប៉ុណ្ណោះដោយសេចក្តីល្ងង់ខ្លៅហើយ . . តែតាំងពីថ្ងៃនេះតទៅ,
បើព្រះអាទិទេពទ្រង់យល់ឃើញថាគួរ, យើងនឹងលែងប្រព្រឹត្តបាប
អកុសលហើយ" ។

តាបសមានចិត្តសោមនស្សពន់ពេកនឹងព្រះរាជបន្ទូល ទើបទូល
ថា: "ដោយទូលបង្គំមានចិត្តរីករាយពន់ពេក នឹងព្រះរាជឧត្តារៈរបស់
ព្រះអង្គ, សូមព្រះអង្គមានព្រះបន្ទូលមកចុះ, ទូលបង្គំនឹងប្រតិបត្តិតាម
ព្រះរាជឧត្តារៈ" ។

ព្រះមហាក្សត្រទ្រង់មានព្រះរាជឧត្តារៈទៅកាន់តាបសថា "បើលោក-
តាពេញចិត្តនឹងយើងៗសូមកញ្ញាលោកតា យកទៅធ្វើជាអគ្គមហេសី" ។

តាបសបានស្តាប់ នូវព្រះបន្ទូលសូរសីហនាទ ក៏បានធ្វើព្រះភជ-
សមរសខ្ទង់នឹងបុត្រី តាមប្រពៃណីពួកគន្ធវ៌ Gàndharsva) ហើយ
ក៏វិលត្រឡប់ទៅអាស្រមវិញ ។

ព្រះមហាក្សត្រខ្ទង់យាងវិលត្រឡប់ទៅកាន់ព្រះភជធានីវិញ ជា
មួយនឹងនាងកញ្ញាកូនតាបស ។ លុះខ្ទង់យាងបានពាក់កណ្តាលផ្លូវ,
ព្រះសុរិយាអស្តង្គត, ព្រះបន្ទូកំរេឡើង ។ ព្រះមហាក្សត្រខ្ទង់បាន
ឥតរុក្ខជាតិមួយដើម មានស្មឹកត្រសុំសាខា, ខ្ទង់ចុះពីព្រះទីនាំងអស្សតរ
យកអស្សតរទៅចងនឹងគល់ឈើ, រួចខ្ទង់ក្រាលកម្រាលក្រោមដើមឈើ
នោះ ហើយខ្ទង់ផ្ទំជាមួយនឹងនាងកញ្ញា ។

ដល់ពាក់កណ្តាលអធ្រាត្រស្ងាត់ មានព្រាហ្មណ៍រក្ខស: (Rāk Shasa)
(ប្រហែលជាយក្ស) ម្នាក់មកដល់ខ្ទង់ ឲ្យខ្ទង់តើនឡើង ព្រោះវាមាន
បំណងនឹងបរិភោគនាងកញ្ញានេះ ។

ព្រះមហាក្សត្រខ្ទង់មានព្រះបន្ទូលថា: "កុំឲ្យអ្នកធ្វើយ៉ាងដូចនេះ,
បើអ្នកឃ្លានថ្នាបង់បានអ្វី, យើងនឹងដូនអ្នកតាមបំណង" ។

រក្ខ:នោះក្រាបទូលថា: "ទូលបង្គំមិនបរិភោគនូវនាងកញ្ញានេះទេ
បើខ្ទង់ព្រមប្រគល់មកឲ្យទូលបង្គំ នូវក្បាលកូនព្រាហ្មណ៍អាយុ ៧ ឆ្នាំ
ហើយដែលព្រះអង្គពិឃាដដោយព្រះហស្តព្រះអង្គ" ។

ព្រះមហាក្សត្រែងន់មានព្រះបន្ទូលថា: "ចុំាពីរថ្ងៃទៀតគិតតាំងពីថ្ងៃនេះទៅ អ្នកឯងអញ្ជើញមកកាន់ព្រះពជ្ឈានីនេះចុះ, យើងនឹងប្រគល់ខ្លួរក្បាលកូនព្រាហ្មណ៍នោះតាមច្បាប់" ។ ព្រះមហាក្សត្រែងន់ជាន ធ្វើកិច្ចសន្យានឹងរុក្ខស: រួចស្រេច ែងន់ក៏យាងវិលត្រឡប់មកកាន់ព្រះពជនិវេសដ្ឋានវិញ ។ រដ្ឋមន្ត្រីកាលជាន ជ្រាបថាព្រះមហាក្សត្រែងន់ស្តេចយាងមកកាន់ព្រះបរមពជកំងវិញហើយ, ក៏គិតរៀបចំពិធីបុណ្យជាទ ឡាវិតហើយក៏គ្រាច់ទៅគាល់ែងន់ ដោយនាំយកដង្វាយទៅថ្វាយ ។ ព្រះមហាក្សត្រែងន់ជានពណិនាសព្វគ្រប់ច្បាប់រដ្ឋមន្ត្រីថា: "ដល់មួយសប្តាហ៍ទៀត, មានរុក្ខស:មួយមកកាន់ទីនេះ, តើយើងនឹងគិតធ្វើយ៉ាងណា?" ។

រដ្ឋមន្ត្រីក្រាបទូលថា: "សូមែងន់កុំព្រួយព្រះពជហ្ឫទ័យអ្វីឡើយ, ខាងខ្ញុំធានាគង់នឹងធ្វើតាមព្រះពជបំណងពុំខាន" ។

រដ្ឋមន្ត្រីលុះមានប្រសាសន៍យ៉ាងនេះហើយ ក៏បង្គាប់ឲ្យគេធ្វើរូបមាសធ្ងាក់ជាតួង ខ្ពស់មួយមាន (man) ថែម ១ ឬ ២ ទៀត យកមកជាក់លើរនេះមួយ តម្កល់ត្រង់ផ្លូវបែក រួចបានយកខាហានទៅយាមល្បាតទៅទីនោះ ហើយបង្គាប់ថា: "បើមានអ្នកណាមកឧស្សាន៍ខ្លួរូបចំឡាក់នេះ ឲ្យពួកអ្នកជាខាហានសួរថា តើអ្នកអាចយកក្បាលនៃកូនព្រាហ្មណ៍អាយុ ៧ ឆ្នាំមកថ្វាយែងន់ជានទេ? បើជាន ែងន់នឹងព្រះពជាន រូបមាសនេះជាដាច់ខាត" ។ ដល់បង្គាប់រួចស្រេច, រដ្ឋមន្ត្រីក៏ចេញពីទីនោះទៅ ។

កន្លះវាន់ពីរថ្ងៃ. ពួកតាហានបានសួរអ្នកដែលអញ្ជើញមកមើលរូបមាសនោះ គ្មានអ្នកណាមួយត្រូវទទួលតាមកិច្ចសន្យានោះសោះឡើយ ។ លុះមកដល់ថ្ងៃទី ៣ មានព្រាហ្មណ៍ម្នាក់នៅទីក្រុងនោះ មានកូនប្រុសបីនាក់ ។ ព្រាហ្មណ៍នោះបានស្តាប់ឮវាតា ដែលតាហាននោះប្រកាស, ក៏រួលត្រឡប់ទៅកាន់គេហដ្ឋាន ហើយពោលទៅកាន់ភរិយាថា: "បើយើងធ្វើពលិកម្មកូនប្រុសយើងម្នាក់ទៅព្រះមហាក្សត្រ យើងនឹងបានខ្លួនរូបចំឡក់មាសរចនាដាំតួងពេជ្រទម្ងន់ហាសិបសិរ (Sirs: ពាក្យថា សិរ ឬ ម៉ាន ជាទម្ងន់ដែលគេសម្រាប់ប្រើនៅប្រទេសនេះ តែមិនដឹងជា ១ សិរ ឬ ១ ម៉ាន មានប៉ុន្មានគ្រាម) ។

ភរិយាព្រាហ្មណ៍នោះពោលថា: ខ្ញុំមិនចង់ឃើញទៅព្រះរាជាខ្លួនកូនប្រុសតូចរបស់ខ្ញុំទេ" ។

ព្រាហ្មណ៍នោះឆ្លើយថា: "ចំណែកកូនប្រុសបួនខ្ញុំ ក៏ខ្ញុំមិនបានចង់ឃើញដែរ" ។

កូនប្រុសទៅបានប្រាប់ឪពុកម្តាយគ្រប់, ក៏យល់ព្រមឲ្យឪពុកម្តាយកខ្ជនទៅចង់ឃើញស្តេច ។ បិតាពោលថា: "ល្អហើយកូន! មានគោលដៅមួយដ៏ប្រសើរនៃវត្តមាន់អស់កល្បលោក, បើគ្មានគោលដៅឲ្យ តើមានសុភមង្គលពីណា, អ្នកណាដែលគ្រគោលដៅឲ្យ តើតមកកាន់ពិភពលោក អ្នកនោះជាមនុស្សលំបាកយ៉ាងខ្លាំង" ។

ព្រាហ្មណ៍នោះលុះពោលដូចនេះ ក៏យកកូនប្រុសពៅនោះទៅថ្វាយព្រះមហាកស្សប ហើយក៏យកវប្បចំឡាក់មាសមកជាក់កន្លែងគេហដ្ឋានខ្លួន ។ ពួកគាហានក៏នាំកុមារនោះទៅដូនដង្ហមន្ត្រី ។ លុះដល់ ៧ ថ្ងៃក្រោយមក, រក្ខសៈនោះមកដល់ ។ ព្រះមហាកស្សបទ្រង់បានព្រះរាជទានទ្រព្យវិមចន្ទន៍, អង្គរ បុប្ផា, គ្រឿងក្រអូប, ផ្លែឈើ, ម្ហូ, គ្រឿងស្លៀកពាក់, រួចដល់គេនាំក្មេងទៅដល់ចំមុខព្រះភក្ត្រ ទ្រង់ក៏ហូតព្រះឱនថ្វាយរៀបទីធម្មជាយ័ញ្ញ ។

កាលពេលនោះ កូនក្មេងនោះក៏សើចរួចយំ តែព្រះអង្គបានកាប់ទីធម្មព្រះឱនថ្វា, ជាច់ក្បាលក្មេងនោះធ្លាក់ដល់ដី ។

ពាក្យដែលពួកបណ្ឌិតពោលជាពាក្យពិត: "នារីកន្លងពិតពីលោកជាអន្ទាំទុក្ខ, ជាគេហដ្ឋាននៃទោស: តែងបំបាត់នូវបំណាង, ជាហេតុនាំឲ្យកើតតណ្ហា ហើយបំផ្លាញនូវគុណធម៌ ។ តើយើងអាចពោលបានថាបុរសគប់ដែលជាឧសថពុល ជារបស់ល្អឬ?, ។

មានគេពោលថា: "ចូរអ្នកកែក្បាលកោគទ្រព្យសម្រាប់ការពារកន្លែងកាលដែលមានគ្រោះថ្នាក់ ។ សូមអ្នកបូជានូវកោគទ្រព្យនោះដើម្បីទំនើសោចស្រង់នូវកាយ តែបើចង់សោចស្រង់ជីវិតរបស់អ្នកឯង អ្នកត្រូវបូជានូវកាយព្រមទាំងកោគទ្រព្យ" ។

អាវក្សុះនិទានរឿងនេះចប់សព្វគ្រប់, គ្រាបទូលព្រះមហាក្សត្រថា: "សូមទ្រង់ព្រះមេត្តាប្រោស! រៀបនឹងធ្វើមរណកាល កូនក្មេងនោះយំ តើហេតុដូចម្តេចបានជាកូនក្មេងនោះប្រែជាសើចទៅវិញ" ។

ព្រះមហាក្សត្រមានព្រះបន្ទូលទៅវិញថា "កូនក្មេងនោះបានជាសើចទៅវិញ ព្រោះក្មេងនោះគិតឃើញថា មិនគួរជាសភាពផ្ទុយសោះ, ធ្លាប់ឃើញថាមាតាតែងទុបត្ថម្ភកូនរបស់ខ្លួន បិតាតែងស្នេហាប្រមថ្នមកូនបង្កើត, មហាក្សត្រតែងទំនុកបម្រុងប្រជាពលរដ្ឋគ្រប់ពេល, ទុនេះហេតុតែបិតាអាត្មាអញ មានសេចក្តីលាភ បានជាគាត់យកអាត្មាអញមកថ្វាយមហាជន ហើយស្តេចប្រឹងប្រែបនឹងពិឃាដខ្លួនហើយ ឃើញថាគ្មានអ្នកណាមួយអាណិតមេត្តាដល់អាត្មាអញសោះ ក្មេងនោះរាគិតឃើញយ៉ាងនេះ បានជារាសើច" ។

អាវក្សុះបានស្តាប់ព្រះបន្ទូលព្រះមហាក្សត្រ ក៏រលេចឮព្រះនាមព្រះភក្ត្រជាតិសិរីសនោះដូចកាលពីមុន ។ ព្រះមហាក្សត្រទ្រង់យកអាវក្សុះនោះមកវិញ ហើយក៏លើកព្រះអង្គានាំយកទៅ ។

ចប់រឿងទី ១៩ មានរឿងទី ២០ តទៅទៀត

រឿងចិញ្ចៀនទិព្យ

អ្នកស្រីសារីយ៉ាន ប្រែពីបារាំងមកជាខ្មែរ

(តមក)

ព្រះមហាក្សត្រមានព្រះបន្ទូលសួរថា: "តើចិញ្ចៀននេះមានគុណធម៌យ៉ាងណាខ្លះ?" ។

– ព្រះករុណាថ្លៃវិសេស! មាន, កាលណាព្រះអង្គបៀមចិញ្ចៀននេះ ខ្ញុំអាចនឹងបំបាំងព្រះអង្គបាត់, បើកាលណាព្រះអង្គពាក់ចិញ្ចៀននេះជាប់នៅព្រះហស្ត អ្នកផងទាំងពួងពុំអាចនឹងមានចិត្តគំនុំ ឬ បៀតបៀនព្រះអង្គបានឡើយ ។

ព្រះមហាក្សត្រកាលខ្ញុំព្រះសណ្តាប់ហើយ ខ្ញុំមានព្រះហឫទ័យសោមនស្សរៃកៃពេក, ខ្ញុំគ្រាប់ចិញ្ចៀនកងព្រះហស្តយាងចេញអំពីកំណប់ ខ្ញុំតាញ្ជូរបិទមក ហើយខ្ញុំឡើងជណ្តើរមកវិញ លុះដឹតមកដល់តំរប ខ្ញុំបៀមចិញ្ចៀននោះក្នុងព្រះឧស្ន ទើបខ្ញុំយាងឡើងផុតមកលើ ។ ព្រះមហាក្សត្រខ្ញុំទតឃើញព្រះរាជបុត្រាពៅបង្អស់អង្គុយយំនៅដឹតតំរបនោះ ហើយពួកសេនាតាហានចេះតែនាំគ្នាទាំងតាញចេញ ដ្បិតព្រះអង្គម្ចាស់ចេះតែចង់ចុះតាមព្រះបិតា ។ ព្រះ

ម៉ហាក្សត្រយាងចុះទៅកន្លងវង្វេងវិញ ដកចិញ្ចៀនពីក្នុងព្រះឧស្ណហើយស្តេចយាងឡើងមកវិញ ។ ព្រះភរតបុត្រាឃើលុះឃើញព្រះបិតាស្តេចយាងត្រឡប់មកវិញសុះទៅឧបថើបព្រះហស្ត ថើបព្រះបាទាព្រះបិតា គាំងទ្រង់ព្រះកន្សែងបណ្តើរផង ។ ពួកសេនាមាត្យគាំងឡាយដែលនៅត្រៀមចាំទ្រង់ ក៏គំនាប់ទ្រង់ដោយគោរពហើយនាំគ្នាសរសើរ ដោយឃើញព្រះកុណាស្តេចត្រឡប់មកវិញជាសុខសប្បាយ ។ ព្រះភរិជាទ្រង់បង្គាប់ឲ្យលើកគំរបនោះគ្របក្លិតទៅវិញ ។ ពួកសេនាធំមន្ត្រីតូចធំនាំគ្នាទូលសួរព្រះអង្គថា "សូមទ្រង់ព្រះមេត្តាប្រោស! តើទ្រង់បានឃើញអ្វីខ្លះដែលស្តេចយាងទៅនោះ?" ។

- យើងគ្មានឃើញអ្វីទេ គឺជាវង្វេងក្នុងដីមួយយ៉ាងវែងដែលគ្មានទីបំផុត ។ ព្រះមហាក្សត្រក៏នាំសេនាគាហានធំនាំមុខគាំងឡាយត្រឡប់មកព្រះបរមរាជវាំងវិញ ។

នៅវេលាយប់ស្ងាត់ ទ្រង់តើនឡើងហើយយាងចូលទៅក្នុងបន្ទប់មួយ ដល់ហើយក៏ដាក់ចិញ្ចៀននោះទៅលើដំ ។ មែមួនមកបង្ហាញខ្លួនហើយទូលថា: "ព្រះកុណាជាម្ចាស់ជីវិតលើត្បូន! ខ្ញុំលែព្រះបង្គំជាទ្បំមកជាបំរើទ្រង់" ។ ព្រះមហាក្សត្រទ្រង់បង្គាប់ឲ្យគារក្ស្យនោះ ទៅនាំយកសម្បត្តិពីក្នុងកំណប់នោះ មកដាក់ក្នុងបន្ទប់មួយក្នុងព្រះបរមរាជវាំង ដែលទ្រង់បានប្រើឲ្យរៀបចំគុកជាស្រេច ។

អាស្រ័យមែ៉ាមូន ទទួលព្រះតម្រាស់ថា: "សូមក្រាបទូល! ទូលបង្គំ
ទទួលធ្វើតាមព្រះពាជបញ្ជាដូចជាទទួលគោរពព្រះជាម្ចាស់" រួចទៅបាត់
ទៅ ។ ព្រះករុណាស្តេចយាងចូលក្នុងបន្ទំរហូតដល់ព្រឹក លុះទ្រង់
តើនឡើងស្តេចយាងទៅទតបន្ទប់ទេ ទ្រង់ឃើញបន្ទប់នោះពេញដោយ
មាសប្រាក់សម្បត្តិទ្រព្យ ដែលទ្រង់បានឃើញនៅក្នុងរូងកំណប់តាំង
ប៉ុន្មាន ស្តេចទ្រង់សោមនស្សទឹងសម្បត្តិនោះពន់ពេក ។

ក្រោយមក ព្រះអង្គទ្រង់ព្រះឈ្មួនជាទម្ងន់ ហើយជ្រាបថាទ្រង់
ទឹងទៀត្តពុំបានក្នុងកាលដ៏ឆាប់ៗ ហើយ ទ្រង់គ្រាស់ហៅព្រះពាជបុត្រ
ប្អូនតាំងពីរទឹងអ្នកដែលនៅក្រោមអំណាចព្រះអង្គមកជួបជុំ ទ្រង់ចែក
ព្រះពាជសម្បត្តិ ទ្រង់ប្រោសលែងខ្ញុំតម្ពរ ទ្រង់ធ្វើទានហើយទឹងផ្តាំផ្ញើ
ព្រះពាជបុត្រៅបង្អស់ ប៉ុន្តែទ្រង់ពុំប្រទានអ្វីដល់ព្រះពាជកុមារៅ
ឡើយ ។ ព្រះពាជបុត្រប្អូនតាំងពីរមានសេចក្តីរីករាយណាស់ហើយ
នាំគ្នាពោលថា "កុងចំណោមយើង ប្អូនៅយើងទឹងទៅជាក្រជាង
គេ" ។ លុះព្រះអង្គម្ចាស់ អាលី-ត្នេលេប៊ី បានឮដូច្នោះក៏ព្រួយ
ព្រះហឫទ័យពន់ពេក ទ្រង់ចូលទៅកុងបន្ទប់ព្រះវរបិតា ហើយក៏ទូលសួរ
ព្រះពាជាថា: "តើទូលបង្គំជាខ្ញុំពុំមែនជាព្រះពាជបុត្រព្រះបិតាទេឬ?" ។
ព្រះមហាក្សត្រមានព្រះបន្ទូលថា: "ទេឯងជាកូនអញ ហើយជាទីគាប់
ក្នែកអញផង" ។

- ចុះហេតុអ្វីបានជាព្រះបិតាចែកព្រះរាជទ្រព្យដល់បងទាំងពីរហើយ មិនទ្រង់ប្រទានដល់ទូលព្រះបង្គំផង ទ្រង់ទុកឲ្យទូលព្រះបង្គំក្រលំបាកជាងគេឬ? ។

- ទុកូនសំឡាញ់! បិតាទុកកំណប់មួយទាំងមូលដែលមានជម្ងៃលើសលុបទ្រព្យសម្បត្តិផងទាំងពួងឲ្យកូន កូនចង់បានរបស់អ្វីក៏បានដូចបំណង ។

- សូមទ្រង់បង្ហាញទូលព្រះបង្គំផង កុំឲ្យទូលព្រះបង្គំព្រួយខ្វាំងពេក ។

ព្រះមហាក្សត្រទ្រង់នាំព្រះរាជបុត្រចូលទៅក្នុងបន្ទប់មួយ ទ្រង់ហូតចិញ្ចៀនពីម្រាមព្រះហស្តហើយបៀមក្នុងព្រះនុស្ស ។ ព្រះអង្គម្ចាស់អាល័ - ត្តេលេប៊ី ងាកមកមើលព្រះបិតាស្រាប់តែពុំឃើញ ហើយក៏នឹកស្តាយថា "បើដឹងជាដូច្នេះ អញមិននិយាយសោះ" ។ កាលនោះព្រះមហាក្សត្រយកចិញ្ចៀនចេញពីព្រះនុស្ស ព្រះអង្គម្ចាស់អាល័ក៏ទូលសួរទ្រង់ថា: "ព្រះបិតា! អម្បាញ់មិញនេះស្តេចយាងទៅណា?" ។

- អញទៅអង្គុយជាមួយនឹងឯងនេះទេតើ, ការសម្ងាត់របស់ចិញ្ចៀននេះ មានដូចតទៅនេះ: បើកាលណាឯងបៀមក្នុងមាត់ ឯងនឹងបំភ្លាំងខ្លួនបាត់ ។ រួចព្រះអង្គដាក់ចិញ្ចៀននោះទៅនឹងដីហើយម៉ៃមួនដែលជារំរើចិញ្ចៀនក៏និម្មិតឲ្យឃើញខ្លួន ហើយនិយាយថា: "ព្រះករុណាជាម្ចាស់ដ៏រឹតលើស្ងួន! ទូលព្រះបង្គំជាខ្ញុំសូមគ្រាបគ្រាមល្អងធូលីព្រះបាទ

តើខ្ញុំមានការអ្វី?" ។ ព្រះមហាក្សត្រមានព្រះបន្ទូលថា: "អញ
សុំឲ្យឯងនៅបំរើកូនអញនេះ នឹងសុំឲ្យឯងធ្វើជាឪពុកកូនអញជំនួស
អញ" ។ មែ"មូនធ្វើយថា: "ទូលព្រះបង្គំសូមប្រតិបត្តិតាមព្រះពាដ-
ន្ធ្លារ" ។ ព្រះមហាក្សត្រប្រគល់ចិញ្ចៀននោះឲ្យទៅព្រះអគ្គម្ចាស់អាលី-
ត្តេលេប៊ូ ហើយមានព្រះបន្ទូលថា: "ឯងប្រយ័ត្នកុំឲ្យបងឯងចាំងពីរដើង
ឲ្យសោះ បើមិនដូច្នេះទេ វានឹងសម្លាប់កូនឯងពីព្រោះតែចិញ្ចៀននេះ" ។
ព្រះពាដកុមារគ្រោកឈរឡើង ថើបព្រះសិរ ថើបព្រះហស្តព្រះវរបិតា
ព្រមទាំងមានព្រះហ្ឫទ័យរីករាយផង ។ ក្រោយពីនោះ ប្រមាណជា
៤ - ៥ ថ្ងៃព្រះមហាក្សត្រឲ្យដើរព្រះសុវណ្ណគតទៅ ។ ព្រះពាដបុត្រ
ទាំងអស់ក៏បំពេញការណីយកិច្ចចំពោះសពព្រះវរបិតា ហើយក៏នាំគ្នាលើក
ព្រះដង្កាច្បាងឲ្យសោយរាជ្យជំនួសព្រះវរបិតា ។ ពួកនាម៉ឺនសព្វមុខមន្ត្រី
តូចធំចូលគាល់ថ្វាយព្រះពរព្រះអគ្គគ្រប់ៗ ប្រាណ ។ ព្រះករុណាថ្មី
ឲ្យប្រទានសំលៀកបំពាក់ ដែលជាគ្រឿងឥស្សរិយយសដល់ពួក
ភ្នាក់ងារពាដការ ឲ្យចាត់ការជាក់ជាវនឹងតាំងភ្នាក់ងារថ្មី ឲ្យព្រះពាដ-
ទានអំណោយផ្សេងៗនឹងធ្វើទានផង ។ ឲ្យកាន់អំណាចលើកងទ័ព
ក្នុងអាណាខេត្ត នឹងលើបណ្តាក្រសួងរាជចំនុះ ។

មានសម័យថ្ងៃមួយ ព្រះអគ្គឲ្យរៀបផប់លៀងយ៉ាងធំហើយឲ្យហៅ
ព្រះអនុជទាំងពីរអង្គមកផង ។ ព្រះពាដនឹងព្រះអគ្គម្ចាស់ទាំងពីរព្រះអង្គ

កំសោយព្រះស្ងួយ សោយទឹកស្រែងដដែកគ្នាលេងហើយនាំគ្នាសរ-
សើរដល់គុណព្រះជាម្ចាស់ដែលទ្រង់បានប្រោសអនុគ្រោះដល់ទ្រង់ទាំង
៣ ព្រះអង្គ លុះទ្រង់សោយកំសាន្តរួចស្រេចហើយ ព្រះពាជាជាព្រះ
ដេជ្ឋាបង្អស់ ដំរេតព្រះកាយទៅលើខ្នើយមួយហើយមានព្រះបន្ទូលថា
"ពុទ្ធោ !" ។ ព្រះដេជ្ឋាបន្ទាប់ក៏ធ្វើដូចេ្នះទៀត ។ ព្រះអគ្គមហាសេ-
នាបតីអាលី-ត្នេលេប៊ី ក៏ទូលសួរព្រះរាមថា: "តើព្រះរាមបង់មានវិតក្កអំពីរឿងអ្វី
បើព្រះវរបិតាយើងបានចែកទ្រព្យសម្បត្តិជាពីរចំណែក: ព្រះរាមទីមួយ
ទ្រង់បានគ្រងរាជសម្បត្តិ ព្រះរាមបន្ទាប់ទ្រង់កាន់តំណែងជាឧបរាជហើយ
តើទ្រង់ទាំងពីរព្រះអង្គព្រួយព្រះទ័យអំពីរឿងអ្វីទៀត បានជាទ្រង់មាន
ព្រះបន្ទូលថា: ពុទ្ធោ?" ។ ព្រះរាមបច្ឆិមបង្អស់ទ្រង់ឆ្លើយតបព្រះអនុជថា:
"ឧកញ្ញាអើយ! មានស្តេចមួយអង្គកាន់សាសនាគ្រិស្ត ទ្រង់បានជ្រាបថា
ព្រះបិតានៃយើងទ្រង់ព្រះសុវណ្ណគត គេចង់លើកទ័ពមកដណ្តើមយករាជ-
សម្បត្តិហើយយើងមិនអាចនឹងទប់ទ័ពគេបានឡើយ, បង់បានដំណឹងថា
ស្តេចបច្ចាមិត្តបានរៀបចំទ័ពចំនួន ៣ទ្រូបមកហើយ ហេតុនេះហើយបាន
ជាបង់ឱ្យថា ពុទ្ធោ !" ។ គ្រានោះ ព្រះអគ្គមហាសេនាអាលី-ត្នេលេប៊ីឆ្លើយ
ថា: "ការណ៍នេះជាការៈបេសកូលព្រះបង្គំ" ហើយក៏មានព្រះបន្ទូលសួរ
ទៅបង់បន្ទាប់ថា: "ចុះព្រះរាមនេះមានរឿងព្រួយព្រះទ័យអ្វី បានជាមាន
ព្រះបន្ទូលថា ពុទ្ធោ ដែរ?" ។

(មានត)

(ត)

- អើបើឯងចឹង ! វីរ៉ស៊ុនី ជាស្ត្រីមានចិត្តធម៌ទេតើ, ដោយចិត្តធម៌នេះហើយបានជាវីរ៉ស៊ុនី ចង់ឲ្យមានសម្បត្តិទ្រព្យដើម្បីនឹងធ្វើកុសល ។ គឺដោយចិត្តធម៌នេះហើយ បានជានាងចេញពីកោះនេះទៅ, បើដូច្នេះធម៌នឹងត្រឡប់នាំនាងមកវិញពុំខានឡើយ" ។

គំនិតនឹកស្មានថាប្រហែលកន្លងពេលគ្រោយ នាងនឹងត្រឡប់វិលវិញហើយ នាំឲ្យអប៉ូលដើរចាកដកន្លងចិត្ត សេចក្តីព្រួយទាំងប៉ុន្មានស្ងប់រំងាប់អស់ ។ វីរ៉ស៊ុនី ចានជាមិនផ្ញើសំបុត្រមក ព្រោះនាងមកជិតដល់ហើយ ។ បើត្រូវឲ្យសំរួលពីនុប គេមកមិនយូរប៉ុន្មានពេលឡើយ ។ រាល់ពេលកប៉ាល់ដែលបើកតាមផ្លូវហ៊ឹងពីមួយទៅមួយ គិតទៅមិនដល់បីខែឡើយ ។ កប៉ាល់ កាលដែលវីរ៉ស៊ុនីដឹះទៅបើកមិនចានជាងពីរខែផង ។ តទៅវិញ ពួកជាងសុទ្ធតែអ្នកចេះពូតែណាស់ ហើយពួកកម្មករ (មាត់តឿ) ច្រើនតែអ្នកប្រសប់ការ ។ អាប៉ូលនិយាយពីរបៀបរៀបចំបំរុងទុកចាំខ្លួនឯង ពីផ្ទះបំរុងសង់ជាថ្មី ពីសេចក្តីសប្បាយរីករាយ ពីបានប្រទះគ្នា ដែលរាល់ថៃទុកពាល់ថ្ងៃ ដល់ពេលណា វីរ៉ស៊ុនី បានធ្វើជាប្រពន្ធ ។

ចានធ្វើជាប្រពន្ធវា! . . . គំនិតនេះនាំឲ្យវាសប្បាយរកអ្វីប្រៀបគ្មាន ។ អាប៉ូលនិយាយច្រាបខ្ញុំថា: "លោកឪពុក! អ្នកមិនចាំបាច់ធ្វើអ្វីឡើយ ចាំតែសប្បាយចុះ ។ វ៉ីស៊ីនី មានទ្រព្យហើយ យើងនឹងលោះពួកគ្នាមកជាច្រើន ដើម្បីធ្វើការជំនួសយើង ។ អ្នកនៅជាមួយនឹងខ្ញុំ ព្រួយតែពីទទួលទាន នឹងលេងកំសាន្តឲ្យសប្បាយចុះ" ។ វាដូចជាក្មេងខ្លួន ហើយនាំសំដីហ្នឹងទៅនិយាយច្រាបម៉ែវានឹងមនុស្សក្នុងផ្ទះទាំងអស់ ។

យូរបន្តិចទៀត ភ័យនឹងសង្ឃឹមលាយច្រឡំគ្នា ។ ចំណង់ដឹកូវ ហានតែងបញ្ជូនដួងព្រលឹងទៅកាន់ទីបំផុតទាំងសង្ឃឹមខាង តែខ្លាចក្រែងបន្តិច មានសង្ឃឹមបន្តិច ។ ស្មើរតែរាល់ព្រឹក អាប៉ូលតែងមកលេងនឹងខ្ញុំមុនព្រួយស្អែក ។ វាច្រាបខ្ញុំថា: "វ៉ីស៊ីនីមិនឃើញមានផ្ញើសំបុត្រមកសោះ ។ បើនាងបានចេញពីនរុបមកហើយ ម៉េចគង់នាងឲ្យដំណឹងដល់ខ្លួនខ្ញុំឲ្យបានដឹងជាមុនដែរ ។ ដំណឹងពីខាងខ្លួននាងដូចជាពិតណាស់ពេក. ច្រាកដជាម្តាយមីងនាងរៀបចំទុកជាក់ខ្លួននាងទៅលើនាហ្នឹងធំណាមួយរួចហើយ ។ ចំណង់ក្នងធនធានាំឲ្យនាងវិនាសខ្លួន ដូចជាអ្នកដទៃគ្រប់គ្នា ។ តាមក្នងគម្ពីរដែលវ៉ូងយ៉ាងត្រឹមត្រូវពីស្រី ។ ចិត្តធម៌នេះឯងគ្រាន់តែជាប្រធាននៃគម្ពីរឿងប៉ុណ្ណោះ ។ បើ វ៉ីស៊ីនី មានចិត្តធម៌មែនវាមិនត្រូវចេញរោលម្តាយបង្កើតខ្លួន នឹងម្តាយខ្ញុំឡើយ ។ ក្នងនុកាសដែលខ្ញុំរលឹកនាងសឹងស្ទាប់ ដេកពុំលក់ នាងក្មេងខ្ញុំ ។ ខ្ញុំតើតុក្ខ នាង

សប្បាយ ។ ខ្ញុំតែមានគំនិតមួយដូច្នេះកើតឡើង ដូចជារកសង្ឃឹមគ្មានទេ តែតែព្រួយឡើង ។ ឈប់ចង់ធ្វើការអីទាំងអស់ ។ តែកាលណាឃើញមនុស្សក្នុងផ្ទះ ខ្ញុំអផ្សុកចិត្តអីម្ល៉ះទេ ។ សុំឲ្យមានចម្បាំងទៅប្រទេសកូរ៉ុង ខ្ញុំនឹងទៅឲ្យស្លាប់ជាមួយនឹងគេចុះ" ។

ខ្ញុំធ្វើយតបទៅវិញថា: "សេចក្តីក្លាហានចំពោះការស្លាប់កើតឡើងតែមួយស្របក់ទេ រាល់ថ្ងៃនេះកើតឡើងតែដោយការបញ្ជោរឥតប្រយោជន៍នៃមនុស្សទាំងឡាយ ។ មានសេចក្តីក្លាហានមួយក្រពក តែសំខាន់អស់ពីចិត្ត ដែលធ្វើឲ្យយើងអាចចប់ទល់នឹងការសុខទុក្ខរាល់ថ្ងៃ មិនបាច់មានកសិណ មាននរណាសរសើរគឺខន្តីចិត្ត ។ ខន្តីចិត្តនេះតែងឈរធឹងប៉ឹងឡើងមិនមែនដោយការពន្យល់នៃជនដទៃ ឬមួយដោយដំរុលនៃចំណង់ឡើយ គឺដោយចំណង់នៃព្រះជាម្ចាស់ ។ ខន្តីគឺជាសេចក្តីក្លាហានប្រកបដោយធម៌ ។

- អើ!... បើឯងចឹង ខ្ញុំគ្មានចិត្តធម៌ទេ ព្រោះតែអ្វីទាំងអស់ទំលាក់លើខ្ញុំ ហើយខ្ញុំព្រួយចិត្តតែខ្លួនឯង ។

ចិត្តធម៌ គឺជាកាគមួយនៃមនុស្សទេ គឺជាសកាពម្យ៉ាងសម្រាប់ញ៉ាំងចិត្តឲ្យស្ងើ។ ឲ្យទៀង កុំឲ្យប្រែប្រួល ។ នៅកណ្តាលតណ្ហាដែលធ្វើយើងឲ្យញាប់ញ័រ ការយល់បែបយើងសឹងខ្វល់ខ្វក់ ងងឹតឈឹង រកអ្វីពុំឃើញ មានតែចង្កៀងបញ្ចាំងគឺអក្សរសាស្ត្រនេះឯងដែលអាចដុតបំភ្លឺសម្រាប់មើលនេះ មើលនោះបាន ។

"នែកូន! អក្សរសាស្ត្រជាជំនួយពីខាងក្នុងមក ។ គេអាចត្រួតលោកទាំងមូលក៏ដោយអក្សរ មនុស្សដែលចេះរៀបចំខ្លួនឲ្យរស់នៅលើផែនដីបានដោយស្រួល ក៏មកតែពីអក្សរសាស្ត្រ ។ គឺអក្សរនេះឯងហើយដែលសម្រាប់បំភ្លឺ សម្រាប់ធ្វើឲ្យសប្បាយរីករាយ សម្រាប់តំណៅឲ្យស្រួលដូចជាព្រះអាទិត្យ: អក្សរសាស្ត្រគឺភ្លើងទិព្វ ។ អក្សរហ្នឹងដែលញុំាងវត្តទាំងពួងឲ្យជាវត្តគួរជាទីបរិភោគបានដូចជាភ្លើងធម្មតា ។ យើងអាចប្រមូលរបស់ទីកន្លែង ជាតិមនុស្សនឹងកាលទាំងឡាយឲ្យបានមកនៅជុំវិញខ្លួនយើង ក៏មកតែពីអក្សរ ។ គឺអក្សរហ្នឹងទៀតដែលសម្រាប់រំលឹកយើងឲ្យប្រព្រឹត្តត្រង់តាមបន្ទាត់ ។ អក្សរសម្រាប់បង្អួនខ្លួនតណ្ហា សម្រាប់រំលុបរំលាងចិត្តអាក្រក់ចោល សម្រាប់ជាជំនួយដល់ចិត្តធម៌ដោយអាងទាហរណ៍មនុស្សចិត្តល្អជាទីគោរពរបស់អ្នកទាំងពួង ។ អក្សរនេះ ខុតដូចជាស្រីទេពកញ្ញាបុះមកពីស្ថានសួគ៌សម្រាប់ជួយដោះទុក្ខទោសនៃមនុស្សជាតិ ។ អ្នកច្បាជ្ញធំៗ ទាំងឡាយខាងអក្សរសាស្ត្រកើតមានឡើងតែក្នុងកាលដែលមានកលិយុគ ក្នុងកាលដែលមនុស្សចិត្តដូចគ្នាបាន ក្នុងកាលដ៏អាក្រក់ ។ នែកូន! អក្សរបានលុង បានរំងាប់ចិត្តមនុស្សព្រៃមិនអស់ដែលមានសេចក្តីទុក្ខវេទនាលើសអ្នកឯងទៅទៀត ។

ចូរឯងខំអានគម្ពីរ ណាកូន! សប្បុរសទាំងឡាយដែលបានសរសេរគម្ពីរពីដើម គឺជាអ្នកដំណើរដែលត្រាច់តាមមាគ៌ាប្រកបដោយទុក្ខព្រួយ

មុនយើង ហើយហុចដៃហៅយើងកាល់គ្នាឲ្យទៅជាមួយពួកលោក ប៉ែ
កាលណាយើងគ្មានអ្វីជាទីពឹង ។ ដូច្នេះ ប៉ាន់ជាគេទិយមទុកតម្លៃវាល្អជា
កល្យាណមិត្ត ។

– ខ្ញុំមិនចាំបាច់ត្រូវការចេះអានតម្លៃវាប៉ុន្មានទេ អាណិតឲ្យតែវីរ៉ស៊ីនី
នៅទីនេះបានហើយ ។ នាងគ្មានបានរៀនអ្វីជាងខ្ញុំទេ ប៉ុន្តែកាលណា
នាងក្រឡេកមើលចំខ្ញុំ ហើយគាន់តែហៅថា: នែអ្នកបងសំឡាញ់ប្អូន
ប៉ុណ្ណោះ សេចក្តីទុក្ខរបស់ខ្ញុំក៏រលាយបាត់អស់ ។

– មែនពិត គ្មានមិត្តសំឡាញ់ណាមួយប្រពៃជាងប្រពន្ធដែល
ស្រឡាញ់យើង ដោយចិត្តត្រង់ឡើយ ។ ម្យ៉ាងទៀត ក្នុងរូបស្ត្រី តែង
មានធម្មជាតិរីកាយមួយដ៏ទន់ល្អិត ដែលអាចកំចាត់សេចក្តីព្រួយនៃបុរស
បាន ។ លំអដ៏ស្រស់នៃស្ត្រីអាចបន្ទោមគំនិតកាចអាក្រក់បាន ។ វាតែង
មានស្នេហ៍មុខនឹងសេចក្តីទុក្ខចិត្ត ។ សេចក្តីសប្បាយណាដែលធ្វើឲ្យមាន
កម្លាំងជាងសេចក្តីសប្បាយរបស់វា ។ ញញឹមហើយ . នរណាមិនញញឹម
តាម កំហឹងណាដែលអាចទប់ទឹកភ្នែកវាបាន កាលណាវីរ៉ស៊ីនីត្រឡប់
មកវិញ នាងមានធម្មិកងខ្លួន ហើយឯងមិនមានដូចនាងឡើយ ។ នាង
មកដល់ មុខជាឆ្ងល់នឹងសួនច្បារដែលមិនបានរៀបចំឲ្យស្អាត មិនមាន
របៀបព្រោះនាងមានចិត្តចង់តែលំអសួន ទោះបីព្រួយចិត្តដោយសារនៅ
ឆ្ងាយពីសាច់ញាតិនឹងខ្លួនអ្នកក៏ដោយ ។

(មានត)

សកម្មភាពនៃក្រុមជំនុំនៅមធ្យមខ្មែរ

បរិយាយអំពីល្បែងភាសាព្រ័ត្រ

លោក ចាប-ពិន រៀបរៀង

អស់លោកគាំង!

ឥឡូវនេះ ខ្ញុំបានកិត្តិយសមកបរិយាយអំពីសកម្មភាពនៃក្រុមជំនុំនៅមធ្យមខ្មែរ ក្នុងនាមពុទ្ធសាសនបណ្ឌិត្យ ជូនជាសណ្តាប់អស់លោកតទៅ:-

ក្រុមជំនុំបានទទួលឯកសារព្រឹងនៅមធ្យមផ្សេងៗ កាន់តែច្រើនឡើង ហើយច្រើនជាឯកសារមានគោលចារិកនឹងដើមកំណើតល្អផង ដោយបណ្តាវិញ្ញាដនជាតិខ្មែរយើងកាន់តែយល់ឧត្តមគតិ របស់ក្រុមជំនុំនៅមធ្យមខ្មែរកាន់តែច្រើនឡើង ប៉ុនសរសេរឲ្យការណ៍មកជាច្រើនៗ

បណ្តាឯកសារដែលបានទទួលមកនោះ មានឯកសារស្តីពីល្បែងខ្មែរច្រើនមុខ, តែវេលានេះ សូមស្រង់ចំពោះតែឯកសារស្តីពីល្បែងភាសាព្រ័ត្រមួយមុខមកបរិយាយដូចតទៅនេះ :-

ល្បែងភាសាព្រ័ត្រ ជាល្បែងមួយយ៉ាងដែលខ្មែរយើងធ្លាប់លេងតាំងពីព្រេងនាយមក ហើយជាល្បែងដែលកាប់ចូលក្នុងពួកគ័ព្ទហាត់ប្រាណដ៏សំខាន់មួយយ៉ាង គឺជាគ័ព្ទហាត់កាយឲ្យមានសាច់កំណួនដៃ

កំភួនដើងមាំមួន ឲ្យពង្រឹងការពារមូលមានសុខភាព ។ ការហាត់លេង
កីឡានេះ ក៏ចូលក្នុងការហាត់រៀនអត្តពលវិទ្យា ។

កីឡានេះ លេងបានទាំងបុរសទាំងស្ត្រី ។ ខ្មែរយើងតែងលេងនៅ
ក្នុងរដូវចូលឆ្នាំខ្មែរ នាខែចេត្រជាទំនៀម, គេចូលចិត្តលេងនៅទីវត្តអារាម
ក្នុងវេលាដែលគេជួបជុំគ្នាធ្វើបុណ្យចូលឆ្នាំហើយ គេចូលចិត្តលេងពេលថ្ងៃ
ជាងពេលយប់; នៅតាមភូមិស្រុកគេលេងដែរ តែលេងដោយតិច ។

របៀបលេងមានបែបបទ ដូចរៀបរាប់ដូនតៅនេះ :-

- គេជ្រើសរកទីណាមួយជាទីវាលទំនេរស្អាតល្អធំទូលាយ, ហើយ
គេគូសឬលុកដីចំកណ្តាលទី ១ ណ្តូងជាទីសំគាល់ ។

- គេយកពួរផាក់ដូង ឬ ពួរផ្តៅ ១ ធំប៉ុនកដៃកូនក្មេង ឬក៏ព្រ័ត្រស្បែក
បែវែង ២០ ឬ ៣០ ម៉ែត្រ មកលាតសន្ធឹងកណ្តាលទី ហើយគេយក
កន្សែង ឬកំណាត់សំពត់ចងចំពាក់កណ្តាលពួរ សំគាល់ពាក់កណ្តាល
ម្ខាងម្ខាក់ ។

- គេជ្រើសយកមនុស្សប្រុស - ស្រី មានមាឌធំៗ មាំៗ ប៉ុនគ្នា,
ដោយគេចុកកេងស្រីជាកេងទន់ខ្សោយជាងប្រុស គេដាក់ចំនួនខាងប្រុស
៨ នាក់ ខាងស្រី ១០ នាក់, បើខាងប្រុសឡើងចំនួនដល់ ១៨ ខាងស្រី
ត្រូវឡើងចំនួនដល់ ២០ គឺឲ្យខាងស្រីលើសពីរៗ នាក់ ជាជាប, តែការ

ពន្លើសចំនួនខាងស្រែនេះស្រែចន្ទវិស្ស័គ្រែចិត្តទេ, ស្រុកខ្លះចួនកាលស្រី ចូលចិត្តលង្ឃ័កម្ងាំងនឹងប្រុស ។ គេជាក់ចំនួនស្មើគ្នាក៏មាន;

- គេជ្រើសយកមនុស្ស២នាក់ខាងប្រុស ២ នាក់ខាងស្រី ដែលមានស្នាគាំង ។ រួបពងធាត់ធំមានកម្ងាំងច្រើន ជាក់ឲ្យកាន់ដើមព្រ័ត្រម្នាក់ ចុងព្រ័ត្រម្នាក់ គាំង ២ ខាង, មនុស្សស្គម ។ គេឲ្យឈរកាន់កណ្តាលព្រ័ត្រប្រឆាំងគ្នាញយកថ្ងៃដែតៀងខ្លួន;

- គេជ្រើសយកមនុស្សជាមេខាងប្រុសម្នាក់ ខាងស្រីម្នាក់ ឲ្យឈរចំកណ្តាលទី ត្រង់ប្រទល់មុខគ្នា ហើយប្រុសម្នាក់តាំងវែកបន្ទឹ ដែលគេហៅធាតកូមាឡើងថា "យក្សអ៊ែ!" ដោយសំឡេងខ្លាំងវែង ។ រលាក់រលែក ។ ពួកអ្នកកាន់ព្រ័ត្រទាំងអ្នកឈរមើលគាំងប៉ុន្មាន ដួយវែកខ្លួលត្រមគ្នាឡើងថា "ហោរ៉ឹ" ៣ដង, ពេលធាតកូមា ៣ដង មានមនុស្សម្នាក់ទះសម្ពោរពេ ៣ បទតាមចង្វាក់សម្រែកយក្សអ៊ែ, លុះគ្រប់ ៣ ដង ទាំងបទហើយទើបអ្នកកាន់ព្រ័ត្រទំពាញតៀងខ្លួន ។

លុះអ្នកពាញព្រ័ត្រកំពុងពាញរយឺតៗ, អ្នកទះសម្ពោរក៏បញ្ចើតសម្ពោរឡើងភ្លាមរួ "តាក់ទីង" ដកបដល់មានឈ្នះម្ងាំ ទើបឈប់បញ្ចើត ។

ការឈ្នះចាញ់ សំគាល់ត្រង់ពួកម្ងាំងអូសពួកម្ងាំងឲ្យផុតកន្លែងពួរអំពីគំនូសដែលគេចាន់ត្រឹតខុកត្រង់កណ្តាលទី ។

ចប់លើកទី ១ ហើយបើគេចង់លេងលើកទី ២ ឬទី ៣ ... ទៀត (ស្រែចម្ការសន្ធតគ្នា) គេរៀបមានរបៀបដូចមុន ។ ក្នុង១លើក។ មានចំរុះវេលាពី ៦ ម៉ាពីម៉ោ ១០ នាទី នាឡិកា អាចដឹងថាញ់ ឈ្នះបាន ។

កីឡាខាញ្រ័ត្រមានរបៀបលេងថ្មែកគ្នាបន្តិចបន្តួចដោយស្រុក គឺស្រុកខ្លះមានស្រែកធាកកូមា យក្សអ័បទ្ធី ទឹងទះសម្ភោរបញ្ឆើតម៉ោពេលលេង ស្រុកខ្លះមិនមាន តែរបៀបក្រៅពីនេះ ដូចគ្នាគ្រប់ស្រុក ។

លោកគ្រូ ឯក - ញឹម បៅអធិការវត្តធម្មិសព្រះភម នៃយធរអនុគណស្រុកសូទ្រនិគម ខែត្រសៀមរាប បានឲ្យការណ៍មកថា ទៅស្រុកសូទ្រនិគម ខែត្រសៀមរាប របៀបលេងកីឡាខាញ្រ័ត្រមានស្រែកធាកកូមាយក្សអ័បទ្ធី ទឹងមានទះសម្ភោរបញ្ឆើតយ៉ាងខ្លាំកអធិកអធំគួរជាទីកំសាន្តសប្បាយក្រៃពេក ។

លោកម៉ៅ ម៉ី យោក្សត្រ នៅក្រសួងមហាផ្ទៃ បានឲ្យការណ៍រឿងកីឡាខាញ្រ័ត្រមានរបៀបលេងដូចគ្នានឹងលោកគ្រូ ឯក - ញឹម ដែរថ្មែក, តែលោកយោក្សត្រនេះ បានបញ្ជាក់ដើមកំណើតនៃល្បែងខាញ្រ័ត្រថា លោកបានឮពីសំណាក់ព្រះតេជព្រះគុណព្រះសពព្រះមហាវិមលធម្ម ថោង អតីតចាងហ្វាងសាលាបាលីជាន់ខ្ពស់ កាលគង់ព្រះជន្មនៅឡើយ លោកនិទានថា ល្បែងខាញ្រ័ត្រមានដើមកំណើតកើតដំបូងមកអំពីពួកយក្សនឹងពួកទេវតាបៃណាំងកម្ចាំងគ្នា មានក្នុងរឿងរាមាយណៈ (រាមកេរ្តិ៍) ថា:

មានកាលមួយថ្ងៃពួកយក្សច្រៀងណែនទឹងពួកទេវតាថា ពួកនេះគ្មានរឹទ្ធិ
ខ្លាំងពូកែជាងពួកយើងជាយក្សប៉ុន្មានទេ, ប៉ុន្តែបានជាពួកនេះមានឋានៈ
ខ្ពស់ជាងយើងដោយសារតែព្រះឥស្សរទ្រង់ច្រោសច្បាណ, បើល្បងកម្លាំងគ្នាមុខជាពួកនេះចាញ់ពួកយើងពុំខាន ។ ពួកទេវតាបានឮក៏អៀនខ្មាស នាំគ្នាទៅនិយាយអួតជាក់យក្សវិញថា "យើងមិនខ្លាចទេមានត្រឹមយក្ស. បើប្រសិនជាបង់ប្រកួតកម្លាំងគ្នាយើងក៏ហ៊ានដែរ រៀវលែងតែប្រើយុទ្ធតំណី" ។ ពួកយក្សទឹងពួកទេវតា ក៏ព្រមព្រៀងគ្នាយកពិធីភាញព្រ័ត្រគាស់ល្បងកម្លាំងគ្នា ថាបើពួកយក្សភាញឈ្នះពួកទេវតា, ពួកយក្សត្រូវបានឋានៈខ្ពស់ជាង ទោះបីចូលទៅកាន់ទីគាល់ព្រះឥស្សរក្តី ទៅកាន់ទីប្រជុំដទៃក្តី ត្រូវពួកយក្សបានទីអគ្គុយខ្ពស់ជាងទេវតាជាដរាប ។ កាលព្រមព្រៀងគ្នាកំណត់រៀលា ថា ទឹងភាញព្រ័ត្រកន្លងថ្ងៃស្អែកហើយ, ពួកទេវតាក៏នាំគ្នាជើរស្រែចុះស្រែឡើងជាពួក ។ ទៅមុខព្រះឈានព្រះឥស្សរ ។ ពេលនោះគាប់ជួនជាស្តេចពាលីន់បានទ្រង់ជ្រាបទ្រង់គ្រាស់ច្រាប់ទុកយថា "ឲ្យកនាគធ្វើព្រ័ត្រ ឲ្យពួកទេវតាភាញខាងក្បាលនាគ, ឲ្យពួកយក្សភាញខាងកន្ទុយនាគ, ដល់ពេលកំពុងភាញឲ្យទេវតា ១ អង្គយកម្រាមដៃចុចត្រង់ផ្ចិតនាគ។ ទឹងរសើប ហើយវាទឹងវាត់កន្ទុយឲ្យរបូតពីដៃយក្ស ស្ទុះទៅខាងទីទេវតា ។ មុខជាឈ្នះយក្សជាពុំខាន" ។ ដល់ពេលភាញព្រ័ត្រពួកទេវតាសុំភាញខាងក្បាលនាគ, ពួកយក្សក៏យល់ព្រម លុះភាញទៅ ពួកទេវតាក៏បានឈ្នះពួកយក្សមែន ។

អាស្រ័យហេតុនេះ បានជាទៅប្រទេសខ្មែរយើងមានទំនៀមលេងល្បែងតាញព្រ័ត្រតាមរឿងនេះតាំងពីព្រេងនាយមករហូតដល់សព្វថ្ងៃ ។

លោក មៅ-មុី បានឲ្យការណ៍បញ្ជាក់ថែមទៀតថា លោកបានឃើញចម្លាក់នៅជញ្ជាំងប្រាសាទនគរវត្តជារូបនាគ ១ រែងសន្ធៃ ខាងក្បាលនាគសុទ្ធតែពួកទេវតា ខាងកន្ទុយនាគសុទ្ធតែពួកយក្សទាញប្រជែងគ្នា ដូចរបៀបទាញព្រ័ត្រយើងសព្វថ្ងៃនេះសុទ្ធសាធប្លែកតែសព្វថ្ងៃយើងយកពួរធ្វើពីជក់ដូង ឬពីផ្លៅឬ យកព្រ័ត្រស្បែកជាព្រ័ត្រទៅវិញប៉ុណ្ណោះ ។

*
* *

ល្បែងតាញព្រ័ត្រ ជាកីឡាសំដែងឥទ្ធិពលនៃកម្លាំងកាយនឹងកម្លាំងប្រាជ្ញា គឺអ្នកលេងកីឡានេះដែលនឹងមានជ័យជំនះទៅបាន អាស្រ័យដោយកម្លាំងកាយដែលត្រមត្រៀងផង, កម្លាំងល្បិចដែលកីឡានោះប្រាប់ដល់អ្នកលេងផង; ដូចទេវតាជាអ្នកខ្សោយទេ តែដោយសារស្គាប់ល្បិចអំពីស្តេចពាលីន៍ បានបបួលយក្សយកនាគធ្វើព្រ័ត្រ បានតាញខាងក្បាលនាគ បានចាក់ផ្ដិតនាគឲ្យរសើប ទើបនាគជួយកម្លាំងទេវតា ។ កំណ្ចុះយក្សទៅបាន ។

និទានេះ បានថាឧត្តមគតិមួយយ៉ាង គឺជាការអ្វីៗ ទោះបីជាផ្លូវធម៌ក្តី ផ្លូវលោកក្តី ត្រូវអាស្រ័យដោយកម្លាំងកាយ នឹងកម្លាំងចំណេះវិជ្ជា

រវាងពួកអ្នកប្រតិបត្តិការ ទើបអាចសម្រេចសារប្រយោជន៍ដ៏ធំធេងឡើយ ។

បរិយាយមកក្នុងអត្ថបទស្តីពីភីឡាខ្មែរ ចំពោះភីឡាតាញ ព័ត៌មានខ្លះយើងធ្លាប់លេងជាទំនៀមមក ចប់ដោយសង្ខេបត្រឹមប៉ុណ្ណេះ ។

ថ្ងៃខាងមុខ ខ្ញុំនឹងមកបរិយាយពីរឿងទំនៀមទម្លាប់ខ្មែរមានប្រការផ្សេងៗ ទៀត សូមអស់លោកប្រុងចាំអានចាំស្តាប់តទៅ ។

ដំណាមរបៀង:

ភីឡាខ្មែរ តូរកែពិត ឫទ្ធិក្លាហាន
នាំឲ្យបាន កាយសុខសាន្ត ចិត្តហានក្លា
មិនខាបខន់ ឬអាប់អន់ ជាងភីឡា
ខាងបច្ចុមា គឺអ៊ីរ៉ុប ប៉ុន្មានឡើយ ។
ហេតុនេះមិញ គួរស្រឡាញ់ ពួកភីឡា
ជាតិខេមរ - របស់យើង កុំកន្តើយ
កុំលះបង់ ភីឡាខ្មែរ ដែលល្អឡើយ
តែចាស់ហើយ ភីឡាយើង ទំនងសាបសូន្យ !

ប. ព.

លោកផែង-វិន ក្រសួងបឋមសិក្សាខេត្តសៀមរាប រៀបរៀង

តាមទំនៀមទំលាប់របស់ខ្មែរ ដែលក្នុងពេលកើតបុត្រិយសរបស់គ្រួសារខ្មែរ និយមបញ្ជូនតែកូនប្រុសឲ្យទៅរៀននៅសាលាពុទ្ធសាសនា ម្ល៉ោះហើយការសិក្សាច្រើនស្រឡះតែចំពោះបុរស ។ ចំណែកខាងស្ត្រីវិញ មាតាបិតាខ្មែរយើងតែងតែទុកនៅផ្ទះ ដើម្បីបង្រៀនបង្ហាត់ឲ្យចេះតែគាន់តែធ្វើការងារសម្រាប់គ្រួសារប៉ុណ្ណោះ ។ គេសង្កេតឃើញជាច្រើនឆ្នាំមកហើយថា មានតែសិស្សានុសិស្សប្រុសៗទេ ដែលមាតាបិតាហ៊ានបញ្ជូនឲ្យទៅបន្តវិជ្ជានៅវិទ្យាល័យឯកជនបាន ។

នៅខេត្តសៀមរាប ខ្ញុំឃើញឧបាសកម្នាក់ឈ្មោះលោកអាំង-ហួន ដែលជាអ្នកចាប់អានព្រះពុទ្ធសាសនាមុតមាំ ហើយយល់នូវប្រយោជន៍នៃវិជ្ជាប្បាស្ថាសាស់ ក្រឡេកឃើញអនាគតដ៏វែងឆ្ងាយ ហ៊ានប្រថុយកាច់ទំនៀមទំលាប់ឃុំគ្រងកូនស្រី ដែលទុកតែកូនប្រុសក្នុងគ្រួសារនេះចេញបណ្តាយជាដំបូងគេបង្អស់ឲ្យកូនស្រីខ្លួនឈ្មោះនាង អាំង-រឹម ចេញពីខេត្ត ទៅបន្តវិជ្ជានៅវិទ្យាល័យក្នុងភ្នំពេញ ឥតគិតនឹកនាដល់សេចក្តីជំទាស់នឹងទំនៀមទំលាប់នេះ នឹងសេចក្តីនិន្ទារបស់ញាតិមិត្តសោះឡើយ ។

ឯនាងអាង - រឹម ជាកូនស្រីនៃទាសកនេះ មានចរិយាសម្បត្តិ សុភាពរាបសា ទឹងមានធន្ទះស្រឡាញ់ចំណេះវិជ្ជាយ៉ាងមុតមាំ បានចំរើន នៅវិទ្យាល័យស៊ីសុវត្ថិ រហូតដល់រៀនវិជ្ជាពេទ្យបឋមជាប់ជាមន្ត្រីសុខាភិបាល ។

ធន្ទះនេះជាកំព្តីយសម្លឹងចំពោះខែត្រសៀមរាប ដោយនារីនេះមានហានៈជាមន្ត្រីសុខាភិបាលជាបឋមនៅកម្ពុជវដ្ឋ ។ នារីនេះ មិនមែនគ្រាន់តែទុកគំរូសេចក្តីអង់អាចតស៊ូខាងចំណេះវិជ្ជានោះទេ នាងនេះទុកគំរូ ១ បែបទៀត ខាងផ្លូវចិត្ត ដែលគួរតែលើកយកមកតំណាលទុកជាឧទ្ទាហរណ៍ សំរាប់យុវជនកុងកាលបច្ចុប្បន្ននេះ ។

នៅថ្ងៃទី ៦ ខែវិច្ឆិកា ១៩៥៦ កន្លងមកនេះ នៅផ្សារខែត្រសៀមរាប លោកអាង - ហួនបានរៀបមង្គលការនាងអាង - រឹម ជាកូនស្រីនេះជាគូនឹងលោក ឡាំ - លិន, ពិធីមង្គលការនោះដំណើរការដោយលោកនិយមយកពុទ្ធនុវាទ ជាមង្គលដែលខែត្រសៀមរាបតែងតាប់អាន ។ លោកបានវេរត្រចីរនឹងចង្ហាន់ដល់ព្រះសង្ឃ ។

កុងពិធីមង្គលការនោះលោកបាននិមន្តធម្មកថិកមកសំដែងធម៌ទេសនាដើម្បីជាសំគាល់គូស្វាមីភរិយាទាំងពីរនាក់ ។ គូស្វាមីភរិយាទាំងពីរនាក់នេះបានបូជាអំណោយ គឺចំណងដៃ ១៧.០០០វ, ដល់មាតាបិតា គឺចំនួន ១ ម៉ឺនរៀល ដើម្បីឲ្យមាតាបិតាយកទៅសង់ភោងរៀនកុងខែត្រ, ៤.០០០វ,០០

ជួយទាំងសាលាអនុវត្តន៍វិជ្ជាគ្រូព្រះសង្ឃទៅវត្តដំណាក់, ១.០០០វ,០០
ជួយសាលារៀនវត្តធម្មិស្សរភាម (រលួស), ១.០០០វ,០០ ទាំងសាលា
រៀនវត្តអម្ពិល (ពួក), រួមជា ១៧.០០០វ,០០ ព្រោះមាតាបិតាពេញចិត្ត
កងការសង់ពេងរៀននេះណាស់ ។ កងអវសានៃពិធីមង្គលការ មាតា-
បិតានឹងគូស្វាមីភរិយា ចានសូត្រសុន្ទរកថាដែលអ្នកស្តាប់ចាប់អារម្មណ៍
ពន់ពេក ។ គូស្វាមីភរិយាថ្មីនេះ សុទ្ធតែជាមន្ត្រីសុខាភិបាលទាំង
២ នាក់ ដែលទើបនឹងចេញពីសាលាវិទ្យាពេទ្យ ឆ្នាំថ្មីនេះ ។

សុន្ទរកថាម្ចាស់បិតា

សូមគោរពចំពោះព្រះតេជព្រះគុណទៅហ្ន៎ាយខ្ញុំ!
សូមគោរពចំពោះលោកមន្ត្រីគ្រប់តំណែងទាំងញាតិមិត្តជិតឆ្ងាយ!
សូមទានជ្រាប សូមជ្រាប ។

ខ្ញុំចាទនាងខ្ញុំ មានមនោសញ្ចេតនាវីរភាពយ៉ាងលើសលែងនឹងសូមអរគុណ
ដ៏ជ្រៅឆ្ងាយ ដោយហេតុចានព្រះតេជព្រះគុណនឹងអស់លោក - អ្នកមាន
ចិត្តពប់អានចានអញ្ជើញមកជាកិត្តិយសនឹងជាសិរីសួស្តី កងមង្គលការ
បុណ្យនេះ ។ ប្រសិនណាបើខ្ញុំចាទនាងខ្ញុំ ចានធ្វើបដិសណ្ឋារកិច្ចជូនទៅ
ហើយ មិនចានបរិបូណ៌គ្រប់គ្រាន់ដោយមានខ្វះវត្ថុណាមួយដែលអ្នកស្រុក
គេជ្រាប់និយមពប់អាន សូមព្រះតេជព្រះគុណនឹងក្រុមញាតិទាំងឆ្ងាយ
អភ័យទោសដល់ខ្ញុំចាទ ដែលជាបុគ្គលមានវ័យចាស់ទី ៤ ទៅហើយ ។

លោកអ្នកគ្រូជ្ជាន់ដើម លោកបានពោលទុកមកថា វ័យទី ១ ត្រូវស្វែងរកវិជ្ជា, វ័យទី ២ ត្រូវស្វែងរកទ្រព្យសម្បត្តិ, វ័យទី ៣ ត្រូវស្វែងរកកល្យាណមិត្ត គឺមិត្តល្អ, វ័យទី ៤ ត្រូវស្វែងរកធម៌ បានសេចក្តីថា ខ្ញែងអំពើល្អ ដែលសន្សំធ្វើទុកមកកុំឲ្យបាត់បង់ទៅបាន ។ ខ្ញុំបានគិតឃើញថា . ខ្លួនខ្ញុំបានមានឧបនិស្ស័យតិចនោះដំបូន្មានលោកអ្នកគ្រូជ្ជាអនេកបរិយាយ បានជាមិនឲ្យផលគ្រប់គ្រាន់ដូចអ្នកដទៃ ដូចជាឈើទាំងឡាយ ដែលមិនសម្បូណាផ្លែផ្កាគឺមកពីរុះដីជាតិប្អូវតែជាគុណាមួយ បានជាមិនបានឲ្យផ្លែផ្កាដល់កំរិតឲ្យគ្រប់គ្រាន់ ។

ទីបំផុតនេះ ខ្ញុំបានានាខ្ញុំ សូមថ្វាយព្រះពរជកុសលទាំង ៣ ផ្នែក ទី ១ គឺធម្មទេសនា, ទី ២ បានរៀបត្រៃចីវរ ៥ ត្រៃ, ទី ៣ ប្រគេនកត្តជល់ព្រះសង្ឃ ទាំងអស់នេះបំពោះដល់ទេពនិកវដែលរក្សាលោកទាំងមូលនឹងថ្វាយដល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នឹងជូនដល់មន្ត្រីក្នាក់ងារគ្រប់តំណែង ព្រមទាំងញាតិមិត្តជិតឆ្ងាយដែលអញ្ជើញមកជួយ ដោយកម្លាំងកាយវាចា ចិត្ត នឹងទ្រព្យធន សូមកុសលទាំង ៣ ផ្នែកនេះ ជួយឧបត្ថម្ភ ខំនុកបំរុងដល់ព្រះតេជព្រះគុណ នឹងលោក - អ្នកទាំងឡាយសម្រេចដូចបំណងកុំបីឃ្លាតឡើយ ។

សួស្តីអាវហាមង្គល !

សុន្ទរកថាបុត្រធីតា

ខ្ញុំបាទនាងខ្ញុំ ជាគូស្វាមីភរិយា បានទទួលនូវអំណោយដ៏គាប់ចិត្ត គឺចំណងដៃដែលអស់លោកបានបង្ហាញតាមប្រពៃណីនៃអ្នកស្រុក ដើម្បីជាដើមទ្រព្យកេទទួលទាន ដោយសេចក្តីអំណរដ៏ក្រៃលែង ។ តែប៉ុន្តែ ខ្ញុំបាទនាងខ្ញុំ សូមលើកយកអំណោយទាំងអម្បាលម៉ាននេះបូជាគុណដល់បុព្វការជន គឺមាតាបិតាបង្កើតរូបយើងខ្ញុំ ទើបមាតាបិតាបន្ទាប់ គឺសាលារៀនដែលបានបង្កើតចំណេះវិជ្ជាដល់យើងខ្ញុំផង ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ ។

ឧត្តមទានទាំងអស់នេះ គឺមាតាបិតានៃយើងខ្ញុំ លោកបានទទួលដោយរីករាយទើបបុរងយកទៅចំណាយ កសាងសាលារៀនកងវែងត្រដោយសេចក្តីជ្រះថ្លា ទុកជាពន្ធីទេមជាតិតទៅ ។

ហេតុនេះ សូមព្រះតេជព្រះគុណ ទើបអស់លោក · អ្នកទាំងឡាយ ព្រមទាំងញាតិមិត្តទាំងអស់គ្នា ដែលបានអញ្ជើញមកកងបុណ្យអាវាហ-មង្គលនេះ ហើយដែលបានរំលែកធនធានឲ្យទានចំពោះខ្ញុំបាទនាងខ្ញុំទាំងប៉ុន្មាន សូមអញ្ជើញទទួលយកនូវកុសលដ៏វិសេសនេះ តាមសេចក្តីជ្រះថ្លារបស់លោកអ្នកទើបញាតិមិត្ត ដោយសុវត្ថិភាព ។

សួស្តី លោក - អ្នកគ្រប់គ្នា !

លោកដុកទ័រគុណបលៈបិយៈសេនៈម៉ាលាសេកេរៈ

ជាប្រធានពុទ្ធិកសមាគមពិភពលោក ថ្លែងក្នុងសមាជសាកលលើកទី ២

នៃពុទ្ធសាសនានៅក្រុងតូក្យូ (ប្រទេសជប៉ុន)

(តូក្យូ ២៥ កញ្ញា; ១៣ តុលា ១៩៥២)

(តមក)

ចំពោះការណ៍យកិច្ចដ៏សំខាន់របស់យើង ដោយផ្សាយនៅក្នុងពិភពលោក នូវសេចក្តីប្រែនៃអត្ថបទដែលសម្រាប់និស្សិត ព្រមទាំងវណ្ណនាចំពោះព្រះពុទ្ធសាសនាគ្រប់លទ្ធិតែងសារសំខាន់ៗ ទើបយើងអាចឃើញដោយរួបរួមនូវចិន្តាពុទ្ធសាសនា ព្រមទាំងផលប្រយោជន៍ក្នុងការពីសោធន៍ជាឯកភាព, ចំពោះការច្បាស្រយ័នឹងទស្សនវិជ្ជាសាកល ។

មហាវិទ្យាល័យពុទ្ធសាសនាកណ្តាលមួយ

ក្នុងរឿងនេះ ខ្ញុំចង់បញ្ជាក់អំពីសេចក្តីស្នើមួយក្នុងការស្ថាបនានូវមហាវិទ្យាល័យ ពុទ្ធសាសនាកណ្តាល ដែលពួកវិញ្ញជននៃប្រទេសជាច្រើនបានអញ្ជើញទៅជួបជុំ ហើយធ្វើសហការនៃកិច្ចការ ខាងចុះតុម្ពផ្សាយ ព្រមទាំងសេចក្តីប្រែនៃអត្ថបទផ្សេងៗ ។ ការស្នើយោបល់នេះបាន

ទទួលដោយសេចក្តីពាក់ពាក់ត្រចង់ដ៏បន់ ហើយសន្និសិទបូព៌ាប្រទេស
នៅទីក្រុងលុកន្ទូ ដែលមានលោកសាស្ត្រាចារ្យនិលកន្ធស្ត្រីជាប្រធាន
បានដួយទុបត្តម្ភជាយ៉ាងមាំមួនផង ។ គេអាចយល់បានថាប្រទេស
សីឡង់ប្រហែលជាដោយហេតុប្រពៃណី ជាយូរណាស់មកហើយ
ត្រមាំងអាកាសជាតុសុខស្រួលជាទីកន្លែងគួរសន្និដ្ឋានទុក ដើម្បីនឹង
ស្ថាបនាទូរមហាវិទ្យាល័យនេះ ។ ខ្ញុំដឹងថារដ្ឋាភិបាលនឹងប្រជាពលរដ្ឋ
ទូរលើភ្លាមទូរបយល់ថា សេចក្តីស្នើនេះត្រូវទទួលដោយសមានចិត្ត ។

មានវិធានការដែលត្រូវធ្វើនៅប្រទេសភូមានឹងសីឡង់ ដើម្បីនឹង
ចោះពុម្ពផ្សាយទូរអត្ថបទនេះ តែត្រូវជ្រើសរើសទូរគម្ពីរស្ទឹកតែឲ្យបាន
ហ្មត់ចត់ ។ នៅប្រទេសភូមាកិច្ចការទាំងនេះ ត្រូវធ្វើនៅក្រោមបង្គាប់
បញ្ជានៃរដ្ឋាភិបាល ដែលបានបំពេញយុត្តិការ (ព្យាយាមម៉ឺងម៉ាត់)
គួរឲ្យសរសើរពន់ពេក ដើម្បីនឹងរចនាព្រះពុទ្ធសាសនា ទៅកាន់សេចក្តី
ចំរើន, តែអ្នកប្រតិភូភូមានឹងពណ៌នារឿងនេះជាវិគ្គារៈពិស្តារ ក្នុងពេល
ខាងមុខនេះ ។ នៅប្រទេសសីឡង់កិច្ចការទាំងនេះដែលគ្រិះស្ថានសាសនា
ហៅថា វិទ្យាលង្ការបរិវេណ បានធ្វើដោយក្លាហានត្រមាំងវិសារ-
ការ ឥឡូវមានលឿនទៅតាមលំដាប់ យើងអាចសង្កេតទៅទៀតជា
វិគ្គារៈពិស្តារ ចំពោះសេចក្តីថ្លៃងការណ៍នៃគណៈប្រតិភូប្រទេសសីឡង់ ។
ក្រៅពីនេះមានកិច្ចការដូចគ្នាដែលធ្វើនៅប្រទេសកម្ពុជាក្រោមអធិបតីភាព

នៃសាលាចាស់ជាន់ខ្ពស់នៅប្រទេសថៃឡង់ ខាងមកុដមហាវជិរាវុធ-លំយ ។ អ្នកប្រតិកូលនៃប្រទេសទាំងនេះ ទទឹងជំរាបសួរមាដកុងកាលឥឡូវនេះ ទូរជំណឹងជាវិត្តារពិស្តារ ចំពោះសេចក្តីព្រាងនោះ ។

ក្រៅពីសៀវភៅដែលពណ៌នា ពីអក្សរសាស្ត្រពិសិដ្ឋដែលចោះពុម្ពផ្សាយហើយឬនៅឡើយ, នៅមានអត្ថបទជាច្រើន ទទឹងសេចក្តីប្រែរបស់ប្រទេសជាច្រើនក្នុងពិភពលោកដែលទទឹងចោះពុម្ពតទៅអនាគត ។ ការដែលចោះពុម្ពសៀវភៅផ្សាយនេះ ត្រូវតែលើកទឹកចិត្តព្រមទាំងសរសើរអ្នកនិពន្ធដែលជាប្រផ្នែលដ៏ល្អមួយ ដោយហេតុជាសៀវភៅដែលតែងជាភាសាជាច្រើន អាចមានចំនួនទ្វេឡើងតាមលំដាប់ ។ សូមសរសើរកិត្តិគុណ ចំពោះអ្នកដែលមានគំនិតត្រួសត្រាយមុនគេ ។

ចំណែកខាងសៀវភៅប្រែជាភាសាអង្គ្លេស មិនទាន់មាននៅឡើយទេ ហើយគួរឲ្យស្តាយពន់ពេក ។ តែបើតាមដែលខ្ញុំដឹង, មានសេចក្តីប្រែធម្មបទជាភាសាស្វាហិលីតំពូងតែង ។ ត្រូវមានសេចក្តីស្នើដូចគ្នាពីមុនព្រមទាំងសេចក្តីស្នើខាងហិរញ្ញវត្ថុ ចំពោះការចំណាយសោះក៏ឃើញប្រាថ្នាចោះពុម្ពសៀវភៅទុកជាកិច្ចល្អ ។ រឯចំណង់របស់យើង ត្រូវតែលែលកឲ្យបានប្រែជាភាសាគ្រប់ជាតិក្នុងពិភពលោក ទូរសៀវភៅទាំងអស់ ឬអត្ថបទដែលសរសើរ ឬស្រង់ពីគម្ពីរពិសិដ្ឋព្រមទាំងសៀវភៅដើមនៃព្រះពុទ្ធសាសនា ដែលមានពុទ្ធសាសនិកជន អ្នកមានសមត្ថភាពតែង ។

ឯមាលិបទខាងព្រះពុទ្ធសាសនាមានប្រយោជន៍ដ៏សំខាន់ក្នុងការយោសនាផ្សាយនូវព្រះធម៌ ហើយខ្ញុំមានអំណរជាយ៉ាងក្រៃលែងដោយខ្ញុំឃើញមាលិបទព្រះពុទ្ធសាសនាជាច្រើនបានចោះពុម្ពផ្សាយពីមុន ។ តែខ្ញុំសង្ឃឹមថាមាលិបទឯទៀតមុខជានឹងបានចោះពុម្ពទៅអនាគតមិនខាន ។

រោងពុម្ពសម្រាប់ចោះសៀវភៅព្រះពុទ្ធសាសនា

តាំងពីមហាសង្គ្រាមសកលលោក, តម្លៃចោះពុម្ពសៀវភៅក្នុងទ្វេឡើងជានិច្ច ។ សៀវភៅតូចក៏ឡើងថ្លៃជាច្រើន ហើយមិនអាចទិញដោយងាយ ពិតមែនតែតម្លៃនោះជាផលប្រយោជន៍អ្នកចោះសៀវភៅ, ដើម្បីនឹងដោះស្រាយនូវបញ្ហានេះ គួរតែចោះពុម្ពគ្រប់ប្រទេសផ្សាយនូវសៀវភៅព្រះពុទ្ធសាសនា ឲ្យមានជាច្រើនតម្កល់ទុកក្នុងបណ្ណាល័យជាសាធារណៈ ។ ការនេះងាយនឹងធ្វើចំពោះសហការនៃអង្គការផ្សេងៗដូចជាអង្គការសេហ្ស៊ែជាដើម អប់រំការសិក្សាវិទ្យាសាស្ត្រនឹងវប្បធម៌តែត្រូវមានប្រាក់ច្រើន ទើបធ្វើការនោះសម្រេច ។ មធ្យោបាយមួយយ៉ាងទៀត គឺត្រូវលើកឲ្យតម្លៃចោះពុម្ពនឹងតែងសៀវភៅឲ្យមានសភាពចុះចាបបំផុត តែបើតាមយោបល់ខ្ញុំថាមិនត្រូវចោះពុម្ពសៀវភៅដែលពិនិត្យទៅឃើញថាមានតម្លៃថោក ជាសៀវភៅមិនសូវល្អមិនមានប្រយោជន៍ទេ ដោយមានភ័ក្តដូចនេះ ប្រាជ្ញអ្នកកាន់កាប់ពុទ្ធិកសមាគមពិភពលោក មជ្ឈមណ្ឌលកូមិកាពសីឡង់រដ្ឋបានផ្តើមបង្កើតនៅពេល

ពុម្ពមួយហៅថា: The Buddist publisherstds ដែលជាមូលដ្ឋាននៃ
ការស្ថាបនាទៅអនាគត នូវភេនពុម្ពចោរសៀវភៅព្រះពុទ្ធសាសនារាល់
ជាតិ ។ ភេនពុម្ពនេះគេអាចមានសង្ឃឹមតទៅអនាគត បើសិនណា
ជាមានអ្នកគាន់កាប់ម៉ាំមួន ហើយបើភេនពុម្ពនេះមានគេជួយឧបត្ថម្ភ
ដោយអំណោយល្មមគ្រប់គ្រាន់ ។ ភេនពុម្ពនេះអាចចោះពុម្ពសៀវ-
ភៅសម្រាប់កូនសិស្សគាន់ព្រះពុទ្ធសាសនា នៃប្រទេសចាំងឡាយ
រៀន មានរូបគំនូរជាច្រើន, ព្រមចាំងសៀវភៅពុទ្ធសាសនាសិល្ប:
ដែលយើងត្រូវការ ។ ព្រោះមិនត្រូវភ្លេចថា ការអប់រំក្មេងកើងឲ្យ
មើលគំនូរក្នុងសៀវភៅ ជាសភាពមានសារ:សំខាន់ក្នុងសម័យបច្ចុប្បន្ន
ដែលគេទទួលស្គាល់គ្រប់ៗគ្នា ពួកពុទ្ធសាសនិកជនដាំងនូវរបៀបនេះ
តាំងពីច្រើនសតវត្សមកហើយ ដែលជាហេតុនាំឲ្យកើតវិចិត្រសិល្ប:
ព្រមចាំងក្បាច់សិល្ប: ដែលមានសភាពល្អផុត ។ គឺជាការស្ថាបនានូវ
លំអជាអនន្តកាល ហើយមានសារ:សំខាន់គ្មានអ្វីស្មើបាន ។ វិចិត្រ
សិល្ប:នឹងក្បាច់សិល្ប: មានសិទ្ធិត្រង់អប់រំការសិក្សាសីលធម៌, ប្រជា
ស្ថិតនៅដូចដែល គ្មានប្រែប្រួល ។

(មានត)

ភ្នំពេញសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៥ ខែសីហា លេខ ៨

ព.ស. ២៤៩៦ – គ.ស. ១៩៥៣



ភ្នំពេជ្រសាសនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— លោកធម៌	ព្រះឧបាលីវង្ស ម៉ឹង - សែស ...	៥៦៣
— កថិនកថា (តមក)	ព្រះមហាឧត្តមវិជ្ជា កែ - អឿន ...	៥៧២
— មនុស្សខ្ពង់ខ្ពស់នឹងថោកទាប	លោក ប៊ូ ប៉ូ	៥៧៧
ផ្នែកអក្សរសាស្ត្រ		
— អំពីដើមកំណើតសកវាដ	លោក ប៊ូ — ប៊ូ	៥៨៦
— ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម ...	៥៨៥
— រឿងសាមកុក (តមក)	ឧកញ៉ា ឆ្វ - កន	៥៨៨
— រឿងអាវ៉ក្សថ្លែងរឿងម្តែប្រាំ (តមក) ...	លោក ភ័យ - ប៊ុក	៦០៤
— រឿងចិញ្ចៀនទិព្យ (តមក)	អ្នកស្រីសារីយ៉ាន់	៦១០
— រឿងប៉ូលនឹងវីរ៉ស៊ីនី (តមក)	លោក ផេង - ជ្រឿ	៦១៤
— សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ (បរិយាយពីដើមកំណើតមហោស្រពៈ) ..	លោក ចាប - ពិន	៦១៩
កំណត់ទឹកប្រវត្តិការណ៍		
— សុត្តរកថាបណ្ឌិតម៉ាល៉ាឡាសេកេរៈថ្លែងក្នុងសមាជសាកលលើកទី ២ នៃពុទ្ធសាសនា	(តមក) ពុទ្ធសាសនបណ្ឌិត្យ ...	៦៣១
— ពិធីស្រោចទឹកព្រះសង្ឃ ៣ អង្គ	ព្រះអាចារ្យ ឈុយ — វិន	៦៣៥

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៨២.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE		Pages
— Lokadharma	Brah Upâlivongs MENG-SES..	563
— Kathinakatha (suite)..... ...	Brah Maha KER-ŒUNE	572
— La destinée des hommes	M. BOU-PO	577

PARTIE LITTERAIRE		
— De l'origine des Sakaraja . .	M. BOU PO	586
— Education morale (suite) . .	Brah Maha PEUNG-PAM . . .	595
— Histoire de SAMŒOK (suite)..	Oknha NOU-KAN	599
— Les vingt cinq récits du Mauvais Génie (suite)	M. RAY-BUC	604
— La bague magique (suite)....	Mme SARIS- YANN.....	610
— Paul et Virginie (suite)	M. PHÉNG-CHRIEU	614
— Activité de la Commission des Mœurs et Coutumes (Origine des théâtres)	M. CHAP-PIN	619

NOTES ET CHRONIQUES		
— Discours du Dr. MALALASEKERA au 2e Congrès Mondial Bouddhique (suite)	INSTITUT BOUDDHIQUE . . .	631
— Cérémonie d'investiture . . .	Brah Achar CHHUY-VON . .	635

Prix d'abonnement annuel comprenant 12 numéros : 192800

លោកធម៌

ព្រះឧបាលិវង្ស ម៉ឹង-សែស វត្តមហាមន្ត្រី ភ្នំពេញ

ទេសនាដាក់វិទ្យុប្រទេសកម្ពុជា · កាលពីថ្ងៃ ១៥ រោច ខែផល្គុន ឆ្នាំជូតសំរឹទ្ធិស័ក
ព.ស. ២៤៩១ (២៨-៣-៤៩)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ដង)

"សូមនមស្ការចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ត្រេកទាំងព្រះធម៌ទ្រង់ព្រះអរិយសង្ឃដោយសេចក្តីគោរព)" ។

អាត្មាភាពសូមសំដែងធម៌ផ្សាយទៅតាមវិស្យកម្មដា តាមសមគួរដល់វេលា ។

សូមសំដែងអំពីលោកធម៌តាមទំនងដែលមានក្នុងលោកធម្មសូត្រគម្ពីរអង្គុត្តរនិកាយ អដ្ឋកនិបាត ព្រះសុត្តន្តបិដក ។ លោកធម្មៈ ប្រែថា "ធម៌របស់លោក" ។ លោក- សព្ទក្នុងពាក្យនេះ ប្រែថា "សត្វ" ដែលគេធ្លាប់និយាយថា "សត្វលោក" ។ លោកធម៌តែងវិលទៅតាមឬជាប់តាមលោក ចំណែកលោកក៏វិលទៅតាមឬជាប់តាមលោកធម៌ដែរ; សត្វលោកចៀសមិនផុតរត់មិនរួចអំពីលោកធម៌ឡើយ, លោកធម៌តែងកើតមានដល់ពួកសត្វទាំងអស់ សូម្បីតែព្រះពុទ្ធជាម្ចាស់ក៏នៅមានលោកធម៌មកប៉ះត្រូវព្រះអង្គដែរ, តែព្រះអង្គមិនកកើកញាប់ញ័រដោយលោកធម៌នោះឡើយ ។

លោកធម៌នោះមាន ៨ ប្រការ គឺ

១ — លោភៈ: ការបានន្ទូវត្ថុមានចីវរមាសជ្រាក់ជាដើម,

២ — អលោភៈ: ការមិនបានន្ទូវត្ថុមានចីវរមាសជ្រាក់ជាដើម

៣ — យសៈ: យសសក្តិ បរិវារសម្បត្តិអំណាចឥស្សរភាព,

៤ — អយសៈ: គ្មានយសសក្តិគ្មានបរិវារសម្បត្តិ គ្មានអំណាចគ្មានឥស្សរភាព,

៥ — ជិគ្ឆា ពាក្យតិះដៀលបន្តុះបង្អាប់,

៦ — បសំសា ពាក្យសរសើរលើកបញ្ជារ ដំកុំដំកើង,

៧ — សុខៈ: សេចក្តីសុខកាយសប្បាយចិត្ត,

៨ — ទុក្ខៈ: សេចក្តីទុក្ខកាយលំបាកចិត្ត,

រួមជា ៨ ប្រការ ។

បណ្តាលោកធម៌ទាំង៨នោះ លោកធម៌ ៤ ប្រការ គឺលាភ ១ យស ១ សេចក្តីសរសើរ ១ សេចក្តីសុខ ១ ទាំង ៤ នេះតែងនាំឲ្យកើតសេចក្តីសោមនស្សសេចក្តីត្រេកអរកើតឡើង ក្លើតក្លើនជាធម្មតា បណ្តាលឲ្យកើតសេចក្តីស្រើបស្រាំង ភ្លើតមាន ឆ្លើងឆ្លៃ ព្រហើនមើលងាយគេពាល់គ្នាថាមិនស្មើនឹងខ្លួនក៏មាន; បណ្តាលឲ្យកើតអាកប្បកិរិយា ដេកដើរឈរអង្គុយមិនសមរម្យដល់កែកអកតាំងពួងក៏មាន ។ បុគ្គលជាសប្បុរសពុំគួរបណ្តែត

បណ្តាយចិត្តឲ្យកន្ត្រេកញាប់ញ័រគឺត្រេកអរហួសហេតុ ដោយលោភយស សេចក្តីសរសើរ ទីដ៏សេចក្តីសុខនេះឡើយ; គួរលែលះកប្រែចិត្តឲ្យសមល្មមទើបល្អ ។

លោកធម៌ ៤ ប្រការទៀត គឺ អលាភ.១ អយស: ១ និន្ទា ១ សេចក្តីទុក្ខ ១ តែងនាំឲ្យកើតមានសេចក្តីខឹងអាក់អន់ចិត្តតូចចិត្តឈឺចិត្ត សុតិសុបជ្រប់ស្រពោនក្រៀមក្រៃសង្ស័យ នាំឲ្យគេស្គាល់ថាជាមនុស្សមិនសប្បាយចិត្ត ។ សាធុជនមិនគួរបណ្តែតបណ្តោយចិត្តឲ្យទន្ទឹតរំភើបរញ្ជួយគឺតូចចិត្តហួសហេតុ ដោយលោកធម៌ទាំង ៤ នេះឡើយ គួរទប់ទល់ចិត្តឲ្យទីដ៏ខ្ជួនល្អទើបគួរ ។

ចិត្តរបស់បុគ្គលណាដែលលោកធម៌ទាំង ៨ នេះពាល់ត្រូវហើយគ្រប សង្កត់ហើយ តែងកន្ត្រើកញាប់ញ័ររំភើប គឺត្រេកអរខ្លាំងនឹងខឹងខ្លាំង, ចិត្តរបស់បុគ្គលនោះមិនមែនជាមគ្គលឡើយ, បើចិត្តមិនកន្ត្រើកមិនញាប់ញ័រមិនរំភើបដោយលោកធម៌ទាំង ៨ នេះទេ ទើបជាមគ្គលដ៏ខ្ពង់ខ្ពស់ ។ ឯព្រះខីណាស្រពតទាំងឡាយ លោកមិនកន្ត្រើកដោយលោកធម៌នោះឡើយ ។

ន័យមួយទៀត លោកជាសត្វ:ដែលគេត្រូវប្រាថ្នាគ្រប់គ្នាក្នុងលោក លើកលែងតែព្រះខីណាស្រពទីដ៏ព្រះនាគាមិបុគ្គលចេញ; តែលោកនោះបើប្រកបដោយធម៌ កំជាការគាប់ប្រសើរក្នុងលោក, បើមិនប្រកប

ដោយធម៌ទេ ជនជាសប្បុរសមិនគួរថ្កោលទោសឡើយ ។ លោកនោះបើកើត ឡើងដល់បណ្ឌិត ច្រើនមានប្រយោជន៍ដួលដល់ជនច្រើនគ្នា, បើកើត ឡើងដល់បុគ្គលពាលមិនសូវមានប្រយោជន៍ប៉ុន្មានទេ ដ្បិនកាលក៏ក្លាយ ទៅជាថ្នាំពិសបំពុលបុគ្គលពាលនោះឲ្យស្លាប់វិនាសវិញក៏មាន ។

អលាភៈ ជាសភាវៈដែលគេមិនត្រូវថ្កោលទោសក្នុងលោកនេះ តែគង់ មានបុគ្គលខ្លះត្រូវការដែរ ដូចយោគីបុគ្គលខ្លះដែលមានសេចក្តីខ្សឹយ ណាយអាក្រក់សង្ស័យទុក្ខ លះបង់លាភសក្ការៈ លះបង់ពួកគណៈចេញ ទៅនៅតែម្នាក់ឯង ធ្វើសមណធម៌ដោយមានបំណងយកឈ្នះបាបកុសល អកុសល និងលោកុត្តរកុសល ។

យសៈ ជាសភាវៈដែលគេត្រូវថ្កោលទោសដោយច្រើនក្នុងលោកនេះ ប្រហែលគ្នានឹងលាភដែរ ។

អយសៈ ជាសភាវៈដែលគេមិនត្រូវថ្កោលទោសដោយច្រើនក្នុងលោក នេះ ប្រហែលគ្នានឹងអលាភៈដែរ ។

និន្ទា ពាក្យតិះដៀលតែងកើតមានដល់ព្រះអាទិត្យ ព្រះចន្ទ ដី ទឹក ភ្លើង ខ្យល់ជាដើម ។ ចំណែកសរីរាណកវត្ថុ សូម្បីតែព្រះពុទ្ធគង់មានដែរ, សមដូចបាលីពុទ្ធភាសិតថា ជគ្គិ លោកេ អតិជ្ជិតោ "ក្នុងលោកនេះគ្មានអ្នកណាមួយដែលគេមិននិន្ទានោះទេ" តែពាក្យនិន្ទារបស់បុគ្គលពាលកំឡៅយកជាការមិនកើត យកជាប្រមាណមិនបាន, បុគ្គល

ពាលជួនកាលនិន្ទាទៅលើបុគ្គលដែលគួរសរសើរ ជួនកាលសរសើរបុគ្គលដែលគួរទទឹងនិន្ទាទៅវិញ, បើបណ្ដិតប្រកបដោយអំពើសុចរិត ទទឹងបញ្ញាជ្រាលជ្រៅ ប្រសិនបើពោលភាក្យនិន្ទាមនុស្សណា ទើបយកជាការបាន យកជាប្រមាណកើត ។

ឧបមា ភាក្យសរសើរមានដំណើរសេចក្ដីផុយគ្នាទទឹងភាក្យនិន្ទានោះ ។ សេចក្ដីសរសើរនេះមានកម្ទាំងអាចប្រាន់មនុស្សខ្ទះឲ្យដួលជេកផ្កាប់ផ្សារទៅលើគំនរក្ដៅដ៏ធំ ទៅលើចំរូងបន្ទា ទៅលើទោសទុក្ខគុកច្រវក់ ជួនកាលក៏ត្រូវទោសអស់ ១ ជីវិតក៏មាន ជួនកាលក៏ដល់នូវសេចក្ដីស្លាប់នាសក៏មាន ។ អ្នកមានប្រាជ្ញាមិនគួរជោរជន់ដោយសេចក្ដីសរសើរពេកឡើយ ។

សេចក្ដីសុខដ៏លោកនេះមានតិចតួចស្ដួចស្ដើង ជាងសេចក្ដីទុក្ខៗមានច្រើនជាងសេចក្ដីសុខហួសប្រមាណ, មនុស្សពាលឆ្លាយតែងស្វះស្វែងរកសេចក្ដីសុខគ្រប់គ្នា ប៉ុន្តែនៅតែមិនសូវបានសេចក្ដីសុខទៀត ។

បើនិយាយដោយសង្ខេបថា សេចក្ដីសុខរបស់គ្រហស្ថមាន ៤ យ៉ាង គឺសុខកើតអំពីមានទ្រព្យសម្បត្តិ ១ សុខកើតអំពីចាយទ្រព្យបរិភោគ ១ សុខកើតអំពីគ្មានចំពាក់ចំណុលគេ ១ សុខកើតអំពីប្រកបការងារដែលឥតទោស ១, សេចក្ដីសុខជាងក្រៅពីនេះក៏មាន តែមិនចាប់យកមកសំដែងឲ្យវែងឆ្ងាយពេកទេ ។

ក្នុងមនុស្សលោកនេះ សេចក្តីសុខមានហើយទើបកើតសេចក្តីចំរើនជាខាងក្រោយ ដូចជាអរុណមានមុនទើបព្រះអាទិត្យមានក្រោយ, ចើយើងចង់បានសេចក្តីចំរើនក្នុងដែនតំាងមូល ត្រូវកសេចក្តីសុខជាមុន ។

ប្រៀបដូចជាត្រកូល ១ ចិញ្ចឹមក្របីមួយហ្វូង, ប៉ុណ្ណងអ្នកម្ចាស់ក្របីនោះចង់ឲ្យហ្វូងក្របីនោះចំរើនលូតលាស់កើតកូនកើតចៅច្រើនឡើង នឹងមានប្រយោជន៍ដល់ខ្លួនដោយសារក្របីតំាងនោះ ទើបអ្នកម្ចាស់ក្របីសួរបណ្ឌិតបុរសម្នាក់ថា: បពិត្របុរសជាបណ្ឌិត.! ខ្ញុំមានក្របី ១ ហ្វូង ខ្ញុំចង់ឲ្យក្របីនោះចំរើនកើតកូនកើតចៅកាន់តែច្រើនឡើង តើធ្វើទុយ ដូចម្តេច? សូមអ្នកប្រាប់ទុយខ្ញុំផង ។

បណ្ឌិតបុរសនិយាយប្រាប់ទុយថា: បើអ្នកត្រូវការចង់ឲ្យហ្វូងក្របីរបស់អ្នកចំរើន ត្រូវអ្នករកសេចក្តីសុខឲ្យដល់ហ្វូងក្របីនោះជាមុន ត្រូវអ្នកស្គាល់ហេតុដែលនាំឲ្យក្របីវិនាសមាន ៤ យ៉ាង គឺ ១ – គ្មានស្មៅគ្មានទឹកឲ្យវាស៊ីផឹក, ២ – មានជម្ងឺដំកាត់ចុះក្នុងហ្វូងក្របី, ៣ – មានចោរលួចបន្ទំយកទៅ. ៤ – ក្របីតំាងនោះបៀតបៀនគ្នា ជេញគ្នារត់ជាន់ទៅវាត់គ្នាស្លាប់វិនាសទៅ ។ ហេតុតំាង ៤ នេះហៅថា: គ្មានសេចក្តីសុខ ត្រូវអ្នកដេញក្របីតំាងនោះទៅកាន់ទីមានទឹកដែលស្មៅវែង ឲ្យវាផឹកវាដេកវាស៊ីតាមចំនើងចិត្តវា, ត្រូវអ្នករកពេទ្យហ្មាំសង្គ្រប់ចាំថែរក្សាការពារកុំឲ្យកើតមានក្នុងហ្វូងក្របីនោះ, ត្រូវប្រុងប្រយ័ត្នកុំឲ្យចោរលួចបន្ទំ

យកគ្រប់បាន, ត្រូវអ្នកប្រុងប្រយ័ត្នកុំឲ្យគ្រប់ប៉ះបៀតបៀនគ្នាដេញគ្នាវាត់ចាត់ទៅ ប្តូរឆ្គាស្លាប់វិនាសទៅ រៀលាយប់ដេញគ្រប់ចូលគ្រោលមើលគ្រប់ណាដែលឈ្នះគេហើយកាចផង ត្រូវយកពួរទាក់ក់ចងឲ្យជាប់កុំឲ្យប៉ះបៀតបៀនគ្នា, អ្នកធ្វើយ៉ាងនេះឈ្មោះថាធ្វើសេចក្តីសុខដល់ហ្វូងគ្រប់ បើបានសុខហើយសេចក្តីចំរើនមុខជានឹងមានពុំខានឡើយ ។

អ្នកម្ចាស់គ្រប់បានស្តាប់ពាក្យបណ្ឌិតបុរសពន្យល់ហើយ ក៏ធ្វើតាមដោយសព្វគ្រប់ ក៏បានសេចក្តីចំរើនដោយលំដាប់ឥតមានវិនាសឡើយ ។

សាធុកៅ បពិត្រសប្បុរសទាំងឡាយ! ជាតិមនុស្សក្នុងលោកនេះដែលបានសេចក្តីចំរើន មកអំពីបានសេចក្តីសុខជាមុន ទើបបានសេចក្តីចំរើនជាខាងក្រោយ ដូចហ្វូងគ្រប់នោះឯង ។

ក្នុងមនុស្សលោកនេះ មានសេចក្តីទុក្ខច្រើនប្រការពេកណាស់ គួរតែអាធុញគ្រាន់ទឹងទុក្ខ. ការស្វែងរកអាហារចិញ្ចឹមជីវិតដោយធ្លៅស្រែចំការក៏មិនងាយនឹងបរិភោគឆ្អែត, ដូនកាលមានភ្លៀងតិចពេកក៏ធ្វើមិនបាន មានភ្លៀងច្រើនពេកក៏ធ្វើមិនកើតដែរ; អ្នកដែលរកចិញ្ចឹមជីវិតដោយស៊ីឈ្នួលគេក៏មិនងាយនឹងគ្រប់គ្រាន់ ។ អ្នកជំនួញជួញប្រែដូនកាលក៏ខាតដូនកាលក៏ចំណេញ, រួមទាំងអស់ទៅហៅថាអាហារបរិយេដ្ឋទុក្ខគឺលំបាកកើតអំពីស្វែងរកអាហារ ។

ជម្ងឺដាក់គ្រប់ជំពូក មានកញ្ជ្រោលអុតស្វាយអុតធំ ពេគពិសអាសន្នពេគជាដើមជាសេចក្តីទុក្ខ ១ ដែរ ។

ចោរកំណាចវុកពានចោកច្រាស់ បំបាត់ប្រវ័ញ្ចន៍លួចឆក់ដណ្តើម គ្រាមប្លន់រាយការប់ចាក់សម្លាប់យកទ្រព្យសម្បត្តិជុតគាំងផ្ទះផងក៏មាន នេះជាសេចក្តីទុក្ខភ័យ ១ យ៉ាងធ្ងន់ក្នុងមនុស្សលោក ។

វិញ្ញ ការខាស់ខែងគ្នា ឈ្លោះប្រកែកគ្នា ប្រណាំងប្រជែងដណ្តើមយកឈ្នះតែរៀងខ្លួនមិនព្រមចុះចាញ់នរណា រហូតដល់ទៅប្រហារគ្នាដោយគ្រឿងប្រហារមានដំបងជាដើមក៏ជាសេចក្តីទុក្ខ ១ ដែរ ។

សេចក្តីទុក្ខដូចបានរៀបរាប់មកមានដូច្នេះជាដើមនេះ មានអារម្មណ៍ ៥ ជាហេតុ ឬបណ្តាលមកអំពីអារម្មណ៍ ៥ ដែលហៅថាបញ្ចពិធកាមគុណគឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដែលជាទីប្ថាថ្នា ជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់សត្វ, ពួកសត្វតែងស្រើរវង្វេងងុលងប់ជ្រុលជ្រប់ផ្តេកផ្តួលចិត្តទៅក្នុងអារម្មណ៍ ៥ នោះខ្លាំងពេកណាស់ បើពួកសត្វរាប់អានប្រើប្ថាស់អារម្មណ៍ ៥ នោះខ្លាំងណាស់ទៅ សេចក្តីទុក្ខក៏ខ្លាំងណាស់ដែរ បើពួកសត្វចន្ទយការរាប់អានប្រើប្ថាស់អារម្មណ៍ ៥ នោះឲ្យថយតិចចុះមក សេចក្តីទុក្ខក៏ថយតិចចុះមកដែរ ។

ម្យ៉ាងទៀត ពួកសត្វដែលជាប់ជំពាក់សល់រាល់ដោយកងទុក្ខ ឬផុតអំពីទុក្ខក៏ព្រោះចិត្តតែម្យ៉ាងជាហេតុ; ចិត្តណាដែលតាមគុណាទាំង ៥ មានអំណាចនាំទៅបាន តាញមកបាន ចាប់បង្ខិលបាន, ចិត្តនោះឯងជាហេតុឲ្យជាប់នៅក្នុងកងទុក្ខ; ចិត្តណាដែលតាមគុណាទាំង ៥ នាំទៅមិន

ចាន ៣ញ្ជាមកមិនរួច ចាប់បង្ខិលមិនចានទេ ចិត្តនោះឯងជាហេតុឲ្យ
ផុតអំពីទុក្ខ ។

លោកអ្នកច្បាជ្រាលមកដោយសេចក្តីសង្វេចបំប្រួញឲ្យខ្លី ហើយឲ្យ
ចានសេចក្តីដែលថ្លាយថា: ទុក្ខំ ភេរ្ភូមិកំវដ្ដិ តណ្ហា សមុទយោ ភវេ
"វដ្ដៈមានភូមិ៣ ហៅថាទុក្ខសច្ច តណ្ហាហៅថា សមុទយសច្ច" ។ វដ្ដៈ
បែបថា ធម្មជាតជាទីប្រព្រឹត្តទៅ ឬវិលទៅនៃកម្មនឹងកម្មវិបាក ។ ភូមិ
៣នោះ គឺកាមាវចរភូមិ ១ រូបាវចរភូមិ ១ អរូបាវចរភូមិ ១ ។ តណ្ហា
ជាហេតុឲ្យកើតកងទុក្ខ ហៅថាសមុទយ, តណ្ហាក៏គឺលោភ ១ ជាមូល
នៃបាបអកុសលទាំងឡាយ ។ តែងឲ្យផលជាទុក្ខ ។

អាត្មាភាពសំដែងលោកធម៌ទាំង ៨ ប្រការមកនេះ ក៏សូមបញ្ចប់
ទេសនាត្រឹមតែប៉ុណ្ណេះ ។

សូមថ្វាយព្រះពរជ័យសួស្តី ចំពោះព្រះករុណាជាអម្ចាស់ដីវិតព្រះចៅ
ក្រុងកម្ពុជាធិបតី ព្រមទាំងព្រះពរជ័យគុណធម៌! សូមជួនកុសលដល់
អស់លោក-អ្នកពាក់ព័ន្ធគ្រប់ដំណែងក្នុងកម្ពុជរដ្ឋ និងពួកសប្បុរសដែល
បានស្តាប់ធម៌នេះគ្រប់ខ្នែងដែលមានវិញ្ញូជនទាំង សូមឲ្យបានសម្រេច
ឥដ្ឋមនុញ្ញផលដូចប្រាថ្នាកុំបីឃ្លាតឡើយ!

ឯវំ សង្វេបេន សម្ពុទ្ធ ធម៌ទេសនាក៏ចប់ដោយសង្វេបតែប៉ុណ្ណេះ ។

រចៀបទេសនាបុច្ឆា - វិសជ្ជនា
ព្រះមហាឧត្តមវិជ្ជា កែ - អឿន (វីរិយប្បញ្ញោ)
វត្តព្រះព្រហ្មវគន៍ ខែត្រសៀមរាប រៀបរៀង
ព្រះទេពសត្ថា សូរ - ហាយ ពិនិត្យកែសម្រួល

(តមក)

– កន្តេ មហាថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! តាមគម្ពីរវិនយាលង្ការដីកា បង្គាប់ថា ញត្តិទុតិយកម្មវាចាយ ទាតព្វំ "ត្រូវសង្ឃប្រគល់ឲ្យដោយញត្តិទុតិយកម្មវាចា" ។ ឯញត្តិទុតិយកម្មវាចា ជាវាចាប្រគល់សំពត់កឋិនតាមពុទ្ធានុញ្ញាតកង៍គម្ពីរមហាវគ្គ ដែលកិកុសង្ឃតែងសូត្រឮរៀងរាល់ពេលកឋិនទានមានឯង សូមទានជ្រាប ។

១៦– ម្នាលអនុត្តរៈ! ខ្ញុំយល់ហើយ, ចុះបើសង្ឃប្រគល់សំពត់កឋិនឲ្យយ៉ាងនេះហើយ ត្រូវឲ្យកិកុអ្នកគ្រាលប្រតិបត្តិដូចម្តេច? ។

– កន្តេ ថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! តាមគម្ពីរបរិវារៈបង្គាប់ថា តេន កឋិនត្ថារកេន ភិក្ខុនា តទហេវ ធោវិត្វា វិបដ្ឋេត្វា វិចារេត្វា ឆិន្ទិត្វា សិព្ពេត្វា រជិត្វា កប្បំ កត្វា កឋិនំ អត្ថរិតព្វំ "ត្រូវឲ្យកិកុអ្នកគ្រាលកឋិននោះ ភ្លាត គក់ ច្រលាច់ រាស់កាត់ ដេរជ្រលក់ ធ្វើកប្បពិន្ទុឲ្យហើយស្រេចតែក្នុងថ្ងៃនោះ. ហើយគ្រាលកឋិន

ទៅចុះ"; តែធ្វើឲ្យកន្ទុងថ្ងៃនោះទៅ ក្រែលកបិនមិនកើតឡើយ ។ បពិត្រ
ព្រះថេរៈ! ខ្ញុំព្រះករុណាសិដ្ឋនាមកបានសេចក្តីប៉ុណ្ណេះ សូមជ្រាប ។

១៧- សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរៈ! ប្រស្នាដែលលោក
ម្ចាស់ធ្វើយមកនេះ ត្រូវពិតហើយ; ចុះបើចីវរកបិននោះទាយកជា
សាមីនានគេធ្វើបវិកម្មសម្រេចជា ស្បង់ - ចីវរ - សង្ឃាដី រួចស្រេច
ស្រាប់មកហើយ, គេវៃប្រគេនដល់សង្ឃតែម្តង តើសង្ឃត្រូវប្រតិបត្តិ
ដូចម្តេច? លោកម្ចាស់ ។

- បពិត្រព្រះមហាថេរៈ! បើតាមក្នុងគម្ពីរកង្ខាវិតរណីអដ្ឋកថានៃ
កង្ខគម្ពីរវិនីព្រះពុទ្ធដីកា ពោលសរសើរថា កតបុព្វករណមេវ ឧប្បជ្ជតិ
ស្តុត្តរមេវ បើចីវរដែលទាយកធ្វើបុព្វករណៈរួចហើយ កើតឡើងដល់
សង្ឃជាការប្រពៃណាស់ហើយ ដោយហេតុគ្រហស្ថជាអ្នកឈ្លាសវៃក្នុង
ការកាត់ដេរជ្រលក់ចីវរ ត្រូវសង្ឃទទួលហើយប្រគល់ឲ្យទៅតិក្ខុអកាល
ក្រែលដោយកម្មវាចាចុះ មិនចាំបាច់ធ្វើបវិកម្មទៀតទេ ព្រៀបដូចកុលបុត្ត
ដែលមានកេសាគោរស្រេចហើយត្រូវបំបួសឲ្យទៅចុះ ឯតិក្ខុអកាល
កបិននោះសោតត្រូវអធិដ្ឋានក្រែលក្នុងមណ្ឌលសីមានោះ រួចហើយត្រូវ
ញុំងសង្ឃឲ្យអនុមោទនាតែម្តងទៅ ព្រោះមិនមានកិច្ចនឹងត្រូវធ្វើបុព្វ-
ករណៈ ដែលគេធ្វើតឹមត្រូវតាំងកាត់ដេរជ្រលក់រួចមកហើយនោះម្តង
ទៀតទេ, កាលបើសង្ឃប្រគល់ចីវរកបិនដែលសម្រេចស្រាប់មកឲ្យយ៉ាង

នេះហើយ បើកិកុអកក្រាលកបិន ត្រូវការក្រាលដោយសង្ឃាដី ត្រូវ
បច្ចុទ្ធរដកសង្ឃាដីចាស់ចេញ អធិដ្ឋានសង្ឃាដីថ្មីឡើង រួចហើយត្រូវ
បញ្ចេញវាចីកេតុក្រាលចុះ, បើត្រូវការក្រាលដោយសួរដំបូចីពរ កំត្រូវ
ធ្វើដូចគ្នានឹងសង្ឃាដីចុះ; បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាវិសជ្ជនា
មក ជានសេចក្តីយ៉ាងនេះ សូមមានជ្រាប ។

១៨— សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរ! ប្រស្នាដែលលោក
ម្ចាស់វិសជ្ជនាមក កំឃើញថាត្រឹមត្រូវពិតជាកដូច្នោះមែនពិតហើយ ។
សាធុវោ បពិត្រសាធុសប្បុរសទាំងឡាយ! លោកអ្នកគប្បីសន្និដ្ឋានចូល
ចិត្តជឿទុកស៊ប់ក្នុងគម្ពីរទាំងពីរ ដែលលោកម្ចាស់អនុត្តរជានោលអាង
ហើយនោះចុះ ឥតមានខុសឃ្លៀងឃ្លាតឡើយ ។ ឥតោ បរំ ជនៃអំពី
នេះទៅ ខ្ញុំនឹងលើកយកអានិសង្សទាន៩យក អ្នកធ្វើចីវរទានមកសួរ
លោកម្ចាស់វិញទៀត ។ អើលោកម្ចាស់ ចំណែក៩យកអ្នកធ្វើចីវរទាន
តើនឹងជានអានិសង្សយ៉ាងណា៧? សូមលោកម្ចាស់និមន្តលើកយក
រឿងនិទានណាមួយ ដែលមានសំដែងក្នុងគម្ពីរមកសំដែងកែវៃសេចក្តី
ដើម្បីអស់លោកអ្នកពុទ្ធបរិស័ទ ជានជ្រាបច្បាស់ផងមើល ។

តន្តេ មហាថេរៈ បពិត្រព្រះគុណម្ចាស់ដ៏ចំរើន! បុគ្គលដែលប្រកប
ដោយសទ្ធា ជានធ្វើចីវរទាន រមែងជានអានិសង្សប្រយោជន៍នឹងសេចក្តី
សុខជាច្រើន ដូចមានវត្ថុនិទានសំដែងថា អតីតេ ពារាណសិរាសិ

ឯកោ កុដុម្ពិកោ កន្លងកាលដ៏កន្លងទៅហើយ មានកុដុម្ពីក៍មួយនាក់នៅក្នុងនគរពារាណសី មានកាលថ្ងៃមួយ ត្រៃចដើរទៅកន្លែងត្រៃ ឃើញជួបនឹងព្រះបច្ចេកពុទ្ធមួយព្រះអង្គកំពុងដើរបីវារ ដែលខ្លះសំពត់មិនជាន់គ្រប់គ្រាន់ត្រង់អនុវាតបណ្តាយ កុដុម្ពីក៍នោះក៏មានចិត្តជ្រះថ្លា ហើយយកសំពត់សម្រាប់បង្កើបរបស់ខ្លួនប្រគេនទៅព្រះបច្ចេកពុទ្ធ ។ ដោយអានុភាពនៃបុញ្ញកម្មនេះ បុរសនោះក៏ឃើញទៅកើតក្នុងស្ថានតាវត្តឹង្សទេវលោកឃើញសោយទិព្វសម្បត្តិជាយូរអង្វែង លុះច្យុតអំពីទេវលោកនោះមកក៏ឃើញមកកើតក្នុងត្រកូលអាមាត្យនៅក្នុងទីចម្ងាយ ១ យោជន៍អំពីនគរពារាណសី ។ បុរសនោះមានវ័យវឌ្ឍនាការចំរើនធំឡើង ។ មានកាលមួយថ្ងៃជាថ្ងៃលេងនក្តួតបុក្ស បុរសនោះនិយាយទៅនឹងមាតារបស់ខ្លួនថា "បពិត្រអ្នកម៉ែ! ចូរអ្នកឲ្យសំពត់ ១ មកខ្ញុំៗ នឹងទៅលេងនក្តួតបុក្សទឹងគេ" ។ មាតានោះក៏ឲ្យសំពត់ស្អាត ១ ទៅ ។ បុរសនោះនិយាយថា "សំពត់នេះមានសាច់គ្រែតគ្រែតណាស់ ខ្ញុំមិនយកទេ" ។ មាតាក៏ឲ្យសំពត់ដទៃទៀត បុរសនោះក៏មិនព្រមយកសំពត់នោះទៀត ឃើញនិយាយទៅនឹងមាតាថា "បើអ្នកម្តាយរកសំពត់សាច់ម៉ដ្ឋឲ្យខ្ញុំមិនបានទេ ខ្ញុំនឹងទៅស្វែងរកសំពត់គួរជាទីគាប់ចិត្តឲ្យបាន" ។ មាតានិយាយថា 'ម្នាលកូន! មាតាមិនស្អប់កូនទេ សព្វថ្ងៃនេះម្តាយចង់ឲ្យកូនឯងបានសោយភោគក្នុងនគរពារាណសីនេះផង' ។ បុរសនោះក៏ថ្វាយបង្គំលាមាតាដើរចេញទៅ ។

ហេតុតែកុសលវាសីអំពីបុព្វជាតិត្រូវអំណោយផល បុរសនោះដើរចូលទៅ
កាន់នគរពារាណសី ហើយចូលទៅដេកទំនេរលើផែនថ្មមង្គលសិលាកន្លែង
សួនច្បារ ។ កាលនោះជាថ្ងៃព្រះពាជាកន្លងនគរពារាណសីទ្រង់សោយ
ព្រះទិវង្គតទៅបាន ៧ ថ្ងៃហើយ ។ ពួកជនមានអាមាត្យជាដើម នាំគ្នា
ធ្វើសរីរកិច្ចនៃព្រះពាជាស្រេច រួចប្រឹក្សាគ្នាថា "ឥឡូវព្រះពាជាមាន
តែព្រះពាជធីតា ឯព្រះពាជបុត្រមិនមានឡើយ ធម្មតាស្រុកនគរបើឥត
មានស្តេច ទឹងមិនបានស្ថិតស្ថេរយូរឡើយ ទឹងត្រូវវិនាសជាប្រាកដ"
ហើយក៏រៀបចំបុស្សរថ ទិមសេះសិន្ធព ៤ មានពាណិសម្បុរដូចផ្កាកុមុទ
ហើយយកពាជកកុធភណ្ឌ ៥ ប្រការដំតល់លើរថ រួចលែងបុស្សរថ
ទៅ ។ បុស្សរថនោះក៏ចេញទៅតាមទិសខាងកើត ហើយចូលទៅ
កាន់សួនច្បារ ប្រទក្សិណកុមារដែលដេកទំនេរក្នុងទីនោះហើយឈប់នៅ
ស្ងៀមធ្វើអាការហាក់ដូចជាប្រុងប្រៀបខ្លួនឲ្យកុមារឡើងជិះ ។ បុរោហិត
ក៏បើកជាយសំពត់ឡើងមើលឃើញផ្ទៃបាតជើងសព្វគ្រប់ ហើយពោល
ថា "បុរសនេះគួរនឹងសោយរាជ្យបាន" ហើយក៏ប្រគំតូរ្យតន្ត្រីអស់ពារៈ
៣ជង ។ លំដាប់នោះកុមារភ្ញាក់ខ្លួនបើកភ្នែកឡើងសួរថា "អ្នកទាំងឡាយ
នាំគ្នាមករកអ្វី?" ។ ជនទាំងឡាយតបថា "បពិត្រព្រះសម្មតិទេព! ឥឡូវ
រាជសម្បត្តិធ្លាក់លើព្រះអង្គហើយ" ។

(មានត)

មនុស្សឆ្កួតខ្លះនិងថោកទាប

ចូឡកម្មវិភង្គសូត្រ ក្នុងសុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក
ឃុនបណ្ណាទុវក្ក ប៊ិ - ប៉ូ ត្រែសួងពុទ្ធសាសនបណ្ឌិត្យ ជាអ្នកប្រែ[1]

គ្រានោះ សុភមាណពជាបុត្តរបស់គោទេយ្យព្រាហ្មណ៍បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលសួរប្រស្នាថា បពិត្រព្រះគោតមដ៏ចំរើន! អ្វីហ្នឹងជាហេតុ អ្វីហ្នឹងជាបច្ច័យ ដែលនាំឲ្យពួកមនុស្សកាលកើតមកជាមនុស្សមានសេចក្តីថោកទាបនឹងខ្លួនដ៏ខ្លះ ប្រាកដច្បើន ព្រោះថា មនុស្សខ្លះឯទៀតមានអាយុខ្លី មានអាយុវែង មានអាពាធច្រើន មានអាពាធតិច មានសម្បុរអាក្រក់ មានសម្បុរល្អ មានសក្តិតូច មានសក្តិធំ មានភោគសម្បត្តិតិច មានភោគសម្បត្តិច្រើន មានត្រកូលទាប មានត្រកូលខ្ពស់ មានប្រាជ្ញាតិច មានប្រាជ្ញាច្រើន? ។

ព្រះ- ម្នាលមាណព! សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងរលឹក កម្មតែងចែកសត្វទាំងឡាយឲ្យថោកទាបនឹងឲ្យខ្ពស់ ។

សុភមាណព - ខ្ញុំព្រះអង្គមិនយល់សេចក្តីពិស្តារបស់កាសិតស្តេចនេះទេ សូមព្រះអង្គសំដែងចែកសេចក្តីពិស្តារឲ្យខ្ញុំ ។

---

១ ប្រែប្រួតកាត់ចោលសេចក្តីខ្លះត្រង់ដែលមានសេចក្តីដូច ។ ។

ព្រះ– ម្នាលមាណព! បើដូច្នោះ អ្នកចូរយកចិត្តទុកដាក់ចាំស្តាប់ឲ្យ ប្រពៃចុះ តថាគតនឹងសំដែង ។

១– ហេតុឲ្យមានអាយុខ្លី

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ប្រព្រឹត្តអាក្រក់ មានដៃប្រឡាក់ឈាម តាំងនៅក្នុងការប្រហារជីវិត នឹងការសម្លាប់ មិនអាណិតពួកសត្វ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ឬសិនបើមិនទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា។ រមែងជាអ្នកមានអាយុខ្លី ។

២– ហេតុឲ្យមានអាយុវែង

ម្នាលមាណព! មួយទៀត ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ លះបង់ចាណាតិចាត វៀរស្រឡះចាកចាណាតិចាត មានដម្បងទន់ស្រាជាក់ចុះហើយ ជាអ្នកមានសេចក្តីអៀនខ្មាស មានសេចក្តីអាណិតអាសូរ អនុគ្រោះដោយប្រយោជន៍ ក្នុងពួកសត្វទាំងអស់ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ឬសិនបើមិនទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា។ រមែងមានអាយុវែង ។

៣–ហេតុឲ្យមានអាពាធច្រើន

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកបៀតបៀនសត្វតាំងឡាយ ដោយចាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆានប្រេតវិស័យ អសុរកាយ នរក ឬសិនបើមិនទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ។ រមែងជាអ្នកមានអាពាធច្រើន ។

៤–ហេតុឲ្យមានអាពាធតិច

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបៀតបៀនសត្វតាំងឡាយ ដោយចាតដៃខ្លះ ដោយដុំដីខ្លះ ដោយដម្បងខ្លះ ដោយសស្ត្រាខ្លះ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ឬសិនបើមិនបានទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ។ រមែងជាអ្នកមានអាពាធតិច ។

៥–ហេតុឲ្យមានសម្បុរអាក្រក់

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីក្រោធច្រើនទៅដោយសេចក្តីចង្អៀតចង្អល់ចិត្ត គ្រាន់តែគេស្តីថាបន្តិច

បន្តួចក៏ភ្ញាក់ ខឹង ព្យាបាទ តបត សំដែងសេចក្តីក្រោធ ច្រណែន ទឹង សេចក្តីមិនត្រេកអរឲ្យច្រើនដងឡើង ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រែតវិស័យ អសុរកាយ នរក ឬសិនបើមិនបានទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ។ រមែងជាអ្នកមានសម្បុរអាក្រក់ ។

៦ - ហេតុឲ្យមានសេចក្តីជ្រះថ្លា (សម្បុរល្អ)

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនក្រោធ មិនច្រើនទៅដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេស្តីថាច្រើន ក៏មិនពាក់ព័ន្ធ មិនក្រោធ មិនព្យាបាទ មិនតបត មិនសំដែងនូវសេចក្តីក្រោធ ច្រណែន ទឹងសេចក្តីមិនត្រេកអរឲ្យច្រើនដងឡើង ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ឬសិនបើមិនបានទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ។ រមែងជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា (សម្បុរល្អ) ។

៧ - ហេតុឲ្យមានសក្តិត្តូប

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកច្រណែនតែងច្រណែន ច្រណែនក្នុងលាភសក្ការៈ ទឹងសេចក្តីគោរព ការរាប់

អាន ការថ្វាយបង្គំ ការបូជា របស់បុគ្គលតាំងខ្លាយដៃ ចង់ទុកនូវ សេចក្តីថ្លៃណែន ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ប្រសិនបើមិនបានទៅកើតក្នុងកំណើតតាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ។ រមែងជាអ្នកមានសក្តិតូច ។

៨_ហេតុឲ្យមានសក្តិធំ

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះក្នុងលោកនេះ ជាអ្នកមិនថ្លៃណែន រមែងមិនថ្លៃណែន មិនប្រទូស្ត ក្នុងលាភសក្ការៈ សេចក្តីគោរព ការកាន់អាន ការថ្វាយបង្គំ ការបូជា របស់បុគ្គលតាំងខ្លាយដៃ មិនចង់ទុកនូវសេចក្តីថ្លៃណែន ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើមិនបានទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា។ រមែងជាអ្នកមានសក្តិធំ ។

៩_ហេតុឲ្យមានភោគសម្បទាពិប

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានឲ្យ បាយ ទឹក សំពត់ យាន ផ្ការម្រះ គ្រឿងក្រអូប គ្រឿងលាបផ្សែង។ ទីដេក ទីអាស្រ័យ ប្រទីប ដល់សមណៈឬព្រាហ្មណ៍ ។ ព្រោះអំពើដែល

ខ្ញុំបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្វាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រែតវិស័យ អសុរកាយ នរក ប្រសិនបើមិនបានទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ។ រមែងជាអ្នកមានភោគសម្បត្តិច ។

១០_ហេតុឲ្យមានភោគសម្បត្តិប្រើន

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សែង ទីដេក គ្រឹស្ម័យ ប្រទីប ដល់សមណៈឬព្រាហ្មណ៍ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្វាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើមិនបានទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ។ រមែងជាអ្នកមានភោគសម្បត្តិច្រើន ។

១១_ហេតុឲ្យមានត្រកូលប៉ោកទាប

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកឆ្អែតឆ្អន់មើលងាយ មិនសំពះបុគ្គលដែលគួរសំពះ មិនក្រោកទទួលបុគ្គលដែលគួរក្រោកទទួល មិនឲ្យអាសនៈដល់បុគ្គលដែលគួរដល់អាសនៈ មិនឲ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ មិនធ្វើសក្ការៈដល់បុគ្គលដែលគួរដល់សក្ការៈ មិនធ្វើសេចក្តីគោរពដល់បុគ្គលដែលគួរធ្វើសេចក្តីគោរព មិនរាប់អានដល់

បុគ្គលដែលគួរពាប់អាន មិនបូជាដល់បុគ្គលដែលគួរបូជា ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រែតវិស័យ អសុរកាយនរក ប្រសិនបើមិនទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ។ រមែងជាអ្នកមានត្រកូលថោកទាប ។

១២ - ហេតុឲ្យមានត្រកូលខ្ពង់ខ្ពស់

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនរឹងត្អឹង មិនមើលងាយ សំពះបុគ្គលដែលគួរសំពះ គ្រោកទទួលបុគ្គលដែលគួរគ្រោកទទួល ឲ្យអាសនៈដល់បុគ្គលដែលគួរដល់អាសនៈ ឲ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ ធ្វើសក្ការៈដល់បុគ្គលដែលគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរពដល់បុគ្គលដែលគួរគោរព ពាប់អានបុគ្គលដែលគួរពាប់អាន បូជាបុគ្គលដែលគួរបូជា ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើមិនបានទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ។ រមែងជាអ្នកមានត្រកូលខ្ពង់ខ្ពស់ ។

១៣ - ហេតុឲ្យគ្រាន់ប្រាជ្ញ

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ចូលទៅរកសមណៈឬព្រាហ្មណ៍ហើយមិនបានសាកសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន! អ្វីជា

កុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស អ្វីគួរសេព អ្វីមិនគួរសេព អ្វីកាលបើធ្វើ ប្រព្រឹត្តទៅដើម្បីជាទោស ដើម្បីជាទុក្ខអស់កាលដ៏យូរ មួយយ៉ាងទៀត អ្វីកាលបើធ្វើ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលដ៏យូរ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រែតវិស័យ អសុរកាយ នរក ប្រសិនបើមិនបានទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ។ រមែងជាអ្នកគ្មានប្រាជ្ញា ។

១៤— ហេតុឱ្យមានប្រាជ្ញាប្រើន

ម្នាលមាណព! ស្តីប្តូរសេពគប្បីកន្លះ កងលោកនេះចូលទៅដល់សមណៈ ឬព្រាហ្មណ៍ហើយសាកសួរថា បពិត្រលោកដ៏ចំរើន! អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស អ្វីគួរសេព អ្វីមិនគួរសេព អ្វីកាលបើធ្វើ ប្រព្រឹត្តទៅដើម្បីជាទោស ដើម្បីជាទុក្ខ អស់កាលដ៏យូរ មួយយ៉ាងទៀត អ្វីកាលបើធ្វើ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលដ៏យូរ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើមិនបានទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ។ រមែងជាអ្នកមានប្រាជ្ញាប្រើន ។

ម្នាលមាណព! ព្រោះហេតុថា សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានអាយុខ្លី រមែងនាំឲ្យមានអាយុខ្លី ។ល។ សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានប្រាជ្ញាច្រើន រមែងនាំឲ្យមានប្រាជ្ញាច្រើន ។

កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ សុភមាណពគោត្រយុត្តបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន! ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន! ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន! ធម៌ដែលព្រះអង្គសំដែងហើយដោយអនេកបរិយាយយ៉ាងនេះ (ក្តីប្រាស់ណាស់) ដូចជាគេផ្ងារបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង. ឬក៏ប្រាប់ផ្លូវដល់មនុស្សវង្វេង ពុំនោះសោត ដូចជាគេត្រាលប្រទីបបំភ្លឺក្នុងទីងងឹតដោយគិតថា ឲ្យពួកមនុស្សដែលមានភ្នែកភ្លឺមើលឃើញរូបតាំងឡាយបាន ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកអ្នកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះតរៀងទៅ ។

ចប់

ធន្លឹ កម្មសមំ ពលំ
គ្មានកំឡាំងអ្វីស្មើនឹងកំឡាំងកម្ម
ជ ។.

ឃុនបណ្ណាសុរ៉ាក្យ ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

បរិយាយដើម

មនុស្សក្នុងសាកលលោកគ្រប់ជាតិគ្រប់សាសន៍ សុទ្ធសឹងតែមានកិច្ចការត្រូវធ្វើពាំងអស់គ្នា គ្មានអ្នកណានៅសៀមឡើយ ព្រោះធម្មតាលោកបង្គាប់ឲ្យធ្វើ ។ ឯកិច្ចការរបស់អ្នកស្រុកពាំងអស់នោះ ដែលទំនងចំរើនកើនឡើងតាមលំដាប់ៗបាន ដោយសារតែមានពេល-ម៉ោង-ថ្ងៃ-ខែ-ឆ្នាំជាគ្រឿងកត់សំគាល់ ដូចមានពេលព្រឹក-ល្ងាច-ថ្ងៃ-យប់ជាដើម ។ សូម្បីការសរសេរសំបុត្រស្នាមៅមកវកគ្នា ក៏ត្រូវចុះថ្ងៃ-ខែ-ឆ្នាំខានមិនបានដែរ ។ ហេតុនេះ ការចេះចាំថ្ងៃ-ខែ-ឆ្នាំ មានប្រយោជន៍ជាយ៉ាងច្រើន ។ បើប្រទេសណាមិនប្រើពេល-ម៉ោង-ថ្ងៃ-ខែ-ឆ្នាំទេ ប្រទេសនោះនឹងធ្វើការអ្វីៗឥតគម្រិត ឥតរបប ឥតក្របខ័ណ្ឌ ឥតរបៀប មិនរៀបរយ នាំឲ្យការងារពាំងនោះច្របូកច្របល់រសេមរសាម គឺថាធ្វើការព្រឹកជាល្ងាចៗ ជាព្រឹក, ខែនេះជាខែនោះ, ឆ្នាំនេះជាឆ្នាំនោះ ចំណាំបានច្បាស់ប្រាកដតែរដូវថា រដូវក្តៅឯង, រដូវពាំង, រដូវទឹកឡើង, រដូវទឹកស្រក នឹងរដូវស្លឹកឈើជ្រុះជាដើម ។ ពុំនោះសោត គេទុកជាកន្លះមនុស្សពួកនោះ ថាជាមនុស្សល្ងីល្ងើ

តួយ៉ាងដូចជាមិលក្ខៈ, គឺមនុស្សវៃព្រ, មនុស្សព្នង ដែលអាស្រ័យនៅក្នុងកោះតូចតាច ឆ្ងាយដាច់ស្រយាលពីគេ ឬអាស្រ័យជិតនៅក្នុងវៃព្រ ជ្រៅជ្រាយកៀនកោះ ជាចន្លោះប្រទេសរបស់គេ, មនុស្សចំពូកនេះប្រើតែគំនូសជំនួសអក្សរ តាំងពីកើតទល់គ្នានឹងស្ងាប់ទៅវិញ ពុំដែលបានស្គាល់នូវសេចក្តីនៃអារ្យធម៌នឹងគេសោះ ។ ហេតុដូច្នោះ បានជាលោកអ្នកប្រាជ្ញជាន់ដើមកំណត់ឲ្យប្រើពេលៈ-មោ៉ង-ថ្ងៃ-វ៉ែ-ឆ្នាំ ហៅថា "សកពជ" ជាគ្រឹងចំណាំ ។

ឯសកពជដែលគេនិយមប្រើក្នុងប្រទេសខ្មែរយើងសព្វថ្ងៃនេះ មាន ៤ យ៉ាង គឺ ១- ពុទ្ធសកពជ, ២- គ្រិស្តសកពជ, ៣- មហាសកពជ, ៤- ចុល្លសកពជ ។ ឯសកពជទាំង ៤ យ៉ាងនេះគេរៀបរៀងតាមលំដាប់ដែលកើតមុន កើតក្រោយ ដូចតទៅនេះ គឺ

១- ពុទ្ធសកពជ កើតមុនសកពជទាំង ៣;

២- គ្រិស្តសកពជ កើតក្រោយ ៣.ស. ៥៤៣ ឆ្នាំ;

៣- មហាសកពជ -ជ- -ជ- ៦២១ -ជ-;

៤- ចុល្លសកពជ -ជ- -ជ- ១.១៨១ -ជ- ។

អធិប្បាយអំពីសកពជទាំង ៤ តាមលំដាប់គ្នា

ពុទ្ធសកពជ.- ក្នុងវចនានុក្រមខ្មែរ ភាគទី ១ ទំព័រ ៦២៩ ប្រាប់ថា ពុទ្ធសកពជ គេកំណត់រាប់ចំនួនថ្ងៃ ខែ ឆ្នាំ តាំងពីក្រោយ

ថ្ងៃដែលព្រះពុទ្ធអង្គ ទ្រង់ចូលបរិនិព្វានទៅបានមួយថ្ងៃរៀងមក ។ ព្រះសក្យមុនីគោតមទ្រង់ចូលបរិនិព្វាននៅថ្ងៃអង្គារ ១៥ កើត ខែពិសាខ ឆ្នាំម្សាញ់,រាប់ពីត្រឹមថ្ងៃ ១ កេះខែពិសាខ ឆ្នាំនោះមក ជាពុទ្ធសកាជ ។

ការរាប់ពុទ្ធសកាជ ជាការកំណត់ថ្ងៃខែឆ្នាំរបស់ពួកពុទ្ធសាសនិកជន សម្រាប់ប្រើខាងទេសនា ដែលហៅថា "បកសកាជ" ។ រាប្យបនេះ រាប់យកចំណែកខាងរនោចខែមួយមុនមកប៉ះរួមនឹងខ្នើតខែបន្ទាប់នោះជា ១ ខែ គឺត្រូវរាប់ពីថ្ងៃ ១ កេះខែពិសាខមកដល់ថ្ងៃ ១៥ កើតខែជេស្ឋ ជា ១ ខែ ។ ល ។ ពីថ្ងៃ ១ កេះខែចេត្រ មកដល់ថ្ងៃ ១៥ កើតខែពិសាខ ជា ១ ខែ (គេញ៉ាជា ១ ឆ្នាំ) រាប់យ៉ាងនេះរៀងរាល់ឆ្នាំ, បើរាប់ពីលើមកដល់ត្រឹមណា ត្រូវទុកថ្ងៃខែឆ្នាំនោះជាបច្ចុប្បន្នកាល មិនចាន់ពេញថាជាសកាជដែលកន្លងទៅហើយទេ, ដូចជាកាលពីក្នុងថ្ងៃ ១៥ កេះខែស្រាពណ៍ ឆ្នាំមមី បន្ទាប់ឆ្នាំពុទ្ធបរិនិព្វាន ត្រូវរាប់ថា ពុទ្ធសកាជកន្លងទៅហើយបាន ១ ឆ្នាំ ៣ ខែ ១៤ ថ្ងៃ (កន្លងទៅហើយបានប៉ុន្មាន ត្រូវថាត្រឹមប៉ុណ្ណោះ), តែបើប្រើខាងការសរសេរសំបុត្រចុតហ្វាយ កត់ត្រាចុះក្នុងគម្ពីរក្បួនច្បាប់ចាំងពួង ឬនិយាយស្តីធ្វើបាប់គ្នាតាមធម្មតានោះ ត្រូវរាប់បេញចំនួនសកាជយកត្រឹមឆ្នាំមមីដែលចូលកន្លងឆ្នាំគំរប់ ២ ខ្ទុះឯងថា ពុទ្ធសកាជ ២ ឆ្នាំ ឬពុទ្ធសកាជ ២, បើប្រើអក្សរសង្ខេបត្រូវសរសេរជា ព.ស. ២ ។

ពុទ្ធសកាជនេះ ចាប់ផ្តើមកើតមានឡើងជាដំបូងនៅក្នុងប្រទេសឥណ្ឌា ដោយពួកពុទ្ធបរិស័ទមានព្រះសង្ឃជាដើមក្នុងប្រទេសនោះ

កំណត់ឲ្យប្រើឡើង ចាប់ពីតាំងពីគ្រាយថ្ងៃដែលព្រះពុទ្ធអង្គចូលបរិនិព្វានទៅបាន ១ ថ្ងៃ គឺកំណត់ពីតាំងពីត្រឹមថ្ងៃពុទ្ធ ១ កើតខែពិសាខ ឆ្នាំម្សាញ់នោះមក ឲ្យឈ្មោះថាជាពុទ្ធសកាជ ដោយមានថ្ងៃបរិនិព្វាននៃព្រះពុទ្ធជាគោលចាក់, ហើយតមកក្នុងប្រទេសនានា ដែលជាប្រទេសកាន់ព្រះពុទ្ធសាសនា ដូចប្រទេសខ្មែរជាដើម ក៏និយមប្រើតៗគ្នាមកវិញតដល់សព្វថ្ងៃនេះ ។

ឯប្រទេសឥណ្ឌា កាលពីសម័យមុន ដែលពុំទាន់មានពុទ្ធសកាជនៅឡើយ គេនិយមប្រើបុរាណសកាជ គឺសកាជខាងសាសនាព្រាហ្មណ៍ជាច្រើនពាន់ឆ្នាំមកហើយ ។ លុះដល់មានពុទ្ធសកាជ ប្រទេសឥណ្ឌា ក៏ចាប់ប្រើពុទ្ធសកាជជាប់ឡើង ។ ក្នុងសម័យបច្ចុប្បន្ននេះ ប្រទេសឥណ្ឌាឈប់ប្រើពុទ្ធសកាជទៅហើយ, តែគេប្រើសកាជអ្វី យើងមិនចាប់និយាយ ។

គ្រិស្តសកាជ.— ក្នុងវចនានុក្រមខ្មែរ កាគទី ២ ទំព័រ ៧៩៧ ថ្លែងថា គ្រិស្តសកាជនេះ គេបង្កើតឡើងតាមនាមនឹងពង្សាវតារនៃសាស្តាម្ចាស់ឈ្មោះ ហ្សេហ្សឹយ ឬហ្សេហ្សឹយ-គ្រិស្ត (Jésus ou Jésus-Christ) ជាអ្នកបង្កើតលទ្ធិ ឬសាសនាមួយ ហៅថាសាសនាគ្រិស្ត (Religion Chretienne) ក្នុងកាលសតវត្សរ៍ទី ៦ នៃពុទ្ធសកាជ (ព.ស. ៥៤៣) ។ ពិតមែនតែព្រះហ្សេហ្សឹយ-គ្រិស្ត ទទួលមរណភាពក្នុង

ព. ស. ៥៧៦ ក្នុងអាយុគំរប់ ៣៣ ឆ្នាំ តែគេបានតាំងសកពជនោះគិត ពីថ្ងៃដែលសាស្តានេះកើត គឺក្នុង ព. ស. ៥៤៣ ហៅថា គ្រិស្តសកពជ សរសេរអក្សរសង្ខេបថា គ. ស. គឺសកពជដែលគេនិយមប្រើក្នុង ប្រទេសអឺរុបនឹងប្រទេសអាស៊ីដោយច្រើន ក្នុងសម័យសព្វថ្ងៃនេះ ។

មហាសកពជ.— ក្នុងវចនានុក្រមខ្មែរ ភាគទី ១ ទំព័រ ៧២២ នឹងភាគទី ២ ទំព័រ ១០៨១ ប្រាប់ថា ស័ក្ក ប្រែថា "កាល, សម័យ យុគ . . .," រ៉ាជ ប្រែថា "ស្តេច" ។ ការរាប់ថ្ងៃខែឆ្នាំឬការរាប់ត្រឹមតែឆ្នាំ តាមកាលកំណត់ដែលតាំងទុកពីមួយរៀងមកដោយមានបុគ្គលអស្ចារ្យ ឬ ដោយមានហេតុអស្ចារ្យណាមួយ ដែលពួកជនានុជនអ្នកគោរពត្រូវតត់ ត្រាទុកមិនឲ្យបាត់, ត្រូវប្រើក្នុងសំបុត្រចុតហ្វាយជាដើម បង្កើនមួយ លេខរៀងពាល់ឆ្នាំ ហៅថា "សកពជ" ។ នេះកើតឡើងអំពីជនមួយ ពួកហៅថា ពួកតាត៌ នៅក្នុងតំបន់មួយខាងទិសពាយ័ព្យប្រទេសឥណ្ឌា ក្នុងកាល ព. ស. ៦២១ ឆ្នាំ ។ កាលជនពួកនេះមានជ័យជំនះក្នុងការ លុកលុយចូលមកវាតអំណាចក្នុងប្រទេសឥណ្ឌាបែកខាងលិច បានតាំង ក្សត្រជាតិរបស់ខ្លួនមានព្រះនាមថា សក: ឬសាលិវាហន:, ហើយក៏ចាប់ ផ្តើមរាប់ឆ្នាំតាំងពីមួយរៀងមក, ហៅរបៀបការរាប់ឆ្នាំនោះថា "ស័កឬ សកពជ" ដែលចំណោះតមក ហៅថា "មហាសកពជ" ប្រែថា "សក់ ពជធំ" ។ នេះកើតមុនចុលសកពជ ៥៦០ ឆ្នាំ, ជាប់មានប្រើក្នុងប្រទេសខ្មែរ

យើងតាំងពីរាជវង្សតាឡែទី ១០ នៃពុទ្ធសករាជ (ព. ស. ៨២១) រហូតមកដល់សព្វថ្ងៃនេះ ប្រើអក្សរសង្ខេបថា ម. ស.(១) ។

មហាសករាជ ចាប់ផ្តើមជាកើតឡើងក្នុងប្រទេសឥណ្ឌាជាដំបូង ក្នុង ព. ស. ៦២១ ឆ្នាំ អំពីជនពួកមួយ ដូចមានរៀបរាប់ខាងលើនេះ, មិនមែនកើតឡើងជាដំបូងនៅប្រទេសខ្មែរដោយព្រះកេតុមាលាតាំងឡើង ក្នុង ព. ស. ៦២១ នោះទេ ។

ក្នុងព្រះរាជពង្សាវតារខ្មែរ ភាគទី ២ ថា ព្រះកេតុមាលាកាលស្តេចឡើងគ្រងរាជសម្បត្តិក្នុង ព. ស. ៦២១ ឆ្នាំមែន ជាមួយនឹងឆ្នាំដែលប្រទេសឥណ្ឌាបង្កើតឲ្យប្រើមហាសករាជ, ប៉ុន្តែគេនៅពុំទាន់បញ្ជូនឲ្យប្រើមហាសករាជ ក្នុងឆ្នាំនោះនៅឡើយទេ ។ លុះដល់មក ព. ស. ៦២៣ ឆ្នាំ ព្រះកេតុមាលាទើបទទួលឥន្ទ្រាភិសេកជាថ្មី ក៏តាំងជាមហាសករាជដំបូងមក ។ (តែនេះហើយប្រហែលជា ព្រះកេតុមាលាបញ្ជូនឲ្យប្រើមហាសករាជ តាមប្រទេសឥណ្ឌា ហើយគេនិយមថា ព្រះកេតុមាលាផ្តើមបង្កើតមហាសករាជ ជាប្រឋមនៅប្រទេសខ្មែរ) ។

ប៉ុល្លុសករាជ.— ក្នុងវចនានុក្រមខ្មែរ ភាគទី ១ ទំព័រ ១៥២

---

១ ប្លាប់មគ្គុទ្ទេសក៍នគរ ភាគទី ១ ទំព័រ ២ ថា លុះដល់មកចុងសតវត្សរ៍ទី៩ និងខាងដើមសតវត្សរ៍ទី ១០ នៃពុទ្ធសករាជ ទើបមានព្រាហ្មណ៍មកពីប្រទេសឥណ្ឌាឈ្មោះកោណ្ឌញ្ញៈ មកសោយរាជ្យនៅប្រទេសហ្វូណន ជានរៀបចំទំនៀមប្រពៃណីប្រទេសហ្វូណនឲ្យប្រព្រឹត្តទៅតាមលទ្ធិប្រទេសឥណ្ឌាឡើង ។

ច្រាប់ថា ចុលសកពជ រៀបថា "សកពជគួច" ។ នេះចាប់ផ្តើមតាំងឡើង នៅថ្ងៃចន្ទ ១២ កើតខែចែត្រ ឆ្នាំកុរឯកស័ក ព. ស. ១.១៨១ ។

កន្លះបន្ទាត់ខ្មែរ ភាគទី ២ ទំព័រ ១.០៨១ ច្រាប់ថា កន្លែងព្រះពជពង្សាវតារខ្មែរថា ព្រះបាទសម្តេចព្រះអរិដ្ឋពលពាហនោ (ព្រះកេតុមាលា) បានតាំងមហាសកពជ ១ កន្លែងកាល ព. ស. ៦២១ ។ ព្រះបាទសម្តេចសិន្ធពអមរិន្ទបរមព្រហ្មកិល (ពញាក្រែក) បានតាំងចុលសកពជ ១ កន្លែងកាល ព.ស. ១.១៨១ កន្លែងឆ្នាំដែលទ្រង់បានសោយរាជ្យនៅនគរធំៗ

កន្លែងច្បាប់ពជពង្សាវតារក្រុងកម្ពុជាធិបតីខ្មែរ ច្រាប់ថា កាល ព. ស. ១ ១៨៣, ម. ស. ៥៦១ ឆ្នាំកុរឯកស័ក ត្រូវនឹង គ. ស. ៦៣៩ ព្រះបាទសម្តេចព្រះបទុមសុរិយាវង្ស ស្តេចតាំងឲ្យមានជាចុលសកពជឡើងកប់ ១ រៀងមក ។

កន្លែងច្បាប់ព្រះពជពង្សាវតារក្រុងកម្ពុជា ដែលលោកខេតពិទូរឈឹម-ក្រសេម បានរួបរួមឡើងជាថ្មីថា ក្សត្រមនព្រះនាមសង្ឃរាជជាក្សត្រទី ១៩ កន្លែងរង្សាសមុទ្រឫទ្ធិ ទ្រង់តាំងចុលសកពជឡើង ។

សេចក្តីវិនិច្ឆ័យ: ចុលសកពជនេះ បានដេញដោលរកទៅយល់ឃើញថា មាន ២ ផ្លូវ គឺយល់ថា ក្សត្រមនបានតាំងឡើងជាដំបូងកន្លែងប្រទេសមននោះក៏បាន ។ បើនឹងយល់ថា ក្សត្រខ្មែរ បានតាំងចុលសកពជឡើងជាដំបូងកន្លែងប្រទេសខ្មែរក៏បានដែរ ។ ប៉ុន្តែ ត្រូវយល់

ថា មានតែព្រះបាទជយវរ្ម័នទី ១ (១) ទ្រង់បានតាំងចុលសកពជឡើង ជាដំបូង ក្នុងឆ្នាំដែលទ្រង់បានសោយពជ្យ ក្នុង ព.ស. ១.១៨១ នេះ យើញគួរជាង ព្រោះក្បួតអង្គនេះសោយពជ្យនៅនគរវត្ត ហើយបានតាំងប្រើចុលសកពជដពមក (ដែលថាយ៉ាងនេះដោយអាងច្បាប់ព្រះពជ-ឥណ្ឌាវគារដែលលោកទេពពិទូរ ឈឹម-គ្រសេម ស្តេចរួមជាន់ក្រោយ) ។

ការប្រើសកពជ.— ក្នុងប្រទេសកម្ពុជាប្រើសកពជ ៤ យ៉ាង គឺ ពុទ្ធសកពជ, មហាសកពជ, ចុលសកពជ នឹងគ្រិស្តសកពជ ។

ឯពុទ្ធសកពជ នឹងមហាសកពជ ប្រាកដជាមានដើមកំណើតកើតឡើងក្នុងប្រទេសឥណ្ឌា ដោយសារជនជាតិឥណ្ឌាដែលជាអ្នកកាន់លទ្ធិសាសនាដូចគ្នានឹងខ្មែរផង ដោយសារអារ្យធម៌ឥណ្ឌាសាយកាយចូលមកក្នុងប្រទេសខ្មែរយើងផង បានជាខ្មែរយើងចាប់និយមប្រើពុទ្ធសកពជ នឹងមហាសកពជខ្លះ តាមអារ្យធម៌ឥណ្ឌាតាំងពីសម័យនោះមក ។

តែកាលពីសម័យនគរភ្នំជាដំបូង រហូតមកទល់គ្នានឹងសម័យនគរជំនជាតិខ្មែរពុំបានប្រើពុទ្ធសកពជនឹងចុលសកពជជាផ្លូវការនៅឡើយទេ ប្រើតែមហាសកពជមួយយ៉ាងប៉ុណ្ណោះ លុះមកដល់ខាងចុងសម័យនគរធំ ទើបមានប្រើចុលសកពជផងជាផ្លូវការ រួមជាមួយពុទ្ធសកពជ នឹងមហាសកពជ រឿងនេះដឹងបានដោយសារមានសិលាចារឹកជាកស្តតាង ។

---

១ ច្បាប់មគ្គុទ្ទេសកនគរភោគទី ១ ទំព័រ ៧ ថា ព្រះបាទជយវរ្ម័នទី ១ ទ្រង់សោយរាជ្យក្នុងសតវត្សរ៍ទី ១៣ នៃពុទ្ធសកពជ (ព.ស. ១.២០៧ - ១.២១០) ។

ចំណែកគ្រឹស្តសភាពជ ចាប់ផ្តើមប្រើក្នុងប្រទេសខ្មែរ តាំងពីរជ្ជ-កាលនៃព្រះបាទសម្តេចព្រះហរិរក្សពមាតស្សរកធិបតី (ព្រះអង្គឌួង) គឺតាំងពី ព. ស. ២.៣៩១, គ. ស. ១.៨៤៧ រៀងមក ដោយសារប្រទេសជាកំណល់សែសនឹងប្រទេសកម្ពុជា មានការទាក់ទងគ្នាតាំងពីសម័យនោះមក ។

ការរៀបរៀងអត្ថបទសភាពជដូចខាងលើនេះ ឃើញថាគ្រឹមត្រូវល្មមទុកជាគតិទៅអនាគតបាន ដោយមានក្បួនតម្រាជាកស្តង់គ្រប់សភាពជ, ប៉ុន្តែបើពិនិត្យអំពីការប្រើសភាពជនៅប្រទេសខ្មែរយើង ក្នុងសម័យបច្ចុប្បន្ននេះ ជាផ្លូវការក្តី ជាសាធារណៈក្តី ឃើញច្រើនតែប្រើគ្រឹស្តសភាពជពុំសូវមានប្រើពុទ្ធសភាពជឡើយ ។

ហេតុនេះ ក្នុងសម័យនេះ គួរលើកយកពុទ្ធសភាពជមកចុះប្រើជាផ្លូវការ ទើបប្រើជាសាធារណៈ ទុកជាសារណៈដល់ពុទ្ធសភាព, នេះឃើញថាជាទីសមរម្យដល់ប្រទេសកាន់ពុទ្ធសាសនា ដូចជាប្រទេសថៃជាដើម ។

ចប់ ដោយសង្ខេប

ព្រះមហាឧត្តមវិជ្ជា ធីលញ្ញាណោ ប៊ុង-ប៉ាម

អាចារ្យសាលាបាលីវគ្គ វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌាគុរ្ក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(ត្រមក)

ចំពោះពួកញាតិ បើលោក-អ្នកគាបជាន់គេដោយវ័យ . សូម្បីលោក-អ្នកជាមនុស្សវៃសេសជាន់គេ ដោយដំរេះវិជ្ជាសក្តិយស អំណាចឫសនានិធីទ្រព្យសម្បត្តិក៏ដោយ ក៏កុំវាយឫកចិត្តមុឺតចើងមុឺងតំកើងខ្លួនឡើយ គួរធ្វើការគោរពនុនលំទោនចំពោះញាតិដែលចាស់ជាង ហើយបើលោក-អ្នកជាបុគ្គលស្មើគ្នាដោយវ័យ ក៏គួរសំដែងសេចក្តីពប់អានគ្នាឲ្យសមវ័យសមជាន់ មិនមើលងាយគ្នាដោយហេតុគ្មានឫសនា ឬសូម្បីលោក-អ្នកជាអ្នកធំ ក៏គួរសំដែងអធ្យាស្រ័យ មេត្រីករុណាប្រណីចំពោះញាតិអ្នកតូច ។ ចំពោះពួកមិត្ត បើលោក-អ្នកជ្រាបស្និទ្ធស្នាលគ្នាមកយ៉ាងណា សូម្បីលោក-អ្នកបានសេចក្តីថ្កុំថ្កើងរុងរឿង ក៏កុំប្រែចិត្តឡើយ ចូររាប់អានគ្នាឲ្យស្និទ្ធស្នាលតាមប្រក្រតីដើម ។ ចំណែកខាងពួកគណៈទំងញាតិមិត្តវិញ បើបានទទួលសេចក្តីគោរពពប់អានយ៉ាងនេះហើយ ក៏គួរសំដែងសេចក្តីស្រឡាញ់សេចក្តីគោរពពប់អានតបវិញ ដែលជាហេតុធ្វើសេចក្តីសាមគ្គីព្រមព្រៀងគ្នាឲ្យជាប់លាប់ម៉ាំមួន ។

នេះជាបទគួរពុក :- "ពួជ ពង្ស ប្រៀបដូចជាឫសដែលមានរងើក
ក្តើង កាលជាក់បង្គរលើគ្នា ក៏ឆេះឡើងបានភ្លាម; សរសៃអំបោះ សូម្បី
តែងប្តឹម បើយកមកវេញផ្ចប់បញ្ចូលគ្នាហើយ ក៏ជាប់ស្អិត អាចចង់ដាំ
បាន; ព្រឹក្សជាតិដែលដុះឡើងនៅទីវាលទោលតែមួយ ទុកជាធំខ្ពស់ម៉ាំ
ពាន់មានឫសតែវាម៉ាំមួនយ៉ាងណាក៏ដោយ ក៏អាចត្រូវពាយុបោកប្រក់បំបាក់
រំលើងឫសគល់ឲ្យបែកធ្លាយ ឲ្យរលើងទៅបានកន្លះខណៈមួយរំពេច តែ
ពួកឈើដែលមានឫសម៉ាំ ដុះឡើងជាមួយគ្នាជាពួកជាក្រុម អាស្រ័យ
ការជួយទប់អំពីគ្នានឹងគ្នា ក៏អាចទប់តនឹងខ្យល់បាន" ។ ដូច្នេះ អ្នកនៅ
តាមទំនើងម្នាក់ឯង សូម្បីសត្រូវតែម្នាក់ឯង ក៏អាចផ្តាញ់ឲ្យចាញ់បាន
ដូចជាខ្យល់ដែលរំលើងដើមឈើដែលដុះតោលតែម្នាក់ឯងបានដូច្នោះ ។
រីឯត្រកូលនឹងចំនើនរុងរឿងដូចឈូកដែលដុះនៅក្នុងស្រះបាន ក៏ព្រោះ
អាស្រ័យមនុស្សនៅក្នុងវង្សត្រកូលនោះមានសាមគ្គីព្រមព្រៀងគ្នា ទោះ
បីអ្នកមានបុទ្ធិអំណាច ក៏គង់ផ្តាញ់អ្នកដែលរួមកំឡាំងគ្នាពុំបាន សូម្បីអ្នក
នោះអន់កម្លាំងជាងក៏ដោយ ។ អ្នកមានបងប្អូនច្រើន ហើយមាន
សាមគ្គីព្រមព្រៀងគ្នា រមែងមានដំហរធំប៉ុន ដូចជាការដុះដាលធំប៉ុន
ឡើងនៃគុម្ពឫស្សីដែលមានបន្ទាដុះដុំវិញ ដែលនរណាក៏ដោយមិនងាយ
នឹងចូលទៅកាប់យកបានដូច្នោះ ។

កាយ វាចា ត្រូវលោក-អ្នកប្រព្រឹត្តឲ្យគួរដល់ឋានៈរបស់បុគ្គល ។ គ្រឿងប្រដាប់សក់ មិនត្រូវយកទៅតុបតែងដើង ឬកងដើងមិនត្រូវយកមកតុបតែងលើសីសៈឡើយ ។ តែរមណីមានដំឡៃច្រើន គួរយកទៅដាំលើផ្ចាំងមាស បើយកទៅដាំលើផ្ចាំងសំណក៏មិនសមនឹងដំឡៃរបស់ពាលបើដូច្នោះ ក៏ដាក់ហុសរបស់ជាងអ្នកធ្វើ, យកកញ្ចក់ទៅដាំនៅមកុដមាស · យកតែរមណីទៅដាំនៅកងដើង យ៉ាងនេះនឹងចាត់ថាជាគោសនៃមាសឬតែរមណីក៏មិនបាន គឺមនុស្សអ្នកប្រើនោះឯងមិនស្គាល់របៀបប្រើនេះយ៉ាងណា អ្នកមិនចេះដាក់ខ្លួនឲ្យត្រូវតាមឋានៈក៏ដូចគ្នា ។ ខ្លួនជាអ្នកគួច ហ៊ានវាយឫកធ្វើជាអ្នកធំកប់ពពក ! ស្ងៀកដណ្តប់ហ៊ឺហាហួសឋានៈ នឹងហួសចំនួនរកបានរបស់ខ្លួន ប្រើមាសច្បាក់បែបដូចជាអ្នករកបានច្រើនណាស់ ឃើញមិត្តកក្តីមានវេយន្តដិះ សូម្បីខ្លួនមិនមានច្បាក់កាស ក៏សុខចិត្តខ្ចីលុយគេទិញ ឬទិញដឹកគេមកដើម្បីឲ្យពេញមុខពេញមាត់ស្មើនឹងមិត្តកក្តី ដែលគេមានទ្រព្យច្រើនជាងខ្លួន ។ បញ្ចេញសិល្បវិជ្ជាដែលខ្លួនមានបន្តិចបន្តួចមកគ្របសង្កត់អ្នកដទៃ ខ្លួនជាអ្នករៀនបានទទួលអាហារូបត្ថម្ភ ឬបានលុយកាក់បន្តិចបន្តួចអំពីមាតាបិតា ហ៊ានស្ងៀកពាក់ស៊ីចាយ ដើរលេងឲ្យហ៊ុកហាក់ស្មើនឹងអ្នកធ្វើការដែលមានប្រាក់ត្រូវច្រើន ឱ ! គួឲ្យចង់សើចណាស់ ! នេះហៅពេញជាមនុស្សមិនចេះដាក់ខ្លួនឲ្យត្រូវនឹងឋានៈ ។

មនុស្សមិនចេះដំកល់ខ្លួនឲ្យសមនឹងឋានៈ តែងប្រព្រឹត្តខ្វះខ្វាននឹងខុសភ្លាត់យ៉ាងនេះ ។ មនុស្សបែបនេះមុខជាបានទទួលសេចក្តីខោមនស្សគួចចិត្ត ព្រោះខុសចំណង់ចង់ច្បាច្បាំតែមខាំងវិបត្តិវិនាសផ្សេង។ ដែលកើតមកអំពីការប្រព្រឹត្តិតាមបែបលង់ខ្លៅរបស់ខ្លួនឯង ។ ព្រោះថាការដំកល់ខ្លួនមិនត្រូវប្តូមិនសមគួរ ដូចយ៉ាងដំកល់ខ្លួនពុកឯងឋានៈខ្ពស់ហួសសាពតិតរបស់ខ្លួនរមែងក្លាយទៅជាការប្រព្រឹត្តរឹងរូសក្រអឺតក្រខមតំកើងខ្លួនចំពោះក្បែកអ្នកដទៃ ។ ការប្រព្រឹត្តដូច្នោះ ក្រៅពីជាគ្រឿងធ្វើខ្លួនឯងឲ្យអាប់ឧន្ទឹងថោកទាបហើយ គង់ជាគ្រឿងទំលាយខ្លួនឲ្យវិនាសផងទៀត ។ ចំណែកការចេះទុកជាក់ខ្លួនឲ្យស្មើឲ្យសមគួរល្មមល្អមើល មិនខ្ពស់ពេក មិនទាបពេក វិមងជាគ្រឿងការពារអ្នកមានឋានៈខ្ពស់មិនឲ្យធ្លាក់ទៅទាប នឹងទំនុកបំរុងផងផ្តើមលើកស្ទួយអ្នកមានឋានៈទាបឲ្យខ្ពស់ឡើងដោយលំដាប់ ចាត់ថា ជាកិត្តិយសដ៏ប្រសើរក្រៃលែង ។

ប្អូរលោក - អ្នកជាក់ទឹកក្នុងត្រឡោក ហើយឈ្លោកឆ្នេះមើលម្ជុខ្លួនឯងខ្លះផង តើជាយ៉ាងណាទៅ?

(មានត)

កណ្ឌទី ១៧

ឧកញ៉ាវិបុលរាជសេនា ង្វ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងឆ្លៀសបើបានអាន
ធំងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ចូរឆូបានស្តាប់ដូច្នោះសើចហើយថា អ្នកនិយាយដូច្នេះយើងក៏ដឹងច្បាស់ហើយ តែនៅបារម្ភក្រែងថាយើងធ្វើការសង្គ្រាមគ្រានេះនឹងមិនដូចពាក្យថា ។ ស៊ុនហុកដំរាបចូរឆូថា ដែលគុយតែនិយាយថាលោកនឹងមានជ័យជំនះអ៊ីនសៀវ ១០ ប្រការនោះ ខ្ញុំបាទយល់ឃើញត្រូវផងព្រោះអ៊ីនសៀវមិនជាអ្នកចេះគិតក្រែនឹ សូម្បីបើមានឥហានច្រើនជាងលោកប៉ុន្មាន ក៏មានតែសេចក្តីចាញ់គំនិតលោកជាប្រាកដ ។ គុយតែឆ្លើយថា ដែលលោកលើកដំកើងលីប៉ោ"ឲ្យធ្វើធំនោះ ខ្ញុំបាទគិតឃើញថាលីប៉ោ"ជាមនុស្សអាក្រក់មិនជាអ្នកស្គាល់គុណអ្នកទាំងពួង សព្វថ្ងៃនេះ លីប៉ោ"

ច្រើនថ្នាក់ទឹងគិតប្រទូសរ៉ាយដល់លោក តែថានៅមិនទាន់មានឧកាស ឧបមាដូចបន្ទាមុតនៅកន្លែងដើមទ្រង់លោក ឥឡូវអ្នកនិងសៀវលើកទៅវាយកន្លែងស៊ុនចាន បើលោកនឹងលើកទ័ពទៅវាយយកស្រុកអ្នកនិងសៀវនឹងបានដោយងាយ តែក្រែងលីចោរដឹងនឹងលើកទ័ពត្រឡប់មកវាយក្រុងហ្គោវិញ ហេតុនេះសូមលោកលើកកងទ័ពទៅកំចាត់លីចោរ ដែលជាសត្រូវនៅទិសបូព៌ាឲ្យរាបទាបហើយ ទើបទ្រង់ទៅវាយយកស្រុកអ្នកនិងសៀវតែម្តងទាន់អ្នកនិងសៀវមិនដឹងខ្លួន ។ ចូរួយល់ឃើញត្រូវក៏ឲ្យទៅប្រមូលសេនាពាហនត្រៀមទុកនឹងលើកទៅវាយយកស្រុកឈីជីវ ។

ស៊ុនម៉ាកដំរាបបូរួថា ដែលលោកនឹងលើកទ័ពទៅនោះ សុំឲ្យមានសំបុត្រទៅប្រាប់ទៀតឲ្យដឹងមុន ឲ្យទៀតជួយគិតកំចាត់លីចោរឲ្យបាន បើមានសំបុត្រទៀតប្តឹងមកដល់លោកជាការមាំមួនប្រាកដហើយ សុំលោកលើកកងទ័ពចេញទៅ ។ ចូរួយល់ឃើញត្រូវ ក៏ធ្វើសំបុត្រតាមពាក្យស៊ុនហុកថា, ហើយឲ្យពាហានកាន់ទៅឲ្យទៀតឯក្រុងសៀវជាយ ហើយតែងព្រះតម្រាស់ព្រះចៅហៀនតេ តាំងឲ្យអ្នកនិងសៀវជាចៅហ្វាយស្រុកគីជីវ ទឹងស្រុកបេងជីវ ស្រុកអ៊ីវជីវ ស្រុកសៀងជីវ ៣ តំបន់នេះឲ្យទៅកន្លែងបង្គាប់បញ្ជាអ្នកនិងសៀវទាំងអស់ ព្រោះអ្នកនិងសៀវមានគុណបំណាច់ល្អកងរាជការ ហើយធ្វើសំបុត្រ ១ ច្បាប់ទៀតជាពាក្យបូរួថា "ឲ្យអ្នកនិងសៀវលើកទ័ពទៅវាយកន្លែងស៊ុនចានចុះ យើងនឹងលើកទ័ពមក

ជួយធ្វើការនោះ" ។ លុះធ្វើសំបុត្រចប់ហើយ ចូរធ្វក់ច្រៃចំរើឲ្យគាន់ទៅឲ្យ
អ្នកសៀវនៅស្រុកគីជីវ ។ អ្នកសៀវទទួលព្រះតម្រាស់ទីឆ សំបុត្រ
ចូរធ្វើមើលដឹងសេចក្តីហើយ ក៏មានចិត្តសោមនស្សត្រេកអរជាខ្លាំងបំផុត ទើប
រៀបចាត់ការប្រមូលសេនាឥឡូវបានច្រើន ហើយលើកកងទ័ពទៅ
វាយកងស៊ុនចានចៅហ្វាយស្រុកចាំកប៉ែង ។

ឯលីចោ"ដែលធ្វើចៅហ្វាយស្រុកឈីជីវនោះ ក៏មានសេចក្តីសុខ
ក្សេមក្សាន្តសប្បាយក្នុងចិត្ត គិតតែរៀបតុះលៀងអាហារសេនា
ឥឡូវជារឿយ ។ ឯគាន់គុយទីឆគាន់តេងក៏ក្លែងចរចាសរសើរលីចោ"ថា
មានបញ្ញាគំរិតចិត្តថ្លៃមក៏ជ្រះថ្លាពន់អានឥឡូវពុកជាការ ទីឆបណ្តាក្រស្តេ
ទួលទៅជាច្រើន ។ គាន់កុងបានឮគាន់គុយទីឆគាន់តេងក្លែងពោលលើក
សរសើរលីចោ"រឿយ ។ ក៏មានសេចក្តីក្រែងចិត្តជាខ្លាំង ។ លុះនៅមក
កងថ្ងៃ ១ នោះគាន់កុងនិយាយទីឆលីចោ"ថា ដែលគាន់គុយទីឆគាន់តេង
និយាយសរសើរលោកនោះ តែត្រឹមបបូរមាត់ក្រៅប៉ុណ្ណោះទេ ឯចិត្ត
គាន់គុយទីឆគាន់តេងតែងគិតរកឧបាយទីឆច្រូសក"យដល់លោកជាជាងប
លោកកុំគប្បីជឿស្តាប់ពាក្យវាគំរិតអាពុកទីឆកូននោះឡើយ បើលោកចេះ
តែជឿវាហើយ អំណើះទៅមុខ លោកក៏ទីឆមានទុក្ខភ័យអន្តរាយជា
ប្រាកដ សុំឲ្យលោកនិះរពឹងឲ្យហ្មត់ចត់កុំធ្វេសប្រហែស ។ លីចោ"ឮ
ដូច្នោះក៏ស្រែកគំហកឲ្យគាន់កុងថា ខ្ញុំឃើញថាយើងមានចិត្តអាណិត

ស្រឡាញ់តាន់គុយតាន់តេង ចានជាខ្លួនឯងមិនសប់ចិត្តមកគិតឬសា
ញុះញង់ឲ្យយើងត្រូវប៉ះធ្លើទោសមនុស្សទៀងត្រង់កុំឲ្យនៅចាន ។

តាន់កុងចានឮដូច្នោះ ក៏ក្រោកដើរចេញហើយដកដង្ហើមធំគិតថា "លីប៉ោ"នេះជាមនុស្សល្អអាប់អត់ប្រាជ្ញា ខ្លួនអញយល់ការថាដោយត្រង់ទៅជាខឹងថាអញអាក្រក់វិញ អំណើះទៅមុខគង់នឹងមានសេចក្តីអន្តរាយដោយទាំងអញផង តែថាបើអញនឹងលះបង់ចោលលីប៉ោដើរទៅរកខែងទាំងពាក់ទៀត ក៏នឹងមានសេចក្តីគរហានិន្ទ" លុះយាត្រាទៅដល់គ្រែហើក៏គិតវិតក្កជាទុក្ខយូរថ្ងៃ ។

កុងថ្ងៃមួយនោះ តាន់កុងក៏នាំបក្សពួកប្រហែល ៤-៥ នាក់ដើរសេះទៅបរបាញ់សត្វក្នុងព្រៃដិតស្រុកសៀវផាយ ឃើញតាហានម្នាក់បំផាយសេះចេញពីស្រុកសៀវផាយទៅ តាន់កុងសង្ស័យក៏នាំបក្សពួកបំផាយសេះតាមស្ទាក់ពីមុខទាន់ ហើយសួរថា នរណាប្រើខ្លួនទៅណាមកណាត្រូវការអ្វី? ។ តាហាននោះក៏ភ័យស្លុតចិត្តព្រោះចាំមុខចានថា តាន់កុងជាតាហានលីប៉ោ" បំរើតាន់សំបុត្រនោះក៏ឆ្លើយច្បាស់មិនរួច ។ តាន់កុងក៏ត្រតគ្នាចាប់យកខ្លួនចានទាំងសំបុត្រ ១ ច្បាប់នាំទៅជូនលីប៉ោ" ។ ក៏ជណ្តឹងសួរថា នរណាឲ្យសំបុត្រនេះមកឯងឯងគាន់យកទៅណា? ។ តាហាននោះខ្លាចមិនអាចនឹងលាក់ទុកចានក៏ឆ្លើយតាមត្រង់ថា មហាឧបរាជប្រើខ្ញុំចាគាន់សំបុត្រទៅឲ្យឡោពីឯស្រុកសៀវផាយ ឡោពីតប

សំបុត្រប្តឹងទៅមហាឧបរាជវិញ សេចក្តីសំបុត្រនោះនិយាយដូចម្តេចខ្ញុំបាទមិនដឹង ។ លីចោ"ក៏ហែកស្រោមសំបុត្រនោះចេញមើលឃើញសេចក្តីថា ខ្ញុំបាទឡៅពីបានដឹងក្នុងសេចក្តីសំបុត្រមហាឧបរាជដែលបំញ្ជូនទៅឲ្យខ្ញុំបាទ ឲ្យជួយរិះគិតកំចាត់លីចោ"ចេញនោះ ខ្លួនខ្ញុំបាទនឹងធ្វើការនោះមិនបានបាន ព្រោះកំឡាំងតាហានតិចជាងលីចោ" បើមហាឧបរាជលើកទ័ពមកកាលណា សឹមខ្ញុំបាទចេញជួយធ្វើការកំចាត់លីចោ" ចេញឲ្យបាន ។

លីចោ"ដឹងក្នុងសំបុត្រដូច្នោះក៏ថា អាចូរនោះវាគិតនឹងធ្វើអញ។ មិនបានកោតខ្លាចវាសោះ ហើយបង្គាប់ឲ្យយកតាហានចូរនោះទៅប្រហារជីវិតបង់ ។ លីចោ"ក៏ប្រើតាន់កុងនឹងបុងចា"ទៅបញ្ចុះបញ្ចូលស៊ុនកួន ១ ងីខុន ១, អ៊ុនឡេ ១, សៀងហ៊ូ ១, ដែលជានាយចោរនៅភ្នំថៃសាន យកមកជាកំឡាំងហើយឲ្យលើកទ័ពទៅវាយខាងទិសបូព៌ា រហូតដល់ស្រុកគុនដីវ ឲ្យកោស៊ុនឡឹងតៀវលៀវលើកទ័ពទៅវាយ ស្រុកសៀវផាយចាប់យកខ្លួនឡៅពីឲ្យបាន ឲ្យស៊ុនហៀនឡឹងដុយសុកលើកទ័ពទៅទិសបស្ចិម រាយយកស្រុកយីអេង តូហានតាំង ៣ កងនោះក៏លើកទៅតាមបង្គាប់លីចោ" ។ ឯខ្លួនលីចោ" ក៏លើកតាហានជាកងទ័ពធំទៅត្រៀមបម្រុងស្តាប់ដំណឹងទ័ពតាំង ៣ កង បើឮថាកងណាខន់ថយនឹងសត្រូវក៏នឹងបានលើកជាទ័ពណូនទៅជួយ ។

(មានត)

រឿងអាវ័ក្សថ្លែងរឿងក្អែកទ្រាំ

លោក រ៉ាយ-ប៊ុក ក្រមការ

ប្រែពីបារាំងមកជាខ្មែរ

(តមក)

រឿងទីម្ភៃ

អាវ័ក្សក្រាបបង្គំទូលថា: បពិត្រមហារាជ! មានព្រះមហាក្សត្រិយ៍មួយអង្គ ទ្រង់ព្រះនាម ពិបុលេសវ៉ារ (Bipuleshvar) សោយរាជសម្បត្តិនៅនគរពិសលបុរៈ (Bisalpur នគរ ពន្លកឈើ) នៅទីនោះមានឧបាសកពាណិជម្នាក់ឈ្មោះអាថ៌ទត្ត (Aarthdatt: អំណោយដ៏ថ្លៃថ្លា), គាត់បានរៀបវិវាហមង្គលការបុត្រីឈ្មោះនាង អនង្គមញ្ជរី (Anangamanjari) ទៅអ្នកជំនួញម្នាក់ឈ្មោះ មុនី នៅនគរ កនវ៉ាលបុរៈ (Kanwalpur) ។

បន្តិចមក លោកមុនីនោះបានចេញចាកគេហដ្ឋាន ធ្វើដំណើរទៅតាមសមុទ្រ ដើម្បីធ្វើពាណិជ្ជកម្ម, នាងអនង្គមញ្ជរីនៅតែម្នាក់ឯង ។ មានកាលមួយថ្ងៃ ក្នុងវេលាព្រឹកនាងនៅលើពន្លាលនៃគេហដ្ឋានបានក្រឡេកមើលទៅតាមផ្លូវ ឃើញព្រាហ្មណ៍យុវនម្នាក់ឈ្មោះ កាមលកវ (KámalaKar) ។ ក្មេកអ្នកទាំងពីរបានជួបប្រទះគ្នាហើយ ក៏កើតមានតណ្ហាច្រើនជួបគ្នាទៅវិញទៅមក ។ លុះកន្លងមួយមោងមក, ព្រាហ្មណ៍កំឡោះនោះ ដោយសេចក្តីឃ្លាតនាងដែលខ្វះនូវស្នេហាអម្បាញ់មិញនេះ

ក៏ទៅសួរមិត្តម្នាក់ដើម្បីបំភ្លេចនូវសេចក្តីស្នេហានេះ ។ ចំណែកនាង អនង្គមញ្ជរីព្រួយពន់ពេក ព្រោះមិនឃើញព្រហ្មណ៍កំឡោះ ទៅជាដួលសន្លប់កាន់តាំងបាត់ស្មារតី ។ តែមានស្រីម្នាក់ជាមិត្តភក្តិមកដល់បានលើកនាងឡើង តែនាងអនង្គមញ្ជរីនៅតែមិនដឹងខ្លួន ។ មិត្តនាងបានប្រោះទឹកកុឡាប, យកទឹកអប់មកឲ្យនាងហិត ។ នាងអនង្គមញ្ជរីបានភ្ញាក់ស្មារតីឡើង ហើយក៏ដេរប្រទេចផ្តាសាកាមថា "ឧកាម! អាទិទេពសិវៈបានធ្វើអ្នកឯងទៅជាផេះ (ក្នុងពេលដែលព្រះអាទិទេពសិវៈកំពុងចម្រើនធម៌, កាមមកធ្វើឲ្យចិត្តភ្ញាល់; ទ្រង់ព្រះក្រោធជាខ្លាំង, ព្រះអាទិទេពសិវៈក្រឡេកទៅកាន់កាម តើតជាអណ្តាតភ្លើងឆាបឆេះកាមទៅជាផេះ ព្រោះហេតុដូចនេះបានជាគេចាត់រូបកាម.ជានាមធម៌) តែអ្នកឯងនៅមិនទាន់ប្រោះបង់នូវចិត្តអកុសល ហើយអ្នកឯងធ្វើទុក្ខធ្វើបាបអ្នកសុចរិត ពុំល្អសោត ។ ដល់នាងពោលពាក្យដូច្នេះ, នាងក៏ស្ងៀតនៅស្ងៀម, យប់ក៏មកដល់, ព្រះចន្ទរះក្តីចាំងចែង ។ នាងក៏ក្រឡេកទៅកាន់ព្រះចន្ទពោលថា: "ឧព្រះចន្ទ! ខ្ញុំបានឮគេថា នៅក្នុងខ្លួនអ្នកមានទឹកអម្រឹតដែលធ្វើឲ្យសត្វមិនស្លាប់ ហើយថាអ្នកឯងតែងបញ្ចេញទឹកអម្រឹតនោះជាមួយនឹងរស្មីអ្នក ។ តែឥឡូវនេះ អ្នកឯងក្រោចមកលើខ្លួនខ្ញុំនូវទុក្ខសោកពុល" ។ រួចនាងក៏ពោលទៅកាន់ស្រីជាមិត្តរបស់នាងថា: "សូមនាងបីយកខ្ញុំចេញពីទីនេះ ព្រោះព្រះចន្ទបញ្ចេញក្តីឆាបឆេះ

ខ្ញុំបាទសព្វសព៌ាង្គកាយខ្ញុំ" ។ ស្រីជាមិត្តបានបីនាងយកទៅដាក់តង់ គេហដ្ឋានសម្រាប់វិស្សាន៍រដូវ ហើយសួរថា: "នាងពោលវាចាបែបនេះ មិនខ្មាសគេទេឬ? ។

នាងអនង្គមញ្ជរីពោលតបទៅវិញថា: "ខ្ញុំពោលតាំងប៉ុន្មាន ខ្ញុំដឹងតាំងអស់ តែតណ្ហាវាយខ្ញុំហើយធ្វើខ្ញុំឲ្យទៅជាស្ត្រីល្ងង់មិនដឹងអ្វីទៅវិញ ។ ខ្ញុំព្យាយាមរក្សាខន្តី តែភ្លើងដែលកើតឡើងមកពីការច្រាសព្រាត់ចាកបរស់ជាទីស្រឡាញ់ពេញចិត្តនេះពេលវាលចិត្តខ្ញុំហើយ គេហដ្ឋាននេះទៅជាដូចនុសថពុល" ។

ស្រីជាមិត្តតបទៅវិញថា: "ចូរនាងស្ងៀតនៅឲ្យស្ងៀម, ខ្ញុំនឹងដេញនូវសេចក្តីទុក្ខចេញពីសន្តានរបស់នាង" ។

នាងឥសីពោលដូចនេះក៏វិលត្រឡប់ទៅគេហដ្ឋានវិញ ។ នាងអនង្គមញ្ជរីក៏គ្រិះរិះក្នុងចិត្តថា. "អញនឹងលះបង់រូបនេះព្រោះសេចក្តីស្នេហាបុរសនេះ, អញនឹងទៅចាប់បដិសន្ធិក្នុងកំណើតខាងមុខ ហើយអញនឹងធ្វើសម្ពន្ធកិច្ចជាមួយនឹងបុរសនេះឲ្យសប្បាយចាំងពីរនាក់" ។ ដល់នាងគិតយ៉ាងនេះ, នាងបានយកវែងចង់ព័ទ្ធជុំវិញក, នាងរៀបនឹងរំតនូវចំណងនោះ, ស្រាប់តែនាងស្រីជាមិត្តមកដល់កន្ត្រាក់វែងចេញពីកនាង ហើយពោលថា: "គេអាចសម្រេចទៅតាមបំណងរបស់ខ្លួនបានលុះត្រាតែខ្លួននោះមានជីវិតរស់នៅ, មិនមែនលះបង់ជីវិតនោះទេ" ។

នាងអនង្គមញ្ជរីតបថា: "គួរតែស្ងាប់ប្រសើរជាង, ខ្ញុំមិនអាចរងទ្រាំទុក្ខលំបាកនេះបានឡើយ" ។

ស្ត្រីជាមិត្តតបទៅវិញថា: "បូរនាងសម្រាកចំនួន ១ ម៉ោងសិន, ចាំខ្ញុំនឹងនាំបុរសដែលនាងស្នេហានោះមកប្រគល់ជូននាង" ។

ស្ត្រីជាមិត្តពោលយ៉ាងនេះ, ហើយក៏ដើរទៅកាន់គេហដ្ឋានតាមលកវ ហើយនាងពួនហើយគ្រេកមើលទៅព្រាហ្មណ៍កំឡោះនោះ ។ តាមលកវ កំពុងអង្គុយកើតទុក្ខវេទន៍ប្រមាណ មានមិត្តម្នាក់បានយកទន្សាយសថមកបិទនៅលើកាយគាត់ លាយទឹមចន្ទន៍ធឹងក្លិនកុង្កុមហើយយកស្ងឹកចេកទន់បក់ឲ្យ ។ តាមលកវជ្រួលជ្រើមកន្ត ចិត្តពន់ពេកដោយក្តៅឥតគន: ដុតពេលមនោទ្វារវង្ខន: កន្ត ការប្រាសព្រាត់ស្រីជាទីស្រឡាញ់របស់ខ្លួន ។ ព្រាហ្មណ៍កំឡោះនោះពោលថា: "បូរអ្នកទៅយកទន្សាយពុលមកឲ្យខ្ញុំៗ ចង់ស្ងាប់ឥឡូវនេះ ដើម្បីឲ្យផុតពីសេចក្តីទុក្ខនេះ" ។ នាងទាសីបានឃើញស្នាមភាពនៃព្រាហ្មណ៍កំឡោះនោះយ៉ាងនេះ នាងគិតថា: "កាមនេះមានកម្លាំងខ្លាំង អាចធ្វើមនុស្សដែលម៉ឺងម៉ាត់មានប្រាជ្ញាឲ្យទៅជាមនុស្សគ្មានថាមភាពក្លាមៗបាន" ។ ដោយនាងបានគិតឃើញបែបនេះ, នាងក៏ស្រែកទៅកាន់តាមលកវថា: "តាមលកវ! នាងអនង្គមញ្ជរីបានពោលថាឲ្យលោកអញ្ជើញទៅជួបនឹងនាង ដើម្បីនឹងឲ្យនាងមានជីវិតរស់នៅតទៅ" ។

កាមលកវតបទៅនាង៣ាសវិញថា: "នាងអនង្គមញ្ជរីជាប្អូនអ្នកឲ្យ
ជីវិតមកខ្ញុំបាន", រួចព្រាហ្មណ៍ក៏ត្រែកឡើង, ដើរតាមនាង៣ាសីនោះ
ទៅ ។ តែដល់ព្រាហ្មណ៍ទៅដល់គេហដ្ឋាននាងអនង្គមញ្ជរីៗ ក៏អនិច្ចកម្ម
កង់ពេលនោះ ។ កាមលកវក៏ដុំស្រែកដួលសន្ធប់ផុតស្មារតីហើយក៏ស្លាប់
កង់ពេលនោះដែរ ។ ពេលបុព្វណ្ហសម័យ, ពួកជនក៏សែងអ្នកទាំង៣ពីរ
នាក់ទៅថ្ងូបដ្ឋានហើយក៏បូជាទៅ ។ កង់ពេលកំពុងបូជាសព, លោក
មុនីជាស្វាមីនាងអនង្គមញ្ជរីក៏វិលត្រឡប់មកពីប្រទេសក្រៅ បានដើរទៅ
កាន់ថ្ងូបដ្ឋាន ។ ដល់ភ្លមនុស្សយំច្រែន នាយពាណិជមុនី ក៏ចូលទៅ
ជិតទីបូជា ហើយក្រឡេកទៅឃើញកិរិយារបស់គាត់កំពុងឱនពោលពាល
ជាមួយបុរសម្នាក់ ។ គាត់ក៏អស់សង្ឃឹម តើតទុក្ខពន់ប្រមាណ សុះ
លោតទៅកណ្តាលភ្លើងស្លាប់ក្នុងពេលនោះទៅ ។ ពួកអ្នកនគរបានឮ
ដំណឹងបែបនេះ ពោលថា: "ក្នែកយើងមិនដែលបានឃើញអច្ឆរិយភាព
សម្បើមបែបនេះទេ, ត្រចៀកយើងក៏មិនដែលបានស្តាប់រឿងពីរោះប្លែក
បែបនេះឡើយ" ។

លុះដល់ថ្ងៃរឿងនេះចប់, អាវ៌ក្សក៏ក្រាបទូលសួរព្រះមហាក្សត្រិយ៍
ថា: "សូមទ្រង់ព្រះមេត្តាប្រោស! អ្នក៣ាំង៣ីរ តើអ្នកណាស្រឡាញ់
នាងអនង្គមញ្ជរីជាងគេ?" ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលថា:
'គឺស្វាមីនាង ស្រឡាញ់នាងជាងគេ" ។

អាវ័ក្សក្រាបបង្គំទូលស្តេចព្រះមហាក្សត្រិយ៍ថា: "សូមទ្រង់ព្រះមេត្តាប្រោស! ព្រោះហេតុអ្វី" ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះពាក្យតបវិញថា: "ព្រោះឃើញកិរិយារបស់ខ្លួនស្ងាប់ដោយសេចក្តីស្នេហាចំពោះបុរសដទៃហើយ, ស្វាមីនាងនៅតែស៊ូបូជាដ៏រឹតដោយប្រាសចាកន្ទួចិត្តទោស: គឺស្វាមីនាងស្រឡាញ់នាងពិតប្រាកដ" ។

អាវ័ក្សបានស្តាប់ព្រះពាក្យតបវិញរបស់ព្រះមហាក្សត្រិយ៍ ក៏វិលត្រឡប់ទៅញុះញង់ខ្លួនទទឹងរុក្ខជាតិសិរិស ។ ព្រះមហាក្សត្រិយ៍ក៏យកអាវ័ក្សលើលែព្រះអង្វាន់យកទៅ ។

ចប់ រឿងទី ២០ មានរឿងទី ២១ តទៅទៀត

ទុក្ខកើតឡើង សុខរលត់

ផ្កាកូឡាបពាប់ពាន់ផ្សាយក្លិនគ្រអូបឈ្ងុយឈ្ងប់ តែបន្ទាប់នៃដើមកូឡាបតែមួយ បើមុត នាំឲ្យឈឺចាប់ ជាត់ធ្ងុំក្លិនគ្រអូបនៃផ្កាកូឡាបពាប់ពាន់; សេចក្តីទុក្ខតែមួយកើតឡើងក៏ឆក់កណ្តាលនៃសេចក្តីសប្បាយរកាយនៃអ្នកមានទ្រព្យច្រើនបណ្តាលឲ្យជាត់សេចក្តីសប្បាយរកាយទាំងនោះ ។

យ. អ.

រឿងចំណេះទិព្យ

អ្នកស្រីសារីយ៉ាន់ ប្រែពីបារាំងមកជាខ្មែរ

(តមក)

– ឧត្តមអនុជ! បងឃើញសេះបាមួយនៅផ្ទះបុរសម្នាក់, បងចង់បានសេះនោះណាស់ បងឲ្យមាស ១ ពាន់ដុំណាហើយ ម្ចាស់វានៅតែពុំព្រមលក់ឲ្យទៀត ហេតុដូច្នេះបានជាបងរកពុទ្ធោ! ។

គ្រានោះ ព្រះអង្គម្ចាស់ អាលី-តេ្លេលុប្ប៉ី ថយចូលទៅកន្លែងបន្ទប់មួយមួយស្របក់ហើយទ្រង់យាងចេញមកវិញ នាំតាំងស្តេចគ្រិស្តសាសនិកដែលមានច្បាក់ច្បាប់ចងព្រះហស្តហើយមានខ្នោះព្រះស្ព័ងមកផង ។ ព្រះអង្គម្ចាស់អាលី-តេ្លេលុប្ប៉ីដើរពីក្រោយ ដល់មកចំពោះព្រះភ័ក្ត្របងតាំងពីរ ទ្រង់ក៏មានព្រះបន្ទូលថា: "ព្រះករុណា! សូមទ្រង់យកស្តេចដែលបងលើកទ័ពមកច្បាំងនឹងព្រះអង្គនេះចុះ" ។ លុះព្រះរាជាបានយល់មនុស្សឈ្លើយមកហើយទ្រង់មានព្រះឧទ្ឃោសថា "ឯងនេះឬ ដែលបងធ្វើបម្រាំងនឹងអញ? តើឯងមិនដឹងថាអញនឹងចាប់ឯងទេឬអ្វី? យី! ឯងនេះថ្មោកជាងសត្វឆ្កែទៅទៀត!" ។ កាលនោះ ស្តេចគ្រិស្តសាសនិកឆ្លើយថា: "គ្រាបទូលព្រះករុណាជាម្ចាស់ជីវិតលើត្បូង! ទូលព្រះបង្គំជាខ្ញុំពុំបានដឹងថា មានអាក្យាខោបំរើព្រះអង្គទេ" ។ បន្ទាប់ពីនោះគេយកអាហារទឹកដឹងមកថ្វាយ ។ ព្រះអង្គម្ចាស់ អាលី-តេ្លេលុប្ប៉ី ទូល

បងបង្ហាប់ថា: "សេះបាទៅកន្លែងសេះទ្រង់ឯណោះ" ។ ព្រះអង្គ
ម្ចាស់ទបពជបានឮដូច្នេះ ទ្រង់ស្ទុះចុះទៅមើលគ្រោល ឃើញសេះទៅ
ទីនោះមែន ទ្រង់មានព្រះទ័យសោមនស្សណាស់ ហើយត្រឡប់មក
អង្គុយជាមួយគ្នាវិញ ព្រមទាំងស្តេចគ្រីស្តសាសនិកផង ។ គ្រានោះ
ព្រះពជាចង់ស្រាយ ច្រាក់ពីព្រះហស្តទំងដោះខ្នោះពីព្រះស៊ូរ៉ែនៃស្តេច
ជាប់ទោស ប៉ុន្តែស្រាយពុំបាន ។ ស្តេចជាប់ទោសមានព្រះបន្ទូលថា
"គ្មាននរណាស្រាយចំណងនេះបានទេ ក្រៅអំពីអ្នកដែលបាននាំទូល
ព្រះបង្គំមក" ។ ស្តេចច្បងទាំងពីរព្រះអង្គនិយាយទៅព្រះអនុជថា:
"ចូរប្អូនស្រាយលែងទៅ" ។ អាលី-គ្នេលប៉ី យកព្រះហស្តទៅជាក់
លើច្រាក់ដែក។ នោះ ក៏រលាចេញហើយខ្នោះនៅព្រះស៊ូរ៉ែនក៏របេះចេញ
រួចក៏នាំរឿងយកមកនិយាយជជែកគ្នាលេង ។ ស្តេចគ្រីស្តសាសនិកទូល
ព្រះពជាថា "ទូលព្រះបង្គំជាខ្ញុំចង់ត្រឡប់ទៅវិញ" ។ ព្រះពជាមានព្រះ
ឧង្ការថា "ចាំយើងឲ្យសេនាជួនដំណើរស្តេចចូលទៅព្រះនគរវិញ" ។

- ក្រោយទូលព្រះកុរណាជាម្ចាស់ជីវិតលើត្បូង គេត្រូវដើរ ៣ ថ្ងៃទើប
ដល់ទៅនគរទូលព្រះបង្គំជាខ្ញុំ ហើយបើសិនជាទូលព្រះបង្គំទៅបាត់តែ
៣ ថ្ងៃ គេនឹងលែងទទួលទូលព្រះបង្គំហើយ គេនឹងបួនហើយកំទេចកំង
ទូលព្រះបង្គំផង ។

ព្រះពជាត្រាស់សួរថា: "តើធ្វើដូចម្តេចទៅ?" ។ ស្តេចគ្រីស្ត
តបព្រះឧង្ការថា: "ត្រូវមុខងារខាងអ្នកដែលនាំទូលព្រះបង្គំមក ទ្រង់នឹង

ជូនទូលព្រះបង្គំទៅវិញ ដ្បិតទូលព្រះបង្គំចុះខសន្យាជានា លើកិត្តិយសជាស្តេចរបស់ទូលព្រះបង្គំ" ។ លុះបានទទួលសំបថហើយ ព្រះរាជាទ្រង់មានបន្ទូលទៅ អាលី - គ្នេលេប៉ូថា "ចូរឯងនាំគេទៅវិញទៅ" ។ ព្រះអង្គម្ចាស់ក៏នាំស្តេចនោះទៅប្រគល់ឲ្យអាវក្បែរមុន ឲ្យនាំត្រឡប់ទៅព្រះនគរវិញ ។

ក្រោយមកស្តេចបង់ពាំង់ពីរអង្គគិតគ្នាថា: "អ្នកដែលអាចនាំស្តេចគ្រីស្តសាសនិកដែលនៅចម្ងាយផ្លូវដើរចំនួន ៣ ខែ ហើយនឹងនាំត្រឡប់ទៅវិញនេះ វានឹងអាចនាំយើង៏ទៅគ្រប់តំបន់បាន តើយើង៏ធ្វើយ៉ាង៏ណាទៅ?" ។ ព្រះរាជាមានព្រះឆន្ទារថា: "យើង៏គិតជប់លៀងទៀត យើង៏ហៅអាលីមកផង ហើយយើង៏នឹងសុំក្រូចនៅស្រុក កាអៀរ "Cha ir" នៅពេលដែលយើង៏កំពុង៏បរិភោគ, បើកាលណាវាចង់ក្រោក ត្រូវយើង៏កុំឲ្យវាក្រោកដើរទៅណា ហើយយើង៏ចាំមើល តើវាធ្វើដូចម្តេច" ។

បង៏បន្ទាប់រៀបជប់លៀង ហើយអញ្ជើញព្រះអង្គម្ចាស់អាលី ។ លុះស្តេចពាំង់បីព្រះអង្គបានសោយចន្ទិចទៅ ស្តេចបង៏ពាំង់ពីរសុំក្រូចដ្បិតនៅក្រុង៏នេះគ្មានសោះ ។ ព្រះអង្គម្ចាស់អាលីធ្វើយថា: "នឹង៏បានមួយរំពេច" ហើយក្រោកឈរឡើង៏ប្រឹង៏នឹង៏ទៅយកក្រូចនោះមកថ្វាយ ប៉ុន្តែព្រះដង្ហាពាំង់ពីរអង្គពុំព្រមឲ្យទ្រង់ទៅណា ។ ព្រះអង្គម្ចាស់អាលីក៏ហូតចិញ្ចៀនពីដៃដាក់ផ្ទាល់នឹង៏ដី ស្រាប់តែមុនបង្ហាញខ្លួនមកភ្លាម

ខ្ញុំក៏បង្គាប់ឲ្យអាកែ្សបំរើទៅយកក្រូច ១ ថាសពីស្រុកគាអៀរ ។ អាកែ្ស
កៀសខ្ជិនបាត់ ១ សន្ទុះ ស្រាប់តែត្រឡប់មកវិញយកចាំងថាស ១ មាន
ក្រូចចំនួន ១០០មកថ្វាយៈស្តេច ហើយទៅវិញបាត់ភ្លាម ។ ស្តេចឮឆ័ងចាំង
ពីព្រះអង្គក៏ជ្រាបនូវគុណធម៌នៃចិត្តខ្ញុំនោះ ប៉ុន្តែខ្ញុំទុកព្រះអង្គធ្វើ
ព្រងើយ ហើយសោយលេងសប្បាយតទៅទៀត ។

ព្រះពជាមានព្រះបន្ទូលទៅព្រះអនុជថា: "បងសូមឲ្យប្អូនធ្វើ
ឲ្យចេញរូបអាកែ្សដែលបំនាក់មកំ ហើយឲ្យមកបំរើយើងដោយកុំផ្ញាស់តែ
ឲ្យសោះ" ។ ព្រះអង្គម្ចាស់ អាលី-ន្តេលេប៊ី ធ្វើយតបព្រះពជនុជ្ញាវថា:
"មិនអ្វីទេ ទូលព្រះបង្គំថ្វាយដោយស្ម័គ្រ" ទើបខ្ញុំជាក់ចិត្តភ្លៀនដូច
កាលសព្វជន ម៉ែមួនមកដល់ភ្លាម ខ្ញុំក៏បង្គាប់តាមពាក្យដែលបង
សុំ ។ ម៉ែមួនទូលថា: "អម្ចាស់អើយ! អាកែ្សបំរើនៅគ្រោយខ្ញុំ
ស្រាប់" ។ ព្រះពជានឹងព្រះអនុជតាំងពីបែរមើលគ្រោយខ្នង ឃើញ
រូបអាកែ្សមួយ ។ ដូចដើមគ្នាត មានមាត់ធំហាក់ដូចជាចង្កែកកំ មានកែក
ដូចក្ងើងចន្ទុះពីរដើម ហើយរន្ទែចមុះហាក់ដូចជាថង់ច្រកទឹកដែលធ្វើអំពី
ស្បែកតពៃ ។ លុះឃើញដូច្នោះព្រះជេដ្ឋាតាំងពីព្រះអង្គគ្រោកស្ទុះត
ហើយខ្ញុំស្រែកប្រាប់ព្រះអនុជថា: "ប្រាប់ឲ្យកំផ្ញាស់តែទៅជា
មនុស្សស្រួលបួលទៅ" ។ ពួកអាកែ្សបំរើផ្ញាស់តែទៅជាមនុស្សបំរើ
យ៉ាងល្អដែលគេតុំដែលប្រទះ តាមព្រះពជបញ្ជា ។ (មានន)

លោក ផេង-ជ្រឿ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

បែរវៀចវៀន

(តមក)

ការដែលដឹងថា វ័ស៊ុនត្រឡប់មកវិញដិតដល់ហើយ ធ្វើឲ្យអាប៉ូលមានកម្លាំងជាថ្មីទៀត ហើយនាំឲ្យវាខំយកចិត្តទុកដាក់ធ្វើការ ។ ហេតុតែកុសល វាកំពុងតែប្រឹងប្រែងខំធ្វើការ ស្រាប់តែមានដំណឹងល្អនាំឲ្យវារីករាយក្រៃពេក ត្រូវនឹងចំណង់របស់វា ។

ព្រឹកឡើងពេលថ្ងៃរះ គឺថ្ងៃ ២៤ ធ្នូ ឆ្នាំ ១៧៤៤ អាប៉ូលក្រោកពីដេក ក្រឡេកទៅឃើញទង់ជ័យសស្គុះដោតនៅលើកំពូលកុំឈ្នោះ ឡាដេគូ-វាក ។ ទង់ជ័យដោតបែបនេះសម្រាប់ឲ្យដំណឹងថាមានឱកាសមួយគេឃើញនៅក្នុងសមុទ្រ ។ អាប៉ូលស្ទុះរត់ទៅផ្សារក្រែងមានសំបុត្រវ័ស៊ុនផ្ញើមក ។ វានៅឆ្ងាយចាំរហូតដល់ (មាត់ឡូ) ម្នាក់ដិះកាណូតទៅសួរដំណឹងឲ្យដឹងតាមច្បាប់ ។ អ្នកនេះ ទាល់តែល្ងាចទើបមកដល់វិញ ។ គេជូនដំណឹងដល់លោកចៅហ្វាយថា នាវានោះឈ្មោះ សាំង-សេរ៉ាំង តែកុងឈ្មោះលោក រូប៉ាំង ចតនៅចម្ងាយ ៦២ គីឡូម៉ែត្រ ទឹងចូលមកដល់តំពង់ពរល្ងៃនៅវេលាព្រឹកស្អែក ពេលថ្ងាយរួច បើមានខ្យល់ស្រួល ។ មាត់ឡូយកសំបុត្រចាំងប៉ុន្មានផ្ញើមកពីប្រទេសថ្មាំងនៅជូនលោកចៅហ្វាយ ។

មានសំបុត្រមួយមកនាងឡាត្ស, អាប៉ូលទទួលសំបុត្រនោះយកមកថើប ដោយស្នេហាយ៉ាងខ្លាំង ហើយកាន់តែយកទៅផ្ទះមួយរំពេច ។ លុះ ក្រែកឃើញក្រុមគ្រួសារវ៉ា អង្គុយឆ៉ៅចាំនៅលើដំបូលថ្មមួយឈ្មោះថ្ម លាគ្នា អាប៉ូលលើកសំបុត្រពីចម្ងាយគ្រវីថ្កាប់ រកនិយាយថាម៉េចមិន កើត ។ ពួកមនុស្សទាំងឡាយមកប្រជុំគ្នាទៅផ្ទះនាងឡាត្ស ចាំស្តាប់គេ មើលសំបុត្រ ។ វ៉ីស៊ីនីថ្កាប់ម៉ែវ៉ាថា ម្តាយមីងវ៉ាចិត្តអាក្រែតពេក ចង់ឲ្យ នាងមានប្តី លុះនាងមិនព្រម គាត់គ្មានចែកទ្រព្យសម្បត្តិអ្វីសោះ ហើយ បញ្ជូននាងមកកងវ៉ូវដែលមានឈ្លើយ មិនចង់ឲ្យនាងមកដល់គោះ ចាំងវិញ ថានាងបានសុំគេមកជាមួយនឹងការណ៍ដែរ តែលោកតែកុង មិនព្រមបើកឲ្យ ព្រោះនៅឆ្ងាយពីកំពង់ពេកហើយសមុទ្រក៏ធំផងត្រង់ កន្លែងនេះខ្លោចបើស្ងប់ឈ្លើយក៏ដោយ ។

គាន់តែមើលសំបុត្រហើយ ក្រុមគ្រួសារសប្បាយចិត្តលោតហក់ កញ្ឆេងស្រែកថា: "វ៉ីស៊ីនីមកដល់ហើយ។" ម្ចាស់ទឹកអ្នកបំរើឧបតិ គ្នាទៅវិញទៅមកដោយសេចក្តីត្រេកអរ ។ នាងឡាត្សថ្កាប់អាប៉ូលថា: "នែកូន! ចូរឯងទៅឲ្យដំណឹងដល់អ្នកជិតខាងថាវ៉ីស៊ីនីមកហើយ" ។ ឱ្យមុំងជុតក្តៅងគប់ក្តាម ហើយពីរនាក់ទឹងអាប៉ូលដើរសំដៅផ្ទះខ្ញុំ (តាថស់) ។

ប្រហែលម៉ោងជប់យប់ ខ្ញុំទើបទឹងលត់ចង្កៀង រៀបដេក ស្រាប់តែឃើញតាមចន្លោះបង្អួច ខ្លាឥន្ធិកងពៃ ។ មិនយូរប៉ុន្មាន

ខ្ញុំឮសូរមាត់អាប៉ូលហៅខ្ញុំ ។ ខ្ញុំក្រោកឡើងកំពុងស្រែកពាក់ អាប៉ូលអរ
តែកបែបក្តៅចខ្លួន ហត់គយូស លោតទុបកខ្ញុំ ហើយទុនខ្សឹបប្រាប់ថា:
"ទៅ! វីរស៊ីនីមកដល់ហើយ! ត្រូវយើងទៅឯកំពង់ផែ នាវាក៏ឡើង
ចូលមកដល់ហើយ" ។

យើងរៀបចំខ្លួនចេញទៅមួយរំពេច ។ វេលាកំពុងដើរធ្លងកៃក្តុ
វែងតាមផ្លូវបុំប្លើមុះសំដៅកំពង់ផែ យើងឮសូរអ្នកណាម្នាក់ដើរពីខាង
ក្រោយ ។ គឺពួងជាតិអ្នកស្រែកអាយម្នាក់ដើរចោះដំហានវែង។ ដើរ
បែបទំ ។ លុះគេមកទាន់យើង ខ្ញុំងាកសួរថា: មកពីណាទៅណា ដើរ
ប្រញាប់អីម្ល៉ះ? ។ គេឆ្លើយថា: "ខ្ញុំមកពីភូមិ ពូត-ឌុរ, គេប្រើខ្ញុំ
មកឲ្យទៅកំពង់ផែ ដំរាបលោកថាហ្វាយពីនាវាមួយដែលមកពីប្រទេស
ជ្វាកំង ចតនៅខាងនាយកោះដំ, គេឮសូរបាញ់កាំភ្លើងហៅមនុស្សទៅ
ជួយ ព្រោះសមុទ្រមិនល្អ" ។ មនុស្សនោះថាតែប៉ុណ្ណោះហើយក៏ទំ
ស្រួតទៅមុខទៀតទៅ ។

ខ្ញុំប្រាប់ទៅអាប៉ូលថា "បើដូច្នោះ យើងត្រូវសំដៅទៅភូមិ ពូត-ឌុរ
វិញ នៅចំពីមុខវីរស៊ីនីប្រហែលបីគីឡូម៉ែត្រទេ ពីនេះទៅ" ។ យើងក៏
ដើរសំដៅទៅកោះបែកទិសខាងដើងវិញ ។ ស្រាប់តែមានចេញចំហាយ
ស្អុះយ៉ាងខ្លាំង ។ ព្រះចន្ទរះផ្លោងឡើង គេឃើញវណ្តមណ្តលបីខ្មៅនៅ
ព័ទ្ធជុំវិញព្រះខែ ។ ដោយពន្លឺរស្មីនៃផ្កែបន្ទោរ គេសំគាល់បានឃើញ

មានពពកភ្លៅវែងលូតបីដួរយ៉ាងក្រាស មិនដាច់ស្រប់ប៉ុន្មាន ដំរួតលើគ្នា
នៅតំលើចំកណ្តាលកោះ ហើយរសាត់មកពីក្នុងសមុទ្រយ៉ាងរហ័ស
ថ្មីដូចមិនឃើញមានឲ្យល់បន្តិចបន្តួចនៅលើដី ។ កំពុងដើរ យើងឮសូរ
ផ្គរលាន់ តែដល់យើងយកត្រចៀកផ្អៀងស្តាប់យកមែនទែន យើងស្គាល់
ជាក់ជាសូរកាំភ្លើងរំពងរំពៃ ។ សូរកាំភ្លើងឮល្អើយៗ ហើយមេឃថែម
ទាំងបំរុងនឹងមានឲ្យល់ព្យុះ ការណ៍នេះនាំឲ្យខ្ញុំចង់ញាក់អីម្ល៉ះទេ ? ខ្ញុំ
ដឿជាក់ច្បាកដជាសូរកាំភ្លើងឲ្យសញ្ញាអំពីនាវាចង់លិច ។ កន្ទុះមៅង
ក្រោយមកបាត់ឮសូរកាំភ្លើង, រឿងស្ងាត់ឈឹងនេះ ធ្វើឲ្យខ្ញុំរឹងរិតតែ
ព្រួយបារម្ភច្រើនជាងឮសូរកាំភ្លើងលើកមុនទៅទៀត ។

យើងបបួលគ្នាខំស្រួតទៅមុខទៀត គ្មានហ៊ាននិយាយគ្នាឡើយ
មិនហ៊ានថ្លែងសេចក្តីព្រួយដល់គ្នានឹងគ្នាទេ ។ ប្រហែលមៅងដប់ពីរយប់
យើងបានដល់មាត់សមុទ្រកងកូមិ ពួត-ឌរ បែកញើសសស្រាក់ ។
រលកទឹកសមុទ្រមកពីនាយបែកសសំពោងកូនព្រាត។ ហូរលិចបាត់ថ្មរហូត
មកប៉ះនឹងច្រាំងឮសូរគ្រុមៗ គួរឲ្យស្ញែបពន់ពេក ។ ខោះបីតែងងឹត
សូន្យឈឹង គង់យើងសំគាល់ឃើញ ដោយសារពន្លឺអម្ពិលអម្ពែកសមុទ្រ
ខ្ចូលខ្ចែកអ្នកនេសាទដែលគេអូសបង្ហើងនៅនាឡាច់ ។

ឆ្ងាយពីយើងបន្តិច ឮដមាត់ត្រៃ គេឃើញភ្លើងមួយមានអ្នកស្រុក
នៅព័ទ្ធជុំវិញ ។ យើងឈប់សម្រាកនៅទីនោះ រង់ចាំព្រឹកឡើង ។

យើងកំពុងតែអង្គុយនៅជិតភ្លើង អ្នកស្រុកម្នាក់និយាយថា: "ពីថ្ងៃរសៀល គេឃើញនាវាមួយនៅកណ្តាលសមុទ្រ បើកសំដៅមកកោះតាមចរន្តទឹកហូរ ដល់វេលាយប់គេមើលមិនឃើញព្រោះងងឹតពេក ប៉ាន់ប្រហែលពីរម៉ោងត្រាយថ្ងៃលិច ក្មួសរបាញ់គាំភ្លើងហៅគេឲ្យទៅជួយ តែទឹកសមុទ្រអាក្រក់ពេក គ្មាននរណាហ៊ានអុំទូកទៅជួយ បន្តិចទៀតឃើញដូចជាមានដុតចង្កៀង បើដូច្នេះ គេខ្លាចក្រែងនាវាមកជិតខាងពេក មិនហ៊ានបើកចន្ទោះច្រាំងនឹងកោះដំ ហើយត្រឡប់យកកោះហ្នឹងជាដម្រុយវិញ ព្រោះនាវាតាំងប៉ុន្មានតែងបើកតាមច្រកហ្នឹងចូលមកកំពង់ផែល្អ បើប្រសិនឯចឹងមែនដូចគេថា គេក៏មិនហ៊ានថាយនោះ នាវាហ្នឹងសមនឹងមានគ្រោះថ្នាក់ធំ" ។ ម្នាក់ទៀតនិយាយឡើងថា: "គេបានឆ្ងល់ត្រង់ច្រកជាចន្ទោះកោះដំនឹងច្រាំងជាច្រើនដង បានវាស់ដំវៅមើលផង ឃើញថាត្រង់ហ្នឹងជ្រៅគួរសម នាវាអាចជ្រកនឹងរលកខ្យល់បាន ដូចជានៅឯកំពង់ផែធម្មតាដែរ" ។ គេនិយាយថែមទៀតថា "ខ្ញុំហ៊ានយកទ្រព្យសម្បត្តិតាំងអស់របស់ខ្ញុំទៅទុកក្នុងនាវានោះ ហើយត្រឡប់មកដេកយ៉ាងស្ងៀមនៅលើគោកឯណេះវិញ" ។ អ្នកឯទីមានវាចាថា "នាវាចូលក្នុងច្រកហ្នឹងមិនបានទេ គ្រាន់តែទូកតូចធម្មតាម៉ែចតង់បើកមិនបាន" ។ គេអះអាងថាបានឃើញនាវាចោះយុថ្កាឆ្ងាយពីកោះដំ ហើយព្រឹកឡើងមានខ្យល់ នាវានោះនឹងចេញទៅក្រៅឬចូលមកផែបាន ។ (មានត)

សកម្មភាពនៃក្រុមជំនុំនៀមទម្ងាប់ខ្មែរ

បរិយាយពីដើមកំណើតមហោស្រព

លោក ប៉ាប-ពិន រៀបរៀង

អស់លោកគាំងឡាយ !

នៅប្រទេសកម្ពុជាយើង មហោស្រពព្រះពុទ្ធឲ្យ នឹងមហោស្រពអ្នកស្រុក គេហៅថា "ល្ខោន" តែនៅប្រទេសជ្វា នឹងសៀម គេហៅថា "ល:ខន" ។

ពាក្យខ្មែរ ថា "ល្ខោន", នឹងពាក្យសៀម ថា "ល:ខន" សរសេរស្រដៀងគ្នា ប្លែកបន្តិចបន្តួចតែខ្យល់អាន, អក្សរធ្មាក់ឆ៍ក៏ប្លែកតែខ្យល់អានដែរ ។

ពាក្យថា "ល្ខោន" ឬថា "ល:ខន" បើតម្រូវទៅតាមក្បាច់គាំងពីកាលនៅយឺតៗ ងាយៗ នៅឡើយ . ទំនងជាមកពីពាក្យជ្វា ថា "ឡាគូ" ដែលប្រែថា "ដើរ" ហើយដោយហេតុខ្មែរ - សៀម - លាវ-ភូមា ធ្លាប់ជាប់ចាក់ទងនឹងទំនៀមទម្ងាប់គ្នាយ៉ាងជិតដិត ទើបក្បាច់មហោ-ស្រពនៃប្រទេសទាំងនេះមានលំនាំស្រដៀងគ្នា ។ ប្រហែលជាមែន, ពីព្រោះពាក្យថា "ល្ខោន" ឬ "ល:ខន" នឹងពាក្យថា "ឡាគូ" មានឫសតែវែជាមួយគ្នាតាំងពីព្រៃឆ៍នាយមក ។

ល្ខោនខ្មែរនឹងលះខនសៀមមិនស្រដៀងគ្នាត្រឹមតែឈ្មោះប៉ុណ្ណោះទេ គឺរហូតទាំងក្បាច់ទាំងជំហាន ទាំងការដើរសើរឿងយកមកលេងទាំងគ្រឿងក្ងេង ទាំងគ្រឿងតុបតែងសម្លៀកបំពាក់ ក៏ស្រដៀងគ្នាដែរ ។

ឃ្លាបន្ថែមដែលយល់ថា ល្ខោន ជាមហោស្រពមានឫសតែរឹតដើមកំណើតជាមួយគ្នា នោះពិតជាត្រូវណាស់ ព្រោះមានដើមកំណើតមកពីឥណ្ឌាទាំងអស់ ដោយមានរឿងល្ខោនផ្សេងៗនឹងក្បាច់រចនាជាច្រើនបែប ដែលគេតាំងនៅក្នុងការតន្ត្រីស្តាស្ត្រ គឺក្បួនរចនាក្នុងរឿងមហាការតយុទ្ធ នឹងការបង្រៀនលែងតណ្ឌៀ ព្រមទាំងនានាប្រទេសដែលនៅក្រោមមហាអំណាចឥណ្ឌាជាសំអាង ។

តាំងពីបុរាណមក ប្រទេសនីមួយៗតែងបន្ថែមគំនិតប្លែកៗ ទៅលើដើមកំណើតនៃវត្ថុនីមួយៗ ហើយសន្សឹមៗកែប្រែខ្លះបន្តិចម្តងៗ ដើម្បីកំណត់គោលរបស់ខ្លួន ។

តាមទំនៀមស្រុក ល្ខោនខ្មែរកើតឡើងតាំងពីរជ្ជកាល ព្រះបាទជ័យវរ្ម័នទី ២ គឺព្រះកេតុមាលា ដែលមានព្រះនាមមួយយ៉ាងទៀតថា "បរមេស្វរៈ" ជាមហាក្សត្រសោយរាជ្យលើកដំបូងបង្អស់នៅអង្គរ ។

រឿងព្រេងដែលនិយាយពីព្រះពជបុត្រនៃព្រះឥន្ទ្រ ជាធំជាងទេវតានៅឋានត្រៃត្រឹង្ស ជារឿងពាក់ព័ន្ធដោយសារតារមហោស្រពដែលនាំឲ្យរឿងនេះល្បីរន្ធឺពេញទូទៅ ។ ហេតុដូច្នេះ ឋានជារឿងដែលពាក់

ទង់ដោយដើមកំណើតព្រះកេតុមាលា ទឹងការកសាងអគ្គ្រ ទៅជាការ
ពិសោធន៍នៃមហាស្រះ ចាំងជាស្នាដៃឫតទ្ធិពលខ្មែរ បញ្ជាក់ឲ្យ
ឃើញ ទី ១ នៅទឹងមហាស្រះ, ទី ២ នៅទឹងគ្រឹះស្ថានសិល្ប: ។

មានរឿងដំណាលថា: ព្រះឥន្ទ្រទង់ចេតនាទិព្វចក្ខុមកឃើញថាព្រះ
អគ្គមហេសីនៃព្រះមហាក្សត្រសោយរាជ្យនៅបុរេសខ្មែរ គ្មានព្រះ
រាជបុត្រដល់មួយព្រះអង្គសោះ, ព្រះឥន្ទ្រមានព្រះទ័យសង្រ្គោះចង់បណ្តុះ
បណ្តាលឲ្យមានព្រះរាជបុត្រា តព្រះរាជសន្តតិវង្ស, ហេតុនេះទើបថ្ងៃ ១
ព្រះឥន្ទ្រទង់ហោះទៅលើអាកាសវេហាស៍ នៅវេលាដែលព្រះរាជ-
អគ្គមហេសីគង់នៅខាងក្រែកព្រះបរមរាជវាំង ។

ជនចាំងឡាយមើលពីដីទៅឃើញព្រះឥន្ទ្រជូបជុំវិស្សីមួយ ក៏នាំគ្នា
ស្រែកថា: "ពន្ធឺ ១ ធ្លាក់! ពន្ធឺ ១ ធ្លាក់!" ហើយព្រះឥន្ទ្រដែលបញ្ជាំង
វិស្សីនោះ ក៏បង្អុរក្លឿងផ្កាស្រោចស្រង់សព្វព្រះកាយនៃព្រះរាជអគ្គ-
មហេសី ។ តាំងពីថ្ងៃនោះមក ព្រះរាជអគ្គមហេសីទ្រង់ព្រះគភ៌ ។
កាលទ្រង់ព្រះសូតព្រះរាជបុត្រ ១ ព្រះអង្គហើយ ព្រះនាងអគ្គមហេសី
ទ្រង់ព្រះរាជទានព្រះនាមថា "ព្រះកេតុមាលា" ប្រែថា "វិស្សីបុជ្ជា"
តាមការណ៍ដែលចាប់ប្រជិសន្ធិជ័អស្ចារ្យនោះ ។

នៅសម័យជដែលនោះ ស្រីទេពអប្សរម្នាក់បានចុះពីឋានសួគ៌មក
បេះផ្កា ៦ ទង់ពីកន្លែងសួនច្បារបស់ចិនអ្នកក្រម្នាក់ ដោយឥតឲ្យនរណា
ឃើញសោះ ។

ព្រោះតែនាងទេពធីតាប្រតិបត្តបណ្ឌិចដូច្នោះ ព្រះឥន្ទ្រទ្រង់ជាក់ណ្តែកម្នាឲ្យនាងចុះមកនៅឋានមនុស្សលោក ធ្វើជាកំរៃយាចិននោះអស់វេលា ៦ ឆ្នាំ ។

នាងទេពធីតាបានប្រសូតបុត្រមួយព្រះអង្គព្រះនាមថា "ព្រះពិស្សការ" តាំងពីកុមារមក ព្រះពិស្សការបុិនប្រសប់ខាងឯការចម្លាក់នឹងគំនូរ ។

កន្លងទៅ ៦ ឆ្នាំ នាងទេពអប្សរវិលត្រឡប់ទៅស្ថានសួគ៌វិញ, មុននឹងវិលត្រឡប់ទៅស្ថានលើ នាងជាក់ផ្កា ៦ទង់លើខ្នើយស្វាមីនាងជាសញ្ញាឲ្យដំណឹងអស់ស្វាមីពីរឿងដែលនាងត្រឡប់ទៅឋានសួគ៌វិញ ។ លុះព្រះពិស្សការមានជន្មាយុ ១០ ឆ្នាំ បានត្រាច់ស្វែងរកមាតាខ្លួន, កាលធ្វើដំណើរទៅជាច្រើនថ្ងៃ អស់កម្លាំងណាស់ ទោអាវជាចអស់ ប៉ុន្តែចេះតែអត់ធ្មត់ ដោយចង់ឃើញមាតា ។ មិនយូរប៉ុន្មាន ព្រះពិស្សការក៏បានជួបនឹងមាតាដូចបំណង ។

នាងទេពធីតា កាលជួបនឹងបុត្រហើយ ក៏នាំទៅថ្វាយព្រះឥន្ទ្រក្សាម, ព្រះឥន្ទ្រទ្រង់ចាត់ឲ្យពួកទេវតាបង្ហាត់ព្រះពិស្សការឲ្យវិជ្ជាសង់ផ្ទះ នឹងតុបតែងលំអផ្ទះ ។

កាលព្រះពិស្សការកំពុងរៀនវិជ្ជាសង់ផ្ទះអំពីពួកទេវតា, ព្រះឥន្ទ្រទ្រង់យាងទៅនាំព្រះកេតុមាលា ជាព្រះពាជបុត្រីព្រះអង្គមកបង្ហាញឋានតាវត្តឹង្ស ទ្រង់ត្រាស់បង្គាប់ឲ្យព្រះកេតុមាលាស្រង់ទឹក ១ ថ្ងៃ ៧ ដង ពីព្រោះទឹកនោះមានគុណធម៌ឲ្យចម្រើនព្រះជន្ម ។

ដោយព្រះកេតុមាលាមានលក្ខណៈជាមនុស្ស ព្រះអង្គមិនអាចគង់នៅឋានតាវត្តឹង្សបានយូរ, ព្រះឥន្ទ្រក៏គ្រាស់បង្គាប់ព្រះកេតុមាលា ទទឹងព្រះពិស្ណុការឲ្យយាងត្រឡប់មកឋានកណ្ដាលវិញ ហើយមានព្រះឫទ្ធានុភាពធ្វើព្រះពិស្ណុការឲ្យសង់ប្រាសាទតាមគំរូប្រាសាទ ដែលព្រះកេតុមាលាទ្រង់ទតឃើញនៅឋានតាវត្តឹង្ស ហើយដែលទ្រង់សព្វព្រះរាជហ្ឫទ័យផង ។

ដោយព្រះទ័យសុភាពរាបសារ ព្រះរាជបុត្រព្រះឥន្ទ្រសុព្ភទ្រះរាជហ្ឫទ័យតឹមប្រាសាទគ្រាលគោប៉ុណ្ណោះ ដូច្នេះ កាលវិលត្រឡប់មកឋានកណ្ដាលវិញ ព្រះពិស្ណុការបានសង់ប្រាសាទមួយល្អវិចិត្រ ដូចប្រាសាទគ្រាលគោនៃព្រះឥន្ទ្រសុទ្ធសោធ ។ ព្រះកេតុមាលាទ្រង់ពេញព្រះហ្ឫទ័យទទឹងប្រាសាទនោះពន់ពេក មិនតែប៉ុណ្ណោះបានត្រាស់បង្គាប់ព្រះពិស្ណុការឲ្យសង់ប្រាសាទមានរំលេចរចនាជាច្រើនទៀត ។ អាស្រ័យហេតុនេះហើយ ទើបកើតក្រុងអង្គរល្អថម្មែក ។

ដល់វេលាធ្វើពិធីព្រះរាជាភិសេកព្រះរាជបុត្រា, ព្រះឥន្ទ្រយាងចុះមកស្ថានមនុស្សលោកម្ដងទៀត ។ នៅឧកាសនោះ ព្រះអង្គទ្រង់ព្រះរាជទានព្រះបរមនាមទី ២ ដល់ព្រះកេតុមាលា ហើយឲ្យហៅនគរនោះជាកម្ពុជាជាប់ដល់សព្វថ្ងៃនេះ ។ ព្រះឥន្ទ្របង្រៀនវិជ្ជាផ្សេងៗ សម្រាប់គ្រប់គ្រងនគរនឹងព្រះរាជទានព្រះខាន់កាយ ដែលធ្វើឲ្យមានទន្លេនគរចំណុះនគរខ្មែរជាច្រើន ទាំងផ្សាយជ័យជោគនៅពេញជុំវិញនគរខ្មែរ ។

ដោយសារព្រះឥន្ទ្រជាន យាងមករៀបចំនគរខ្មែរសម័យអង្គរ ហើយ
ពួកស្រីទេពអប្សរនឹងស្រីស្នែនល្អៗ នៅឋានតាវត្តឹង្សបានប្រគល់ល្បិច
ក្បាច់ស្នែនគ្រប់បែបឲ្យមកខ្មែរ បានជាខ្មែរយើងប្រើសម្រាំកបំពាក់នឹង
គ្រឿងប្រដាប់ស្រីស្នែន តាមការស្រីទេពអប្សរនៅឋានសួគ៌តាំងពី
សម័យអង្គរមក ដរាបដល់សព្វថ្ងៃនេះ ។

យើងសូរើរឿងព្រេងត្រឹមនេះ ដើម្បីអធិប្បាយបញ្ចប់ដើមកំណើត
ស្នែនខ្មែរថែមទៀត ឲ្យជាក់លាក់តទៅ ៖

រជ្ជកាលព្រះបាទជ័យវរ្ម័នទី ២ តាំងនៅក្នុង ឆ្នាំ ៨០២ ដល់ ៨៦៩ ។
ដូច្នេះ ស្នែននោះជាស្នែនចាស់ប្រហែលជាជិត ១១ សតវត្សមក
ហើយ, ទោះបីស្នែនសម័យនោះមិនដូចស្នែនសព្វថ្ងៃសុទ្ធសាធក្តី ក៏គេ
សន្និដ្ឋានបានថាលំនាំតាត់ស្នែនសព្វថ្ងៃ ប្រហែលនឹងលំនាំឬការស្នែន
ក្នុងសតវត្សទី ៩ ឯណោះ ដោយគេបានឃើញនៅប្រាសាទបាយ័នមាន
រូបចម្លាក់លំនាំក្បាច់ព័ន្ធនឹងក្បាច់ស្នែន ដែលស្ត្រីរាំខ្មែរសព្វថ្ងៃយកដំរាប់
តាមសុទ្ធសាធ ។ លំនាំក្បាច់ដែលគេតែងយកមកតាំញឹកញាយ គឺលំនាំ
ក្បាច់កាន់ផ្កា។ កាពាំ ដើងពីរបោះកន្ទែកឆ្ងាយពីគ្នាបន្តិច, ដើងមួយបត់
លើកឡើងផុតពីដី, ដាក់ដៃម្ខាងសណ្តូកតាមភ្លៅ, ដៃម្ខាងទៀតបត់ត្រឹម
កែងដៃ, ឫតដៃទ្រផ្កាឬរំយោលឬផ្កាឈូកមួយទង, មេដៃនឹងចង្អុលដៃ
ដីបក្លាប់គ្នា ម្រាមដៃ ៣ ទៀតពត់ងងាំឃ្លាតឆ្ងាយពីគ្នាបន្តិច ។

ក្បាច់មួយយ៉ាងដែលបង្ហាញឲ្យយើងឃើញញឹកញយ គឺក្បាច់ហោះ ជាក្បាច់គួរពិតពិលរមិលមើល, ប៉ុន្តែច្រើនតែមានលំនាំគ្នាគួរខ្លះ ដោយបញ្ចេញការបត់បែនវិលវង់ហួសខ្នាតឃ្លាតចាកការពិត, តែទោះបីដូច្នោះក៏គេអាចពាប់បញ្ចូលក្បាច់នោះទៅនឹងក្បាច់ផ្កាជាដែលមានរបៀបហោះដូចគ្នា ជាក្បាច់មួយចម្លែក ល្អមើលជាងគេក្នុងចំណោមក្បាច់ល្ងែនទ្បែរ ។

រូបចម្លាក់ទៅច្បាសាទបាយ័ននឹងក្បាច់ចម្លាក់ នៅលើច្បាសាទតាំងឡាយក្នុងអង្គរ មិនមែនធ្វើដណាងក្បាច់ល្ងែនតាំងអស់ទេ, ក្បាច់ដែលធ្វើបង្ហាញឲ្យឃើញតាំងប៉ុន្មាន នោះគ្រាយទៅជាក្បាច់ឯទៀតជាច្រើន, ប៉ុន្តែបើគេសំគាល់ក្បាច់ល្ងែន ដែលមានយកទៅធ្វើជារូបចម្លាក់នោះ គេអាចសន្មតថាការព្យាយាមក្នុងកិច្ចគោរពប្បាប់ដើមមិនចេះអស់ឡើយ ។

គ្រឿងអលង្ការ ដែលស្ត្រីល្ងែនយកមកពាក់ គឺជាគ្រឿងតុបតែងរបស់ពួកស្ត្រីទេពអប្សរ ប៉ុន្តែឯម្ហូបមិនមែនរបស់ស្ត្រីទេពអប្សរទេ លើកតែតំណាត់ដែលយកមកធ្វើជាសំពត់សំឡុយប៉ុណ្ណោះ ។

ឯគ្រឿងតុបតែងនេះ មិនមែនប្រើតាមទំនើងចិត្តអ្នកស្អាងឲ្យទេ គឺដល់ពេលគ្រោយ ទើបគេបន្ថែមសម្ហូបបំពាក់បន្តិចម្តងៗ ទ្បើងទ្បែរ ។ ត្រង់កន្ទែងនេះគ្មានការអ្វីគួរឲ្យឆ្ងល់សោះ ពីព្រោះល្ងែនតាំងស្រុកខ្មែរ តាំងស្រុកដទៃកើតទ្បើងតាំងពីអ្នកស្រុកនៅអាក្រាតនៅទ្បើយ ។

នៅក្នុងសាធុជាតិយើង គេឃើញមានរូបចម្លាក់មួយដំណាក់ជីវភាព ស្ត្រីស្លៀកម្នាក់ គឺរបៀបដុតទឹក របៀបតុបតែងកាយ, របៀបពត់ខ្នងនឹង របៀបហាត់ គួរឲ្យពេញចិត្តចំពោះរូបចម្លាក់មួយនេះខ្លាំងណាស់ ដោយបានធ្វើឲ្យយើងដឹងថាស្ត្រីស្លៀកខ្មែរយើងមានជីវភាពហ្មត់ចត់ ដូចជាស្ត្រីស្លៀកក្រមព្រះរាជទ្រព្យដែលតែងតែប្រកបជីវភាពនោះតរៀងមក ។

ចំណែកម្ហូបតែងប្រកាន់ខ្ជាប់ដោយម៉ឺងម៉ាត់ទូវដើមកំណើត, ច្បាប់ជីវភាពសម្រាប់ស្ត្រីស្លៀន នឹងរបៀបកំសាន ។ តាមមតិរបស់អ្នកចេះដឹងជាតិថៃខ្លះថា នៅប្រទេសកម្ពុជានេះហើយ ដែលកាន់ចំណែមជ័បរិសុទ្ធ ។ គេបានដឹងថាប្រជាជនថៃ ក៏បានធ្វើឲ្យមហោស្រពរបស់គេបានចំរើនណាស់ដែរ ។ ឯមហោស្រពរបស់ខ្មែរយើង ពិតមែនតែយើងមិនចុះបង់ចោលស្មោះ ប៉ុន្តែយើងធ្វេសប្រហែសមិនសូវនិយមអស់រយៈពេលជាយូរណាស់ដែរ គឺក្នុងរវាងសតវត្សរ៍ទី ១៦ ដែលប្រទេសកម្ពុជាកំពុងតុនថយអនុភាព ហើយជល់សតវត្សរ៍ទី ១៧ ខ្មែរយើងទៅយករបៀបមហោស្រពរបស់ខ្លួនពីប្រទេសថៃមកវិញ ដែលគេកំពុងតែរៀបរយមហោស្រពនោះ តាមបំណងរបស់គេ ។ ប៉ុន្តែខ្មែរយើងមិនយកគ្រឹមតែរបៀបល្ខោនមកវិញប៉ុណ្ណោះទេ គឺរហូតដល់ប្រែពាក្យរឿងដែលថៃគេយកទៅលេងល្ខោនផង ។

នៅសម័យនោះ ក៏មានក្រុមល្ខោនប្រុសស្រីក្នុងព្រះបរមរាជវាំងស្តេចនានា. ម្យ៉ាងទៀត ទាសកដើងវត្តខ្លះៗ ដែលបានរក្សាពុក

ខ្ញុំសាស្ត្រាចារឿងភមរកេ្ខ្ត ជាន់ប្រមូលកូនសិស្សលោកបង្កើតធ្វើជាក្រុមល្ខោនខ្មែរ ដើម្បីជាការកំសាន្តខ្លួនឯង និងពួកកូនសិស្សលោក ។ អាស្រ័យហេតុនេះហើយ ទើបចំនៀមក្បាច់ល្ខោនមាននៅសល់ដោយអន្លើ ។ ។

ឯបព្វជិតនៅសម័យនោះកំពាន់វិន័យតឹងតែងណាស់ សូម្បីតែការកំសាន្តបែបនេះ ក៏បព្វជិតឥតជាន់នៅកំសន្តផងទេ ។ ម្ល៉ោះហើយ ក៏បណ្តោយឲ្យឧបាសកម្ពុជាយរបស់កូនសិស្សធ្វើតាមចិត្ត ។

គេមិនសូវដឹងឮច្បាស់ពីការផ្ទាស់ប្តូរពាក្យប្រើក្នុងមហោស្រព, ល្ខោនប្តូរចាំ និងរឿងល្ខោនទេ ។

នៅចុងបូព៌ាប្រទេស មហោស្រពនិងរចាំផ្សេងៗ ដែលលាយឡំគ្នា គេមិនអាចនិយាយពីមួយចោលមួយបានឡើយ ។

ការចាក់ក្បាច់ ដំបូងគ្រា តែជាការសំដែងមនោសញ្ចេតនារបស់មនុស្សប៉ុណ្ណោះទេ ដាច់ក្រោយមកទើបបានគេកាត់រឿង ដែលបានលេងនៅក្នុងព្រះវិហារធំបំផុតរបស់សាសនា ។

សេរីភាពក្នុងការកាត់និងក្នុងគំនិតផ្តើម ចួនកាលចំរែនពីការពិសិដ្ឋទៅជាមិនពិសិដ្ឋវិញក៏មាន, ប៉ុន្តែក្បាច់នៅដូចក្បាច់ដើមដដែល ព្រោះសៀវភៅពិសិដ្ឋបំបត់មហោស្រព និងល្ខោនឲ្យមានច្បាប់ដូចគ្នា ។

ពាក្យមហោស្រពនិងល្ខោន ហៅជាពាក្យសំស្ក្រឹតតែមួយម៉ាត់ថា នាដ្យៈ ។

មុននឹងបង្រៀនមេរៀនមហាស្រុត នៅមានបរិយាយអំពីការមុតច្បាយ
រវស់ស្មោនដែលខ្មែរយើងយកគម្រាប់ពីប្រទេសសៀម ។ អធិប្បាយ
អំពីលីកេ ឬយីកេដែលប្រជាជនច្រើននិយមពាប់អាន ។ យីកេកើតមាន
នៅក្នុងប្រទេសកម្ពុជារវាងពាក់កណ្តាលសតវត្សរ៍ប៉ុណ្ណោះ. ចាំងអាយប៉ែ
ឬអាប៉ែ គឺកើតកងរវាងសតវត្សរ៍នោះដែរ គឺកងធាំ ១៨៧៦ កងរជ្ជកាល
ព្រះបាទនរោត្តម ។

អាប៉ែ គឺជាស្មោនបរទេសមកពីស្រុកសៀម ដែលមានបែបដូចជា
ចម្រៀងផ្តោះផ្តង់នៅប្រទេសលាវ ។

ជួនកាលអាប៉ែនោះ គ្រាន់តែស្រីទង់ប្រុសម្នាក់អង្គុយទល់មុខគ្នា
ច្រៀងចោទឆ្លើយផ្តោះផ្តង់ទៅវិញទៅមក, ជួនកាលមានពួកស្រី-ប្រុស
ជាច្រើននាក់អង្គុយមួយបែកម្ខាងច្រៀងម្នាក់ម្តង។ ពីរឿងអ្វីមួយ ហើយ
ទះដៃធ្វើជាចង្វាក់ក្លេង ។

អាប៉ែ បើកុំឲ្យតែបណ្តាជនដាយកដំកប់តាមចម្រៀងផ្តោះផ្តង់ នៅ
ប្រទេសលាវ ហេយយកមកក្លាយជាចម្រៀងសាសនា គឺជារបាំផ្សំអំពី
យីកេជាន់ដើម ដែលមានដើមកំណើតពីដូរ ទំនុំយស៊ុលម៉ង់ ។ ប៉ុន្តែ
យីកេដូរមិនមែនជារបាំកំសាន្ត ដូចជាអាប៉ែនឹងយីកេនៅស្រុកសៀមទេ
គឺជាចម្រៀងសាសនា ។

របៀបលេង គឺគេធ្វើជាពួកតាបសអង្គុយដំកង់សូត្រធម៌តិចៗ ត្រមគ្នា មានតាបសម្នាក់និយាយរអ៊ូតែម្នាក់ឯង កាត់ធម៌តាបសឯទៀតម្តងៗ ហើយមានពួកផ្សាដែលខ្វះកិច្ចគោរពពោលភាក្យក្រៃអំពីធម៌ បន្ទប់ពាក្យរអ៊ូរបស់តាបសដែលកើតទៅជាការកំផ្លែងចំអន់លេងពិតៗ ទៅវិញ ។ បណ្តាជនសៀមចូលចិត្តនឹងរបៀបកំផ្លែងដូច្នេះ ម្ល៉ោះហើយបើគេមើលយីកេគេគិតតែពីនាំគ្នាសើចមិនចេះស្រាក ។ ឯហេតុដែលយីកេផ្សាកើតទៅជាអាប៉ោសៀម នោះជាការងាយរៀបរាប់ទេ ប៉ុន្តែការដែលធ្វើឲ្យយីកេចំរើនពីសៀមមកខ្មែរទៀត ជាការលំបាកណាស់ទៅវិញ ពីព្រោះយីកេដែលយើងធ្លាប់បានឃើញ គឺជាល្ខោនពិតៗ មានលេងជាច្រើននាក់មានសំលៀកបំពាក់ ចេញចូលក្នុងនាគរាំចាក់ក្បាច់មានក្តេងពិណពាទ្យអមផង មិនមែនច្រៀងផ្តោះផ្តងទេ ។ យីកេជាន់ក្រោយឃើញថាខុស ពីអាប៉ោពីជាន់មុនឆ្ងាយណាស់ ។ ប៉ុន្តែយីកេឬអាប៉ោមានគោលតែពីរមួគ្នា គឺការកំផ្លែងនឹងការស្មូទ្ធស្មាល ។

ចម្រៀងក្នុងអាប៉ោ គ្មានភាក្យពីរោះពីសាថ្លៃថ្លាទេ ពីព្រោះកាលដើមឡើយ អាប៉ោតើតឡើងដោយសារតែពាក្យចំអន់ធម៌តាបសផ្សាលេងប៉ុណ្ណោះ ។

ចំណែកឯយីកេទៅជាល្ខោនមួយបែប ដែលគេយកដំរាប់ពីល្ខោនធម្មតានឹងលំនាំល្ខោនជាតិបរទេសនានា, ក្បាច់ល្ខោននោះច្រើនសម្រាប់

កិរិយាកំផុតកំផែងលែបខាយ សម្រែកបំពាក់ក៏ជ្រែជារបៀបកំផែងវែង, ឯរឿងព្រែនច្របូកច្របល់លាយឡំនឹងរឿងរបស់ជ្វា, កូមា, មាឡាយ៉ា, លាវ, ចិន ។ល។

គេជឿថា: វែលយ៉ីគេលេងរបៀបនេះ គឺជាល្បែងថ្មីទើបនឹងកើតប្រហែលជា ២០០ ឆ្នាំប៉ុណ្ណោះ ។

បរិយាយតាដើមកំណើតមហោស្រពចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

ឥតមរិបាន:

ក្នុងលោកគេស្គាល់ខ្មែរយើងបាន
ដោយហានសិល្បៈអង្គរវត្ត
នឹងដោយមហោស្រពខ្មែរជាតជាតិ
ជាច្រើនសតវត្សរ៍យ៉ាងចំណាន ។
ដូច្នេះ ខ្មែរថ្មីត្រូវរក្សា
មហោស្រពខេមរា នឹងគ្រឹះស្ថាន
សិល្បៈខ្មែរយើងតំបូកណា
ឲ្យបានគង់វង្សរឿងអើយ !

ប. ព.

លោកដុកទ័រគុណាបលៈបិយៈសេនៈម៉ាលាំលៈសេកេរៈ

ជាប្រធានពុទ្ធិកសមាគមពិភពលោក ថ្លែងក្នុងសមាជសាកលលើកទី ២

នៃពុទ្ធសាសនានៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

ពុទ្ធសាសនបណ្ឌិត្យ

(តមក)

ពួកពុទ្ធបរិស័ទត្រូវចេះលៃលកវៀនខាងវិទ្យុនឹងកុន ដើម្បីជាប្រយោជន៍សំខាន់ដល់សាសនារបស់ខ្លួន ។ ព្រោះហេតុដូចនេះ តាំងពីអតីតកាល, ពួកពុទ្ធបរិស័ទមួយៗ តែងឃោសនាផ្សាយព្រះបរមពុទ្ធោវាទទៅប្រទេសនានាៗ ខ្លួន, ឥឡូវនេះពួកនេះ ត្រូវព្រួតដៃគ្នាព្យាយាមឃោសនាផ្សាយព្រះពុទ្ធសាសនា ដោយមធ្យោបាយវេងជាតិ ។ បានន័យថា ត្រូវតែយើងប្រឹងប្រែងឃោសនាផ្សាយព្រះធម៌ឲ្យបានឆ្ងាយទូលាយ ព្រមទាំងធ្វើសកម្មភាពឲ្យបានខ្ជាប់ខ្ជួនជាងមុនទៅទៀត ។ មធ្យោបាយក្នុងការឃោសនា ត្រូវយកទៅប្រើតាមវត្ថុបំណងនេះដោយគតិបណ្ឌិត ព្រមទាំងសន្និច្ឆយ ។ ដូចជាវឿងកំលោនដែលមានក្នុងផែនការណ៍អបរំមនុស្ស ផ្សែងពីទីនេះបានបង្ហាញដោយជាក់លាក់ទៅ

ផលដ៏ប្រសើរ ហើយត្រូវតែយកមកលេងដោយប្រយ័ត្នមាំមួន ព្រោះថា មានពុទ្ធសាសនិកជនជាច្រើនយល់ថា ពួកបុគ្គលិកពិសិដ្ឋមិនត្រូវឲ្យបុគ្គលសាមញ្ញ យកមកត្រដាងបង្ហាញនៅលើវិការដ្ឋាន ។ បុគ្គលសាមញ្ញនេះមានសិទ្ធិតែមួយយ៉ាង គឺបង្ហាញនូវសេចក្តីប៉ុនប្រសប់របស់ខ្លួនក្នុងការរាំច្រៀងប៉ុណ្ណោះ ។ នេះគឺជានិយដែលត្រូវគោរពខានមិនបាន ។

ក្រុមពុទ្ធសាសនា

ការអប់រំនូវធម្មទូត មានហេតុបច្ច័យជាក់ខ្លឹងនឹងការយោសនាជានិច្ច ។ ត្រូវជ្រាបថា ព្រះពុទ្ធសាសនាជាសាសនាដែលបានចាត់ពួកបេសកធម្មទូតទៅផ្សាយក្នុងពិភពលោកមុនគេ ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់បានទេសនាទូន្មានប្រដៅយើងឲ្យគប់គ្នាឲ្យនាំព្រះពុទ្ធោវាទ ទៅពន្យល់សត្វលោកគ្រប់ទីកន្លែង ដើម្បីជាសារៈប្រយោជន៍ដល់ទៅនឹងមនុស្សទាំងឡាយ ។ ពួកធម្មទូតមិនអាចបំពេញនូវសាសនកិច្ចឲ្យបានផលដ៏ល្អទេ បើខ្លួនមិនបានអប់រំជាមុនឲ្យមានវិជ្ជាគ្រប់គ្រាន់ ដើម្បីនឹងដំណើរការនោះឲ្យបានស្រួល, ឥឡូវនេះ សកម្មភាពនៃពួកធម្មទូត ស្ថិតនៅតែត្រឹមទ្វីបអាស៊ី បើយើងគិតជាមុនត្រង់ឥតសកម្មភាពឲ្យបានឆ្ងាយទូលាយតទៅទៀត មានបញ្ហាសំខាន់ៗត្រូវយកមកវិនិច្ឆ័យដោយហ្មត់ចត់ គឺភោជនាហារ, សំលៀកបំពាក់ ដោយហេតុអាកាសជាតុមានសភាព

ផ្សេងគ្នា ព្រមទាំងលែលកកង្វក់ការប្រែប្រួលប្រតិបត្តិ ជាយ៉ាងម៉ឺងម៉ាត់ ទៅតាមវិធានការនៃវិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាប្រដៅ ដូចជាការកាន់ប្រាក់ជាដើម ។ នេះត្រូវយល់ថាពួកធម្មទូតជាសមាជិក នៃព្រះសង្ឃ ។ បើតាមយោបល់បស់ខ្ញុំ មិនអាចមានវិចារណញ្ញាណ ណានឹងធ្វើដូចនេះបាន ហើយចំពោះខ្លួនខ្ញុំ។ សូមស្នើអំពីការស្នាបនាទូត ក្រមទូតជាថ្មីដែលមិនត្រូវប្រតិបត្តិតឹងរឹង ទៅតាមបំណងនៃសាសនា ដូចជាព្រះកិម្ពុ ខ្ញុំសូមស្នើរឿងនេះ សូមព្រះតេជព្រះគុណលោកអ្នក ជួយពិនិត្យ ។

ខ្ញុំអាចប្រគេន ឬដូនយោបល់ដូចគ្នា អំពីសកម្មភាពនៃមនុស្ស ជាតិ, សង្គមនឹងការអប់រំខាងព្រះពុទ្ធសាសនា ។ នៅប្រទេសដែល កាន់ព្រះពុទ្ធសាសនាមហាយាន ដែលគេទុកទុត្តមគតិនៃព្រះពោធិសត្វ ជាឧត្តុង្គ, មិនមានអ្នកណាមួយអាចយល់ផ្លូវនឹងការណ៍ដែលព្រះកិម្ពុ សាមណេរបានចូលទៅធ្វើសកម្មភាពបែបនេះ តែវិន័យខាងគណៈពុទ្ធ-សាសនាថេរវាទហាមមិនឲ្យធ្វើជាដាច់ខាត ។ ព្រោះហេតុដូចនេះ ក្នុងសម័យនេះបានជានៅប្រទេស ដែលនិយមកាន់ព្រះពុទ្ធសាសនាជា ច្រើន, ការបង្កើតទូរស្ទាប័ន សម្រាប់ជួយសង្គ្រោះដល់អ្នកគ្រុំប្រាក់ ដូចជាគេហដ្ឋានសម្រាប់កូនកំព្រា, មន្ទីរពេទ្យចាលក្មេងក្រ, មនុស្ស ចាស់ជរា, មនុស្សពិការ, មនុស្សខ្វះក្បែរហើយខ្វាក់ខ្វិន ធ្លាក់ទៅលើ

អ្នកដែលមិនបានកាន់ព្រះពុទ្ធសាសនា ។ មិនចាំបាច់ស្វែងរកនូវវិចារ-ណញ្ញាណក្នុងគោលការណ៍ទេ តែត្រូវជ្រាបជាមុនថា ព្រះពុទ្ធសាសនាពីបឋមសម័យ អាចមានប្រពៃណីល្អ ប្រកបដោយមនុស្សធម៌ (សប្បុរសជាលក្ខណៈ) ។ យើងបានដឹងច្បាស់អស់គ្នាថា ព្រះសម្មាសម្ពុទ្ធទ្រង់បានបញ្ចាប់ថែរក្សាកិក្ខុអាពាធមួយមគ្គ ដែលមានកាយសុទ្ធតែរមាស់ ហើយទ្រង់បានត្រាស់ បង្គាប់ឲ្យ។ អាហារបរិភោគ ចំពោះមនុស្សឃ្លានមុនទើបឲ្យមនុស្សនេះចូលមកស្តាប់ព្រះសទ្ធម្មវិសេសទេសនា; មែនហើយ, ហើយព្រះអង្គទ្រង់បានប្រគល់សេចក្តីថ្លៃថ្នូរឲ្យនាងពេស្យាម្នាក់ដោយឲ្យអ្នកឯទៀត ពុកថាស្ត្រីនោះជាមនុស្សជាតិ មិនមែនជាស្ត្រីមណ្ឌលថោកទាបទេ ។ តើយើងអាចមានទស្សនៈអ្វីប្រកបដោយអតិជនភាពជាងនេះទៅទៀតឬ?

អ្នកបានជ្រាបឬទេ ពីកាលព្រះមជ្ឈិមជអរសោក បានស្ថាបនាមន្ទីរព្យាបាលនឹងជដិសរណាដ្ឋាន, មិនចំពោះតែមនុស្សទេ ថែមទាំងសត្វតិរច្ឆានផង ។ ប្រហែល ១ ៦០០ ឆ្នាំមកហើយ ព្រះមហាក្សត្រិយ៍ប្រទេសស៊ីឡង់មួយអង្គ ទ្រង់បានតែងតាំងពិសេសនូវគ្រូពេទ្យ សំរាប់មើលថែរក្សាជំរឹ, សេះ គ្រែពីបដិសរណាដ្ឋានដែលទ្រង់បានបង្កើតសំរាប់ពួកកិក្ខុពិការ, ពួកខ្វិនទើងពួកអ្នកដំណើរតាមផ្លូវឆ្ងាយ ។

ពិធីបុណ្យស្រោចទឹកព្រះសង្ឃប៊ីអង្គ

ជាមន្ត្រីសង្ឃ កុងវត្តព្រះព្រហ្មរតន៍ ខែត្រសៀមរាប

ព្រះអាចារ្យ ឈុយ-រិន (ធម្មលិក្ខិតោ) ធម្មកោសលទោ

គ្រូបង្រៀនសាលាបំពេញវិជ្ជាធម្មវិន័យ

រៀបរៀង

កាលពីថ្ងៃ ១៦-១៣ ១៤ កេច ខែដែស្ដ ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៨៦ គឺថ្ងៃទី ៨ ៩ ១០ ខែមិថុនា គ.ស ១៩៤៣, ក្នុងវត្តព្រះព្រហ្មរតន៍ ខែត្រសៀមរាប មានពិធីបុណ្យមួយជាមហោឡារិក គឺបុណ្យសម្ពោធទួលសញ្ញាប័ត្រ ស្រោចទឹកព្រះគ្រូបាសាធម្មី កែ-អឿន (វិរិយប្បញ្ញោ) ដែលឡើងទីជាអនុគណ, លោកគ្រូ សែម-វ៉ាន (ធម្មជោតត្ថេរ) ដែលឡើងទីជាចៅអធិការ នឹងលោកគ្រូ ឈឺន ញ៉ូង (បញ្ញាសិរី) ដែលឡើងទីជាអនុលេខាធិការនៃអនុគណ ។ ឯពិធីបុណ្យនោះដូចមានសេចក្ដីខាងក្រោមនេះ :

ក្លោងទ្វារធំខាងមុខវត្ត

នៅក្លោងទ្វារធំ មានតាក់តែងដោយអំពូលក្លែងអគ្គិសនីធំ-តូចជាច្រើន នឹងជោតទង់ជាតិទង់សាសនា, នៅចំកណ្ដាលក្លោងទ្វារមានចារឹកអក្សរដោយផ្ទាំងសំពត់ថា "បុណ្យស្រោចទឹកព្រះគ្រូអនុគណ នឹង

បៀអធិការ" ។ បន្ទាប់អំពីក្លោងទ្វារមក មានចង្កេតដ៏ជាតិខ្សែវែងតាម
សងខាងផ្លូវ. នៅតាមសសរមួយៗ ចង្កេតដ៏ជាតិដ៏សាសនាធំៗ ដរាប
ដល់យ៉ាមុខព្រះវិហារ ។

យ៉ាមុខព្រះវិហារ

នៅយ៉ាមុខព្រះវិហារ · មានរៀបគ្រឿងសក្ការបូជាថ្វាយចំពោះព្រះ
រតនត្រ័យ នឹងចង្កេតដ៏ជាតិដ៏សាសនា រំយោលផ្កាគ្រជាស្រគែបពណ៌
ជាក់អំពូលភ្លើងធំ · តូចវែងខ្ចប់ពេញរស្មីភ្លឺនាលក្នុងវេលាយប់ ។ នៅ
មុខទ្វារធំព្រះវិហារសងខាង · មានរៀបគ្រឿងតាំងតុដាក់ព្រះពុទ្ធរូប
កញ្ចក់ធំពីរលើតុនោះ នឹងគ្រឿងសក្ការៈផ្សេងៗ ។ នៅចំកណ្តាលយ៉ា
គ្រាលកន្ទេលចៀមចំពែព្រំនឹងកៅអីជាដួរៗ, ផ្នែកខាងត្បូង សម្រាប់
ទទួលបដិសណ្ឋារៈចំពោះព្រះ·រុណាជាម្ចាស់ជីវិត ស្តេចយាងទៅជាព្រះ
ពជាធិបតី នឹងឥស្សរជនជាច្រើនដែលហែហមព្រះអង្គទៅ, ផ្នែកខាង
ជើង សម្រាប់ព្រះសង្ឃដែលមានសមណសក្តិ មានព្រះតេជព្រះគុណ
ព្រះមុនីគោសលមេគណខែត្រចាត់ដំបង់ជាដើម នឹងកុដែលត្រូវទទួល
សមណសក្តិថ្មី ។ នៅត្រង់ចន្លោះកណ្តាលមានតុមួយគ្រាលកម្រាលដ៏
ស្អាត ដាក់តោកដាំឈើពីរជាន់ រចនាដោយផ្កាស្រស់ៗចំរុះពណ៌ផ្សេងៗ
ដំកល់សញ្ញាប័ត្រ ។ នៅចំកណ្តាលទ្វារធំព្រះវិហារ មានតុតូចមួយ
គ្រាលកម្រាលដ៏ស្អាត ដំកល់តោកដាំឈើមួយ រចនាដោយផ្កាស្រស់ៗ

បិទខៀន ៥ ផ្ទប ៥ ជាគ្រឿងសក្ការបូជា សម្រាប់ព្រះគុណជាម្ចាស់ ជីវិតបូជានមស្សការព្រះរតនត្រ័យ, នៅខាងៗ ក្រាលកន្ទេលសម្រាប់ពុទ្ធបរិស័ទ ។

បារាំនៅខាងមុខព្រះវិហារ

នៅខាងមុខយ៉ាព្រះវិហារមានធ្វើបារាំ ១ ខ្នង បណ្តាយ ៦ ម៉ែត្រ ទទឹង ៤ ម៉ែត្រ កំពស់ ៥ ម៉ែត្រ ខាងលើពាសដោយសំពត់ឆត្រ. នៅសសរទីមួយ ។ សុទ្ធតែស្រោបដោយស្លឹកដៃគ្រមទឹងកម្រងផ្កាឈើស្លឹកដៃគ្រមស្លឹកច័ន្ទន៍ ចងព័ទ្ធខ្សែខ្នងជាក្រឡាសំណាញ់ ទឹងផ្កាវែយលផ្កាក្រដាសជាច្រើន, នៅខាងលើដុំវិញបារាំ ពាយសំពត់រៃសណ្តានទង់ជាតិសំយុងចុះមក, នៅក្រោមសំពត់រៃនោះពាយខ្សែក្រងឹងអគិសនីមានអំពូលគ្រប់ពណ៌ជាច្រើនព័ទ្ធដុំវិញ ។ នៅកណ្តាលបារាំនោះមានធ្វើបុស្សក ១ កំពស់ ៥ ម៉ែត្រ ទំហំ ១ ម៉ែត្រកន្ទុះដុំវិញ សម្រាប់ស្រោចទឹកអនុគណ - ចៅអធិការ - អនុលេខាធិការថ្នៃ ។ បុស្សកនោះប្រដាប់រចនាវិចិត្រដោយផ្កាឈើស្រស់ទឹងអំពូលភ្លើងតូចៗ បញ្ចេញរស្មីខៀវ - លឿង - ក្រហម - ស ។ នៅថ្នាក់កណ្តាលទឹងថ្នាក់ក្រោមរៀបធើងផ្កាឈើដុំវិញ, ថ្នាក់កណ្តាលខាងមុខសងខាង ដម្កល់ពានទានតីរសម្រាប់ដាក់ទឹកមន្តស្រោចព្រំ, នៅមុខសងខាងបុស្សក មានតុតូចពីរតាំងគ្រឿងសក្ការៈ, ត្រង់កណ្តាល មានជណ្តើរបួនកាំបី សម្រាប់ឡើងទៅលើបុស្សក ។

ថ្ងៃទី ១ គឺថ្ងៃទី ៨ ខែមិថុនា ព. ស. ២៤៨៦

មោ៉ង ៨ យប់ទិមន្តព្រះសង្ឃចំរើនព្រះពុទ្ធមន្ត ទំនង់ទិមន្តព្រះតេជព្រះគុណ ព្រះមុនីកោសល មេគណវត្តពោធិវាល ខែត្រចាត់ដំបន់សំដែងធម៌ទេសនាលើបុស្បក ។

មោ៉ង ១១ បំបួសនាគ ។

ថ្ងៃទី ២ គឺថ្ងៃទី ៩ ខែមិថុនា ព. ស. ២៤៨៦

មោ៉ង ៨ កន្ទុះព្រឹក ព្រះសង្ឃចាំឆាយ មានព្រះតេជព្រះគុណមុនីកោសលជាប្រធានទំនង់ពុទ្ធបរិស័ទជារួចន ដួបជុំរង់ចាំទទួលព្រះប្រិយមហាក្សត្រិយ៍ ទំនង់ឥស្សរជនដែលហែហមព្រះអង្គ ទំនង់មន្ត្រីកងខែត្រ ។

មោ៉ង ១០ កន្ទុះ ព្រះករុណាជាម្ចាស់ជីវិតស្តេចយាងទៅដល់ ក្រុមភ្លេងលេងភ្លេងនគរាជថ្វាយ, លុះស្តេចយាងដល់ហើយ គង់ប្រថាប់លើព្រះទីនាំងកៅអី ។ បន្ទាប់ពីនោះមក ទុចាសកខ្មែរ រឿន ប៊ុនវឿន ដំកល់លើដើងពានកែវ យកទៅថ្វាយព្រះករុណា ។ ទ្រង់ប្រទានព្រះអគ្គីហើយទុចាសកនោះទទួលយកទៅបូជាព្រះរតនត្រ័យ ។ តមកព្រះតេជព្រះគុណព្រះមុនីកោសលឆ្លើមសូត្រជយន្តោថ្វាយព្រះពរជយមង្គល ព្រះសង្ឃចាំងអស់ក៏ទទួលសូត្រទ្រហឹងអឺងកងឡើង ។ លុះចប់ហើយ

ព្រះតេជព្រះគុណ ព្រះមុនីកោសល ថ្លែងសេចក្តី ទទួលអំណរព្រះប្រិយ-
មហាក្សត្រ ដែលស្តេចឈ្វេតយាងមកជា ព្រះពាជាធិបតី ហើយសូត្រ
អានសញ្ញាបំត្រតាំង ៣ នោះ រួចព្រះកុណា ប្រគេនសញ្ញាប័ត្រដល់គ្រូ
តាំង ៣ រូប ។ តពីនោះមក ព្រះអាចារ្យ កែវ អ៊ីវ ថ្លែងសេចក្តីទទួល
អំណរថ្វាយ ព្រះពាជកុសលទឹងអធិប្បាយអំពីកិច្ចផ្សេងៗទៀត ចប់ហើយ
ព្រះគ្រូអនុគណថ្មី លោកគ្រូចៅអធិការថ្មី ទឹងលោកគ្រូអនុលេខាធិការ
ថ្មីឡើងកាន់បុស្បក ព្រះកុណាឡើងតាមក្រោយ ទើបៗថ្វាសកគុយ-
ច្រៀកយកផ្តិលច្រាក់ជាក់សុគន្ធព្រីថ្វាយព្រះកុណា ។ ទ្រង់ច្រិះ
សុគន្ធព្រីនោះលើព្រះហស្តព្រះគ្រូអនុគណ - លោកគ្រូចៅអធិការ ទឹង
លោកគ្រូអនុលេខាធិការ ទ្រង់មានព្រះពាជឧង្ការប្រទានពរថា: " សូម
ឲ្យព្រះកុណាំ តាំង ៣ អង្គបានប្រកបដោយសេចក្តីសុខ ទឹងសេចក្តីចំរើន
អស់កាលជាយូរអង្វែង " ។ ព្រះសង្ឃតាំងអស់សូត្រជយន្តោប្រគេន
ពរដល់ព្រះគ្រូអនុគណ - ចៅអធិការ ទឹងអនុលេខាធិការ ។ បន្ទាប់មក
ព្រះតេជព្រះគុណ ព្រះមុនីកោសលឡើងកាន់បុស្បក ច្រៀកសុគន្ធព្រីម្តង
ទៀតដល់ព្រះគ្រូអនុគណ - ចៅអធិការ - អនុលេខាធិការ ។ រួចកិច្ចនេះ
សព្វគ្រប់ហើយ ព្រះកុណាស្តេចយាងត្រឡប់វិញ ។

មោ៉ង ១២ ប្រគេនកត្តាហារចំពោះព្រះសង្ឃ ។

មោ៉ង ៨ យប់ និមន្តព្រះសង្ឃចំរើនព្រះបរិត្ត រួចនិមន្តព្រះអាចារ្យ
កែវ អ៊ីវ សំដែងធម្មទេសនា ។

ថ្ងៃទី ៣ គឺថ្ងៃទី ១០ ខែមិថុនា ព. ស. ២៤៩៦

ម៉ោង ១១ និមន្តព្រះសង្ឃសូត្រឥហូវេលាធ្វើ ហើយប្រគេនកត្តាហារ, ម៉ោង ៨ យប់និមន្តព្រះវិន័យធរ ឯក-ញឹម សំដែងធម៌ទេសនា សម្រេចកិច្ចបុណ្យតែប៉ុណ្ណោះ ។

វត្តព្រះពុទ្ធវត្តន៍កន្លងពេលនេះមានភ័ព្វគាប់ប្រសើរជាងពេលណា ។ ទៅទៀត ព្រោះកន្លងពិធីបុណ្យណា ។ មិនដែលបានព្រះករុណាជាម្ចាស់ដ៏វិតស្តេចយាងមកជាព្រះពាជាធិបតីទេ ទើបតែកន្លងពិធីបុណ្យនេះ បានស្តេចទ្រង់យាងមកជាសិរីសួស្តីជយមង្គល ។

យើងខ្ញុំព្រះអង្គជាក្រុមពុទ្ធបរិស័ទចាំងបពូជតាំងគ្រហស្ថ មានសេចក្តីសោមនស្សចំពោះព្រះគុណាតិរេកជាយ៉ាងក្រៃលែង ទីឯរកវត្ថុអ្វីក្នុងលោកប្រៀបផ្ទឹមស្មើពុំបាន ។

យើងខ្ញុំព្រះអង្គសូមនូវិសកុសលបុញ្ញភាសីកន្លងពេលនេះ ថ្វាយចំពោះព្រះប្រិយមហាក្សត្រ សូមឲ្យទ្រង់ស្ថិតកន្លងព្រះសិរីរាជសម្បត្តិខ្ចាត់កយាជាសុខសាន្ត សម្បាន្តកន្លងព្រះកាយពល ចាំងមានព្រះជន្មាយុយឺនយូរ ព្រមចាំងមានព្រះតេជានុភាពច្រើន អស់កាលជាយូរអង្វែងទៅហោង ។

តាំងជាសទ្ធិយោ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៥ ខែកញ្ញា លេខ ៩

ព. ស. ២៤៩៦ – គ. ស. ១៩៥៣



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— សារាណីយធម៌	ព្រះមហាថាច់ - សើរឹង	៦៤៣
— កបិនកថា (តមក)	ព្រះមហាឧត្តមវិជ្ជា កែ - អឿន ...	៦៥៦
— ខ្លួនមនុស្សទុកដូចជាឆ្នាំង	លោក សុិន — ហ៊ាន	៦៦៥
ផ្នែកអក្សរសាស្ត្រ		
— ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៊ម ...	៦៦៩
— រឿងសាមកុក (តមក)	ឧកញ៉ា ឌួ - កន	៦៧៥
— រឿងអារ៍ក្សរថ្លែងរឿងម្តែប្រាំ (តមក) ...	លោក វ៉ាយ - ប៊ុក	៦៨៦
— រឿងចិញ្ចៀនទិព្យ (តមក)	អ្នកស្រីសារីយ៉ាន់	៦៩០
— រឿងប៊ូលនិងវីរ៉ស៊ីនី (តមក)	លោក ផេង - ជ្រើរ	៦៩៥
— សកម្មភាពនៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរ បរិយាយពីដើមកំណើតរឿងរាមកេ្តរ៌ ...	លោកចាប - ពិន	៧០៣
កំណត់ទឹនប្រវត្តិការណ៍		
— សុន្ទរកថាបណ្ឌិតម៉ាល៉ាឡ័ៈសេកេរៈថ្លែងក្នុង សមាជសាកលលើកទី ២ នៃពុទ្ធសាសនា	(តមក) ពុទ្ធសាសនបណ្ឌិត្យ ...	៧១៤

មួយឆ្នាំមាន ១២ ក្បៀវភៅ — ដំឡៃជាវ ១៩២រ. ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE		Pages
— Saraniyadharma	*Brah Maha THACH-SOEUNG*	643
— Kathinakatha (suite).....	*Brah Maha KER-ŒURN*	656
— L'homme est comparable à une marmite	*M. SIN-.HEAN*.....	665
PARTIE LITTERAIRE		
— Education morale (suite) . .	*Brah Maha PEUNG-PÁM* . . .	669
— Histoire de SAMŒOK (suite)..	*Oknha NOU-KAN*	675
— Les vingt cinq récits du Mauvais Génie (suite)	*M. RAY-BUC*	686
— La bague magique (suite)....	*Mme SARIS- YANN*.....	690
— Paul et Virginie (suite)	*M. PHÉNG-CHRIEU*	695
— Activité de la Commission des Mœurs et Coutumes (Origine du Reamker)	*M. CHAP-PIN*	703
NOTES ET CHRONIQUES		
— Discours du Dr. MALALASEKERA au 2e Congrès Mondial Bouddhique(suite)	*INSTITUT BOUDDHIQUE* . . .	714

Prix d'abonnement annuel comprenant 12 numéros: 192$00

សារណីយធម៌

ព្រះមហាបវ្វជ្ជសិរី ប៊ាប់-សៀង

ទេសនាជាកិត្តិយសប្រទេសកម្ពុជា កាលពីថ្ងៃ ៨ ភោជនៃចេត្រឆ្នាំជូតសំរឹទ្ធិស័ក
ព.ស. ២៤៩១ (២១-៤-៤៩)

ធម្មោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការថ្វាយបង្គំ ចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយគោរព) ។

តអំពីនេះទៅ សូមសំដែង សារណីយធម៌ ផ្សាយតាមខ្សែគ្លាសនសព្ទ តាមសមគួរដល់កាលវេលា ។

ពាក្យថា "សារណីយធម៌" នេះ ប្រែថា "ធម៌ដែលបុគ្គលគប្បីរឭក" ចែកចេញជាមេមាតិកាមាន ៦ យ៉ាង គឺ:

១ – កាយកម្មប្រកបដោយមេត្តា

២.– វចីកម្មប្រកបដោយមេត្តា

៣.– មនោកម្មប្រកបដោយមេត្តា

៤.– ចែកលាភដែលបានមកដោយធម៌ដល់គ្នា

៥.– រក្សាសីលឲ្យបរិសុទ្ធស្មើគ្នា

៦.– បញ្ញាយល់ឃើញត្រូវគ្នា ។

សូមលើកយ :បទមាតិកាមួយម្តងៗ មកអធិប្បាយពន្លឹកសេចក្តីដូចតទៅនេះ ៖

កាយកម្មប្រកបដោយមេត្តា ... មុននឹងអធិប្បាយបទមាតិកានេះ សូមដកយកពាក្យ "មេត្តា" មកបែកនឹងអធិប្បាយជាតួយ៉ាងខាងដើមសិន ។

មេត្តា បែបថា "មេត្រី, សេចក្តីស្និទ្ធ, ការពាក់អាន, សេចក្តីស្រឡាញ់, ធម្មជាតដែលមានក្នុងមិត្រ ឬបែពឹត្តទៅដល់មិត្រ" ។ បើសំដែងតាមលក្ខណៈ, កិច្ច, ផល នឹងអាសន្នហេតុវិញ មេត្តានេះមានការបែពឹត្តទៅដោយអាការជាបែយោជន៍ ជាលក្ខណៈ (គ្រឿងកំណត់កត់សំគាល់), មានការបែមូលទុកនូវបែយោជន៍ ជាកិច្ច (ភ្នាក់ងារការៈ), មានការកំចាត់បង់នូវគំនុំគុំគួន ជាផល, មានការឃើញនូវសភាពជាទីគាប់ចិត្តពេញចិត្តនៃសត្វទាំងឡាយ ជាអាសន្នហេតុ ។

កាយកម្មប្រកបដោយមេត្តានេះ មានអត្ថាធិប្បាយថា មនុស្សនិករគ្រប់ជាតិ-ភាសា ដែលទុប្បត្តិឡើងក្នុងកាជនលោកទាំងមូលនេះ ទោះរួមសញ្ជាតិ រួមភេទ រួមទីលំនៅភូមិឋានស្រុកទេសជាមួយគ្នាក៏ដោយ ផ្សេងគ្នាក៏ដោយ សុទ្ធតែមានការបែស្រ័យជាប់ពាក់ព័ន្ធរកគ្នាជាជាប ។ គ្មាននរណាមួយកើតមក រស់នៅឯោលតែឯកឯង ដោយគ្មានការបែស្រ័យរកគ្នាទេ ។ ឯគោលការណ៍បែស្រ័យគ្នា មានត្រឹមតែ ៣ យ៉ាងគឺ: ១- ខាងផ្លូវកាយ, ២- ខាងផ្លូវសំដី, ៣- ខាងផ្លូវចិត្ត ។

ចំពោះមាតិកានេះ, ១សំខាន់បំផុត ជនរួមសញ្ជាតិភាសា រួមលទ្ធិ
មធ្យបាយតែប្រតិបត្តិដូចគ្នា ត្រូវធ្វើជាជាប់ខាត ។ កិច្ចការទាំងពួងតាំង
ពីការងារតូចតាចបន្តិចបន្តួច មានការចៃសំអាតជូសជុលទីលំនៅជាដើម
រហូតដល់ការងារធំៗ, កាលបើគេតែឡើងក្នុងពួកត្រួតទីមួយ។ ហើយ
មិនត្រូវធ្វើកាយឲ្យរឹងតាំងឬមើលងងឹងក្អែក ចិត្តត្រដើយកន្តើយឥតរវីរវល់
ទេ ត្រូវទាំគ្នា១ខ្នែងយកចិត្តទុកដាក់ ចាប់នេះលើកនោះជ្រោមជ្រែង
ធ្វើកិច្ចការនោះ។ លុះតែតែបានសម្រេច ។

ម្យ៉ាងទៀត ពួកជនដែលរួមសង្គមជាមួយគ្នា មានពេគាពាធបៀត
បៀន ពោះធ្ងន់ក្តី ស្រាលក្តី មិនត្រូវដំណើច មើលបំណាំទេ ត្រូវទាំគ្នាឈឺ
ឆ្អាល ចាត់ចែងទឹកក្តៅទឹកត្រជាក់ រកថ្នាំសង្ឃឹមកបុកជូសលាបស្រឡាប
គក់ច្រមាច់តែរួតពួតសរសៃដៃជើង ជោកគក់លាងសំលៀកបំពាក់ទឹង
សេនាសន: នៃអ្នកជម្ងឺឲ្យស្អាតជាដើម ។ ការបំរើជម្ងឺនេះ គួរយក
តម្រាប់ព្រះបរមគ្រូរបស់យើង កាលព្រះអង្គថៃទាំជម្ងឺកុកមួយរូបឈ្មោះ
បូតិគត្តតិស្យ: ដោយព្រះហស្តព្រះអង្គ ជាគួយ៉ាង ។

មនុស្សណាដែលនៅក្នុងពួកត្រួតជាមួយគ្នា មិនរវីរវល់ មិនអើពើ
ធ្វើដៃជើងឲ្យគាំងដូចស្ងាប់ ធ្ងន់ដូចថ្មកំលើកកំរើកមិនរួច ដាប់ស្លុកដូច
ដង្កូតឈើ ក្នុងពេលមានកិច្ចរវល់កើតឡើងក្នុងពួកគណ:របស់ខ្លួន,
មនុស្សនោះ ទំងៅជាអ្នកខ្វះមិត្រ ខ្វះការរាប់អាន រស់នៅកំព្រា

ខោលតែឯង ។ ទីបំផុត គ្មានហេតុអ្វីដទៃ ក្រៅពីការក្រៀមមុខ ដេក
គ្រងដៃលើថ្ងាសកើតទុក្ខ តូចចិត្តតឹងច្រែង ឋវតែម្នាក់ឯង ក្នុងពេលមាន
ទុក្ខធុរៈកើតឡើងចំពោះខ្លួននោះទេ ។ ការយកចិត្តទុកដាក់ ជួយផ្តល់
ធុរៈគ្នាដោយមេត្រីចិត្ត តែងជួបប្រទះនឹងគំនរសេចក្តីសុខចំរើន ដូចមាន
ភាសិតសំដែងទុកថា អត្តត្ថិ ជាតត្ថិ សុខា សហាយា
"កាលបើមានកិច្ចរវល់កើតឡើង មិត្រសំឡាញ់ឬគ្រួសារតាំងឡាយ តែង
នាំសេចក្តីសុខមកឲ្យ" ។

វិបាកម្នប្រកបដោយមេត្តា.— មានអត្ថាធិប្បាយថា សំដីសំដៅ
ដែលត្រូវនិយាយទៅកាន់បុគ្គលដទៃ ក្នុងសង្គមជាមួយគ្នាម្តងៗ គួរ
ប្រើវាចាស្អ ប្រកបដោយសេចក្តីពន្យល់អាងហេតុផល មានការច្បាស់
ច្រងាញ់គោលការណ៍ពិត មកលាតសាត្រដាងឲ្យឃើញជាស់តឿន
ចង្អុលច្បាស់គុណទោស, ល្អអាក្រក់, ត្រូវខុស, ហេតុមានប្រយោជន៍
ឥតប្រយោជន៍ ក្នុងបច្ចុប្បន្នទឹងបរលោកជាដើម ។ ពេលនិយាយ
សោតទៀត គួរនិយាយឲ្យសមរម្យតាមគោលចរិកលក្ខណៈរបស់វាចា
ល្អទាំង ៥ យ៉ាង គឺ:

๑.— ពោលពាក្យតាមកាលគួរ សេចក្តីថា មុននឹងនិយាយ
គួរពិចារណាមើលថា ពេលនេះ គួរអាត្មាអញនិយាយបានឬមិនបាន,
បើឃើញថាគួរនិយាយ ក៏និយាយ បើមិនគួរទេក៏ឈប់ស្ងៀម ។

២.— ពោលពាក្យសច្ចៈ សេចក្តីថា សំដីណាមិនរើរុះ មិនសារដើម មិនកែប្រែជាថ្មីទៀត ជាសំដីមិនមានពីរ ពោលទៀងទាត់ពិតមែន ហៅថាពាក្យសច្ចៈ ។ សំដីដែលយើងនិយាយក្នុងទីសន្និបាតម្តង។ មិនមែនចេញផុតពីមាត់ភ្លាម ហើយរសាត់បាត់ទៅតាមរលកជាតុអាកាសទេ ទៀងតែនឹងចូលទៅកាន់ត្រចៀកបុគ្គលដទៃជាច្រើនផង ។ ហេតុនោះអ្នកនិយាយ ត្រូវស្វែងរកការពិតឲ្យឃើញ សឹមហាមាត់និយាយ ។ បើហេតុផលមិនពិតទេ ស្ងៀមស្ងៀម ប៉ិនប្រសប់មាត់ឲ្យដិតល្អផង ។ ពាក្យសំដីពិតត្រង់ អាចធ្វើមនុស្សឲ្យមានតំលៃបាន ទើបមានពាក្យបុរាណភាសិតថា "សូបចង់ទ្រព្យកុំឲ្យបង់សំដី, មនុស្សគេយកសំដី ដំរីគេយកភ្លុក, ស្ងៀមជាជាងស្រដី, អណ្តាតជាអាវុធ បានសុខទុក្ខផងពីព្រោះអណ្តាត" ។ អ្នកប្រាជ្ញបានឲ្យមានព្រះពុទ្ធដីកាដើម ប្រកបដោយវិចារណប្បញ្ញា ឈ្លូងយល់យើញគុណានិសង្សនៃពាក្យសច្ចៈ ទើបប្រកាសសេចក្តីពិតថា ៖

សច្ចំ ហវេ អមតា វាចា ឯស ធម្មោ សនន្តនោ
សច្ចេ អត្ថេ ច ធម្មេ ច អាហុ សន្តោ បតិដ្ឋិតា

"គួរឲ្យសរសើរពេក ពាក្យពិតជាពាក្យមិនចេះស្លាប់, ធម៌នេះជាប្រពៃណីមានមកតាំងពីបុរាណ, សប្បុរសតាំងឡាយ បានតាំងនៅក្នុងហេតុនឹងផលដ៏ពិតត្រង់" ។

មួយយ៉ាងទៀត ពាក្យសច្ចៈនេះ អាចឲ្យផលប្រច័ក្សជាក់ស្តែងក្នុងបច្ចុប្បន្នខាន់ក្នុកឃើញ គឺអាចការពារជីវិតខ្លួននឹងក្រុមគ្រួសារឲ្យផុតអំពីមរណភាពបាន, តួយ៉ាងដូចអធិមុត្តកសាមណេរនឹងមហាសុតសោម-បណ្ឌិតជាដើម ។ ចានជាមានភាសិត ក្នុងកិន្នរវត្ថុ អដ្ឋកថាតក្ការិយ-ជាតក ក្នុងតេរសនិបាត ប្រកាសទុកមកថា ៖

តស្មា មរណាតោ មោក្ខំ បត្ថយន្តេន ជន្តុនា
បហាយ អលិកំ សព្ពំ ភាសិតព្វំ សុធីមតា

"ព្រោះហេតុនោះ សត្វដែលមានប្រាជ្ញាល្អ កាលប្រាថ្នាឲ្យផុតអំពីមរណៈ គ្រូវលះបង់ពាក្យឡេះឡោះចោល ហើយពោលតែពាក្យពិត្យចុះ" ។

๓.— ពោលពាក្យស្រទន់ផ្អែមល្ហែម គឺនិយាយពាក្យពីរោះល្អ នាំឲ្យអ្នកស្តាប់កើតសេចក្តីជ្រះថ្លាសោមនស្សចាន ។

๔.— ពោលពាក្យប្រកបដោយប្រយោជន៍ គឺពាក្យពោលពន្យល់ប្រាប់ហេតុផល នឹងការខុសត្រូវក្នុងបច្ចុប្បន្ននឹងបរលោក, ការនិយាយខ្លួនាន ឲ្យចេះរៀបចំខ្លួនប្រាណមានរបៀបរៀបរយគ្រប់គ្រងយោបថទាំងបួន ស្ទៀតដណ្តប់បិទបាំងកាយ នឹងដាស់តំនិតឲ្យដឹងការខុសត្រូវជ្រាលក់, ការនិយាយពន្យល់ប្រាប់ប្រយោជន៍ខាងកសិកម្ម ឲ្យខំព្យាយាមប្រឹងប្រែងស្វែងរកទ្រព្យសម្បត្តិ ដោយការក្លែវក្លាស់កាប់គាស់

កកាយធរណី បណ្តុះដាំស្រូវ, ពោត, សណ្តែក, លូនឆ័ដំណាំនានា ជាបុព្វន្តជាតិនឹងអបរន្តជាតិក្តី ខាងពាណិជ្ជកម្ម ផ្លូវដំទួញដួញលក់ ចាំង ២ ពួកគឺ ជង្ឃពាណិជ (ឈ្មួញសំពាយ), សកដពាណិជ (ឈ្មួញទូកទេះកប៉ាល់នឹងឈ្មួញធម្មតាតាមផ្លូវផ្សារ) ក្តី ហៅថាពោលពាក្យប្រកបដោយប្រយោជន៍ ។ មួយយ៉ាងទៀត ការនិយាយសរសើរគុណសម្បត្តិវិទ្យាសាស្ត្រជាសំគំនិតអ្នកស្តាប់ឲ្យចូលចិត្ត ស្រឡាញ់ការសិក្សារៀនសូត្រដោយន័យថា វ៉ែនកុមារកុមារីតុំឆ្លាយ! វិទ្យាឫសាស្ត្រក្នុងលោកនេះច្រើនណោស់ តែបើបំប្លែងឲ្យខ្លីមកមានត្រឹមតែ ៥ យ៉ាងគឺ នីតិវិជ្ជា បានដល់វិជ្ជាខាងការសិក្សារៀនសូត្រអក្សរសាស្ត្រ លេខនព្វន្ត គុណហាជាដើម ១, យន្តវិជ្ជា បានដល់វិជ្ជាខាងគ្រឿងចក្រយន្ត (គ្រឿងមាស៊ីន) ចាំងអស់ ១, វេជ្ជវិជ្ជា បានដល់វិជ្ជាពេទ្យហូរចេះមន្តអាគមឬពេទ្យផ្សំថ្នាំ ១, រដ្ឋវិជ្ជា បានដល់វិជ្ជាខាងផ្លូវច្បាប់សម្រាប់ប្រទេស ១, យុទ្ធវិជ្ជា បានដល់វិជ្ជាចំបាំង ១ បណ្តាវិជ្ជាឫសាស្ត្រ ចាំង ៥ យ៉ាងនេះ សុទ្ធតែមានប្រយោជន៍សម្រាប់ខ្លួននឹងប្រទេសជាតិចាំងអស់, វិជ្ជាមិនដែលអាក្រក់ទេ មានតែមនុស្សទេតើទើបអាក្រក់, អ្នកត្រូវខំប្រឹងប្រែងសិក្សា ខាំមាត់អត់ធន់តស៊ូនឹងសេចក្តីទុក្ខលំបាកគ្រប់យ៉ាង ប្តូរយកវិជ្ជាសម្បត្តិណាមួយឲ្យបាន ខាន់ខ្លួនអ្នកកំពុងតាំងនៅក្នុងយោព្វនវ័យដើម្បីនឹងកែខ្លួនអ្នកឲ្យជាមនុស្សម្នាក់ បីតនៅក្នុងហាន:ដ៏ខ្ពង់

ខ្ពស់ ព្រមទាំងលើកសួយប្រទេសជាតិមាតុភូមិអ្នកឲ្យមានតម្លៃ ឃ្លាតឆ្ងាយពីហីនភាពនឹងទាសភាពឡើង ហេតុនេះ ចូរអ្នកកុំឲ្យលុកុំទំនង់ណាក់ក្រាញធ្វើអត្តភាពប្រហែលគ្មានទឹងដង្កត់ឈើប្តុដុំថ្មឡើយ, អ្នកទាំងឡាយមិនធ្លាប់បានស្តាប់ទេឬ? ពាក្យសុភាសិតថា:

អបុត្តកំ ឃរំ សុញ្ញំ រដ្ឋំ សុញ្ញំ អរាជិកំ
អសិប្បស្ស មុខំ សុញ្ញំ សព្វសុញ្ញំ ទុលិទ្ធកំ

ផ្ទះដែលឥតកូនសូន្យស្ងប់ស្ងាត់ ដែនដែលឥតក្សត្រសូន្យអាជ្ញា មាត់ឥតសិល្បសាស្ត្រសូន្យពាក្យចរចា ខ្ញុក្រែកំព្រាសូន្យសព្វទាំងអស់ ។

ការរួន្ទានពន្យល់ប៉ុណ្ណេះជាដើម ចាត់ថាវាចាប្រកបដោយប្រយោជន៍ផ្លូវបច្ចុប្បន្ន ។

បំណែកទាន់វាចាប្រកបដោយប្រយោជន៍ផ្លូវបរលោកវិញ ជាន់ដល់ការនិយាយជាស់តឿនឲ្យមានសទ្ធាជឿបុណ្យចាប, វក្សាសីល, លះលោភៈនឹងមច្ឆរិយៈចេញហើយបរិច្ចាគទាន នឹងបញ្ញាសម្រាប់ពិចារណាឲ្យដឹងហេតុផលសព្វគ្រប់ រហូតដល់ការពិចារណាអត្តភាពថា ជារោគាតុរបិតនៅក្នុងកណ្តាប់ដៃនៃសាមញ្ញលក្ខណធម៌ទាំង ៣ គឺ ទុក្ខំ, អនិច្ចំ, អនត្តាលុមកើតជម្មសង្វេគចំពោះបញ្ចក្ខន្ធ ដោះខ្លួនគេចចេញចាកកពាលវដ្តសង្សារដែលកំពុងឆេះសន្ធោសន្ធៅដោយភ្នក់ភ្លើងទាំង ៣ គឺរាគៈទោសៈមោហៈ។

វាចាច្រាសចាកប្រយោជន៍ បើទុជាបុគ្គលអត្តុយនិយាយប៉ាច់ប៉ាច ដូចលាជផ្ទុះ តាំងពីព្រឹលឹមទល់ព្រលប់ ពីព្រលប់ទល់ភ្លឺក៏ដោយ មិនអាចយកទៅប្រៀបធៀបនឹងវាចាជាប្រយោជន៍ សូម្បីមួយចំណិតបានឡើយ ។ ព្រោះហេតុនោះ បានជាព្រះបរមគ្រូជាមហាអ្នកច្រាជ្រូតប្រកាសគាថា ទុកជាឧត្តមគតិថា:

សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា
ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ

"បុគ្គលស្តាប់នូវបទណា ហើយស្ងប់រម្ងាប់បាន, បទនោះជាបទមានប្រយោជន៍ សូម្បីតែមួយ គង់ប្រសើរជាងវាចាមួយពាន់ម៉ាត់ដែលមិនប្រកបដោយប្រយោជន៍" ។

៥.— ពោលពាក្យដោយបិត្តមេត្តា គឺនិយាយដោយសេចក្តីអនុគ្រោះអាណិតអាសូរច្រាថ្នាឲ្យកើតប្រយោជន៍ពិតៗ មិនច្រាថ្នាក់ម្លៃអ្វី ។ អ្នកពោលវាចាល្អតាំង ៥ យ៉ាងនេះសឹងជាប្រយោជន៍ខ្លួននឹងអ្នកជាខ្លែគប់ៗ ។

មនោកម្មប្រកបដោយមេត្តា.— មានអត្ថាធិប្បាយថាចិត្តដែលត្រិះរិះពិចារណា ស្រាវជ្រាវរកតែមធ្យោបាយ ដោយសន្តិវិធីចំពោះការណីយកិច្ចប្រកបដោយហេតុផល ដើម្បីញ៉ាំងសន្តិសុខនឹងថាវរៈប្រយោជន៍ឲ្យកើតមានឡើងក្នុងសង្គមនីមួយៗ តាំងពីប្រឹងរិះរកកលល្បិចយ

រក្សាការពារសេចក្តីសុខនឹងក្រៃយោជន៍ ដែលបានមកហើយឲ្យរឹងរឹតតែ
រឹងប៉ឹងបិតថែរក្សាទៀត ហៅថាមនោកម្មប្រកបដោយមេត្តា ។ ការ
ពិចារណាយល់កិច្ចកល តាំងចិត្តជាសប្បុរសរកគ្នាទៅវិញទៅមកវាងវ
មនុស្សនឹងមនុស្សផងគ្នាក្នុងគណៈជាមួយគ្នាបាន ចាត់ថាជាគុណសម្បត្តិ
មួយដ៏ប្រសើរបំផុត ព្រោះមានបុរាណភាសិតថា:

ក្រកិច្ចក្រកល ក្រដឹងក្រយល់ ក្រវៃឆ្នៃឆាស់
ក្របានជាធំ លើគេតាំងអស់ ក្រចិត្តសប្បុរស
នឹងមនុស្សផងគ្នា ។ ក្រធំបំផុត គឺក្រទី៧ខាងចុង ។

បែកលាភដែលបានមកដោយធម៌ដល់គ្នីគ្នា — មាន
អត្ថាធិប្បាយថា លោកប្រកបដោយធម៌ ខាងបព្វជិត បានដល់ចតុប្បច្ច័យ
កើតឡើងអាស្រ័យកំឡាំងស្នងរបស់ខ្លួន ទំដើរស្វែងរកតាមច្រកល្អក
ប្រាសចាកបាបធម៌ប្រាំ នឹងអនេសនៈមែកមួយ ។ ពុំនោះសោតកើត
ឡើងដោយអាស្រ័យឥយកឥយិកា ជះថ្លាក្នុងគុណសម្បត្តិនឹងចរិយា
សម្បត្តិខ្លួនហើយប្រគេនមក ។ ខាងគ្រហស្ថ បានដល់លាភសក្ការៈ
កើតឡើងត្រឹមត្រូវតាមធម៌ប្រាសចាកបញ្ហាវោរដាដើម ។ លាភបែបនេះ
បើបានមកហើយ មិនគួរហួងហែងខុសសម្បរិភោគប្រើប្រាស់តែឯងទេ
ត្រូវចែកចាយគ្នីគ្នាបរិភោគប្រើប្រាស់តាមមានតាមបាន ។ មនុស្សរួម
សំវាសប្រសង្គីមជាមួយគ្នា បើបានលាភសក្ការៈមកហើយ លាក់លៀមខុក

បរិភោគប្រើប្រាស់តែម្នាក់ឯង ក្នុងសំឡឹងឃើញសេចក្តីទុក្ខអ្នកដទៃ មិនខ្វល់គ្នាអំពីបុពណ្ណកាសិតថា "ចូលមៃត្រីសត្វសាហាវ រកអំពាវគ្នាមកជុំ ដល់បានស្ករទឹកឃ្មុំ ពួនសម្ងំស៊ីម្នាក់ឯង", ពុទ្ធកាសិតថា សក្កោ កាបុរិសំ ហន្តិ "គ្រឿងសក្ការៈ តែងសម្លាប់បុគ្គលអាក្រក់" ដូច្នេះ ។

រក្សាសីលឲ្យបរិសុទ្ធស្មើគ្នា.— មានអត្ថាធិប្បាយថាអ្នកដែលតាំងវិរតិចេតនាវៀរគ្រប់សិក្ខាបទដែលខ្លួនសមាទានហើយ រៀបចំកាយទ្វារមនោទ្វារនឹងវចីទ្វារ ឲ្យមានរបៀបរៀបរយហៅថា អ្នកមានសីល ។ ការមិនចាប់កាន់គ្រឿងសស្ត្រាវុធ, ព្រនង់ដំបង ដោយហោចទៅសូម្បីបហរណវត្ថុដទៃៗទៀត ដើម្បីពិឃាដសត្វ ឈ្មោះថាជាគុណសម្បត្តិផ្នែកបាណាតិបាត ។ ការមិនលួចកាត់របង ឬបើករបងច្រកល្ហក កាត់ទឹតមានជញ្ជាំងផ្ទះ ពុះបំបែកតុទូ ធក់ជណ្តើមយកទ្រព្យសម្បត្តិអ្នកដទៃជាដើម ឈ្មោះថាជាគុណសម្បត្តិផ្នែកអទិន្នាទាន ។ ការមិនកន្ទួចប្រពៃណីធម៌ គឺមិនលួចកូនប្រពន្ធអ្នកដទៃ ដោយអាការៈកំរៀចប្រើអំណាចជាដើម ឈ្មោះថាជាគុណសម្បត្តិផ្នែកកាមេសុមិច្ឆាចារៈ ។ ការមិននិយាយកុហកកូតកវ ឈ្មោះថាជាគុណសម្បត្តិផ្នែកមុសាវាទ ។ ការមិនចាប់ពាល់ដបឬកែវ ដែលពេញដោយទឹកស្រវឹង មានសុរានឹងមេរ័យជាដើម ឈ្មោះថាជាគុណសម្បត្តិផ្នែកសុរាមេរ័យ ។

មនុស្សក្នុងក្រុមនីមួយៗ ប៉ើមានការរៀបចំដូចគ្នា ចំពោះសិក្ខាបទ
សម្រាប់កេតវបស់ខ្លួនហើយ ឈ្មោះថាជាអ្នកមានសីលដូចគ្នា ។
ចំពោះសមណកេតវិញ ក៏មានលំនាំដូចគ្នាដែរ ។ អ្នកនៅក្នុងសង្គ័មជាមួយ
គ្នា មានសីលស្មើគ្នារមែងបានសេចក្តីសុខសេចក្តីចំរើន សព្វពេលវេលា ។

បញ្ញាយល់ឃើញត្រូវគ្នា.— មានអត្ថាធិប្បាយថា ទិដ្ឋិនេះ
ជាតួបញ្ញា ចំនួនជាសម្ប៉ាន់សម្រាប់ពិចារណាវកហេតុផលសព្វ
គ្រប់ ។ ជនមានចំនួនច្រើន រួមសង្គ័មជាមួយគ្នាត្រូវប្រឹងគំនិតឲ្យ
ស្របគ្នាគឺមានការយល់ឃើញចំពោះប្រយោជន៍ ក្នុងសង្គ័មជាមួយគ្នា
តែម្ប៉ាន់ ។ ដ្បិតការយល់ឃើញផ្ទុយគ្នាខុសឃ្លាតគ្នា មួយទៅឆ្ងន់មួយ
ទៅស្តាំ ទុកថាជាគោសមួយយ៉ាងធំ អាចទំលាយមិត្តសាមគ្គី ព្រមទាំង
សន្តិសុខនិងប្រយោជន៍ គ្រប់ស្ថានក្នុងសង្គ័មឲ្យរលាយបាន ។

ប្រយោជន៍របស់សារណីយធម៌នោះមាន ៦ យ៉ាង គឺ

១.— ជាទីស្រឡាញ់ពេញចិត្តអ្នកដទៃ

២.— ជាទីគោរពរាប់អានអ្នកដទៃ

៣.— បានសេចក្តីសរសើរអំពីសំណាក់អ្នកដទៃ

៤.— មិនវិវាទខាស់ខែងខ្វែងគំនិតនឹងអ្នកណាមួយឡើយ

៥.— សាមគ្គីជមិតែងកើតមានឡើង

៦.— មានការយល់ឃើញត្រូវគ្នា ។


សំដែងធម៌ទេសនា អំពីសាវណីយធម៌ ល្មមសមគួរដល់កាលវេលាតែប៉ុណ្ណេះ ។

ទីបំផុតនេះ សូមថ្វាយព្រះពរជ័យសួស្តី ចុំពោះព្រះករុណាជាម្ចាស់ដ៏វិត ព្រមទាំងអាណាប្រជារាស្ត្រ ក្នុងព្រះពរជ័យអាណាចក្រទាំងមូល សូមឲ្យបានប្រកបដោយសុខសាន្តនឹងវឌ្ឍនធម៌គ្រប់យ៉ាងកុំបីឃ្លាតឡើយ ! ។

រតនត្តយតេជេន ភវោជវរដ្ឋិវាសិនោ
រ៊ុឌ្ឍី រ៊ុឌ្ឍិំ បប្បោន្តុ សទ្ធិភាវិញ្ញូ នាញ្ញថា

ដោយតេជៈនៃព្រះរតនត្រ័យ សូមឲ្យប្រជាជននៅក្នុងឥតម្ពុជវរដ្ឋដល់នូវសេចក្តីចំរើនលូតលាស់ នឹងសន្តិភាព កុំបីឃ្លាតក្បាយទៅជាបកាៈដទៃឡើយ ! ។

បរិឃាយអំពីសាវណីយធម៌ ចប់តែប៉ុណ្ណេះ



រៀបទេសនា បុច្ឆា-វិសជ្ជនា

ព្រះមហាឧត្តមវិជ្ជា កែ-អឿន រិរិយប្បញ្ញោ

វត្តព្រះពហ្មវតន៍ ខែត្តសៀមរាប រៀបរៀង

ព្រះទេពសត្ថា សួរ-ហាយ ពិធីត្បែសម្រួល

(តបប់)

កុមារសួរថា "ព្រះពជារបស់អ្នកតាំងឡាយទៅណា?" ។ - ព្រះពជារបស់យើងខ្ញុំតាំងឡាយទ្រង់សោយទិវង្គតទៅហើយ ។ - សោយទិវង្គតទៅប៉ុន្មានថ្ងៃហើយ? ។ - មកដល់ថ្ងៃនេះ ៧ថ្ងៃហើយ ។ - ចុះព្រះពជបុត្រក្តី ព្រះពជធីតាក្តីមិនមានទេឬ? ។ - មានតែព្រះពជធីតា ព្រះពជបុត្រពុំមានទេ ។ កុមារឆ្លើយថា "បើដូច្នោះយើងនឹងសោយ-ពជ្ជ" ។ ជនតាំងនោះក៏ធ្វើមណ្ឌបសម្រាប់អភិសេក ១ រំពេច ហើយរៀបចំអភិសេកក្នុងមណ្ឌបនោះ ថ្វាយព្រះនាមជា ព្រះបាទធម្មរាជ ហើយនាំយកសំពត់មានដំរែ ១ ពាន់កហាបណៈទៅថ្វាយ ។ គ្រានោះ ព្រះពជាមានព្រះបន្ទូលថា "សំពត់នេះជាសំពត់មានសាច់គ្រោតគ្រាតណាស់ យើងមិនត្រូវការទេ អ្នកតាំងឡាយចូរយកកុណ្ឌីមាសមក យើងមុខជានឹងបានសំពត់ល្អ" ហើយក៏គ្រាតឡើងយកព្រះហស្តកាន់កុណ្ឌីបាចសាចទឹកទៅកាន់ទិសខាងកើត ។ ដើមកល្បព្រឹក្ស ៩

ដើមកំណើយផែនដីតាន់ផុសឡើងភ្លាម, ទិសខាងត្បូងក្តី ខាងលិចក្តី ខាងជើងក្តី មានដើមកល្បព្រឹក្ស ៨ ដើមៗ ផុសឡើងជួចគ្នា ។ រួមជាដើមកល្បព្រឹក្ស ៣២ ដើម ផុសឡើងដោយប្រការដូច្នេះ ។ សំពត់កំកើតឡើងបរិបូណ៌ក្នុងដើមកល្បព្រឹក្សទាំងអម្បាលនោះ ។ ព្រះពជានោះទ្រង់ស្ងៀកសំពត់ទិព្វ ១ ដណ្តប់សំពត់ទិព្វ ១ ទ្រង់ឲ្យទូន្មសូរកេរីប្រកាសប្រាប់មនុស្សទាំងអស់នៅក្នុងផែនថា "ពួកស្រីកុងផែនព្រះបាទនន្ទពជ កុំបាច់រវៃសូត្រអម្បាះឡើយ" ហើយទ្រង់ឲ្យលើកធ្នូឡើងទ្រង់គង់លើដំរីដ៏ប្រសើរយាងចូលទៅកាន់ព្រះនគរ ទ្រង់ឡើងកាន់ប្រាសាទសោយសម្បត្តិដ៏ប្លុងប្លែង ទ្រង់រៀបចំផែនទាំងមូលឲ្យស្អាតល្អប្រហែលនឹងទ្តវក្បុរទ្វីប ទ្រង់ព្រះពជានសំពត់ទិព្វដល់ពួកមនុស្សដែលមកទាំងអម្បាលម៉ាន ។ លុះកាលជាចំណេរខាងក្រោយមក ទ្រង់មានសេចក្តីខ្ទើយណាយកងឃពាស ហើយទ្រង់ព្រះផ្នួសជាមួយនឹងនាងទេវីជាអគ្គមហេសី ទ្រង់គង់នៅកងទ្យាន ជានឈានសមាបត្តិមានសភាពជាបុគ្គលមិនជានសាបសូន្យចាកឈាន លុះអស់ព្រះជន្មាយុទៅ ក៏ជានទៅកើតក្នុងព្រហ្មលោក ។ ព្រះជានន្ទពជនោះគឺព្រះមហាកស្សបត្ថេរកុងកាលឥឡូវនេះ, ខាងទេវីគឺនាងភទ្ទាកាបិលានី ជាភរិយាព្រះថេរៈកុងកាលនៅជាគ្រហស្ថ ។ រឿងព្រះជានន្ទពជនេះមានមកកុងអដ្ឋកថាសំសារមោចកបេតវត្ថុ; ក្នុង មហាថេរៈ បពិត្រព្រះ

មហាថេរដ៏ចំរើន! ខ្ញុំព្រះករុណាបាននាំរឿងនេះមកសំដែង ដើម្បីឲ្យ
ឃើញជាតួយ៉ាងថា អ្នកដែលបានធ្វើចីវរទាន មានអានិសង្សដូចបាន
វិសជ្ជនាមកនេះ សូមមានជ្រាប ។

១៩- សាធុ សាធុ អនុត្តរេ: ម្នាលអនុត្តរៈ! អានិសង្សចីវរទាន
ដែលលោកវិសជ្ជនាមក ព្រមទាំងពាក្យរឿងនិទានមកសំដែងជាតួយ៉ាង
ឃើញថាពីរោះគ្រោះក្បាយ ល្មមលោកអ្នកសប្បុរសទាំងឡាយ សន្និដ្ឋាន
ចូលចិត្តយកជាបែបយ៉ាងបានហើយ ។ តពីនេះទៅខ្ញុំនឹងសួរលោកតទៅ
ទៀត ។ អើលោក! ចីវរទាន ឃើញថាមានអានិសង្សជាអស្ចារ្យមែន
ហើយ ចុះអានិសង្សនៃចីវរទាន ដែលស្ត្រីបុរសបានធ្វើហើយ តើនឹង
បានសម្រេចយ៉ាងណាទៅទៀត? សូមលោកនិមន្តសំដែងញែកចែក
ឲ្យស្រឡះពីគ្នា ដើម្បីលោកអ្នកទាំងឡាយបានជ្រាបផងមើល ។

- ភន្តេ មហាថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! ឯអានិសង្ស
ចីវរទានយ៉ាងខ្ពស់របស់ស្ត្រីបុរសដែលបានធ្វើហើយ បើតាមគម្ពីរធម្មបទ-
ខុទ្ទកនិកាយ បុប្ផវគ្គវណ្ណនា លោកសំដែងថា តិត្តិំ ហិ ចីវរទានំ
មហាលតាបសាធនេន មគ្គកំ បប្បោតិ បុរិសានំ តិទ្ធិមយបត្តំ
ចីវរេនាតិ សេចក្តីថា «ចីវរទាននៃស្ត្រីទាំងឡាយមែនបានប្រដាប់
ដោយគ្រឿងមហាលតាបសាធនៈ តួយ៉ាងដូចនាងវិសាខាមហាឧបាសិកា
នាងបានប្រដាប់ដោយគ្រឿងមហាលតាបសាធនៈនេះ ដោយផលា-

និសង្សដែលនាងបានថ្វាយចីវរសោដក អំពោះ ចេស នឹងទឹកដ្រែលក់ដល់
កិក្ខុសង្ឃ ២០ ពាន់អគ្គ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាម
កស្សបៈឯណោះ ឯត្រឹងប្រជាប់នាងនោះដំណែ ៩ កោដិ ឈ្មួលជាង
ដែលធ្វើមួយសែន, ចីវរខាងបុរសចាំងឡាយវិញ នឹងបានសម្រេច
ដោយបាត្រចីវរប្រកបដោយបុញ្ញបុទ្ធិ គឺថាបុរសនោះបានដួបប្រទះ
ព្រះសម្មាសម្ពុទ្ធអគ្គណាមួយ មានប្រាថ្នានឹងបួសមិនបាច់ស្វែងរកបាត្រ
និងចីវរអំពីណាឡើយ គ្រាន់តែព្រះអគ្គគ្រាស់ថា "ឯហិ ភិក្ខុ អ្នក
ឯងចូរជាភិក្ខុទៅចុះ" បានសម្រេចទៅជាភិក្ខុ ១ រំពេច; ភន្តេ ថេរៈ
បពិត្រព្រះមហាថេរដ៏ចំរើន! អានិសង្សចីវរទាន យ៉ាងខ្ពស់បំផុតរបស់ស្ត្រី
បុរសដែលបានធ្វើចីវរទានដល់សង្ឃ ដូចខ្ញុំព្រះករុណាបានវិសជ្ជនាមក
នេះ សូមទានជ្រាប ។

២០– សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរៈ! ប្រស្នាដែលលោក
សំដែងមក យើញថាពីកេរអស្ចារ្យណាស់, លោកអ្នកសប្បុរសចាំងឡាយ
គប្បីសន្និដ្ឋានចូលចិត្តចុះ ។ កឋិនទាននេះមានផលវិសេសជាងអាមិស-
ទានទាំងអស់ បើលោកអ្នកចាំងឡាយមានសេចក្តីខ្វល់ខ្វាយចំណាយ
ទ្រព្យធ្វើចីវរទាន ឬកឋិនទាននេះ ទោះបីប្រាថ្នាចង់បានសម្រេចឥដ្ឋផល
យ៉ាងណា: ក៏សឹងតែបានសម្រេចដូចសេចក្តីប្រាថ្នាយ៉ាងនោះ។ មិនខាន
ឡើយ ។ តអំពីនេះទៅទៀត ខ្ញុំសូមសួរលោក តែមួយប្រស្នាទៀត

ទេ ។ អើអនុត្តរៈ! — អានិសង្សនៃកឋិនទាន ខាងតាយកអ្នកធ្វើដូច លោកបានសំដែងតែប៉ុណ្ណោះ ឬនៅមានដូចម្តេចតទៅទៀតដែរឬទេ? បើនៅមាន សូមទ្រង់មេត្តាសំដែងឲ្យបានពួលំពួលាយ ដើម្បីពុទ្ធបរិស័ទ ខាងឯឲ្យស្តាប់តទៅទៀតមើល ។

— ភន្តេ មហាថេរៈ បពិត្រព្រះមហាថេរៈដ៏ចំរើន! ឯអានិសង្សនៃកឋិនទានរបស់តាយកអ្នកធ្វើនោះ នៅមានតទៅទៀត, វេលានេះខ្ញុំព្រះករុណានឹងថែកអានិសង្សនៃតាយកអ្នកបរិច្ចាគកឋិនទាន ពុកក្នុងព្រះពុទ្ធសាសនាតាមបទព្រះគាថា ដែលព្រះបរមសាស្តា ទ្រង់ទេសនាជាបទឋាលីមានដើមថា: "យោ សោ វិធេយ្យ មប្បេមលំ វិប្បសន្នេន បេតសា ទជ្ជា កាលេន អរិយេសុ យត្ត ទិដ្ឋំ មហប្ផលំ កឋិនញ្ច ដូច្នេះជាដើម អធិប្បាយថា បុគ្គលណា មានចិត្តដ៏ថ្លា អាចកំចាត់បង់នូវមច្ឆរិយៈគឺសេចក្តីកំណាញ់ ហើយស្រឡាញ់ក្នុងការកុសលផលបុណ្យបានលះនូវធនធាន ធ្វើកឋិនទានថ្វាយចំពោះព្រះអរិយសង្ឃ ឬសម្មតិសង្ឃក្នុងព្រះពុទ្ធសាសនា គួរជាទក្ខិណាចំរើនផលបាន, លុះអ្នកនោះចំណាយទ្រព្យចាកអត្តភាពជាមនុស្សនោះហើយ ក៏មានមុខទៅកាន់ស្ថានសួគ៌ទេវលោក ៈសោយទិព្វសម្បត្តិជាទ្រព្យវិកអធិកមហិមានៅក្នុងសួគ៌អស់កាលជាយូរអង្វែងវែងឆ្ងាយ សប្បាយក្សេមក្សាន្តសំភក្ត ដោយនាងទេពកញ្ញា ច្រើនកំប្រុតគាល់បំរើស្មើតាំងយប់ថ្ងៃ

លុះដល់អស់កាលវេយុទ័យក៏ក្ស័យច្យុតស្រុតចុះមកកើត ក្នុងត្រកូលចាំង
ពីរគឺត្រកូលព្រាហ្មណ៍ទំាងត្រកូលក្សត្រ ប្រកបដោយសម្បត្តិឥស្សរសក្តិ
យសខ្ពស់ក្រៃលែងជាងជនទាទា នៅនាលោកិយនេះ, ហើយអន្លោល
ទៅអន្លោលមកក្នុងសង្សារកើតតែក្នុងស្ថានទេវតានឹងមនុស្សទេត្តម មិន
ចេះរៀទៅកើតក្នុងត្រកូលអ្នកហិនហោចឥតពងរ្យា ពុំដែលទៅកើតក្នុង
ទុគ្គតិកំពប់តុកប្បាយចាំង ๔ អស់ ๑ សែនកំប្ប មិនដែលស្គាល់ទូវ
សេចក្តីគោកយ៉ាកលំបាកក្រីក្រឡើយ បើបុគ្គលនោះចង់ប្រាថ្នាជាពុទ្ធភូមិ
ក្តី ជាបច្ចេកភូមិក្តី ជាសាវកភូមិក្តី កំអាចសម្រេចដូចសេចក្តីប្រាថ្នា
ប្តូចង់បានជាបកតិសាវកសាវិកា ក្នុងសំណាក់នៃព្រះអរិយមេត្រីដែល
ព្រះអគ្គនឹងយាងមកត្រាស់ប្បាស់ក្នុងខាងមុខនោះ និមិត្តតែបួលទៅស្តាប់
ស័ព្ទព្រះសទ្ធម្មវិសេសទេសនានៃព្រះអង្គ កំបានលុះដល់សម្បត្តិអរហត្ត
ភាត់កិលេស, លុះដល់ទូវធម៌ជាកំពូល គឺបានទូវបដិសម្ភិទា ๔ មាន
អត្ថប្បដិសម្ភិទាជាដើម បានទូវវិជ្ជានឹងអភិញ្ញាចាំង ๖ ផង ហើយមាន
ប្រាជ្ញាដ៏មុតថ្លាចាំងក្បៀវក្បាក្នុងឈានសមាបត្តិ ជាព្រះអរហត្តមានឥទ្ធិឫទ្ធិ
មានតេជះឈ្នះទូវបញ្ចពិធមារទំាង ๕ ប្រការ ជាព្រះអរិយបុគ្គលដ៏ប្រសើរ
ក្នុងព្រះពុទ្ធសាសនានៃព្រះអរិយមេត្រីសម្មាសម្ពុទ្ធ, នៅអស់កំណត់ក៏
រលត់ទូវខន្ធទៅកាន់នគរកែវ គឺអមតមហានិព្វាន ជាស្ថានក្សេមសុខ
ប្រាសចាកចតុទុក្ខ គឺជាតិ ជរា ព្យាធិ មរណៈ ទៅតាមមិនដល់ ដោយ

អំណាចគុណសីលគុណកបិនទានខេះឯង ។ សាធុវោ បពិត្រសាធុជនប្បុរសទាំងឡាយ ! ឯផលានិសង្សអង្គកបិនទានខេះ ឃើញថាវិសេសប្លែកៗ ជាអនេកអនន្តពន់ប្រមាណ នៅមានពិស្តារក្នុងគម្ពីរបញ្ញាសជាតក ។ អាត្មាភាពនឹងតស់ឈោងយកមកទេសនាក្នុងវេលាខេះ ក៏ជាការខ្លីវេលា ហេតុខេះទើបរួបរួមពណ៌នាដោយសង្ខេប ពុកជាបែបនៃអ្នកមានសទ្ធា នឹងចង់ប្រាវឮធ្លើតទៅ ។

កន្តេ ថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន ! ខ្ញុំព្រះករុណាបានសំដែងមកអំពីអានិសង្សកបិនទាន មានន័យប្លែកផ្សេង។ ក៏អស់សេចក្តីដោយសង្ខេបតែប៉ុណ្ណោះ, សូមមានជ្រាប ។

๒๑ - សាធុ សាធុ កល្លោសិ អន្តុត្តរៈ ទីឃាយុកោ ហោតុ ម្ចាលអន្តុត្តរ ! លោកជាបុគ្គលឆ្លៀវឆ្លាសពន់ពេកណាស់ ចេះធ្លើយប្រស្នាមកពីកេះក្បោះក្បាយ ល្មមលោកអ្នកសប្បុរសទាំងឡាយ មានចិត្តជ្រះថ្លាក្នុងការចំណាយទ្រព្យបរិច្ចាគធ្លើកបិនទាន ដោយសេចក្តីត្រេកអរយ៉ាងក្រៃលែង ខ្ញុំសូមបួងសួងដល់គុណព្រះរតនត្រ័យ ឲ្យលោកមានជន្មាយុយឺនយូរអង្វែង ។ សាធុវោ បពិត្រសប្បុរសទាំងឡាយ ! លោកអ្នកគប្បីសន្និដ្ឋានចូលចិត្តចុះ ថាព្រះកបិនទាននេះជាទានកម្រក្រៃលែងជាងទានទាំងពួង ឯទានទាំងពួងគ្រៃអំពីកបិនទានសឹងពុំមានខែត្រហាមតាមតែចង់ធ្លើថ្ងៃណា វេលាណាក៏អាចធ្លើបានទាំងអស់ ឯកបិនទាន

នេះពុំដូច្នោះ ចំពោះមានវៃត្រមានសម័យ ក្នុង ១ ឆ្នាំមានពុទ្ធន្តរកាល ពិសេស បានតែ ២៩ ថ្ងៃទេ គឺពីខាងរនោចវៃអស្សុជ ចាប់តាំងពីថ្ងៃ ១ រោចទៅដកបដល់ថ្ងៃពេញបូណ៌មីវៃកត្តិកជាទីបំផុត អស់រយៈកាលកប៉ិនហើយ, មួយទៀតកឋិនទានេះ ចំពោះមានតែក្នុងពុទ្ធុប្បាទប៉ុណ្ណោះ ពុទ្ធុប្បាទោ សបេ ឥត្ថិ ថាមើលកល្បណាពុំមានព្រះពុទ្ធគ្រាស់ហើយ កឋិនទាននេះសោតក៏ពុំមាន ពុទ្ធុប្បាទោ សបេ ហោតិ ថាមើលកល្បណាមានព្រះពុទ្ធមកគ្រាស់ កឋិនំបិច វិជ្ជតិ ទើបកឋិនទានក៏មានក្នុងពុទ្ធុប្បាទនោះឯង ។ ហេតុនោះកឋិនទាននេះជាទានកម្រកៃក្រពេកទាត់ព្វំ កឋិនំ បតិត្រសប្បុរសចាំងឡាយ ! កឋិនទានដែលយើងកាលគ្នាគប្បីឲ្យក្នុងរដូវកាលនៃកឋិន ពេញជាមានកត្តិកាប់ប្រសើរលើសលន់ បានកើតចាន់ព្រះពុទ្ធុប្បាទនៃព្រះគោតមបរមគ្រូជាហេតុ កឋិនក្តៅក៏ដល់ត្រមល្មមបតិត្រកុំប្រមាទ ទំសង្វាត១ស្បាហ៍សាង១ស្បាហ៍សន្សំធ្វើទុកជាបច្ច័យទៅមុខឲ្យព្រះពុទ្ធ ១០ ព្រះអង្គទ្រង់ចំបួសជាឯហិភិក្ខុ ភិក្ខុនីមិនចាំបាច់ស្វែងរកចីវរស្បង់សង្ឃាដី ព្រះជិនស្រីគ្រាស់ថាតែ "ឯហិ" ប៉ុណ្ណោះ ក៏កើតវៃត្រចីវរខ្លួនបរិក្ខារមួយរំពេច បានសម្រេចមគ្គផលដល់ព្រះនិព្វានហោង ។

អាយស្មា អនុត្តរៈ ម្នាលអនុត្តរៈដ៏មានអាយុ ! យើងបានសំដែងព្រះសទ្ធម្មវិសេសទេសនា---មូច្ឆា---វិសជ្ជនា---មកអំពីរឿងកឋិនទានត្រម

ទាំងអានិសង្សរបស់កឋិនទានជាច្រើនណាស់មកហើយ កំលុមសមគួរនឹងបញ្ចាប់តែប៉ុណ្ណេះ, ឬ ឬ ឬ កាលបើចប់ព្រះសទ្ធម្មវិសេសទេសនា បុច្ឆាវិសជ្ជនានេះហើយ សូមផ្សាយបុញ្ញភាគីគំនរបុណ្យដែលកើតអំពីអាមិសទានទំាងធម្មទាន ជូនទៅដល់ដួងវិញ្ញាណនៃបុព្វការីបុគ្គលទាំងឡាយ មានមាតាបិតា ជីដូន ជីតា គ្រូឧបជ្ឈាយាចារ្យនូវញាតិកាទាំងឋិសន្តាន សូមឲ្យលោកបានទទួលអនុមោទនាត្រៃកអរចំពោះចំណែកបុណ្យនេះ មួយយ៉ាងទៀត សូមផ្សាយដល់ពួកទេព្តាទាំងឡាយទាំង ១ សែនកោដិចក្កវាឡ សូមឲ្យលោកបានអញ្ជើញទទួលអនុមោទនា ចំពោះការកុសលផង កាលបើបានទទួលហើយ សូមឲ្យជួយបីបាច់រក្សាព្រះពុទ្ធសាសនា ឲ្យបានថ្កុំថ្កើងរុងរឿងជាបជាល់តែ ៥ ពាន់ព្រះវស្សា ទាំងលោកអ្នកជាពុទ្ធបរិស័ទទាំងឡាយសោត ទោះបីបើលោកអ្នក មានប្រាថ្នាទូវឥដ្ឋផលណា ។ គឺពុទ្ធភូមិ បច្ចេកភូមិ សាវកភូមិ ពុទ្ធមាតា ពុទ្ធបិតា ពុទ្ធបុត្ត កនៀ្សរាវពេជ្ឈ ឬផលណាមួយក៏សូមឲ្យបានសម្រេចដូចសេចក្តីប្រាថ្នា នឹងសេចក្តីសុខគ្រប់ប្រការតាំងអំពីបច្ចុប្បន្នជាតិនេះ ជាបជល់ព្រះនិព្វានជាអវសានជាតិ កុំបីឃ្លៀងឃ្លាតឡើយ ។ អយំ ធម្មទេសនា វិ ព្រះធម៌ទេសនានេះ សម្តា សូមសន្តតថាចប់ ឯវំ ក៏សមគួរដោយទៅវិលានេះឯងហោង ។

លោក ស៊ុន-ហ៊ាន ស្មៀនសៅពន្ធសាសនបណ្ឌិត្យ រៀបរៀង

ឆ្នាំងមាន ៤ យ៉ាង គឺ:

១- ឆ្នាំងទទេ បិទជិត,

២- ឆ្នាំងពេញ បើកចំហ,

៣- ឆ្នាំងទទេ បើកចំហ,

៤- ឆ្នាំងពេញ បិទជិត ។

ឆ្នាំងជាភាជន៍សំខាន់មួយរបស់មនុស្ស ព្រោះជារបស់សម្រាប់ចំអិនអាហារបរិភោគ ។ ឆ្នាំងដែលមានអាហារពេញខាងក្នុង តែងញ៉ាំងប្រយោជន៍ឲ្យសម្រេចដល់អ្នកត្រូវការអាហារ ព្រោះគេឃ្លានពេលណាក៏អាចបរិភោគបានពេលនោះ តែបើគ្មានគ្របបិទក៏មិនល្អមើលសោះ ព្រោះខ្លះគ្រឿងប្រដាប់របស់ឆ្នាំង ថែមទាំងផង់ធូលីហុយចូលធ្វើឲ្យបង់កូលកើតទៀតជាមេរោគបានដោយងាយ, បើមានតែគ្របបិទជិតល្អ តែខាងក្នុងទទេមិនមានអាហារ ក៏គ្មានតែល្អមើលប៉ុណ្ណោះ - មិនញ៉ាំងប្រយោជន៍ឲ្យសម្រេចដល់អ្នកដែលត្រូវការអាហារឡើយ, បើគ្មានគ្របបិទក៏តែតែអាក្រក់ថែមទៀត, បើមានអាហារពេញខាងក្នុងទាំងមានគ្របបិទជិតល្អ ក៏ជារបស់គួរមើល គួរពីតភយ៉ាងក្រៃលែង ទាំងញ៉ាំងប្រយោជន៍ដល់អ្នកត្រូវការអាហារគ្រប់ពេលផង ។

ការដែលខ្ញុំពោលដល់ឆ្នាំងបែបនេះ ជាកិច្ចសំដែងឲ្យឃើញថាឆ្នាំង ប្រៀបបានទឹងរូបមនុស្សយើង ព្រោះខ្លួនយើងដូចឆ្នាំង, ចរិយាសេចក្តីប្រព្រឹត្តដូចគ្រប់ឆ្នាំង, វិជ្ជាសេចក្តីចេះដឹងដូចអាហារដែលពេញខាងក្នុងឆ្នាំង ។ វិជ្ជាសេចក្តីចេះដឹង ទឹងសេចក្តីប្រព្រឹត្តិល្អ ជាគោលសំខាន់យ៉ាងក្រៃលែងរបស់មនុស្ស ព្រោះជាគ្រឿងឧបករណ៍ ដែលទឹងធ្វើជីវិតឲ្យចំរើនឈានទៅមុខបាន ។ អ្នកដែលមានចរិយាសេចក្តីប្រព្រឹត្តរៀបរយ តែបើគ្មានវិជ្ជាដែលទឹងលើកតំកើងហាន:របស់ខ្លួនឲ្យខ្ពស់ឡើងទេ អ្នកនោះដូចគ្មានទឹងឆ្នាំងទេបិទគ្របជិត ជាមនុស្សល្អដោយសារសេចក្តីប្រព្រឹត្តមួយយ៉ាង តែងសេចក្តីចេះដឹងមិនល្អ ព្រោះខ្វះវិជ្ជាជាគ្រឿងឧបត្ថម្ភ ។ មនុស្សបែបនេះ រមែងបណ្តុះសេចក្តីពាប់អានឲ្យកើតដល់ជនាទុជនបានតែមួយជងមួយគ្រាប៉ុណ្ណោះទេ លុះកាលគេដឹងថាខ្លួនមិនមានវិជ្ជាអ្វីសោះហើយ ក៏សាបរលាបលែងពាប់អានទៅវិញ, សម្ពន្ធភាពក៏មិនបានបិតថេរយូរប៉ុន្មាន. ដូច្នេះនឹងចាត់ថាជាមនុស្សល្អពេញហាន:មិនបាន តែកំតង់ល្អជាងអ្នកដែលមិនមានសេចក្តីប្រព្រឹត្តិល្អសោះដែរ ដូចភាសិតបុពណ្ណថា "ផ្លែល្វាមើលទៅឃើញច្រែនស្អុកស្អាស់ មនុស្សដើរមកបានឃើញក៏ត្រេកអរចង់បាន, បេះយកមកជាក់កងមាត់បរិភោគទៅមិនមានឧជារសផ្អែម" ដូច្នេះ ។

អ្នកដែលមានវិជ្ជាតែម្យ៉ាង សេចក្តីប្រព្រឹត្តិល្អគួរសោះ តាមដែលមានចំណេះនោះ គួរណាស់តែនឹងខ្នាតការយ៉ាងចាប់ចិត្តឲ្យប្រព្រឹត្តិទៅដោយរៀបរយបាន តែមិនដូច្នោះ ត្រឡប់ជាប្រព្រឹត្តិអាក្រក់ថោកទាបទៅវិញ បង្កសេចក្តីវិនាសឲ្យកើតឡើងដល់ពួកគណៈ ឬដល់ប្រទេសជាតិ មានវិជ្ជាដូចមានសត្រូវចាំប្រទូសក៏ឃ្លាតខ្លួនឯង សមដូចពាក្យតិះដៀលថា "សេចក្តីចេះដឹងជុំវិញខ្លួន យោងខ្លួនមិនរួច" ។ មនុស្សប្រៀបនេះ ប្រៀបដូចឆ្នាំងពេញដោយអាហារតែបើកគ្រប់ចំហរ ឆ្កែឈ្លអំពីណាបាន? អ្នកណាឆ្កែច្រាច្នាសេពគប់មនុស្សប្រៀបនេះកើត ។

បុគ្គលណាមិនមានសម្បត្តិទាំង ២ យ៉ាងគឺ សេចក្តីចេះដឹងក៏មិនមានសេចក្តីប្រព្រឹត្តិក៏ថោកទាបអាក្រក់ បុគ្គលនោះតែងមិនយកចិត្តទុកដាក់កងអំពើល្អណាមួយឡើយ ធ្លាប់ទាបថោកក៏នៅជាទាបថោក ធ្លាប់ឆ្កឹតក៏នៅជាឆ្កឹត ជាអ្នកបន្ថែមសេចក្តីល្ងង់ឲ្យវិតវែងច្រើនឡើង ។

វិជ្ជាមិនមាន តើប្រព្រឹត្តិឲ្យត្រូវផ្លូវដូចម្តេចបាន? វិជ្ជាមិនមានសេចក្តីភ្លឺស្វាង សេចក្តីឈ្វាសវៃមោះមុតនឹងមានដូចម្តេចកើត? អ្នកមិនមានវិជ្ជាដូចមនុស្សភ្នែកខ្វាក់នឹងដើរទៅផ្លូវណាក៏មិនស្រួល, បើមិនមានវិជ្ជាទេសេចក្តីប្រព្រឹត្តិក៏តែងតែថោកណាស់ទៅទៀត ព្រោះមិនមានអ្វីជាគ្រឿងបំភ្លឺផ្លូវ ។ អ្នកដែលមិនមានវិជ្ជា ទាំងមិនមានសេចក្តីប្រព្រឹត្តិត្រឹមត្រូវធ្វើអ្វីច្រើនខុសគួរឲ្យតិះដៀល ។ មនុស្សប្រៀបនេះ លោកពោលថាដូចឆ្នាំងទទេមិនមានអាហារទាំងមិនមានគ្រប់ចិទផង រមែងធ្វើបាន:របស់

ខ្លួនឲ្យលិចចុះទៅ ព្រោះមិនមានអ្វីដែលនឹងលើកតំកើងហានៈឲ្យល្អឡើងបាន ។ នេះឯងជាចំពូកថោកទាប អាក្រក់ជាងចំពូកជាច្រើនទាំងអស់ ។

អ្នកណាមានវិជ្ជា ទាំងមានចរិយាសេចក្តីប្រព្រឹត្តរៀបរយ លោកទុកអ្នកនោះដូចឆ្នាំងពេញដោយអាហារ ទាំងមានគ្រប់បរិបូណ៌ ។ ជននោះល្អទាំងសេចក្តីចេះដឹង ល្អទាំងសេចក្តីប្រព្រឹត្តិ មិនមានចន្លោះគប្បីតិះដៀលបានឡើយ ។ មនុស្សប្រៃបនេះ តែងធ្វើសម្ពន្ធភាពរវាងមនុស្សឲ្យបិតថេរ មិនសាបរលាប ព្រមទាំងបានទំនុកបំរុងជាន:របស់ខ្លួនឲ្យខ្ពស់ឡើងដោយលំដាប់ ព្រោះមានគុណសម្បត្តិទាំង ២ ប្រការជាគ្រឿងឧបត្ថម្ភ ។ បណ្ឌិតទាំងឡាយតែងប្រាថ្នាមនុស្សប្រៃបនេះ ទៅតានឹងមនុស្សទាំងឡាយតែងលើកតំកើងស្ងួយជាដរាប, មនុស្សប្រៃបនេះនឹងធ្លាក់ទៅក្នុងកន្លែងណាក៏ដោយ ក៏គង់មានមនុស្សមកចោមរោមស្រឡាញ់រាប់អានបូជាយ៉ាងក្រៃលែង ។

ព្រោះហេតុនោះ កុលបុត្តកុលធីតាជាអ្នកប្រាថ្នាទំនុកបំរុងជាន:របស់ខ្លួនឲ្យខ្ពស់ឡើង ជាអ្នកប្រាថ្នាលាភ យស សរសើរ សុខខ្ពស់ៗឡើងទៅ។ គួរតែព្យាយាមអប់រំសេចក្តីចេះដឹងទាំងផ្លូវលោកនឹងផ្លូវធម៌ឲ្យកើតមានឡើង ហើយអប់រំសេចក្តីប្រព្រឹត្តិរបស់ខ្លួនឲ្យសុភាពរៀបរយត្រឹមត្រូវតាមសេចក្តីនិយម ទាំងឲ្យមានសីលធម៌ប្រចាំនៅក្នុងសន្តានជានិច្ចឡើង ទើបនឹងបានជួបប្រទះតែផ្លូវសុភមង្គលតុំឃ្លៀងឃ្លាត ។

ការប្រមូលនិងរៀបរៀង

ព្រះមហាឧត្តមវិជ្ជា ធីលញ្ញាណោ ប៊ុំង-ប៊ីម

អាចារ្យសាលាឃ្លាំលើង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌាធរក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

បើនឹងខ្ចស់ កុំខ្ចស់ ហួសតំណែង
យូរទៅក្រែង ភ្លាត់ថ្នាក់ ធ្លាក់មកក្រោម
បើនឹងមុត មុតចុះ កុំបើកស្រាម
នៅផ្ទៃក្រោម គួរស្តាប់ មនុស្សជក ។
កុំលូកដៃ ចាប់ផ្តាយ នៅលើមេឃ
តែខ្ចស់ពេក ច្រែនឲ្យ វេទនា
គួរយកតែ តំណែង សមវិជ្ជា
ទើបស្មើគ្នា នឹងថ្នាក់ របស់យើង ។

នេះជាកាសិតបុរាណ ដែលជាស់តឿនឲ្យយើងស្គាល់ហានៈរបស់ខ្លួនឯង ។ ដោយហេតុតែការគាំងខ្លួនឲ្យស្មើជាកិត្តិយស ១ យ៉ាង ដែលអាចលើកតំកើងអ្នកប្រព្រឹត្តឲ្យក្លាយទៅ ជាទីនិយមរាប់អានរបស់ប៉ុន្តែលជាខៃយ៉ាងនេះហើយ យើងទើបគួរដំកល់ខ្លួនឲ្យស្មើ កុំឲ្យខ្ចស់ហួសប្រមាណ ដរាបដល់ក្លាយទៅជាមនុស្សព្រហើនប្តូរលើកតំកើងខ្លួនខាល

តែក្មេចខ្លួន នឹងមិនថាបាលតែទៅជាមនុស្សវង្វេង ឬក្លាយទៅជាអ្នកមើលងាយខ្លួនឯង ត្រូវកុំប្រកាន់ខ្លួន កុំខុកយសសក្តិឲ្យជាគ្រឿងសម្រាប់អួត ឬសង្កត់សង្កិនអ្នកដទៃ គួរជឿខ្លួនថាគ្រប់តែមនុស្សតែងមានសភាពប្រហែលគ្នាដោយជាតិកំណើត ផ្សេងគ្នាតែតិចតួចប៉ុណ្ណោះ។ ជាតិកំណើតមិនបានធ្វើនរណាមួយឲ្យជាមនុស្សល្អ ឬជាមនុស្សថ្លៃព្រេងឡើយ តាមពិត ការប្រព្រឹត្តិទេតើ ដែលធ្វើមនុស្សឲ្យក្លាយទៅជាអ្នកល្អឬអាក្រក់ ។ កាលជ្រាបដូច្នេះហើយ ចូរព្យាយាមសំដែងអាការកិរិយាឧនលំអោនទន់ភ្លន់ ឲ្យល្មមមនុស្សគ្រប់ជាន់ចូលមកសមាគមបាន ឬឲ្យជាមនុស្សល្មមចូលទៅកាន់សមាគមនៃមនុស្សគ្រប់ជាន់បាន ចូរធ្វើខ្លួនឲ្យសមគួរដល់បុគ្គលនឹងប្រដុំជននោះ។ កុំក្មេចថាកើតមកជាមនុស្ស ត្រូវគិតដល់កិត្តិយសជាមុន ព្រោះសរីរៈពង់កាយនឹងកិត្តិយសនោះខុសគ្នាឆ្ងាយណាស់ គឺសរីរៈពង់កាយ តែងសូន្យអស់ទៅក្នុងវេលា ១ រំពេចក៏មានឯកិត្តិយសវិញ មិនសូន្យទៅទេ តែងឋិតថេរតទៅដល់អវសានៃកប្ប ។

៣ – លើកជំពើងសរសើរគ្នា .– ធម្មតាមនុស្សគ្រប់រូបរមែងស្រឡាញ់កិត្តិយស មិនចង់ឲ្យនរណាមួយ សូម្បីតែម្នាក់តិះដៀលរិះគន់ ចាក់ដោតខ្លួនបន្តិចបន្តួចឡើយ បើមាននរណាមួយមកធ្វើប្តូរិយាយឲ្យជាការសាបរលាប ឬមើលងាយខ្លួន ខ្លួនក៏មិនគាប់ចិត្ត រមែងសំដែងអាការកិរិយាមិនចូលចិត្តឲ្យច្បាស់ជាឡើងភ្លាម ។ ព្រោះឃើញថាជាការ

ចំណាយក្តៅឈ្មោះបស់ខ្ញុំនឲ្យសាបសូន្យ ។ មនុស្សគ្រប់រូប ត្រូវថ្នាំ
ណាស់ តែនឹងឲ្យអ្នកដទៃលើកតំកើងសរសើរខ្លួន បើមាននរណាមួយ
គេធ្វើប្តូនិយាយឲ្យជាកិត្តិយស សូម្បីតែបន្តិចបន្តួចដល់ខ្លួន ខ្លួនក៏គាប់ចិត្ត
ហើយសំដែងអធ្យាស្រ័យដ៏ប្រពៃតបទៅវិញ ឲ្យត្រូវចិត្តគេក្នុងកាល
មួយរំពេច នេះជាដំណឹង (សេចក្តីដឹង) របស់អ្នកស្រឡាញ់ក្តៅឈ្មោះ ។
ដំណឹងបែបនេះ មានចំពោះខ្លួនយើងដូចម្តេច មានចំពោះអ្នកដទៃ
ក៏ដូច្នោះដែរ ។

លោក-អ្នក ចូរលើកតំកើងសរសើរបុគ្គលដទៃ ឲ្យដូចជាលើក
តំកើងសរសើរខ្លួនឯងចុះ ព្រោះបើគេបានទទួលការលើកតំកើងសរសើរ
អំពីលោក-អ្នកហើយ គេនឹងលើកតំកើងសរសើរលោក-អ្នកវិញ ដូចជា
ទឹកថ្លាត្រជាក់ កាលលោក-អ្នកផ្តួតនឹងបរិភោគហើយ រមែងផ្តល់ឲ្យនូវ
សេចក្តីត្រជាក់ត្រជំរីករាយចិត្ត ដល់លោក-អ្នកដូច្នោះ តែកាលបើលោក-
អ្នកតិះដៀលចាក់រុកគេហើយ ក៏មុខជាគេនឹងតបមកលោក-អ្នកវិញតាម
លក្ខណៈដូចគ្នាជាពុំខាន ត្រូវនឹងភ្ជួនថា :– បាបធ្លាលីប្រាស់ខ្យល់,
ស្ពោះទឹកមាត់ជាក់អាកាស ។ ការមើលគ្នាក្នុងចំណុចដ៏ល្អ, ការ
ប្រព្រឹត្តធ្វើអំពើដែលជាប្រយោជន៍ដល់គ្នា នឹងការជួយទំនុកបំរុងសេចក្តី
ល្អរបស់គ្នា នេះជាលក្ខណៈនៃការលើកតំកើងសរសើរគ្នា ។ បើលោក-
អ្នកសំឡឹងមើលមនុស្សដទៃក្នុងចំណុចដ៏ល្អ, ប្រព្រឹត្តនូវអំពើដែលជា

ប្រយោជន៍ដល់គេនឹងជួយទំនុកបំរុងសេចក្តីល្អរបស់គេហើយ គង់ចាត់ថាន ថា លោក អ្នកជាមនុស្ស ១ រូបបានធ្វើការលើកតំកើងសរសើរគ្នា ដែលបានឈ្មោះថាជាអ្នកមានទិស្សយកចំអានគ្នា ។

ក)- ការមើលគ្នាក្នុងចំណុចដ៏ល្អ នោះ បានដល់ការ ប្រាថ្នាចំណុចដែលល្អ ចាប់ចំណុចដែលត្រូវ នឹងស្មូនរកខ្វះដែលត្រូវ ដោយចំណាំចំពោះគុណគឺសេចក្តីល្អដល់គ្នានឹងគ្នា ដែលចាត់ថាជាការ លើកយកគុណគឺសេចក្តីល្អរបស់គេដែលមានឡើងសរសើរតាមសភាព ពិត មិនមែនប្រាថ្នាចំណុចអាក្រក់ ដើម្បីនឹងសំឡឹងរកទោស មិនមែន ចូលទៅចាប់យកចំណុចដែលខុសដើម្បីនឹងឡកឡឺយចំអកចំអន់ នឹងមិន មែនស្មូនរកខ្វះដែលខុស ដើម្បីនឹងប្រទេចផ្តាសា ឬផ្តាញ់ឱ្យសមនឹងមុខ នោះទេ ។ អ្នកណាព្យាយាមក្នុងការប្រាថ្នាចំណុចដ៏ល្អដល់មនុស្សដទៃ ដូចជាខ្លួនត្រូវការឱ្យគេប្រាថ្នាចំណុចដ៏ល្អដល់ខ្លួនឯងដូច្នោះ អ្នកនោះ ឈ្មោះថាមានជីវិតបរិសុទ្ធ ។ ពេតអាក្រក់របស់មនុស្សគឺសេចក្តីប្រាថ្នា ក្នុងចំណុចដ៏អាក្រក់ដល់មនុស្សដទៃ ដែលជាហេតុនាំឱ្យខ្លួនឯងក្លាយទៅ ជាអ្នកដើរបំផ្ទិចបំផ្លាញមនុស្សដទៃជាដរាបទៅ ។

វិស័យរបស់មនុស្សដែលសំឡឹងមើលគ្នា ក្នុងចំណុចដ៏អាក្រក់នោះ ចូលចិត្តសំឡឹងទោសរបស់អ្នកដទៃ ដើម្បីឱ្យខូចសិរីរបស់គេឃើញតែ អ្នកដទៃអាក្រក់ទាំងអស់ ប្រាថ្នាចាប់ទោសនឹងស្មូនរកកំហុសរបស់គេ

តែម្ល៉ាង មើលមនុស្សដទៃដោយពេញភ្នែក មើលខ្លួនឯងដោយកន្ទុយភ្នែក ឃើញទោសកំហុសរបស់គេបានដោយងាយសូម្បីទោសនោះតូចតាចប៉ុនគ្រាប់ល្ង៉ក់ដោយ តែឃើញទោសកំហុសរបស់ខ្លួនបានដោយកម្រ សូម្បីទោសនោះប៉ុនដូងតាំងសំបកក៏ដោយ ប្រៀបដូចជាមើលធូលីកងភ្នែករបស់បងប្អូនឃើញបាន តែមើលធូលីដែលចូលភ្នែកខ្លួនឯងមិនឃើញដូច្នោះ ព្រោះចេះតែប្រកាន់ថាខ្លួនល្អជាងអ្នកដទៃហើយកំរ៉ាយដំឡៃខ្លួនលើសលុប លើកកំពស់ខ្លួនឡើងឲ្យខ្ពស់ជាងអ្នកដទៃ ។

ប្រុគ្គលយល់ទោស អ្នកដទៃ
តូចប៉ុនគ្រាប់ស្ពៃ ឬ ល្ង៉ក
ទោសខ្លួនប៉ុនដូង តាំងសំបក
បែរកេរិះគយ គន់មិនយល់

(លោកនីតិ)

ទោសកំហុសក្នុងខ្លួនអ្នកដទៃនោះ បើយើងគិតតែពិនិត្យមើលច្រើនឡើងត្រឹមណា ក៏ធើតែតែបង្កើនអនុសយក្លិសឲ្យចំរើនដល់ខ្លួនយើងច្រើនឡើងត្រឹមនោះ ក្នុងទីបំផុត ត្រូវធ្វើឲ្យខ្លួនយើងវិនាស កើតអវិចិត្តបែកបាក់គ្នាឡើងក្នុងរវាងអ្នកដទៃ ។ មនុស្សស្រែងស្រា មនុស្សធ្ងុសប្រហែសប្រមាទ, មនុស្សក្រោធច្រើន, មនុស្សល្ងង់ខ្លៅ, មនុស្សលោភខ្លាំង, មនុស្សកាចសាហាវ, មនុស្សខ្ជាចច្រើន, មនុស្សមាយា

ច្រែន. មនុស្សអំនួត, មនុស្សប្រុសក្បាលឈ្នានិសន្ទឹងមនុស្សសំឡឹងទោស
របស់អ្នកដទៃលាក់ទោសរបស់ខ្លួន អស្ចារ្យនេះ រមែងបានចំរើនតែខាងអាសវធម៌ ។ អ្នកសំឡឹងមើលគាត្មកងំចំណុចដ៏ល្អ ឈ្មោះថាប្រព្រឹត្តធ្វើអំពើជាប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃ ។ ចំណែកអ្នកដែលសំឡឹងមើលគាត្មកងំចំណុចដ៏អាក្រក់ ហើយខំលាក់បិទបាំងទោសរបស់ខ្លួនវិញ ចាត់ថាជាអ្នកប្រព្រឹត្តធ្វើអនត្ថ សេចក្តីវិនាស ចំពោះខ្លួនឯងនឹងអ្នកដទៃផង ។

មិនឲ្យអ្នកគ្រៅ ដឹងទោសខ្លួន ·
ទោសគេបំពួន អាចដឹងបាន
ទោសខ្លួនពួនលាក់ ធ្វើហាក់គ្មាន
ដូចលាក់ដើងក្រាន លាក់គ្រាប់ផ្សិង

(លោកនីតិ)

ខ) ប្រព្រឹត្តធ្វើអំពើដែលជាប្រយោជន៍ដល់គ្នា — ការធ្វើអំពើដែលជាទីគាប់ចិត្ត ជាទីត្រេកអរចំពោះគ្នានឹងគ្នា ទាំងអំពើនោះក៏មនុស្សពួកច្រែនយល់ព្រមថាល្អ ចែមទាំងខំព្យាយាមធ្វើខ្លួនឲ្យជាប្រយោជន៍ចំពោះមនុស្សខ្លួនៅ ដោយតាំងចិត្តថាជាមនុស្សដូចគ្នា នេះចាត់ថា ជាការប្រព្រឹត្តធ្វើអំពើដែលជាប្រយោជន៍ដល់គ្នាមួយ ។ មនុស្សដែលនៅរួមជាមួយគ្នា ត្រូវតែគោរពចំពោះប្រយោជន៍នៃគ្នានឹងគ្នា ។ ព្រោះថារបស់ណាជាប្រយោជន៍ខ្លួន របស់នោះគង់ជាប្រយោជន៍អ្នកដទៃដែរ ។

(មានត)

កណ្ដាំទី ១៦

ឧកញ៉ាវិបុលរាជសេនា ស្ងួ-កន ប្រែរៀបរៀង

(តមក)



បំរើសេះដើរថា លីចោ៉ះប្រើកោស៊ុនទុំនតៀវលៀវលើកទៅកាយស្រុកសៀវផាយ កំនាំយកសេចក្តីនោះទៅជំរាបឡៅពីថា លីចោ៉លើកទ័ពមកធ្វើអន្តរាយដល់លោកហើយ ឥឡូវកងទ័ពលើកមកដាច់ព្រំដែនស្រុកសៀវផាយ ។ ឡៅពីឮដូច្នោះក៏ភ័យស្លុតចិត្ត ទើបប្រឹក្សានឹងសេនាគហានគំនង់ពួងថា ដែលលី ចុ៉ឲ្យលើកកងទ័ពមកនេះ អ្នកគំនង់ឡាយនឹងគិតឃើញប្រការម្តេចខ្លះ? ។ សុនវៀនឆ្លើយថា សុំឲ្យលោកធ្វើសំបុត្រប្តឹងចូលទៅសុំកងទ័ពចូរឲ្យលើកមកជួយ ។ ឡៅពីយល់ឃើញត្រូវក៏សួរថា នរណានឹងយកអាសានាំសំបុត្រទៅបាន? ។ តាន់យ៉ុងដែលទើបមកចូលធ្វើពដការថ្មី ធ្វើយសុំយកអាសានាំសំបុត្រទៅឲ្យចូរ ។

កណ្ឌទី ១៧

តាំងពីឡៅពីធ្វើសំបុត្រចាត់ចំរើឲ្យទៅ សុំកងទ័ពចូលក្រុងហ៊ូគោមកជួយប្លន់ នឹងលីបៅ រហូតដល់ត្រូវហ៊ុយចាប់ឡាន់បេងសេនាលីបៅបានតាំទៅឲ្យឡៅពី ។

ឡៅពីក៏សរសេរសំបុត្រថា "ឥឡូវនេះលីបៅប្រែគាហានលើកទ័ពទៅច្បាំងយកស្រុកសៀវផាយហើយ ខ្ញុំបានឡៅពីសុំកងទ័ពមហាឧបរាជឲ្យលើកទៅជួយ" លុះសរសេរចប់ក៏ប្រគល់សំបុត្រនោះឲ្យតាន់-យ៉ុងកាន់នាំសំបុត្រនោះទៅក្រុងហ៊ូគោ ហើយឡៅពីឲ្យជួសជុលបន្ថែយរយៈចំងាយ ជីកស្នាមក្តោនខ្ពស់ជាគួរកំផ្សរជុំវិញកំពែងយ៉ាងមាំមួន ហើយចាត់គាហានយាមល្បាតលើសើនបន្ថែយ រយៈផ្ទាស់ប្តូរវេនគ្នាទាំងយប់-ថ្ងៃ ចាត់គៀវហ៊ុយឲ្យធំជាងគេ ថែរក្សាគយល្បាតហាតក្រវែលខាងទិសបូព៌ា ចាត់ឲ្យកួនអ៊ូថែរក្សាគយខាងទិសបស្ចិម ចាត់ឲ្យស៊ុនខៀនថែរក្សាគយខាងទិសទក្សិណ ខ្លួនឡៅពីថែរក្សាគយខាងទិសឧត្តរ ចាត់ឲ្យប៊ីតុកជាបង់ប៊ីហាងត្រួតជាបង់ថ្នៃ ឡៅពីនោះនៅត្រួតត្រាក្សាគ្រប់គ្រង ។

ឯកោស៊ុននឹងគៀវលៀវ លើកគាហានចូលទៅតាំងក្បាច់នឹង ដីងកំពែង ឡៅពីនៅលើសើនក្រឡេកឃើញក៏ស្រែកសួរកោស៊ុននឹងគៀវលៀវថា យើងនឹងលំបោះមិនមានហេតុអ្វីជាខោសខាស់គ្នាសោះ ហេតុម្តេចក៏បានជាលើកទ័ពមកទប់រាយស្រុកយើងដូច្នេះ ។ កោស៊ុនឆ្លើយថា "ខ្លួនអ្នកឯងគិតតែគ្មានឹងចូលធ្វើសំបុត្រទៅវិញទៅមក ដើម្បីនឹងធ្វើសេចក្តី

អ្នកយកដល់ទៅហ្វាយយើង រឿងទាំងអស់លើចៅដឹងអស់ហើយ ហេតុ
ម្តេចខ្លួនឯងថា មិនមានទោសទាស់ខុសវិញ។ ហើយគោស៊ុនក៏បង្រៀន
ដេញគាហានឲ្យចូលទៅមុខដុំវិញដើងកំពែង ។ ទៀតពីក៏ប្រើគាហាន
ឲ្យត្រួតត្រាក្បាដើងបន្ទាយជាយ៉ាងមាំមួន លុះពេលព្រឹកឡើង តៀវ-
លៀវក៏លើកគាហានចូលវាយគយខាងទិសបូព៌ ។

កួនអ៊ូឃើញរូបតៀវលៀវស្អាតល្អសមជានាហ្មឺនមុខន្ត្រី ក៏ស្រែក
សួរជាកលទុបាយថា ខ្លួនអ្នកមានព័ណ៌សម្បុរបរិបូណ៌ល្អត្រម យើង
យល់ឃើញថាជាមនុស្សមានសតិបញ្ញានឹងសេចក្តីអឿនខ្លាស ហេតុម្តេច
មកនៅជាបាវព្រាវលើចៅដែលជាមនុស្សចិត្តអាក្រក់ យើងឃើញមិនសម
គួរសោះ ។ តៀវលៀវបានឮដូច្នោះក៏មានសេចក្តីខ្មាសណាស់ មិនមាន
ឆ្លើយតបថាអ្វី ។ កួនអ៊ូឃើញថាតៀវលៀវមានបញ្ញាហើយមានសេចក្តី
អឿនខ្មាស ក៏មិនបាននិយាយទៀតោះបែកចោះមើលផ្លាយទៅទៀត ។
តៀវលៀវក៏លើកគាហានថយទៅ ហើយលើកទៅវាយគយខាងទិស
បូព៌ ។ តៀវហ៊ុយឃើញក៏នាំគាហានចេញតច្បាំងនឹងតៀវលៀវ ។
មានគាហានតែ់ទៅប្រាប់កួនអ៊ូថា ឥឡូវតៀវលៀវលើកចូលទៅវាយគយ
ទិសបូព៌ ហើយតៀវហ៊ុយក៏លើកចេញត ។ កួនអ៊ូបានឮដូច្នោះក៏
ស្រែតទៅប្រាប់ ឃើញតៀវហ៊ុយលើកចេញពីទ្វារស្រុកទៅ ។
តៀវលៀវក្រឡេកឃើញតៀវហ៊ុយចេញមក ក៏ឲ្យនឹកវន្ទត់ភ័យខ្លាចមិន

អាចនឹងចូលតស៊ូបាន នាំគាហានតាំងអស់ថយទៅទៀត ។ តៀវហ៊ុយ
ឃើញបានការកំបរពេលចូលដេញពីក្រោយ ។ កូនអ៊ូស្រែកឃាត់ថា
កុំអាលដេញឲ្យត្រឡប់មកវិញសិន ។ តៀវហ៊ុយបានឮក៏ប្រែត្រឡប់
ទ័ពមកក្រោយហើយស្ទុះកូនអ៊ូថា សឹកសត្រូវត្រូវឧកាសស្រួលនឹងចូល
យកជ័យជំនះបាន ហេតុម្តេចមកស្រែកឃាត់ឲ្យខូចការដូច្នេះវិញ ។
កូនអ៊ូក៏អធិប្បាយពាយរឿងឲ្យតៀវហ៊ុយស្តាប់ហើយថា ចូរដៃប្អូននឹង
តៀវលៀវនេះ បើនឹងច្បាំងតស៊ូគ្នាក៏ល្មមកំឡាំងនឹងធ្វើបាន តែបងគិត
ស្មានថាតៀវលៀវនោះមានសតិបញ្ញាកិរិយាជាអ្នកមឿនខ្មាស បានជា
នាំគាហានត្រឡប់ចាស់ថយក្រោយទៅវិញ ២ លើកហើយ បងឃើញថា
តៀវលៀវមានគំនិតនឹងគិតបែកចិត្តចេញពីលិ៉ចុ៉ បានជាបងឃាត់ហាមដូច្នេះ ។ តៀវហ៊ុយក៏សរសើរថា "បងគិតនេះប្រសើរណាស់ ព្រោះ
យល់ស្គាល់ឃើញចិត្តមនុស្សច្បាស់" ហើយតៀវហ៊ុយក៏លើកគាហាន
ត្រឡប់ចូលក្នុងស្រុកវិញ ឲ្យត្រួតត្រាក្សាសើនបំនួយដូចដែល ។

ឯតាន់ឃ៊ុងដែលកាន់សំបុត្រទៅប្តឹងបួនោះ លុះបានទៅដល់
ហើយក៏ជូនសំបុត្រនោះទៅបួ ។ ដងសេចក្តីហើយក៏ប្រឹក្សានឹងសេនា
គាហានថា លីចុ៉លើកទ័ពទៅវាយយកស្រុកសៀវផាយនោះ ត្រូវតែ
យើងលើកទ័ពទៅជួយឡៅពីជាប្រញាប់ ទោះប៉ុន្តែសៀវនឹងលើកទ័ព
មកខាងណេះយើងក៏មិនត្រូវតក្តត្រួយ ខ្លាចមួយតែឡៅពៀវនឹងតៀវស៊ីវ
វែងលើកត្រឡប់មកពីក្រោយវាយយកស្រុកយើង ។

ស៊ុនហ៊ីដំណាលថា ឯទ្ធភៀនឌីងតៀវស៊ីនោះ ទើបតែនឹងបរាជ័យ
ចាញ់យើង បើគោះបីយ៉ាងណាក៏មិនអាចនឹងរៃគិតលើកមកកងពលនេះ
បានទេ, ឯលីចោ៉ាងនោះដាមនុស្សមានថ្វីដៃខ្លាំងពូកែ តាំងចិត្តក៏ប្រែកំរើប
តាំងខ្លួនជាធំ បើយើងនឹងសម្លុកយូរទៅ មុខជាលីចោ៉ានឹងអ្នុនសុគតប់
គិតគ្នាជារូបមួយ កំឡាំងក៏តែតែមានច្រើនឡើង ឃើញថាយើងនឹង
កំចាត់ចេញបានដោយលំបាកណាស់ ។

គុយតែបានឮស៊ុនហ៊ីនិយាយត្រូវនឹងគំនិតខ្លួនដូច្នោះ ទើបដំរាប
ចូនួថា ដែលស៊ុនហ៊ីនិយាយនេះត្រូវណាស់ សុំឲ្យមហាឧបរាជលើក
ទំពៅកំចាត់លីចោ៉ាជាប្រញាប់ចុះ ព្រោះពេលនេះកំលាំងវាទៅខន់មុខ
ជានឹងបានជ័យជំនះដោយងាយ ។ ចូនួយល់ឃើញត្រូវក៏តម្រូវឲ្យប្រុង
ប្រៀបរៀបកងទ័ព បង្គាប់ហៃហ៊ុន, ហៃហ៊ូអៀន, លីយ៉ាយ លើតៀន
តាំង ៤ នាយនេះឲ្យលើកទាហាន ៥ ម៉ឺនជាកងទ័ពមុខលើកស្រុតទៅមុន
ចូនួលើកទាហានដែលមានថ្វីដៃច្រើនអ្នកជាកងស្លង លើកទៅជួយទ្ធភៀ
ឯស្រុកសៀវជាយ ឯគាន់យ៉ូងដែលកាន់សំបុត្រទៅនោះ ក៏ត្រឡប់មក
ជាមួយនឹងកងទ័ពចូនួ ។

បំរើសេះកោស៊ុនទាំសេចក្តីទៅប្រាប់កោស៊ុនថា ចូនួឲ្យហៃហ៊ុន
លើកកងទ័ពទៅជួយទ្ធភៀជាច្រើន ឥឡូវលើកមកដល់ដែនស្រុកសៀវ
ជាយហើយ ។ កោស៊ុនដឹងដូច្នោះក៏ភ័យស្លុតចិត្ត ទើបប្រើបំរើសេះឲ្យ

នាំសេចក្តីនោះទៅថ្វាយលីចាំ" ។ កំប្រើហៃហ៊ីឡេង ១, ឡាន់បេង ១, ចោសេង ១ នឹងគាហានសេះ ២៥០ លើកជាទ័ពណ្តូនទៅជួយកោស៊ុន ឯស្រុកសៀវផាយ ។ ឯកោស៊ុនបានកម្លាំងច្រើនឡើង កំថយកងទ័ពចេញទៅតាំងបន្ទាយចាំទទួលកងទ័ពចូឆ្ងូ ក្បែរព្រំដែនស្រុកសៀវផាយ ចម្ងាយផ្លូវប្រហែល ១០ សិន (៤ គីឡូម៉ែត្រ) ។ ឡៅពីឃើញកោស៊ុនថយទ័ពចេញទៅដូច្នោះ កំគិតឃើញថាចូឆ្ងូលើកកងទ័ពមកដល់ហើយ កោស៊ុនចាំមកខ្វាចចូឆ្ងូ នឹងលើកទ័ពមកវាយខ្ទប់ពីក្រោយបានជាថយទៅ" ឡៅពីកំប្រើស៊ុនខៀន, ប៉ុតុកនឹងប៉ុហង៍ឲ្យនៅរក្សាស្រុកសៀវផាយហើយនាំយកកងទ័ពអ៊ូ តៀហ៊ុយនឹងគាហានចាំងតួង៉ចេញទៅតាំងបន្ទាយក្រៅកំពែងស្រុកចាំទទួលទ័ពចូឆ្ងូ នឹងបានរិះគិតគ្នាផ្តើការសង្គ្រាមតទៅ ។

ហៃហ៊ីទុនលើកទ័ពមកដល់ដែនស្រុកសៀវផាយ កំប្រទះទល់ទ័ពកោស៊ុន, ហៃហ៊ីទុនកំបរសេះចូលតយុទ្ធនឹងកោស៊ុនបាន ៥០ ភ្លេត, កោស៊ុនតទល់នឹងហៃហ៊ីទុនមិនបានកំញាក់សេះរត់គ្រឡប់ចូលបន្ទាយទៅវិញ, ហៃហ៊ីទុនបានទំនងស្រួលកំបរពលចូលតាមទៅ ។ ចោសេងឃើញហៃហ៊ីទុនដេញកោស៊ុនមក កំលើកធ្នូបាញ់ត្រូវក្អែកវាធ្លាក់ហៃហ៊ីទុនខ្លាក់ ព្រួញកំធ្លាក់ជោតជាប់ក្នងវាល់ក្អែក ហៃហ៊ីទុនស្រែកសន្ធាប់ដោយសំឡេងខ្លាំង កន្ត្រាក់ដកយកព្រួញមកមើលឃើញក្អែកសណ្តកជាប់នឹងចុងព្រួញចេញមកកំស្រែកទៀតថា ក្អែកក្អែកនេះជាដួងកំណើត

ដ៏រសេសមិនគួរនឹងបោះចោល ហៃហ៊ុនក៏ចំពាលេបស្រូបចូលទៅតាំងតែ ក្អែកនឹងព្រួញបាត់ទៅក្នុងពោះ ។

ឯចោរសេងនោះក្រឡេកឃើញហៃហ៊ុនត្រូវព្រួញហើយ ក៏ធ្វេសប្រហែសគិតថាហៃហ៊ុនកាលណានឹងធ្វើការតទៅទៀតបាន ក៏មិនប្រុងរាំងខ្លួន ហៃហ៊ុនក៏បំផាយសេះចូលទៅលើកខ្លួនចាក់ត្រូវចោរសេងធ្លាក់ពីលើសេះស្លាប់ ។ ហៃហ៊ុនក៏ត្រឡប់ចូលបន្ទាយ តាហានតាំងឡាយក៏សរសើរហៃហ៊ុនថា មានថ្លើដែងខ្លាំងពូកែគ្មាននរណាស្មើបាន សត្រូវបាញ់ត្រូវក្អែកហើយក៏នៅទំយកដាយជំនះបានទៀត គួរជាសេនាឯក ។

កោស៊ុនឃើញហៃហ៊ុនត្រូវព្រួញ ហើយត្រឡប់ចូលបន្ទាយដូច្នោះ ក៏លើកទ័ពត្រឡប់ដេញតាមក្រោយទៅ ចូលប្រកាប់កងកងទ័ពហៃហ៊ុន ។ តាហានហៃហ៊ុនមិនដឹងខ្លួនក៏ចាក់បែកខ្ចាត់ខ្ចាយ, ហៃហ៊ុនអៀនភ័យណាស់ក៏នាំហៃហ៊ុនរត់ទំលាយបន្ទាយចេញទៅ. លីយ៉ាយនឹងលីទៀនក៏នាំតាហានរត់ទៅតាំងបន្ទាយនៅចុងស្រុកចេង៉ាក ។ កោស៊ុន ក៏លើកទ័ពដេញកាប់សម្លាប់កងទ័ពហៃហ៊ុនស្លាប់ជាច្រើន ហើយលើកទ័ពត្រឡប់ទៅវាយស្រុកសៀវផាយវិញ ។ ខ្លួលលីចោ៉ លើកទ័ពមកជួបនឹងកោស៊ុនៗ ក៏ថ្លែងនាតិមាន ដែលហៃហ៊ុនបែកទ័ពឲ្យលីចោ៉ស្លាប់គ្រប់ប្រការ ។ លីចោ៉ក៏លើកទ័ពរួមគ្នានឹងទ័ពកោស៊ុនទៅ

ទល់ទឹងកំពែងស្រុកសៀវភៅយ ឃើញទ្លៅពីតាំងបន្ទាយនៅត្រើកំពែងញអន្ទើ ។ លីចោ"ក៏ប្រើគោស៊ុនទឹងតៀវលៀវលើកចូលវាយបន្ទាយកួនអ៊ូ ។ ខ្ញុនលីចោ"លើកចូលវាយបន្ទាយតៀវហ៊ុយ, ឯកួនអ៊ូទឹងតៀវហ៊ុយក៏លើកទាហានចេញតតែសព្វខ្ញុននៅមុខបន្ទាយ ។ លីចោ" បែងទាហានលើកត្រឡប់ទៅខូបវាយពីត្រើយបន្ទាយកួនអ៊ូ ទឹង តៀវ-ហ៊ុយ។ មិនដឹងខ្ញុន ហើយទាហានតិចជាង់លីចោ"ទឹងតស៊ូមិនបានក៏បែកខ្ចាត់ខ្ចាយចេញពីបន្ទាយអស់ ។

ទ្លៅពីឃើញកួនអ៊ូតៀវហ៊ុយបែកបន្ទាយ ក៏នាំទាហានប្រមាណ ៣ ០ នាក់រត់ចេញពីបន្ទាយទៅដល់ទ្វារស្រុក ហើយទ្លៅពីស្រែកឲ្យអ្នកចាំទ្វារបើកទ្វារទួល។ លីចោ"ដេញតាមមកទាន់ទ្លៅពី ទាហានចាំងសងខាងក៏លាយឡំគ្នា, ទ្លៅពីរត់ចូលទៅក្នុងស្រុកបំទ្វារមិនទាន់, លីចោ"ក៏បរពលចូលតាមទៅបាន, ទាហានដែលនៅក្នុងស្រុកសៀវផ្សាយក៏បែកខ្ចាត់ខ្ចាយអស់ទៅ ។ ទ្លៅពីឃើញទំពលីចោ"ដេញខ្លាន់ៗ ចូលមកទឹងតស៊ូមិនបាន ក៏លះចោលគ្រប់គ្រឿងយុទ្ធ បរសេះរត់តាមទ្វារទៅទិសឯលិច ។ លីចោ"ក៏ដេញកាប់សម្លាប់ទាហានទ្លៅពីស្លាប់វិនាសជាច្រើន ។

ឯប៉ុតុកដែលនៅរក្សាគ្រប់គ្រងទ្លៅពី ឃើញលីចោ"ដេញកាប់សម្លាប់មនុស្សមកដល់មុខផ្ទះ ក៏ចេញទៅគោរពគំនាប់លីចោ"ថា ខ្ញុំបាទបាន

ព្រះចាស់បុកណាពោលតៗ មកថា អ្នកដែលទន្ទឹងតាំងខ្លួនជាធំតទៅបាននោះ
នោះទន្ទឹងរកយកទំពាប់យកស្រុកណា ក៏ប្លាស់ថ្នាតែជ័យជំនះ មនុស្សណា
ដែលជាគូសត្រូវក៏ធ្វើអន្តរាយតែអ្នកនោះ មិនបានធ្វើអន្តរាយទៅដល់
គ្រប់គ្រងទឹកឃើយបុត្រនូវអាណាប្រជានុកូលដែលឥតកំហុសនោះ
ឡើយ ឥឡូវខ្លួនលោកក៏ប្រឆាំងទន្ទឹងតាំងខ្លួនធ្វើធំ ឯគូសត្រូវរបស់លោក
ក៏គឺបូធូតែមួយប៉ុណ្ណោះ ដូចឡៅពីនោះមិនមែនជាគូវៃរទន្ទឹងលោកសោះ
ឡើយ សព្វថ្ងៃនេះឡៅពីមានតែសេចក្តីគិតដល់លោកជារឿយៗ ថា
កាលគ្រាអ៊ីនសុតប្រើគីឡេងលើកទំពាមកវាយស្រុកសៀវជាយ បាន
លោកលើកទំពាមកជួយ សូវដែលបាញ់ធ្នូធំសំឡេងដែលនិយាយគ្នា
ក៏ច្រឡំនាំឲ្យគីឡេងប្រែចិត្តគិតមេត្រីលើកទំពាត្រឡប់ទៅវិញ ឡៅពី
នោះមិញក៏បានសេចក្តីសុខដោយមកគុណលោកមានលើខ្លួនឡៅពី; មួយ
ទៀតឡៅពីធំលោកក៏មានឧបការៈទៅវិញទៅមក សុំកុំឲ្យលោកធ្វើ
អន្តរាយកឃើយបុត្រឡៅពីឡើយ គុណរបស់លោកក៏ធំមានលើឡៅពី
ទៅមុខទៀត ។

លីប៉ាធ្វើយថា "អ្នកកុំបារម្ភដាក្តុក្តុឡើយ យើងធំទឹងឡៅពីក៏ដា
មិត្តវិស្សាសៈនឹងគ្នាមកពីដើម ឯគ្រប់គ្រងកឃើយបុត្រឡៅពីនោះ យើង
មិនបានធ្វើអន្តរាយទេ" ថាហើយក៏ឲ្យប៊ីតុកនាំកឃើយឡៅពីទៅកុងឯ
ស្រុកគីដូវ ។

លីចាំ"ក៏ចាត់ចែងរៀបចំឲ្យកោស៊ុនទឹងតៀវលៀវនៅឈរវក្សាស្រុកសៀវផាយ ឯលីចាំ"ក៏លើកទ័ពស្រុតចេញទៅទិសបូព៌ា ធ្វើថ្នាំដើម្បីទឹងវាយយកស្រុកគុនជីវ ទទួលជួបទឹងតាន់កុង, ពុងចាំ" ដែលមកពីបញ្ជុះបញ្ជូលពួកចារនៅលើភ្នំថៃសាន់ លីចាំ"ក៏ចាត់តាន់កុងទឹងនាយចារចាំង ៤ នាក់ ឲ្យនៅរក្សាគយសៀវគួន ហើយលីចាំ"ក៏លើកទ័ពទៅវាយអាណាខែត្រខាងទិសបូព៌ ។

ឯកួនអ៊ូកាលវត់ពីលីចាំ"ចេញផុតពីបន្ទាយ ក៏ឃានជួបគ្នាទឹងតៀវហ៊ុយកណ្តាលផ្លូវ កួនអ៊ូសួរតៀវហ៊ុយថា ឬអ្នកឃានជួបប្រទះទឹងឡៅពីឬទេ? ។ តៀវហ៊ុយធ្វើប់ថាកាលខ្ញុំបែកមកនោះក៏ខ្លាត់ខ្លួយគ្នាមិនបានដឹងថា ឡៅពិនទឹងវត់ទៅខាងតំបន់ណា ។ កួនអ៊ូ តៀវហ៊ុយ គិតដល់ឡៅពីក៏ភ្ញៀកកគ្នាយំ ហើយក៏នាំគ្នាទៅតាំងហ្វឹកហាត់សេនាគាហានទៅតំបន់ច្រកភ្នំ ១ អន្លើ ។

ឯឡៅពីវត់ចេញពីស្រុកសៀវផាយ បំផ្ទាយសេះទៅឆ្ងាយណាស់ចម្ងាយផ្លូវប្រហែល ៥០០ សិន (២០ គ.ម.) ជួបប្រទះទឹងស៊ុនខៀនដែលឲ្យនៅរក្សាស្រុកវត់ចេញទៅមុន ឡៅពិនទឹងស៊ុនខៀនក៏នាំគ្នាយំសោកាហើយឡៅពីសួរថា កួនអ៊ូ តៀវហ៊ុយឬអ្នកយើងទឹងស្លាប់ឬរស? វត់ទៅទីណាក៏មិនបានដឹងដំណឹងសោះ? ខ្ញុំយើងពេលនេះអស់ទីពឹងហើយដូចជាគេហែលទឹកកណ្តាលសមុទ្រ ។ ស៊ុនខៀនថា តើតហេតុ

តាំងនេះ ព្រោះលោកគប់គិតទុំងគេធ្វើអាក្រក់នឹងលីហ្ចោ លោកមើប
ឃើនសេចក្តីលំបាកដូច្នេះ តទៅនេះគួរលោកទៅរកចូរធ្វើជាទីពឹងទុំងឃើន
តាំងខ្លួនគិតការតទៅ ។ ឡៅពីឮស៊ុនខៀនថាដូច្នោះ ក៏ធូរស្រាកក្នុងចិត្ត
ទើបនាំស៊ុនខៀនគេចចូលទៅកងកៃ ដើម្បីទឹងទៅរកចូរឯក្រុងហ៊ូតោ ។

កាលឡៅពីទឹងស៊ុនខៀនរត់ទៅនោះ អត់ឃាយអតទឹកលំបាកពេក
ណាស់ លុះដើរទៅដល់ភូមិតំបន់ណា ក៏បបួលគ្នាចូលទៅសុំឃាយគេ
អាស្រ័យ ។ បណ្តាពស្ត្រតាំងពួងដឹងថាឈ្មោះឡៅពីចាញ់ទ័ពគេរត់មក
ក៏មានចិត្តអាណិតអាសូរគន់ប្រមាណ នាំញាតិសន្តានរៀបតុលៀង
អ៊ាហារឲ្យឡៅពីបរិភោគគ្រប់ភូមិស្ថានរៀងទៅ ។ រំលោងឃើថ្ងៃ ១
នោះឡៅពីក៏ដើរទៅផុតភូមិកែរព្រៃហើយប្រឹក្សាទឹងស៊ុនខៀនថា យើង
ឃ្លាតចាកមកពីស្រុកជាច្រើនថ្ងៃហើយ មិនដែលខ្វះខាតចំណីអាហារ
បរិភោគសោះ ដើមតែថ្ងៃនេះទឹងរកទីសំណាក់អាស្រ័យពុំបាន បើដូច្នេះ
តើនឹងគិតធ្វើដូចម្តេច? ។ កាលឡៅពីទឹងស៊ុនខៀនកំពុងប្រឹក្សាគ្នា
ក៏ក្រឡេកមើលទៅឃើញផ្ទះ ១ នៅកងកៃ ពឡៅពីអរណាស់ក៏នាំស៊ុន
ខៀនចូលទៅសុំសំណាក់នៅផ្ទះនោះ ។ ឯឡៅអាន់ម្ចាស់ផ្ទះ ក្រឡេក
ឃើញឡៅពីទឹងស៊ុនខៀនចូលមកក៏មិនស្គាល់ថាជាអ្នកណាទេ ចេញមក
ទទួលហៅឡើងទៅលើផ្ទះ ។

(មានត)

រឿងអាវ៉ក្សថ្លែងរឿងម្ចៃទ្រាំ

លោក រ៉ាយ - ប៊ុក ក្រមការ

ប្រែពីចាវ៉ាំងមកជាខ្មែរ

(តមក)

រឿងទីម្ភៃមួយ

អាវ៉ក្សក្រាបបង្គំទូលថា: មាននគរមួយឈ្មោះជយសថល (Jayasthal) មានព្រះមហាក្សត្រិយ៍មួយព្រះអង្គសោយរាជ្យ ទ្រង់ព្រះនាម វ៉ធម៌ន (Vardhaman) ។ មានព្រាហ្មណ៍ម្នាក់នាម វិស្ណុ ស្វាមី (Vishnu-Swâmi) (នាមនេះប្រែថា ព្រះអាទិទេពវិស្ណុ) ដែលស្ថិតនៅទីនគរនោះ គាត់មានកូនប្រុស ៤ នាក់ ។ កូនទីមួយជាអ្នកលេងល្បែងស៊ីសង, កូនទីពីរជាអ្នកលេងស្រី. កូនទីបីជាអ្នកប្រតិត្តអច្ចាយមុខ, កូនទីបួនជាអ្នកមិនជឿព្រះអាទិទេព ។ ម៉ានកាលមួយថ្ងៃ, ព្រាហ្មណ៍ពោលទៅកាន់កូនទាំង ៤ នាក់នោះថា: "ជោគវាសនាមិនបានស្ថិតនៅក្នុងគេហដ្ឋានអ្នកលេងល្បែងស៊ីសងទេ" ។ កូនប្រុសដែលជាអ្នកលេងល្បែងស៊ីសង ដល់ពុទ្ធាប៉ាបិតាក៏មានគុណតែមនស្សត្រង់ឆេក ។ ព្រាហ្មណ៍ក៏ពោលថែមទៀតថា: "នៅក្នុងគម្ពីរ ធីតិវ៉ែងថា ត្រូវតែអ្នកដេញអ្នកលេងល្បែងស៊ីសងចេញពីភូមិអ្នក, ហើយមុខនឹងដេញត្រូវគាត់ច្រមុះនឹងត្រចៀកវាចេញ ដើម្បីកុំឲ្យអ្នកឯទៀតយកតម្រាប់តាម ហើយអ្នកកុំទូលអង្វរវាឲ្យសោះ ទោះបី

ឥមានតវិយោ, កូនក៏ដោយ ព្រោះរាល់ដង្ហើមរបស់អ្នកវង្វេងគ្មានសំបាក ។ អ្នកណាដែលមានចិត្តទន់ខ្សោយចំពោះសេចក្តីកាន់ខ្លួននៃពួកពាលអតិថុតបុរស (បុរសដែលបញ្ចើចព្រះមហាក្សត្រិយ៍) អ្នកនោះតែងបានទទួលទុក្ខលំបាក ។ បើអ្នកនោះនៅក្រោមបង្គាប់អ្នកលេងស្រី, អ្នកនោះមុខជាអន្តរាយខ្លួនពុំខាន ។ មួយទៀតមានគម្ពីរពោលថា ស្ត្រីអាចបញ្ឆោតចិត្តបុរសបានក្នុងមួយម៉ោង; បើអ្នកណាចង់សង្កត់អំពើស្ត្រីបាន អ្នកនោះគេទុកជាបណ្ឌិត, អ្នកណាដែលមានចិត្តស្នេហាចំពោះស្ត្រី អ្នកនោះនឹងអន្តរាយទាំងអស់ គឺអន្តរាយ សទ្ធា, គុណសម្បត្តិ, សច្ចធម៌, ការល្បីល្បាញ, គុណធម៌, បំណាង, សាសនា ។ យោបល់នៃពួកគ្រូ ពួកនេះមិនចូលចិត្តស្តាប់ ហើយគេបានពោលថា អ្នកណាដែលគ្មានហិរិនុត្តប្បៈ អ្នកនោះមិនខ្វាចបំបាត់កិត្តិនាមនៃអ្នកដទៃទេ ។

មានសុភាសិតមួយពោលថា: "ឆ្នាំព្រៃតែងបរិភោគកូនវា តែមិនអាចឲ្យកណ្តុរណាមួយ រត់ផុតពីក្រហានឡើយ" ។

ព្រាហ្មណ៍បិតាពោលតទៅទៀតថា: "អ្នកណា កាលនៅយុវន័យមិនបានសូត្រសៀនខ្ទរវិទ្យាសាស្ត្រ. អ្នកណាផ្ញើចិត្តឲ្យកន្ត្រាក់កន្តែងតាមគុណហើយអួតអាងខ្លួនឯង អ្នកនោះដល់ទៅចាស់ជរាមុខជានឹងស្តាយក្រោយតែងត្រូវក្តៅគឹសេចក្តីកំណាញ់ជុតពេលក្នុងហាទយវត្ថុ" ។

អ្នកទាំងប្អូននាក់ ដល់បានស្តាប់ពាក្យព្រាហ្មណ៍ជាបិតា, ក៏ប្រឹក្សាគ្នាហើយក៏ពោលថា "ជាតិកូនប្រុស គួរតែស្តាប់ល្អជាង បើរស់នៅដោយ

គ្មានវិន្យា, ដូច្នេះយើងត្រូវតែទៅប្រទេសដទៃ ដើម្បីនឹងស្វែងរកវិន្យាទាំងនេះ" ។ ដល់សម្រេចកង់ចិត្តដូចនេះ អ្នកទាំងបួនក៏ចេញចាកកូមិរបស់ខ្លួនទៅកាន់ទីក្រុងមួយ. ហើយក៏បានទៅសិក្សារៀនសូត្រនូវវិន្យាចំណេះ, បានច្រេះសព្វគ្រប់ក៏វិលត្រឡប់មកកាន់គេហដ្ឋានវិញ ។ ទៅតាមផ្លូវដែលធ្វើដំណើរវិលមកវិញ, ពួកនេះបានឃើញកញ្ជរ (Kanjar= មនុស្សមានវណ្ណៈទាបតែងសម្លាប់ពស់យកមកបរិភោគជាអាហារ) ដែលបានទាំឆ្អឹង ស្បែកខ្លាស្ងាប់ប្រមូលចងជាកញ្ចប់យកទៅ ។ កន្លងពេលនោះ, បុរសទាំង ៤ នាក់ពោលថា "នេះជាពេលនុកាសល្មមពិសោធន៍មើលនូវវិន្យាដែលបានរៀនចេះចាំ" ។ ដល់ត្រមៃព្រឹងគ្នាស្រែចក៏ហៅកញ្ជរនោះមក, បានឲ្យតម្លៃនូវកញ្ចប់នោះ យកកញ្ចប់ទៅក៏ធ្វើបាប់កញ្ជរនោះឲ្យចេញចាកឆ្ងាយពីទីនោះទៅ ។ បុរសទីមួយបានបើកកញ្ចប់នោះយកឆ្អឹងខ្លាស្ងាប់រៀបតម្រៀបឲ្យស្រួល, ហើយបានសូត្រមន្តអាគមប្រោះទឹកទៅលើឆ្អឹងនោះ។ ក៏រៀបចំខ្លួនឯងតាមជម្មតា, បុរសទីពីរបានសូត្រមន្តធ្វើឲ្យសាច់នោះស្រោបរុំខ្លាតាមលំនាំដើម, បុរសទីបីបានសូត្រមន្តយកស្បែកទៅព័ន្ធរុំគ្រប់ខ្លួនខ្លា បុរសទីបួនសូត្រមន្តឲ្យដឹកនាំដង្ហើមចូលទៅប្រតិស្ឋានក្នុងរូបខ្លាទៅជាខ្លារស់ ។ ខ្លានោះក៏លោតទៅទាំបុរសទាំងបួននាក់ស្ងាប់ទៅ ។

អាវ៌ក្សក្រាបទូលសួរព្រះមហាក្សត្រិយ៍ថា: "សូមទ្រង់ព្រះមេត្តាប្រោស! បុរសទាំងបួននោះតើអ្នកណាគួរគប្បីជាងគេ?" ។

ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះបន្ទូលតបទៅអាវ័ក្សវិញថា: "បុរសដែលឲ្យដីវិតទៅខ្លានោះឯងជាអ្នកឆ្កួតជាងគេ, ព្រោះមានសុភាសិតថា វិទ្យាស្ថិតស្ថិតមិនមានប្រយោជន៍ដល់បុរសដែលគ្មានប្រាជ្ញា ។ គេអាចពោលទៀតាមសភាពផ្ទុយថា ប្រាជ្ញាវិសេសជាងវិទ្យាស្ថិត ហើយអ្នកណាគ្មានវិចារណញ្ញាណតែងស្មើបដូចអ្នកដែលប្រុះសិង្ហ (ប្រហែលជាខ្លាទេដឹង) ឲ្យមានជីវិត" ។

អាវ័ក្សបានស្តាប់ព្រះបន្ទូលព្រះចាតិក្រម ក៏ស្ទុះទៅព្យាយាមនៅលើវត្តជាតិ, ព្រះនរបតីទ្រង់បានចាប់លើលើព្រះអង្សាទាំយកទៅ ។

ចប់ រឿងទី ២១ នៅមានរឿងទី ២២ តទៅទៀត

អ្នកមានទ្រាប្ញាធ្លុកជាមានកម្លាំង ។
នរជនណាមានប្រាជ្ញា នរជនគោះឈ្នោះបាមានកម្លាំង
ឯនរជនដែលមិនមានប្រាជ្ញា ម្តេចនឹងមានកម្លាំងមក
ពីណា? ។ ប្អូរមើល! សីហៈមួយកាបទ្រនង់តែអាប់
ឥតប្រាជ្ញា ត្រូវទន្សាយសម្លាប់បាន ។

បញ្ចតន្ត្រៈ

រឿងចិញ្ចៀនទិព្យ

អ្នកស្រីសារីយ៉ាន់ ប្រែពីបារាំងមកជាខ្មែរ

(តមក)

ព្រះរាជ្ញាតាំងពីព្រះអង្គហោនព្រះនុស្តថា: "នេះទើបហៅថារូបល្អ!" ។ អាវក្សត្រនៅចំរើតាលតែហើយការជប់លៀង ។ ព្រះអង្គម្ចាស់អាលិ - ត្តេលេប៊ូ ក៏ត្រឡប់ទៅ ។ លុះព្រះអង្គម្ចាស់ អាលី ស្តេចយាងចេញផុតទៅ ព្រះរាជ្ញាតាំងពីរក៏ជំទុំគ្នាថា "យើងត្រូវតែសម្ងាប់វាយកចិញ្ចៀននោះ ពីព្រោះវាមានអំណាចលើយើងខ្លាំងណាស់ ព្រះបិតាយើងពុំបានព្រះពរជាន់ទិព្យសម្បត្តិឲ្យវាមែន ប៉ុន្តែទ្រង់បានប្រទានចិញ្ចៀននេះ ប្រសិនបើវាចង់យកទិព្យសម្បត្តិយើង វាយកមិនឲ្យយើងដឹងខ្លួនផង ថែមទាំងយកពរជ័យសម្បត្តិថែមទៀត" ។ លុះបានសន្ធនាគ្នាយ៉ាងនេះហើយ ក៏ព្រមព្រៀងគ្នាធ្វើគត់ព្រះអង្គម្ចាស់អាលី ។

ប៉ុន្តែនៅពេលដំទុំគ្នា មានទាស៊ីម្នាក់ឈរប្រុមាត់ទ្វារ ។ ទាសីនោះកាលពីដើមជាមេនំព្រះអង្គម្ចាស់ អាលី លុះបានស្តាប់រឿងក្បត់យ៉ាងនេះហើយក៏រត់តាមក្រោយព្រះអង្គម្ចាស់អាលិ ទូលទ្រង់អំពីព្រះរឿមទាំងពីរប្រុងនឹងធ្វើគត់ ។ កាលណោះព្រះអង្គម្ចាស់អាលីក៏ប្រាសប្រទានទូវសំពត់អាវសារស្បែជាកិត្តិយស មានសេចក្តីសរសើរតម្កើងហើយមានព្រះបន្ទូលថា: "សូមឲ្យព្រះម្ចាស់សួគ៌ជួយទ្រទ្រង់ឯង!" ទ្រង់នឹក

ឃើញទៅដល់បណ្តាំនៃព្រះវរបិតា ។ លុះពាសីចេញផុតទៅ ទ្រង់ហៅ
ស្រីចំរើមកជួបជុំ ហើយទ្រង់បង្គាប់ឲ្យធ្វើម្ហូបចំណីផ្កាកង្កងពានពាសីឲ្យទ្រង
គួបឲ្យស្រួលបួលទុកមួយកន្ទេង ។ ហើយទ្រង់ក៏លើកលែងខ្ញុំកម្ពុ
ទ្រង់ចែកប្រាក់ដល់ពាសីពាំងឡាយហើយផ្តាំថា ឲ្យផ្ញើម្ហូបចំណីនោះទៅ
ថ្វាយទ្រង់តាមអាវ័ក្សបំរើ បើកាលណាស្តេចត្រូវការអ្វី ស្តេចនឹងផ្តាំតាម
អាវ័ក្សនោះមក ។ ផ្តាំផ្ញើស្រេចកាលណា ទ្រង់ជាក់ចិញ្ចៀនផ្ទាល់ទៅដ
មៃ"មូនមកដល់ភ្លាម ព្រះអង្គម្ចាស់មានព្រះបន្ទូលសួរថា: "ស្រុកណាល្អ
ជាងគេ?" ។ មៃ"មូនទ្វើយថា "ក្រាបទូលគោះអែលកាហ្វូរ (គោះកាហ្វូរ)។
ព្រះអង្គម្ចាស់អាលីបង្គាប់ថា "យកខ្ញុំទៅឯកន្ទេងនោះហើយនឹងយកអា-
ហារដែលពាសីរបស់ខ្ញុំប្រគល់ឲ្យឯងពាលថ្ងៃទៅឲ្យពេលព្រឹក ថ្ងៃត្រង់
ហើយនឹងរៀលាច" ។ មៃ"មូនទទួលថា: "ព្រះករុណាថ្ងៃវិសេស"
ហើយក៏ថ្វាយស្នាក់ទៅព្រះអង្គម្ចាស់ ។ ទ្រង់ឡើងគង់កាលណា មៃ"មូន
ក៏ហោះសំដៅទៅគោះអែល - កាហ្វូរ ហើយជាក់ព្រះអង្គម្ចាស់នៅ
ទីនោះ ។

ព្រះអង្គម្ចាស់គង់នៅទីនេះពាល់តែព្រះអាទិត្យរះឡើង ទ្រង់សូត្រធម
ថ្វាយបង្គំទឹកដល់គុណព្រះជាម្ចាស់ រួចទើបស្តេចយាងដើរក្រសាលពាល់
តែដល់ទៅកន្លែងត្រង់ ។ អ្នកស្រុកគ្រាន់តែក្រឡេកឃើញទ្រង់ ក៏ស្គាល់ថា
ជាអ្នកបរទេស ។ ដោយទ្រង់មានសំលៀកបំពាក់ដូចជាកូនស្តេច គេអាច

ដឹងថាជាអ្នកស្តុកស្តម្ភ អ្នកណាដែលបានយើញខ្ញែនំាងប៉ុន្មាន មានចិត្ត
ស្នេហាខ្ញែនំាងអស់ ។ ខ្ញែនយាងទៅ។ ទាល់តែដល់ផ្សារលក់គន្ធ-
ពីដោរខ្ញែនបានប្រទះនឹងតាចាស់ម្នាក់ ហើយខ្ញែនមានបន្ទូលសួរថា:
"លោកតាមានផ្ទះទំនេរជួលឬទេ?" ។

- សួរធ្វើអ្វី កូន? - ដើម្បីនឹងនៅលោកតា! - កូនអើយ! ខ្ញុំមាន
ផ្ទះមួយគ្រាលព្រំមានរបស់ប្រើស្រែច គ្មានមនុស្សនៅ ហើយវាសមនឹង
ឯងនៅណាស់ ។ ព្រះអង្គម្ចាស់អាលី-ត្នេលប៉ុន្តែយាយថា "សូមលោក
តាបង្ហាញខ្ញុំឯង" ។ តាចាស់ក៏ដើរដំរង់ទៅផ្ទះជាមួយនឹងព្រះពជកុមារ
ដល់ហើយគាត់បើកទ្វារ ព្រះអង្គម្ចាស់ខ្ញែនយាងចូលទៅ យល់ផ្ទះធំទូ-
លាយស្អាតបាតសមគួរ ហើយគ្រាលសុទ្ធតែព្រំចៀមធំៗ ខ្ញែនក៏មាន
បន្ទូលសួរថា "ថ្លៃឈ្នួលផ្ទះនេះប៉ុន្មាន?" - "ទេ តាឲ្យឯងនៅទេ
មិនយកថ្លៃ" ។ ព្រះអង្គម្ចាស់តបថា "សូមឲ្យព្រះអង្គជួយខ្ញែនតា"
ទើបខ្ញែនអង្គុយជជែកលេងនឹងតាម្ចាស់ផ្ទះ ។ នៅពេលនោះ ម៉ែមួនយក
អាហារដែលដាក់កង់បានពកសឹទ្បែន សំពាប់ស្រស់ស្រូបមកថ្វាយខ្ញែន
ដោយតាចាស់នោះមិនបានទាំងចាប់ភ្នែកមើលឆង ។ ព្រះអង្គម្ចាស់អាលី
មានបន្ទូលថា: "យកចំណីនេះមកណោះ យើងបរិភោគ" ។ តាចាស់
នឹងខ្ញែនក៏នាំគ្នាស្រស់ស្រូប ហើយអង្គុយឲ្យស្រួលខ្លួន ។ តាចាស់នៅ
បំរើខ្ញែនលែងទៅណាទៀត ។

ថ្ងៃមួយ ព្រះពុទ្ធកុមារស្តេចទៅក្រសាលផ្សារ ទ្រង់ចូលទៅគង់ក្នុងផ្ទះអ្នកលក់គ្រឿងក្រអូប ដើម្បីនឹងនិយាយលេងជាមួយនឹងនាយពាណិជ្ជ ។ នៅពេលនោះ មានយាយចាស់ម្នាក់ដើរកាត់ មានចាំងពាសីដើរតាមក្រោយផង លុះក្រឡេកឃើញទ្រង់អាលី ស្រែនោះស្ទុះចូលទៅក្នុងផ្ទះពាណិជ្ជហើយដួលសន្លប់ ១ រំពេច គេតាំងតែស្រោចទឹកពាល់តែស្រែនោះដឹងខ្លួនឡើង ។ យាយចាស់សួរនាយពាណិជ្ជថា "បុរសនេះជាអ្នកណា ?" - គឺជាជនបរទេសម្ចាស់ ។ ស្រីនោះក៏និយាយទៅកាន់ទ្រង់ថា "កូនមាសម្តាយ! ខ្ញុំមានកូនប្រុសម្នាក់ដែលមានរូបភាពដូចគ្នានឹងឯងដែរ ប៉ុន្តែកូនខ្ញុំស្លាប់ពីរឆ្នាំទៅហើយ ដូច្នេះ ឯងត្រូវតែមកជាជំនួសកូនខ្ញុំ ហើយទ្រព្យសម្បត្តិទាសាទាសីចាំងប៉ុន្មាននឹងត្រូវបានឯងចាំងអស់" ។ ឈ្មួញគ្រឿងក្រអូបសួរទ្រង់ថា: "តើអ្នកធ្វើតទុកាសនឹងយកជនជាននោះបានឬទេ ?" ។ ប៉ុន្តែស្រីនោះនិយាយតទៅទៀតថា: "កូន! ម្តាយជាក់តម្រិតមិនឲ្យកូនចេញទៅណា លើកតែថ្ងៃសុក្រដែលគេត្រូវទៅសូត្រធម៌ឯព្រះវិហារ" ។ ព្រះអង្គម្ចាស់អាលីនឹងអ្នកនៅជិតខាងចាំងអស់មានសេចក្តីពេញចិត្តណាស់ ។ ស្រីចាស់និយាយទៀតថា "ចូរឯងរង់នៅកន្លែងនេះសិនចុះ ខ្ញុំទៅសិន សិមខ្ញុំប្រើអ្នកណាម្នាក់មកនាំឯងទៅ" ថាហើយក៏ត្រឡប់ទៅកាន់ទីលំនៅខ្លួនជាមួយនឹងទាសីវិញ ហើយប្រើបំរើពីរនាក់ដឹកលាពីរមកទទួលទ្រង់ ។ ស្រីនោះទំរៀបតុប

ដឹងថាជាអ្នកស្តុកស្តម្ភ អ្នកណាដែលបានយើញខ្ញែនំាងប៉ុន្មាន មានចិត្ត
ស្នេហាខ្ញែនំាងអស់ ។ ខ្ញែនំាយាងទៅ។ គាល់តែដល់ផ្សារលក់គន្ធ-
ពីដោរខ្ញែនំាបានប្រទះនឹងតាចាស់ម្នាក់ ហើយខ្ញែនំាមានបន្ទូលសួរថា:
"លោកតាមានផ្ទះទំនេរដួលឬទេ?" ។

- សួរធ្វើអ្វី កូន? - ដើម្បីនឹងនៅលោកតា! - កូនអើយ! ខ្ញុំមាន
ផ្ទះមួយគ្រាលព្រំមានរបស់ប្រើស្រែច គ្មានមនុស្សនៅ ហើយវាសមនឹង
ឯងនៅណាស់ ។ ព្រះអង្គម្ចាស់អាលី-ត្នេលប៉ុន្តែយាយថា "សូមលោក
តាបង្ហាញខ្ញុំផង" ។ តាចាស់ក៏ដើរដំរង់ទៅផ្ទះជាមួយនឹងព្រះរាជកុមារ
ដល់ហើយគាត់បើកទ្វារ ព្រះអង្គម្ចាស់ខ្ញែនំាយាងចូលទៅ យល់ផ្ទះធំទូ-
លាយស្អាតបាតសមគួរ ហើយគ្រាលសុទ្ធតែព្រំចៀមធំៗ ខ្ញែនំាមាន
បន្ទូលសួរថា "ថ្លៃឈ្នួលផ្ទះនេះប៉ុន្មាន?" - "ទេ តាឲ្យឯងនៅទេ
មិនយកថ្លៃ" ។ ព្រះអង្គម្ចាស់តបថា "សូមឲ្យព្រះអង្គជួយខ្ញែនំាតា"
ទើបខ្ញែនំាអង្គុយជជែកលេងនឹងតាម្ចាស់ផ្ទះ ។ នៅគេលនោះ ម៉ែមួនយក
អាហារដែលដាក់កង់បានពេកសឹងខ្សែន សំពាប់ស្រស់ស្រូបមកថ្វាយខ្ញែនំា
ដោយតាចាស់នោះមិនបានតាំងចាប់ភ្លឹកមើលឆង ។ ព្រះអង្គម្ចាស់អាលី
មានបន្ទូលថា: "យកចំណីនេះមកណោះ យើងឋរិកោគ" ។ តាចាស់
នឹងខ្ញែនំាក៏នាំគ្នាស្រស់ស្រូប ហើយអង្គុយឲ្យស្រួលខ្លួន ។ តាចាស់ទៅ
បំរើខ្ញែនំាលែងទៅណាទៀត ។

ថ្ងៃមួយ ព្រះកុមារស្តេចទៅក្រសាលផ្សារ ទ្រង់ចូលទៅគង់ក្នុងផ្ទះអ្នកលក់គ្រឿងក្រអូប ដើម្បីនឹងនិយាយលេងជាមួយនឹងនាយពាណិជ្ជ ។ នៅពេលនោះ មានយាយចាស់ម្នាក់ដើរកាត់ មានទាំងទាសីដើរតាមក្រោយផង លុះក្រឡេកឃើញទ្រង់អាលី ស្រីនោះស្ទុះចូលទៅក្នុងផ្ទះពាណិជហើយដួលសន្លប់ ១ រំពេច គេតាំងតែស្រោចទឹកថាល់តែស្រីនោះដឹងខ្លួនឡើង ។ យាយចាស់សួរនាយពាណិជថា "បុរសនេះជាអ្នកណា?" – គឺជាជនបរទេសម្នាក់ ។ ស្រីនោះក៏និយាយទៅកាន់ទ្រង់ថា "កូនមាសម្តាយ! ខ្ញុំមានកូនប្រុសម្នាក់ដែលមានរូបភាពដូចគ្នានឹងឯងដែរ ប៉ុន្តែកូនខ្ញុំស្លាប់ពីរឆ្នាំទៅហើយ ដូច្នេះ ឯងត្រូវតែមកជាជំនួសកូនខ្ញុំ ហើយទ្រព្យសម្បត្តិទាសាទាសីទាំងប៉ុន្មាននឹងត្រូវបានឯងទាំងអស់" ។ ឈ្មួញគ្រឿងក្រអូបសួរទ្រង់ថា: "តើអ្នកធ្វើតទុកាសនឹងយកធនធានទាំងនោះបានឬទេ?" ។ ប៉ុន្តែស្រីនោះនិយាយតទៅទៀតថា: "កូន! ម្តាយជាក់តម្រិតមិនឲ្យកូនចេញទៅណា លើកតែថ្ងៃសុក្រដែលគេត្រូវទៅសូត្រធម៌ឯព្រះវិហារ" ។ ព្រះអង្គម្ចាស់អាលីនឹងអ្នកនៅជិតខាងទាំងអស់មានសេចក្តីពេញចិត្តណាស់ ។ ស្រីចាស់និយាយទៀតថា "ចូរឯងរង់នៅកន្លែងនេះសិនចុះ ខ្ញុំទៅសិន សិមខ្ញុំប្រើអ្នកណាម្នាក់មកនាំឯងទៅ" ថាហើយក៏ត្រឡប់ទៅកាន់ទីលំនៅខ្លួនជាមួយនឹងទាសីវិញ ហើយប្រើបំរើពីរនាក់ដឹកលាពីរមកទទួលទ្រង់ ។ ស្រីនោះទំរៀបតុប

តែងផ្ទះសំបែងយ៉ាងស្អាត ថែមទាំងដាក់អាសនៈលាបទឹកមាសមួយផង នៅកន្លែងកិត្តិយស ។

ក្រោយបន្តិចមក លាន់ឮអ្នកបំរើពីរនាក់ចាន់ដល់ផ្ទះឈ្មួញ ។ អាលីលាតាចាស់ទឹងនាយពាណិជហើយទ្បើងជិះលាទៅ លុះមកដល់ផ្ទះស្រីចាស់ ។ ក៏ចុះមកខ្លួល នាំគ្នាដំទៅអង្គុយនៅលើអាសនៈលាបទឹកមាស ហើយបង្គាប់ទៅបំរើថា "ក្មេងស្រី! ឯងទៅដាំទឹកឆ្ងូត, ថែមទាំងឲ្យស្រីក្រមុំយ៉ាងស ។ នៅកម្ពុជាប្រាំមួយនាក់ទៀត ហើយនិយាយប្រាប់គ្នាថា: "កូន! បើកូនពេញចិត្តស្រីណា កូនយកចុះ ម្តាយគ្មានឲ្យអ្វីឲ្យកូនទេ" ។ ស្រីចាស់នោះក៏ឲ្យក្មេងស្រីនាំគ្នាទៅឆ្ងូតទឹក លុះចេញពីបន្ទប់ទឹកមកវិញ គាត់យកសំលៀកបំពាក់យ៉ាងល្អឆើតទៅថ្វាយគ្នា ។ ព្រះអង្គម្ចាស់គ្នាគង់នៅផ្ទះស្រីនេះជាយូរថ្ងៃ ហើយគ្នាយាងចេញតែថ្ងៃសុក្រ ដើម្បីទៅសូត្រធម៌នៅព្រះវិហារ ។

(មានត)

លោកផេង-ជ្រៃ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

មានអ្នកខ្វះយល់ផ្សេងៗ ទៅទៀត ។ ក្នុងពេលដែលគេកំពុងជជែកគ្នា អាប៉ូលនិងខ្ញុំឈប់ស្ងៀមឈឹងចាំស្តាប់ យើងឈប់សម្រាកនៅទីនោះ រហូតដល់ព្រះអរុណរះឡើង តែពន្លឺភ្លឺមិនសូវច្បាស់ គេមិនអាចនឹងមើលឃើញតែអ្វីផងចាំងពួងកងសមុទ្រទេ ព្រោះមេឃចុះអ័ព្ទ ឃើញតែស្ពឹងៗ កងសមុទ្រដូចជាពពក គេថាអាដែងស្ពឹងៗ ហ្នឹងគឺកោះដំ នៅប្រហែលមួយគីឡូកន្លះពីច្រាំង ។ ដោយអំណាចចុះអ័ព្ទខ្លាំងពេក គេមើលឃើញតែត្រង់មនុស្សអង្គុយនាឆ្នេរសមុទ្រ និងកំពូលភ្នំ នៅកណ្តាលកោះមើលឃើញម្តងៗ ដោយសារពពកសោតដុំវិញ ។

មាំងប្រាប់ពីព្រឹកឮសូរគ្រាប់យន្តកងវៃ គឺលោកចៅហ្វាយជិះសេះអញ្ជើញមកមានទាហាន អ្នកស្រុកនឹងពួកឮងជាច្រើនមកជាមួយផង ។ លោកចៅហ្វាយបង្គាប់ឲ្យទាហានឈរនៅមាត់ច្រាំងហើយធ្វើបទបញ្ជាឲ្យបាញ់កាំភ្លើងស្រះៗគ្នា ។ គ្រាន់តែខាងយើងបាញ់ហើយស្រាប់តែឃើញចេញពន្លឺភ្លឺព្រាតៗ រួចឮសូរទើង ។ តាមស្មានទៅដូចជានាវាមិននៅឆ្ងាយពីយើងប៉ុន្មាន រួចយើងនាំគ្នាវត់សំដៅខាងដែលនាវាបញ្ចេញ

ពន្ធ ។ យើងមើលគាត់អ្នកទៅយើញគ្នាវាងនឹងក្តោងសូង ។ នាវ
នៅជិតយើងសោះ ទោះបីលកយ៉ាងដូចម្តេចក៏ដោយ គេគង់អាចស្តាប់
ឮសូរតែក្តៅដែលលោកតែកុងធ្លុបគ្នាប់មនុស្សក្នុងកប៉ាល់ នឹងសំឡេង
ម៉ាត់ឡូស្រែកបីជងថា: "ជយោ ព្រះករុណា!" ព្រោះសម្រែកហ្នឹង
ជាសំដីនៃសាសន៍ចាំងកងវេលាដែលមានគ្រោះថ្នាក់យ៉ាងធ្ងន់បំផុត នឹង
កងវេលាដែលមានសេចក្តីសប្បាយយ៉ាងខ្លាំងបំផុត សម្រែកនេះដូចជា
ស្រែកអំពាវនាវហៅម្ចាស់ឲ្យមកជួយ ឬមួយគេស្រែកឲ្យសាក្សីថាគេនឹង
សុំប្តូរជីវិត ដើម្បីជាប្រយោជន៍ដល់ខ្លួន ។

តាំងពីពេលដែលគេមើលឃើញបា្រស់ទូកប៉ាល់ សាំងសើរង់
នៅត្រង់ខ្ទមគេទៅជួយបានកាលណា យើងឮគេបាញ់កាំភ្លើងមិនដាច់
សូរសោះ ប៉ាម៉ាតុតម្ពង ប៉ាម៉ាតុតម្ពង ។ លោកចៅហ្វាយបង្គាប់មនុស្ស
ចាំងឲ្យទៅឯកូម៉ាតស្បៀង រកក្តារ រកខ្សែពួរនឹងធុងទេ ។
មិនយូរប៉ុន្មាន គេឃើញមនុស្សមួយហ្វូងមកដល់ មានពួកពួងដើរពីក្រោយ
ខ្លះវែក ខ្លះសែង ខ្លះកាន់សឹងតែគ្រប់ដៃ ខ្លួះគ្រឿងកោជនាហារនឹង
គ្រឿងប្រដាប់ប្រដាសម្រាប់ខាងកប៉ាល់ នាំមកពីភូមិ ពួត-ឧរ ពីភូមិ
ហ្វាក់ នឹងស្ទឹង កំបុ ។ នៅបណ្តាមនុស្សចាំងឲ្យនោះ មាន
មនុស្សចាស់ម្នាក់ចូលទៅនិយាយនឹងលោកចៅហ្វាយថា: "សូមមានអត់
ទោស ព្រះគេជគុណ! ពីយប់មិញគេឮសូរអ្វីសន្ធឹកអឺតេញចាំងពីក្នុង

ទាល់ត្រឹក ក្នុងព្រៃឈើ ស្ទឹកឈើកម្រើកឥតមានខ្យល់បក់ បក្សាបក្សី សម្ងុតទាំងប៉ុន្មានចុះដេកដីអស់ជ្រាកដណាស់ បើតាមច្បាប់ហ្នឹងគឺនឹងមានខ្យល់ព្យុះយ៉ាងធំអស្ចារ្យ" ។ លោកចៅហ្វាយធ្វើយថា "យើងរៀបចំប្រុងប្រៀបស្រេចហើយខាងទឹកខាងគោក" ។

ការណ៍ហ្នឹងពិតមែន ភាពមេឃទំនងនឹងមានខ្យល់ព្យុះធំជ្រាកដ ។ ពពកទាំងឡាយដែលគេសំគាល់ឃើញនៅថ្ងៃត្រង់ មានភ្លៅដុំមួយគួរឲ្យខ្លាចនៅចំកណ្តាល ហើយជុំវិញគ្រហមដូចស្តាន់ ។ អាកាសលាន់សូរដូចខ្យល់បក់ត្រវែលក្រញ៉ាង សម្លេងសុណា គេះបីមេឃងងឹតក៏ដោយក៏ទំប្រឹងហើរមកអំពីទិសផ្សេងៗ រកកន្លែងជ្រកនៅក្នុងគោះ ។

ពេលមោងជ្រុំបួនត្រឹក គេឮពីខាងសម្ងុតមកវិញ នូវសូរស័ព្ទសន្ធឹកគួរស្ញែងខ្លៀកពេកដូចជាសូរទឹកជ្រោះលាយសូរផ្គរលាន់ ហូរជ្អាក់ពីលើកំពូលភ្នំទាំងឡាយ ។ មនុស្សទាំងអស់ស្រែកឡើងថា: "នុះហ្ន៎ខ្យល់ព្យុះ!" ។ បានប្រហែលមួយស្របក់ស្រាប់តែខ្យល់កំបុតត្បូងបក់ក្តួចអ័ព្ទទៅឯណាអស់រលីង លេចកោះដំនឹងច្រកនៅជិតឃើញច្បាស់ថែស ។ កប៉ាល់នៅកណ្តាលវាល គេឃើញមនុស្សទាំងឡាយជាច្រើន ឃើញជងក្តោង ខន់ជ័យបក់រវៃ។ ខ្សែព្រួរបោះយុថ្កាជ្រែងពីខាងមុខ ខ្សែមួយបោះខាងកន្ទៃសម្រាប់ជួយទប់កប៉ាល់ឲ្យនឹង ។ កប៉ាល់នៅជាបន្ទោះកោះដំនឹងច្រាំង ទៅពីជួរថ្មដែលជុះព័ទ្ធកោះបាំងត្រង់កន្ទៃងមួយដែលគ្មានអ្នក

ណាឆ្ងាប់ដើរសោះ ។ វាចតឈមមុខទៅរកលុកដែលមកពីសមុទ្រធំ ហើយចាលណាវង់លុកមួយៗ ផាត់មក លុកនេះលើកក្បាលកប៉ាល់បញ្ឆរត្រដែត រហូតដល់បានឃើញនៅកណ្តាលវាល ក្នុងខណៈនោះ កន្ទៃទាវជ្រមុជទៅក្នុងទឹក រហូតដល់ថ្នាក់លើដូចជាលិចរួចហើយ ។ ក្នុងពេលដែលកប៉ាល់កំពុងតែឃ្លេងឃ្លោង ខ្យល់ធំវិលកលើកចោះទៅផ្ទប់ធំដ៏ រកទាំងបើកត្រឡប់ទៅតាមផ្លូវដែលមកពុំបាន ឬរកតែកាត់ខ្សែបណ្តាច់ឲ្យកប៉ាល់នៅទើរជាប់លើផ្នែរ ដែលមានខ្សាច់យ៉ាងខ្ពស់ពាសពេញដោយថ្មច័ន្ទពីខាងត្រៃ មិនកើត ។ លុកមួយៗដែលមកផ្ទប់បែកធំធ្ងន់ណាស់ ហូរមកលាន់ឮឈូរឆ្ងាក់រហូតចូលក្នុងអូរ ហើយចោកដុំត្រួសខ្ចាតទៅលើគោក ចម្ងាយជាងហាសិបម៉ែត្រ លុះត្រឡប់ថយទៅវិញ លុកស្រូបយកទាំងត្រួសទៅផង រមៀលឮសូរពោកពាកគួរខ្លាចខ្លុកដីឆ្នេរសមុទ្រឲ្យទៅវាលថ្ងំធំ ។ ទឹកសមុទ្រជោរជោយខ្យល់ធំបន្តិចម្តងៗ ត្រមទាំងត្រីតូចក្នុងកោះនឹងកោះដំ ក្លាយជាសមុទ្របៃតពុះសសំពោង សុទ្ធតែរលកយ៉ាងគ្រោងៗ ។ ពពុះទឹកទាំងឡាយប្រទះលើគ្នាទៅក្នុងអូរ ខ្ពស់ជាងជ្រុំមួយម៉ែត្រ ខ្យល់ដែលបក់ពីលើ បក់ដោយទាំងពពុះនោះទៅលើគោកចម្ងាយជាងកន្លះគីឡូម៉ែត្រ ។ ដោយអំណាចពពុះទឹកទាំងឡាយពាប់មិនអស់សសំពោង ដែលខ្យល់បក់ផាត់នាំទៅដល់ដើងកុំ គេមើលទៅស្មានជាគ្រាប់ព្រិលចេញមកពីក្នុងសមុទ្រ ។

មើលទៅដើងមេឃ ខំនងដូចជាមិនងាយនឹងអស់ឲ្យល់ព្រះ សមុទ្រ ហាក់ដូចជាជាប់គ្នានឹងមេឃ ។ ពពកចាំងដុំៗ ខំនងគួរខ្លាច ដែលឲ្យល់បក់មកជាប់ពីគ្នាមិនឈប់ឈរ រសាត់ភាត់អាកាសលឿនដូចសត្វហើរចំណែកអាខ្លះទៀតនៅទ្រឹងស្ងៀម មិនកម្រើកដូចមហាបព្វតាចាំងឡាយ ។ នៅលើមេឃគ្មានស្រឡះឃើញពណ៌ខៀវសោះ មានតែពន្លឺក្រហមពពក់តែម្យ៉ាង ដែលបញ្ចាំងវត្ថុចាំងឡាយនៅដីនឹងកងសមុទ្រនៅលើអាកាស ។

កប៉ាល់ចេះតែឃ្លេងឃ្លោងជានិច្ច ហើយត្រង់ណាគេខ្លាចមានរឿងមកចំត្រង់ហ្នឹង ។ ខ្សែពួរខាងក្បាលស្រាប់តែជាប់កឹង សល់នៅជាប់តែកន្ទៃ កប៉ាល់ចេះតែតែលគោល ឲ្យល់បក់ជាង រលកក្បាលទៅប៉ះនឹងថ្ម នៅក្បែរចំងចម្ងាយពីរយម៉ែត្រ ។ ឃើញដូច្នោះហើយ យើងស្រែកថ្ងូរគ្រប់គ្នា ។ អាប៉ូលរៀបសួរហែលទៅហើយ កុំតែខ្ញុំគោងដៃទុក "នែកូន! ឯងចង់ស្លាប់ឬ?" ។ - "ត្រូវខ្ញុំទៅជួយនាង, មិនជួយទេ ខ្ញុំមុខជានឹងស្លាប់ឥឡូវហើយ!" ។ ដល់ព្រួយខ្លាំងតេកអាប៉ូលលែងដឹងអី ។ ដើម្បីកុំឲ្យវាស្លាប់ ម្ចាំងនឹងខ្ញុំយកខ្សែមួយចងនឹងខ្សែក្រវាត់វា យើងនាំគ្នាកាន់កន្ទុយខ្សែទុក ។ អាប៉ូលសុំទៅរកកប៉ាល់ ចួនកាលហែល ចួនកាលដើរលើថ្មដែលដុះក្នុងសមុទ្រ ។ ចួនណាវាសន្សឹមថាមុខជានឹងដើរទៅដល់ ព្រោះរលកដែលមិនធ្លាក់ដ ធ្វើ

ឲ្យឃើញកប៉ាល់ដូចជាក្បឿងនៅគោក រហូតដល់គេសឹងអាចដើរដុំវិញ
ដោយដើងបាន មិនយូរប៉ុន្មានត្រឡប់សាជានមកវិញយ៉ាងខ្លាំងអស់
ពីចិត្ត រលត់ជះមកលើកប៉ាល់ លើកក្បាលបញ្ឈរឡើងឃើញរហូត
បាត ហើយលើកអាប៉ូលចោះទៅលើខ្សាច់យ៉ាងឆ្ងាយ បែកឈាម
ដើងអស់ ជាំខ្លួនខ្លោចរលេស្ទើរសន្លប់ ។ អាប៉ូលគ្រាន់តែដឹងខ្លួនភ្លាម
ងើបឡើងត្រឡប់សុះសំដៅកប៉ាល់ម្តងទៀត ក្នុងពេលដែលរលកជក់ថយ
ទៅវិញ ។ ពួកអ្នកជិះទាំងប៉ុន្មានអស់សង្ឃឹមថានឹងបានរួចខ្លួនគ្នាំគ្នា
លោតទៅក្នុងសមុទ្រ ខ្លះគោងសារក្តាង ខ្លះគោងក្តារ គោងខ្លួនមាន់
គោងតុនឹងធុងទាំងឡាយ ។ គេឃើញវត្ថុមួយគួរឲ្យអាណិតខ្លោចចិត្ត
មិនដាច់ គឺនារីម្នាក់ឈរនៅលើកប៉ាល់ ហុចដៃសំដៅមាណពម្នាក់ដែល
ខំប្រឹងគ្មានគិតនឿយហត់ ដើម្បីសុះទៅឲ្យបានដល់នាង ។ នារីនោះ
មិនគឺស្រីដទៃក្រៅពីវីរ៍ស៊ីនីឡើយ ។ នាងស្គាល់ច្បាស់ជាប្តីគួរសង្ឃឹម
ខំប្រឹងដោយចិត្តក្លាហានយ៉ាងមាំ ។ ក្រឡេកឃើញនារីជាទីស្រឡាញ់
ដល់នូវគ្រោះកាចយ៉ាងធំបំផុតដូច្នោះ យើងភាល់គ្នាមានទុក្ខព្រួយអម្ល៉េទេ។
វីរ៍ស៊ីនី នាងធ្វើសញ្ញាដោយដៃ ដោយចិត្តឥតកំរើក ថាដូចជាសូម
លាយើងភាល់គ្នាហើយ ។ ពួកកម្មករនាពទាំងឡាយលោតទៅក្នុង
សមុទ្រទាំងអស់ ។ មាននៅសល់តែម្នាក់ ឈរនៅលើកប៉ាល់ស្រាត
នន្ល សាច់ឡើងរឹងដុំៗ ភាពដូចជាមនុស្សមានកំឡាំង ។ បុរសនោះ

ចូលទៅជិតនាង ដោយសេចក្តីភាពជាប: យើងឃើញគេលុតជង្គង់ទៅក្បែរ
នាងក្រមុំ ហើយទំប៉ែងដោះសំលៀកបំពាក់នាងចេញពីខ្លួន តែនាងរុញ
គេថយ ហើយបែរមុខចេញ មិនហ៊ានមើលចំ ។ គេស្មអ្នកឈរមើល
ពីខាងគោកស្រែករន្ធែនថា: "ជួយនាងផង! ជួយនាងផង! កុំចេញពី
នាង!" ។ តែក្នុងពេលនោះ រលកមួយដូចភ្នំធំក្រលែងធំ គួរឲ្យខ្លាច
តេកភ្នែងនឹតសសំពោង បក់ប៉ោកធ្លាក់មកជាបខ្នោះកោះដំនឹងច្រាំង
ហើយហូរលឿនទៅមុខលាន់ឮឈូរ . . សំដៅ។ប៉ាល់បុរាំងនឹងខ្ទិច ។

លុះឃើញអាការអាក្រក់ដូច្នោះ កម្មករនោះស្ទុះលោតទៅក្នុងសមុទ្រ
តែម្នាក់ឯង ចំណែក រ៉ែស៊ីន ដឹងថាសេចក្តីស្លាប់នឹងមកដល់ រៀរាំរួច
ហើយ ក៏ដាក់ដៃមួយផ្អោបនឹងខ្លួនលើសំលៀកបំពាក់ ដៃមួយទៀតដាក់
ត្រង់ដើមទ្រូង ក្អែកថ្ងាហូរដ៏សំឡឹងឡើងលើដូចជាទេពធីតាបុរាំងនឹងហោះ
ទៅស្ថានសួគ៌ ។ ឧថ្ងៃនេះចំជាថ្ងៃចម្លែងៗគ្មាតអីម្ល៉ះទេ គ្មានសល់អ្វី
ឡើយលិចលង់អស់ហើយ! កុំតែរលកច្រានពួកជនអ្នកមើលទាំងអស់ឲ្យ
ភ្លូតថយទៅលើគោកឆ្ងាយ កុំអីអ្នកទាំងនោះរៀបស្ទុះទៅជួយនារី រ៉ែស៊ីន
ដូចជាកម្មករនាពម្នាក់ដែលចង់ជួយស្រង់ជីវិតនាងដែរ ។ កម្មករនោះ
ដែលបានរត់ចេញពីសេចក្តីមរណៈរួច ហើយមកអង្គុយលើដីឮប្រាប់
ក៏មានវាចាថា: "ឧព្រះអាទិទេពម្ចាស់ថ្ងៃអើយ! ព្រះអង្គបានជួយ
ស្រង់អាយុជីវិតខ្ញុំរួច ខ្ញុំចង់ជួយនារីនោះដោយចិត្តស្មោះត្រង់ ប៉ុន្តែធ្វើ

ម៉េចនាងមិនព្រមដោះសំលៀកបំពាក់ចេញពីខ្លួន" ។ ខ្លួម៉ាំងនឹងខ្ញុំ (តាចាស់) ទំនាំគ្នាទាញអាប៉ូលពីរលកមកសន្ទប់ចេញឈាមពីមាត់ពីត្រចៀក ។ លោកចៅហ្វាយឲ្យគេច្រតស់អាប៉ូលទៅលើដៃពេទ្យ ចំណែកយើងបបួលគ្នាដើរតាមឆ្នេរសមុទ្រ ក្រែងលោរលកបោកខ្មោចនាងមកជាប់នៅនាខាង: ព្រោះខ្យល់បក់វិលវល់ត្រឡប់ហ៊ាសណាស់ យើងព្រួយពេក ក្រែងរកបុកាយ វ៉ីស៊ីពុំឃើញ ។ យើងមុខស្លុតរៀនខ្លួនដើរចៀសចេញពីទីនោះ ទ្រូងគាន់តឹងស្ទើរប្រែះ ការវិនាសដោយទឹកនឹងខ្យល់ អស់មនុស្សទាំងឡាយដ៏ច្រើន មានជីតជាប់ក្នុងដួងវិញ្ញាណជានិច្ច ប៉ុន្តែបណ្តាអ្នកស្លាប់ទាំងឡាយនោះ គេនៅសង្ឃឹមតែវ៉ីស៊ីនី មួយទេដែលជាស្រីមានធម៌ក្នុងខ្លួន ក្រែងលោគេព្ពាជួយ ព្រោះអន្តរាយនេះសម្បើមពេក ហើយមិនសមគួរដល់រូបនាងផង ប្រហែលរឿងនេះធ្វើឲ្យកំរើកអាសនាព្រះអាទិទេពមិនដឹងឡើយ ។

ខណៈនោះ អាប៉ូលត្រឡប់ដឹងខ្លួនបានបន្តិច ។ គេយកទៅផ្ទៃនឹងផ្ទះជិតខាងទំាងដឹងខ្លួនមែនទែនតាលណា គេនឹងជឹកនាំយកទៅផ្ទះ ។ ចំណែកខ្ញុំត្រឡប់មកផ្ទះមុនជាមួយនឹងខ្លួម៉ាំង ដើម្បីឲ្យដំណឹងគ្រាន់នេះដល់ម្តាយ វ៉ីស៊ីនី នឹងមែអាប៉ូល ។ កាលដែលយើងមកដល់ច្រកចូលស្ទឹងស្ទឹកតែ មានពួកគ្នាងនិយាយថ្កាច់ថា: មានតំណេចកថ្កាល់ថ្កាក់បែកខ្យល់មកជាប់នៅឈូងមួយច្រើនណាស់ នៅចំពីមុខហ្នឹង ។ យើងចុះទៅឈូងនោះ រួតដែលយើងឃើញមុនគេ គឺកាយខាង វ៉ីស៊ីនី ។ (មានត)

សកម្មភាពនៃក្រុមដំណុំទំនៀមទម្លាប់ខ្មែរ

បរិយាយពីដើមកំណើតរឿងរាមកេរ្តិ៍

លោក ចាប-ពិន រៀបរៀង

អស់លោកគាំង ឡាយ !

សព្វថ្ងៃនេះ ពាល់ៗ សប្តាហ៍ ក្រសួងយោសនាការជាតិបានចាត់ការឲ្យលេងល្ខោនរឿងរាមកេរ្តិ៍ ផ្សាយតាមវិទ្យុប្រទេសកម្ពុជា ឲ្យជាសណ្តាប់ដល់ប្រជាជនទេមរជាតិ. អស់លោកគាំង ឡាយបានស្តាប់រឿងនេះតាមវិទ្យុកម្ពុជាហើយ ។

ក្រុមដំណុំទំនៀមទម្លាប់ខ្មែរ ចាប់យកឧកាសនេះមករៀបរៀងជាអត្ថបទស្តីពីដើមកំណើតរឿងរាមកេរ្តិ៍ ទំនងសេចក្តីអាថ៌កំបាំងខ្លះ នៃរឿងនេះ ជូនជាសណ្តាប់អស់លោកគាំង ឡាយ ឲ្យយល់សេចក្តីជ្រាលជ្រៅឆ្ងាយទូលាយតទៅទៀត ដូចតទៅនេះ ៖

រឿងរាមកេរ្តិ៍ ជារឿងកន្ធសាសនាព្រាហ្មណ៍ ចាប់ដើមបង្អស់ហៅថា "រឿងរាមាយណៈ" ជារឿងដែលឥស្សីម្នាក់ឈ្មោះ "វាល្មីកិ" នៅប្រទេសឥណ្ឌា បានតែងឡើងមុនជំបូងបំផុត ជាមហាកាព្យភាសាសំស្ក្រឹត ។

សេចក្តីបង្ហើមដើមកំណើតនៃរឿងរាមកេរ្តិ៍ថា :

"ថ្ងៃមួយ ឥសីឈ្មោះឥល្លីកិ សួរទៅឥសីឈ្មោះនារទៈ ដែល
"ចេះចប់ត្រៃវេទ ថ្វាយបង្គំហើយថា "បពិត្រលោកនារទៈ! ក្នុង
"លោកនេះ តើនរណាជាវីរបុរស ប្រកបដោយគុណធម៌ យុត្តិធម៌,
"មានគតិបណ្ឌិត ទំនឹងវិយោគថ្ងៃថ្ងូរ, មានមុខញញឹមស្រស់ជានិច្ច,
"មានឥន្ទ្រិយទ្រង់ផ្សាយទូទៅក្នុងសកលលោក, ទោះបីទេវតាក៏មិនអាច
"បៀតបៀនបាន ?

"ឥសីនារទៈ សំឡឹងមើលត្រៃលោក ហើយឆ្លើយថា:

"ទុព្រះមុនី! ខ្ញុំស្គាល់ហើយ វីរបុរសនោះ គឺព្រះពុទ្ធ ដែលជា
"បុត្តានៃវង្សត្កូកុ (ភាសាចាលីថា វង្សក្កាកៈ) ព្រះអង្គមាន
"ព្រះប្រាជ្ញាញាណ ក្លាហាន វិទ្យាសាស្ត្រ ទំនឹងប្រពៃណីដ៏បរិសុទ្ធត្រកាល
"ឥតថ្លង់ស្មើ មានព្រះហស្តរឹងមាំ, ដើមព្រះទ្រូងធំ, ព្រះនេត្រចេញរស្មី
"ផ្លេកៗ, ព្រះទ័យសប្បុរស, ព្រះវិចារណញ្ញាណជ្រាលជ្រៅដូច
"មហាសាគរ, ជំហររឹងដូចភ្នំហេមពាន្ត, កម្លាំងដូចព្រះវិស្ណុ, លំអដូច
"ព្រះចន្ទ, វីរយ ដូចប្រាថ្នាឥតខ្ចីឥតធរណី. ទ្រង់ចេះចប់ត្រៃវេទ ។

"ព្រះបិតាព្រះពុទ្ធ គឺព្រះបាទឧសរាជ ត្រង់ជាសម្ព័ន្ធនៅនគរ
"អយោធ្យា, ទ្រង់មានព្រះបំណងនឹងបង្វែរពាក្យព្រះពុទ្ធទានដល់ព្រះពុទ្ធ
"តែដោយព្រះនាងកៃកេយី ព្រះទេពីទីពីរ ប្រណែនដោយចង់ឲ្យព្រះភរត
"ជានរៈបព្រះនាងសោយរាជ្យវិញ ក៏ទ្រង់ដំបៅបង់ព្រះពុទ្ធចេញចាកព្រះ

"នគរតែព្រះលក្ខ្មណ៍ជាព្រះអនុជ នឹងព្រះនាងសិតាជាព្រះអគ្គមហេសី
"សុំតាមទៅផង ។ ព្រះពមព្រះលក្ខ្មណ៍នឹងព្រះនាងសិតាក៏យាង
"ទៅនៅក្នុងព្រៃសីតាកុត, ក្នុងអាស្រមប្រកបដោយជោគជ័យល្អស្មើ
"នឹងទេវតា ។

"ក្នុងកាលក្រោយនោះ ដោយហេតុទ្រង់ព្រះវិតក្កខ្ជាក់ពេកព្រះ
"ឋានទេសវថក៏ទ្រង់សោយទិវង្គតទៅ, ភជសម្បត្តិបានដល់ព្រះករតព្រះ
"អនុជធីពីរ ប៉ុន្តែព្រះករតមិនព្រមទទួល ស្តេចទៅអង្វរព្រះពមជាព្រះ
"ជេដ្ឋាឲ្យតែឡប់មកទទួលម្តងពីរដងវិញ តែព្រះពមទ្រង់ប្រកែក ទ្រង់
"ប្រទានតែសុពណ៌បាទ ដល់ព្រះករតជាកស្តេតាងនៃអំណាចដែលទ្រង់
"ព្រះពជានុញ្ញាតឲ្យគ្រងព្រះនគរជំនួសទ្រង់, រួចទ្រង់ស្តេចចូលកាន់
"ព្រៃមួយទៀតឈ្មោះទណ្ឌក:" ។ ល ។

"ឥសីនារទ:អានរឿងព្រះពមតាំងពីដើមដល់ចប់ មានសេចក្តី
"ពិស្តារពិពេះពិសា ដូចជារឿងដែលលោកអ្នកធ្លាប់បានស្តាប់បានអាន
"រួចមកហើយ ។

"លុះឥសីនារទ អានរឿងព្រះពមចប់ហើយ, ឥសីវល្លិកិក៏ទូលសំរាប
"គោរពឥសីនារទ:ហើយថយចេញទៅ ទៅឈប់នៅទីមួយឈ្មោះ
"តមស: ជាទីប្រសព្វមុខទន្លេតាំង ៥ មានទន្លេគង្គាជាដើម និយាយ
"ប្រាប់សិស្សម្នាក់ដែលតាមទៅផងថា:

"នែការព្វាជ:! ចូរអ្នកមើលទន្លេជាទីគោរពនេះ ដ៏មានពន្លឺ នៅ
"ទឹងថ្កល់ដូចអាត្មានរបស់បណ្ឌិតម្នាក់, ចូរអ្នកទៅយកសំពត់សម្បកឈើ
"ពីអាស្រមមកឲ្យខ្ញុំហើយឲ្យកុណ្ឌីមួយមកខ្ញុំ។ ទឹងមុជក្នុងទន្លេនេះ" ។

"ឥសីវល្កិបានធ្វើតទឹកដ៏ថ្លាវិន់ លាងបាបបានសម្រេចមគ្គផល
"ហើយ មុនទឹងចូលកាន់អាស្រមកណ្តាលព្រៃ ឥសីយាត្រាតាមមាត់
"ច្រាំងទន្លេ បានឃើញព្រានព្រៃម្នាក់ចាប់ឆ្កួតសម្លាប់សត្វក្រសារ
"ឈ្មោលមួយដែលកំពុងដើរជាមួយនឹងក្រសារញីជាគូ ។ វាល្អិតល្អន
"សង្វេគក៏ចង់ជាពាក្យស្មោក គឺពាក្យគាត្យនិយាយពីរឿងក្រសារនឹង
"ព្រានព្រៃ ។

"កាលឥសីវល្កិចូលទៅដល់អាស្រមភ្លាម, ស្រាប់តែឃើញព្រះ
"ព្រហ្មមានកក្តី ៤ ជាព្រះអាទិទេពអ្នកសាងលោក មានមហិទ្ធិឫទ្ធិមក
"ប្រតិស្ឋានចំពោះមុខ ។

"ឥសីវល្កិក្រោកឈរបង្អោនកាយឆ្ពងអញ្ជលី ហើយថ្វាយទឹក
"ទឹងអាសនៈដល់ព្រះព្រហ្ម រួចអានស្មោករឿងក្រសារនោះចំពោះព្រះ
"កក្តីព្រះព្រហ្មថា:

"ខុ! អំពើនេះលាមកពិត បណ្ឌិតពោលថាបាបលើសខ្លាត
"ខុ! អ្នកប្រមាញ់ចិត្តប្រមាថ ម្តេចអ្នកតិយាតសត្វក្រសារ ។
"សំឡេងពិរោះល្អក្រៃកដ ឲ្យព្រាត់ប្រាសពាក្យសង្ឃរ

"អ្នកបានឈ្មោះថាមនុស្សចិត្តមារ សម្លាប់ក្រសាវដែលឥតទោស" ។

"ព្រះព្រហ្មបានស្តាប់ក៏ញញឹមហើយពោលថា ឱព្រះមុនី! គ្រាន់
"តែរឿងព្រានព្រៃបាញ់ក្រសាវស្ងប់ លោកអាចចងជាពាក្យស្មោក
"ពិរោះពិសាទៅបាន ខ្ញុំឃើញថាលោកជាអ្នកធ្វាជ្ញាឯវេហារ, ដូច្នេះ
"សូមលោកថ្លែងនូវសាវតារនឹងថ្លៃដៃនៃព្រះពាម តាមដែលលោកបាន
"ស្តាប់ពីសំណាក់ឥសីនារទៈមកនោះ ជាពាក្យគាថាឲ្យពិស្តារពិរោះពិសា
"ចុះ, សូមលោកកុំក្តៅចរិយាយរឿងតាំងប៉ុន្មានដែលលោកបានដឹង
"មិនអីទេ បើលោកក្តៅខ្ញុំនឹងជួយរំលឹកលោក ។ រឿងព្រះពាមនោះយូរ
"ទៅនឹងក្រអូបសាយសព្វក្រឡាមហាប្រឹថពី ភ្នំ សមុទ្រ ទន្លេ បឹងថេរ
"នៅដកចរលាយទឹករលាយដី ។ កាលរឿងព្រះពាមបានក្រអូបសាយទៅ
"សព្វទិសានុទិសហើយ ខ្លួនលោកនឹងបានឋានៈខ្ពស់បន្ទាប់ពីខ្ញុំ" ។

"ពោលហើយ ព្រះព្រហ្មក៏ជាត់មួយរំពេចទៅ ។ ដើម្បីគោរព
"ដល់បណ្តាំរបស់ព្រះព្រហ្ម, បន្ទាប់ពីនោះ ឥសីវាល្មីកិបានសរសេរ
"សាវតារព្រះពាម ធ្វើជាគម្ពីរមួយឲ្យឈ្មោះថា "ពាមាយណៈ" ជា
"ពាក្យស្មោកសំស្លឹត មានស្មោកដល់ ២៤.០០០ ខែកជាវគ្គមាន ៥០០
"ជាកណ្ឌមាន ៦ ជាមហាគាព្យដ៏ពិរោះ ជាទីគោរពកប់អានរបស់
"ប្រជាជនទូទៅសព្វទិសានុទិស ។

"កាលឥសីវាល្មីកិសរសេរវឿងរាមាយណៈរួចហើយ បានបង្រៀន
"ដល់ឥសី ២ នាក់ ឈ្មោះកុសៈ ១ លវៈ ១ ជាសិស្សរបស់លោកផ្ទាប់
"នៅក្នុងសំណាក់លោកពីដើម ហើយត្រូវជាព្រះនុរសក្មួយរបស់ព្រះ
"រាមទន្ធ ព្រះនាងសិតា ដែលទ្រង់ព្រះសម្ភពក្នុងវេលាព្រះនាងត្រូវព្រះ
"រាមបំបះបង់ គឺដែលខ្មែរយើងហៅថា រាមល័ក្ខ្ណ៍ ជប្បល័ក្ខ្ណ៍ ។

"កុសៈ នឹងលវៈ កំបាននាំរឿងព្រះរាមទៅផ្សាយដល់ប្រជាជននៅ
"នគរអយោធ្យា ។

"លុះផ្ទាបដល់ព្រះរាមក៏ត្រាស់ឲ្យហៅកុសៈ នឹងលវៈ ទៅឲ្យ
"និយាយរឿងរាមាយណៈចំពោះព្រះកក្ត្រព្រះអង្គ ។ ចប់រឿងហើយ
"ទើបព្រះរាមទ្រង់ជាបថា កុសៈ នឹងលវៈ ជាព្រះនុរសរបស់ព្រះអង្គ
"ក៏ទ្រង់ខ្សឹកខ្សួល ហើយទ្រង់សោមនស្សរៀក្រៃពេកដែលបានជួបព្រះ
"រាជនុរសទាំងនោះ" ។

នេះជាសេចក្តីបំព្រួញនឹងសេចក្តីអាថ៌កំបាំងក្នុងរឿងព្រះរាម ។

តាមការស្រាវជ្រាវរក គេឃើញថាខ្មែរយើងសម័យបុរាណធ្លាប់
កាន់សាសនាព្រាហ្មណ៍មកហើយ បានតាំងសាងបូជនីយស្ថានខាង
សាសនានេះ ទុកជាទីបូជានៅពាសពេញប្រទេសកម្ពុជា, ដូចគ្នានឹង
សម័យបច្ចុប្បន្នដែលខ្មែរយើងកាន់ពុទ្ធសាសនា គេបានសាងវត្តជាបូជ-
នីយស្ថានសំរាប់បូជាព្រះពុទ្ធ មានវត្តអារាមជាដើមឡើងជំនួសបូជនីយ-

ស្ថានខាងសាសនាព្រាហ្មណ៍សម័យបុរាណ ។ សូមសង្កេតមើលចុះ ស្ទើរតែសុះសព្វដីខ្មែរយើង បុរាណវត្ថុស្ថាន ដែលជាដំណែលខាងសាសនាព្រាហ្មណ៍ គឺទេវរូបផ្សេងៗ នឹងសិវលិង្គដែលធ្វើអំពីថ្ម នឹងសម្ទឹង្គ នឹងច្រុង្គទេវស្ថានដែលគេច្រើនហៅថា ច្រាសាទ សឹងធ្វើអំពីថ្ម អំពីឥដ្ឋ ហើយទ្វីងអង្គដែលមានភាពដូចជាស្រះ ដូចយ៉ាងអង្គភ្នៅ, អង្គតាសោម, អង្គព្រះលិង្គ នឹងតាំង មានតាំងគោក តាំងក្រសាំង ព្រមទាំងក្រាំង មានក្រាំងចេក ក្រាំងធ្នង់ ជាដើម ។ តាំងនេះសុទ្ធតែជាបុរាណវត្ថុស្ថានក្នុងសាសនាព្រាហ្មណ៍ ដែលបុព្វបុរសរបស់យើងបានកសាងមកហើយ សឹងមាននៅជាកស្តូតាងដរាបដល់សព្វថ្ងៃនេះ ។

បានជាខ្មែរយើងសព្វថ្ងៃមានសទ្ធាជ្រះថ្លារាប់អានរឿងពមក្តី ព្រោះខ្មែរបុរាណបានបង្កាត់បង្កើនរឿងនេះ ដោយនិយាយឲ្យស្តាប់, ដោយទ្វាក់ឫគ្រូរាជរឿងនៅតាមជញ្ជាំងព្រះវិហារ, ច្រាសាទឲ្យឃើញ, ដោយនិទានជាកាព្យឃ្លោងដែលមានសម្ផស្សគួរឲ្យអានឲ្យមើល, ដោយលេងល្ខោនមានល្ខោនខោលនឹងណាំងស្បែកជាដើម ។

រឿងពមក្តីជារឿងយោសនានឹងជាចំណងឲ្យដឿសាសនាព្រាហ្មណ៍ដូចខាងព្រះពុទ្ធសាសនាប្រើការយោសនាដោយរឿងជាតក មានមហាវេស្សន្តរជាតកជាដើម ដែលជាបច្ច័យឲ្យដឿព្រះពុទ្ធសាសនា ។ គេថាព្រះពមជាអាវតារព្រះនារាយណ៍មកជួយស្រោចស្រង់លោក ដូចគ្នានឹងព្រះពុទ្ធជាម្ចាស់ ។

រឿងភមក្មេរ្ចប់ដើមបង្ហស់តើតនៅប្រទេសណា? កុងសម័យ
ណា? នរណាទិពន្ធ?

សូមបញ្ជាក់ថែមទៀត ដូចតទៅនេះ៖

តាមការស្រាវជ្រាវរបស់អ្នកស្រី ស៊ុយសាន - កាបីឡែស
អតីតអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យថា:

"រឿងភមក្មេរ្ចប់ដើមបង្ហស់ហៅថា "រឿងភមាយណ." និយាយ
ពីរឿងព្រះភម តែតវីបណ្ឌិតម្នាក់ឈ្មោះ "វាល្មីគិ" ចានទិពន្ធជាភាសា
កាព្យភាសាសំស្ក្រឹត កុងប្រទេសឥណ្ឌា នាពុទ្ធសកភជ្រមាណជា
៧៥០ គ្រិស្តសកភជ ២០៩ ។

តមកពាក្យកាព្យរឿងព្រះភមនេះ ក៏ផ្សាយចេញពីខែត្រមួយទៅ
ខែត្រមួយ, ពីប្រទេសមួយទៅប្រទេសមួយ ។

នានាប្រទេសចានប្រែពាក្យកាព្យរឿងនេះ ពីភាសាសំស្ក្រឹតមកជា
ភាសាជាតិរបស់ខ្លួន ។, ខ្មែរយើងក៏ចានប្រែមកជាភាសាខ្មែរដែរដាក់
ឈ្មោះថា "រឿងភមក្មេរ" រឿងនេះក៏ទៅជាចេតិយស្ថានធំមួយសម្រាប់
អក្សរសាស្ត្រ និងសាសនា បញ្ជាក់នូវគំនិតនឹងអារ្យធម៌សម័យបុពណ
របស់ប្រទេសឥណ្ឌាទៅលើនានាប្រទេស ។

ពាក្យកាព្យរឿងភមាយណ: ភាសាសំស្ក្រឹត នៅប្រទេសឥណ្ឌា
មានបែបបទដូចម្តេច? រឿងភមាយណ:ដែលនានាប្រទេសចានប្រែផ្សាយ

ដោយតែងជាពាក្យកាព្យតាមភាសារបស់ខ្លួនៗ តៗគ្នាមក ក៏មានបែបបទដូចគ្នាដែរ, ប៉ុន្តែដោយអំណាចទំនៀមទម្លាប់ស្រុក នឹងអំណាចអក្សរសាស្ត្រ របស់ប្រទេសនីមួយៗ ចូលទៅផ្សំផ្សង ក៏សេចក្តីប្រែនោះទៅជាមិនសុទ្ធដូចច្បាប់ដើមជាភាសាសំស្ក្រឹតនោះឡើយ, ហើយរឿងពាយណៈនោះ ក្លាយទៅជាពាក្យកាព្យមួយយ៉ាងធំសម្រាប់ប្រជាជាតិនីមួយៗ ដែលមានរឿងនេះ ។

អាស្រ័យដោយចម្លាក់នៅប្រាសាទអង្គរ នឹងប្រាសាទបន្ទាយក្តីកោះផ្ទា នោះយើងសន្និដ្ឋានថា រឿងពាយណៈបានផ្សាយទូទៅក្នុងរវាង ព.ស. ១៧០០ គ.ស. ១១៥៧ ។

ពាក្យកាព្យរឿងពាយណៈបានចូលមកដល់ប្រទេសខ្មែរយើងតាមផ្លូវណា ? សម័យណា ?

តាមការពិនិត្យនឹងការស្រាវជ្រាវ របស់អ្នកប្រាជ្ញនៅប្រទេសឥណ្ឌា នឹងប្រទេសអឺរ៉ុប យើងដឹងថារឿងពាយណៈបានផ្សាយដោយសារសេចក្តីប្រែរបស់ស្រុកបច័ងគ័ល (ឥណ្ឌា) នឹងដំបន់ឥណ្ឌាបែកខាងត្បូងមកតាមប្រទេសជ្វា នឹងម៉ាឡេស៊ី ទើបចូលមកដល់ប្រទេសខ្មែរយើងក្នុងសម័យអង្គរហើយផ្សាយពីប្រទេសខ្មែរទៅប្រទេសថៃ នឹងប្រទេសលាវ។

សព្វថ្ងៃនេះ នៅប្រទេស ជ្វា ថៃ លាវ នឹងខ្មែរ ប្រជាជនទៅនិយមរឿងពាយណៈនៅឡើយ គេតែងយករឿងនេះមកលេងល្ខោននានាមានល្ខោនព្រះរាជទ្រព្យជាដើម ។

ក្នុងផ្លូវរឿងពាមក្តើតាំងមូល, រឿងដែលអ្នកស្រុកចូលចិត្តជាងគេ គឺត្រង់កន្លែងដែលកពន់ធក់នាងសិតា ។

រឿងពាមក្តើ គេមានគូរជាលំអនៅជញ្ជាំងព្រះវិហារជាច្រើនតាំងក្នុងប្រទេសខ្មែរ លាវ ទឹងប្រទេសថៃ" ។

ប្រទេសកម្ពុជាយើងមានគូរគំនូររឿងពាមក្តើដ៏ជាតិនៅជុំវិញជញ្ជាំងថែវនៃព្រះវិហារព្រះកែវមរកត គូរប្លែចស្រេចធ្វើបុណ្យឆ្នូងព្រះវិហារនេះនៅឆ្នាំខាលចត្វាស័ក ព.ស. ២៤៤៦ គ ស. ១៩០៣ ក្នុងរជ្ជកាលព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម (ព្រះសុវណ្ណគោដ្ឋ) ។

តាមសៀវភៅ "អំពីប្រាសាទខ្លះនៅអង្គរ" ទឹងសៀវភៅ "មគ្គទ្ទេសក៍នគរ" របស់ពុទ្ធសាសនបណ្ឌិត្យមានសេចក្តីសង្ខេបមួយអន្លើថា:

សម័យអង្គរ ក្នុងសតវត្សរ៍ទី ១៧ នៃពុទ្ធសកពាជ, សតវត្សរ៍ទី ១២ នៃគ្រិស្តសកពាជ, ព្រះមហាក្សត្រខ្មែរ ព្រះនាមសូរ្យវរ្ម័នទី ២ ទ្រង់បានសាងប្រាសាទនគរវត្ត, ទ្រង់ឲ្យធ្វើរឿងពាមក្តើជាច្រើនអន្លើនៅជញ្ជាំងប្រាសាទនគរវត្ត មានរឿងត្រង់ព្រះពាមថ្លែងសរសៃឡើងទ្វើដណ្តើមនាងសិតា, ត្រង់ហនុមន្តយកចិញ្ចៀនទៅថ្វាយនាងសិតា, ត្រង់ព្រះពាមឲ្យនាងសិតាចូលភ្លើងដើម្បីសំដែងសេចក្តីស្មោះត្រង់, ត្រង់ទេវតាទឹងអសុរពាញព្រ័ត្រដែលយកនាគឈ្មោះវាសុកីជាព្រ័ត្រ ទេវតាពាញខាងក្បាលនាគ អសុរពាញខាងកន្ទុយនាគ ..... ជាដើម ។

ដោយកស្តុតាងដូចរៀបរាប់ខាងលើនេះ សូមអស់លោកជ្រាប ដោយសង្ខេបថា:

រឿងភមក្តើ មិនមែនជាមតិរបស់បុព្វបុរសខ្មែរយើងទេ ជារឿងកើតដំបូងបំផុតនៅប្រទេសឥណ្ឌា គឺកវីបណ្ឌិតឈ្មោះវាល្មីកិតែងឡើងក្នុងរាជសតវត្សរ៍ទី ៨ នៃពុទ្ធសករាជ, ទី ៣ នៃគ្រិស្តសករាជ ហើយបានផ្សាយចូលមកដល់ប្រទេសខ្មែរយើងក្នុងរាជសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ, ទី ១៤ នៃគ្រិស្តសករាជ គឺសម័យអង្គរ ហើយខ្មែរយើងរាប់អានរឿងភមក្តើនេះ រហូតមកដល់សម័យបច្ចុប្បន្ន ។

តែទោះបីយ៉ាងណាក៏ដោយ រឿងភមក្តើដែលបានផ្សាយមកជាច្រើនសតវត្សរ៍ហើយ គេរាប់ជារឿងសំខាន់ ១ សម្រាប់ជាតិខ្មែរ ក្នុងបណ្តារឿងផ្សេងៗទៀតដែលជាសម្ភារៈខាងអក្សរសាស្ត្រ ។

បរិយាយពីដើមកំណើត នឹងសេចក្តីអាថ៌កំបាំងរបស់រឿងភមក្តើចប់ដោយសង្ខេបប៉ុណ្ណេះ ។

ថ្ងៃខាងមុខ ខ្ញុំបាទនឹងបរិយាយពីរឿងទំនៀមទម្លាប់ខ្មែរមានប្រការផ្សេងៗទៀត ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា នឹងការចេះដឹងតទៅ ។

សុន្ទរកថា

លោកជុំកន់រតនបលៈបិយៈសេនៈម៉ាលីលៈសេកៈ

ជាប្រធានពុទ្ធិកសិមាគមពិភពលោក ថ្លែងក្នុងសមាជសាកលលើកទី ២

នៃពុទ្ធសាសនាទៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

ពុទ្ធសាសនបណ្ឌិត្យ

(តមក)

ដល់ទៅចុងបង្អស់នៃព្រះពជដីវភាព ទ្រង់ចាន្តតទៅខាងអតីតកាលរបស់ទ្រង់ ទ្រង់អាចមានព្រះឧទ្ការៈដោយវិចារណញ្ញាណថា: "សូម្បីតែសត្វតិរច្ឆានចាន់ស្គាល់ន្ទូវសភាពសប្បុរសពីអញ; អញចាន់សោយភជ្យដោយយុត្តិធម៌" យើងអាចសរសើរចំពោះប្រវត្តិសាស្ត្ររបស់យើងចាន់ ។ យើងមិនត្រូវភ្លេច ថាពួកពុទ្ធសាសនិកជន ចាន់លៃលកជាបឋម ជួយពួកអ្នកកំសត់ទុគ៌ត ។ គេមិនអាចថា ដោយសេចក្តីអំពាវនាវ, យើងមិនចាន់មក, ព្រោះមានទុក្ខលំចាកជាច្រើន ដែលយើងត្រូវជួយការពារ ឬវិលកតាមគួរការ ។ យើងមិនត្រូវភ្លេចយកគ្រោយ, កង្វល់ដីវភាពឯកជនរបស់យើង, ត្រង់ចំពេញករណីយកិច្ច, ដោយធ្វើអំណោយន្ទូវច្រាក់ចំពោះអង្គការកុសលផ្លានខាងនេះឬខាងនោះ ដែលយើងចាន់ចូលច្រាក់កលវៃ ឬដោយបង់ពន្ធទៅរដ្ឋាភិបាល ឬជាអង្គការក្នុងស្រុក ដើម្បីនឹងឲ្យយើញថា យើងចាន់បំពេញករណីកិច្ចរបស់យើង ។ យើងត្រូវ

ព្យាយាមចាំងកាយនឹងចិត្ត, ហើយបើត្រូវការ យើងត្រូវទទួលទុក្ខ ចំពោះការរុកកួននឹងការគាស់ធ្លាំធ្លងដែលអ្នកដទៃធ្វើចំពោះយើង ។ លុះតែតែបែបនេះ ទើបយើងជាពុទ្ធសាសនិកជនគេថាជាអ្នកសប្បុរសពិត ។

មួយយ៉ាងវិញទៀត ក្នុងការព្យាយាមរបស់យើងដើម្បីនឹងជួយរបត្តមអ្នកដែលរងទុក្ខលំបាក, កុំឲ្យយើងពិនិត្យកិច្ចការទីមួយៗ តែត្រឹមត្រូវដែនប្រទេសរបស់យើង ។ សេចក្តីទុក្ខគ្មានព្រំដែនទេ, សេចក្តីលំបាកធ្វើឲ្យមនុស្សទាំងអស់ជាញាតិមិត្តគ្រប់ៗគ្នា ។ ពិភពលោកត្រូវប់ទៅជាមានសភាពតូចជាងពីមុន ហើយអង្គការរវាងជាតិឥឡូវទៅជាងាយនឹងស្ថាបនា ។ ខ្ញុំសូមជូនយោបល់ថា ពួកពុទ្ធសាសនិកជនបានស្ថាបនា នូវវង្វែងមួយសមាសនៃករុណាចិត្តដូចកាកបាទក្រហម, ព្រះសម្មាសម្ពុទ្ធ ទ្រង់បានទេសនាទូន្មានប្រាប់យើងថា ឲ្យមានករុណាចិត្តចំពោះសត្វលោកទាំងអស់ "ដើម្បីនឹងផ្សាយនូវអានុភាពកុសលដ៏ធំធេងហួសប្រមាណនូវមេត្តាភាព គ្មានព្រំដែនចំពោះសត្វលោកនឹងដីរសត្វដែលរស់នៅក្នុងពិភពលោក, តស៊ូនឹងរបស់គ្រប់យ៉ាង, ចៀសវាងនូវសេចក្តីស្អប់ខ្ពើម" ខ្ញុំសូមបន្ថែមថាមូលដ្ឋាននៃអង្គការបែបនេះមានស្រាប់ហើយចំពោះប្រទេសជាច្រើនដែលនិយមកាន់ព្រះពុទ្ធសាសនា ។

យើងត្រូវរួបរួមគ្នា

ដើម្បីនឹងឲ្យសម្រេច នូវការណ៍យកចិត្តដ៏ប្រសើរនេះនឹងការណ៍យកចិត្ត ឯទៀតដែលយើងនៅរង់ចាំ, ឮ្លាក់គោលជាបឋម គឺឯកភាព, សមាគម ហើយនឹងសហការពួកពុទ្ធសាសនិកជនពិភពលោក ។ ក្នុងចំណោម វត្ថុបំណង ពួកពុទ្ធិកសមាគមពិភពលោក, វត្ថុបំណងទីមួយគឺការ ស្ថាបនា នៃមនោធម្មឯកភាព ចំពោះពួកពុទ្ធសាសនិកជននោះឯង ។ តាំងពីយូរណាស់មកហើយ, យើងបានស្ថិតនៅឆ្ងាយពីគ្នា, ម្នាក់ៗនៅ ក្នុងក្រុមសព្វៗខ្លួន, ព្យាយាមរួបរួមសេចក្តីផ្សេងៗគ្នាទៅតាមប្រទេស ដែលគ្មានសារៈសំខាន់អ្វីឡើយ ។

ការដែលបែកសាមគ្គីនេះស្ថិតនៅមាន ក្នុងលទ្ធិពុទ្ធសាសនាគ្រប់ៗ ប្រទេស មានសភាពហួសកំរិតពីសេចក្តីពិតនោះទៅទៀត ។ ការ បែកសាមគ្គីនោះ ដូចជាគ្រប់គាំងផ្សេងៗ រួមចូលទៅក្នុងការសំខាន់ តែមួយឯកឯង ។ យើងមិនអាចយើញបាន ចំពោះគណៈក្នុងពុទ្ធ-សាសនា ថាមានអ្វីដូចជាសភាពផ្សេងនៃលទ្ធិដែលស្ថិតនៅក្នុងនាមជា ច្រើន ក្នុងគ្រិស្តសាសនានោះឡើយ ។ ព្រោះថា ឮ្លាក់គោលនៃ ព្រះពុទ្ធសាសនា ដែលមាន ៣ យ៉ាង (ដួងគាលបួន), អរិយសច្ចធំង ៤, មគ្គសច្ចដែលមានផ្លូវ ៨ យ៉ាង, ពួកពុទ្ធសាសនិកជនក្នុងពិភពលោកយល់ព្រមថាជាពាក្យពិត, ឥតមានយល់ខាស់អ្វីសោះឡើយ ។

យើងមិនត្រូវឲ្យកំសួល ដែលផ្សាយចេញពីសភាពផ្សេងគ្នាខាងខំនៀមទម្លាប់ ព្រមទាំងពិធីដឹកនាំយើងបានសោះឡើយ, ហើយមិនត្រូវឲ្យសភាពទាំងនេះ ឃាត់ហាមយើងមិនឲ្យរួបរួមគ្នាជាសមាគមមួយដើម្បីជាប្រយោជន៍ដល់ពិភពលោក ដើម្បីនឹងបំបាត់នូវការលំបាកក្នុងសង្គម បង្កើននូវសុភនាមទាំងញាណដ៏បរិសុទ្ធ, វឌ្ឍនូវវិសាលភាពនៃសីលធម៌មនុស្សជាតិ, ញុំាងសន្តិភាពពិភពលោកឲ្យកើតមានឡើង ហើយនឹងលៃលកឲ្យមានសុភមង្គល ចំពោះមនុស្សជាតិទាំងអស់ ។ យើងត្រូវលះបង់នូវទុបាទានជាធម្មជៈកខាប ហើយត្រូវប្រឹងប្រែងព្យាយាមស្ថាបនា នូវពិភពលោកពុទ្ធសាសនាប្រាសចាកនូវគារុណភាព ត្រូវតាំងចិត្តស្មោះស្ម័គ្រចំពោះព្រះធម៌ រួបរួមកម្លាំងកិត្តិយសចំពោះព្រះអនាវរណញ្ញាណ ដែលទុកជាបរមគ្រូនៃយើងទាំងអស់គ្នា ព្រមទាំងជាមគ្គទេសក៍នៃសត្វទាំងឡាយ, ភាតរភាពនៃពួកពុទ្ធសាសនិកជនជាអតីតនិម្មិត ដែលនាំឲ្យកើតនូវភាតរភាព ចំពោះមនុស្សទាំងអស់ក្នុងពិភពលោក ។

ក្នុងសេចក្តីព្យាយាមរបស់យើង ដើម្បីនឹងសម្រេចនូវភាតរភាពនៃពួកពុទ្ធបរិស័ទ យើងអាចនឹងជួបប្រទះនូវឧបសគ្គនឹងបច្ចាមិត្តជាច្រើនដែលជាអ្នកបំផ្លាញនូវសភាពសុខដុមព្រមទាំងធ្វើឲ្យបែកសាមគ្គី ។ ឧបាយទាំងនេះមិនមែនទើបនឹងមានមកថ្មីៗនេះទេ ពួកទាំងនេះពោលបង្កើស

ចំពោះផែនការណ៍របស់យើង ។ ទ្វារគ្មិបំណងដែលយើងគ្មានសោះឡើយ ។ កិច្ចការនេះគឺធ្វើដោយមានបំណងល្អមក. តែច្រើនដោយសេចក្តីល្ងង់ខ្លៅគ្រប់សង្កត់. សេចក្តីល្ងង់ដែលព្រះពុទ្ធសាសនាយល់ថាជាប្រភព នៃការអាក្រក់នោះ។ ។ យើងមិនត្រូវអើពើនឹងបុគ្គលទាំងនេះទេ, ហើយយើងត្រូវតែទុកចិត្តចំពោះកិច្ចការស្មោះត្រង់ នៃវត្ថុបំណងរបស់យើង ។ យើងមិនមែនឲ្យបុគ្គលណាលះបង់យោបល់របស់ខ្លួនសោះឡើយ ។ ចូរឲ្យបៀសចេញឆ្ងាយទៅ, ចិត្តាចំពោះតែដ៏ទុក្ខឧត្តមនៃព្រះពុទ្ធសាសនា មានសម្តេចព្រះសង្ឃរាជ ដូចជា "ចាប" ខាងគ្រិស្តសាសនា មានបុគ្គលជាឥស្សរជនស្ថិតនៅក្រោមបង្គាប់បញ្ជាតែមទាំងយោបល់បែបនេះ ។

យើងមានវត្ថុបំណងតែមួយយ៉ាង គឺរៀបចំប្រតិបត្តិតាមជីវភាពដ៏ល្អព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាទូន្មានប្រដៅដើម្បីនឹងឲ្យយើងតែមទាំងពិភពលោក ចានទទួលនូវផលប្រយោជន៍គ្រប់ៗគ្នា ។ យើងត្រូវតែដំណើរការធ្វើឲ្យរលកសុខដុមនោះគ្រាប់ទៅតាមលំនាំស្រួល, យើងត្រូវតែព្យាយាមធ្វើឲ្យរលកនោះចម្រើនធំឡើង ក្លាយទៅជារង្វង់ធំមានពលភាពអាចនាំយកសភាពល្អមកឬឧបសគ្គដែលកំពុងតូវខាងមុខ ។ ឥឡូវនេះយើងគ្រាន់តែព្រោះសាបពូជនៃសហការប៉ុណ្ណោះ ។ ពូជនេះត្រូវយកដីនៃជីវភាពខាងក្នុងយកទៅបរិភោគ; ចម្រើនវិធីវប្បធម៌ឡើង,

ផ្សាយទៅពាសពេញ, វាតសកម្មភាពធំឡើង ។ ឯកភាពរបស់យើង
ត្រូវមានមូលដ្ឋានធំហើយរឹងប៉ឹង ហើយតឹងផ្អែកទៅលើពលភាពជ្រាជ្រា
នៃព្រះធម៌ ។ យើងត្រូវទៅមុខ មានសម្បជញ្ញៈចំពោះវត្តុបំណង
ដ៏ខ្ពង់ខ្ពស់ពិតជ្រាកដគ្រប់ៗគ្នា ។

បើកឲ្យធំទូរប្រមុំអមត្តភាព បើអ្នកជ្រាបសេចក្តីជ្រៅផ្លូវធម៌ ចូរ
នាំគ្នាចិត្តកុំឃ្លងព្យាយាមដំ ចិត្តស្មោះសមត្រង់តបស្នេគ្រាច់តាមទៅ ។

វត្តុបំណងសន្តិភាពរបស់យើង

ឯកភាពដែលយើងសង្ឃឹមរក្សាទុកជាមុនទឹងយកប្រើការ មិនមែន
ឲ្យបានសម្រេចនូវពលភាព, តែដើម្បីឲ្យបាននូវសន្តិសុខហើយនឹងសុក-
មង្គលនៃមនុស្សជាតិទាំងអស់ដោយទុបត្តម្ភ ត្រង់ស្នាងនូវសង្គមសីលធម៌
មួយ ហើយនឹងមនោធម៌ជាសមូហភាពនៃប្រជាជនពិភពលោកតស៊ូនឹង
សង្គ្រាម ឬនឹងការដែលមានសង្គ្រាមទៅអនាគត ។ មនុស្សជាតិប្រកប
ដោយទុក្ខលំបាកជាច្រើនប្រការ វិទ្យាសាស្ត្រូបភជ័យ ក្នុងសេចក្តី
ព្យាយាមរំរែកនូវសភាពអាថ៌កំបាំងនៃសុភមង្គល ។

"ការតស៊ូរបស់ធម្មជាតិ មិនអាចសម្រេចឲ្យបានមកយើងនូវ
សម្បូណភាពឬសន្តិភាព" ។ បើតាមយើង, របស់អស់ទាំងនោះចៀស
វាងមកមិនរួច ។ ព្រះពុទ្ធសាសនាមិនបានយល់ថា ធម្មជាតិត្រូវតែ
យើងតស៊ូឲ្យឈ្នះយកធម្មជាតិនោះប្រើជាទាសា សម្រាប់មនុស្ស ដើម្បី

ទើសម្រែចទៅតាមបំណងថ្នូរប្រយោជន៍ផ្ទាល់ខ្លួន (អត្តទត្ថភាព) គេបាន
បង្រៀនយើងថាសុភមង្គលស្ថិតនៅក្នុងដំរិភាព ប្រកបទៅតាមសុខដុម
ចំពោះព្រះធម៌ គឺធម្មជាតិ, ព្រមទាំងសុភនាមទើងត្តមភាព ។

គេបានបង្ហាត់យើងជាមធ្យោបាយ ដែលនឹងឲ្យបានសម្រែច
សន្តិភាព គឺត្រូវបំបាត់នូវហេតុដែលជាលេជ្ជាំនៃសង្គ្រាម ចិត្តលោភ,
ចិត្តស្អប់, ចិត្តលង់ខ្វៅ ។ តែឥឡូវនេះពិភពលោកមានញែកជាដុំនៃ
ពលភាពបានព្យាយាមប្រឹងរូវថាមភាព ទើងប្រាជ្ញាចំពោះចម្ងាំង ដែល
គ្មានផលប្រយោជន៍អ្វីសោះឡើយ ។ មនុស្សជាតិរស់នៅក្នុងអជ្ឈជ-
ភាសខ្លាចជានិច្ច មិនអាចបញ្ចេញនូវចិត្តាឲ្យបានច្បាស់លាស់ ។
ពិភពលោកមិនអាចនឹងមានសន្តិភាពបាន បើមនុស្សទើងប្រជាជាតិ
មិនលះបង់នូវបំណងជាអត្តទត្ថភាព គេមិនប្រាសចាកនូវការគំនុំគុំគួនពី
ជាតិ ហើយមិនអាចធ្វើចិត្តឲ្យបានបរិសុទ្ធស្អាតងាកចេញពីគំនិត អាណា
និគមនិយម ដែលសម្រែចប្រយោជន៍ផ្ទាល់ខ្លួន បង់បានបង់មានបង់កាន់
អំណាច ។ គោគ្គៃព្យមិនដែលឲ្យសុភមង្គលទេ ។ ការដែលបង្ហាញ
នូវពលភាពនេះ មិនមែនសមស្របសម្រាប់ការពារសភាពលាមកអាក្រក់
ព្រោះថាពលភាព ធ្វើឲ្យសេចក្តីអាក្រក់កាន់តែចម្រើនឡើង ។

កត្តិកាសញ្ញា, សន្តិសញ្ញាគ្មានតម្លៃអ្វីសោះឡើយ ។

(មានត)

ភាវនាសនវិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៥ ខែតុលា លេខ ១០

ព.ស. ២៤៨៦ – គ.ស. ១៩៤២



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— ធម្មទាសកថា	ព្រះបាឡាត់ឧត្តមលំទិត សុង - ស៊ីវ	៧២៣
— ពិធីក្រាលគ្រងកបិន	ព្រះមហាឧត្តមវិជ្ជា កែ - អឿន ..	៧៣២
— ពិធីបុណ្យវិសាខបូជានៅលង្កាទ្វីប	អ្នកស្រីសារីយ៉ាន់	៧៤៣
ផ្នែកអក្សរសាស្ត្រ		
— ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៊ម	៧៥៥
— រឿងសាមកុក (តមក)	ឧកញ៉ា នូ - ហន	៧៦០
— រឿងអាវ៉ក្សថ្លែងរឿងម្តែប្រាំ (តមក) ...	លោក ភ័យ - ប៊ុក	៧៦៧
— រឿងជិញ្ជៀនទិព្យ (តមក)	អ្នកស្រីសារីយ៉ាន់	៧៧១
— រឿងប៉ូលនឹងវីរ៉ស៊ីនី (តមក)	លោក ផេង - ជ្រឿ	៧៧៧
— សកម្មភាពនៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរ បរិយាយអំពីរបៀបដង្ហែទន្លេ	លោកចាប - ពិន	៧៨៣
កំណត់ទឹកប្រវត្តិការណ៍		
— សុន្ទរកថាបណ្ឌិតម៉ាល៉ាល់សេកេរៈថ្លែងក្នុងសមាជសាកលលើកទី ២ នៃពុទ្ធសាសនា (ត-ចប់) ពុទ្ធសាសនបណ្ឌិត្យ ...		៧៩៤

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៩២រ. ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE

		Page
— Dhammadasakatha	*Brah Balat Uttamalikhita SONG-SIEU*	723
— Vidhikralkrong-kathin	*BraH Maha KER-OEURN* . . .	732
— La Fête bouddhique de Visakha à Ceylan	*Mme SARIS-YANN*	743

PARTIE LITTERAIRE

— Education morale (suite) . .	*Brah Maha PEUNG-PAM* . . .	755
— Histoire de SAMKOR (suite) . .	*Oknha NOU-KAN*	760
— Les vingt cinq récits du Mauvais Génie (suite)	*M. RAY-BUC*	767
— La bague magique (suite)	*Mme SARIS-YANN*	771
— Paul et Virginie (suite et fin) . . .	*M. PHÉNG-CHRIEU*	777
— Activité de la Commission des Mœurs et Coutumes (Accouchement)	*M. CHAP-PIN*	783

NOTES ET CHRONIQUES

— Discours du Dr. MALALASEKERA au 2e Congrès Mondial Bouddhique (suite et fin)	*INSTITUT BOUDDHIQUE* . . .	794

Prix d'abonnement annuel (comprenant 12 numéros): 192$00

ធម្មទេសកថា

ព្រះបាទ្បាត់ឧត្តមលិខិត សុង-សីរី វត្តលង្កា ភ្នំពេញ

ទេសនាដាក់វិទ្យុប្រទេសកម្ពុជាកាលពីថ្ងៃ ៨ កើតខែដេស្ស ឆ្នាំជូតសំរឹទ្ធិស័ក

ព.ស. ២៤៩១ (៤-៦-៤៩)

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ត្រមាំងត្រែធម៌ ទឹងព្រះសង្ឃដោយគោរព) ។

វេលានេះ អាត្មាភាពសូមសំដែងនូវធម្មបរិយាយឈ្មោះ ធម្មាសៈ "ធម៌ដូចកែវធ្ងុះ" ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែង មាននៅក្នុងសុត្តន្តបិដក គម្ពីរទីឃនិកាយ មហាវគ្គ ជាធម្មស្រវ៉ានាការ ដូចតទៅនេះ ។

ធម្មបរិយាយឈ្មោះ ធម្មាសៈ នេះមាន ៤ យ៉ាង គឺ:

១.— ពុទ្ធេ អវេច្ចប្បសាទោ សេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធ ។

២.— ធម្មេ អវេច្ចប្បសាទោ សេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះធម៌ ។

៣.— សង្ឃេ អវេច្ចប្បសាទោ សេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះសង្ឃ ។

๔.— អរិយកន្តសីលំ សីលជាទីគាប់ចិត្តរបស់អរិយបុគ្គល ។

ធម៌ទាំង ៤ យ៉ាងនេះតែងមានក្នុងអរិយបុគ្គល, ជាធម៌ជាន់ខ្ពស់ ដូចជាគ្រឿងសំពាប់ធ្នូរមើលទៅវត្ថុនឹងបរលោក របស់ខ្លួនទើបបុគ្គលដទៃ ឬថាសំពាប់ធ្នូរមើលទៅវត្ថុនឹងបដិសន្ធិក៏បាន ។

អធិប្បាយ

តាមពិត ធម្មទាសកថានេះ ព្រះសក្យមុនីសម្ពុទ្ធទ្រង់សំដែងក្នុងមហាបរិនិព្វានសូត្រ ចំពោះព្រះអានន្ទដ៏មានអាយុថា: "ម្នាលអានន្ទ! សត្វគឺមនុស្សដែលធ្វើមរណកាលដោយហេតុណា ហេតុនោះមិនជាអស្ចារ្យទេ ព្រោះកាលបើមនុស្សនោះៗ ធ្វើមរណកាលហើយ អ្នកទាំងឡាយមុខជានឹងមករកតថាគត ហើយស្នូរទៅដំណើរនោះ, ម្នាលអានន្ទ! នេះជាសេចក្តីលំបាកដល់តថាគតណាស់" ។ ហើយទ្រង់សំដែងតទៅទៀតថា "ម្នាលអានន្ទ! ព្រោះហេតុនោះ អរិយសាវ័កប្រកបដោយធម្មបរិយាយណា កាលបើប្រាថ្នានឹងព្យាករ ក៏គប្បីព្យាករខ្លួនដោយខ្លួនឯងបានថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បេត្តិវិសំយហើយ អស់អបាយទុគ្គតិនិងឋានៈហើយ អាត្មាអញជាសោតាបន្នបុគ្គល លែងធ្លាក់ចុះហើយ ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅខាងមុខ ដូច្នេះ តថាគតនឹងសំដែងទូរធម្មបរិយាយនោះឈ្មោះ ធម្មទាសៈ (ធម៌ដូចជាកែវធ្នូ) ។

ធម្មបរិយាយទី ๑ - ព្រះសម្ពុទ្ធបរមគ្រូទ្រង់សំដែងថា: អរិយសាវ័កប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធថា: ឥតិបិ សោ ភគវា អរហំ ព្រះមានព្រះភាគអង្គនោះទ្រង់ធ្វើយចាកកិលេស ហើយ សម្មាសម្ពុទ្ធោ ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯងដោយប្រពៃ វិជ្ជាចរណសម្បន្នោ ទ្រង់បរិបូណ៌ដោយវិជ្ជានឹងចរណៈ សុគតោ ទ្រង់ដល់នូវសុន្ទរស្ថាន លោកវិទូ ទ្រង់ជ្រាបច្បាស់នូវលោក អនុត្តរោ ទ្រង់ប្រសើរដោយសីលាទិគុណ បុរិសទម្មសារថិ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន សត្ថា ទេវមនុស្សានំ ទ្រង់ជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ពុទ្ធោ ទ្រង់ត្រាស់ដឹងនូវអរិយសច្ចធម៌ ភគវា ទ្រង់លែងវិលត្រឡប់មកកាន់កំពង់ថ្មីទៀត; ព្រះអរិយបគ្គលទាំងឡាយមានមនោសញ្ចេតនាជ្រះថ្លាចំពោះព្រះពុទ្ធគុណទាំង ๑๐ នេះ ពុំមានរំភើបញាប់ញ័រឡើយ, នេះជាធម្មទេសនាទី ๑ ។

ឯព្រះពុទ្ធគុណទាំង ๑๐ នេះ បើបំប្រួញឲ្យខ្លីមកនៅត្រឹមតែ ๓ គឺ ๑ - បញ្ញាគុណ សំដៅយកការត្រាស់ដឹងនូវមគ្គញ្ញាណ ដែលជាទីតាំងនៃសព្វញ្ញុតញ្ញាណនឹងញ្ញាណដ៏សេស មានចតុវេសារជ្ជញ្ញាណ, ទសពលញ្ញាណនឹងអនាវរញ្ញាណជាដើម ដែលជាហេតុឲ្យសម្រេចគុណដល់សព្វសត្វ ។

๒ - វិសុទ្ធិគុណ សំដៅយកសេចក្តីបរិសុទ្ធិរបស់ព្រះអង្គ ចាន់ដល់ការលះបង់នូវកិលេសតែមចាំង៧សន្ទានជាប់ស្រឡះ តោះបីលោកធម្មចាំង ៨ ប្រការកើតឡើងចំពោះព្រះអង្គ ក៏ទុកព្រះទ័យរបស់ព្រះអង្គមិនញាប់ញ័រឡើយ ។

៣ - ករុណាគុណ ចាន់ដល់សេចក្តីអាណិតអាសូរដល់ពួកសត្វដែលកំពុងក្តៅក្រហល់ក្រហាយអន្ទះអន្ទែងដោយភ្លើងទុក្ខ ភ្លើងកិលេសជ្រមុជឈ្លក់នៅក្នុងសមុទ្រគឺសង្សារ រងទុក្ខវេទនារកទីបំផុតគ្មាន ទ្រង់មានព្រះទ័យប្រាថ្នានឹងស្រោចស្រង់ លើកស្ទួយសត្វទាំងនោះឲ្យរួចអំពីទុក្ខវេទនានោះ ។

គុណចាំងបីនេះ ជាទីប្រជុំចុះនៃគុណចាំង ១០ គឺ សម្មាសម្ពុទ្ធោ ១, វិជ្ជាចរណសម្បន្នោ ១, លោកវិទូ ១, បីនេះសន្រ្គោះចូលក្នុងបញ្ញាគុណ ។ អរហំ ១, សុគតោ ១ អនុត្តរោ ១, បីនេះសន្រ្គោះចូលក្នុងវិសុទ្ធិគុណ ។ បុរិសទម្មសារថិ ១, សត្ថាទេវមនុស្សានំ ១, ពុទ្ធោ ១, ភគវា ១ ប្លែនេះសន្រ្គោះចូលក្នុងករុណាគុណ ។

ម្យ៉ាងទៀតគុណចាំងបីនេះ បើបំប្រែញឲ្យខ្វែមកទៀតនៅតែពីរ គឺ អត្តហិតគុណ ១, បរហិតគុណ ១, គុណចាំងពីរនេះជាទីប្រជុំចុះនៃគុណចាំង ១០ គឺ អរហំ ១, សម្មាសម្ពុទ្ធោ ១, វិជ្ជាចរណសម្បន្នោ ១, សុគតោ ១, លោកវិទូ ១, ប្លែនេះជាអត្តហិតគុណព្រោះគុណជា

ប្រយោជន៍ចំពោះព្រះអង្គ ។ អនុត្តរោ ๑, បុរិសទម្មសារថិ ๑, សត្ថា-
ទេវមនុស្សានំ ๑,ពុទ្ធោ ๑, ភគវា ๑, ឯ៎ះនេះជាបរមិតគុណ ព្រោះ
គុណជាប្រយោជន៍ចំពោះសត្វដទៃ ។

ធម្មបរិយាយទី ๒— ព្រះសម្ពុទ្ធជាបរមគ្រូទ្រង់សំដែងថា
អរិយសាវ័កប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ថា
स्वाक्खातो भगवता धम्मो ធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ
ដោយប្រពៃ सन्दिट्ठिको ធម៌ដែលអរិយបុគ្គលគប្បីឃើញច្បាស់ដោយ
ខ្លួនឯង अकालिको ជាធម៌ឲ្យផ្លូវផលមិនរង់ចាំកាល ឯហិ-
पस्सिको ជាធម៌គួរនឹងហៅថា អ្នកចូរមកមើលដូច្នេះបាន ឱបន-
यिको ជាធម៌ដែលអរិយបុគ្គលគប្បីបង្អោនចូលមកកុំកន្តឹងខ្លួន បច្চត្តំ
वेदितब्बो विञ्ञूहि ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយមានតុគ្ឃជិតញ្ញូ-
បុគ្គលជាដើម គប្បីដឹងដោយជាក់ច្បាស់ក្នុងចិត្តនៃខ្លួន ។

អរិយបុគ្គលទាំងឡាយ មានមនោសញ្ចេតនាជ្រះថ្លាចំពោះព្រះធម្ម-
ណាទាំង ๖ នេះតុំមានរំកើបញាប់ញ័រឡើយ, នេះជាធម្មាសៈទី ๒ ។

ឯព្រះធម្មគុណនេះបានដល់បិដកទាំងបី គឺ: វិន័យបិដក ๑, សុត្តន្ត
បិដក ๑ អភិធម្មបិដក ๑ ។ ដែលហៅថាវិន័យបិដក គឺកញ្ចើប្អូកាជន:

សម្រាប់ដម្កល់នូវវិភង្គ៌ចំនួនពីរ គឺ កិក្ខុវិភង្គ៌ ទី៨កិក្ខុនីវិភង្គ៌, ទី៨ខន្ធក: ចំនួន ២២ មានមហាខន្ធក:ជាដើម, ទី៨ចាតុមោក្ខចំនួនពីរគឺ កិក្ខុចាតុមោក្ខ ទី៨កិក្ខុនីចាតុមោក្ខ, ចំនួនបរិវារ: ១៦ មានភគ្គបញ្ញត្តនិវារ:ជាដើម ដែលព្រះថេរ:ចំនួនឡាយសមោធានរួបរួមកុងឯបឋមសង្គីតិ ។

ដែលហៅថា សុត្តន្តបិដក គឺកញ្ចើប្អូកាជន សម្រាប់ដម្កល់នូវពុទ្ធវចន: ដែលមាននៅកុងនិកាយចំនួន ៥ គឺ ទីឃនិកាយ សង្គ្រោះដោយសូត្រ ៣៤ មានព្រហ្មជាលសូត្រជាដើម ១ បឋ្ឍមនិកាយ សង្គ្រោះដោយសូត្រ ២៥២ មានមូលបរិយាយសូត្រជាដើម ១, សំយុត្តនិកាយ សង្គ្រោះដោយសូត្រ ៧.៧៦២ មានឧឃឥរសូត្រជាដើម ១, អង្គុត្តរនិកាយ សង្គ្រោះដោយសូត្រ ៩ ៥៥៧ មានចិត្តបរិយោទានសូត្រជាដើម ១, ខុទ្ទកនិកាយ មានប្រភេទ ១៥ មានខុទ្ទកបាឋជាដើម ១ ។

ដែលហៅថា អភិធម្មបិដក គឺកញ្ចើប្អូកាជន: សម្រាប់ដម្កល់នូវពុទ្ធវចន: ដែលមាននៅកុងគម្ពីរចំនួន ៧ និយាយអំពីចិត្ត, ចេតសិក, រូប, និព្វាន ។ គម្ពីរចំនួន ៧ នោះ គឺ: ១ - ធម្មសង្គ្រណី មានគំនរធម៌ចំនួន ១ ៣០០ (ធម្មក្ខន្ធ), ២ - វិភង្គ៌ មាន ៦ ៥០០ ធម្មក្ខន្ធ, ៣ - ធាតុកថា មាន ៧.០០០ ធម្មក្ខន្ធ, ៤ - បុគ្គលប្បញ្ញត្តិ មាន ៥.៦០០ ធម្មក្ខន្ធ, ៥ - កថាវត្ថុ មាន ៧ ១០០ ធម្មក្ខន្ធ, ៦ - យមក: មាន ៥.១០០ ធម្មក្ខន្ធ, ៧ - មហាបដ្ឋាន មាន ៤.៥០០ ធម្មក្ខន្ធ ។ បិដកចំនួនបីនេះ

មានគំនរធម៌ចំនួន ៨៤.០០០ (ចតុរាសីតិសហស្សធម្មក្ខន្ធ) គឺព្រះវិន័យបិដកមាន ២១.០០០ ធម្មក្ខន្ធ, ព្រះសុត្តន្តបិដក មាន ២១.០០០ ធម្មក្ខន្ធ, ព្រះអភិធម្មបិដក មាន ៤២.០០០ ធម្មក្ខន្ធ ។

ធម្មបរិយាយទី ៣— ព្រះសម្ពុទ្ធជាបរមគ្រូទ្រង់សំដែងថា ព្រះអរិយសាវ័កប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះសង្ឃថា: សុបដិបន្នោ ភគវតោ សាវកសង្ឃោ ពួកសាវ័កបស់ព្រះដ៏មានព្រះភាគប្រតិបត្តិដោយប្រពៃ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ពួកសាវ័កនៃព្រះដ៏មានព្រះភាគប្រតិបត្តិដោយត្រង់ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ពួកសាវ័កបស់ព្រះដ៏មានព្រះភាគប្រតិបត្តិដើម្បីព្រះនិព្វាន សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ពួកសាវ័កបស់ព្រះដ៏មានព្រះភាគប្រតិបត្តិដោយសមគួរ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ ព្រះសង្ឃទាំងនោះ បើពាប់ជាគូនៃបុរសមាន ៤ គូ បើពាប់រៀងជាបុរសបុគ្គលមាន ៨ ពួក នៃសាវ័កបស់ព្រះដ៏មានព្រះភាគទុំនេះ, អាហុណេយ្យោ លោកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា បាហុណេយ្យោ លោកគួរទទួលនូវទក្ខិណាទាន អញ្ជលិករណីយោ ជាបុគ្គលដែល

សត្វលោកគប្បីធ្វើអញ្ជលីកម្ម អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ជាបុញ្ញក្ខេត្តដ៏ប្រសើរបស់សត្វលោក ។ អរិយបុគ្គលទាំងឡាយលោកមានមនោសញ្ចេតនា ដែះថ្ងាចំពោះព្រះសង្ឃគុណទាំង ៩ នេះ តុំមានរំតើបញ្ចាប់ញ័រឡើយ, នេះជាធម្មទេសៈទី ៣ ។

ឯគុណព្រះសង្ឃទាំង ៩ នេះ បើបំប្រួញចុះមកនៅត្រឹមតែពីរយ៉ាង គឺ អត្តហិតគុណ ១ បរហិតគុណ ១; ត្រង់បទថា: សុបដិបន្នោ ១, ឧជុបដិបន្នោ ១ ញាយបដិបន្នោ ១. សាមីចិបដិបន្នោ ១ ទាំង ៤ នេះឈ្មោះថា អត្តហិតគុណ ព្រោះជាគុណទំនុកបំរុងដល់ខ្លួន ។ អាហុណេយ្យោ ១, បាហុណេយ្យោ ១, ទក្ខិណេយ្យោ ១, អញ្ជលិករណីយោ ១, អនុត្តរំបុញ្ញក្ខេត្តំលោកស្ស ១, ទាំង ៥ នេះឈ្មោះថា បរហិតគុណ ព្រោះជាគុណទំនុកបំរុងដល់អ្នកដទៃ ។

ធម្មបរិយាយទី ៤— ព្រះសម្ពុទ្ធជាចរមគ្រូត្រង់សំដែងថាអរិយសាវ័កប្រកបដោយសីលជាទីគាប់ចិត្តរបស់អរិយៈ ជាសីលមិនដាច់, ជាសីលមិនធ្លុះ, ជាសីលមិនពពាល, ជាសីលមិនពព្រៃ, ជាសីលរបស់អ្នកជា, ជាសីលមិនជ្រែកជ្រាកដោយតណ្ហានិងទិដ្ឋិ ជាសីលញុំងសមាធិឲ្យប្រព្រឹត្តទៅបាន; នេះជាធម្មទេសៈទី ៤ ។

អរិយបុគ្គលទាំងឡាយប្រកបដោយធម្មបរិយាយ ឈ្មោះធម្មទេសៈទាំង ៤ នេះ កាលបើលោកត្រូវការនូវមើលនូវតំនឹងបរលោក

របស់បុគ្គលដទៃ ទើបខ្លួនលោកក៏អាចតម្កល់បានថា: អាត្មាអញ
អស់នរកហើយ, អស់តំណើតតិរច្ឆានហើយ, អស់បេត្តិវិស័យហើយ
អស់អបាយទុគ្គតវិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល លែងធ្លាក់
ចុះហើយ ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅខាងមុខ ។

សាធុវៅ បពិត្រសប្បុរសទាំងឡាយ! បើសប្បុរសមានមនោសញ្ចេ-
តនាប្រាថ្នាខ្លួរសេចក្តីសុខសេចក្តីចំរើន គួរខំញ៉ាំងសេចក្តីជ្រះថ្លាក្នុងព្រះ
រតនត្រៃ គឺព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ ឲ្យស្ថាពរមាំមួនពុំគប្បីស្ទើបរំភើប
ញាប់ញ័រដោយវត្ថុជាតុផ្សេង។ ទាំងចំថែរក្សាសីលរបស់ខ្លួនឲ្យបរិសុទ្ធគត់
មត់ល្អ ឲ្យជាសីលគួរដល់សេចក្តីសរសើររបស់អរិយបុគ្គលទាំងឡាយ ។

ដោយតេជៈនៃធម្មទេសនានេះ សូមទេវតាទាំងមួយហ្មឺនលោក-
ធាតុជួយពិភក្តិរក្សាព្រះបិយមហាក្សត្រ ព្រមទាំងព្រះពជវង្សានុវង្ស
សូមទ្រង់ប្រសិទ្ធដោយចតុត្ថជ្ឈានវារ គឺ: អាយុ, វណ្ណៈ, សុខៈ, ពលៈ:
បរិបូណ៌ដោយតេជានុភាពបរិហារកម្មដប្រទេស ឲ្យបានលុះដល់នូវ
ឧត្តមគតិដោយមុហុត្តកាលដ៏រួសរាន់ទាន់សម័យ!

ទាំងសូមពុទ្ធបរិស័ទគ្រប់ជាន់ ដែលបានប្រតិបត្តិតាមសាសនវិធី
ក្រោមអធិបតេយ្យនៃព្រះសម្មាសម្ពុទ្ធ ឲ្យបានប្រកបដោយសុខភាព
អនាម័យដ៏បរិបូណ៌ សមតាមអធ្យាស្រ័យវត្ថុបំណងកុំបីឃ្លាតឡើយ! ។

ចប់

ពិធីក្រាលគ្រួសកឋិន

ព្រះមហាឧត្តមរាជ្ញា កែ-អ្រឿន (រ៉ាំយប្បញ្ញោ)
វត្តព្រះពុទ្ធវត្តន៍ ខេត្តសៀមរាប រៀបរៀង
ព្រះទេពសត្ថា សូរ-ហាយ ពិនិត្យកែសម្រួល

ក្នុងទីនេះ នឹងរៀបរៀងជាលីសម្រាប់វេរកឋិន ត្រមៗតាមកិច្ចផ្សេងៗ មានពិធីក្រាលគ្រួសកឋិនជាដើម ទុកជាបែបក្នុងបុណ្យកឋិនទាន ។

ជាលីវេរកឋិនទានដល់ព្រះសង្ឃ

(១) តិមំ ទុស្សំ កឋិនបិរិវារំ សង្ឃស្ស ទេម ។ ទុតិយម្បិ, តតិយម្បិ ។

ប្រែថា "(បពិត្រព្រះគម្ពីរសង្ឃដ៏ចំរើនអើយ) យើងខ្ញុំទាំងឡាយសូមវេរនូវសំពត់នេះ ជាសំពត់កឋិនបិវារ ប្រគេនចំពោះព្រះសង្ឃ ។ អស់កាល:ពីរដងផង, អស់កាល:បីដងផង" ។

ឬនឹងវេរដោយជាលីផ្សេងទៀតក៏បាន ដូចមានខាងក្រោមនេះ

(២) មយំ ភន្តេ តិមំ វត្ថំ កឋិនបិរិវារំ សង្ឃស្ស និយ្យាទេម
សាធុ ភន្តេ សង្ឃោ តិមំ វត្ថំ កឋិនបិរិវារំ បដិគ្គណ្ហាតុ បដិគ្គ-

---

១ ជាលីនេះបានដកស្រង់ពីសៀវភៅតិហិប្បដិបត្តិ នៃលន្ធប់រៀងមក ។ ២ ជាលីនេះរៀបរៀងថ្មី លោកអ្នកបើគាប់ចិត្តបែបណា តាមស្ម័គ្រចិត្ត ។

ហេតុនេះ ដូចនេះ អត្ថន្តរតុ ដូចមែន កប៊ិនទានបត្តិយោ សមិជ្ឈន្តុ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ, តតិយម្បិ ។

ប្រែថា "បពិត្រព្រះសង្ឃដ៏ចំរើន! យើងខ្ញុំទាំងឡាយសូមវេរចង្ហាយនូវសំពត់នេះ ជាកប៊ិនចីវរ ចំពោះព្រះសង្ឃ, បពិត្រព្រះសង្ឃដ៏ចំរើន! សូមព្រះសង្ឃទទួលយកនូវសំពត់ជាកប៊ិនចីវរនេះ; លុះទទួលរួចហើយ សូមនិមន្តក្រាលគ្រងដោយសំពត់កប៊ិនចីវរនេះ; សូមចំណែកបុណ្យនៃកប៊ិនទានទាំងអម្បាលនេះសម្រេច ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។ អស់ពីរៈពីរដងផង, អស់ពីរៈបីដងផង' ។

ចាលីវេរៀងបរិក្ខារជាបរិវារកប៊ិន

យេនម្ហាកំ[1] កប៊ិនំ គហិតំ កប៊ិនាធិសង្ឃាធិ តស្សេ ទេមេ ។ ទុតិយម្បិ, តតិយម្បិ ។

ប្រែថា "បពិត្រព្រះគម្ពីនសង្ឃដ៏ចំរើនអើយ! រីកប៊ិននៃយើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អគ្គណា បានទទួលកាន់យកហើយ យើងខ្ញុំ

---

๑ ចាលីនេះដកស្រង់ពីសៀវភៅគីហិប្បដិបត្តិ ដែលធ្លាប់ដំរៀងមក ។

ទាំងឡាយ សូមវេរទូវគ្រឿងបរិក្ខារជាបរិវារនៃកឋិនទាំងឡាយ ប្រគេនដល់លោកម្ចាស់អង្គនោះ ។ អស់វារៈពីរដងផង. អស់វារៈបីដងផង" ។

ក្នុងអដ្ឋកថាពន្យល់ថា: បើតាមកវេវថា យេនម្ហាកំ ។ល។ តស្សេវ ទេមិ ដូច្នេះ, ព្រះសង្ឃមិនជាឥស្សរៈធំលើគ្រឿងបរិក្ខារជាបរិវារកឋិននោះទេ, បើតាមកចន៍ឲ្យព្រះសង្ឃជាឥស្សរៈធំលើគ្រឿងបរិក្ខារទាំងនោះ ហើយនឹងចន៍ចានផលានិសង្សច្រើន ត្រូវវេរដោយចាលីផ្សេងវិញ; ក្នុងទីនេះនឹងរៀបរៀងចាលីវេរគ្រឿងបរិក្ខារជាបរិវារបស់កឋិនដល់ព្រះសង្ឃ ទុកជាបែបថា:

មយំ[1] ភន្តេ តិមេ កឋិនបរិក្ខារេ សង្ឃស្ស ទិយ្យាទេមសាធុ ភន្តេ សង្ឃោ តិមេ កឋិនបរិក្ខារេ បដិគ្គណ្ហាតុ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ. តតិយម្បិ ។

ប្រែថា: បពិត្រព្រះសង្ឃដ៏ចំរើន! យើងខ្ញុំទាំងឡាយសូមវេរថ្វាយទូវគ្រឿងបរិក្ខារជាបរិវារកឋិនទាំងឡាយនេះដល់ព្រះសង្ឃ, បពិត្រព្រះសង្ឃដ៏ចំរើន! សូមព្រះសង្ឃទទួលយកទូវគ្រឿងបរិក្ខារជាបរិវារកឋិនទាំងឡាយនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តី

---

๑ ចាលីនេះតែងថ្មីសម្រាប់វេរគ្រឿងបរិក្ខារជាបរិវារកឋិនដល់ព្រះសង្ឃ ។

សុខ ដល់លោកអ្នកដ៏មានគុណចំនួនប្លាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំចំនួនប្លាយផង អស់កាលជាអង្វែង ๗ហោង ។ អស់ក៖ពីរដងផង, អស់ក៖បីដងផង" ។

បាលីវេរ្ជាក្រាក់

មយំ ភន្តេ សទ្ធាបសន្នា ឥធ អារាមេ (សេនាសន-(๑) ករណត្ថាយ) ឥមានិ ហិរញ្ញបុប្ផានិ សង្ឃស្ស បរិវេមុ ។

សាធុ ភន្តេ សង្ឃោ វិនយានុរូបំ កប្បិយការកស្ស ហត្ថេ បឋិគ្គាហិ ឥមានិ ហិរញ្ញបុប្ផានិ បដិជានាតុ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ, តតិយម្បិ ។

ប្រែថា: "បពិត្រព្រះសង្ឃដ៏ចំរើន! យើងខ្ញុំចំនួនប្លាយមានសទ្ធាជ្រះថ្លា បានលះបង់នូវផ្កាគឺហិរញ្ញវត្ថុចំនួនប្លាយនេះ សូមបវារណាដល់ព្រះសង្ឃ (ដើម្បីកសាងសេនាសនៈ) ក្នុងវត្តនេះ ។ បពិត្រព្រះសង្ឃដ៏ចំរើន! សូមព្រះសង្ឃទទួលដឹងនូវផ្កាគឺហិរញ្ញវត្ថុចំនួនប្លាយនេះដែលយើងខ្ញុំចំនួនប្លាយ បានដំកល់ទុកហើយក្នុងដៃនៃកប្បិយការកៈដ៏

---

๑ បើកសាងវត្ថុអ្វី ត្រូវបញ្ចូលបាលីក្នុងវង់ក្រចកនេះ ។

សមគួរដល់វិន័យ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ត្រង់ប្រការដល់លោកអ្នកដ៏មានគុណតាំងពីក្មេយ មានមាតាបិតាជាដើមធង, ដល់យើងខ្ញុំតាំងពីក្មេយផង អស់កាលជាអង្វែងទៅហោង ។ អស់ពារៈពីរដងផង, អស់ពារៈបីដងផង" ។

កាលបើថាយកវេរអង្គកឋិន ទឹងត្រឹងជាបរិក្ខារជាបរិវារកឋិនរួចហើយ ត្រូវដំនុំសង្ឃថាត់កិក្ខុពីរូប (គឺកិក្ខុដែលត្រូវសូត្រកឋិន) ឲ្យប្រកាសសេចក្តីដល់ដំនុំសង្ឃ ដែលឆ្ងាប់ហៅថា ត្រើនកឋិន ។

កង់ទីនេះ ទឹងរៀបរៀងជាបែបបុកតាមទម្ងាប់ដែលឆ្ងាប់ធ្លើមក ។

ភិក្ខុថាស់ត្រើនថា:

កន្លៃបពិត្រដំនុំសង្ឃដ៏ចំរើន! វែអង្គកឋិនទាននេះជាកឋិនទានរបស់ (...[1]) មានបសាទស្ទ្រាជ្រះថ្លាដើជាក់ក្នុងបវរពុទ្ធសាសនា ចាន បរិច្ចាគធនធានចាត់ចែងធ្លើជាអង្គកឋិនទាននេះ ដង្ហែចូលមកវេរប្រគេនចំពោះព្រះសង្ឃ ដែលគង់ចាំព្រះវស្សាគ្រប់កំណត់ត្រៃមាសក្នុងអាវាសវត្ត (...[2]) នេះ ជាសំពត់ដ៏ស្អាតបរិសុទ្ធផុតចាកមន្ទិល ហាក់ដូចជាសំពត់ទិព្វកោសេយ្យពំស្ត្រ អណ្តែតត្រសែតឡាក់ពុះអំពីអាកាស មកប្រតិស្ឋានក្នុងកណ្តាលដំនុំសង្ឃនេះ ទឹងចាន:ស្មោះចំពោះកិក្ខុអង្គ៌ណាមួយ

---

๑ ត្រូវបញ្ចូលនាមលោកអ្នកដែលមានសទ្ធាធ្លើកឋិនទាន ។ ๒ ត្រូវបញ្ចូលឈ្មោះវត្តដែលហៃចូលទៅ ។

នោះក៏ដែរ ។ ហេតុនេះ បើភិក្ខុអង្គណាមានត្រៃចីវរខ្វះខូចលាភ ដាច់ដាច ហើយធ្វើវត្ថាសាឥតវិកឥតបិនគ្មានកិច្ចគឺចេះបុព្វកិរណៈ ๗ មាតិកា ๘ បលិពោធ ๒ នឹងអានិសង្ស ๕ ប្រការដោយ ដើម ដោយសព្វគ្រប់ ក៏សូមធ្វើយមក កុំបីអាមអៀមឡើយ ដំនុំសង្ឃនឹងបង្វែប្រគេនឲ្យភិក្ខុអង្គនោះគ្រាលគ្រងក្នុងកាលឥឡូវនេះហោង ។

ភិក្ខុខ្ចីត្រៃនតបទៅវិញថា:

ឥទានេវ៎ ខោ ភន្តេ អតិសុន្ទរំ បកាសីតំ

បពិត្រព្រះករុណាដ៏ចំរើន ! ពាក្យដែលព្រះករុណាម្ចាស់បានប្រកាសមកអម្បាញ់មិញនេះ ពិរោះណាស់ហើយ; រីភិក្ខុសង្ឃ ដែលគង់ចាំវស្សាក្នុងអាវាសនេះ សឹងមានត្រៃចីវរល្មមប្រើប្រាស់គ្រប់គ្រាន់ហើយ មិនខាន់ខ្វះលាភទេ, តែបើតាមយោបល់របស់ខ្ញុំព្រះករុណាយល់ឃើញថា: គួរព្រះសង្ឃបង្វែប្រគេនដល់ព្រះតេជព្រះគុណ (..[1]) ព្រោះលោកប្រកបដោយអង្គសម្បត្តិច្រើនប្រការ គឺ:

๑ លោកជាព្រះថេរៈដ៏ឯកត្តិច្រើន, ជួសហើយអស់កាលយូរជាអធិការនៃសង្ឃ, ជាវិចារកៈរបស់សង្ឃ ។

---

๑ ត្រូវបញ្ចូលតាមភិក្ខុ ដែលក្រាលកឋិន, ពាក្យនេះសម្រាប់ភិក្ខុដែលមានសមត្ថភាព ។

២ លោកជាអ្នកត្រូវទ្រង់នូវធម្មវិន័យ ។

៣ លោកជាអ្នកធ្វើវត្តសក្ខីកបិនគ្មានកិច្ចជាដើម ហើយមានសមត្ថភាពគួរនឹងគ្រាលកបិនបាន, បពិត្រព្រះសង្ឃគ្រប់ព្រះអង្គ ! បើព្រះសង្ឃយល់ព្រមតាមយោបល់របស់ខ្ញុំព្រះករុណា ដែលបានប្រកាសមកហើយនេះ សូមមេត្តាបន្ទន្ទូរសន្ធូសញ្ញាថា "សាធុ" គ្រប់ៗ អង្គ ទៅហោង ។

កាលបើគ្រែនរួចហើយ ដំទុំសង្ឃត្រូវប្រគល់សំពត់កបិនឲ្យទៅភិក្ខុអ្នកគ្រាល ដោយញត្តិទុតិយកម្មវាចា តាមពុទ្ធានុញ្ញាតក្នុងគម្ពីរមហាវគ្គថា:

សុណាតុ មេ ភន្តេ សង្ឃោ, ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ ឥមំ កឋិនទុស្សំ ឥត្ថន្នាមស្ស[1] ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុំ ។ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ, ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ សង្ឃោ ឥមំ កឋិនទុស្សំ ឥត្ថន្នាមស្ស[1] ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ ។ យស្សាយស្មតោ ខមតិ ឥមស្ស កឋិនទុស្សស្ស ឥត្ថន្នាមស្ស[1] ភិក្ខុនោ ទានំ កឋិនំ អត្ថរិតុំ, សោ តុណ្ហស្ស យស្ស ន ខមតិ សោ ភាសេយ្យ ។ ទុតិយំ ឥទំ សង្ឃោ

---

១ បាលីថា "ឥត្ថន្នាមស្ស" នេះត្រូវដាស់ដាក់តាមនាមរបស់ភិក្ខុអ្នកក្រាលឲ្យរាល់បទ ។

กปิณฑุสฺสุ ตีตฺตฺถามสฺส ภิกฺขเว กปิโณ อตฺตภิตุ ฯ ๑มติ สงฺฆสฺส ตสฺส ตุณฺหี ฉวิเมตำ ธารยามิ ฯ

"ปติตฺรพระคัมภีร์สงฆ์ผู้เจริญ! สูมพระสงฆ์สดับคำข้าพเจ้า, สัตว์กปิณนี้ เข้าเฝ้าสงฆ์แล้ว ฯ ถ้า (การนี้) มีกาลควรแก่สงฆ์แล้ว, สงฆ์ควรให้สัตว์กปิณนี้ ชื่อกิกุ (ชื่อนี้) เพื่อประโยชน์กปิณ ฯ นี้เป็นคำขอ ฯ ปติตฺรพระคัมภีร์สงฆ์ผู้เจริญ! สูมพระสงฆ์สดับคำข้าพเจ้า, สัตว์กปิณนี้ เข้าเฝ้าสงฆ์แล้ว ฯ (ต่อไป) สงฆ์ให้สัตว์กปิณนี้ ชื่อกิกุ (ชื่อนี้) เพื่อประโยชน์กปิณ ฯ การที่ให้สัตว์กปิณนี้ชื่อกิกุ (ชื่อนี้) เพื่อประโยชน์กปิณ ควรแก่พระผู้มีอายุผู้ใด พระผู้มีอายุผู้นั้นจงนิ่ง ไม่ควรแก่พระผู้มีอายุผู้ใด พระผู้มีอายุผู้นั้นจงกล่าวขึ้น ฯ สัตว์กปิณนี้ สงฆ์ให้ชื่อกิกุ (ชื่อนี้) แล้ว เพื่อประโยชน์กปิณ ฯ (การนี้) ควรแก่สงฆ์แล้ว เพราะเหตุนั้น จึงเป็นสงฆ์นิ่ง ข้าพเจ้าจำทรงการนี้ด้วยอาการที่สงฆ์นิ่งอย่างนี้" ฯ

ครั้นเมื่อสงฆ์สวดประกาศสัตว์กปิณ ด้วยญัตติทุติยกรรมวาจาดังนี้แล้ว, เมื่อสัตว์กปิณนั้นได้ยินกรรมวาจาจบลงแล้ว สัตว์กปิณนั้นก็ได้เป็นสามเณรแล้ว ฯ สัตว์กปิณนั้นได้ชื่อว่าสามเณร

គប្បីបច្ចុទ្ធរដកស្បង់ចីពរសង្ឃាដីចាស់ចេញ ហើយធ្វើកប្បពិន្ទុ-អធិដ្ឋានស្បង់ចីពរសង្ឃាដីថ្មីឡើង ។

ឯពិធីដកដូច្នេះ

ដកសង្ឃាដីថា: តិមំ សង្ឃាដិំ បច្ចុទ្ធរាមិ "អាត្មាអញដកនូវសង្ឃាដីនេះ" ។

ដកឧត្តរាសង្គ (ចីពរ) ថា: តិមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ "អាត្មាអញដកនូវឧត្តរាសង្គ: (ចីពរ) នេះ" ។

ដកអន្តរវាសក: (ស្បង់) ថា: តិមំ អន្តរវាសកំ បច្ចុទ្ធរាមិ "អាត្មាអញដកនូវស្បង់នេះ" ។

ដកចីពរ-ស្បង់-សង្ឃាដីរួចហើយ ត្រូវធ្វើកប្បពិន្ទុចីវរថ្មីដែលចំរុងគ្រាលកឋិនោះ ត្រង់ជ្រុងខ្ពស់មុមចីវរដោយពណ៌ ៣ យ៉ាងពណ៌ណាមួយដែលមានសំដែងក្នុងសិក្ខាបទស្រាប់ ។

ឯពិធីពិន្ទុកប្បដូច្នេះ

តិមំ ពិន្ទុកប្បំ ករោមិ "អាត្មាអញធ្វើនូវពិន្ទុកប្បនេះ" ។

តពីនេះត្រូវអធិដ្ឋានចីវរថ្មីឡើង, ពិធីអធិដ្ឋាននោះដូច្នេះ

អធិដ្ឋានសង្ឃាដីថា: តិមំ សង្ឃាដិំ អធិដ្ឋាមិ ។ ទុតិយម្បិ,

តតិយម្បិ "អាត្មាអញអធិដ្ឋានខ្ញុំវសង្ឃដីនេះ ។ អស់ពរៈពីរដងផង, អស់ពរៈបីដងផង" ។

អធិដ្ឋានទុតិយគណ្ឋិៈថា: ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ ។ ទុតិយម្បិ, តតិយម្បិ "អាត្មាអញអធិដ្ឋានខ្ញុំវទុតិយគណ្ឋិៈនេះ" . . . ។

អធិដ្ឋានអន្តរវាសកៈថា: ឥមំ អន្តរវាសកំ អធិដ្ឋាមិ ។ ទុតិយម្បិ. តតិយម្បិ "អាត្មាអញអធិដ្ឋានខ្ញុំវអន្តរវាសក នេះ" . . . ។

កាលបើធ្វើអធិដ្ឋានរួចហើយ ត្រូវគ្រាំលកឥនដោយចីវរណាមួយតាមត្រូវការ ហើយគប្បីបញ្ចេញវាចាឲ្យដំទុំសង្ឃបានឮច្បាស់ ។

បើចង់គ្រាលដោយសង្ឃាដីថា: ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ "ខ្ញុំគ្រាលកឋិនដោយសង្ឃាដីនេះ" ។

បើចង់គ្រាលដោយចីវរថា: ឥមិនា ឧត្តរាសង្គេន កឋិនំ អត្ថរាមិ "ខ្ញុំគ្រាលកឋិនដោយឧត្តរាសង្គៈ (ចីវរ) នេះ" ។

បើចង់គ្រាលដោយអន្តរវាសកៈថា: ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ "ខ្ញុំគ្រាលកឋិនៈដោយអន្តរវាសកៈ (សង្ឃាដ៌) នេះ" ។

កាលបើកិច្ចបានគ្រាលកឋិនតាមបែបនេះរួចហើយ ត្រូវចូលទៅដិតសង្ឃឬគណៈឬបុគ្គល គ្រងចីវរស្មាម្ខាងអង្គុយច្រហោង ប្រណម្យអ ឬឡើង ពោលប្រាប់ឲ្យលោកទាំងនោះ អនុមោទនាថា: អត្ថតំ

អាវុសោ[๑] សង្ឃស្ស កឋិនំ, ធម្មិកោ កឋិនត្ថារោ, អនុមោទថ "ម្នាលលោកដ៏មានអាយុ! កឋិនរបស់សង្ឃខ្ញុំគ្រាលរួចហើយ, ការគ្រាលកឋិន (នុ៎ះ) ប្រកបដោយធម៌, សូមលោកចាំដ៏ឲ្លាយអនុមោទនាចុះ" ។

ចំណែកខាងភិក្ខុអកអនុមោទនាវិញ ត្រូវគ្រងចីពរស្មាម្ខាង អង្គុយប្រហោងជើងម្យ៉ាងលើឡើងពោលអនុមោទនាថា: អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ, ធម្មិកោ កឋិនត្ថារោ, អនុមោទាម "បពិត្រលោកម្ចាស់ដ៏ចំរើន កឋិនរបស់សង្ឃ លោកគ្រាលរួចហើយ, ការគ្រាលកឋិន (នុ៎ះ) ប្រកបដោយធម៌ យើងសូមអនុមោទនា" ។

ឬនឹងអនុមោទនាមួយបែបទៀតក៏បាន: អត្ថតំ ភន្តេ[๒] សង្ឃស្ស កឋិនំ, ធម្មិកោ កឋិនត្ថារោ, អនុមោទាម[๓] "បពិត្រ[๔] ព្រះគុណដ៏ចំរើន! កឋិនរបស់សង្ឃ ដែលសង្ឃបានឲ្យហើយដល់លោក។ បានគ្រាលហើយ, កឋិនដែលលោកបានគ្រាលហើយនេះ ជាធម៌សមគួរតាមតុដ្ឋានុញ្ញាត, ខ្ញុំព្រះគុណាចាំដ៏ឲ្លាយ សូមអនុមោទនាតើថាគ្រែកអាតាមន្ទូកឋិន" ។

ចប់វិធីក្រាលគ្រងកឋិន

---

๑ បើភិក្ខុអ្នកក្រាលខ្វីដាងត្រូវថា ភន្តេ ប្រែថា បពិត្រលោកចាំងឲ្លាយដ៏ចំរើន ។ ๒ បើភិក្ខុអ្នកអនុមោទនាថាសំដាង ត្រូវថា អាវុសោ ប្រែថា ម្នាលលោកដ៏មានអាយុ ។ ๓ បើភិក្ខុតែ ๑ រូបអនុមោទនាថា អនុមោទាមិ ប្រែថា ខ្ញុំសូមអនុមោទនា ។ ๔ ប្រែថា នេះគឺប្រែសម្រួលសេចក្តី បើភិក្ខុតាប់ចិត្តយកតាមបែបណាក៏គប្បីយកតាមបែបនោះចុះ ។

ពិធីបុណ្យវិសាខបូជា នៅលង្កាទ្វីប

របស់លោក ទ.ត. ទេវិន្ទ្រ (D.T. Devendra)

ផ្សាយក្នុងទស្សនាវដ្តី "ហ្វ្រង់អាស៊ី" លេខ ៨៤ ខែឧសភា ឆ្នាំ ១៩៥៣

អ្នកស្រីសារីយ៉ាន់ ប្រែមកជាខ្មែរ

បណ្តាបុណ្យកុនពុទ្ធសាសនាគាំងប៉ុន្មាននៅលង្កាទ្វីប បុណ្យវិសាខ-បូជា ជាបុណ្យមួយដ៏មហោឡារកលើសបុណ្យគាំងពួង ដោយហេតុអ្នកកាន់ពុទ្ធសាសនាក្នុងប្រទេសនោះមានចំនួនច្រើន ។

បុណ្យវិសាខបូជានេះ ផ្តុំយកអំពីបុណ្យណូងលនៃពួកសាសនាគ្រិស្ត ព្រោះជាបុណ្យដែលគេធ្វើរំលឹកចំពោះព្រឹត្តិការណ៍ដ៏ប្រសើរ ៣ យ៉ាង ក្នុងព្រះជន្មនៃព្រះសម្មាសម្ពុទ្ធ គឺរំលឹកពេលដែលព្រះពោធិសត្វទ្រង់ប្រសូត, ពេលដែលទ្រង់ឃានគ្រាស់ដឹង ទីពេលដែលទ្រង់ចូលព្រះបរិនិព្វាន ។

បុណ្យដ៏ទឡារកនេះ គេប្រារព្ធធ្វើកងថ្ងៃពេញបូណ៌មីនៃរាងខែឧសភា មិថុនា កាលំដាំ ហើយជាទំនៀមនៃថេរវាទ (ទក្ខិណនិកាយ) ក្នុងប្រទេសលង្កា ដែលជាប្រទេសកាន់កាប់ពុទ្ធសាសនាមុតមាំ តាំងពីយូរអង្វែងណាស់មកហើយ ។ ហេតុនេះ ទើបមានកើតទម្លាប់ផ្សេង ។ នៅវិញ្ញាស្ថានគាំងឡាយ ខាងព្រះពុទ្ធសាសនា ដូចគ្នានឹងពួកពុទ្ធសាសនិកជនជាតិជប៉ុន ដែលនាំគ្នាធ្វើបុណ្យឱបំលើកថ្ងៃកំណើត នៃអ្នកបង្កើតលទ្ធិពុទ្ធសាសនាកុងប្រទេសជប៉ុន កុងរៀងមួយរាល់ ១ ឆ្នាំ ។

ព្រះពុទ្ធសាសនាដែលទ្រង់ប្បត្តិឡើងនៅប្រទេសឥណ្ឌា ចូលមកក្នុងលង្កាទ្វីប ប្រហែល ៣០០ ឆ្នាំ មុនសាសនាគ្រិស្ត ដោយសារព្រះមហាថេរ ព្រះនាម មហិន្ទ ជាព្រះរាជបុត្រនៃព្រះអធិរាជ ព្រះនាម អសោកៈ ។ ចាប់តាំងពីកាលនោះមក លទ្ធិពុទ្ធសាសនា គេទុកជាធំបណ្តាច់ តាំងចេះតែមានកម្លាំងជ្រាបចូលក្នុងពង្សាវតារ ប្រទេសលង្កានោះ ហាក់ដូចជាថ្មាំពិស រហូតទាល់តែដីវគាពនៃបណ្តាជនក្នុងកោះនោះតាំងមូល គ្មាននៅក្រៅមនុវាទអ្វីក្រៅពីពុទ្ធសាសនា ។

ឯបុណ្យរំលឹកដល់ព្រឹត្តិការណ៍នោះ ជាបុណ្យមួយយ៉ាងឯកគ្មានគូប្រៀប ដែលនាំឲ្យជនបរទេសមានបំណងចង់ឃើញជាទីបំផុត ។ បុណ្យវិសាខបូជានេះ ជាបុណ្យរបស់ជនទូទៅពេញតាំងប្រទេស ហើយជាអាការបង្ហាញឲ្យឃើញនូវនិស្ស័យចិត្តថ្លៃថ្នូរនៃអ្នកលង្កាប្រទេស ដែលជឿស៊ប់ផ្ទាល់ខ្លួនម្នាក់ៗ ។ បុណ្យនេះគ្មានមេដូចឆ្លើមទេ ជាបុណ្យដែលគេធ្វើដោយសិរី ហើយមានតំឡាងនឹងសំរស់តើតឡើងអំពីការធ្វើរបស់ពពួកជន ព្រោះឃើញតែសេចក្តីសប្បាយរីករាយចិត្តជ្រះថ្លាដោយពិធីបុណ្យនេះ ។ ក្នុងថ្ងៃបុណ្យ គ្រឿងសប្បាយដោយទឹកស្រវឹងគេហាមជាដាច់ខាត ។ បុណ្យវិសាខបូជា គេធ្វើឡើងដោយការគ្រែកអរចំពោះកំណើតនៃព្រះសម្មាសម្ពុទ្ធ ចំពោះការដែលទ្រង់រកឃើញនូវសព្វញ្ញុតញ្ញាណ និងចំពោះការដែលទ្រង់ប្រកាសផ្សាយនូវព្រះធម៌

វិសេសទេសនាក្រែបាសមនុស្សលោក ។ ថ្ងៃបុណ្យវិសាខបូជា ជា
ពេលមួយដែលស្តេចាំងចេញអំពីគំនិត គឺជាសេចក្តីសប្បាយពិសិដ្ឋ មិន
មែនជាការផ្ចិចផ្តើមឡើងដោយអាការខាងក្រៅណាមួយទេ ។

ពុទ្ធសាសនិកជនជាថេរវាទ នៅកោះលង្កាគ្មាននាយកទេ, ក្រុម
សង្ឃនីមួយៗ មានផ្នែកផ្សេងៗគ្នា លោកសង្ឃមួយរូបៗ ត្រូវនៅក្រោម
អំណាចមេក្រុមរបស់ខ្លួន តាមកំណើតនៃគណៈដែលខ្លួនបានមកកាន់
ផ្នួស ។ ក្រុមអ្នកបួសដែលហៅថា "សាមនេរកាយ" មានអ្នកពប់អាន
ច្រើនជាងគេ ស្ថិតនៅក្រោមបញ្ជាការនៃមេ ២ នាក់ ដែលជាមេកុដិ
ម៉ាលវត្ត (malavatte) ទី១ អស្គិរិយៈ (asgiriya) នៅកន្ទី, មាន
បែកជាវត្តតូចៗ ទៅទៀតនៅកោះខ្លះ ដូចជាកុត្ត (kotte) នៅជិតក្រុង
កូឡុំបូ ។ ក្រុមអ្នកបួសឈ្មោះ "អមរបុរៈ" ទី១ "រាមញ្ញៈ" ក៏ចាត់
ចូលក្នុងចំណោមក្រុមអ្នកបួសធំៗដែរ ។

លោកសង្ឃគ្មានអំណាចតាំងច្បាប់សម្រាប់ពួកឧបាសកឧបាសិកាទេ
ព្រោះលោកសង្ឃក្តីឧបាសកក្តីជាពុទ្ធបរិស័ទ ត្រូវតែធ្វើតាមការបង្ហាត់
បង្រៀនរបស់គ្រូ ។ មេក្រុមនីមួយៗ កាលអនុម័តតាមកិច្ចដំនុំរបស់ខ្លួន,
ដែលបានកំណត់ទុកជាមុនហើយ ក៏បង្គាប់បញ្ជាទៅសមាជិករបស់ខ្លួន
ឯសមាជិកមិនត្រូវធ្វើអ្វីហួសពីនោះទេ ។ ដោយហេតុនេះហើយបានជានៅ
ពេលបុណ្យម្តងៗ គ្មានច្បាប់ថាត្រូវធ្វើយ៉ាងនេះ ឬធ្វើយ៉ាងនោះសោះ ។

បុណ្យវិសាខបូជាដូចយើងបានពោលមកខាងលើនេះ ជាពិធីឯកជន ប៉ុន្តែដោយជនម្នាក់ៗ និយមធ្វើតាមមនោសញ្ចេតនានៃពួកនៃក្រុមរបស់ខ្លួន សង្គមទាំងមូលហាក់ដូចជាធ្វើតាមសេចក្តីបង្គាប់ណាមួយ ។ ហេតុនេះ ចានជាវត្ត ផ្ទះសម្បែង ទីធ្លាវិច្ចល់ទាំងឡាយ មានរបៀបតាក់តែង ហើយពិធីបុណ្យខាងសាសនាមានដំណើរហាក់ដូចជាមានបង្គាប់អំពីអំណាចក្រៅណាមួយ ។

បុណ្យវិសាខបូជានេះ មានលក្ខណៈ ២ យ៉ាង គឺ ភាពពាណិជ្ជកម្ម និងសេចក្តីសប្បាយដោយផ្នែកថ្លៃ ។ លក្ខណៈទាំង ២ យ៉ាងនេះតែងមានជាដរាប ។

ព្រះអាទិត្យក្នុងថ្ងៃបុណ្យវិសាខបូជា រះឡើងដោយមានពន្លឺស្រស់ត្រជាក់ល្អ ហើយហាក់ដូចជាក្តីជាងថ្ងៃសព្វដង ។ ពពួកជនរវល់រវៃគ្រប់ៗគ្នា ម្នាក់ៗសឹងតែទំនុបតែងតាំងលំអផ្ទះរបស់ខ្លួន តាមតែចិត្តស្រឡាញ់ ។ គេច្រើនឃើញតាំងគោមក្រងាស ដែលធ្វើដោយពិចាកហើយយូរឆង ការណ៍នេះបង្ហាញឲ្យឃើញថា ជនម្នាក់ៗគោរពព្រះពុទ្ធដល់ថ្នាក់ណា ។

គោមមានពាងរៀងផ្សេងៗគ្នា គោមខ្លះធំៗមានជ្រុងច្រើន ដែលមានពាងធ្វើអំពីដើមបបុស ឬត្រែង ហើយមានគោមតូចៗជាច្រើនអមចង្កាម់ទឹកឃ្មុំ ហើយមានទាំងរំយោលក្រងាសជាលំអឆង, រំយោល

នោះឮសូរខ្លាកៗ នៅពេលខ្យល់បក់ ។ គោមទាំងនោះហាក់ដូចជាភ្ញាំងគំនូរពណ៌ពិតៗ ។ មានគោមរយៈឯទៀតជាច្រើន មានក៏ងដូចជាធុនមូលព្យួរនៅទឹងវៃលួស ដែលគេចងសន្ធឹងនឹងបង្គោលដែក ។ មានទង់ជាតិធ្វើអំពីក្រដាសស្តើងៗ អំពីក្រដាសនឹងបជា ចងនៅទឹងវៃលួសនោះឆ្ងាសគ្នា ដោយគ្មានរបៀបរៀបរយទេ ប៉ុន្តែគេមើលទៅគ្មានខាស់ភ្នែក ។ នៅទីផ្សារមានក្រងស្មឹកជូនចងជារង្វង់កោងៗ ហើយមានបង្គីតទង់ពុទ្ធសាសនាយ៉ាងខ្ពស់ជាងគេ ទុង់នោះមានពណ៌ ៦ ជាពណ៌ដែលពុទ្ធបរិស័ទដឿថា រស្មីដែលចាំងចេញអំពីអង្គនៃព្រះសម្មាសម្ពុទ្ធ ។

ជួនកាលនៅគ្មានចូលអាគារធំៗ នៅគ្មានវត្តឬនៅមុខផ្ទះដំនួញ គេមានធ្វើតូប ១ សំរាប់ចែកគ្រឿងផឹក ។ ជួនកាលគេធ្វើជាដំបូលទឹងដើមស្វា ឬដើមឫស្សីកោងខ្ពស់លយគ្របទៅលើផ្លូវ មានចងផ្កែដូងជាំងជ្រាយ។ នៅចន្លោះឫស្សី ។ សណ្ឋានស៊ុមបែបនេះ ជាតំណាងក្លោងទ្វារនៅ "សានជិ" ក្នុងប្រទេសឥណ្ឌៀ ។

ផ្ទះលក់ទំនិញតាន់តាប់នៅដោយមនុស្ស ចូលទិញអីវ៉ាន់បង្ហើយ : ក្រដាស - អង្កាំកែវ ទង់ជាតិ - គោម - មុខក្រមាច់ផ្សង។ - មួកក្រដាសសំរាប់ក្មេងពាក់ដើរលេងសប្បាយពេញតែផ្លូវឮថ្ងល់ - ខ្ទៀន - ធូប ហើយទឹងសម្ភារៈជាច្រើនទៀត សំរាប់ការសប្បាយដល់ពួកចាស់ៗផង ។

នៅគេហស្ថានមួយ។ មានសុទ្ធតែរបស់សម្រាប់តុបតែងក្នុងបុណ្យ
វិសាខបូជា ដែលនាំឲ្យគេអត់ងងុយអស់ពេលជាច្រើន ក្នុងប៉ុន្មានថ្ងៃមុន
ពេលបុណ្យ ដើម្បីនឹងរៀបចំឲ្យល្អ ។ ដោយមានការច្រើនពេក គេ
ស្មានថានឹងមិនបានរៀបហើយ ទាន់ពេលបុណ្យនោះទេ ។ ប៉ុន្តែគួរ
ឲ្យជ្រះថ្លាពេកណាស់ នៅពេលព្រះអាទិត្យរះឡើង គេឃើញផ្ទះបោស
ច្រាស់ហើយយ៉ាងស្អាត ហើយក្នុងសួនច្បារមានផ្ការីកដុះយ ដើម្បីការ
រចនាខាងក្រៅ ។ ទោះពាណិសជាពាណិបវិសុទ្ធសម្រាប់ថ្ងៃសីលក៏
ដោយ គង់តែមានពួកយុវជនមីរដេរជាស ដែលស្លៀកពាក់ទោអាវ
ពណ៌ស្រស់ៗ (ក្រៅពីពណ៌ស) តាមតែចិត្តស្រឡាញ់រឿងៗខ្លួន
ដោយសេចក្តីសប្បាយ ។

ដួនកាលនៅថ្ងៃដំបូង ជនខ្លះធ្វើតយកឧកាសយ៉ាងខ្វៃដើម្បីទៅវត្ត
ជនខ្លះទៀតប្រជុំគ្រួសារខ្លួននៅផ្ទះ ធ្វើការកិច្ចចំពោះព្រះបដិមាការ
ហើយនាំគ្នាសូត្រសរណាគមន៍ ៣ និងស្មាធានសីល ៥ ។

នៅវេលាព្រលឹម ពេលស្រស់ស្រូបរួច ពួកជនដែលគ្មានការ
វល់នៅផ្ទះ តែងចូលទៅកាន់ទីវត្ត ។ ទីវត្តជាកន្លែងប្រជុំអ្នកធម៌អាថ,
គេឃើញមានជនប្រុសស្រីកុះករ, បុរសចាស់ៗ និងពួកយុវជនស្លៀក
ពាក់សំពត់អាវសឹងតែមានពណ៌សសុទ្ធ ថែមទាំងកានាក្រមាយ៉ាងធំមួយ។
ម្នាក់ផង ពួកជនទាំងនោះហើយដែលបានសមាទានសីល ៨ តាំងពី

ត្រលឹមដងឹត ហើយត្រូវកាន់សីលនោះជាប់ក្នុងមួយថ្ងៃ ឬក៏ក្នុងរវាង ៦០ មោង ។ ក្នុងពេលនោះ ត្រូវអត់អាហារល្ងាច មិនត្រូវកៅអីនឹងដែលជារបស់ស្រួលកាយ មិនត្រូវសប្បាយដោយល្បែងច្រៀងរាំទេ ។ សីល ៨ នេះហើយដែលគេតែងសមាទានក្នុងថ្ងៃតេញបូណ៌មី ឬថ្ងៃបុណ្យធំៗ ។ ការសមាទានសីលក្នុងទុកាសបុណ្យបែបនេះ គេទុកជាត្រូវកាលៈទេសៈល្អណាស់ ។

ក្នុងវត្តនិមួយ ៗ មានទុបាសកទុនឹងទុបាសិកាទៅស្មាក់អាស្រ័យច្រើននាក់ដែលនាំគ្នាតែសមាទានសីល អង្គុយសមាធិ ជជែកគ្នាតែអំពីធម៌នឹងស្តាប់ធម៌ទេសនា ។ ដើម្បីនឹងរៀបចំបុណ្យឲ្យបានអឺកធឺកដូចជាបុណ្យវិសាខបូជានេះ ជនទាំងនោះនាំគ្នាថយទៅកន្លែងមួយ ជួនកាលជនទាំងនោះនាំគ្នាធ្វើដំណើរដោយពួក។ ទៅកាន់ទីពិសិដ្ឋណាមួយ ។

ទោះនៅក្នុងផ្ទះក្តី ទៅក្រៅផ្ទះក្តី សឹងមានសកម្មភាពយ៉ាងខ្លាំង ។ នៅតាមផ្លូវធំៗ ក្នុងទីក្រុង នៅតង់ផ្លូវត្រែឡែងកែង នៅទីប្រជុំជននឹងនៅទីផ្សារ មានធ្វើតូបដាក់ចំណីអាហារនឹងគ្រឿងផឹក ទុកចែកទានដល់ពួកអ្នកដំណើរ ពួកអ្នកដើរលេង នឹងជនផ្សេង។ ទៀតដោយឥតយកថ្លៃថ្នូរ ។ ក្នុងទីនោះ គេតែងចាប់បញ្ចាប់នេះឡាន ឬរនេះឯទៀត បើប្រសិនជាមានអ្នកមានយសសក្តិដឹកក្នុងរថនោះផង គេអញ្ជើញឲ្យចូលទៅពិសាទឹក "ដូងរាជ" ឬគ្រឿងផឹកផ្សេង។ ដែលមិនត្រូវកាន់ផ្ទាល់

ទឹងដៃ ។ អ្នកស្ម័គ្រចិត្តសង់តូប តែងទិញចំណីអាហារដាក់ដើម្បីសំដែង
សេចក្តីរីករាយមួយយ៉ាងប្រសើរជាងគេ ក្នុងបុណ្យវិសាខបូជាពលតែធ្នាំ ។
មានកន្លែងជាច្រើនទៀតដែលគេតុបតែងរចនាយ៉ាងល្អ។, នៅទីនោះក្នុង
ពេលយប់មានបទភ្លេងសាសនាយ៉ាងធំ សម្រាប់អ្នកត្រូវការស្តាប់បាន
តាមចិត្ត ។

ជារឿយ។ នៅលើវេទិកាគ្មានដំបូល ដែលគេធ្វើក្លាប់អំពីកន្លែង
ល្អ។នេះ មានលោកសង្ឃប្រែកបដោយបញ្ញា ទេសនាប្រដៅពពួកជន ។
មនុស្សដែលដើរសម្រាញ់ពេញផ្លូវថ្នល់ ពុំមែនមានការទៅឯណា
ទេ គឺសុទ្ធតែដើរលេងលំហើយខ្លួន លំហើយគំនិតស្មារតី ។ ដូនកាល
មានពួកពុទ្ធសាសនិកជនដើរដួរជាច្រើនវែង តម្រង់ទៅកាន់ក្រុងចាស់ដែល
ប្រាត់បង់អស់ទៅហើយ។ មាននៅសល់តែ.ឆ្នាសាច់បែក ជាស្នាព្រះហស្តស្តេចបុរាណ ដែលមានព្រះពរជ័យជាបុណ្យប្រាសាទុក
ជាអនុស្សាវរីយ៍ ។ រទេះគោ រថយន្តអូតូកា រថភ្លើង ដឹកនាំមនុស្ស
ណែន។ បរតម្រង់ទៅកូឡំបូ ឬបរចេញពីទីក្រុងហើយបែកចេញទៅតាម
ផ្លូវផ្សេង។ ហាក់ដូចជាទឹកហូរយ៉ាងលឿន ។ សេចក្តីខ្ជឿយព្រួយ
ដោយការងារ ប្រាសចេញផុតអំពីទឹកមុខនៃជនទាំងឡាយ ទុកកន្លែង
ឲ្យសេចក្តីសប្បាយចូលទៅ ធ្វើឲ្យទឹកមុខស្រស់បស់ថ្លៃ ។

លុះពត្រីចុះគ្រប់ដណ្តប់ផែនដីវេលាណា ស្រុកទាំងមូលក៏ផ្ទាស់
ភេទភ្លាម គឺកន្លែងទាំងប៉ុន្មាន ស្រាប់តែមានពន្លឺភ្លឺទាំងមុខទាំងសែនគ្រប់

ពណ៌ចាំងចេញអំពីគោមហាក់ដូចជាគេដុប ។ នៅកូនឡំបូគេលក់ទំនិញ
រស់ណាស់, នៅផ្លូវត្រែឡើងកែងធំៗ ដែលឆ្ពោះទៅ "មណ្ឌល" ក្តី
ចំញាច, មនុស្សមកឈរផ្តុំគ្នាកកកុញរកតែជ្រៃតដើងពុំរួច ។ នៅទី
"មណ្ឌល" គេចេះតុបតែងពន្ធឹក្តើងអគ្គិសនីឲ្យចាំងទៅលើផែនគំនូរប្រវត្តិ
នៃព្រះសម្មាសម្ពុទ្ធ ធ្វើឲ្យអណ្តែត ។ មណ្ឌលនេះហើយដែលជាទី
ចាប់ចិត្តធំរបស់ជនានាមកតាំងពីស្រុកឆ្ងាយៗ ។ រូបពុទ្ធប្រវត្តិទាំងនេះ
មានជំទៃចំពោះពួកអ្នកកាន់ព្រះពុទ្ធសាសនា ដូចគ្នានឹងរូបប្រវត្តិគ្រិស្ត
នៃពួកបច្ចឹមប្រទេស ។ គំនូរនោះគ្មានទាស់ចិត្ត នៃពួកទេសចរដែល
ចូលចិត្តចង់ដឹងចង់ឃើញទេ ។

គោះគេនៅកន្លែងណាក៏ឮសូ ស្គរវត្តដែរ គឺជាសំនួរសួរដែលគេទូន
ថ្វាយក្នុងពិធីបុណ្យ ឬជាសញ្ញាចាប់ពេលទេសនា ។ បន្ទាប់មកគេ
ឃើញនៅក្បាលស្ពានហែ ១ មានអ្នកពំ អ្នកភ្លេង តមកទៀតមានលោក
សង្ឃគ្រងចីពរពណ៌លឿង អង្គុយធ្វើសក្ការបូជាតាមពិតានសំពត់ស ។
គេឮសូរផ្ទាវផ្ទុះ សូរកណ្តឹងដែលភ្លេងអង្រួនទ្រហឹងអឺងអាប់លាយច្របល់
នឹងសំរែកមនុស្ស ។ មានមនុស្សជ្រើរជំទើតដើងលើឈើតាវពាក់អាវ
ស្រីអឺរុបយ៉ាងថ្លែក ។

នៅពេលយប់ លាន់ឮសុទ្ធតែសកម្មភាពនៃមនុស្ស ។ នៅឯលើ
ផ្ទៃមេឃ ព្រះចន្ទពេញបូណ៌មីរះឡើងពេញវង់ក្រឡង់ ភ្នំសត្រចះត្រចង់
អស្ចារ្យ ធ្វើឲ្យអ្នកនិយមធ្វើបុណ្យនេះមានដួងចិត្តនឹកដល់ពុំក្រើប ។

នៅមានរបៀបតាក់តែងបែកៗ ផ្សេងទៀត ដែលគួរឲ្យចង់មើលណាស់ ។ នៅក្នុងវត្ត គ្រួសារខ្លះនាំកូនចៅចូលទៅ មានដែកាន់ថាសដាក់ផ្កាគ្រអូប ធូប ទៀន កាបូ ជាគ្រឿងសក្ការបូជា ។ អ្នកគោរពសាសនា ដើរប្រទក្សិណព្រះសារីរិកធាតុ៣ដុំ បន្ទាប់មកគេយកផ្កាទៅដាក់បូជាចំពោះព្រះបរមធាតុ ហើយនាំគ្នាសូត្រនូវសេចក្តីថា ៖

"ទុព្រះសម្ពុទ្ធជាម្ចាស់! ខ្ញុំសូមបូជាផ្កានេះ, ដោយសេចក្តីជ្រះថ្លានេះ ខ្ញុំម្ចាស់សូមឲ្យបានសម្រេចនូវបរមសុខ ។ ផ្កានេះ មុខជានឹងស្អិតស្រពោនទៅ យ៉ាងណាមិញ រូបខ្ញុំម្ចាស់ក៏មុខតែនឹងវិនាសទៅវិញ យ៉ាងនោះដែរ ។"

លុះសូត្រសេចក្តីនេះហើយ ក៏លើកដៃទាំងគូរផ្គុំដាក់ត្រង់ថ្ងាសហើយថយទៅលុតជង្គង់ឯរបងវត្ត ទុនក្បាលពាល់តែថ្ងាសប៉ះដីខ្ទាប់យ៉ាងស្អាតនៅទីនោះ ទើបសូត្រធម្មិថ្វាយបង្គំ បង្ហាញនូវសេចក្តីគោរពដល់ព្រះសម្ពុទ្ធ ព្រះធម៌និងព្រះសង្ឃ ។ ក្នុងសេចក្តីដែលសូត្រនោះ អ្នកគោរពសាសនា រំលឹកដល់ព្រះពុទ្ធថាទដែលមានវាងជាផ្កាឈូក. ដល់កន្ទែងស្នាមព្រះបាទ ទង់កន្ទែងផ្សេងៗទៀត ជាតំណែលព្រះពុទ្ធគាលគង់ព្រះដន្ទៅទៀបនៅក្នុងប្រទេសឥណ្ឌា ។ ល ។

សេចក្តីពោលច្រើនតែធ្វើចំពោះព្រះសម្មាសម្ពុទ្ធ ដែលចូលព្រះនិព្វានទៅហើយ មិនមែនចំពោះតេជាទុកាពរបស់ព្រះអង្គនោះទេ ព្រោះ

គេយល់ថាព្រះពុទ្ធគ្រាន់តែបង្ហាញផ្លូវ ព្រះអង្គទ្រង់បរិនិព្វានទៅហើយ ទ្រង់ពុំបានស្គាល់សេចក្តីសុខទុក្ខក្នុងលោកទៀតទេ ។ ទស្សនវិជ្ជាខាងព្រះពុទ្ធសាសនា សង្ខេបសេចក្តីថា: ការរលែកើតរលែស្លាប់នៃសត្វលោក ប្រៀបដូចជាកង់រទេះដែលវិលទៅតាមដើងគោ ។ ការកើតហើយស្លាប់ ស្លាប់ហើយកើតវិញ ត្រូវតែមានការឈប់, ការឈប់នេះហើយដែលហៅថាព្រះនិព្វាន ជាស្ថានបរមសុខជាទីបំផុត ។

បើប្រសិនជាមានព្រះសង្ឃ ១ អង្គគង់នៅកន្លែងដែលគេសូត្រធម៌នោះ គេនិមន្តលោកឲ្យសីល ៥ នឹងសូត្រធម៌ឯទៀត ។ គេមកគេចូលទៅមើលព្រះបដិមាកនុងព្រះវិហារ ដែលមានព្រះពុទ្ធរូបច្រើនអនេក ។ មានរូបព្រះអគ្គសាវ័កស្តាំ-ឆ្វេងរបស់ព្រះអង្គផង គឺព្រះសារីបុត្តនឹងព្រះមោគ្គល្លាន ដែលមានសំបុរលឿងខ្ចីនឹងខៀវក្រមៅ ។ គេទើបពន្យល់បង្ហាញព្រះបរមធាតុដ៏ជាក់ស្តែងនេះ ដល់ប្រទេសឥណ្ឌា ប្រទេសកូមា នឹងប្រទេសកម្ពុជា ។

គំនូរគឺជាស៊ុតគឿនចិត្តឲ្យចំពោះការកុសល នៅលើជញ្ជាំងធំៗ ខ្ពស់ៗ បញ្ចេញឲ្យឃើញសិល្បៈខាងវិជ្ជាសាស្ត្រ ធម្មជាតិ នឹងបុរាណវត្ថុ ដែលមានលក្ខណៈត្រង់ស្មោះក៏ដោយ ក៏គង់ធ្វើឲ្យរំកើបចិត្តមនុស្សណាដែលណាយជាងគេបំផុតដែរ ។ ក្រោយបំផុត គេចូលទៅមើលដើមពោធិព្រឹក្ស ដែលព្រះសិទ្ធត្ថគោតមជាព្រះពុទ្ធបុត្រនៃស្តេចសាក្យៈ

ចានយាងចូលទៅដែកគ្រែតាមមួយចន្លែមការនោ លុះត្រាតែចានសម្រែច
គតិបណ្ឌិត ទើងពោធិញ្ញាណ ទៅជាព្រះពុទ្ធក្នុងលោក ។

បើប្រសិនជាមានថាសខ្លះមានផ្ដាំពុំត្រូវគ្នា នោះពួកសមាគម
ខាងសាសនានាំគ្នាបន្ថែមឲ្យគាល់តែពេញ ព្រោះពួកនេះមានការណ៍ យ-
កិច្ចតែនឹងជួយអ្នកដំណើរនៅថ្ងៃបុណ្យធំ បើអ្នកដំណើរនោះត្រូវការ ។

ក្រោយអំពីការកិច្ចចំពោះបូជនីយស្ថានទាំងនេះ គេនាំគ្នាក្រោក
ឈរឡើង ហើយទូលសុសលជូនដល់ដីដូនដីតាមាតាបិតានឹងញាតិ
ទាំង ៧ សន្ដានដែលចែកឋានទៅកាន់លោកខាងមុខ នឹងទូលដល់
ខ្យល់ ទឹក ដី នឹងអាកែ្សអ្នកគាដែលនៅឥសេពញដែនដី ទោះមានរូបក្ដី
គ្មានរូបក្ដី សូមអញ្ជើញមកទាំងអស់ ដោយចិត្តមេត្តាករុណា គ្មាន
ចំពោះរូប ។ កិច្ចកុសលគឺគុណធម៌នេះកើតឡើងដោយចិត្តសោមនស្ស
ដែរថ្ងៃ ដែលអាចបន្ថែញសង្ខារក្នុងកពទាំង ៣ ឲ្យបានខ្លី ។

នេះជាសេចក្ដីពណ៌នាយ៉ាងសង្ខេប អំពីបុណ្យវិសាខបូជាដែលជា
បុណ្យធំបំផុតក្នុងព្រះពុទ្ធសាសនា នៅលង្កាទ្វីប ។

ព្រះមហាឧត្តមរដ្ឋា ជាសញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីវេន វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌាធុរក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

ដូច្នេះ បើលោក-អ្នកឃើញប្រយោជន៍ខ្លួនយើង ត្រូវឃើញប្រយោជន៍អ្នកជាទៃផង សូម្បីកាលស្រឡាញ់ខ្លួនយើង. ក៏ត្រូវស្រឡាញ់អ្នកជាទៃផងដែរ កុំបណ្តោយឲ្យការឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ចូលមកគ្របសង្កត់ឡើយ ។ បើកាលណា ការឃើញតែប្រយោជន៍ផ្ទាល់ខ្លួនចូលមកគ្របសង្កត់លោក-អ្នកហើយ កាលនោះ ស្មាន់ធឹតត្បប់ទៅជាធ្ងេង ហើយធ្ងេងធឹតត្បប់ទៅជាស្មាន់ ដូចជាស្រមោលកង្កែកញ្ចក់ទុំដូច្នោះ ទើបចាត់ថាជាផ្លូវនៃទុក្ខទោសច្រើនយ៉ាង ។ ដើម្បីនឹងបិទផ្លូវនោះ លោក-អ្នកទើបគួរប្រតិត្តអំពើដែលជាប្រយោជន៍ដល់អ្នកជាទៃផង ។

បើជាមាតាបិតា គួរខ្វល់ខ្វាយធ្វើកិច្ចការៈ ចំពោះបុត្រធីតា ដូចយ៉ាងហាមប្រាមបុត្រធីតាមិនឲ្យធ្វើអំពើអាក្រក់, ដឹកនាំឲ្យតាំងនៅតែក្នុងអំពើល្អ, ចាត់ចែងឲ្យបានទទួលការសិក្សា, ឲ្យតាំងគ្រួសារ, ឲ្យតាំងគេហស្ថានផ្ទះសម្បែងជាគោលចារឹត ។ បើជាបុត្រធីតា គួរតាំងចិត្តចិញ្ចឹមថែទាំទំនុកបំរុងរក្សាលោក, ជួយខ្វល់ខ្វាយកង្វល់កិច្ចការរបស់លោក,

តម្រង់រង្វង្រ្តែកូលឲ្យល្អក្រៃលែងឡើងកុំឲ្យសាបសូន្យ, ប្រព្រឹត្តខ្លួនឲ្យជាមនុស្សល្អ គួរបានទទួលទ្យមតិក នឹងធ្វើបុណ្យទុិសផលបញ្ជូនទៅលោកក្នុងកាលដែលលោកចែកឋានទៅហើយ ។ បើជាអ្នកធំ គួរយកចិត្តទុកដាក់ចំពោះអ្នកដែលពឹងពាក់អាស្រ័យ; ចិញ្ចឹមដប់លៀង, ទំនុកបំរុងឲ្យមានយសសក្តិកេរ្តិ៍ឈ្មោះប្រាកដក្នុងប្រជុំជន ។ បើជាអ្នកតូច ដែលត្រូវពឹងពាក់លោកវិញនោះ ក៏គួរធ្វើកិច្ចការរបស់លោកឲ្យសម្រេចតាមបំណងរបស់លោក, ធ្វើខ្លួនឲ្យលោកជឿទុកចិត្តគួរជាទីពាប់អាន ។ បើជាមិត្តនឹងគ្នា ក៏គួរជួយទ្រំទ្រាយធ្វើកិច្ចធុរៈរបស់គ្នានឹងគ្នាដោយកំឡាំងកាយខ្លះ ដោយកម្លាំងវាចាខ្លះ ដោយចិត្តខ្លះ ដោយកម្លាំងទ្រព្យខ្លះ ដោយកំម្លាំងបរិវារខ្លះ នឹងដោយកំឡាំងសតិបញ្ញាខ្លះ ។

បើលោក-អ្នកធ្វើយ៉ាងនេះបានហើយ នឹងបានឈ្មោះថា ជាអ្នកប្រព្រឹត្តជាប្រយោជន៍ចំពោះគ្នានឹងគ្នា ដែលនាំឲ្យមនុស្សគ្រប់រូប មានសេចក្តីស្រឡាញ់គោរពរាប់អាន នឹងមានសាមគ្គីព្រមព្រៀងគ្នាតទៅបានយូរអង្វែង ។ ចូរចាំទុកថា "អ្នកដែលសុខចិត្តលះប្រយោជន៍ខ្លួនហើយខំព្យាយាមធ្វើប្រយោជន៍ឲ្យដល់អ្នកដទៃនោះ គឺមនុស្សទេវតា, អ្នកដែលបានឃើញថាប្រយោជន៍ខ្លួនមិនខូច ហើយទើបសុខចិត្តធ្វើប្រយោជន៍ដល់អ្នកដទៃនោះ គឺមនុស្សធម្មតា, អ្នកដែលបំផ្លាញប្រយោជន៍អ្នកដទៃដើម្បីប្រយោជន៍ខ្លួននោះ គឺមនុស្សប្រេត, អ្នកដែល

បំផ្លាញប្រយោជន៍ដនដៃ ដោយឥតបានជាប្រយោជន៍អ្វីដល់ខ្លួននោះ គឺមនុស្សតិរច្ឆាន" ។

គ)- ជួយថែរក្សាសេចក្តីល្អរបស់គ្នា .- សេចក្តីល្អទឹងលាភ-យស-សរសើរ-សុខ-សេចក្តីចំរើនវុឌ្ឍរឿង រមែងជាវត្ថុដែលបុគ្គលគ្រប់គ្នាត្រូវការគ្រែលង់ ។ មនុស្សគ្រប់គ្នា តែងព្យាយាមលះបង់កំឡាំងដើម្បីស្វែងរកវត្ថុទាំងនេះក្នុងកាលដែលមិនទាន់បាន លុះបានមកសមដូចបំណងហើយ ក៏គ្រែកអស្រឡាញ់ហួងហែង ចូលចិត្តចង់ឲ្យអ្នកដទៃទឹងសេចក្តីល្អដែលខ្លួនបាន ចូលចិត្តចង់ឲ្យអ្នកដទៃដឹងរឿងរ៉ាវដែលជាប់ទាក់ទងនឹងសេចក្តីល្អដែលខ្លួនបានមកហើយ ទឹងត្រូវការឲ្យអ្នកដទៃជួយថែរក្សាសេចក្តីល្អរបស់ខ្លួន ។ ពិតមែន! មនុស្សយើងរមែងមានគំនិតយ៉ាងនេះដូចគ្នាទាំងអស់ តែអ្នកដែលទឹងយកចិត្តទុកជាក់ចំពោះដំណឹង (សេចក្តីដឹង) របស់អ្នកដទៃយ៉ាងនេះវិញមានតិចណាស់ ព្រោះមនុស្សយើងតែងមានទិស្សយផ្សេងគ្នា ខ្លះមានទិស្សយរីករាយតាមខ្លះមានទិស្សយឫស្យា ។ មានតែមនុស្សដែលមានទិស្សយរីករាយតាមប៉ុណ្ណោះទេ ទើបយកចិត្តទុកជាក់ចំពោះដំណឹងរបស់អ្នកដទៃ ។ ឯមនុស្សដែលមានទិស្សយឫស្យា ឥតបានយកចិត្តទុកជាក់ ចំពោះដំណឹងរបស់អ្នកដទៃឡើយ ។ គឺថាមនុស្សដែលមានទិស្សយរីករាយតាម ចូលចិត្តយកចិត្តទុកជាក់ចង់ដឹងរឿងរបស់អ្នកដែលមានជោគវាសនា

ល្អ ដោយចំណាំនឹងដួយការពារ: ចំណែកមនុស្សដែលមានទិស្សយ
ឫស្យាវិញ ចូលចិត្តតែយកចិត្តទុកដាក់ចង់ដឹងរឿងរ៉ាវរបស់មនុស្សដែល
មានគ្រោះថ្នាក់ ដោយចំណាំនឹងដឹងជាន់សង្កត់សង្កិនថែម មិនចូលចិត្ត
ចង់ដឹងរឿងរ៉ាវរបស់អ្នកដែលមានជោគវាសនាល្អទេ ព្រោះមានចំណាំ
នឹងចិត្តជាំង ។

មនុស្សឫស្យា ច្រើនមានទិស្សយអាក្រក់ ហួងហែងសេចក្តីល្អ
របស់អ្នកដទៃ មិនចង់និយាយអំពីគុណសម្បត្តិរបស់អ្នកដទៃ មិនចូល
ចិត្តប្រព្រឹត្តតាមបែបយ៉ាងនៃគុណគឺសេចក្តីល្អរបស់អ្នកដទៃ ទឹងមិនចង់
ឲ្យអ្នកដទៃបានល្អជាងខ្លួន សូម្បីសេចក្តីល្អនោះ ខ្លួនមិនបានប្ល
មិនមានឱកាសនឹងបានក៏ដោយ ក៏ទំហាមឃាត់ខាំងាំងកាងកស្ងាត់ដំណើរ
មិនឲ្យគេធ្វើសេចក្តីល្អបាន បើដឹងឬឃើញគេបានសេចក្តីសុខ សេចក្តី
ចំរើន មានជោគវាសនា នៅស្ងៀមមិនបាន ក៏ខ្វល់ខ្វាយរកទុច្ចរិត
ឈ្មោះសេចង្កិនបង្ហើចគេ គិតផ្តាច់បង់សេចក្តីសុខសេចក្តីចំរើនរបស់គេ
លុះរកឱកាសនឹងផ្តាច់បង់ពុំបាន ក៏ផ្តើមបង្កកម្ចែខ្ញុសក៏យចង់ពឹរ
ព្យាបាទប្រាថ្នាបំផ្លាញដីវិតគេតទៅ ដោយចំណាំនឹងផ្សំបណ្តុះសេចក្តី
ល្អរបស់អ្នកដទៃជាក់លើសាកសពនៃសេចក្តីលិតល្អង់របស់ខ្លួនឯង ។
កន្លះណ: ដែលខ្លួនវេលាតែគិតបំផ្លេចបំផ្លាញ សេចក្តីល្អរបស់អ្នកដទៃនោះ
ហាន:ដ៏ថ្លៃថ្លាជាងមុន ដ្រៃទៃដែលខ្លួនប្រឹងនឹងបាននោះ ក៏តែឡប់ទៅ

ជាៈថាកថាបចុះមកវិញ អន់ថយចុះទៅតាមលំដាប់ ចូលក្នុងចំនងថា "ចង់ខ្ពស់បានតាប ចង់ចើងចង់លាក វែងបានតំធនទៅ" ឬ ថា "ឲ្យខ្លួនក្តៅខ្លួននោះមកដល់ខ្លួនវិញ" ឬក៏ថា "បាចធូលីចែសខ្យល់" ហេតុនេះបើលោក-អ្នកចង់ជួយថែរក្សាសេចក្តីល្អរបស់ជនដទៃ កាលបើបានដឹងឬបានឃើញអ្នកដទៃ ខ្ទួលលាក-យស-បរិវារ-សរសើរ សុខ ទឹងសេចក្តីចំរើនផ្សេង។ សូម្បីផលនោះមិនបានសម្រេចដល់ខ្លួនផង ឬខ្លួនត្រឡប់ជាវិនាសគឺអន់ថយថោកតាបជាដរាបក៏ដោយ ក៏ត្រូវកុំធ្វើខ្លួនឲ្យជាមនុស្សឈ្នានីសឬស្យាគេឡើយ ចូរមានទិស្សយរីករាយ ព្រមអនុមោទនាគ្រែកអរជាមួយអ្នកដទៃ ទើបត្រូវជួយថែទាំរក្សាការពារ ដើម្បីឲ្យអ្នកដទៃនោះគ្រប់គ្រងផលល្អនោះបានរហូតទៅ ហើយសូម្បីកាលបើឃើញគេបានខុសក្តៅក្រហាយ ព្រោះប្រសព្វគ្រោះថ្នាក់ មានខូចលាភ-យស សរសើរ-សុខជាដើម សូម្បីសេចក្តីខុសក្តៅក្រហាយនោះ ខ្លួនមិនបានខ្ទួលក៏ដោយ ក៏ចូរមានចិត្តអាណិតអាសូរ គិតជួយឲ្យគេផុតខុសនោះបានផង បើអាចនឹងជួយបាន ។

ចូរថែរក្សាឫសគល់នៃសេចក្តីល្អរបស់ខ្លួន ដោយការជួយថែរក្សាសេចក្តីល្អរបស់អ្នកដទៃ, ចូរកុំដីកកប់ខ្លួនឯងដោយនិស្ស័យឫស្យាឡើយ ។

(មានត)

កណ្ឌទី ១៧

ឧកញ៉ាវិបុលរាជសេនា ដួ-កន ប្រៃរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ឆឹងបេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ខ្ញៀពីសួរថា អ្នកឈ្មោះអ្វី ? ។ ខ្ញៀអាន់ឆ្លើយថា "ខ្ញុំបាទ ឈ្មោះខ្ញៀអាន់ជាមនុស្សក្រខ្សត់អនាថា នៅតែ ២ នាក់ឪពុកកូនរៀបរៀងធ្វើចម្ការដាំបន្លែបង្ការនៅទីនេះ" រួចហើយខ្ញៀអាន់ក៏សួរទៅវិញថា អ្នកទាំង ២ អញ្ជើញមកពីស្រុកណាឆ្ងាយនៅណា ? ហេតុម្ដេចក៏ស្ទុះស្ទែងមកដល់ទីនេះតែ ២ នាក់ មិនឃើញមានពួកបក្សដួនមក ។ ខ្ញៀពីក៏ថ្លែងពត៌មានតាំងពីដើមដល់ចុងឲ្យខ្ញៀអាន់ស្ដាប់ហើយថា យើងមកនេះដើម្បីនឹងរកចូលគួ តែឥឡូវដួនពេលក៏យប់ យើងសុំឈប់ស្នាក់ ១ ភ្លឺ ដល់ថ្ងៃស្អែកនឹងលាចេញទៅទៀត ។ ខ្ញៀអាន់ឮស្ដាប់ក៏មានចិត្តត្រេកអរ អញ្ជើញ

ឡៅពីទឹងស៊ុនឈៀនចូលទៅក្នុងផ្ទះ ហើយឡៅអាន់ក៏ចូលទៅក្នុងទី
ដើងគ្រាន រីឯតអានទឹងធ្លើអាហារជូនឡៅពីបរិភោគទឹងរីឯរកវត្ថុអ្វីក៏គ្មាន
សោះ បើទឹងចុះទៅរកឯណាក៏ជូនវេលាយប់ត្រែងមិនទាន់ការ ឡៅ-
អាន់ក៏សម្ងាប់ការិយារបស់ខ្លួននោះ ហើយរះពន្លះយកសាច់ត្រៅនៃការិយា
នោះ ចៀនឆាខ្លះស្ងួះរួចហ៊ាសលើកចេញមកជូនឡៅពីទឹងស៊ុនឈៀន
បរិភោគ ។

ឡៅពីសួរថា នេះសាច់សត្វអ្វី? ។ ឡៅអាន់ឆ្លើយថា សាច់នេះខ្ញុំ
រកបានពីព្រៃកមិញ ។ ឡៅពីសំគាល់ថាពិតក៏នាំស៊ុនឈៀនបរិភោគគាល់
តែឆ្អែត ។ លុះវេលាយប់ឡៅអាន់ក៏យកសេះរបស់ឡៅពីទឹងស៊ុនឈៀន
ទៅចងទុកខាងក្រោយផ្ទះ ហើយរៀបដំណេកឲ្យឡៅពីទឹងស៊ុនឈៀន
ដេកក្នុងផ្ទះ ។ ព្រឹកឡើងឡៅពីលាឡៅអាន់ហើយចុះទៅស្រាយយក
សេះក្រោយផ្ទះ ឧទ្ទូលក្រឡេកទៅឃើញសពការិយាឡៅអាន់ចោលនៅ
ខាងក្រោយផ្ទះ ឡៅពីភ័យស្ទុតចិត្តក៏ពិចិត្យសួរឡៅអាន់ថា នេះសពអ្នក
ឯណាបានជាយកមកចោលនៅទីនេះ? ។ ឡៅអាន់ឆ្លើយថា "សពនេះ
ជាសពការិយារបស់ខ្ញុំ" ហើយនិយាយរៀបរាប់តាមហេតុដំណើរត្រង់ជូនប
ឲ្យឡៅពីស្តាប់ ។ ឡៅពីបានឮដូច្នោះ ក៏គិតអាណិតខ្លោចចិត្តស្រក់ទឹក
នេត្រាយំសោកនៅទីនោះ ហើយនិយាយថា "គុណូបការៈរបស់អ្នក
មាននៅលើខ្លួនខ្ញុំធំរកទីបំផុតគ្មាន បើប្រសិនខ្ញុំមានជីវិតរស់នៅដរាបណា

ខ្ញុំនឹងតបស្នងគុណអ្នកដរាបនោះ" ហើយឡៅតាំងើរដើរសេះលាឡៅអាន់ចេញពីភូមិនោះទៅបម្ងាយផ្លូវ ៣០០ សិន (១២ គ.ម.) ឃើញកងទ័ពលើកមកជាច្រើន ឡៅតាំងក្រែងឡុកមើលឃើញទន់ដ៏យជាសំគាល់ក៏ដឹងថាកងទ័ពចូឡូលើកមក ឡៅពីក៏ធ្លាស្រាលក្នុងចិត្តគិតត្រែកអរ ទើបនាំស៊ុនខៀនគេចពីផ្លូវត្រមង់ទៅជួបនឹងចូឡូហើយឡៅពីដរាបថា "ស្រុកសៀវផាយអន្តរាយនឹងលីបាំ"ទៅហើយ កូនអ៊ូ, តៀវហ៊ុយប្អូនខ្ញុំបានទឹងបុត្រកំសាស្ត្រគ្រប់ក្បាញ្ជូតទាំងឡាយ ក៏បែកបាក់ខ្ចាត់ខ្ចាយទៅអស់មិនដឹងជាស្ងាប់ឬរស់នៅឯណាឡើយ" និយាយហើយក៏យំដំ។ ចូឡូឃើញការណាក៏ឲ្យមានចិត្តអាណិតអានាថខ្លោចផ្សាយំសោកានៅទីនោះ ។ ឡៅពីពណិនារឿង ដែលឡៅអាន់សម្លាប់តំរាយអាវយកសាច់ចំអិនជាអាហារ ឲ្យឡៅពីនឹងស៊ុនខៀនបរិភោគនោះឲ្យចូឡូស្កប់ ។ ចូឡូក៏មានចិត្តគិតសរសើរថា ទឹងរកអ្នកឯណាល្អស្មើគ្មាន ទើបយកមាសឲ្យស៊ុនខៀន ១០០ ដំរឿងនាំទៅឲ្យឡៅអាន់ដែលមានគុណនឹងឡៅពី ហើយចូឡូក៏នាំឡៅពីលើកទ័ពទៅដែនស្រុកចេង៉ាក់ ។

ឯហៅហ៊ូអៀនទឹងហៅហ៊ូខ្ពុនដែលនាំគ្នាតាំទៅនោះ ក៏បានជួបប្រទះនឹងលីយ៉ង,លីតៀន ហើយតាំងបញ្ជុះបញ្ចូលឲ្យប្រមូលសេនាពាហាននៅជាមួយគ្នានឹងលីយ៉ង លុះបានដឹងថាចូឡូលើកទ័ពមកហើយ ក៏នាំគ្នាចេញទៅទទួលចូឡូ ហើយអញ្ជើញឲ្យចូលទៅកងជាន់ខ្ពស់អធិប្បាយពាយរឿងឲ្យ

ចូធូស្តាប់ ។ ចូធូក៏ចូលទៅសួរហៃហ៊ីខុនតំពូនដេកឈឺធ្ងន់ ឃើញអាការមិនអន់ស្រែកក៏ចាត់ឲ្យហានខាំខ្នងហៃហ៊ីខុនចូលទៅក្រែងហ៊ីតោ ហើយចាត់ឲ្យហានយាមល្បាតលាតត្រែវែលស្តាប់ការឲ្យដឹងថា លីចោ"វែលានេះទឹងគិតប្រការម្តេច ។ បំរើសេះក៏ចេញទៅស្តាប់ការវិលមកវិញដំរាបចូធូថា លីចោ"ទឹងតាន់កុង ចុងចា" ទៅបញ្ចុះបញ្ចូលបានពួកចោរដែលតាំងនៅក្នុងថៃសាន់ជាច្រើន ឥឡូវលើកជាកងទ័ព ទៅវាយយកអាណាខែត្រខាងទិសបូពាបានជាច្រើនតំបន់ហើយ ។

ចូធូបានឮដូច្នោះ ក៏ចាត់ប្រើចោយិនលើកពល ៣ ពាន់ទៅវាយស្រុកសៀវផាយ ខ្លួនចូធូក៏នាំទ្បៅតីទឹងគាហានតាំងឡាយ លើកតាមលីចោ"ទៅដល់គយសៀវគួនជាដែនស្រុកខាងទិសបូពា ក៏ជួបប្រទះទឹងស៊ុនគួន, ង៉ីខុន, អ៊ីនឡេ. សៀងហ៊ី ដែលជានាយចោរនៅក្នុងថៃសាន់លើកបក្សពួកប្រហែល ៣ ម៉ឺនមកស្កាត់ពីមុខទ័ពចូធូ ។ ក៏ប្រើទៅជូចេញច្បាំងទឹងពួកចោរ ទៅឆូទឹងពួកចោរតាំង ៤ នាយបានតច្បាំងគ្នាជាពន្ធឹកតាំងពីព្រឹកគាល់ថ្ងៃត្រង់ នាយចោរតាំង ៤ នោះអស់កម្លាំងខ្សោយណាស់ ។ ចូធូក៏លើកទ័ពណូនចូលទៅជួយទៅឆូ សម្លាប់ពួកចោរស្លាប់បែកទ័ពរត់ទៅកាន់កុងដែលនៅចាំគយ ចូធូលើកគាហានបណ្តាយទៅតាំងបន្ទាយជាប់ជិតគ្នាទឹងគយសៀវគួន ។

លីចោ"ដឹងដំណឹងថា "ចូធូលើកទ័ពមកវាយពួកចោរបែក ក៏ធ្ងល់ក្នុងចិត្តគិតក្រែង ចូធូទឹងលើកទ័ពទៅវាយយកស្រុកឈឺដីវ, ក៏លើក

ពេលចូលទៅក្នុងស្រុកវិញ ហើយចាត់ច្រើនាក់ក្នុងឲ្យទៅការពារក្បាស្រុកឈើដីវ រួចប្រមូលសេនាគាហានបានច្រើនច្រូងនឹងលើកទៅវាយគុយសៀវគួនវិញ ។ តាន់តេងដឹងការណ៍ដូច្នោះក៏ទៅជួបនឹងតាន់គុយជាបិតានិយាយថា ពីដើមកិច្ចការទាំងអម្បាលនេះ លីបោ"ផ្តុតធុរៈដាក់ឲ្យយើងគិត តឡប់ចូធ្លូលើកទ័ពមកដិតហើយ ឃើញថាលីបោ"នឹងមានសេចក្តីថ្នាំងការដោយចូធ្លូជាច្រាកដ ព្រោះវេលានេះលីបោ"ច្រូងនឹងលើកទ័ពទៅតច្បាំងនឹងចូធ្លូ បើលីបោ"បែកទ័ពត្រឡប់ចូលមកស្រុកវិញ ត្រូវបិតានឹងបុត្តកបិទទ្វារស្រុកទុកឲ្យមាំ កុំឲ្យលីបោ"ចូលមកបានខ្លួនឡើយ ទើបនឹងទៅជាមួយនឹងលីបោ"ដើម្បីគិតការតទៅ ។ តាន់គុយឆ្លើយថា កូនិយាយដូច្នេះក៏ត្រូវហើយ តែថាដែលលីបោ"នឹងឲ្យទៅរក្សាស្រុកនោះមិនមែនតែយើងម្នាក់ឯងទេ គាហានរបស់លីបោ"ក៏ទៅជាមួយដោយច្រើនឃើញថាយើងនឹងធ្វើការមិនសំរេច ។ តាន់តេងឆ្លើយថា "បិតាកុំតក្តួយ ខ្ញុំបាទនឹងរិះគិតឲ្យលីបោ"បែងគាហានទៅទុកឯស្រុកដទៃ" និយាយហើយក៏លាតាន់គុយជាបិតាទៅជួបនឹងលីបោ" ។

លីបោ"ក្រឡេកឃើញតាន់តេងចូលទៅ ក៏មានចិត្តត្រេកអរសាទរហើយបបួលតាន់តេងថា យើងនឹងលើកទ័ពទៅច្បាំងនឹងចូធ្លូទៅគុយសៀវគួន ។ តាន់តេងជំពប់ថា ដែលលោកនឹងលះចោលស្រុកឈើដីវឥឡូវនេះមិនស្រួលទេ ព្រោះខ្ញុំបាទយល់ឃើញថា ស្រុកនេះជាទីមុខសឹក

ភ្ញាចចូរគួរនឹងលើកទៅមកវាយខ្លួបតីក្រោយ ដោយយើងមិនទាន់ដឹងខ្លួនក៏ បានទៅចូរគួ សុំឲ្យលោកចាត់ចែងស្បៀងអាហារនឹងគ្រប់គ្រួឲ្យបែងវិលក ទៅខុកឯស្រុកហែហ្វីខ្លះ ខុកជាស្រុកឈើដីវែនេះអន្តរាយ យើងនឹងបានអាស្រ័យស្រុកហែហ្វីជាកម្ចាង ។ លីប៉ោមិនបានដឹងថា តាន់តេងនឹងគិតប្រទូសវាយដល់ខ្លួន ក៏បង្គាប់សុងហៀននឹងឲ្យសុកឲ្យឃុំទាំគ្រប់គ្រួនឹងស្បៀងអាហារទៅខុកឯស្រុកហែហ្វីតាមពាក្យតាន់តេង ហើយលីប៉ោនាំតាន់តេងនឹងតាហានលើកទៅគយសៀវគួន ។ លុះទៅដល់កណ្តាលផ្លូវ តាន់តេងនិយាយនឹងលីប៉ោថា យើងនឹងលើកទៅធ្វើសង្គ្រាមនឹងចូរគួនេះ មិនបានដឹងថាកម្ចាងសឹកនឹងច្រើនឬតិចដូចម្តេចសោះឡើយ សុំឲ្យលោកតាំងបន្ទាយនៅតំបន់នេះសិនចុះ ខ្ញុំបានទៅសុំយកអាសាចេញទៅស្តាប់មើលកម្ចាងចូរគួ បើបានដឹងជាច្រើនឬតិចហើយទើបត្រឡប់មកជំរាបលោកវិញ ។ លីប៉ោមិនបានដឹងដល់កំណប់ទៅតាំងនៅទីនោះ ។

តាន់តេងលាលីប៉ោទៅត្រង់គយសៀវគួន ហើយក៏ចូលទៅជួបនឹងតាន់កុងកុងទៅគយនិយាយនឹងតាន់កុងថា លីប៉ោដឹងរឿងថា ចូរគួវាយនាយចោរតាំង ៤ នោះបែកហើយ ក៏លើកទៅមកតាំងក្លាប់គ្នានឹងទៅគយសៀវគួននេះ លីប៉ោឲដឹងណាស់ថា អ្នកធ្វើការធ្វេសប្រហែសឲ្យចាញ់ប្រៀបចូរគួ បានជាលីប៉ោលើកទៅមកនឹងយកទោសអ្នក ។ តាន់កុងធ្វើយថា ចូរគួលើកទៅមកគ្រានេះធំជាពន្លឹក យើងនឹងតស៊ូមិនបានទេ

ត្រូវតែប្រុងប្រៀបរៀបចំមាហានរក្សាស្រុកខុកឲ្យមាំមួន ចូរអ្នកត្រឡប់ទៅដំរាបលីចោ"ចុះ ថាយើងនឹងបង់លស់ទ័ពចូរួនោះ យើញទញ់ចាស់ណាស់ ឲ្យលីចោ"លើកទ័ពត្រឡប់ទៅរក្សាស្រុកឈើជីវ នឹងស្រុកចំណុះឲ្យមាំមួនចុះ ដើម្បីកុំឲ្យមានសេចក្តីអន្តរាយ ។ គាន់តេងបានស្តាប់គាន់កុងថាដូច្នោះ ក៏មិនធ្វើយតបថាអ្វីសោះ គ្រាកឡើងទៅពិនិត្យមើលលើសើនបន្ទាយ យើញកងទ័ពចូរួតាំងជាប់គ្នាដិតរកួរបន្ទាយ លុះពេលយប់គាន់តេងក៏សរសេរសំបុត្រចំចងទៅចុងព្រញ ហើយបាញ់ធ្នូសំដៅទៅកុងកងទ័ពចូរួ សេចក្តីកងសំបុត្រនោះថា "ខ្ញុំបាទគាន់តេងនឹងសុំយកអាសាជាកលសឹកខាងកុង ខ្ញុំបាទនឹងយកក្លៀងអុជឡើងជាសំគាល់ សុំឲ្យមហាទបាជលើកចូលបន្ទាយចុះ ខ្ញុំនឹងជួយធ្វើការឲ្យសម្រេច" ។ លុះវេលាព្រឹកគាន់តេងក៏លាគាន់កុងត្រឡប់ទៅរកលីចោ" ហើយជំរាបថា ខ្ញុំបានយើញចូរួមានកំឡាំងច្រើនណាស់ ទាំងសុំនគួនឹងនាយចារទាំងពួងដែលលោកឲ្យនៅនឹងគាន់កុងនោះ ខ្ញុំបានយើញប្រែចិត្តទៅខាងចូរួហើយ ឥឡូវខ្ញុំបានកំរាប់គាន់កុងឲ្យប្រយ័ត្នរក្សាគយឲ្យមាំទាំ ខំរំលែកលោកលើកទ័ពទៅដល់ គាន់កុងក៏មានបំណងព្រួយបារម្ភខ្លាំងណាស់ សូមលោកលើកទ័ពប្រញាប់ឲ្យដល់ទៅគយសៀវគួនក្នុងវេលាថ្ងៃនេះ នឹងបានជួយគាន់កុងក្នុចមាំងវេលានេះ ។

(អានត)

រឿងអាក្សរថ្មែងរឿងឆ្កែចាំ

លោក រ៉ាយ-ប៉ុក ក្រមការ

ប្រែពីភាសាំងមកជាខ្មែរ

(ត្រមក)

រឿងទី២ថ្មែពីរ

អាក្សរក្រាបទូលព្រះនរបតីថា "សូមទ្រង់ព្រះមេត្តាជ្រាស! នៅក្នុងនគរឈ្មោះវិស្ណុបុរៈ (Vishnapur) មានព្រះមហាក្សត្រិយ៍មួយអង្គទ្រង់ព្រះនាមពិទាយៈ (Bidâgh) សោយរាជសម្បត្តិ។ នៅក្នុងនគរនោះមានព្រាហ្មណ៍ម្នាក់ឈ្មោះនារាយនៈ (Narayan)។ មានមួយថ្ងៃនារាយនៈគិតឃើញថា: "រូបកាយអញចាស់ទ្រុឌទ្រោមហើយ អញមានវិជ្ជាសាស្ត្រអាចចូលក្នុងរូបអ្នកដទៃបាន គួរតែអញចេញចោលរូបកាយចាស់ជរានេះ ចូលទៅស្ថិតនៅក្នុងរូបក្មេងដ៏ទន់ម្នាក់ហើយប្រព្រឹត្តត្រែតត្រអាលក្នុងបញ្ចកាមគុណប្រសើរជាង"។

លុះគិតយ៉ាងនេះ, ព្រាហ្មណ៍នោះក៏ចូលទៅស្ថិតនៅក្នុងរូបក្មេងដ៏ទន់ម្នាក់, យុរូបសើច, ហើយរលែងឡប់មកកាន់គេហដ្ឋានវិញ។

បិតាមាតាបានដឹងថាបុត្រនោះ ប្រព្រឹត្តិអាកប្បកិរិយាយ៉ាងនោះ ក៏ចូលមកវាកបុត្រ ព្រាហ្មណ៍ជាបុត្រនោះពោលថា "ខ្ញុំជាយោគី"។ ដល់បានពោលដូចនេះហើយក៏ចាប់ផ្តើមអានថា:

"អ្នកដែលគេឲ្យនាមថា ព្រះយោគីដោយពិត គឺអ្នកដែលបានរក្សាទុកកង់ហទយវត្ថុ នូវសេចក្តីសង្ឃឹមដែលក្លឹងគារវភាពបានដុតបំផ្លាញអស់ហើយ អ្នកដែលធ្វើឲ្យអារម្មណ៍ស្ងប់ស្ងាត់ចាំងខាងក្នុងខាងក្រៅ ។

"ជីវសត្វក្នុងពិភពលោក ត្រូវចែកចិត្តទៅតាមស្ថានភាពដូចគ្នាចាំងអស់ ។ រូបកាយជីវសត្វគ្មានកម្លាំង. ក្បាលកន្ទើក, ធ្មេញជ្រុះ, ជីវសត្វនោះទៅជាចាស់ជរា, ដើរកាន់ឈើច្រត់, តែចិត្តកំណាញ់មិនបានរលត់ទេ ។

"កាលវេលាចេះតែត្រាច់ទៅតាមលំនាំដូចគ្នា ។ ថ្ងៃរួចយប់, ឆ្នាំតពីខែ, វ័យចាស់មកដល់វ័យក្មេង, ហើយយើងមិនដឹងថាយើងជាអ្វី, អ្នកឯទៀតយើងក៏មិនដឹង ហើយហេតុដូចម្តេចបានយើងខ្វល់សេចក្តីទុក្ខចំពោះអ្នកដទៃ ។

"អ្នកនេះមកដល់, អ្នកនោះដើរតទៅទៀត ។ ដល់អវសាន, ព្រលឹងចាំងអស់ទៅបាត់ អ្វីក៏គ្មានស្ថិតនៅ ។ មានជីវសត្វជាច្រើនមានសភាពផ្សេងៗគ្នា, មានច្បាស់, មានតណ្ហាផ្សេងៗគ្នា ហើយព្រះព្រហ្មបានស្ថាបនាចាប់មានរូបលក្ខណៈជាច្រើនបែប ច្រើនយ៉ាង; តែពួកបណ្ឌិតដែលផុតចាកចាវអកុសល ដែលបានសម្ងាប់នូវតណ្ហានឹងចិត្តកំណាញ់ បានគោរក្បាល កាន់ដំបងហើយនឹងសូមទានគេបរិភោគ បានសម្ងាប់ចំពោះខ្លួននូវសេចក្តីស្នេហានឹងទោមនស្សចិត្ត ទៅជាពួក

យោគី តែតាច់ទៅដោយឯកតៈដ៏ឥតទេ តាមឫជនីយដ្ឋានមួយទៅកាន់ឫជនីយដ្ឋានមួយ, ជានៈទៅដល់ស្ថានដ៏ឥតវាកឫបអកុសល ព្រមទាំងអមតបុរីគឺព្រះនិព្វាន ។

"ពិតពលោកនេះ ជាយល់សប្តិ ។ តើពិតពលោកនេះឲ្យសប្បាយ, ឲ្យទុក្ខយ៉ាងណាខ្លះ ពិតពលោកនេះគ្មានតម្លៃអ្វីសោះឡើយ ដូចជាស្នឹកចេកក្រៀម, ហើយអ្នកណាដែលមានចិត្តជាប់ចំពាក់នឹងកោគទ្រព្យ, នឹងវ័យក្មេង នឹងវិទ្យាសាស្ត្រ ទុកជាពួកលូនំ. ។ ពួកយោគីកាន់អំបែងសូមទានគេបរិភោគ, ចំញឹមរូបកាយទឹកដោះគោ, នឹងគោមេទម័យ (beurre) ហើយនឹងស្ករ, ធ្វើខ្លួនឲ្យស្រស់ តែត្រេកត្រអាលនឹងស្ត្រី ឈ្មោះថាបំផ្លាញនូវផលនៃការប្រព្រឹត្តិល្អរបស់ខ្លួន" ។

ដល់ឫជានអានដូចនេះហើយ, នាយនៈប្រកាសខ្លួនថានឹងទៅកាន់ឫជនីយដ្ឋានមួយ ។ ពួកគ្រួសាររបស់លោកមានចិត្តសប្បាយពន់ពេកដោយបានឮសំឡេងដ៏វិសេសនេះ ។

អាកាស្យកាលពណ៌នារឿងនេះទូលព្រះមហាក្សត្រិយ៍សព្វគ្រប់ហើយទូលសួរថា តព្រះមហាក្សត្រិយ៍! ហេតុម្តេចក៏ព្រាហ្មណ៍នោះយំ? ហើយហេតុម្តេចក៏ព្រាហ្មណ៍នោះសើចវិញ?" ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលថា: "ព្រាហ្មណ៍នោះយំដោយគិតទៅដល់សេចក្តីស្នេហាមាតារបស់គាត់ កាលគាត់នៅវ័យក្មេង

នឹងគិតដល់សេចក្តីសប្បាយ កាលគាត់នៅវ័យដំទន់ ហើយនឹងគិតដល់ពេលវេលាដែលរូបកាយនេះធ្វើឲ្យគាត់សប្បាយសព្វគ្រប់ប្រការ; តែព្រាហ្មណ៍នោះបានជាសើចវិញ ដោយបានដឹងថាវិជ្ជារបស់គាត់បានឲ្យផលផ្លែផ្កា, ហើយគាត់មានរូបកាយថ្មីទៀត" ។

អាក្ស្យលុះបានស្តាប់នូវព្រះបន្ទូលព្រះមហាក្ស្យត្រិយ៍ហើយ ក៏វិលត្រឡប់ទៅកាន់រុក្ខជាតិនោះវិញ ។ ព្រះនរបតីទ្រង់បានចងអាក្ស្យនោះជាក់លើព្រះអង្សាហើយនាំយកទៅ ។

ចប់ រឿងទី ២២ នៅមានរឿងទី ២៣ តទៅទៀត

ទាសភាពបៅកបំផ្លិត
ដួងប្តេះ ប្តូរទំរើខ្លួនទ្បើងបាកទាសភាព
ដួបជាជីវិជាប់ភក់ហើយរើខ្លួនទ្បើងបាន ។

ខ្ញុំ. ធ.

រឿងចំក្លៀងចំក្យ

អ្នកស្រីសារីយ៉ាង់ ប្រែពីបារាំងមកជាខ្មែរ

(តមក)

នៅថ្ងៃសុក្រមួយ ព្រះអង្គម្ចាស់អាលីខ្លែងយាងចេញពីវិមារ
មកវិញ ខ្លែងយាងសន្សឹមៗ ទាល់តែដល់ទៅសួនស្តេច ហើយខ្លែង
យាងចូលទៅក្នុងសួននោះ ស្រាប់តែឃើញសុទ្ធតែក្បាលមនុស្សព្យួរ
នៅចុងឈើ; លុះឃើញបុរសម្នាក់ដើរមកជិត. ខ្លែងមានបន្ទូលសួរថា
"អ្វីដូច្នេះ" ។ បុរសនោះតបថា: "ទូលព្រះបង្គំពុំបានដឹងទេ" ។ ប៉ុន្តែ
បុរសនោះមានចិត្តអាម្មណ៍ដួសខ្លែងក៏ពោលថែមទៀតថា: 'ម្ចាស់អើយ!
ព្រះពជបុត្រីស្តេច ខ្លែងបានសច្ចាធិដ្ឋានថា ទឹងរៀបមង្គលការជាមួយនឹង
បុរសណាដែលលេងប្រណាំងសេះឈ្នះព្រះនាង ។ បានប្រណាំងឈ្នះ
បុរសដែលមានបំណងចង់បានព្រះនាងធ្វើជាឯកអគ្គទេតើ ហើយព្រះនាង
កាត់កបុរសចាញ់នោះយកទៅព្យួរនៅដើមឈើ ដូចខ្លែងគតឃើញស្រាប់
រឿងវាមានយ៉ាងនេះ ទូលព្រះបង្គំសូមថ្វាយបង្គំហើយ" ។

ព្រះពជកុមារខ្លែងយាងចេញពីសួនឈើ ដោយមានព្រះទ័យខ្វល់
ចំមែង ហើយខ្លែងគិតថា: "យ៉ាងណាក៏ដោយ អញត្រូវតែមើល
ក្បត្តិនោះឲ្យឃើញ" រួចខ្លែងចេះតែយាងទៅ។ សួរកាំងស្តេចទាល់តែ
ឃើញ កាលណោះខ្លែងហូតចិញ្ចៀនពីម្រាមព្រះហស្តព្រះអង្គ ដាក់ទៅ

ក្នុងព្រះទីស្ថានហើយ ទ្រង់យាងចូលទៅក្នុងដំណាក់ ។ ទ្រង់ទតឃើញព្រះមហាក្សត្រគង់ ទើបទ្រង់វែកកាំជន្លនពីក្រោយព្រះពាជាចូលទៅទៀត ទ្រង់ឃើញព្រះនាងគង់ ល្អដូចព្រះចន្ទពេញបូណ៌មី ទ្រង់យាងចេញជាប្រញាប់មកវិញដោយមានព្រះទ័យកួចស្រឡាញ់ព្រះនាងផង ហើយក៏ស្តេចឆ្ពោះទៅកាន់ផ្ទះម្ហូយចិញ្ចឹមរបស់ទ្រង់ ទ្រង់គង់សំងំគាល់តែយប់ ទើបទ្រង់ហៅម៉ែមួនមកប្រាប់ថា: "អញត្រូវការទាសា ១០ នាក់ ស្លៀកពាក់សំពត់អាវយ៉ាងវិសេស ទឹងសេះ ១ យ៉ាងត្រកាលដើម្បីទឹងទៅដណ្តឹងព្រះពជបញ្ជាដោយគោរព" ។ - សូមទ្រង់ព្រះមេត្តាប្រោសបានហើយនៅពីរាល ឯណោះ ។ អាលីប្រាប់ថា "យកអញទៅ" ។ ម៉ែមួនក៏ពត្រង់ហោះសំដៅទៅទីប្រជុំ ។ ទ្រង់សូត្រធម៌បើកដៅគ ទ្រង់ព្រះពស្តេស្រេចស្តេចឡើងគង់លើសេះចា មានម៉ែមួននៅអមខាងស្តាំទ្រង់ ។ ឆេម-អ៊ូននៅអមខាងឆ្វេង ហើយទឹងពួកទាសា ១០ នាក់ដើរពីមុខ ។ ក្បួនហែទ្រង់កាត់ទីក្រុង ។ លុះទ្រង់យាងចូលដល់ក្នុងព្រះបរមពជវាំង, ពួកកងទាហានទាំងអស់ឲ្យពរទ្រង់ ហើយទូលទ្រង់ថា: "ម្ចាស់អើយ នៅទីនេះមានគ្រោះថ្នាក់ដល់ស្តាប់" ។ អាលីទ្រង់ព្រះសណ្តាប់ដោយពុំមានវាចាអ្វីសោះ ទ្រង់ចេះតែយាងរហូតដល់ជណ្តើរនៃព្រះដំណាក់ ។ ព្រះមហាក្សត្រកាលឃើញព្រះអង្គម្ចាស់អាលីយាងមកដល់ ក៏ស្តុះចេញមកគាំទ្រឲ្យពរឲ្យទ្រង់មានជីវិត រួចទ្រង់តង់ជិតព្រះអង្គ ហើយត្រាស់សួរថា: "តើកូនមានការអ្វី ដែលចូលមកនេះ? ។

- ទូលព្រះបង្គំជាខ្ញុំ សូមដណ្តឹងព្រះពជបុត្តីនៃព្រះមហាក្សត្រ ។

- កូនស្រីរបស់ឯងតែងជាក់កម្រិត ។ - កំរិតនោះយ៉ាងណា ទៅ
ក្រាបទូល? ។

- ឯងធ្លាប់មានគំនិតជាមួយបុរសណា ដែលលេងប្រណាំងសេះ
ឈ្នះ, វាបានសម្លាប់មនុស្សជាច្រើនរូបមកហើយ តើកូនឯងមានសុខចិត្តធ្វើ
ដូច្នេះឬទេ? ។ - ក្រាបទូលសុខចិត្ត ។

ព្រះមហាក្សត្រនាំរឿងនេះទៅថ្លែងព្រះពជបុត្តី។ មានបន្ទូលសួរ
ថា: "តើព្រះបិតាបានជាក់កម្រិតតាមរូបម្ចាស់ឬទេ?" ។ - ជាក់
ហើយ ។ លុះព្រះពជបុត្តីទទួលព្រមហើយ ព្រះមហាក្សត្រយាង
ចេញមកថ្លែង ស្តេចអាលី-គ្នេលេប៉ី តាមដំណើរវិញ ហើយថ្លែង
ទ្រង់ថា បីថ្ងៃទៀតនឹងត្រូវទៅដួបគ្នានៅទីប្រណាំងសេះ ។

ព្រះអគ្គម្ចាស់ អាលី ទទួលតាមព្រះពជនុង្ការហើយ ត្រឡប់
ចេញពីវាំងមក ទ្រង់ចំណាយទ្រព្យសម្បត្តិ ទ្រង់ចែកទានឲ្យពួកភ-
ហានៗ ថ្វាយពរជ័យសើរដល់ទ្រង់ ។ លុះដល់ថ្ងៃជាគំរបបី ទ្រង់យាង
ជាមួយអាវ៉ក្ស ៧០,០០០ នាក់ ព្រះមហាក្សត្រស្តេចយាងមកជាមួយ
នឹងពួកសេនាភហាន ។ គណៈបក្សទាំងពីរដង្រៀបទ័ពតែពល់ខ្លួន
ហើយព្រះពជបុត្តីទ្រង់ចាញ់ព្រួញមួយក្តាម ។ ម៉ែមួនវាយកាត់
ហើយធ្វើឲ្យហើរទៅលើអាកាស ។ ព្រះនាងចាញ់មួយមកទៀត,

ឆេម-អ៊ិន ទះម្ខាក់ចោលទៅដី ។ ព្រះនាងចេះតែជាញាក់ទាល់តែអស់ព្រួញ ក្រោយបង្អស់ព្រះនាងយកលំពែងចោលតម្រង់ព្រះអង្គម្ចាស់អាលី។ ចាប់លំពែងនោះចោលទៅវិញ លុះដល់លំពែងនោះធ្លាក់ ហៀបនឹងត្រូវព្រះនាង, ម៉ែមូនចាននាងដួលដេកទៅដី ។ ព្រះនាងទំសុះក្រោកឡើងក្រទីក្រថា រត់ឡើងលើសេះ ទ្រង់ព្រះខន្ធែបណ្តើររត់ចូលទៅដិតពួកកងទាហានហើយមានព្រះបន្ទូលថា: "ចូរអ្នកពាល់គ្នាសម្ងាប់អាចោរកំណាច អារយកសាច់វាមកឲ្យអញ។ ទឹងថ្ងឹងមាសខ្មន់ស្មើគ្នាឲ្យជារង្វាន់" ។ នៅក្នុងពេលប្រយុទ្ធនោះ ព្រះមហាក្សត្រទ្រង់ឃើញថាប់នៅទីនោះដែរ ពួកកងទាហាននៃព្រះមហាក្សត្រព្រួតគ្នាចាញ់ចម្រុះទៅលើស្តេចអាលី ម៉ែមូនឃើញដូច្នោះក៏បង្គាប់ពួកអាវ៉ក្សទាំងអម្បាលម៉ានឲ្យចោលសម្រុកទៅ ។ ពួកអាវ៉ក្សតាំងបញ្ជេញមុខយ៉ាងសំបើម បញ្ជេញអណ្តាតភ្លើងផងគំរាមពួកឧថាមិត្តដែលវត់ ស្ទើរដល់ខ្លួវសេចក្តីស្លាប់ ។

តពីនោះមក ម៉ែមូន ឆក់យកព្រះនាងហើយហោះសំដៅទៅដិតព្រះមហាក្សត្រ ។ ពួកបណ្តាជនឃើញដូច្នោះ នាំគ្នាស្រែកថា: "អត់ទោស! អត់ទោស!" ។ ព្រះអង្គម្ចាស់អាលីស្តេចមកដល់នៅពេលដែលព្រះនាងគង់នៅមុខម៉ែមូន ហើយមានព្រះបន្ទូលថា: "តើឲ្យអញធ្វើកម្មឯងនឹងម្តេចឯងយ៉ាងណា?" ។ ព្រះមហាក្សត្រឆ្លើយតបថា: "ខ្ញុំថ្វាយកូន

ស្រីខ្ញុំជាកវិយាខ្ញែងហើយ ព្រមទាំងថ្វាយខ្ញុំសម្បត្តិខ្ញុំទាំងអស់” ។
អាលីនុនថើបព្រះកេសព្រះមហាក្សត្រ ។ ព្រះអង្គម្ចាស់អាលីនៅរួម
រាស្ន៍ជាមួយនឹងព្រះនាង ដែលខ្ញែងយល់ថាប្រាកដជាស្រីបរិសុទ្ធល្អមែន
ហើយខ្ញែងឡើងសោយរាជ្យនៅទន្លេរាលីហ្វាតនោះទៅ ។ ព្រះនាង
យ៉ាគូតាហ៍មិនសុខចិត្តយកព្រះអង្គម្ចាស់អាលីជាស្វាមីទេ ដ្បិតខ្ញែងធ្លើ
បំបាក់មុខព្រះនាងនៅកណ្តាលចំណោមពលរដ្ឋ ព្រះនាងពីបាកព្រះទ័យ
ពន់ពេក ប៉ុន្តែរឿងនេះព្រះនាងនៅស្ងៀមស្ងាត់រហូត ៣ ខែ ។

ព្រះនាងមានស្នំម្នាក់ឈ្មោះ មាជីនា (marjahna) ដែលធ្លាប់នៅ
ជាមួយព្រះនាងតាំងតែពីតូច ស្នំនោះល្អឯក ហើយមានចិត្តគំនុំគុំគួននឹង
ស្តេចអាលី ព្រោះខ្ញែងយកម្ចាស់ស្រីបំបែកឆ្ងាយពីវា ។ ថ្ងៃមួយវាទូល
ព្រះនាងយ៉ាគូតាហ៍ថា: “តាំងពីបានព្រះអង្គម្ចាស់អាលីជាគូស្និទ្ធ ព្រះ
នាងលែងរវល់ទឹកដល់ខ្ញុំម្ចាស់” ។ - ទេ មិនមែនដូច្នេះទេ ព្រះអើយ!
ខ្ញុំមិនដឹងជាធ្លើម្តេច ខ្ញុំស្អប់ខាល់តែមិនចង់មើលមុខស្តេចផង ប៉ុន្តែខ្ញុំពុំហ៊ាន
និយាយ ព្រោះខ្ញែងមានអំណាចប្រើអាក្សរបាន ។ នាងស្នំធ្លើយថា:
“ពុទ្ធោ! ព្រះអង្គពុំមែនជាស្តេចអាក្សរតែមួយគត់ទេ ខ្ញែងគ្រាន់តែមាន
របស់អ្វីមួយដែលអាចបង្ខិតបង្ខំឲ្យអាក្សរនៅបំរើខ្ញែងតែប៉ុណ្ណោះទេតើ យប់នេះ
ចូរព្រះនាងទៅជិតស្តេច ហើយទូលសុំរបស់អ្វីមួយដែលគ្មាននៅតាមទី
ក្រុងយើង ចូរព្រះនាងប្រុងចាំមើល តើព្រះអង្គខ្ញែងធ្លើយ៉ាងដូចម្តេចខ្លះ

ហើយព្រះនាង់ស្តេចមកជ្រាប់ខ្ញុំម្ចាស់ ។ នឹងគិតឧបាយសម្រាប់ស្តេចឲ្យ
បាន" ។ ព្រះរាជធីតា មានព្រះបន្ទូលតបថា "ឯង់ទើបនឹងជ្រាប់
ការមួយៗ ល់ខ្ញុំដែលខ្ញុំ ពុំបានចាប់ក្តីក" ។

លុះយាង់ចូលដល់ព្រះដំណាក់ ព្រះនាង់យាង់ទៅដិតស្តេចហើយ
ថើបព្រះអង្គ ។ ព្រះរាជាដោយឃើញអាការៈខុសពីធម្មតា ក៏ត្រាស់សួរ
ថា: "ព្រះនាង់មានបំណង់អ្វីឬ?" ។ ព្រះនាង់តបថា: "ទេន់! ទេន់
មិនសោយអ្វីទេឬ?" ហើយព្រះនាង់ប្រើឲ្យបំរើលើកចំណីអាហារមកថ្វាយ
ស្តេច ។ ព្រះនាង់នាំព្រះមហាក្សត្រសោយកំសាន្ត ព្រះមហាក្សត្រមាន
ព្រះឆ្លើយថា: "ចិត្តបង់ចង់បំពេញបំណង់ប្អូនគ្រប់យ៉ាង់" ។ ព្រះនាង
ឆ្លើយថា: "ខ្ញុំម្ចាស់ចង់បានផ្ទៃសារីមួយ ដ្បិតទៅក្នុង់ក្រុង់នេះរកមួយគ្មាន
ទេ" ។ ព្រះមហាក្សត្រទ្រង់ហូតចិញ្ចៀនពីម្រាមព្រះហស្ត ហើយ
មៃ៉ម្ងូនមកដល់ភ្លាម ព្រះអង្គត្រាស់បង្គាប់ថា: "អញចង់ឲ្យឯង់យកផ្ទៃ
សារី ១ ចានមកឲ្យអញ" ។ មួយស្របក់ក្រោយមក មៃ៉ម្ងូនត្រឡប់មក
វិញកាន់ទាំង់ផ្ទៃសារី ១ ចានមកផង់ ។ ព្រះអង្គទ្រង់មានព្រះបន្ទូលទៅ
កាន់ព្រះនាង់ថា: "ព្រះនាង់! របស់ដែលប្អូនសុំនោះ ចាំនមកហើយ" ។
ព្រះនាង់យកផ្ទៃសារីទៅថ្វាយព្រះបិតា ហើយហួសទៅជ្រាប់នាង់មាជិនា
ថា: "ព្រះអង្គមានចិញ្ចៀនមួយវង់ ដែលអាចឲ្យអាស័ក្សបំរើបាន" ។

(មានត)

លោក ផេង-ជ្រើរ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

ដ៏ឆ្ងាច់តប់ខ្ទួនពាក់កណ្តាល ហើយមានទំនងដូចកាលដែលនាងរៀបស្លាប់ ។ ដៃមួយជាក់លើសំពត់ ដៃមួយទៀតជាក់ត្រង់ដើមទ្រូងទុបនៅរឹងក្តឹង ។ ខ្ញុំទំនេរទំពាំយកបានកូនប្រអប់មួយតូច ខ្ញុំរកតែពុំឮទេ! កាលណាខ្ញុំបានឃើញរូបអាប៉ូល ដែលនាងបានសន្យាថានឹងមិនបោះបង់ចោលឡើយ ក្នុងពេលដែលនាងមានជីវិតរស់នៅជាកបណា ។ លុះបានឃើញគ្រឿងសំគាល់ខាងចុងនៃចិត្តដ៏ទៀង ទឹងសេចក្តីស្នេហាដ៏មានមុតនៃនាងក្រមុំដែលគួរឲ្យអនិច្ចា ខ្ញុំស្រាប់តែហូរទឹកភ្នែកច្រោកៗ ឥតពុំបាន ។ ដូម្ចាស់យកដៃគក់ទ្រូងខ្លួនឯងៗ ហើយទ្រហោយំ គួរឲ្យស្រងេះស្រងោចពេក ។ យើងយកសពនាងនាំទៅផ្ទះកុនឯងខ្លួនអ្នកនេសាទ សូមឲ្យគេរក្សាមើលឲ្យផង ហើយពួកស្រី។ ក៏យកចិត្តទុកដាក់ជួយចំអាសទឹកយ៉ាងស្អាត ។ ក្នុងពេលដែលស្ត្រីចាងឡាយនោះកំពុងសំរេចកិច្ចខាងលើ យើងឡើងទៅផ្ទះ ឃើញនាងឡាតូរនឹងនាងម៉ាតីតកំពុងថ្វាយបង្គំព្រះ រង់ចាំស្តាប់ដំណឹងពីកប៉ាល់មក ។ លុះក្រេឡុកឃើញខ្ញុំ នាងឡាតូរស្រែកសួរថា: "ឯណាកូនស្រីខ្ញុំ កូនស្រីសំឡាញ់

ខ្ញុំ ម្តេចមិនឃើញមក?" ។ កាលណានាង់ឃើញខ្ញុំនៅស្ងៀម ហើយ
ទឹកភ្នែកចេះតែហូរ នាង់ឈប់សង្ស័យ ទ្រូងតឹងស្ទើរបែកជាច្រើនពីរភាគ
គេព្រួតែសំឡេងថ្ងូរនឹងសំឡេងយំ ។ នាង់ម៉ារតាតែក៏សួរដៃថា: "ចុះ
កូនប្រុសខ្ញុំ ម្តេចក៏មិនឃើញផង? ខ្ញុំមិនឃើញកូនប្រុសខ្ញុំសោះ"
រួចនាង់ដួលសន្លប់ទៅ ។

យើង់វត់ទៅលើកនាង់ យកទឹកមកស្រិតមុខឲ្យបានដឹង្ហួន ខ្ញុំច្រើប
ថាអាប៉ូលនៅរស់ទេ លោកចៅហ្វាយឲ្យគេមើលរក្សាហើយ ។ នាង់
ដើរពីសន្លប់មក ខំប្រឹង់ជួយគាំពារគ្រាហ៍នាង់ឡាតួរ ដែលចេះតែច្រាត់
ស្មារតីម្ត្ង។ ។ នាង់ឡាតួរខ្ចូកខ្ចាំង់ពេក យប់ហ្នឹង់គ្មានដេកសោះ
តាមខ្ញុំពិចារណាមើល គ្មានខ្ចូកអ្វីធំជាង់ខ្ចូកព្រោះស្លាយកូនដែលស្ងាប់
ឡើយ ។ កាល់នាង់បានដឹង្ហួនច្រាកដមែនទែន នាង់មានមុខក្រៀមក្រំ
សំឡឹង់មើលតែមេយ ។ ខ្ញុំនាង់នឹង់ម៉ារតាតែ ចាប់ដៃនាង់ទាញ ហើយ
និយាយច្រាប់ក៏ឥតអំពើ នាង់ដូចជាលែង់ដឹង់លែង់យល់អំពីការពាប់អាន
នៃយើង់ពីមុនមក ហើយយូរៗ គេព្រួសួរនាង់ថ្ងូរនឹង់ដកដង្ហើមធំម្ត្ង។ ។

ព្រហាមឡើង់ គេនាំអាប៉ូល ដោយអង្រឹង់ស្នែង់មក ។ វាបាន
ដឹង្ហួនសព្វគ្រប់ហើយ តែនិយាយមិនសូវច្បាស់ ។ ដល់ដួចដុំម្តាយ
មឹង់កូនមិនដឹង់ជាយ៉ាង់ណាទេ ខ្ញុំបារម្ភពេក តែលុះបានច្រេះគ្នា ត្រឡប់
ជាស្រួលគួរសម មិនយំស្រែកប៉ុន្មាន ។ នាង់ចាំង់ពីរយើញអាប៉ូលមក

ដល់គាលណា បែបអន់ព្រួយបន្តិច ។ នាងនាំគ្នាទៅអង្គុយជិតចាប់ផ្តើម ទឹកភ្នែកដែលអាក់ខានហូរក្នុងពេលមុន ព្រោះព្រួយខ្លាំងពេក ក៏ផ្តើមហៀរហូរក្នុងពេលនេះ ។ អាប៉ូលក៏ចេញទឹកភ្នែកនឹងគេដែរ ។ ជនកំសត់ទាំងបីនាក់ ធូរទ្រូងបន្តិចដោយបានជួបគ្នា ចំណែកសេចក្តីត្រេកត្រអកក្នុងចិត្តដែលបណ្តាលមកពីសេចក្តីទុក្ខ បង្កើតដល់សត្វទាំងបីដែលទៅជានៅស្ងៀមព្រងើយ។ អត់ឃ្យាយ អត់ទឹក ដេកស្តូកស្តឹងដូចមនុស្សស្លាប់ ។

លោកចៅហ្វាយឲ្យមនុស្សមកជ្រាបខ្ញុំដោយស្ងាត់ថា សពនាង វ៉ីស៊ីនី លោកឲ្យគេនាំទៅឯផ្សារហើយ។ ឲ្យគេនាំទៅឯព្រះវិហារបុំប្លែមុះបណ្តាយ ។ ខ្ញុំចុះទៅតារ - ល្លី ភ្លាម ឃើញអ្នកស្រុកទាំងឡាយគ្រប់កូមិទៅជួយហែខ្មោចនោះគគ្រឹកគគ្រេង ហាក់ដូចជាគេជាត់វត្តដ៏ថ្លៃថ្លារបស់គេគ្រប់គ្នាទៅក្នុងកោះ ។ ទៅកំពង់ផែ គេចងសាវក្តោងច្រងាងជាកាកបាទនៅលើនាវា គេបង្ហូតទង់ជ័យខ្មៅ យូរៗ គេបាញ់កាំភ្លើងមួយគ្រាប់ ។ កងពលថ្មើរជើងដើរដង្ហែគ្នាជាជួរ ចុងកាំភ្លើងទំលាក់ចុះក្រោមស្គរប៉ុំសំពត់ខ្មៅរាយព្យួរស្ងួតឲ្យអាណោចអធម្មម៉្លេះទេ! នារីយ៉ាងស្អាតចំបាំនាក់ជ្រើសរើសយកពីក្នុងកូមិផ្សេង។ ស្ងៀកសរាក់ស កាន់គ្រឿងលំអក្នុងដៃនាំគ្នាជួយទ្រ នឹងហែសពនាងវ៉ីស៊ីនី ដែលជាធីតាមានធម៌ក្នុងខ្លួន មានសុទ្ធតែក្លិនផ្កាគ្របពីលើ ។ ពួកក្មេង។ សូត្រធម៌ព្រម។

គ្នា ដើរបន្ទាប់ពីក្រោយ តមកទៀត សទ្ធតែមនុស្សចាស់នៅក្នុងភោះ រួចពីនោះមកលោកចៅហ្វាយ ក្រោយបំផុតពួកប្រជារាស្ត្រ ដើរស្រែបៗ ស្ងាត់ឈឹងតែសូរជើង ។

ហ្នឹងហើយមើលចុះ រាជការបង្គាប់ឲ្យគេធ្វើកិច្ចជាកិត្តិយសដ៏ខ្ពង់ខ្ពស់សប្បុរសធម៌នៃនាងវីរ៉ាស៊ូនី ។ កាលណាក្បួនហែមកដល់ដើងកុំគេក្រឡេកទៅឃើញខ្មែទាំងពីរគួរឲ្យស្រអែះស្រអាចខ្ញាចចិត្តក្រៃពេក ដែលពីដើមនាងធ្លាប់នៅជាសុខសប្បាយជាមួយក្រុមគ្រួសារ ឥឡូវពេញដោយសេចក្តីទុក្ខនឹងសេចក្តីព្រួយ ។ ក្បួនហែឈប់មួយស្របតមនុស្សទាំងឡាយបែកខ្ញែកពីគ្នា ពួកភ្លេងក៏ឈប់សូត្រធម៌ នៅតង់ពីរាលគេឮសូរតែសំឡេងដកដង្ហើមធំនឹងសំឡេងខ្សឹកខ្សួល ។ គេឃើញនារីទាំងឡាយខ្លះដាច់ខាងរត់មកំ ខ្លះកាន់កន្សែងដៃ ខ្លះមានផ្កាំ ខ្លះមានកូនផ្កាយកមកគំនាប់បូជាសពនាងដោយសេចក្តីគោរពយ៉ាងមាំ ហាក់ដូចជាយកទៅថ្វាយព្រះ ។ ស្ត្រីជាមាតាទាំងឡាយបន់ព្រះថា: សូមឲ្យមានកូនស្រីចិត្តល្អដូចនាង ពួកកំឡោះថា: សូមឲ្យមានប្រពន្ធចិត្តត្រង់ដូចនាង, ពួកអ្នកកំសត់ថា: សូមឲ្យមានប្រពន្ធចិត្តទន់ប្រកបដោយមេត្តាដូចនាង, ពួកចាវបំរើថា: សូមឲ្យមាននាយចៅហ្វាយចិត្តសន្តោសដូចនាង ។

លុះគេហែសពទៅដល់រណ្តៅ ពួកស្រីភ្នែកប្រទេស ម៉ាជាគស្ការនឹងប្រទេសមូសមៈហឹក យកកញ្ជើដាក់ផ្ទៃឈើពេញ ទៅដំរៀបដុំវិញ

សភានាង ហើយនាំគ្នាយកសំពត់ទៅព្យួរនៅលើចុងឈើជិតខាងតាមទំនៀមស្រុក, ស្រីកុំគ្គីប្រទេសបង្កាល់ទឹងស្រីទៅផ្ទេរសម្រូច មាន់ជាគស្ការយកសត្វស្វាបមកបើកលែងតាំងទ្រូង ។ រឿងតាំងនេះកើតមានឡើងមកតែពីបាត់បង់នូវតុជាទីស្រឡាញ់ពេញចិត្តនៃសាសន៍គ្រប់យ៉ាង នឹងដោយអំណាចសប្បុរិសធម៌របស់នាង ដូច្នេះនាងអាចសង្គ្រោះអន្តរាយហៅសាសនាគ្រប់ជាតិឲ្យមកនៅជុំវិញផ្ទះនាង ។

ត្រូវដាក់ឲ្យមនុស្សយាមនៅក្បែរៗណា . ហើយដេញពួកស្រីក្រមុំកូនអ្នកក្រឲ្យចេញ ដ្បិតគេថាពីថ្ងៃនេះទៅ ឥតមានអ្នកណាជាទីពំនាក់អាស្រ័យឡើយ បើដូច្នេះមានតែកិច្ចមួយគឺលោតចូលរណ្តៅឲ្យស្លាប់ជាមួយអ្នកមានឧបការគុណវិញល្អជាងរស់នៅ ។ គេកប់នាងនៅជិតវិហារ ប៉ុន្តែមុនឈឿនខាងលិច ក្បែរប្តីមួយគុត្ត ជាកន្លែងដែលនាងចូលចិត្តឈប់សម្រាកកាយជាមួយម្តាយនាង នាងមានតីរតីនឹងមនុស្សម្នាក់ដែលនាងហៅបង ។ កន្លះវេលាដែលនាងមកពីវិហារសូត្រធម៌ ។

ត្រឡប់ពីហៅសពនាងនារី វីស៊ីនី វិញ លោកចៅហ្វាយត្រមតាំងអ្នកជួយហៅជាច្រើននាក់ ទៅឯខ្ទមនាង ។ លោកចៅហ្វាយសុខចិត្តជួយសម្ភារៈគ្រប់យ៉ាងដល់នាង ឲ្យតួរ នឹងកូនាង គឺម្តាយអាប៉ូល លោកមានវាចាបន្ទោសម្តាយមីងរបស់នាងពីរបីម៉ាត់ថា ជាស្ត្រីចិត្តអាក្រក់

ហើយលោកចូលទៅជិតអាប៉ូល និយាយលួងលោមដោយសំដីពីពេះគួរ
ឲ្យសុខចិត្តដូច្នេះថា: "ខ្ញុំមានព្រះជាច្រើនកាលពីដើមឡើយតែខ្ញុំ
ថ្វាយថ្នូរសេចក្តីសុខស្រួលដល់អ្នកទើបដល់គ្រួសាររបស់អ្នក ។ នែ
សំឡាញ់! ចូរឯងទៅឯស្រុកចាំងចុះ ខ្ញុំនានឹងរកការឲ្យឯងធ្វើ ។
ហើយចូរឯងកុំព្រួយក្នុងពេលដែលឯងមិននៅ ខ្ញុំនឹងចិញ្ចឹមម្តាយឯងដូច
ជាម្តាយខ្ញុំ" ។ រួចលោកលូកដៃទៅរកអាប៉ូល រាដកដៃថយក្រោយ
ហើយងាកក្បាលចេញមិនរវល់មើលលោកសោះ ។

ចំណែកខ្ញុំ។ នៅទីឆ្ងាយនោះបីបួនថ្ងៃ ដួយកំដរទីឆ្ងាយលួងលោម
នាយអាយ ។ កន្លងទៅបានបីសប្តាហ: អាប៉ូលជាស្រឡះបានដើរវិញ
តែសេចក្តីទុក្ខដូចជាចំរើនខ្លាំងឡើង ពីដួចខ្លួនរាល់តែជាមានកំឡាំងច្រើន
រាល់ដងទីតាំងអស់ រាមើលអ្វី មើលស្ងួត ក្នុងខ្លួនដូចជាគ្មានវិញ្ញាណ
ហើយអ្នកណាសួរក៏ដោយរាល់តែធ្ងន់ ។ នាងឡាតួរព្រួយពេកចង់ស្លាប់
មានរាចាថា: "ទុកូនមាសម្តាយ! ម្តាយបានឃើញថាជារបណា ម្តាយ
ស្មានដូចជាបានឃើញកូនស្រីសំឡាញ់ដរាបនោះដែរ" ។ ឆ្នាស្ងួរចេញ
ឈ្មោះ រីស៊ីនី អាប៉ូលភ្ញាក់ព្រឺតហើយដើរចៀសចេញឆ្ងាយពីនាងទៅ
ខោះបីម្តាយបង្កើតទំហាវាឲ្យមកជិតនាងឡាតួរជាសំឡាញ់ក៏ដោយ ។
រាថយទៅអង្គុយក្នុងសួនតែម្នាក់ឯង ក្រែមម្ចប់ដើមដូនាងរីស៊ីនី
ក្អែកសំឡឹងទៅតំពន់ទឹកដែលធ្លាប់ងូត ។ (មានត)

សកម្មភាពនៃក្រុមជំនុំទៀមទម្ងាប់ខ្មែរ

បរិយាយអំពីរបៀបធ្វងទន្លេ

លោក បាប-ពិន រៀបរៀង

អស់លោកគាំង ឬ ឡាយ !

ទុកាសនេះ ក្នុងនាមនៃក្រុមជំនុំទៀមទម្ងាប់ខ្មែរ នៅពុទ្ធសាសន-បណ្ឌិត្យ ក្រុងភ្នំពេញ ខ្ញុំសូមពណ៌នាអំពីរបៀបធ្វងទន្លេតាមទំនៀមទម្ងាប់ខ្មែរបុរាណ ជូនអស់លោកអ្នកស្តាប់ :

ទំនៀមខ្មែរយើង :

– ហៅស្ត្រីមានគភ៌ថា "មានផ្ទៃ" ឬ "មានផ្ទៃពោះ" ឬ "មានទម្ងន់" តាមដែលគភ៌ជាភារៈមួយដ៏ធ្ងន់ពិបាកថែរក្សា ។

– ហៅការដែលភ្ជាំងគារកឲ្យកើត ឲ្យចេញចាកគភ៌មាតា ថា: "សម្រាលកូន" ជាវេហារៈសម្រាលភារៈដ៏ធ្ងន់ឲ្យស្រាល ។

– ហៅមួយយ៉ាងទៀតថា "ធ្វងទន្លេ" ជាវេហារៈប្រៀបធៀបទៅនឹងដំណើរធ្វងទន្លេ - សមុទ្រ ដែលជាដំណើរលំបាក ។

– ហៅជាភាសាបូតថា "ប្រសូតកដបុត្រ" ។

ការធ្វងទន្លេ បែកជា ៣ ពេល គឺ

១.– ពេលមុនធ្វងទន្លេ;

២.– ពេលធ្វងទន្លេ;

៣.– ពេលក្រោយធ្វងទន្លេ ។

១.— បរិយាយអំពីពេលមុនឆ្លងទន្លេ:

ការមានផ្ទៃ នឹងការឆ្លងទន្លេជាការគ្រែបំផុតរបស់ស្ត្រី ឬនជាស្ត្រីមានផ្ទៃខ្មែរយើង គេតែងកាន់ទំនៀមដោយម៉ឺងម៉ាត់ គឺ

តាំងពីមានផ្ទៃ ១ ខែជរាបទៅ គេតែងតមត្រណាម គឺ

ក) មិនឲ្យបរិភោគអាហារហើរ ដូរ ដៃប្រពៃក នឹងលៀស ឲ្យឆ្ងបបរ ជាដើម ដែលនាំឲ្យមានជម្ងឺដល់មាតានឹងទារកនៅក្នុងផ្ទៃ;

ខ) មិនឲ្យបរិភោគអាហារខុសពេលជម្មតា ដែលនាំឲ្យទារកកើតឥតសណ្តាប់;

គ) មិនឲ្យទទួលទានដំណេកថ្ងៃ ដ្បិតទឹកយប់ ដែលនាំឲ្យទារកនៅក្នុងផ្ទៃថ្ងាសពេកពិបាកឆ្លងទន្លេ;

ឃ) មិនឲ្យអង្គុយមាត់ជណ្តើរ មាត់ទ្វារ ដែលនាំឲ្យពិបាកឆ្លងទន្លេ។

កាលមានផ្ទៃបាន ៨ ខែ គេតែងកាន់ទំនៀម គឺ

ក) រៀបពិធីសូត្រមន្តបម្រើនសុខសួស្តីមង្គលដល់មាតានឹងទារកនៅក្នុងផ្ទៃ;

ខ) បន់ខ្សែបង្កង់ ឬខ្សែក;

គ) ធឹកចាំ ជាំទឹកផ្កាឈូក, - ស្វឹកខ្ទះសម្ង, - សំបកតង់មាន់, ម៉ើមត្រាញ់ជ្រូក ឲ្យស្រួលដល់ផ្ទៃ ដើម្បីឆ្លងទន្លេងាយ;

ឃ) ទស្សាហ៍ដើរធ្វើការឲ្យច្រើនល្មមដល់កម្លាំង ដើម្បីឆ្លងទន្លេរហ័សស្រួល។

អ្នកអង្គម្ចាស់ នពេត្តម-សុខានារី ផ្តល់ឲ្យការណ៍ថា:

- ទំនៀមអ្នកមានផ្ទៃជាក្បូត្រ, លុះព្រះគភ៌ចាស់ជិន ៨ ខែ គេតែងរៀប "ពិធីចងសំពោង" ប្រហែលនឹងពិធីសូត្រមន្តរបស់ពួកស្តូ ប្លែកបន្តិចតែមានធ្វើពានទេពតា នឹងមានពួកបាគូសូត្រសុតីជ័យមង្គលប៉ុណ្ណោះ ។

- គ្រប់តែអ្នកមានផ្ទៃ, តែជិតដល់ពេលឆ្លងទន្លេ, ស្វាមីឬញាតិតែងរកស្បែវ ១ កូនកញ្ជើ, ចេក ១ ស្ទិត អំបោះ ១ ចង្កោយ, កាំបិតកោរឬកន្ត្រៃ ១ ជាក់កងកញ្ជើ ១ ហៅថា "ស្បែវពន្ធ" បម្រុងទុកជាទ្រនឹបជូនឆ្លង, នៅលើស្បែវពន្ធគេតែងជាក់ដី ១ ដុំដែលទុកជាកំណើតមនុស្ស. ចាំងគ្រែសម្រាប់អាងក្មេង, ដើងគ្រានដើមចេក, អុសក្រសាំង, កំណាត់សំពត់, ទឹកក្តៅ ក៏គេបម្រុងទុកជាស្រេច ។

- គេតែងឆ្លងទន្លេនៅកងផ្ទះ, តែជនខ្លះ គេសង់ពេងមួយជាប់ពីផ្ទះជំក៏មាន ឲ្យមានឈរលំអាកាសល្អ ជាកន្លែងឆ្លងទន្លេ ។

- នោះគេឆ្លងទន្លេនៅផ្ទះក្តីពេងក្តី គេតែងយកកំបោរគូសដើងក្អែកនៅសសរផ្ទះឬពេង, នៅមាត់ទ្វារផ្ទះឬពេង, រកគ្រូព័ទ្ធអំបោះសិមាជុំវិញទីឆ្លងទន្លេ ឧទ្ធិស្រាសសម្រាប់បន្ទាក្រោមទីឆ្លងទន្លេ ត្រង់ដែលទឹកស្ងោះធ្លាក់ ដើម្បីការពារបិសាចឧទ្ធិម្ភាយដើម ។

២.- បរិយាយអំពីពេលឆ្លងទន្លេ:

លោក អៀង-សាយ មេជាងវាចនានៅផ្ទះលេខ ៣៨ ផ្លូវព្រៃពនសង្កាត់លេខ ៦ ក្រុងភ្នំពេញ ផ្តល់ឲ្យការណ៍ថា:

បេអ្នកមានផ្ទៃចាប់ឈឺផ្ទៃធ្ងន់ចុះទៅក្រោម ថ្ងៃកំពីឈឺពោះសព្វដង នោះជាសញ្ញាថាជិតដល់ពេលឆ្លងទន្ទេ ។ ខណៈនោះគេរកឈប់បម្រុះប្រែទៅជាចំកោងខ្លួនវាទៅវិញ ដើម្បីរៃគ្រួចាប់រកផ្លូវ ជាធម្មតារបស់គេរក ។

– កាលណាអ្នកមានផ្ទៃគ្រៃជាក់ពីចុងជើងខ្សែដល់ដង្គង់ គេចំណាំថានឹងឆ្លងទន្ទេក្លាម ។ ម្យ៉ាងទៀត កាលដឹងថាគេរកឃ្លាតពីចុងដងក្តើមចុះមក ៤ ធ្នាប់ បើឆ្លងមកពីព្រលឹម គេចំណាំថា នឹងកើតនៅពេលថ្ងៃត្រង់ កាលដឹងថាឃ្លាត ៨ ធ្នាប់ បើឆ្លងមកពីព្រលឹម គេចំណាំថា នឹងកើតនៅពេលថ្ងៃពេញពន្លឺ ។ ចំណាំនេះច្បាកដណាស់ ។

– ឆ្លួបខ្មែរបុរាណមិនប្រើប្រាស់អ្វីក្រៅពីដើងដៃរបស់ខ្លួនទេ គឺឆ្លួបតែងឲ្យមាតាគេរកទទួលថាន់ដំណេកផ្ទាល់ អង្គុញដើងចាំងពីរបញ្ឆរដង្គង់ខ្លួនឆ្លួបតែងគាត់ក្រវាត់ចូលប្រតិបត្តិការ ដង្គង់ចាំងពីរបស់ឆ្លួបទប់ក្តៅមាតា ដៃចាំងពីរទប់ផ្ទៃបង្ការមិនឲ្យគេរកផ្អៀងទទឹងផ្ទៃ, ដល់ពេលមាតារមាត់បម្រុងឆ្លងទន្ទេ ឆ្លួបតែងជួយទប់ផ្ទៃដោយដៃម្ខាង, កាលបើឃើញគេរកចេញមក គេតែងចាប់ចង្កាគេញចេញចាកទ្វារដោយដៃម្ខាង ។

– ទៅពេលឆ្លងទន្ទេគេតែងអុជទៀនឆ្លួបសំបូងសង្ឃឹងដល់គ្រួ ចាំងខាងឆ្លួប ចាំងខាងអ្នកមាងផ្ទៃឲ្យមកជួយកាន់ខ្នងវង្សមុខឲ្យគេរកកើតធាប់ៗ គេតែងរកគ្រួឲ្យធ្វើតឹកមន្តគ្រោះយោងជាតុយោងកម្លាំងអ្នកមានផ្ទៃ, គេ

តែងបើកគ្មារ បង្អួច ទ្វារ ហិប ចំហរ ទឹងឲ្យស្វាមីកន្ទុងខ្លួនកើយា ៣ ដង ជាឧបកិច្ចដើម្បីឲ្យគារកកើតធាប់ ។

លោក ឆួង-អ៊ិច មេឃុំ។ អង្គាញ់ ស្រុកព្រៃកប្បាស (តាកែវ) បានឲ្យការណ៍ថា :

– ឆ្មបដែលត្រូវគេអញ្ជើញ មុនទឹងទៅ តែងធ្វើជាទៅដោះទឹកសត្វគូថ ឧបកិច្ចថា - "រួចហើយ។" លុះទៅដល់ផ្ទះអ្នកមានផ្ទៃ តែងជាក់កាំ-ជណ្តើរ ៣ ដង ឧបកិច្ចថា "រួចហើយ។" ដែរ ដើម្បីឲ្យកូនកើតរហ័ស ។

៣.– បរិយាយអំពីក្រោយពេលឆ្លងទន្លេ :

លោក គង់-ចន្ធូ: នៅឃុំព្រៃវៀន ស្រុកព្រៃឈរ (កំពង់ចាម) បានឲ្យការណ៍ថា:

– ការ៉ាតកចេញចាកឧទរមាតារួចក្តាម ឆ្មបតែងយកអំបោះដែលខ្មុកលើកញើ្ជស្រាវពង្វៃ មកចងទងផ្ចិតគារក ២ ចំណងរឹតយ៉ាងតឹង បង្អាវដល់កាត់ផ្ចិតទៅកុំឲ្យឲ្យល់ជ្រាបចូលទៅកងពោះគារក ទឹងមិនឲ្យឈាមចេញពីកងពោះគារក, រួចយកកាំបិតកោរឬកន្ត្រៃថ្នមស្អាត ដែលខ្មុកលើកញើ្ជស្រាវពង្វៃមកកាត់ផ្ចិតគារក ។ គេតែងកាត់ខ្មុកចំណងទី ១ ឲ្យជាប់នៅទឹងទងសុក, ចំណងទី ២ នៅមឹងទងផ្ចិតគារក ។

លោក ស៊ុន-សាំង មេឃុំចាស់ នៅឃុំគោកត្រឹង ស្រុក-វៀតស្វាយវៀង បានឲ្យការណ៍ថា:

– របៀបកាត់ផ្តិត, ឆ្មបគេយកក្ងានឬសរីថ្ង. មកបិតឲ្យមានមុខមុត កំដៅភ្លើងឲ្យក្តៅ, រួចកាត់ គេយកធ្យូង ១ ដុំប៉ុនមេដើងត្រាប់ពីក្រោមទង់ផ្តិត ហើយគេកាត់ផ្តាច់ត្រង់ចន្លោះចំណងទាំងពីរ ។ បានជាគេយកធ្យូងធ្វើដូច្នេះ ពីព្រោះធ្យូងជាធម្មជាតិម្យ៉ាងសម្រាប់ឃាត់ឈាមធ្វើឲ្យឈាមសោះធាប់សះ, បានជាគេយកបុស្សរីថ្ងជាកាំបិតកាត់ផ្តិតនោះដើម្បីជាប្រផ្នូលដល់ពារកធំឡើងកុំឲ្យវាមានចិត្តខ្មោមុះ ។

– លុះកាត់ផ្តិតហើយ ឆ្មបតែងលាងពារកដោយទឹកក្តៅអ៊ុនៗហើយយកស្វឹកគ្នោតគៀរអិលដែលជាប់នៅក្បាលឫខ្លួនពារក, រួចគេចាប់ដើងទាំងពីរបស់ពារកយូរឡើងលើ សំយុងក្បាលចុះក្រោម, ខះគូធជាងៗ ទាល់តែពារកនោះយំព្ងួចាំង ដើម្បីឲ្យទឹកត្រៃហូរចេញអស់, ហើយឆ្មបស្រែក ៣ ដងថា "បានគេឬបានយើង?" ស្តីអ្នកផ្ទាប់ចិញ្ចឹមកូនតបដែលចាំទទួលបីកូនមុនគេធ្វើយតប ៣ ដងថា "បានយើង" រួចយកក្រណាត់សំពត់ថ្មីសស្អាត ១ ផ្ងាំងរុំខ្លួនពារកឲ្យកកក្តៅ ។

លោក សុខ - នៅ នៅឃុំ - ស្រុកពញាលឹ (កណ្តាល) បានឲ្យការណ៍ថា:

– បើកូនណាកើតមកសន្ធប់ គេយកសុកកូននោះទៅលើងក្នុងអំបែងឲ្យក្តៅ ទើបកូននោះដឹងខ្លួនយំមួយរំពេច ។

– បន្ទាប់ពីកាត់ផ្តិត ឆ្មបតែងយកក្រូចធ្នាវខ្ចីច្រាច់យកទឹកត្រងយ៉ាងស្អាតបន្តក់ភ្នែកពារកបង្អាល់ភ្នែក ។

- ឆ្មបតែងលាងចង្កឹលដៃស្តាំខ្លួនឲ្យស្អាតលូកចូលទៅក្នុងមាត់ខ្លួនមួយស្របក់ឲ្យក្តៅអ៊ុនៗ ហើយលូកប្រទៀលទៅក្នុងមាត់ទារក ដើម្បីការពារមិនឲ្យវាកើតជ្រាំងទៅថ្ងៃមុខ ។

- លុះស្រែចកិច្ចការងារហើយ, ឆ្មបតែងប្រញាប់ត្រឡប់ទៅកាយផ្ទៃមាតាទម្លាក់សុកនឹងឈាមដ៏ឲ្យអស់. បើសុកមិនធ្លាក់ គេហៅថាជាប់សុកឬថាជាប់តន្ទុយ ពិនជាការក្រែណាស់ ។ ត្រង់បទនេះ លោក ស៊ុន - សាង បានឲ្យការណ៍ថា:

- បើជាប់សុកគេតែងយកឫសត្រែលដែលចាក់ឫសទៅទិសខាងកើតមកបុកលាយទឹក ដាក់អុបិល ៣ គ្រាប់កំដៅក្តៅឲ្យក្តៅ ពាសោះមាតាឬស្មៅឲ្យផឹកតែងធ្លាក់សុករួចរាយ ។

- សុកគេតែងប្រឡាក់អំបិលខ្លះកំណាត់កខ្វេល ទុកទាល់តែដល់ពេលទម្លាក់ដើងគ្រាន បានគេយកទៅកប់ចោលក្នុងដីតាមទិសដង្ហើមរស់ទីងតាមក្បួនកំណើត. ។ អ្នកខ្លះយកសុកទៅដុតចោលក៏មាន ដើម្បីការពារកុំឲ្យកូននោះកើតកមរមាស់, អ្នកខ្លះយកសុកទៅទើលើប្រគាបឈើធំឆ្ងាយពីភូមិពីផ្ទះក៏មាន ។

- បន្ទាប់ពីពេលទម្លាក់សុកនឹងឈាមដ៏រចេញអស់, ឆ្មបតែងប្រញាប់ជាន់ត្រគាកអ្នកឆ្លងទន្ទេឲ្យរួមចូលទៅវិញ ពីព្រោះពេលទារកកើតតែងសញ្ជោកឆ្អឹងត្រគាកមាតា រួចគេយកអង្រែងក្តើងដីរក្រសាំងចំហុ

ប៉ុតលាយគ្នាច្រចាច់លាយទឹកម្តូត ១ តោមត្រង់ឲ្យមានទន្លួលខាន, ហើយចាប់ផ្តើមអាំងភ្លើងតទៅ ។ ពេលអាំងភ្លើងគេឲ្យមានទន្លួលខាន ថ្នាំដែលត្រាំស្រា ៣-៤ ខែ មកហើយប្តូថ្នាំដាំ គឺរំដិញមាស, ឈើភ្លើង, សំបកស្តុកស្ពោរ, ឫសគ្គំាងចុយ, សំបកជ្រួយ·រលាយ, ផ្សែតសុក្រំ, ដើមដាំងគី ជាដើម ។

- ពេលឆ្អិនទន្ទេចុ្ចៗ ដែលមាតាមិនខាន់មានទឹកដោះ គេតែងយកឈើអែមត្រាំទឹក យកសំឡីបន្តក់កងមាត់ពាងជំនួស ចាំពេលមាតាមានទឹកដោះបានគេឲ្យកូនបៅតទៅ ។

អំពីរបៀបអាំងភ្លើង: គេតែងយកត្រែកំពស់ ២ ហត្ថ ១ ចំអាម បណ្តាយ ៥ ហត្ថ ទទឹង ២ ហត្ថ ១ ចំអាម ជាទីអាំងភ្លើង, តែអ្នកខ្លះដោយផ្ទះគេមានរនាបគេធ្វើធ្នើរទើរដើងក្រានក្រៅមផ្ទះអាំងភ្លើង, គេយកអុសក្រសាំងដុតអាំង, គេយកដែកគោលខ្នែរ ១ ចោះចំកណ្តាលដើងក្រានសែកតាថាដកពីសភ្លើង. គេចម្លងភ្លើងពីដើងក្រានធម្មតាទៅបង្អាត់, គេតមមិនឲ្យអ្នកណាយកភ្លើងនោះច្រើការឯទៀត, តមមិនឲ្យគោះឬដេះរងើកភ្លើងនោះ បង្គាប់កុំឲ្យមានក្រសែលើងក្តែក ទឹងតមមិនឲ្យដុតត្រីងៀតឬធ្វើម្ហូបអ្វីក្នុងភ្លើងនោះ ។ គេយកថាំងដោតនៅដើងក្រាននោះឲ្យខ្ទោចខ្ទាច ។ អ្នកខ្លះគេយកដើងក្រានដ៏ធម្មតា ២ ឬ ៣ ជាក់ដ៏តខ្លះថ្នាង ២ ឬ ៣ ជាក់ធ្យងដុតអាំង ។ គេគួសដើងក្តែកនឹងព័ទ្ធសីមានៅ

បន្ទប់អាំងក្តៅ ការពារព្រោយក្រដាក្តៅនឹងចិសាចផ្សេង ។, គេតម
មិនឲ្យអ្នកក្រៅចូលក្នុងសីមា ជាន់តែអ្នកថែរក្សាប៉ុណ្ណោះ ។

គេអាំងក្តៅ ៣ ថ្ងៃ ៥ ថ្ងៃ ៧ ថ្ងៃ ឬ ដល់ ៩ ថ្ងៃក៏មាន, ព្រោះតែ
ជាន់ពីដើមគេអាំងក្តៅដល់ ៩ ថ្ងៃ ជាន់ជាមានចំនៀមខាងកិក្តុតែងចូល
បរិវេស ៩ ថ្ងៃ សង្ឃគុណមាតាកាលនៅក្តៅ ។ ពេលអាំងក្តៅគេតែងតម
មិនឲ្យអ្នកដទៃ ឬ ស្វាមីខ្លួនអ្នកអាំងក្តៅនិយាយពាក្យថាក្តៅ - មិនល្អ - មិន
ស្រួល ទំនងតមមិនឲ្យអ្នកក្រៅផ្ទះចូលទៅសួរផ្តល់អ្នកអាំងក្តៅ, គេ
តែងយកស្លឹកម្នាស់ ១ ជាងចង់នៅមាត់ទ្វារចូលទៅថែអាំងក្តៅជាសំគាល់
ថាមានត្រណមនេះ ។

អំពីអាបម៌ព្រៃ: បើតាកណាកើតមក, ហ៊ាយមានលាមកព្រៃភ្លាម
គេចំណាំថាមិនយូរប៉ុន្មានតាកនោះទំនងក្សយទៅវិញ, បើកើតមកយូរបាន
មានលាមកព្រៃ តាកនោះទើបរស់នៅ ។

អំពីស្រោម: បើតាកកើតមកមានស្រោម គេតែងយកស្រោម
ប្រឡាក់អំបិលហាលថ្ងៃទុក, ដល់តាកនោះធំឡើង ចេះបរិភោគបបរ
គេយកទៅលាយបបរឲ្យបរិភោគ, តាកនោះទំនងទៅជាមនុស្សគ្រងំកាប់
មិនមុត ។

អំពីការសែនពន្លែ: នៅវេលាព្រឹកថ្ងៃទី ៣ បន្ទាប់ពីថ្ងៃតាក
កើតមក គេតែងរៀបពិធីសែនពន្លែ គឺ គេយកឧរុកដាក់ទន្ទឹមកញ្ជើស្រូវ

ពន្លៃដែលបម្រុងទុកតាំងពីមុនធ្វើនេះ, គេរៀបគ្រឿងស្រែកពាក់ល្អ។ ទឹងបង្អែមចំអាបជាក់ដើងពានទឹងតុថាសធ្វើស្តាំ គេអញ្ជើញញាតិអង្គុយជុំវិញខាងក។ ពេលនោះធ្លុបចិតមើមពន្លៃ ៩ ចំណិត, ជ្រែកមួយ ៣ ចម្រែក ១ ចម្រែកខ្ចប់ពន្លៃ ៣ ចំណិត, រួចទំពាវពន្លៃទឹងមួយនោះឲ្យស្អិត, យកមួយ ១ សន្ទឹកទៀត កាត់ធ្វើរង្វង់មូលចំកណ្តាលយកទៅជាក់ពីលើបង្អើយខាងក។ ហើយខ្ចាក់ស្រឹកមួយទឹងពន្លៃដែលទំពាវស្អិតនោះបិទចំបង្អើយខាងក។ ពេលបិទបង្អើយគេអុជទៀនធូបសំបូងសង្ឃឹងដល់ជីដូនជីតា សូមឲ្យជួយខាកឲ្យបានសេចក្តីសុខ - ចម្រើន. ឯស្រូវពន្លៃគេទុកជាដំណាងពូជស្រែរាំងពួង បានជាពេលនោះគេបន់ថា "សូមឲ្យពន្លៃនេះ ជាឧសថពិពូពិសេស បិទបង្អើយកូននេះទៅពេលណា សូមឲ្យងាប់រើរលាក្បាល". ។ រួចធ្វើបយកកន្ត្រៃច្រៀបសក់ខាងក ២ ៣ សរសៃជាក់កន្ទោង សំបូងសង្ឃឹងថា "ម្តាយដើម! អ្នកឯងបានឲ្យកូននេះមកយើងហើយ, តឡូវអ្នកឯងយកបុងសក់បន្តិចនេះទៅចុះ, កុំមកយាយីកូននេះឲ្យសោះ, ឲ្យកូននេះបានសុខ - ចម្រើនតទៅ" ។ ដូច្នេះហៅថា "សែនផ្តាច់ម្តាយដើម" ។

បន្ទាប់ពីនោះ គេចាប់កន្ទុយអុស ទឹងកន្ទុយចន្ទុះ ជាក់កងចាន ១ ជាមួយទឹងបង្អែមបន្តិច ចំអាបបន្តិច យកទៅចោលក្រៅបង ដូច្នេះហៅថា "សែនផ្តាច់ស្រូវពន្លៃ" ។

នៅពេលសែនពន្លៃ គេតែងឲ្យមាតាបិតាឬកសុំស្មាលាគោសនឹងធ្នូប ហើយដូនស្រីពន្លៃនឹងម្ហូបចំណីជ្រាក់កាសដល់ធ្នូបតាមសមគួរ, ហេតុនេះបានជាគេហៅការនោះជា២ យ៉ាងផ្សាស់ប្តូរគ្នាថា "សែនពន្លៃ" ក៏បាន ថា "បង្កក់ធ្នូប" ក៏បាន ។

អំពីទម្លាក់ជើងក្រាន: កាលបង្កក់ធ្នូបរួចហើយ គេតែងរើជើងក្រានគាំងភ្លើងដាក់ទៅដី ហៅថា "ទម្លាក់ជើងក្រាន" ។ មុនទម្លាក់ជើងក្រាន, គេយកថ្ម ១ ដុំនៅលើជើងក្រានមកសូត្រស្រោចទឹកម្ងាប់, គេដកដែកគោលដែលចោះកណ្តាលជើងក្រាន នឹងដុំថ្មនោះទម្លាក់ទៅដីដំណាលគ្នា, គេកៀបរងើកភ្លើង នឹងកន្ទុយអុសឬកន្ទុយផ្សូងជ្រលក់ទឹកកន្ធរជើង រួចយកកន្ទុយអុសឬកន្ទុយផ្សូង គ្រវាសពីខាងទៅជាក់លើស្រីពន្លៃ, គេយកផ្សូងគូសជើងក្អែកតែង់ប្រជុំចិញ្ចើមខាងដោយមានជំនឿថាកុំឲ្យកើតស្កន្ធ ។

ក្រោយពីពេលសែនពន្លៃ បង្កក់ធ្នូប ទម្លាក់ជើងក្រាន គេអញ្ជើញញាតិសន្តានដែលមកជួយកិច្ចធ្វើទាំងប៉ុន្មានពិសាគោជនាហារ នៅពេលនោះ, រួចគេដូនធ្នូបទៅទីលំនៅវិញជាការបង្ហើយកិច្ចបង្កក់ធ្នូប ។

ការផ្សាយសកម្មភាពនៃក្រមជំនុំទំនៀមទម្លាប់ខ្មែរ ស្តីពីរបៀបធ្វើទន្ទេញតាមប្រពៃណីខ្មែរចប់តែប៉ុណ្ណេះ ។

លោកជុំកទ័រគុណបណ្ឌិតបិយៈសេនៈម៉ាលាលៈសេកៅរៈ

ជាប្រធានពុទ្ធិកសមាគមពិភពលោក ថ្វែងកន្លែងសមាជសាកលលើកទី ២

នៃពុទ្ធសាសនានៅក្រុងតូក្យូ (ប្រទេសជប៉ុន)

(តូក្យូ ២៥ កញ្ញា ១៣ តុលា ១៩៥២)

(ត - ចប់)

មានអ្នកខ្លះពោលថា ការបន្ធូរបន្ថយនូវសព្វាវុធគឺមានសារៈសំខាន់ចំពោះសន្តិភាពក្នុងពិភពលោក ។ បើសភាពបែបដូចនេះគេយល់ថា ការបំបាត់នូវសព្វាវុធ នៃសង្គ្រាមនាំឲ្យបានសន្តិសុខ, តែមានពួកខ្លះយល់ថា សន្តិសុខកើតឡើង ដោយត្រូវជានិរន្តរ៍នូវវិសាលភាព នឹងពលភាពនៃសព្វាវុធក្នុងសង្គ្រាមចប់ទៅ ។ ទាំងអស់នេះមិនអាចយកមកអនុវត្តបានប្រយោជន៍ទេ ។

មានប្រយោជន៍អ្វី បើគេមិនបានរៀនខាងការអប់រំនូវគុណធម៌ ខាងចិត្តដែលអាចដឹកនាំមនុស្សស៊ីវិល្យៃ កុំឲ្យពិឃាដគ្នាទៅវិញទៅមកបាន ។ ពិភពលោកមានសេចក្តីទ្បើយណាយ ជិនឆ្ពន់ នឹងសន្តិសិទសន្តិភាព សន្តិសញ្ញា ហើយនឹងប្រកាសឯកភាជ្យដែលតែងមានការពិឃាដនឹងការអន្តរាយនៃប្រជាពស្តូនឹងប្រទេសជានិរន្តរ៍ ។

ការណីយកិច្ចនៃសាសនា

មានតែសាសនាមួយទេ ដែលអាចធ្វើឲ្យចិត្តងាកបែរកែបាន, មិនមែនសាសនាចាត់ឲ្យប្រព្រឹត្តតាមពិធី តាមទំនៀមទម្លាប់ទេ, តែសាសនាធ្វើដើរកាពម៌ទុស្សឲ្យស្ថិតនៅក្នុងសន្តិភាព ព្រមទាំងសន្តិសុខខាងក្នុងដែលកើតឡើងអំពីការផ្ទេរញាប់ញ័រចិត្តដែលជាធម៌ពិត ។ សាសនាមុនដំបូងបង្អស់ជាបញ្ជាចំពោះបុគ្គល ។ គេមិនអាចប្រែស័ង្គម៌ឲ្យទៅជាសន្តិភាព បើខ្លួនយើងមិនបានប្រែកែគំនិតជាមុន ដោយព្យាយាមខាងសីលធម៌ធំការចរនាចំពោះបុគ្គលិកលក្ខណៈ ។ គេមិនមែនគ្រាន់តែស្រឡាញ់អ្នកដទៃ, តែត្រូវរស់នៅចំពោះខ្លួនឯង ដោយយុត្តិធម៌ គឺអ្នកឬខ្ញុំមិនមែនរង្គាកិច្ចលទេ ដែលរចនាឲ្យបានសន្តិភាព ។

ពួកពុទ្ធសាសនិកជនមានចំនួនច្រើនអស់ មួយភាគច្រើននៃប្រជាពលរដ្ឋច្រើនអស់ កន្លះពិភពលោក យើងត្រូវយល់ការទទួលខុសត្រូវ មានយ៉ាងតិចមួយភាគច្រើនចំពោះសុភមង្គល ហើយនឹងសន្តិភាពពិភពលោកជាការៈលើយើង, នៅប្រទេសស៊ីឡង់, កូមា, ថៃឡង់, លាវ, កម្ពុជា, វៀតណាម, យើងមានរង្គាកិច្ចលអប់រំពុទ្ធសាសនា ដែលមានការណីយកិច្ចដ៏មានប្រយោជន៍ ចំពោះវឿងរ៉ាវកន្លះទ្វីបអាស៊ី ។ បើសន្តិភាពកើតមានឡើងនៅប្រទេសចិន ឬប្រទេសកូរ៉េបូរួមជាឯកភាព ហើយប្រទេសជប៉ុនមានជីវិតរស់ឡើងជាថ្មី ពុទ្ធសាសនិកជននឹងត្រូវមាន

ការណ៍យកចិត្តដ៏សំខាន់ ក្នុងកិច្ចការពិភពលោក ។ បើតាមសម្លឹងហាក់ព
យើងមិនអាចធ្វើអ្វីបានដើម្បីជាហេតុឲ្យកើតសន្តិភាព បើយើងមិនសម្រេច
ខ្លួនយើងថា ត្រូវតែចាប់ផ្តើមតាមផ្លូវធ្នូដ៏ល្អ សុខដុម, ទទឹងលាក់
ច្បាស់ដែលអាចមានអានុភាពផ្សាយទៅកន្លែងយោបាយ នៃប្រទេស
ទាំងឡាយទៅតាមទុក្ខនៃព្រះធម៌ ។ បើសិនណាជាក្រុមយើងខ្លះ
បានទៅកាន់តាប់ការនៅទីកន្លែងសំខាន់ ។ ក្នុងរដ្ឋ ឬមួយយើងទទួល
ខុសត្រូវតែងការរចនាជីវភាពឯទៀត នៅក្នុងប្រទេសយើង ម្តេច
ក៏យើងមិនបំពេញកិច្ចការរបស់យើងទៅតាមផ្លូវព្រះពុទ្ធសាសនា ឯផ្លូវ
ដែលរចនាពិភពលោកឲ្យបានល្អ មិនមែនផ្លូវដែលយើងយើញនៅ
ប្រទេសដែលពិយាជគ្នាទៅវិញទៅមកនេះឡើយ.។ បើក្នុងចំណោមអរិយ
ដែលប្រវត្តិសាស្ត្របានបង្ហាត់បង្រៀនពីអតីតកាល . យើងអាចថាបាន
ព្រះពុទ្ធសាសនាមិនសមយកមកអប់រំក្នុងពិភពលោក ទំនើបទុកជាយើង
ប្រកាសជាមុន នូវទុក្ខលាភនៃធម៌ជារបស់យើង ។ យើងអាចស្វែង
រកយើញនូវផ្លូវដែលយើងត្រូវការតែចំពោះតែព្រះបរមពុទ្ធាទេ ។
យើងមិនអាចទៅស្វែងរកអ្នកទស្សនវិទូនយោបាយឯទៀត ឲ្យចំណាន
ជាងព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ ។ តាំងពី ១ ៣០០ ឆ្នាំមក
ហើយ មានព្រះអគ្គមហាសេដ្ឋីមួយ ១ អង្គនាម ស្តូតូកុ បានឲ្យទុក្ខក្នុង
រដ្ឋធម្មនុញ្ញ មានដប់ប្រាំពីរមាត្រាថា: "អ្វីដែលវិសេសជាងគេ គឺមិន

ត្រូវពោលពាក្យផ្ដុំយទន្ធឹងអ្នកដទៃ" ។ ពាក្យនេះគឺពាក្យមានតំសួលចេញពីព្រះបរមពុទ្ធោវាទដែលទ្រង់ទេសនាតាំងពី ២.០០០ ឆ្នាំមុន ។

"ពៀរមិនដែលឈ្នះ ដោយការចងពៀរឡើយ គឺឈ្នះដោយការស្រឡាញ់ (ការមិនចងពៀរ) ការជោគជ័យនាំឲ្យកើតពៀរ ព្រោះអ្នកបរាជ័យទទួលសេចក្ដីទុក្ខលំបាក អ្នកណាមានចិត្តសប្បុរសប្រែទូរផ្ទុសវាវិញ ចំពោះអ្នកដែលបានទទួលជាប ដូចជារោយអំបិលទៅលើដំបៅគឺការខុសនោះ" ។

ការណាំយកិច្ចរបស់យើង

គោលការបច្ចុប្បន្ននៃមនុស្សជាតិ ដែលនាំឲ្យទុក្ខវាតដល់ទ្រង់នៃមនុស្សជាតិនេះ ត្រូវយើងទាំងអស់គ្នា ព្យាយាមការពារជាយ៉ាងម៉ឺងម៉ាត់ដោយប្រើប្រាជ្ញា តែដោយសង្ឃឹមយ៉ាងធ្ងន់ទូលាយតទៅអនាគត ។ កុំឲ្យយើងកាន់ច្រឡំចំពោះសេចក្ដីលំបាកដែលរង់ចាំយើង តែត្រូវយើងធ្វើកិច្ចក្សាហានដោយប្រតិបត្តិតាមព្រះពុទ្ធោវាទ គេឈ្នះទុក្ខបានដោយការព្យាយាមប្រកបដោយគតិបណ្ឌិត (សជាតិបញ្ញា) ដូចជាការខ្វះខ្វែងជាផ្លូវនៃដីវភាព នោះប្រហែលជាសេចក្ដីមិនប្រមាទជាផ្លូវមិនស្លាប់ ហើយសេចក្ដីប្រមាទជាផ្លូវនៃសេចក្ដីស្លាប់ ។ បើតាមព្រះសម្មាសម្ពុទ្ធទ្រង់ទូន្មានថា ពិភពលោកគឺធ្វើសម្រាប់មនុស្ស ។ សេចក្ដីសប្បាយ (សុខ) ព្រមទាំងសេចក្ដីទុក្ខរបស់មនុស្ស គឺជាលទ្ធផលបានមកពីសកម្មភាពនៃ

មនុស្ស ហើយបើមនុស្សនោះមានធន្លុះដ៏មាំ ធ្វើការដើម្បីសុភមង្គល ហើយនឹងសន្តិសុខ គ្មានព្រះអាទិទេពឬអារក្សណា អាចមកឃាត់ហាមមិនឲ្យទៅកាន់វត្តបំណងនោះឡើយ ។ ពេលវេលាគឺឥឡូវនេះ ហើយស្ថានទីគឺខ្លួនយើង ។ គឺជីវភាពរបស់យើង ព្រមទាំងជីវភាពនៃគ្រួសាររបស់យើងដែលយើងត្រូវធ្វើជាដំបូង ។ កិច្ចការប្រញាប់ត្រូវតែធ្វើខានមិនបាន ។ គ្រប់ទីកន្លែង, នៅក្នុងជីវភាពសាធារណៈឬក្នុងជីវភាពឯកជន គេឃើញតែទំនៀមដ៏លាមក ហើយនឹងផលនៃទុច្ចរិត ។ ការប្រព្រឹត្តិទុច្ចរិតមាននៅគ្រប់ផែនការណ៍នៃសកម្មភាពពិភពលោក ។ ត្រូវយើងនីមួយៗ បំពេញភារកិច្ចគ្រប់ៗគ្នា ចំពោះការតស៊ូនឹងសភាពដ៏អាក្រក់បែបនេះ ។ យើងជាមនុស្សចង់បានសន្តិសុខ, តែបើតាមន័យមួយយ៉ាងទៀត យើងជាមនុស្សចង់ធ្វើសង្គ្រាមដែរ ។ ព្រះសម្មាសម្ពុទ្ធទ្រង់តាស់ទេសនាថា: "យើងទាំងអស់គ្នាជាមេទ័ព គឺមេទ័ពសម្រាប់តស៊ូនឹងលោភៈ, ភគៈ, ព្យាបាទ, ថ្នាំបៈ, ឆន្ទតណ្ហា, អវិជ្ជា ។ យើងត្រូវតែស៊ូនឹងសេចក្តីក្រហើយនឹងទុព្ភិក្ខភ័យ, សេចក្តីរំលោភហើយនឹងជម្លឿសុស, សេចក្តីមិនស្មោះស្ម័គ្រ ព្រមទាំងកូតកវកុហក ។ ចំពោះការតាំងចិត្តជាដាច់ខាតដែលអាចឈ្នះទូវេបសត្តគ្រប់យ៉ាង, យើងត្រូវតែតស៊ូដោយធ្វើសង្គ្រាមដើម្បីយុត្តិធម៌, កន្លងមក, ជាមេទ័ពពិត, ស្រោចឈ្លួនដោយអាវដែក

មានព្រហ្មវិហារ, ជិះលើអាជានេយ្យថាមភាព ព្រមទាំងកាន់ព្រះទ័នថ្នាក់ជ្ញានៅដៃម្ខាង, ឯចំណែកដៃម្ខាងកាន់ទង់ទិយ្យានិកធម្ម ហើយយកសច្ចធម្មជាសង្រែកសង្គ្រាម ។


ត្រូវលោកអ្នកនីមួយៗ បំពេញភារណីយកិច្ចនេះសព្វៗខ្លួន ។ បើយើងមិនអាចបំពេញបាន, យើងត្រូវធ្វើបើយ៉ាងតិចគ្រាន់តែជួយយកឫជាបម្រមៅជាក់លើគ្រឹះហា ដែលមានមេជាងចំណាន. បច្ចុប្បន្នទីអនាគត បម្រុងយកដៃទៅរៀបចំដើម្បីទីឆ្ងាយព្រះវិហារ ដែលជាទុគ្គហនិមិត្ត តើតកងមនោទ្វាររបស់យើង ពិតពលោកមួយដែលមានជីវសត្វរស់នៅប្រកបដោយសុភមង្គលព្រមទាំងសន្តិសុខ, ស្រួលសប្បាយក្នុងសន្តិភាពជាអនន្តកាល, ជីវសត្វខ្សោយទន់ខ្ចាំង ជីវសត្វធំទីតូចដែលគ្មានអ្នកណាឡកចំអក ឬអ្នកណាពាក្យចចេសសោះឡើយ, តែជីវសត្វទាំងអស់ប្រកបដោយព្រហ្មវិហារ ដែលមានអាទុភាពផ្សាយទៅកងចក្រវាឡទាំងអស់ ទាំងកំពស់, ជម្រៅទីទទឹង, ព្រហ្មវិហារជាអនន្តមាត្រគ្មានស្អប់, គ្មានការគំនុំគុំគួន ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានទេសនាបញ្ជាក់យើងថា សុភមង្គលដ៏ធំ (ព្រះនិព្វាន) អាចរកបានក្នុងពេលឥឡូវនេះ មិនមែនទៅក្នុងជីវភាពអនាគត, ពីក្រោយហើយពីលើពពកទេ ។ ត្រូវតែយើងព្យាយាមស្វែងរកព្រះនិព្វាននោះដោយខ្លួនឯង ។

យើងជាមនុស្សនៅលើផែនដី, យើងមានរូបធាតុនៃមហាមេឃដែរ ។ យើងមានច្រើន ដែលយើងត្រូវការនោះទៀត យើងមិនត្រូវការអ្វីដើម្បីទិញស្អាងផណ្តើរដែលចូលទៅដល់អសេក្ខបុគ្គល, គ្មានថ្លៃវ៉ាអ្វីឡើយ យកមកធ្វើកម្រាល. គ្មានឈើ (សែជ) យកមកធ្វើផ្ទោង · ហើយទំនៃពិតានៃនិម្មិតជាអនន្តកាលនៃមនុស្ស ។ គឺនៅទីនេះតាមផ្លូវសព្វថ្ងៃ, នៅទីនេះ តាមផ្លូវដីវភាពសាមញ្ញ ដែលត្រូវស្អាងនូវមេឃមួយ . . . គ្រឿងទ្រូសម្ភារៈវិសេស គឺយើងដែលស្អាងអនន្តនាមកង់កាល ។

សូមឲ្យព្រះពុទ្ធព្រះសម្មាសម្ពុទ្ធ, ព្រះធម្មប្រកបដោយអភិជនភាព ព្រះសង្ឃសាវ័កព្រះបរមគ្រូជាអម្ចាស់ ស្ថិតនៅពីលើយើងទាំងអស់គ្នា ។ សូមសេចក្តីសុខកើតមានឡើងចំពោះសត្វលោកទាំងអស់ ។

ចប់



ភ្នំពេញសន្ទេយ៍

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៥ ខែវិច្ឆិកា លេខ ១១

ព.ស. ២៤៩៦ — គ.ស. ១៩៥៣



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— នវឋករណធម៌	ព្រះមហា យ៉ែត-ទ្រុសន៌.....	៨០៣
— យក្សប្រែតមានមែនឬទេ	លោក ប៊ូ-ប៊ូ	៨២៣
ផ្នែកអក្សរសាស្ត្រ		
— ការបណ្តុះនិស្ស័យ (តមក).....	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៊ម....	៨៣០
— រឿងសាមកុក (តមក).....	ឧកញ៉ា ន្ហូ-កន.....	៨៣៥
— រឿងអាវ៌ក្សថ្លែងរឿងម្តែប្រាំ (តមក)...	លោក វ៉ាយ-ប៊ុក	៨៣៩
— រឿងចិញ្ចៀនទិព្យ (តមក).....	អ្នកស្រីសារយ៉ាន	៨៤៩
— សកម្មភាពនៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរ		
មរិយាយពីពាក្យ វ៉ែន	លោកចាប-ពិន	៨៥៣
កំណាត់ទឹតប្រវត្តិការណ៍		
— ពិធីប្រឡងសិស្សសាលាបាលីរងនៅដែន កូសាំងស៊ីន ភាគខាងត្បូង	ព្រះញាណកោសល ញាណ-ឈីន	៨៦៦

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដារ ១៨២.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

		Page
PARTIE RELIGIEUSE		
— Nathakaranadharma	brah maha YAT-TRALON. . .	803
— Les Démons infernaux . . .	M. BOU-PO	823
PARTIE LITTERAIRE		
— Education morale (suite) . .	Brah Maha PEUNG-PAM . . .	830
— Histoire de SAMKOK (suite) . .	Oknha NOU-KAN	835
— Les vingt cinq récits du Mauvais Génie (suite)	M. RAY-BUC	839
— La bague magique (suite) . . .	Mme SARIS-YANN	849
— Activité de la Commission des Mœurs et Coutumes (Varman)	M. CHAP-PIN	853
NOTES ET CHRONIQUES		
— Examen de sortie des Ecoles Elementaires de Pali en cochinchine	Ven. NHEAN-CHHŒUN . . .	866

Prix d'abonnement annuel (comprenant 12 numéros): 192$00

ព្រះមហា យ៉ត-ទ្រលង់ វត្តលង្កា ក្រុងភ្នំពេញ

ទេសនាជាក់វិទ្យុប្រទេសកម្ពុជា កាលពីថ្ងៃ១៤កើត ខែដើរ្ឋ ឆ្នាំជូរឯកសក៌
ព.ស.២៤៩ (១១-៦-៤៩) ។

ឥមេ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

កិរិយានមស្សការ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគ អង្គនោះ ព្រះអង្គជាព្រះអរហន្តត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង (ព្រមទាំងព្រះធម៌នឹងព្រះអរិយសង្ឃដោយសេចក្តីគោរព) ។

វេលានេះ អាត្មាភាពសូមសំដែងអំពីនាថករណធម៌ គឺធម៌ជាគ្រឿងធ្វើទ្បូវទីពឹង ជូនជាសណ្តាប់នៃសាធុសប្បុរសទាំងឡាយ ។ ឯនាថករណធម៌នោះ ១០ យ៉ាង គឺ:

១_ សីល *រក្សាកាយវាចាឲ្យបរិសុទ្ធ,*

២_ ពាហុសច្ចៈ *ភាពជាបុគ្គលបានស្តាប់ បានរៀនពុទ្ធវចនៈច្រើន,*

៣_ កល្យាណមិត្តតា *ភាពជាបុគ្គលមានមិត្តសំឡាញ់ល្អ,*

៤_ សោរេយ្យតា *ភាពជាបុគ្គលងាយប្រដៅ,*

៥_ កិការណាយេសុ ទក្ខិណា ភាពជាបុគ្គលមានសេចក្តីខ្នះខ្នែងក្នុងកិច្ចធ្វើរបស់មិត្តអ្នកប្រតិត្តធម៌ជាមួយគ្នា,

៦_ ធម្មកាមតា ភាពជាបុគ្គលស្រឡាញ់ធម៌ដែលប្រពៃ,

៧_ វីរិយៈ ការព្យាយាមលះអំពើអាក្រក់ ហើយប្រតិត្តតែអំពើល្អ,

៨_ សន្តោសៈ ការត្រេកអរចំពោះវត្ថុដែលជារបស់ខ្លួនតាមមានតាមបាន,

៩_ សតិ ការរលឹកឃើញកិច្ចការដែលធ្លាហើយនឹងពាក្យសំដីដែលនិយាយហើយ,

១០_ បញ្ញា ការដឹងច្បាស់ក្នុងកងសង្ខារតាមសភាពពិតមែន ។

ធម្មតាមនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ នឹងនៅតែម្នាក់ឯងមិនបាន, ដូចក្មេង ៗ ដែលទើបនឹងកើតមក តោងអាស្រ័យនឹងចាស់ ៗ មានមាតាបិតាជាដើម ឲ្យជួយចិញ្ចឹមជីវិតផងទើបរស់, កាលបើធំបន្តិចឡើងហើយ ក៏នៅតែអាស្រ័យនឹងអ្នកដទៃទៀតដោយបំដាប់ដូចអាស្រ័យនឹងគ្រូអាចារ្យឲ្យជួយបង្ហាត់បង្ហាញវិជ្ជាចំណេះ នឹងសេចក្តីប្រតិត្តជាដើម,លុះដល់ពេញកំឡោះក្រមុំ ដែលជាពេលត្រូវរកទ្រព្យសម្រាប់ចិញ្ចឹមជីវិតនោះសោត ក៏តោងពឹងពាក់អ្នកនេះខ្លះ អ្នកនោះខ្លះ

ជានសេចក្តីថា មនុស្សដែលកើតមកកន្លងលោក តោងពឹងអ្នកដទៃ ដើម្បីប្រយោជន៍លោកិយសម្បត្តិទើបបាន, តែនឹងពឹងដើម្បីលោកុត្តរសម្បត្តិ គឺមគ្គផលព្រះនិព្វានផង នោះមិនបានឡើយ ។

សេចក្តីនេះសមដូចព្រះពុទ្ធភាសិតក្នុងព្រះធម្មបទថា:

អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា
អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ

សេចក្តីថា ខ្លួនឯងជាទីពឹងរបស់ខ្លួន អ្នកដទៃដូចម្តេចឡើយនឹងជាទីពឹងបាន ព្រោះបុគ្គលដែលមានខ្លួនហ្វឹកហ្វឺនល្អហើយ តែងបានទៅទីពឹងដែលគេរកបានដោយកម្រ ។

សម្តេចព្រះទេសពលញ្ញាណបវរមេគ្គជាម្ចាស់ ទ្រង់គ្រាស់ទេសនាប្រៀនប្រដៅពុទ្ធបរិសទ្យឲ្យចំប្រឹងធ្វើសេចក្តីប្រតិបត្តិ យកសម្បត្តិសួគ៌និងសម្បត្តិព្រះនិព្វាន ចំពោះខ្លួនឯងពល់ៗគ្នា មិនឲ្យអាងអ្នកដទៃក្រៅអំពីខ្លួនឯងឡើយ ព្រោះបណ្តាមនុស្សដែលនឹងបានទៅកើតស្ថានសួគ៌ នឹងធ្វើមគ្គផលឲ្យកើតមានជាក់ច្បាស់ប្រាកដឡើងបាននោះ ក៏ព្រោះតែគេខំប្រឹងកសាងសន្សំបុណ្យកុសល ដម្កល់កន្លងខ្លួនចំពោះៗខ្លួនរបស់គេឲ្យសម្បូណ៌ឡើង, មិនមែនបានមកអំពីអ្នកដទៃឡើយ ។ បើជនណាបានហ្វឹកហ្វឺនខ្លួនឯងឲ្យល្អប្រពៃ គឺឲ្យមានកាយវាចាចិត្តសុចរិតល្អបរិសុទ្ធគ្មានពុតកុតហើយ ជននោះឯងតែងបានទៅទីពឹងដ៏ខ្ពង់ខ្ពស់ គឺបាន

សំរេចព្រះអរហត្តផល ដែលជាគុណវិសេសយ៉ាងខ្ពស់បំផុតក្នុងព្រះពុទ្ធ-សាសនាដែលគេរកបានដោយកម្រៃក្រៃពេក ។

ត្រង់ពាក្យថា: "មនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ សុទ្ធតែត្រូវពឹងពាកគ្នាទៅវិញទៅមក ទើបអាចប្រព្រឹត្តទៅបាន" នោះក៏ពិតមែនហើយ ប៉ុន្តែពឹងគ្នាបានតែត្រឹមលោកិយសម្បត្តិប៉ុណ្ណោះ ទឹងពឹងដួទៅទាំងលោកុត្តរសម្បត្តិ គឺមគ្គផលព្រះនិព្វានផងនោះមិនបានទេ, ចំណែកខាងលោកុត្តរសម្បត្តិនោះត្រូវតែរកចំពោះខ្លួនទើបបាន តែបើទុកជាដូច្នោះ ក៏គង់តែអាស្រ័យគ្រូអាចារ្យមានព្រះសម្មាសម្ពុទ្ធជាដើម ឲ្យទ្រង់សំដែងណែនាំពន្យល់ជាមុនដែរ រៀរលែងតែព្រះសម្មាសម្ពុទ្ធ ១ ព្រះអង្គប៉ុណ្ណោះ ទើបទ្រង់ត្រាស់ដឹងឯងហើយទ្រង់ណែនាំអ្នកដទៃឲ្យត្រាស់ដឹងផង, ប៉ុន្តែការណែនាំនោះ ក៏បានចំពោះតែនរណាដែលមានវាសនាបារមី មិនមែនបានទាំងឥតវាសនាផងទេ, សូម្បីតែសម្តេចព្រះបរមគ្រូជាម្ចាស់ដែលប្រកាសប្រដៅថាជាទីពឹងពំនាក់របស់សត្វលោក មិនមាននរណាជាងព្រះអង្គនោះ ក៏ទ្រង់ជាទីពឹងចំពោះតែសត្វណាដែលមានកម្ពស់គួរឲ្យព្រះអង្គណែនាំបានប៉ុណ្ណោះ, ព្រះអង្គទ្រង់ពឹងណែនាំបានដួទៅទាំងមនុស្សដែលជាអកម្ពុបុគ្គលនោះក៏ទេ ។ សេចក្តីនេះគួរយើញដូចជាទេវទត្តដែលជាអកម្ពុបុគ្គលជាដើម, សូម្បីចូលមកបួសក្នុងព្រះពុទ្ធសាសនាទឹងគេដែរ តែជាមនុស្សប្រព្រឹត្តអាក្រក់ច្រើនពេកណាស់, ព្រះសម្មាសម្ពុទ្ធជា

ម្ចាស់ក៏មិនអាចធ្វើមនុស្សមានសភាពដូច្នោះ ឲ្យសំរេចមគ្គផលដូចជាបុគ្គលឯទៀតបានទេ. ព្រោះមិនមានធម៌ជាទីពឹងចំពោះខ្លួនឯងផង លុះតែនរណាដែលជាបុគ្គលមានកំពូលធ្លាប់ធ្វើបុណ្យកុសលដម្កល់ទុកមកពីមុនៗដែលហៅថា ពន្ធុរនេយ្យសត្វ ជាផៅពង្សគួរឲ្យព្រះអង្គជួយទ្រាន់បាន, ទើបអាចជួយអប់រំនិស្ស័យនៃជនមានសភាពដូច្នោះ ឲ្យសំរេចមគ្គផលសមគួរតាមឧបនិស្ស័យរបស់គេ ។

ចំណែកឯសម្តេចព្រះអនាវរណញ្ញាណ ដែលទ្រង់ប្រទានព្រះធម្មទេសនាក៏គ្រាន់តែប្រៀបដូចអ្នកបង្ហាញផ្លូវប៉ុណ្ណោះ ត្រង់ដើរតាមគន្លងនោះកើតឬទេ ក៏ស្រេចនៅលើអ្នកដើរ សេចក្តីនេះសមដូចជាពុទ្ធភាសិតក្នុងព្រះធម្មបទថា:

តុម្ហេហិ កិច្ចំ អាតប្បំ អក្ខាតារោ តថាគតា
បដិបន្នា បមោក្ខន្តិ ឈាយិនោ មារពន្ធនា

សេចក្តីថា: អ្នកទាំងឡាយត្រូវធ្វើសេចក្តីព្យាយាមចំពោះខ្លួនឯងចុះ ព្រះតថាគតទាំងឡាយគ្រាន់តែជាអ្នកប្រាប់ផ្លូវឲ្យទេ, បើពួកជនណាបានដើរតឹបានរំពឹងពិនិត្យធ្វើតាមហើយ ជនទាំងនោះមុខជានឹងបានរួចចាកចំណងគឺកិលេសមារមិនខានឡើយ ។

សេចក្តីប្រតិបត្តិដែលជាហេតុឲ្យដល់ទីរំលត់ទុក្ខប្រៀបដូចជាផ្លូវ, ជនដែលជាអ្នកប្រតិបត្តិប្រៀបដូចជាអ្នកដំណើរ, ព្រះពុទ្ធជាម្ចាស់ដែលត្រាស់

ទេសនាប្រដៅសត្វច្រៀបដូចជាអ្នកបង្ហាញផ្លូវក្នុងលោកនេះ, កាលបានបង្ហាញអ្នកណាហើយ បើអ្នកនោះគេមិនដើរ អ្នកបង្ហាញនោះនឹងដើរជំនួសគេក៏ទេដែរ ត្រង់ដើរកើតឬមិនកើតនោះក៏ស្រេចទៅលើអ្នកដំណើរ បើអ្នកដំណើរនោះគេដើរទៅ ខ្លួនគេទើបបានដល់ទីដែលគេប្ដូរថា បើគេមិនដើរក៏មិនបានដល់ ។ ព្រោះហេតុនេះហើយ បានជាសម្ដេចព្រះមុនិន្ទសាស្ដាចារ្យជាម្ចាស់ត្រាស់ទេសនាថា: ខ្លួនឯងជាទីពឹងចំពោះខ្លួន អ្នកដទៃដូចម្ដេចឡើយ ទើងជាទីពឹងបាន ។ ជាមសេចក្ដីថា: ខ្លួនរបស់ខ្លួនត្រូវប្រឹងជួយខ្លួនឯងផង, ទើបអ្នកឯទៀតគេជួយបាន បើខ្លួនឯងមិនប្រឹងផង់ទេ, អាងតែគេ គេក៏ជួយមិនកើត ។ មួយទៀតគួរឃើញដូចអ្នកដែលឡើងដើមឈើខ្ពស់ ។ មានដើមត្នោតជាដើម ហើយមិនរបូតធ្លាក់នោះក៏ព្រោះអាស្រ័យកម្លាំងខ្លួនឯងផ្សំផង់ទើបឡើងរួច ទើងបណ្ដាយថាស្រេចទៅលើដើមឈើទាំងអស់តែម្ដងក៏មិនបាន ។

ហេតុនេះ ពុទ្ធបរិសទ្យដែលប្ដូរថាចង់បានសេចក្ដីសុខ ក្នុងជាតិនេះទើងជាតិខាងមុខទើងសេចក្ដីសុខយ៉ាងខ្ពស់បំផុតគឺព្រះនិព្វាននោះ ត្រូវតែខំកសាងសន្សំបុណ្យកុសលចំពោះ ។ ខ្លួន ព្រោះសម្បត្តិសួគ៌ទើងសម្បត្តិព្រះនិព្វានដែលបុគ្គលទើងបាន ក៏សុទ្ធតែបានអំពីសេចក្ដីប្រតិបត្តិរបស់ខ្លួនឯងទាំងអស់ មិនដែលបានមកអំពីអ្នកដទៃឲ្យទេ ។ ម្យ៉ាងទៀត សាធុសប្បុរសទាំងឡាយដែលជាអ្នកស្រឡាញ់ខ្លួន ត្រូវមានធម៌ជាទីពឹង

ចំពោះខ្លួនពស់ ។ ខ្លួន ព្រោះអ្នកដែលមានធម៌ជាទីពឹងចំពោះខ្លួន តែងនៅជាសុខគ្មានទុក្ខលំបាកឡើយ ។ សេចក្តីនេះសមដូចជាពុទ្ធភាសិត ដែលសម្តេចព្រះកែវន្តមុនីបរមគ្រូជាម្ចាស់ត្រាស់ទេសនា ទុកក្នុងនាថករណធម្មសូត្រ គម្ពីរឥទ្ធិយនិកាយ ចុងដីកវគ្គថា: សនាថា ភិក្ខវេ វិហរថ មា អនាថា ទុក្ខំ ភិក្ខវេ អនាថោ វិហរតិ ដូច្នេះជាដើម ។

សេចក្តីថា: ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរជាបុគ្គលមានទីពឹងសិនហើយសឹមនៅចុះ កុំជាបុគ្គលឥតទីពឹងឡើយ ព្រោះបុគ្គលឥតទីពឹងតែងនៅជាទុក្ខ ។

នាថករណធម៌ គឺធម៌ធ្វើទីពឹងរបស់អ្នកប្រតិបត្តិធម៌នេះ ដំបូងឡើយ សម្តេចព្រះអរហំសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ទេសនា ដើម្បីជាវត្តប្រតិបត្តិរបស់អ្នកបួសទេ, ព្រោះបណ្តាពុទ្ធបរិសទ្យទាំង ៤ ពួកនោះ មានពួកភិក្ខុនេះឯងជាប្រមុខរបស់បរិស័ទ្យទាំងអស់ លោកប្រែនបានស្តាប់ធម៌មុនគេ តែបើទុកជាដូច្នោះ គ្រហស្ថនឹងអនុលោមប្រតិបត្តិតាមផងបានឥតមានខាស់ទេ សឹងបានសម្រេចប្រយោជន៍គ្រប់គ្នា ។ រីឯនេះអាត្មាភាពនឹងពណ៌នា ឲ្យសមគួរដល់សេចក្តីប្រតិបត្តិទាំងបព្វជិត និងគ្រហស្ថដូចតទៅនេះ ៖

๑ – ការរក្សាកាយកំចាត ឲ្យបរិសុទ្ធ លោកហៅថា សីល សីលនេះបើសំដែងដោយចរិយាយ បានដល់សិក្ខាបទដែលបុគ្គលសមាទាន

ហើយ មានវិតិចេតនាវៀរចាកចាបដោយកាយទ្វីន៍ផ្ទា មានវៀរចាក
បញ្ចវេរភាដើម ។

សីលនេះ ជាធម៌ធ្វើទីពឹងរបស់អ្នកដែលរក្សា គឺអាចការពារនូវ
អំពើខូចកាចអាក្រក់តាមកាយទ្វីន៍ផ្ទាមិនឲ្យកើតឡើងបាន ។ បុគ្គលដែល
ទ្វីន៍រក្សាសីលបរិសុទ្ធ តែងបានសេចក្តីសុខយើញាតន់ក្នែក គឺរួចពាក
ទោសដែលមានក្នុងបច្ចុប្បន្នមានរាជអាជ្ញាភាដើម, តាំងបានជាទីគោរព
រាប់អានស្រឡាញ់របស់ជនាទុជន ហើយទ្វីន៍ជាមនុស្សក្លៀវក្លាក្នុង
កណ្តាលប្រជុំបរិសទ្យ ។ ម្យ៉ាងទៀតសីលនេះ តែងបានជាបច្ច័យនៃ
ការប្រតិបត្តិធម៌ជាន់ខ្ពស់ ។ ទៅដោយលំដាប់ផង ។ ធម្មតាបុគ្គលដែល
ប្រតិត្តតាមតាក្យប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដរាបដល់បាន
សំរេចមគ្គទ្វីន៍ផលយ៉ាងខ្ពស់ គឺរហូតដល់លះកិលេសឲ្យអស់ទៅ ដែល
ហៅថាព្រះខីណាស្រពបាននោះ ក៏ព្រោះតែប្រតិត្តធម៌ជាន់តាប ៗ ជា
ដំបូងសិន ទើបសំរេចទៅបាន គួរយើញដូចអ្នកឡើងទៅលើខ្ពស់ ។
ក៏ព្រោះតែអាស្រ័យទ្វីន៍ត្រឹងមានជណ្តើរភាដើម តាំងពីជាន់តាប ៗឡើង
ទៅជាប្តាក់ ។ ទើបទៅដល់ទីដែលខ្លួនប្រាថ្នាបាន បើមិនដូច្នោះទេ ក៏ទៅ
មិនដល់ឡើយ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ការដែលប្រតិបត្តិ
ធម៌វិន័យក្នុងព្រះពុទ្ធសាសនាក៏មានឧបមេយ្យយ៉ាងនោះដែរ គឺសីលនេះ
ឯងតែងជាទីដម្កល់នៃការកុសលជាន់ដំបូងសំរាប់អ្នកដែលប្រតិបត្តិ ត្រូវ

បំពេញឲ្យគ្រប់គ្រាន់ជាមុនសិន, ហើយសិមណានឡើងទៅរកសមាធិ
នឹងបញ្ញាជាលំដាប់ៗទៅ ដ៏ពេជដល់ធ្វើទុក្ខឲ្យដល់នូវទីរលត់ទុក្ខ, គឺព្រះ
និព្វានបាន ។ ព្រោះហេតុនោះ សីលទេបលោកចាត់ជាធម៌ធ្វើទីពឹងខាង
ដើមបំផុត ។

๒- ឯការដែលបុគ្គលនឹងរក្សាសីលនោះបាន, ក៏តោងអាស្រ័យ
នឹងការស្តាប់ការរៀនធម៌ឲ្យចេះដឹងស្គាល់ទុសត្រូវល្អអាក្រក់ ឲ្យគ្រាស់
ត្រែលជាមុនសិន ទើបអាចប្រព្រឹត្តទៅបាន ដោយហេតុនេះ បាន
ជាសម្តេចព្រះអានន្ទរណញ្ញាណជាម្ចាស់ទ្រង់លើកយក ពាហុសច្ចៈ
(ការជាបុគ្គលបានស្តាប់ ហ្មានរៀនទន្ទេញពុទ្ធវចនៈចេះចាំច្រើនឡើង)
សំដែងថាជាធម៌ធ្វើទីពឹង គំរប់ពីរ ។ ឯគុណធម៌ពាហុសច្ចៈនេះបើមានកង
សន្ធានៃបុគ្គលណាហើយ តែងធ្វើបុគ្គលនោះឲ្យជាមនុស្សចេះដឹងនឹង
ចូលចិត្តហេតុផលដោយច្បាស់លាស់, ជាគ្រឿងដឹកនាំឲ្យប្រព្រឹត្តត្រឹម
ត្រូវ, នឹងនាំឲ្យបានសេចក្តីសុខទាំងជាតិនេះនឹងជាតិខាងមុខសមតាម
ប្រាថ្នា, មិនតែប៉ុណ្ណោះសោត តែងនាំឲ្យបានជាទីពុំនាក់អាស្រ័យកិក្ខុ
សាមណេរនឹងឧបាសកឧបាសិកាថែមទៀតផង ។ រឿងនេះគួរឃើញ
ដូចព្រះអានន្ទត្ថេរដែលជាអគ្គពហុស្សុតលោកបានធ្វើបឋមសង្គាយនារៀប
រៀងព្រះត្រៃបិដកពុទ្ធវចនៈ ធ្វើឲ្យព្រះពុទ្ធសាសនាផ្សាយទូលាយឡើង
ទុកឲ្យជាប្រយោជន៍ដល់ពុទ្ធបរិសទ្យ ជនដែលកើតមកខាងក្រោយ ក៏បាន

នាំគ្នារៀនសូត្រចេះដឹងនឹងចូលចិត្តប្រតិបត្តិតាមដោយសារលោក ដរាបដល់មកសព្វថ្ងៃនេះ ទាំងនេះក៏ដោយអំណាចលោកបានរៀនបានស្តាប់ពុទ្ធវចនៈ ចេះដឹងច្រើនជាដើមហេតុ ។ ព្រោះហេតុដូចពោលមកនេះ ពាហុសច្ចៈ (ភាពជាបុគ្គលបានស្តាប់បានរៀនពុទ្ធវចនៈចេះដឹងច្រើន) នេះឯងទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ពីរ ។

៣- ឯការដែលស្តាប់នឹងរៀនពុទ្ធវចនៈឲ្យបានចេះដឹងច្រើននោះ សោតក៏អាស្រ័យដោយការចូលទៅគប់ប្រសព្វ នឹងកល្យាណជនជាអ្នកប្រាជ្ញ ឲ្យលោកបង្ហាត់បង្ហាញផ្លូវខុសនឹងត្រូវជាគោលចារិកសិន ទើបសម្រេចទៅបាន ព្រោះហេតុដូច្នេះបានជាព្រះសក្យមុនីបរមគ្រូជាម្ចាស់ទ្រង់លើកយក កល្យាណមិត្តតា (ភាពជាបុគ្គលមានមិត្តសំឡាញ់ល្អ) ឡើងសំដែងថាជាធម៌ធ្វើទីពឹង គំរប់បី ។ ឯគុណធម៌នេះជាគ្រឿងសំខាន់ ក្នុងការយឹតយោងសណ្តោងបុគ្គលឲ្យប្រព្រឹត្តល្អត្រឹមត្រូវ ព្រោះតាមធម្មតាមិត្តសំឡាញ់រមែងដឹកនាំអ្នកដែលគប់រកឲ្យប្រព្រឹត្តល្អនឹងប្រព្រឹត្តអាក្រក់ទៅតាមគ្នាដោយឆាប់រហ័ស គប់នឹងពាល ។ តែងនាំឲ្យធ្វើទុច្ចរិត គប់នឹងបណ្ឌិត។ តែងនាំឲ្យធ្វើត្រឹមត្រូវល្អ ដូចសំពត់សតែងជិតពណ៌ទៅតាមទឹកជ្រលក់ ទោះបីសំពត់នោះស្អាតដូចម្តេចក៏ដោយ ឲ្យតែមកអាស្រ័យនឹងទឹកជ្រលក់។ ក៏តែងនាំឲ្យផ្លាស់សម្បុរទៅតាមទឹកជ្រលក់នោះ។ សេចក្តីនេះមានគួរនាដូចម្តេចមិញ ការដែលគប់នឹងមិត្តសំ-

ឡាញ់ក៏ដូច្នោះដែរ, ទោះបីនរណាច្រឹត្តល្អមកពីដើមក៏ដោយ ឲ្យតែមកគប់ប្រសប់នឹងពាលវិញ ។ ក៏មុខជានឹងក្លាយនិស្ស័យល្អនោះបាត់ទៅត្រឡប់កើតនិស្ស័យអាក្រក់ឡើងជាថ្មី ។ សេចក្តីនេះ គួរឃើញដូចរឿងអជាតសត្តុពជកុមារ ព្រោះតែយកទេវទត្តជាមិត្ត បានជាផ្តាច់ជីវិតព្រះបាទពិម្ពិសារជាព្រះបិតា ។ ហេតុដូច្នេះ បានជាសម្តេចព្រះលោកុត្តមាចារ្យជាម្ចាស់ ត្រាស់ទេសនាប្រដៅប្រដុំជនឲ្យលះបង់ការសេពគប់នឹងជនពាល ឲ្យស្និទ្ធស្នាលតែនឹងជនជាបណ្ឌិត ព្រោះបណ្ឌិតនោះបើនរណាគប់រកហើយ តែងធ្វើអ្នកនោះឲ្យសំរេចប្រយោជន៍ទាំងឥតលោកនឹងបរលោក ហើយនឹងប្រយោជន៍ដ៏ប្រសើរបំផុតគឺព្រះនិព្វាន ។ ព្រោះហេតុដូច្នេះ កល្យាណមិត្តតា (ភាពជាបុគ្គលមានមិត្តសំឡាញ់ល្អ) ទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ ៣ ។

៤ - ឯការដែលគប់ប្រសប់នឹងអ្នកប្រាជ្ញនោះ លោកពន្យល់ថាជាឫសគល់នៃសេចក្តីច្រឹត្តល្អក្រៃពៃ ក៏ពិតមែនហើយ ប៉ុន្តែបើគ្រាន់តែគប់ប្រសប់ប៉ុណ្ណោះមិនតាំងចិត្តស្តាប់ពាក្យប្រដៅនឹងមិនច្រតិបត្តិតាមទេ, ក៏មិនគង់ជាប្រយោជន៍ប៉ុន្មាន ហេតុនេះ បានជាសម្តេចព្រះជិនស្រីម្ចាស់ទ្រង់លើកយក សោវចស្សតា (ភាពជាបុគ្គលងាយប្រដៅ) ឡើងសំដែងថាជាធម៌ធ្វើទីពឹង គំរប់បួន ។ ឯគុណធម៌នេះ បើមានក្នុងសន្តានរបស់បុគ្គលណាហើយ តែងធ្វើបុគ្គលនោះឲ្យជាទីជ្រះថ្លា ទាំង

ជាទីពប់អានដល់អ្នកប្រដៅ ហើយទំនឹងជាផ្សះផ្សាប្រឡាយជាទីហួរមកនូវ
គុណធម៌ដទៃទៀតច្រើនយ៉ាងផង, ព្រោះគុណធម៌ឯទៀតៗ ដែលនឹង
កើតឡើងបាននោះ ក៏អាស្រ័យនឹងការស្តាប់ហើយប្រព្រឹត្តតាមនេះជា
ទីតាំង តែបើស្តាប់ហើយមិនបានតែរះឲ្យចូលចិត្តនឹងមិនប្រព្រឹត្តតាមទេ,
ក៏មិនទាន់ពប់ថាវិសេសជាងគេដែលមិនបានស្តាប់ប៉ុន្មាន, ព្រោះមិនបាន
សំរេចប្រយោជន៍យ៉ាងណាឡើយ, មានគួរនាដូចវែកដែលមិនដឹង
រស់សម្ងំ ។ ព្រោះហេតុនោះ កាលបើបានដួបប្រទះនឹងអ្នកប្រាជ្ញ
ហើយបានស្តាប់ពាក្យប្រដៅរបស់លោក ត្រូវកុំមានទិដ្ឋិមានះឡើយ,
គួរតែរះឲ្យដឹងច្បាស់ឲ្យចូលសិប់ក្នុងចិត្ត ហើយខំប្រតិបត្តិឲ្យដល់តំរែត
របស់ធម៌នោះ ។ ចុះ ទើបនឹងបានសម្រេចប្រយោជន៍អំពីការសេពគប់ គឺ
មុខជាបានចេះដឹងនឹងបានប្រព្រឹត្តល្អរៀបរយដោយធាប់ភ្លាម ។ មានគួរ
នាដូចអណ្តាតដែលធាប់ដឹងរសសម្ងំ ។ ព្រោះហេតុនេះ សោរិបស្សត្ថា
(ភាពជាបុគ្គលងាយប្រដៅ) ទើបលោកចាត់ជាធម៌ធ្វើទំពឹង គំរប់ ៤ ។

៩- ឯការដែលគប់រកគ្នាជាមិត្តសំឡាញ់នោះសោត, អ្នកទាំងពីរ
ខាងត្រូវមានគុណប្រយោជន៍អ្វីមួយ តិចឬច្រើន ឲ្យជាគ្រឿងភ្ជាប់ចិត្ត
គ្នានឹងគ្នា ទើបយកជាគ្នាបាន, បើមិនដូច្នោះទេ ក៏មិនផ្សំពីគេដែល
មិនមែនជាមិត្តប៉ុន្មាន, ឬកប់ប្រសប់គ្នាមិនជាប់បានយូរ ដោយហេតុដូច
ពោលមកនេះហើយ បានជាសម្តេចព្រះទីបវុត្តមាចារ្យជាម្ចាស់ទ្រង់លើក

យក កិកវណ៌យេសុ ទក្ខិណា (ភាពជាអ្នកជួយទ្រទ្រង់ក្នុងកិច្ចធ្វើរបស់មិត្តអ្នកប្រតិបត្តិធម៌ជាមួយគ្នា) ឡើងសំដែងថាជាធម៌ធ្វើទីពឹង គំរប់ ៦ ព្រោះគុណធម៌នេះឯង តែងជាគ្រឿងគាញ់ចិត្តរបស់អ្នកដែលបានទទួលឧបការៈឲ្យមកជាមិត្តសំឡាញ់បាន មិនតែប៉ុណ្ណោះឡើយ តែងធ្វើបុគ្គលដែលជាមិត្តសំឡាញ់ទឹងគ្នាស្រាប់មកហើយ ឲ្យរឹងតែតែជាតស្និទ្ធទឹងគ្នាថែមទៀតផង ។ ម្យ៉ាងទៀត បុគ្គលដែលទឹងតាំងខ្លួនឲ្យជាមនុស្សស្តុកស្តម្ភមាំមួនបាននោះ ព្រោះតែកម្លាំងរបស់ខ្លួនម្នាក់ឯងអាចធ្វើបានគ្រប់យ៉ាងក៏ទេ លុះតែអាស្រ័យកម្លាំងរបស់មិត្តសំឡាញ់ច្រើនអ្នកផង ទើបតាំងបាន ប៉ុន្តែដែលអ្នកឯទៃគេទឹងមកជួយជាកម្លាំងឬទេនោះ ក៏ព្រោះតែខ្លួនធ្លាប់ជួយគេដែរ ។ ដោយហេតុនេះឯង កិកវណ៌យេសុ ទក្ខិណា (ភាពជាអ្នកចំប្រឹងយកចិត្តទុកជាក់ជួយធ្វើកិច្ចធ្វើរបស់មិត្តអ្នកប្រតិបត្តិធម៌ជាមួយគ្នា) ទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ ៥ ។

៦- ឯការដែលបុគ្គលទន់ធ្វើសេចក្តីល្អដូចពណ៌នាមកហើយ ឲ្យគ្រប់តាំងអស់ ឬយ៉ាងណាម្យ៉ាងនោះ ក៏លុះតែមានសេចក្តីស្រឡាញ់នូវការល្អនោះ ឲ្យណាស់ទើបធ្វើបាន ។ ហេតុដូច្នេះ បានជាសម្តេចព្រះសយម្ភូញាណជាម្ចាស់ ទ្រង់លើកយក ធម្មកាមតា (ភាពជាបុគ្គលស្រឡាញ់ធម៌ដែលប្រពៃ) ឡើងសំដែងថាជាធម៌ធ្វើទីពឹងជាគំរប់ ៦ ។ ឯគុណធម៌នេះ ជាគ្រឿងជួយទំនុកបំរុងឲ្យបុគ្គលមានកម្លាំង

ប្រព្រឹត្តធម៌ ទើបលោកចាត់ជាឥទ្ធិបាទធម៌ គឺធម៌នាំឲ្យសម្រេចប្រយោជន៍តាមបំណងប្រកាន់មួយ ។ សេចក្តីនេះ គួរឃើញដូចបុគ្គលដែលនឹងប្រកបកិច្ចការណាមួយ បើប្រសិនជាមិនបណ្តុះចិត្តឲ្យស្រឡាញ់កិច្ចនោះ។ ជាមុនទេ សេចក្តីប្រឹងប្រែងក្នុងការប្រកបកិច្ចនោះ ។ ក៏នឹងធ្វើថយចុះមិនពេញកម្លាំង កុំថាដល់កិច្ចធំ ។ ឡើយ សូម្បីកិច្ចតូច ។ ដូចគ្រាន់តែនិយាយសន្ទនាប្រស្រ័យនឹងគ្នាជាដើម ដ្បិនកាលអ្នកស្តាប់មិនគាប់ចិត្តនឹងពាក្យសំដីរបស់អ្នកនិយាយ ក៏នាំឲ្យខូចប្រយោជន៍ក្នុងការសន្ទនាប្រស្រ័យនោះមិនខាន, អម្បាលការបន្តិចបន្តួចគ្រាមប៉ុណ្ណេះម្តេចមិនសម្រេចទៅហើយ ចំណង់បើដល់ទៅការធំ ។ ដូចយ៉ាងការប្រតិបត្តិធម៌វិនិយដើម្បីធ្វើខ្លួនឲ្យដល់នូវទីរំលត់ទុក្ខគឺព្រះនិព្វាននោះទៀត, បើមិនបណ្តុះសេចក្តីស្រឡាញ់ឲ្យច្រើនទេ ធ្វើម្តេចនឹងកើត ។ ព្រោះហេតុដូចសំដែងមកនេះ ឆន្ទាធិបតេយ្យ (ភាពជាបុគ្គលមានសេចក្តីស្រឡាញ់ពេញចិត្តចំពោះធម៌ណ្ហ) ទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ ៦ ។

៧– បើមានសេចក្តីស្រឡាញ់ពេញចិត្តណាស់ដែរ ប៉ុន្តែមិនបានចុះដៃធ្វើឬគ្រាន់តែធ្វើ ។ តែមិនខំប្រឹងខ្នះខ្នែងឲ្យមែនទែនទេ កិច្ចការនោះ ។ ក៏មិនបានសម្រេចឡើយ ព្រោះហេតុនេះហើយ បានជាសម្តេចព្រះសព្វញ្ញូញាណទ្រង់ត្រាស់លើកយក វីរិយៈ (សេចក្តីប្រឹងប្រែង) ឡើងសំដែងថា ជាធម៌ធ្វើទីពឹង គំរប់ ៧ ។

ឯគុណធម៌នេះ ជាធម៌សំខាន់បំផុតខាងឯជួយគាំទ្រចិត្តឲ្យមានកម្លាំងក្លាហានមិនឲ្យលះបង់ការងារបស់ខ្លួនដែលត្រូវធ្វើឡើយ ជាហេតុនាំឲ្យសម្រេចប្រយោជន៍ដូចសេចក្តីប៉ុនប៉ងឯ សេចក្តីនេះយ៉ាងណាមិញ ការដែលប្រតិបត្តិធម៌នៅក្នុងព្រះពុទ្ធសាសនាក៏យ៉ាងនោះដែរ, គឺអាស្រ័យនឹងសេចក្តីព្យាយាមទំប្រឹងលះបង់អកុសលចោលចេញ ហើយចម្រើនកុសលឲ្យកើតកើនឡើង ទើបអាចរំដោះខ្លួនឲ្យផុតស្រឡះអំពីទុក្ខបានសម្រេចសេចក្តីសុខតាមប្រាថ្នា ។ សេចក្តីនេះ សមដូចពុទ្ធភាសិតថា រ៉ីយើងទុក្ខមប្បេតិ "បុគ្គលតែងកន្ទងទុក្ខបានដោយសារសេចក្តីព្យាយាម" ។ ព្រោះហេតុនេះ រ៉ីយ៉ៈ (សេចក្តីព្យាយាមលះបង់អំពើអាក្រក់ហើយប្រព្រឹត្តតែអំពើល្អ" ទើបលោកចាត់ជាធម៌ធ្វើទីពីរ គំរប់ ៧ ។

៨- ឯសេចក្តីព្យាយាមនោះសោតដែលបុគ្គលនឹងធ្វើឲ្យពេញទីបាននោះ, ក៏អាស្រ័យនឹងមានៈសេចក្តីសន្តោសត្រេកអរចំពោះតែកិច្ចណាដែលខ្លួនត្រូវធ្វើម្យ៉ាងប៉ុណ្ណោះ ទើបបណ្តាយឲ្យចិត្តរសាត់ទៅជាប់នឹងកិច្ចឯទៀតផ្សេងៗ ខុសពីកិច្ចដែលខ្លួនត្រូវធ្វើ ដូចសុភាសិតថា: "ចាប់នេះចាប់នោះ មិនឆ្ពោះត្រង់ណាហើយ ក៏មុខជានាំឲ្យកិច្ចដែលត្រូវធ្វើនោះៗរាយមាយទៅមិនសម្រេចប្រយោជន៍ឡើយ" ហេតុនេះហើយបានជាសម្តេចព្រះមហាកុរណាធិគុណជាម្ចាស់ទ្រង់លើកយក សន្តោសៈ (សេចក្តីសន្តោស) ឡើងត្រាស់ទេសនាថាជាធម៌ធ្វើទីពីរ គំរប់ ៨ ។

ឯគុណធម៌នេះ ជាធម្មជាតិយ៉ាងសំខាន់បំផុតខាងឯដួយទុបត្តម្ភក៍ឲ្យសេចក្តីព្យាយាមនោះមានកម្លាំងឡើង គឺកាលបើបុគ្គលណាមួយជាន់ធ្វើសេចក្តីសន្តោសត្រេកអរចំពោះតែវត្តជារបស់ខ្លួន ឬការងារដែលខ្លួនត្រូវធ្វើតែម្យ៉ាងប៉ុណ្ណោះ បុគ្គលនោះក៏នឹងមានសេចក្តីប្រឹងប្រែងចំពោះតែកងតិចធុរៈដែលខ្លួនត្រូវការ, មិនយូរប៉ុន្មានក៏នឹងជានសំរេចសេចក្តីសុខសេចក្តីចម្រើន ដែលកើតអំពីសេចក្តីព្យាយាមនោះដោយឆាប់រហ័ស សេចក្តីនេះដូចម្តេចមិញ ការដែលប្រតិបត្តិធម៌កងព្រះពុទ្ធសាសនាក៏ដូចគ្នា គឺកាលបើបុគ្គលណាមួយ មានសេចក្តីសន្តោសត្រេកអរចំពោះតែវត្តជារបស់ខ្លួនតាមមានតាមជាន ឬចំពោះវិជ្ជាដែលត្រូវរៀនសូត្រ មិនបណ្តាយឲ្យសេចក្តីល្មោភច្រើនហួសប្រមាណតេក ឬមិនបណ្តាយឲ្យសេចក្តីរវើរវាយមកគ្របសង្កត់ចិត្តឡើយ ក៏ជាហេតុឲ្យប្រឹងធ្វើចំពោះតែកិច្ចធុរៈដែលត្រូវធ្វើ ទំនឹងផ្សាំណែដែលត្រូវរៀនសូត្រនោះ ឲ្យរឹងរឹតតែមាំមួនឡើង ដំណអំពីនោះទៅ ក៏នឹងជានសំរេចផលប្រយោជន៍ដែលកើតអំពីសេចក្តីប្រឹងប្រែងនោះជាលំដាប់ ។ ព្រោះហេតុដូចអធិប្បាយមកនេះ សង្គ្រោសៈ (សេចក្តីសន្តោស) ទើបលោកចាត់ជាធម្មិធ្លីទី៨ គំរប់ ๘ ។

ឯសេចក្តីសន្តោសនោះសោត ដែលបុគ្គលនឹងធ្វើឲ្យកើតក្នុងក្នុងឡើងជាន ក៏តោងអាស្រ័យ សតិ គឺស្មារតី សេចក្តីរលឹកឃើញ

មកជាគ្រឿង១បត្ថម្ភក៍ជាគ្រឿងទ្រផងទើបបាន បើមិនមានគុណធម៌នេះ
មកជួយ១បត្ថម្ភក៍ផងទេ សេចក្តីសន្តោសនោះក៏ទឹងសាបសូន្យទៅឆាប់
រហ័ស ព្រោះហេតុនោះ បានជាសម្តេចព្រះសិរីសុគតបរមគ្រូជាម្ចាស់
ទ្រង់លើកយក សព្តិ ឡើងសំដែងថា ជាធម៌ធ្វើទីពឹង គំរប់ ៤ ។

ដ្បិតគុណធម៌នេះ ជាធម្មជាតិយ៉ាងសំខាន់បំផុតក្នុងវេលាដែលប្រកប
កិច្ចអ្វី ។ គ្រប់យ៉ាងទាំងអស់ ។ សតិនេះមានលក្ខណៈឬមានក្បាក់ជារខាង
ទឹករលឹកដល់កិច្ចការគ្រប់យ៉ាងដែលបានធ្វើរួចមកហើយ ឬពាក្យសំដី
ដែលបាននិយាយរួចមកហើយ ទឹងគំនិតដែលបានគិតទុកយូរៗ មកហើយ
ក៏អាចនឹកឃើញថា: ដូចជាខើបនឹងធ្វើ ខើបនឹងនិយាយ ខើបនឹងគិតថ្មី ។
បាន ដូចមានពុទ្ធភាសិតថា: សព្តិ លោកស្មឹ ជាគរោ "សតិជាធម៌
គ្រឿងក្បាក់រលឹកនៅក្នុងលោក" ។ សតិគឺស្មារតីនេះឯងតែងធ្វើបុគ្គលឲ្យ
ធាប់នឹកឃើញ ឬឲ្យដឹងខាន់ខួរទៅក្នុងកិច្ចការទាំងពួង ទឹងធ្វើបុគ្គលឲ្យជា
កាលញ្ញូ គឺជាអ្នកស្គាល់កាលវេលាដ៏សមគួរ ។ បុគ្គលដែលខ្វះសតិ រមែង
ឥតដំណឹងដែលហៅថាអកាលញ្ញូ មិនស្គាល់កាលវេលា ប្រហែលគ្នា
ទឹងមនុស្សកំពុងដេកលក់ ដែលមិនអាចប្រកបកិច្ចការជាប្រយោជន៍ឲ្យ
សម្រេចបានដូច្នោះឯង ។ ចំណែកមនុស្សដែលមានសតិបរិបូណ៌មិន
ប្រហែសធ្វេសជាមនុស្សមានដំណឹងធាប់ មិនបង្អែរបង្អន់ឲ្យយឺតយូរ

តែងបានសម្រេចសេចក្តីសុខ-ចម្រើន មិនលិចចុះកន្លងសេចក្តីវេទនាបខ្លាំយ ។ ប្រហែលគ្នានឹងមនុស្សដែលក្រាស់លើកហើយចេះប្រកបកិច្ចការជាប្រយោជន៍នឹងបង្ការភ័យអន្តរាយកុំឲ្យមានមកដល់ខ្លួនបាន ។ សេចក្តីនេះ សមដូចព្រះគាថាថា: អប្បមាទេន តរតិ អណ្ណវំ "បុគ្គលតែងឆ្លងសមុទ្រគឺភពវដ្តសង្សារដោយអប្បមាទ គឺមានស្មារតីមិនប្រហែសឆ្មើស" ។ ព្រោះហេតុដូចពោលមកហើយនេះ សូមើលោកចាត់ជាធម្មិធ្លីទីពីរ គំរប់ ៩ ។

១០- ឯសតិ សេចក្តីរឭកនោះសោត, ដែលបុគ្គលនឹងរឭកឲ្យឃើញត្រូវតាមគន្លងធម៌បាននោះ ក៏គោងអាស្រ័យនឹងបញ្ញាគឺ សេចក្តីដឹងច្បាស់ឆ្លៀវឆ្លាសវាងវៃ ស្គាល់ត្រូវខុសអាក្រក់ល្អមកជួយឧបត្ថម្ភក៏ផងទើបបាន បើឥតគុណធម៌នេះមកជួយឧបត្ថម្ភក៏ផងទេ សតិនោះ ក៏នឹងទ្រេតទ្រោតទៅរលឹកខ្លួវអារម្មណ៍ផ្សេង ។ ដែលជាអារម្មណ៍នាំចិត្តឲ្យប្រព្រឹត្តខុស, លុះតែមានបញ្ញាជាគ្រឿងបំភ្លឺផ្លូវ ទើបសតិនោះនឹងឃើញត្រូវតាមផ្លូវធម៌ឡើងបាន, ហេតុនេះ បានជាសម្តេចព្រះវិតែលោកនាថជាម្ចាស់ទ្រង់លើកយក បញ្ញា ឡើងត្រាស់ទេសនាថាជាធម្មិធ្លីទីពីរ គំរប់ ១០ ។ ដ្បិតគុណធម៌នេះ ជាធម្មជាតិយ៉ាងសំខាន់បំផុតក្នុងពេលដែលប្រកបការគ្រប់យ៉ាង ហើយជាពន្លឺភ្លឺស្វាងវិសេសអាចធ្វើបំភ្លឺឲ្យឃើញសេចក្តីកំចាំង

ច្រាកដដល់ចិត្ត ដូចព្រះអាទិត្យដែលអាចបំភ្លឺឲ្យឃើញរបស់ក្នុងទីងងឹតបាន ដូចមានពុទ្ធភាសិតថា បញ្ញា លោកស្មឹ បជ្ជោតោ "បញ្ញាជាពន្លឺដ៏រុងរឿងក្នុងលោក" ។ ពន្លឺព្រះអាទិត្យព្រះចន្ទទីងក្មេងកំជារបស់ធ្លុះបំភ្លឺឲ្យឃើញវត្ថុដែលកំចាំងបានដោយយ៉ាង ។ តែពន្លឺទាំងនោះធ្លុះបំភ្លឺបានតែរបស់ខាងក្រៅ ។ មិនអាចធ្លុះបំភ្លឺសេចក្តីអាថ៌កំបាំងខាងក្នុងសន្តានរបស់មនុស្សឲ្យស្គាល់ថា នេះជាហេតុនៃទុក្ខ នេះជាហេតុនៃសុខ នេះជាហេតុសេចក្តីវិនាស នេះជាសេចក្តីចម្រើនដូច្នេះបាន.ឡើយ មានតែបញ្ញាម្យ៉ាងនេះហើយ ទើបអាចធ្លុះបំភ្លឺឲ្យស្គាល់ហេតុផលនោះបានវិសេសជាងពន្លឺដទៃ ដូចមានពុទ្ធភាសិតថា: ធម្មិ បញ្ញាសមា អាភា "រកពន្លឺអ្វីឲ្យក្តីស្មើនឹងពន្លឺគឺបញ្ញានេះមិនមានឡើយ" ។ ម្យ៉ាងទៀត បុគ្គលដែលអាចសំអាតចិត្តឲ្យបរិសុទ្ធផុតស្រឡះអំពីសេចក្តីសៅហ្មង ហើយបានសម្រេចព្រះនិព្វានោះ ក៏ព្រោះតែបញ្ញា បញ្ញានេះលោកប្រៀបដូចជាកែវភ្នែករបស់នរជន ព្រោះចេះពិនិត្យគប្បីគន់រកទោសគ្រឿងមន្ទិលដែលជាប់នៅក្នុងចិត្ត ទោះបីតិចតួចក៏អាចសំឡឹងឃើញច្បាស់ហើយលះបង់ចោលចេញ បើទុកជាធ្ងន់ប្រឡាក់ប្រឡូសមកអំពីមុន ព្រោះសេចក្តីល្ងង់ខ្លៅ ក៏គង់តែឆ្លាប់ជាស្អាតបរិសុទ្ធបាន ដូចពុទ្ធភាសិតថា: បញ្ញាយ បរិសុជ្ឈតិ "បុគ្គលតែងបរិសុទ្ធចិត្តបានដោយសារបញ្ញា" ។

អ្នកមានបញ្ញា ទើបចេះគេចវេះចេញអំពីសេចក្តីវិនាសហើយតាំងខ្លួនឲ្យរឹងដំហរនៅក្នុងសេចក្តីចំរើនបាន ឯអ្នកដែលអាចបីបាច់រក្សាខ្លួនឯងព្រមទាំងអ្នកដទៃឲ្យបានសុខស្រួលនោះ ក៏ព្រោះតែមានបញ្ញាធ្វើវិនិច្ឆ័យក្នុងបាយផ្សេង ។ នេះឯង, ដូចពុទ្ធភាសិតថា: បញ្ញា ពេធំ បសោ-សតិ "បញ្ញាតែងគ្រប់គ្រងរក្សាបុរសខ្ទុះ" ។ ព្រោះហេតុនេះ បញ្ញា ទើបលោកចាត់ជាធម៌ធ្វើទីពឹង គំរប់ ១០ ដោយប្រការដូច្នេះឯង ។

សំដែងមកអំពីនាថករណធម៌ ដោយសង្ខេបនេះ សន្តុតថាចប់ប៉ុណ្ណោះ ។ សូមសិរីសួស្តីជោគជ័យមង្គលដោយអំណាចនៃធម្មទេសនាផ្សាយតាមវិស្សុតម្ពជានេះ សូមកើតមានដល់ អស់ពួក ពុទ្ធបរិសទ្យ តាំងឡាយ ដែលបានស្តាប់សំឡេងឮតាម ។ គ្បាសនសព្ទក្នុងទីនានា សូមឲ្យ ។ បច្ច័យអន្តរាយគ្រប់យ៉ាងវិនាសអន្តរាយកុំបីសេសសល់ឡើយ ។

ការសំដែងធម៌ទេសនាសន្តុតចប់ដោយសង្ខេបបែបខ្លី ឯវំ ដូចសេចក្តីរៀបរាប់មកនេះឯង ។

មានពិតមែនឬ?

សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លក្ខណសំយុត្ត

ឃុនបណ្ណាសុរក្ខប្បិ-ប្បី

ក្រសួងពុទ្ធសាសនបណ្ឌិត្យ ជាអ្នកប្រែ(១)

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវនជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះមហាមោគ្គល្លានត្ថេរនិងព្រះលក្ខណត្ថេរគង់នៅនាកំគិជ្ឈកូដ និមន្តចុះពីកំគិជ្ឈកូដចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ព្រះមហាមោគ្គល្លានត្ថេរកាលចុះពីកំគិជ្ឈកូដក៏ផ្ញើនូវការញញឹមឲ្យប្រាកដក្នុងប្រទេសមួយ ។ ព្រះលក្ខណត្ថេរសួរអំពីការញញឹមនោះចំពោះព្រះមហាមោគ្គល្លានត្ថេរ ។ ឃាត់ថាកុំសួរខ្ញុំក្នុងទីនេះ ចាំទៅសួរខ្ញុំក្នុងសំណាក់ព្រះដ៏មានព្រះភាគចុះ ។

លុះព្រះថេរៈទាំងពីរអង្គចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ត្រឡប់ពីបិណ្ឌបាតមកវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ ទើបព្រះលក្ខណត្ថេរសួរព្រះមហាមោគ្គល្លានត្ថេរអំពីការញញឹម

---

១ មិនបានប្រែពេញតាមប្រយោគបាលីទេ ប្រែកាត់ខ្លី ។ ដើម្បីឲ្យងាយស្តាប់ ។

នោះ ។ ព្រះមហាមោគ្គល្លានត្ថេរ ច្រៀបថា ម្នាលអាវុសោលក្ខណៈ កុងនេះ ឯណោះ កាលដែលខ្ញុំចុះមកអំពីកំពូតដ្បូកូដបានឃើញភាងធំធ្ងន់ កំពុងតែអណ្តែតទៅលើអាកាស ហូរធ្លាតក្អែកអោតដេញតាមធាបចោមចឹកចោះកើចដណ្តើងខ្លួរភាងធ្ងន់នោះ ។ កំចេះតែស្រែកថ្ងូរ ទើបខ្ញុំគិតថា យ៉ាអើ អស្ចារ្យណាស់ យ៉ាអើ មិនធ្លាប់កើតមានសោះឡើយ យ៉ាអើ សត្វបែបនេះនឹងត្រូវប់ទៅជាមានខ្លះដែរ យក្សបែបនេះនឹងត្រូវប់ទៅជាមានខ្លះដែរ ការបានអត្តភាពបែបនេះនឹងត្រូវប់ទៅជាមានខ្លះដែរតើ ។

គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កមានចក្ខុមានញាណកើតពិតហើយ ដ្បិតថាសាវ័កដឹងឃើញសត្វបែបនេះ ឬថានឹងធ្វើសត្វបែបនេះឲ្យជាសាក្សីដល់តថាគតបាន ។ សត្វនោះតថាគតធ្លាប់ឃើញមកអំពីមុនដែរ ប៉ុន្តែតថាគតមិនទាន់សំដែង បើតថាគតសំដែងអំពីរឿងសត្វនុ៎ះទៀ ជនទាំងឡាយដទៃមិនជឿពាក្យតថាគតទេ អ្នកណាមិនជឿពាក្យតថាគត ការមិនជឿរបស់អ្នកនោះនឹងនាំឲ្យទានបានប្រយោជន៍ នាំឲ្យបានតែសេចក្តីទុក្ខអស់កាលជាយូរអង្វែង ។ សត្វនោះពីដើមជាអ្នកសម្លាប់គោក្នុងក្រុងពជ្រនេះឯង ដោយវិបាកបាបកម្មនោះ អ្នកសម្លាប់គោនោះ ក៏ទៅធ្លាក់ក្នុងនរកប់រយ

ពាន់ម៉ឺនសែនឆ្នាំជាច្រើន, ដោយសេសសល់វិបាកនៃកម្មនោះ ទើបបាន
ត្រឡប់មកទទួលផល គឺត្រឡប់បានអត្តភាពបែបនេះ ។

(រឿងប្រែតជនៃតពីនេះទៅទៀត កំព្រះលក្ខណត្ថេរជាអ្នកសួរ,
ព្រះមហាមោគ្គល្លានត្ថេរជាអ្នកឆ្លើយ ចុះ, ព្រះដ៏មានព្រះភាគទ្រង់
ទទួលបញ្ជាក់ថា ប្រែតនោះ។ មានពិតប្រាកដមែន) ។

- ម្នាលអាវុសោ លក្ខណៈ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពី
កំពូលភ្នំគិជ្ឈកូដ ខ្ញុំបានឃើញចំរៀកសាច់ កំពុងតែអណ្តែតទៅលើអាកាស
ហូរឆ្ពាតក្អែកអាតដេញតាមធាបចោមចឹកចោះកើចជញ្ជែងនូវចំរៀកសាច់
នោះ។ ក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលកិកុទាំងឡាយ! សត្វទុ្ទះជាអ្នក
សម្លាប់គោពីដើម ក្នុងក្រុងពាជគ្រឹះនេះឯង ។

- ខ្ញុំបានឃើញដុំសាច់ កំពុងតែអណ្តែតទៅលើអាកាស ហូរឆ្ពាត
ក្អែកអាតដេញតាមធាបចោមចឹកចោះកើចជញ្ជែងនូវដុំសាច់នោះ។ ចេះតែ
ស្រែកថ្ងូរ ។ - ម្នាលកិកុទាំងឡាយ! សត្វទុ្ទះជាព្រានបក្សីអំពីដើម ក្នុង
ក្រុងពាជគ្រឹះនេះឯង ។

- ខ្ញុំបានឃើញបុរសគ្មានស្បែកក្រៅ កំពុងតែអណ្តែតទៅលើ
អាកាស ហូរឆ្ពាតក្អែកអាតដេញតាមធាបចោមចឹកចោះកើចជញ្ជែងនូវ

បុរសនោះ។ ចេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកសម្ងាប់ចៀមអំពីដើម ក្នុងក្រុងពន្ធគីរីនេះឯង ។

- ខ្ញុំបានឃើញបុរសមានពេមដូចជាវ កំពុងតែអណ្តែតទៅលើអាកាស ដាវទាំងនោះរបស់បុរសនោះអណ្តែតជាប់ៗ មកត្រូវកាយរបស់បុរសនោះឯង។ ក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកសម្ងាប់ជ្រូកអំពីដើម ក្នុងក្រុងពន្ធគីរីនេះឯង ។

- ខ្ញុំបានឃើញបុរសមានពេមដូចព្រួញ កំពុងតែអណ្តែតទៅលើអាកាស ព្រួញទាំងនោះរបស់បុរសនោះអណ្តែតជាប់ៗ មកត្រូវកាយរបស់បុរសនោះឯង។ ក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាពេជ្ឈឃាដអំពីដើមក្នុងក្រុងពន្ធគីរីនេះឯង ។

- ខ្ញុំបានឃើញបុរសមានពេមដូចដែកស្រួច កំពុងតែអណ្តែតទៅលើអាកាស ដែកស្រួចទាំងនោះរបស់បុរសនោះអណ្តែតជាប់ៗ មកត្រូវកាយរបស់បុរសនោះវិញ បុរសនោះក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកបរគោអំពីដើម ក្នុងក្រុងពន្ធគីរីនេះឯង ។

- ខ្ញុំបានឃើញបុរសមានពេមដូចដែកស្រួច កំពុងតែអណ្តែតទៅលើអាកាស ដែកស្រួចទាំងនោះរបស់បុរសនោះក៏ជោតចូលទៅក្នុងក្បាលផ្ងាយចេញមកតាមមាត់ ជោតចូលទៅក្នុងមាត់ផ្ងាយចេញមកតាមទ្វារ

ដោតចូលទៅក្នុងច្រមុះខ្លួនឯងហើយចេញមកតាមពោះ ដោតចូលទៅក្នុងពោះហើយចេញមកតាមក្រចៅ ដោតចូលទៅក្នុងក្រចៅហើយចេញមកតាមស្មារ ដោតចូលទៅក្នុងស្មារ ហើយចេញមកតាមជាតជើង ។ បុរសនោះក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុទាំងឡាយ សត្វខ្លុះជាអ្នកចាក់ដោតតិរច្ឆានគេអំពីដើម ក្នុងក្រុងពជគ្រឹះនេះឯង ។

- ខ្ញុំបានឃើញបុរសមានអណ្តៈ (ពងសា) ប៉ុន្តែក្តម តែងតែអណ្តែតទៅលើអាកាស កាលបុរសនោះដើរទៅលុះតែលើកអណ្តៈទាំងនោះដាក់ត្រង់កល្លើ ទើបដើរទៅបាន កាលអង្គុយក៏អង្គុយសង្កត់លើអណ្តៈទាំងនោះឯង ហូរឆាតក្អែកអោតដេញតាមនាឬចោមចឹកចោះកើចជាច្រើន ខ្លួនបុរសនោះៗ ក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុទាំងឡាយ សត្វខ្លុះជាអ្នកកាន់អំពើវៀចក្នុងស្រុក គឺជាអាមាត្យអ្នកវិនិច្ឆ័យក្តីដោយទុច្ចរិតអំពើដើមក្នុងក្រុងពជគ្រឹះនេះឯង ។

- ខ្ញុំបានឃើញបុរសម្នាក់ តែងតែមុជក្បាលចុះទៅក្នុងរណ្តៅលាមក ។ - ម្នាលភិក្ខុទាំងឡាយ សត្វខ្លុះជាអ្នកប្រព្រឹត្តបរទារកម្មគឺលួចប្រពន្ធអ្នកដទៃពីដើម ក្នុងក្រុងពជគ្រឹះនេះឯង ។

- ខ្ញុំបានឃើញបុរសម្នាក់តែងតែមុជទៅក្នុងរណ្តៅលាមក ចាប់លាមកដោយដៃទាំងពីរស៊ី ។ - ម្នាលភិក្ខុទាំងឡាយ សត្វខ្លុះពីដើមជា

ព្រាហ្មណ៍ក្នុងក្រុងភដ្ទគ្រឹះនេះឯង ។ ព្រាហ្មណ៍នោះ កាលក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ចូរនមស្ការកិត្តុសង្ឃដោយកត្តាហារ តំដាក់លាមកពេញក្នុងស្មុក រួចហើយប្រើគេឲ្យច្រាប់កត្តកាល ហើយនិយាយថា សូមលោកម្ចាស់ចាំនឹងឲ្យនមស្ការដល់ផ្នែកផង សូមនមស្ការយកទៅផង ។

- ខ្ញុំបានឃើញស្រីគ្មានស្បែកក្រៅ តំពុងតែអណ្តែតទៅលើអាកាស ហ្វូងត្មាតក្អែកអោតដេញតាមនាបចោមចឹកចោះកើចដណ្តើងនូវស្រីនោះ។ ក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុចាំងឲ្យស្រីនោះកាលពីដើមជាស្រីប្រព្រឹត្តកន្ទួចបិត្តប្អូកន្ទួលក្រឡាងក្រុងភដ្ទគ្រឹះនេះឯង ។

- ខ្ញុំបានឃើញស្រីមានរូបអាក្រក់ ដៃលប្រុសគួរខ្ពើមមានក្លិនស្អុយ តំពុងតែអណ្តែតទៅលើអាកាស ហ្វូងត្មាតក្អែកអោតដេញតាមនាបចោមចឹកចោះកើចដណ្តើងនូវស្រីនោះ។ ក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុចាំងឲ្យ ស្រីនុ៎ះកាលពីដើមជាស្រីមេមត់ ក្នុងក្រុងភដ្ទគ្រឹះនេះឯង ។

- ខ្ញុំបានឃើញស្រីមានកាយឆេះពេលភ្លេចភ្លើងដោយភ្លើង មានកាយស្មើមដោកដាំ មានកាយដេរដាសដោយរំដើកភ្លើង តំពុងតែអណ្តែតទៅលើអាកាស ស្រីនោះក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលភិក្ខុចាំងឲ្យ

ស្រីនុ៎ះកាលពីដើមជាអគ្គមហេសី នៃស្តេចកនិដ្ឋ ស្រីនោះជាអ្នកមានសេចក្តីប្រុសា្រគបសង្កត់ ហានចាក់រើកកូនមួយអំបែងលើស្តេជាមហេសីចុង ។

- ខ្ញុំបានឃើញប្រែតគ្មានក្បាល កំពុងតែអណ្តែតទៅលើអាកាស ប្រែតនោះមានក្អែកនឹងមុខនៅត្រង់ទ្រូង ហូនគ្នាតក្អែកអោតដេញតាមធាបចោមចឹកចោះកើបដណ្តើនទូរប្រែតនោះៗក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលកិកុំតាំងឡាយ សត្វនុ៎ះកាលពីដើមឈ្មោះហាវិក:ជាអ្នកពិយាជចោរកនក្រែងរាជគ្រឹះនេះឯង ។

- ម្នាលអាវុសោ លក្ខណៈ កនទីឯណោះ កាលដែលខ្ញុំចុះមកអំពីកំពូលភ្នំ ខ្ញុំបានឃើញកិកុ, កិកុនី, សិក្ខមានា, សាមណេរ, សាមណេរី កំពុងតែអណ្តែតទៅលើអាកាស សង្ឃាដី, ចាត្រ, វត្តពន្ធបង្កើនទឹកឆកាយរបស់កិកុ ។ល។ សាមណេរីនោះ មានកូនឆ្មេះសន្ធោសន្ធៅ កិកុ ។ល។ សាមណេរីនោះក៏ចេះតែស្រែកថ្ងូរ ។ - ម្នាលកិកុំតាំងឡាយ កិកុ ។ល។ សាមណេរីនុ៎ះកាលពីដើមជាកិកុ ។ល។ ជាសាមណេរីលាមក កនសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ។

ចប់

ព្រះមហាឧត្តមវិជ្ជា ធីលញ្ញាណោ ប៊ុង-ប៉ម
អាចារ្យសាលាចុលីវង្ស វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង
ឃុនមណ្ឌារក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

៤— អើពើស្តាប់បង្គាប់គ្នា.— មនុស្សយើងដែលនៅរួមគ្នាជាពួកគណៈ រមែងមានចាងអ្នកធំចាងអ្នកតូច ។ ដូច្នេះ អ្នកធំគួរអើពើចំពោះអ្នកតូច ចាងអ្នកតូចក៏គួរអើពើស្តាប់បង្គាប់អ្នកធំ ។ សម្រាប់អ្នកធំ ត្រូវឲ្យស្គាល់ខុស-ត្រូវ-អាក្រក់-ល្អ ទើរតែដែលជាគុណជាទោសច្រើនជាងអ្នកតូច ចាងមានពាក្យគ្រប់គ្រងមើលថែរក្សាបង្គាប់បញ្ជា-ណែនាំប្រៀនប្រដៅអ្នកតូច ឲ្យធ្វើតែអំពើដែលជាប្រយោជន៍ ឲ្យវៀរអំពើជាទោសដែលអាចនាំមកនូវទុក្ខភ័យ ក្តៅក្រហាយផ្សេងៗ ។ សម្រាប់អ្នកតូច ទោះមានចំណេះដំណឹងតិចជាង ឬច្រើនជាងក៏ដោយ តែដើម្បីទទួលអំណាចដ៏ត្រឹមត្រូវតាមច្បាប់នឹងភាពជាអ្នកជាចំពោះខ្លួន ក៏គួរស្តាប់បង្គាប់អ្នកធំដែលមានអំណាចដ៏ត្រឹមត្រូវតាមច្បាប់លើខ្លួន ។ ពិតមែន! អ្នកធំនឹងមានអំណាចបាន ព្រោះអ្នកតូចស្តាប់បង្គាប់តាំងចិត្តធ្វើតាមពាក្យប្រៀនប្រដៅ ។ សូម្បីអ្នកតូចនឹងមានអំណាច តាំងមានភាពជាអ្នកជាចំពោះខ្លួនបានក៏ព្រោះការស្តាប់បង្គាប់ តាំងចិត្តធ្វើតាមពាក្យប្រៀន

ប្រដៅរបស់អ្នកធំ ។ គ្រាណាដែលអំណាចនឹងមតិមហាជនរួមផ្សំគ្នា គ្រានោះ អំណាចរមែងខ្ពស់ឡើង គ្រាណា អំណាចផ្ទុយគ្នានឹងមតិមហាជន គ្រានោះ អំណាចរមែងដល់នូវកាលអវសាន (ផុតរលត់) ។ ហេតុនេះ ដើម្បីឲ្យបានសន្តិសុខរៀបរយនៃពួកគណៈ: អ្នកធំនឹងអ្នកតូច ត្រូវធ្វើឲ្យត្រូវហាន: ឲ្យត្រូវអធ្យាស្រ័យគ្នា គឺអ្នកធំកាន់នាទីជាអ្នកអើតើ ផ្សាយមេត្រីចំពោះអ្នកតូចដែលនៅក្រោមបង្គាប់, អ្នកតូច កាន់មុខគ្រប្បូនខាងការស្តាប់បង្គាប់ - គោរពអ្នកធំដែលនៅលើខ្លួន ដោយចេះរំងាប់អារម្មណ៍អាក្រក់ ចេះធ្វើសេចក្តីល្អក្នុងទិដ្ឋិតាំងតួង ។

អ្នកធំ ចូរអើតើអនុគ្រោះដល់អ្នកតូចតាមនាទី ដោយការគ្រប់គ្រង-មើល-ថែទាំ បង្គាប់បញ្ជា ណែនាំប្រៀនប្រដៅ ដោយមេត្តាករុណា ។ ចូរជ្រាបចុះថា កាលបើជាតិចំរើនហើយ អ្នកតូចរមែងស្គាល់ពេលវេលាដែលគួរស្តាប់ ឬមិនគួរស្តាប់ នូវពាក្យបញ្ជូនឬបង្គាប់បញ្ជា ។ ដូចេ្នះ អ្នកធំដែលជាមនុស្សខ្ពស់ជាងអ្នកតូច ហើយដែលត្រូវឃុំគ្រងអ្នកតូចនោះត្រូវស្គាល់ថា វត្ថុណាត្រូវច្បាប់ គួរបង្គាប់ វត្ថុណាខុសច្បាប់ មិនគួរបង្គាប់ បើនឹងបង្គាប់ដំរុលៗដោយមិនស្គាល់ថាគួរឬមិនគួរទេ លុះកាលអ្នកតូចនៅក្រោមបង្គាប់មិនធ្វើតាម ឬ ធ្វើមិនកើតសូម្បីនឹងប្រើអំណាចកំហែងបង្ខំៗ ក៏គង់មិនបានសម្រេចផលគង់ចូលក្នុងទំនងថា "ប្រើដំរីឲ្យចូលរន្ធគូថម្ជុល" ឯអ្នកដែលប្រើអំណាចខុសច្បាប់ បង្ខំកំហែងគ្រប់សង្កត់អ្នកដទៃនោះ មុខជាត្រូវគេតប

ស្នងសងគុណមកវិញ ដោយអំណាចដូច្នោះ ក្នុងកាលដែលខ្លួនអស់អំណាចពុំខាន មើលពស់វែកចុះ កាលអស់អំណាចហើយក៏ត្រូវហួងស្រមោចស៊ីបាន ។

អ្នកតូចត្រូវបង្អោនខ្លួននៅក្រោមបង្គាប់បញ្ជារបស់អ្នកធំ ដែលគ្រប់គ្រង ឬមានអំណាចលើខ្លួនដែលជាអ្នកមានដំណឹង (សេចក្តីដឹង) ឈ្វាសវៃអាចគ្រប់គ្រងនឹងបង្គាប់បញ្ជាខ្លួនបាន នឹងត្រូវជាមនុស្សប្រដៅងាយ ដាក់កាយដាក់ចិត្ត គោរព-ស្តាប់អាន-ស្តាប់បង្គាប់ តាំងចិត្តធ្វើតាមឧត្តរដែលលោកណែនាំប្រៀនប្រដៅ ដោយកាន់បែបផែនគំនៀមទំលាប់ សេចក្តីបង្គាប់ ទុកជាគ្រូនៅក្នុងចិត្តយ៉ាងខ្ជាប់ខ្ជួន ។ ព្រោះកាលអ្នកតូចស្តាប់បង្គាប់អ្នកធំ នឹងប្រតិបត្តិត្រឹមត្រូវតាមគួរ ឲ្យជាទីពុកចិត្តបានហើយ អ្នកធំក៏រមែងឲ្យការជាអ្នកជាដល់ខ្លួនកង់ចំណែកនាទីរបស់ខ្លួន គោលគឺទុកចិត្តយល់ព្រមឲ្យទទួលខុស-ត្រូវក្នុងចំណែកខ្លួនតាមធម្មតា តែបើអ្នកតូចប្រកាន់យកការជាអ្នកជាចំពោះខ្លួនហួសប្រមាណថា "យើងស្គាល់ខុស-ត្រូវ-អាក្រក់-ល្អ ល្មមសមគួរហើយ មិនចាំបាច់ឲ្យអ្នកណាប្រៀនប្រដៅ មិនចាំបាច់ស្តាប់បង្គាប់នរណា ទឹងមិនចាំបាច់ធ្វើតាមពាក្យពន្យល់ ឬពាក្យបង្គាប់បញ្ជារបស់នរណាឡើយ" ដូច្នេះ សូម្បីមានអំណាចចំពោះខ្លួនយ៉ាងណា ក៏ឈ្មោះថាខុសធម្មតា ។

ការសិក្សាសូត្រវៀន ទឹងការប្រព្រឹត្តិល្អ ឬកិច្ចការដទៃ ៗ បើអ្នកធំមិនអើពើចំពោះអ្នកតូច តាំងអ្នកតូចក៏មិនដឿមិនស្តាប់អ្នកធំហើយ

ក៏ឥតបានសម្រេចផលអ្វីឡើយ បើជាការគ្រប់គ្រងពួកគណៈផង ក៏ប៉ុន
គ្មានធ្វើពួកគណៈឲ្យបែកបាក់ប្រែធាតៅបណ្តាយ ដូចជាមេឃុំមិន
អើពើចំពោះកូនឃុំ កូនឃុំមិនដឹ មិនស្តាប់បង្គាប់ មេឃុំ, តៅហ្វាយ
ស្រុក មិនអើពើចំពោះមេឃុំ, មេឃុំមិនដឹមិនស្តាប់បង្គាប់តៅហ្វាយ
ស្រុក, តៅហ្វាយខែត្រមិនអើពើចំពោះតៅហ្វាយស្រុក, តៅហ្វាយ
ស្រុកមិនដឹមិនស្តាប់តៅហ្វាយខែត្រ, នាយកសួនតៗឡើងតៅទៀត
ក៏មិនអើពើទឹងមិនស្តាប់បង្គាប់គ្នាយ៉ាងនេះ ការគ្រប់គ្រងពួកគណៈ ក៏មុខ
ជាត្រូវប្រែប្រួល ទឹងកើតចលាចលមិនស្ងប់រៀបរយឡើយ ។

លក្ខណៈនៃនិស្ស័យកប់អានអ្នកជនៃ គឺសំដែងកិរិយា វាចាសុភាព
ទន់លំទោន ផ្អែមល្ហែមចំពោះគ្នា, ប្រព្រឹត្តិខ្នះឲ្យស្មោះស្ម័គ្រចំពោះគ្នា
ទឹងគ្នា, លើកដំកើងសរសើរគ្នា ទឹងអើពើស្តាប់បង្គាប់គ្នាទាំង ៤ ប្រការ
ដូចពោលមកហើយនេះ រមែងជាផ្លូវគោចរមកនៃសេចក្តីល្អ សេចក្តី
ចំរើនចំពោះមនុស្សដែលនៅរួមគ្នាជាពួកគណៈ ។ ព្រោះកងពួកគណៈ
នោះ បើអ្នកធំកប់អានអ្នកតូច ហើយអ្នកតូចស្តាប់បង្គាប់អ្នកធំ ដោយ
សុទ្ធចិត្តតិតៗ កិច្ចការរបស់ពួកគណៈ ទាំងចំណែកខ្លួនទាំងចំណែករួម
គ្នា ក៏ចំរើនរុងរឿងជារបៀបរៀបរយឡើង បើនិយាយដល់ចំណែក
បុគ្គលផងហើយ និស្ស័យកប់អានអ្នកជនៃនេះ រមែងជាគ្រឿងប្រដាប់
សម្រាប់ធ្វើអ្នកធំ ឲ្យទៅជាទីគោរពសក្ការបូជារបស់អ្នកតូច ទឹងជាគ្រឿង
ប្រដាប់សម្រាប់ថែរក្សាអ្នកតូចឲ្យជាទីស្ងួរស្រឡាញ់ គួរទុកចិត្តរបស់អ្នកធំ

ចាំដ៏សង្ឃខាងក៏ស្រឡាញ់គោរពរាប់អាន ព្រមព្រៀងគ្នាមុឺងម៉ាត់ពេញទី ប្រៀបដូចទឹកបន្សាវដែលតឲ្យជាប់គ្នារលាយសាច់ ១ ដូច្នោះ សូម្បីកាលមានហេតុត្រូវបែកចាកគ្នាកើតឡើង ក៏ព្យាយាមរង់ចាំការប្រែធានោះ មិនឲ្យខ្លួនខ្លាយសាយភាយចេញទៅ ចាំដ៏មិនសំដែងវិការ. កាយ វាចា ឲ្យប្រាកដ នៅតែធ្វើសេចក្តីគោរពរាប់អានស្រឡាញ់គ្នាដូចដើម ប្រៀបដូចជាចង្រៃរបស់ដែលបែកខ្វែកឲ្យនៅជាប់មូលគ្នា មិនឲ្យខ្ចាត់ខ្ចាយរាត់រាយទៅដូច្នោះ ។

ដោយន័យនេះ យើងទើបអាចយល់ឃើញបានថា លក្ខណៈនៃនិស្ស័យរាប់អានអ្នកដទៃចាំដ៏ ៤ យ៉ាងនោះ រមែងជាវិថីនាំជីវិតរបស់យើងឲ្យឈានទៅកាន់សេចក្តីចំរើនរុងរឿងជាស្ថាពរបានច្រើនប្រការ គឺឲ្យកើតសេចក្តីនិយមរាប់អាន ស្រឡាញ់រីករាយនឹងគ្នា មិនរើទោសខ្ពើមគ្នា, ឲ្យបានទទួលអនុគ្រោះកុងការសិក្សាសិប្បវិជ្ជាគ្នាទៅវិញទៅមក ដោយសេចក្តីត្រេកអរនឹងពេញចិត្ត, ឲ្យកិច្ចការដំណើរទៅដោយស្ងួស្តី ប្រាសចាកឧបសគ្គ ឲ្យកើតសេចក្តីសាមគ្គីនឹងគ្នាកុងរវាងបុគ្គលនឹងពួកគណៈ ឲ្យជាមនុស្សខ្លួលខ្លាយកុងពួកគណៈ អាចចូលសមាគមណា ។ ក៏ចូលបាន, ឲ្យកើតកិត្តិយសកុងការទទួលអញ្ជើញ ទទួលស្គាប់បង្គាប់ដោយអធ្យាស្រ័យមេត្រី នឹងឲ្យកើតសន្តិសុខ រៀបរាយដល់គ្នានឹងគ្នា ដែលជាផ្លូវនាំឲ្យកើតសេចក្តីត្រជាក់ត្រជុំដល់អ្នកតូច នឹងឲ្យកើតការធ្លុះចិត្តដល់អ្នកធំបាន ។

(មានត)

កណ្ឌទី ១៧

ឧកញ៉ាវិបុលរាជសេនា ឆ្លូ-កន ប្រៃរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជវិទ្យាសបើបានអាន
ធំឯបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

លីប៉ោ"បានស្តាប់ដូច្នោះក៏មានសេចក្តីត្រេកអរពន់ពេក ហើយបាន និយាយទឹងតាន់តេង៉ថា ឥឡូវបងឆ្លូលើកចូលមកព័ទ្ធជុំគំពែងស្រុកហើយ បើទឹងនៅក្រែងចូលទៅបន្ទាយគយមិនបាន ឲ្យអ្នកឯងស្រូតទៅមុនដើម្បីទឹងប្រាប់តាន់កុងថា យើងទឹងលើកទំពៅដល់ក្នុងវេលាយប់នេះ ឲ្យចាំបើកទ្វារទទួលហើយអុជភ្លើងសញ្ញាឡើង យើងទឹងលើកពលការំលាយទ័ពចូលចូលទៅឲ្យបាន ។ តាន់តេង៉ក៏លាលីប៉ោ"ស្រូតទៅគយសៀវគួនជាមុនលុះដល់ហើយក៏ប្រាប់តាន់កុងថា ខ្ញុំបាននាំដំណឹងទៅដំពហលីប៉ោ"ៗ ក៏យល់ឃើញត្រូវដូចគំនិតខ្ញុំ ឥឡូវលីប៉ោ"ផ្តាំមកថា កម្ចាំងទ័ពចូលចូលភ្លាំង

ពន្ធឹកណាស់ ឃើញថាលោកនឹងតទល់មិនបានទេ ព្រោះគយសៀវគួនេះមិនមែនជាទីសំខាន់ ឲ្យលើកទ័ពទៅស្រុកឈើជីវនឹងបានជួយលីប៉ោ" គឺតគួរគ្នាការពារស្រុក ។ តាន់កុងមិនដឹងក្នុងកលតាន់តេងក៏សំគាល់ថាមែន លុះពេលយប់ក៏នាំទាហានរត់ចោលបន្ទាយគយនោះទៅ មិនបានប្រាប់នាយចោរទាំង ៤ ឲ្យដឹង ។ ខណៈតាលតាន់កុងលើកពលរត់ទៅនោះ តាន់តេងក៏លបដុតភ្លើងឆេះឡើងក្នុងបន្ទាយ ទទួលលីប៉ោលើកទ័ពមកដល់ក្រឡេកឃើញពន្លឺភ្លើងភ្លឺឡើង ក៏សំគាល់ថាតាន់កុងអុជទទួល ក៏ឋង្ខិបរពលចូលទៅចួបនឹងតាន់កុងដែលកំពុងរត់ចេញមក ។ លីប៉ោសំគាល់ថាកងទ័ពចូនក៏ដេញទាហានចូលប្រកាប់ជាប់ដៃគ្នា ខាងតាន់កុងមិនដឹងថាលីប៉ោសំគាល់ថា ទ័ពចូនលើកចូលមកស្អាត់ពីមុខ ក៏ដេញពលចូលគ្រលុកដើម្បីនឹងឈ្លោយចេញទៅ ទាហានទាំងសងខាងក៏ចាក់កាប់សម្លាប់គ្នាស្លាប់ជាច្រើនណាស់ ។

ឯចូនឃើញភ្លើងឆេះក្នុងបន្ទាយដូចសំបុត្រសញ្ញាតាន់តេង ក៏ដេញពលចូលទៅតាមទំលាយបន្ទាយ នាយចោរទាំង ៤ នាក់ដែលនៅរក្សាគយនោះ មិនបានដឹងការថាយ៉ាន់ម្តេច ក៏ប្រមូលទាហានចេញទៅតាំងច្បាំងគ្នានឹងកងទ័ពចូនជាពន្លឹក ។ ពួកចោរនោះមានទាហានតិចតស៊ូនឹងកងទ័ពចូនមិនបាន ក៏ចាក់បែកខ្ចាត់ខ្ចាយរត់យកតែខ្លួន ។ ចូនក៏លើកពលចូលទៅតាំងនៅក្នុងគយសៀវគួនបាន ។

ឯលីចោ៉ាន៏តាន់កុង៏រវន្ទ្រង៏ច្រឡំចាក់កាប់សម្លាប់គ្នាត្រាតែថ្ងៃរះទាហាន
ទាំងសងខាង ក៏ក្រឡេកឃើញមុខគ្នាច្បាស់ស្គាល់ជាទំពាក្នាឯង៏ឈប់
ប្រកាប់គ្នា តាន់កុង៏ម្ចាស់ចូលទៅជួបនឹងលីចោ៉ា ពណិនាកយរឿង
ឲ្យលីចោ៉ាស្តាប់ត្រប់ត្រងការ លីចោ៉ានឹងតាន់កុង៏ក៏ដឹងច្បាស់ថា· ហេតុដែល
កើតជាចលាចលដូច្នេះដោយសារទុចាយកលតាន់តេង លីចោ៉ាក៏នាំសេនា
ទាហានទាំងអស់ស្រុតត្រឡប់ទៅស្រុកឈើដីវ លុះដល់ដើងកំពែងលីចោ៉ា
ក៏ហៅសេនាទាហានដែលយាមល្បាតឲ្យបើកទ្វារទទួល ។

ឯបុតុកឃើញកង៏ទំពលីចោ៉ាលើកចូលមកស្រែកឲ្យបើកទ្វារ ក៏បង្គាប់
ឲ្យទាហានដែលនៅលើសើនលើកធ្នូបាញ់ចម្រុះចុះទៅ ហើយបុតុកស្រែក
ប្រាប់លីចោ៉ាថា ស្រុកឈើដីវនេះមិនមែនជារបស់លីចោ៉ាឯង៏ទេ គឺជាស្រុក
ខ្មៅពីចៅហ្វាយយើង៏ កាលពីមុននោះ ឯង៏បានមកដណ្តើមយក ឥឡូវ
យើង៏មកដណ្តើមយកវិញ ចូរឯង៏លើកទាហានត្រឡប់ទៅវិញចុះ ។

លីចោ៉ាក៏យល់តចិត្តក៏ស្រែកសួរបុតុកថា តាន់គុយដែលយើង៏ឲ្យ
នៅរក្សាស្រុកនេះឥឡូវទៅឯណាទៅហើយ ? បុតុកឆ្លើយថា តាន់គុយ
នោះយើង៏ចាប់ខ្ជួនសម្លាប់ទៅហើយ ។ លីចោ៉ាបានឮដូច្នោះទើបងាកមក
សួរតាន់កុង៏ថា តាន់តេង៏បានមកជាមួយដែរឬទេ ? តាន់កុង៏ឆ្លើយថា
ហេតុដូចម្តេចលោកទៅសួរកេណ្ឌោះអាសត្រូវនោះទៀត ។ លីចោ៉ាក៏ឲ្យ
ត្រួតពិនិត្យមើលក្នុង៏ពួកទាហានមិនឃើញតាន់តេង៏សោះ ។ តាន់កុង៏និ-

យាយនឹងលីចោ"ថា ដែលយើងនឹងលើកចូលកាប់ចំការយាយយកស្រុកឈើ-ដីវគ្រានេះ ជាការពុញចាល់ហើយ សុំឲ្យលោកលើកទាហានទៅស្រុកសៀវផាយចុះ នឹងបានរិះគិតគ្នានឹងកោស៊ុន តៀវលៀវ ហើយលើកទ័ពត្រឡប់មកយកស្រុកយើងឲ្យបានវិញ ។ លីចោ"យល់ឃើញត្រូវ ក៏លើកកងទ័ពទៅស្រុកសៀវផាយ ។

ឯតាន់តេង កាលលបដុតភ្លើងឆេះឡើងក្នុងបន្ទាយគយសៀវគួនហើយ ក្រឡេកមើលទៅឃើញទាហានលីចោ"នឹងទាហានតាន់កុងវង្វេងកាប់សម្លាប់គ្នាជាពន្លឹកដូច្នោះ តាន់តេងក៏លបចេញពីក្នុងបន្ទាយសៀវគួនស្រូតរួតទៅស្រុកសៀវផាយជ្រាប់កោស៊ុន, តៀវលៀវថា មន្ត្រីលមិញ ចូរឆ្លើកទ័ពមកឡោមព័ទ្ធលីចោ" ។ តស៊ូនឹងចូរមិនបាន ក៏ប្រើឲ្យមករកអ្នកដើម្បីឲ្យអ្នកលើកទាហានទៅជួយ ។ កោស៊ុន តៀវលៀវក័យស្ទុតចិត្តសំគាល់ថាពិតជ្រាកដ ក៏លើកទាហានចេញពីស្រុកសៀវផាយទៅជួយលីចោ" ។ ឯតាន់តេងក៏ចេញទៅរកចោយិន ហើយនាំយកកងទ័ពចោយិនចូលទៅតាំងនៅក្នុងស្រុកសៀវផាយ ។

ឯកោស៊ុននឹងតៀវលៀវ លើកទ័ពទៅដល់កណ្តាលផ្លូវ ប្រទះនឹងទ័ពលីចោ"លើកមក ក៏ចូលទៅជួបនឹងលីចោ" ។ ទឹកឆ្អល់ក្នុងចិត្ត ក៏សាកសួរកោស៊ុននឹងតៀវលៀវថា យើងចាត់ប្រើអ្នងឲ្យនៅត្រួតត្រាការពារស្រុកសៀវផាយ ហេតុម្តេចអ្នងចេញចោលស្រុកមកដូច្នេះ ? ។

(មានត)

រឿងអាស័ក្សថ្មែងរឿងម្កែច្រាំ

លោក វ៉ាយ-ប៊ុក ក្រមការ

ប្រែពីចាក់ឆមកជាខ្មែរ

(តមក)

រឿងទីម្ភៃបី

អាស័ក្សក្រាបបង្គំទូលព្រះនរបតីថា: "បពិត្រព្រះករុណាថ្លៃវិសេស! កន្លងអតីតកាលមានខេត្ត ១ ឈ្មោះ ធម៌បុរៈ (Dharmapur) (ប៉ុរីនៃជនប្រព្រឹត្តធម៌) ព្រះមហាក្សត្រិយ៍ទ្រង់ព្រះនាមព្រះបាទធម្មជៈ (Dharmaj) សោយរាជ្យក្នុងខេត្តនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះគោវិន្ទ (Gôbind) ជាអ្នកចេះវេទាំងបួននឹងសាស្ត្រាំងជុំមួយ បានបំពេញការណ៍យកតំណែងសាសនា, ព្រាហ្មណ៍នេះមានបុត្រ៤នាក់គឺ: ហរិទត្ត (Haridatt) ១, សោមទត្ត (Sômadatt) ១, យគ្យទត្ត (Yagya 'att) ១, និងព្រហ្មទត្ត (Brahmadatt) ១, ជាបណ្ឌិត ជាសន្តបុគ្គល ហើយតែងតែនៅក្រែមឧបាទបិតាជានិច្ចរាល់ ។

ក្រោយមក, កូនច្បងនៃព្រាហ្មណ៍នោះទទួលអនិច្ចកម្ម ហើយខ្លួនលោកជិតនឹងទទួលមរណភាពដោយកើតទុក្ខធំនេះ ស្រាប់តែលោកវិស្ណុសម៌ៈ (Vishnu'sharma) ជាគ្រូព្រះមហាក្សត្រិយ៍បានអញ្ជើញទៅកាន់

គេហដ្ឋានរបស់គាត់ទៀត្រ ហ្មណ៍ហើយពោលថា: "មនុស្សយើងតែងតែ
មានទុក្ខតាំងពីចូលមកនៅក្នុងទ្រង់មាតា ។ ដល់មកយុវនភាពមនុស្ស
យើងតែងលុះក្នុងកណ្តាប់ដៃនៃតណ្ហា (សេចក្តីស្នេហា), ទំរង់នូវសេចក្តី
លំបាកដែលកើតឡើង ដោយការត្រាស់ត្រាត់ចាកសត្វទំនឹងសង្ខារដែល
ជាទីស្រឡាញ់ពេញចិត្ត ។ ដល់វ័យចាស់, រូបកាយក៏ពុលភាព
ហើយធ្លាក់ទៅក្នុងទុក្ខលំបាកគ្រប់យ៉ាង ។ បើពោលដោយសង្ខេប,
តាំងពីថ្ងៃដែលយើងបដិសន្ធិមក, យើងតែងជួបប្រទះនឹងទុក្ខច្រើនជាង
សុខ ព្រោះថាពិភពលោកនេះជាអន្ទឹងទុក្ខ ។

"បើទុកជាឡើងទៅនៅលើចុងឈើក្តី, ស្ថិតនៅលើទ្រនំកំពូតី, ចូល
ទៅពួនសម្ងំនៅក្រោមភ្នាសមុខក្តី, ចូលទៅនៅក្នុងទ្រុងដែកក្តី. ចូល
ទៅពួននៅកន្លែងស្ងាត់ក្តី, ក៏ព្រះកាលមិនដែលយាកយល់អ្នកនោះឡើយ ។

"បើទុកជាអ្នកនោះជាបណ្ឌិតឬល្ងង់ខ្លៅ, មានឬគ្រ មានវិចារ-
ណញ្ញាណឬមិនមាន ខ្លាំងឬខ្សោយ ក៏ព្រះកាលដែលធ្លាប់តែលេប
សត្វទំនឹងសង្ខារទាំងអស់ មិនយោគយល់សោះឡើយ ។

"មនុស្សតែងរស់នៅ បើយ៉ាងយូរ ១០០ ឆ្នាំ, ហើយក្នុងពាក់-
កណ្តាលនៃដីវភាពសត្វៗខ្លួន ស្ថិតនៅក្នុងការដេកលក់, ពាក់កណ្តាល
ទៀត ស្ថិតនៅក្នុងវ័យក្មេង, ជរា, ហើយគ្រាតិនេះ រស់នៅដោយទុក្ខ,
ការដំលោះ ទំនឹងការត្រាត់ត្រាសចាកសត្វទំនឹងសង្ខារជាទីស្រឡាញ់ពេញ
ចិត្ត ។ ដីវិតប្រែប្រួលដូចរលកទឹក តើត្រង់ណាដែលហៅថាសុខ? ។

«ឥឡូវយើងបានមកដល់វ័យក្មេង (ប្រហែលជាចាស់ដក!), យើងមិនដែលបានជួបប្រទះនឹងមនុស្សដែលគោរពសច្ចធម៌ ។ ក្នុងមួយថ្ងៃ មានកូមិកាគេតបូលទៅលុកលុយខ្លួចខ្លីអស់គ្មានសល់, ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះទ័យកំណាញ់, ផែនប្រថពីឲ្យផលានុផលកាន់តែតិចៗទៅ, ពួកចោរកាចសាមានប្រព្រឹត្តលួចប្លន់កាប់សម្លាប់ជាច្រើន, ហើយការដឿឿជាក់ នូវលទ្ធិសាសនា នឹងសច្ចធម៌ស្ថិតនៅក្នុងពិភពលោក កាន់តែតិចតួចស្ទើរ ។ មហាក្សត្រិយ៍ប្រព្រឹត្តពាលទុច្ចរិតជាច្រើន; ពួកព្រាហ្មណ៍លុះក្នុងអំណាចមាតុគ្រាម, ស្វាមីចិត្តមិនត្រង់នឹងប្រពន្ធ, កូនស្អប់ឪពុក, មិត្តទៅជាសត្រូវ ។ ចូរអ្នកក្រឡេកមើល! មច្ចុរាជមិនបានអត់ឱនចំពោះអភិមន្យុ (Abhimanyu) ដែលមានមារាងាមាតានាមកិស្ណៈ ហើយមានបិតានាមអជ៌ុន (Arjuna), ហើយកាលណាព្រះយមរាជនាំយកមនុស្សទៅ គោតទ្រព្យស្ថិតនៅចោលក្នុងគេហដ្ឋាន ហើយមាតាបិតា, ប្រពន្ធ កូន បងប្អូនមិត្តញាតិសាលោហិត គ្មានប្រយោជន៍អ្វីសោះឡើយ ។ បុណ្យ, បាប,កម្មអាក្រក់, គុណធម៌តែងជូនដំណើរមនុស្សនោះ ហើយញាតិសាច់សន្តានក្នុងគ្រួសារនាំមនុស្សនោះយកទៅថ្ងូរដ្ឋានដើម្បីបូជា ។ អ្នកឃើញឬទេ! យប់ជ្រៅទៅ, ថ្ងៃមកដល់, ព្រះចន្ទលិចទៅ, ព្រះអាទិត្យរះឡើង ។ ដូចជាវ័យក្មេងទៅជ្រៅ, វ័យ

ចាស់មកដល់ ។ កាលវៃលោអស់ទៅៗតែមនុស្សមិនអាចប្រព្រឹត្តល្អទៅ
បាន ។ ចូរអ្នកអានគម្ពីរ "សត្យយុគ" (សម័យវិសេសមាន ៤.០០០
ឆ្នាំស្ថានសួគ៌, ក្នុងមួយឆ្នាំស្ថានសួគ៌មាន ៣៦០ ឆ្នាំស្ថានមនុស្សលោក
ឬ ១.៤៤០.០០០ ឆ្នាំស្ថានមនុស្សលោក មានបុព្វណ្ហកាលជាបឋម គឺ
មុនចូលទៅកាន់សម័យនេះ, ៤០០ ឆ្នាំស្ថានសួគ៌ (រាប់ថា ១៤.៤០០ ឆ្នាំ
ស្ថានមនុស្សលោក) ហើយមានសាយណ្ហកាល ៤០០ ឆ្នាំស្ថានសួគ៌ជាអ-
វសាន, តាំងពីសម័យនេះ គឺ១៤.៤០០ ឆ្នាំស្ថានមនុស្សលោក. បើរាប់តាំង
អស់, សត្យយុគនេះមាន ១.៧២៨.០០០ ឆ្នាំស្ថានមនុស្សលោក, កំណត់
៣៦០ថ្ងៃក្នុង ១ ឆ្នាំ) ។ ក្នុងកាលនោះ មានបុរសម្នាក់នាម មន្ធាត:
(Mandhata) ដែលបានសោយរាជ្យជាស្តេចមានព្រះកិត្តិនាមល្បីល្បាញ
ហើយព្រះរាជកិត្យានុភាព ប៉ះពាល់ទូទៅពាសពេញពិភពលោក ហើយ
នៅក្នុងកាលដែលគេហៅថាត្រៃតាយុគ (Trêta-Yug) កាលជាពលិកម្ម
មាន ១.២៩៨.០០០ ឆ្នាំស្ថានមនុស្សលោក, មានព្រះរាជាមួយអង្គទ្រង់
ព្រះនាមព្រះចាន្ទស្រីរាមចន្ទ្រ (Çri-Râma Chandra) ទ្រង់បានកសាង
ស្ពានមួយឆ្លងកាត់មហាសាគរ ។ ទ្រង់បានរុះរើទូវបន្ទាយធំសីលង់ ហើយ
ពិឃាដរាវណ: ។ អ្នកជ្រាបដឹ កាលនៅទ្វាបយុគ (Dvâpar-Yug)
កាលជាវិចិត្តិច្ចា,សង្ឃ័យមាន ៨៦៤.០០០ ឆ្នាំស្ថានមនុស្សលោក, មាន
មហារាជមួយអង្គទ្រង់ព្រះនាមយុធិស្ឋិរ (Yudhisthir) បានសោយរាជ-

សម្បត្តិមានព្រះកិត្តិនាមល្បីល្បាញលុះសព្វថ្ងៃ ។ ព្រះមហាក្សត្រិយ៍ដែលមានឫទ្ធានុភាពបែបនេះ ក៏តែងកាលវេលាលេបយកព្រះជន្មាយុអស់ទៅ គ្មានគេចរួចសោះឡើយ ។

" កាលវេលាតែងលេបយកដំរីតសត្វបក្សាបក្សី នៅលើអាកាស, សត្វនៅក្នុងសមុទ្រ ហើយទុក្ខក៏តែងធ្លាក់ទៅលើសត្វទាំងនេះថែមទៀត ។ អ្នកណាដែលនៅលើផែនដីនេះ ក៏មិនអាចគេចឲ្យរួចផុតពីកាលវេលាសោះឡើយ ។ បើទុកជាខ្លួនមានចិត្តជាប់ស្អិតចង់រស់នៅលើផែនដីនេះ ក៏ជាអសារឥតការ ហើយត្រូវតែគោរពប្រតិបត្តិតាមទម្លាប់ នៃសាសនាទាំងឡាយ " ។

កាលលោកវិស្សសម៌ពោលរួចហើយ, គោវិន្ទព្រាហ្មណ៍ ក៏តាំងចិត្តថា " ត្រូវតែប្រព្រឹត្តខ្លួនឲ្យគុណធម៌ " ហើយមានប្រសាសន៍ទៅកាន់បុត្រាខ្លួនថា: " កូនពេលដែលអញកំពុងអង្គុយធ្វើពលិកម្ម, ចូរឯងទៅឯសមុទ្រ ទៅរកអណ្តើកមួយមកឲ្យអញ " ។

បុត្រាបានទទួលបង្គាប់ហើយក៏ទៅរកអ្នកនេសាទត្រី ហើយពោលថា " ចូរអ្នកយកក្រចាក់នេះហើយយកអណ្តើកមកឲ្យខ្ញុំមួយកុំខាន " ។ អ្នកនេសាទក៏យកក្រចាក់នោះ ហើយក៏យកអណ្តើកមកឲ្យបុរសនោះ ។ កូនប្សធ៌ពោលទៅកាន់ប្អូនបង្ហាប់ថា: " ចូរអ្នកយកអណ្តើកនេះទៅឲ្យលោកឪពុក " ។ ប្អូនបង្ហាប់ប្រើទៅប្អូនទៀត, តែប្អូនទៅមិនព្រមយក

ទៅ, ដោយពោលច្រែកថា: "ចានជារបស់ខ្ញុំមិនយកទៅ, ព្រោះដៃខ្ញុំកាលណាពាល់អណ្តើកមុខជាជាប់ភ្ជុនស្អុយមកជាមួយផង ព្រោះខ្ញុំជាបុគ្គលរើសអើងម្ហូបអាហារ ។

អ្នកបន្ទាប់ថា: ខ្ញុំជាបុគ្គលរើសអើងស្លឹក ។

បន្ទាប់ថា: ខ្ញុំជាបុគ្គលរើសអើងវែក ។

ដល់ឈ្មោះគ្នាទៅវិញទៅមក, បុរសទាំងបីនាក់ក៏មិនបានយកអណ្តើកទៅដូនព្រាហ្មណ៍ជាបិតា, ហើយក៏ដើរទៅដល់មុខទ្វារព្រះបរមរាជវាំង, បង្គាប់ទៅនាយទ្វារថ្វាយឲ្យទៅក្រាបទូលព្រះមហាក្សត្រិយ៍ថា មានព្រាហ្មណ៍បីនាក់មានរឿងវិវាទឈ្មោះគ្នា" ។

នាយទ្វារក៏បានទៅក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ ។ ទ្រង់មានព្រះបន្ទូលឲ្យហៅព្រាហ្មណ៍ទាំងបីនាក់មកសួរថា "ហេតុម្តេចក៏បានជាអ្នកឯងទាស់ឈ្មោះគ្នា?" ។

អ្នកទៅក្រាបបង្គំទូលថា: "ទូលបង្គំជាអ្នករើសអើងម្ហូបអាហារ ។

អ្នកបន្ទាប់ក្រាបបង្គំទូលថា "បពិត្រព្រះភូមិន្ទ, ទូលបង្គំជាអ្នករើសអើងស្លឹក" ។

បន្ទាប់ទៀតក្រាបបង្គំទូលថា: "បពិត្រព្រះធម្មិកពាជ, ទូលបង្គំជាអ្នករើសអើងវែកដេក (ដំណេក)" ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះពាជនុង្ហារថា: "ខ្ញុំនឹងពិសោធន៍មើលខ្លួរការសើរអើងគំនិនេះឲ្យដាក់ស្តែង" ហើយទ្រង់ហៅនាយពិសេស មកបង្គាប់ឲ្យរៀបចំម្ហូបអាហារផ្សេង ។ ដោយម៉ត់ចត់ ដើម្បីឲ្យដល់ព្រាហ្មណ៍ដែលជាអ្នកសើរអើងអាហារ ។ នាយពិសេសក៏បានធ្វើម្ហូបអាហារដាក់នឹងបានយកមកជូនព្រាហ្មណ៍ តែដល់ព្រាហ្មណ៍បរិភោគម្ហូបនោះមួយម៉ាត់ទៅក៏យល់ថាម្ហូបនេះមានក្លិនស្អុយ ។ ព្រាហ្មណ៍ក៏ទុកម្ហូបនៅទីនោះ, លាងដៃស្អាតហើយទៅក្រាបបង្គំគាល់ព្រះមហាក្សត្រិយ៍ ។ ទ្រង់មានព្រះបន្ទូលសួរថា "តើអ្នកឯងបានបរិភោគអាហារនោះមានឆ្ងាសេដ្ឋទេ?" ។

ព្រាហ្មណ៍ក្រាបបង្គំទូលថា: "ម្ហូបនោះមានក្លិនស្អុយ, ទូលព្រះបង្គំមិនបានបរិភោគនូវម្ហូបនោះទេ" ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះពាជនុង្ហារសួរថា: "តើក្លិនស្អុយនៃម្ហូបនោះមកពីហេតុអ្វី?" ។

ព្រាហ្មណ៍ថ្វាយបង្គំទូលថា: "បពិត្រមហាពាជ, ប៉ាយនេះមកពីស្លរដែលស្ងួតនៅលើថូរបង្ហានចាស់, ហើយប៉ាយនេះបញ្ចេញក្លិនសាកសពស្អុយពន់ពេក, បានជាទូលព្រះបង្គំបរិភោគមិនកើត" ។ ព្រះពាជាកាលទ្រង់ព្រះសណ្តាប់នូវពាក្យព្រាហ្មណ៍នោះហើយ ក៏ត្រាស់ហៅនាយពិសេសមកសួរថា "អង្ករដែលយកមកដាំប៉ាយនេះបានមកពីកូមិណា?" ។

នាយពិសេសក្រាបបង្គំទូលថា: "បពិត្រមហាកជ, ចាយនេះទូលព្រះបង្គំបានយកអង្ករពីភូមិសិវបុរៈ (Çivapur) មកជាំ ។

ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះបន្ទូលឲ្យហៅអ្នកស្រែនៅភូមិនោះមកជួបនឹងព្រះអង្គ ។ ដល់សាមិន្ទារៈ (Samindâr, អ្នកកម្មសិទ្ធដី) មកចំពោះព្រះភក្ត្រព្រះពជា។ ទ្រង់មានព្រះបន្ទូលសួរគហបតីនោះថា: "ស្រែវានោះដាំនៅលើដីឯណា ?" ។ គហបតីក្រាបបង្គំទូលថា: "បពិត្រមហាកជ, ស្រែវានេះដាំលើថ្ងូរដាន" ។

ព្រះពជាទ្រង់មានព្រះបន្ទូលទៅកាព្រាហ្មណ៍នោះថា: "អ្នកឯងថាត្រូវមែន, អ្នកឯងជាអ្នកចិញ្ចឹមប្រសប់ខាងបរិភោគអាហារមែន" ។

រួចទ្រង់ត្រាស់បង្គាប់ឲ្យហៅអ្នកដែលរើសអើងស្ត្រី, ទ្រង់ចាត់ឲ្យជាក់ស្តែងមួយក្នុងបន្ទប់ព្រមទាំងវត្ថុទាំងឡាយ ជាគ្រឿងត្រៃតគាលសព្វគ្រប់, ទ្រង់ត្រាស់បង្គាប់ឲ្យហៅស្ត្រីមួយស្អាតបិមបិយ, មកដេកជាមួយបុរសនោះ ។ អ្នកទាំងពីរកំពុងដដែកគ្នា, ព្រះមហាក្សត្រទ្រង់លាក់បំពួនព្រះអង្គ ហើយឆ្ងើងព្រះនេត្រតាមប្រហោងជញ្ជាំងទៅឃើញព្រាហ្មណ៍នោះរៀបនឹងនុបស្ត្រីនោះ, ស្រាប់តែងាកក្បាលចេញ, ដល់គាត់បានហិតក្លិនមិនគប្បីដែលមកពីឫស្សីដង្កើមស្ត្រី ដកចេញចូលនោះ រួចគាត់ក៏និត្តូលក់ទៅ ។

ព្រះពជាទ្រង់បានជ្រាបនូវរឿងរ៉ាវទាំងនេះ, ទ្រង់ស្តេចយាងវិលត្រឡប់មកកាន់ព្រះបរមរាជវាំងវិញដើម្បីទឹងផ្ទុសម្រាកព្រះកាយ, ព្រឹកឡើងដល់ទ្រង់ស្តេចតើនពីក្នុងព្រះបន្ទំ, ទ្រង់ត្រាស់បង្គាប់ឲ្យហៅព្រាហ្មណ៍នោះមកគាល់ហើយសួរថា "តើព្រាហ្មណ៍ឯងឥយប់មិញ, បានដេកលក់សប្បាយត្រេកត្រអាលសុខស្រួលឬ" ។ ព្រាហ្មណ៍ក៏ក្រាបបង្គំទូលថា: "បពិត្រមហារាជ, ទូលព្រះបង្គំឥតបានសប្បាយត្រេកត្រអាលនឹងស្ត្រីនេះសោះ ព្រោះស្ត្រីនេះមានឱ្យលំអស្បាស:បស្បាស:ដូចកូនពពែ ហើយចិត្តទូលបង្គំមិនប្រតិព័ទ្ធ" ។

ព្រះនរបតីទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ព្រាហ្មណ៍ហើយ ទ្រង់ហៅស្ត្រីម្នាក់ដែលបានយកនារីនេះមកហើយទ្រង់មានព្រះបន្ទូលសួរថា "នារីនេះមកពីណា?" ។ ស្ត្រីនោះក៏ក្រាបបង្គំទូលថា: "នារីនេះជាកូនស្រីបងស្រីខ្ញុំម្ចាស់ ។ កាលនាងនេះមានជន្មាយុ ៣ ខែ មាតាក៏អនិច្ចកម្មទៅ ។ ខ្ញុំម្ចាស់ក៏ឲ្យទឹកដោះពពែចុះ ហើយខ្ញុំម្ចាស់ថែទាំរក្សាតមក" ។

ព្រះពជាទ្រង់ព្រះសណ្តាប់ដូចនោះហើយ, ទ្រង់មានព្រះបន្ទូលទៅកាន់ព្រាហ្មណ៍នោះថា: "មែនហើយ, អ្នកឯងជាអ្នកចេះដឹងជ្រៅជ្រះខាងស្ត្រីពិតមែន" ។

រួចទ្រង់បានបង្គាត់ឲ្យគេយកពូតជាច្រើនផ្ទត់មកក្រាលលើគ្រែ, ហើយទ្រង់ត្រាស់បង្គាប់ឲ្យអ្នកដែលរើសអើងគ្រែ, និទ្រាលើពូតនោះទៅ ។

ដល់ព្រឹកស្អែក ទ្រង់ឃានត្រាស់បង្គាប់ឲ្យហៅបុរសនេះមកហើយទ្រង់មានព្រះបន្ទូលសួរថា "អ្នកឯងដេកលក់ស្រួលទេយប់មិញ?" ។

បុរសនោះក្រាបបង្គំទូលថា: "បពិត្រមហាភាជ, ទូលបង្គំទទួលទានដំណេកឥតលក់សោះយប់មិញ" ។ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលសួរតទៅទៀតថា: "ព្រោះហេតុអ្វី?" ។ បុរសនោះក៏ក្រាបបង្គំទូលថា: "បពិត្រមហាភាជ នៅផ្នត់ពួកទី៧មានភេមមួយចាក់ខ្ទឹងទូលបង្គំ, ហើយទូលបង្គំទទួលទានដំណេកមិនបានសោះ" ។

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្តាប់, ទ្រង់តន្ទូវផ្នត់ពួកទី ៧ ឃើញមានភេមមួយមែន ហើយទ្រង់មានព្រះបន្ទូលទៅកាន់ព្រាហ្មណ៍នោះថា: "ឯងជាអ្នកឆបដឹងពិតប្រាកដជាឆ្កែដេកមែន" ។

ដល់អាវ៉ែក្សបានក្រាបបង្គំទូលព្រះមហាក្សត្រិយ៍សព្វគ្រប់, ក៏ទូលសួរទ្រង់ថា: "បណ្តាអ្នកទាំងបី, តើអ្នកណាប៉ុនប្រសប់ជាងគេ?" ។

ព្រះបាទពិរ - ពិក្រមាជិត ទ្រង់មានព្រះបន្ទូលតបថា: អ្នកក្រោយបង្អស់ ។

អាវ៉ែក្សដល់បានឮព្រះពាជនុង្ការព្រះមហាក្សត្រិយ៍ ក៏វិលត្រឡប់ទៅកាន់រុក្ខជាតិវិញ, ព្រះពាជាទ្រង់ក៏មកយកអាវ៉ែក្សនោះ ចងជាប់លើលើព្រះអង្សានាំយកទៅ ។

ចប់រឿងទី ២៣ នៅមានរឿងទី ២៤ តទៅទៀត ។

រឿងចិញ្ចៀនចិត្យ

អ្នកស្រីសារីយ៉ាន់ ប្រែពីបារាំងមកជាខ្មែរ

(តមក)

ព្រះស្នំតបថា "ម្ចាស់ក្សត្រី! យើងយកថ្នាំពុលបន្តិចដាក់កន្លះកែវ ថ្វាយស្តេចសោយ លុះទ្រង់សោយស្រេចកាលណា ព្រះអង្គមុខជានឹងសន្ធប់"។ ព្រះនាងនឹងស្រីស្នំធ្វើតាមដែលបានគិតគ្នា មិនយូរប៉ុន្មានព្រះមហាក្សត្រដោកសន្ធប់ទៅ ព្រះនាងហូតយកចិញ្ចៀនពីព្រះហស្តព្រះអង្គហើយមានព្រះបន្ទូលថា: "មាជិនា! ខ្ញុំចង់ដោះខ្លួនឲ្យរួចអំពីអំណាចព្រះមហាក្សត្រនេះ ជ្រុតខ្ញុំមិនចង់មើលព្រះភក្ត្រទ្រង់សោះ"។ ស្នំទូលតបថា: "បើដូច្នេះ ចូរព្រះនាងបង្គាប់អាវក្សជាបំរើនៃចិញ្ចៀននេះឲ្យនាំយកស្តេចនេះទៅឯនគរស្តេចវិញទៅ ព្រះនាងនឹងបានរួចពីព្រះអង្គហើយ"។

ព្រះនាងដាក់ចិញ្ចៀនទៅដដែលហើយមានរាជឱង្ការថា: "សូមឲ្យអាវក្សដែលនៅរក្សាចិញ្ចៀននេះ ចេញមក"។ ម៉ែមួនបង្ហាញខ្លួនឲ្យឃើញភ្លាមព្រះនាងហើយនិយាយថា: "បើព្រះជាម្ចាស់លោកត្រាស់ប្រណីព្រះនាងដូច្នេះហើយ សូមព្រះនាងត្រាស់បង្គាប់មកចុះ"។ – ចូរយកអាមនុស្សកំណាចនេះទៅចោលឯស្រុកវិញទៅ"។ ម៉ែមួនត្រកងស្តេចហោះឡើងហើយយកទៅទម្លាក់ចោលនៅប្រាសាទក្នុង។

លុះព្រលឹមឡើងគេមកបើកទ្វារ គេឃើញរូបព្រះអង្គល្អដូចជាព្រះច័ន្ទពេញបូណ៌មី ។ អ្នកស្រុកឃើញហេតុដូច្នេះហើយនោះឡើងទៅទូលព្រះមហាក្សត្រថា: " ព្រះអង្គម្ចាស់អាលីដែលជាព្រះអនុជរបស់ទ្រង់ ឥឡូវផ្ទុះទៅស្តុកស្តឹងក្បែរមាត់ទ្វារក្រុងឯណោះ " ។ ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់ហើយក៏ឡើងគង់សេះប្រញាប់ទៅទីនោះ ទ្រង់បង្គាប់ឲ្យលើកព្រះអនុជយកទៅព្រះបរមរាជវាំង ទ្រង់ហៅពេទ្យហ្មកពិនិត្យក្រែងមានជម្ងឺអ្វី ប៉ុន្តែគេមិនឃើញមានអ្វីសោះ គ្រូពេទ្យក៏បង្គាប់ឲ្យយកទឹកខ្ទេមមកចាក់លើព្រះកេសព្រះអង្គម្ចាស់អាលី ។ ភ្លាវព្រះអង្គឡើង ទ្រង់ចង្អោរទឹកថ្នាំពុលមកវិញ ហើយស្រែកថា: " មាដិនា " ។ ព្រះករុណាទ្រង់ព្រះសំរួលហើយមានព្រះបន្ទូលថា " ចុះរឿងហេតុអ្វីបានជាដល់ម្ល៉េះប្អូន ! មានរឿងរ៉ាវយ៉ាងណាខ្លះ? " ។ ព្រះអង្គម្ចាស់អាលីជំនិតខ្ញុំឡើងទ្រង់ព្រះកន្សែងជាខ្លាំងហើយទូលព្រះពម ទើបទ្រង់ទូលព្រះពមថា: " ក្រាបទូលព្រះពម ! គេលួចយកចិញ្ចៀនរបស់ទូលព្រះបង្គំជាខ្ញុំដោយប្រើកលឧបាយបញ្ឆោត " ។ ព្រះពមទាំងពីរកំសួរទៀតថា " តើគេធ្វើកលបញ្ឆោតយ៉ាងណា? " ។ ព្រះអង្គម្ចាស់អាលីមានព្រះបន្ទូលរៀបរាប់រឿងរ៉ាវតាំងតែពីដើមដល់ចប់ថ្វាយព្រះពមទ្រង់ព្រះសណ្តាប់ ។

- តើប្អូនគិតធ្វើយ៉ាងណាបើដូច្នេះ? ។

- ទូលព្រះបង្គំជាខ្ញុំនឹងទៅតាមរកចិញ្ចៀននោះវិញ លុះត្រាតែមរណភាពមកដល់ ទើបទូលព្រះបង្គំឈប់ ។

- កុំទៅតាមធ្វើអ្វី នៅជាមួយនឹងយើងបានហើយ ។

- ពុទ្ធោ! ខ្ញុំលែងត្រូវតែទៅខាងពុំបានទេ ។

ព្រះអង្គម្ចាស់អាលីបានយាងទៅកាន់ព្រះដំណាក់ដើមវិញ ។ ពួកអ្នកបំរើឃើញព្រះអង្គត្រឡប់មកវិញ ដោយសេចក្តីសុខសប្បាយដូច្នោះ ក៏នាំគ្នាលេងសប្បាយរីករាយ ហើយសរសើរដល់ព្រះសំណាងល្អនៃព្រះអង្គ ។ ទ្រង់ក៏ដោះលែងពួកអ្នកបំរើ ពួកទ្រុកម្ភរភ្លៀ ព្រមទាំងព្រះពរជាន់ខ្លួរផ្សែរៗផង ។

ក្រោយនោះព្រះអង្គម្ចាស់អាលីយកព្រះពរទ្រព្យចំនួន ៥០ ពាន់ឌីណា ទ្រង់ឡើងគង់សេះមួយយ៉ាងចំណាន ទៅក្រាបបង្គំលាព្រះមាតាទាំងពីរ ហើយក៏ស្តេចឆ្ពោះដំរង់ទៅអៀក៉ក់ ។ ទ្រង់ចូលទៅដល់ប៉ាងជាត ទ្រង់ចុះទៅចាស្រាហ៍ ទ្រង់លក់សេះហើយស្តេចដង្ហែទៅមាត់សមុទ្រដើម្បីនឹងឆ្ពោះទៅកាន់កោះ អែលកាហ្សូរ ទ្រង់ប្រទះសំពៅមួយរៀបនឹងចេញ ទ្រង់ទិញសំបុត្រស្រេចក៏ឡើងគង់ទៅ ។

ជួនជាមានដំនោរល្អណាស់ ទ្រង់សោយក្រយាស្ងោយនឹងសោយទឹកស្រាវឹងជាមួយនឹងពួកនាវិក ហើយប្រស័យគ្នាលេងយ៉ាងស្និទ្ធស្នាល, កំពុងតែលេងសើចសប្បាយ ស្រាប់តែសំពៅទៅដល់កោះអែល អង់ប៉ារដែលនៅពាក់កណ្តាលផ្លូវ ។ នៅពេលនោះ មានមនុស្ស ២០០ នាក់ឡើងមកលើសំពៅ ។ វរនាវិកដើរចូលទៅជិតហើយសួរថា: "សូម

លោកមានប្រសាសន៍មកមើល! លោកមានការអ្វី?" ។ តាហានម្នាក់ឆ្លើយថា: "ចូរតាជាបថ: ព្រះពជនី យ៉ាគូតាហ៍ ដែលគង់នៅឯកោះ មែល-កាហ្វូរ ចានផ្ញើសារមួយមកថ្វាយស្តេចកោះនេះថា: បើមានអ្នកដំណើរមកតាអៀកក់ សូមទ្រង់កុំលែងឲ្យទៅ មុនទ្រង់ចានពិនិត្យមើលលក្ខណៈដូចតទៅនេះ: បើទ្រង់ចានឃើញបុរសម្នាក់ក្មេង គ្មានពេមថ្ពាល់ សម្បុរស មុខល្អមានសក់វែង មានប្រជ្រុយមួយនៅថ្ពាល់ខាងស្តាំ មានប្រជ្រុយមួយទៀតធំនៅស្មាខាងស្តាំ សូមព្រះអង្គនាំយកមកឲ្យយើងៗ ទើសម្លាប់ចោល" ។ លោកវេនាវិឯកឆ្លើយតបថា "យើងគ្មានមនុស្សណាមានលក្ខណៈដូចនេះទេ" ។ តាហានតបថា "ព្រះមហាក្សត្រកោះនេះ ទ្រង់បង្គាប់ឲ្យសំពៅចូលមកកែ្សរច្រាំងដើម្បីពិនិត្យមើលម្នាក់ម្តងៗ បើសិនជាគ្មានមនុស្សកិនកាតបែបនេះនៅលើនាវានេះទេ សូមឲ្យព្រះដ៏មានបុណ្យជួយថែរក្សា" ។ លោកវេនាវិឯកត្រឡប់ចូលកងសំពៅហើយច្រាប់ពួកពាណិជថា "ចូរអ្នកដឹងថា ប្រុសម្នាក់ដែលនៅកងកប៉ាល់ជាមួយនឹងយើង ជាមនុស្សដែលគេកំពុងតែរកចាប់តើអ្នកគិតធ្វើដូចម្តេច?" ។ តាចាស់ម្នាក់ដែលមានច្រើជ្រាតជាងគេឆ្លើយថា: "ព្រះអើយ! កិច្ចការនេះនាំឲ្យយើងឃើញហេតុពីរយ៉ាង: ១ យ៉ាងមានអត្ថប្រយោជន៍ ១ យ៉ាងទៀតនាំឲ្យយើងវិនាស" ។

(អានត)

សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

បរិយាយពីពាក្យ "វ៉ន់"

លោក ជាវ-ពិន រៀបរៀង

ក្នុងនាមនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ខ្ញុំសូមបរិយាយនូវបទពិចារណា ព្រះពជពន្ធវតារខ្មែរ ចំពោះពាក្យ "វ៉ន់" ដែលជាព្រះនាមនៃព្រះមហាក្សត្រិយ៍ខ្មែរយើង សម័យអតីត និងសម័យបច្ចុប្បន្ន ដូចតទៅនេះ :

ប្រវត្តិសាស្ត្រខ្មែរ បានបញ្ជាក់ថា: ប្រទេសខ្មែរយើងសម័យអង្គរ មានព្រះមហាក្សត្រិយ៍ដែលមានចុងព្រះនាម "វ៉ន់ ។" ជាច្រើនព្រះអង្គ, សម័យឯទៀត ។ មានសម័យលង្វែកសម័យឧត្តុង្គជាដើម គ្មានទេ; លុះដល់មកសម័យភ្នំពេញទើបមានឡើងវិញ គឺព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម-សីហនុ វ៉ន់ ជាអម្ចាស់ផែនដីប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ, ដែលជាបញ្ហាគួរឲ្យអ្នកប្រវត្តិសាស្ត្រសន្និដ្ឋានជាបទពិចារណា ព្រះពជពន្ធវតារខ្មែរ ដូចខ្ញុំនឹងអធិប្បាយជូនខាងមុខ ។

ពាក្យ "វ៉ន់" ជានាមស័ព្ទ តាសាសំស្ក្រឹត, វចនានុក្រមខ្មែរប្រែថា "ក្រោះ" គឺគ្រឿងក្រោះធ្វើពីដែក ឬពាសដែក ជាគ្រឿងសឹកគ្រឿងចម្បាំង មានអាវក្រោះ រថក្រោះជាដើម; បើជានាមមនុស្ស ដូច

ព្រះនាមព្រះមហាក្សត្រខ្មែរយើងសម័យអង្គរ មានព្រះនាម "ជយវរ្ម័ន" ជាដើម ប្រែថា "ព្រះរាជាទ្រង់ត្រឿងក្រោះឬអាវុធក្រោះមានជ័យ" ។

ព្រះមហាក្សត្រខ្មែរយើងសម័យអង្គរ ដែលមានព្រះនាម "វរ្ម័ន ?" មាន ៣២ ព្រះអង្គ សឹងមានប្រាកដក្នុងសិលាចារឹកខ្មែរ ដែលលោក អាចារ្យ ប៉ាង-ខាត់ ក្រុមជំនុំព្រះវិត្រចិដក នៅពុទ្ធសាសនបណ្ឌិត្យ បានស្រង់មករៀបរៀងជាសៀវភៅ "មគ្គុទ្ទេសក៍នគរ" ដូចរាយព្រះនាម តទៅនេះ គឺ

១ - ព្រះភវវរ្ម័ន ទី ១	រវាង ព.ស.	១០៩៣
២ - ព្រះមហេន្ទ្រវរ្ម័ន	-ដ-	១១៤៣
៣ - ព្រះឦសានវរ្ម័ន ទី ១	-ដ-	១១៥៩, ១១៦៩
៤ - ព្រះភវវរ្ម័ន ទី ២	-ដ-	១១៨២
៥ - ព្រះជយវរ្ម័ន ទី ១	-ដ-	១២០០, ១២១៧
៦ - ព្រះជយវរ្ម័ន ទី ២	-ដ-	១៣៤៥, ១៣៤៧
៧ - ព្រះជយវរ្ម័ន ទី ៣	-ដ-	១៣៤៧, ១៤៤០
៨ - ព្រះឥន្ទ្រវរ្ម័ន ទី ១	-ដ-	១៤២០, ១៤៣២
៩ - ព្រះយសោវរ្ម័ន ទី ១	-ដ-	១៤៣២, ១៤៥៣
១០ - ព្រះហរ្សវរ្ម័ន ទី ១	-ដ-	១៤៥៣, ១៤៦៥
១១ - ព្រះឦសានវរ្ម័ន ទី ២	-ដ-	១៤៦៨

១២ - ព្រះជយវរ្ម័នទី ៤	រវាង ព. ស.	១៤៦៤, ១៤៨៥
១៣ - ព្រះហរ្សវរ្ម័នទី ២	-ដ-	១៤៨៥, ១៤៨៧
១៤ - ព្រះកដេន្ទ្រវរ្ម័នទី ២	-ដ-	១៤៨៧, ១៥១១
១៥ - ព្រះជ័យវរ្ម័នទី ៥	-ដ-	១៥១១-១៥៤៤
១៦ - ព្រះទុទយាទិត្យវរ្ម័នទី ១	-ដ-	១៥៤៤, ១៥៤៥
១៧ - ព្រះជយវីរវរ្ម័ន	-ដ-	១៥៤៥, ១៥៥៣
១៨ - ព្រះសូរ្យវរ្ម័នទី ១	-ដ-	១៥៥៤, ១៥៨២
១៩ - ព្រះទុទយាទិត្យវរ្ម័នទី ២	-ដ-	១៥៨២, ១៦០៨
២០ - ព្រះហរ្សវរ្ម័នទី ៣	-ដ-	១៦០៨, ១៦៣៣
២១ - ព្រះជយវរ្ម័នទី ៦	-ដ-	១៦២៥, ១៦៥០
២២ - ព្រះធរណីន្ទ្រវរ្ម័នទី ១	-ដ-	១៦៥០, ១៦៥៦
២៣ - ព្រះសូរ្យវរ្ម័នទី ២	-ដ-	១៦៥៦, ១៦៧៨
២៤ - ព្រះធរណីន្ទ្រវរ្ម័នទី ២	-ដ-	១៦៧៣
២៥ ព្រះយសោវរ្ម័នទី ២	-ដ-	១៧០៣
២៦ - ព្រះត្រីភុវនាទិត្យវរ្ម័ន	-ដ-	១៧០៨, ១៧២០
២៧ - ព្រះជយវរ្ម័នទី ៧	-ដ-	១៧២៤, ១៧៤៤
២៨ - ព្រះឥន្ទ្រវរ្ម័នទី ២	-ដ-	១៧៤៤, ១៧៨៦
២៩ - ព្រះជយវរ្ម័នទី ៨	-ដ-	១៧៨៦, ១៨៣៨

៣០ -	ព្រះស្រីន្ទ្រវរ្ម័ន	រវាង ព. ស.	១៨៣៨, ១៨៤០
៣១ -	ព្រះស្រីន្ទ្រជយវរ្ម័ន	-ដ-	១៨៤០, ១៨៧០
៣២ -	ព្រះជយវរ្ម្មទិបរមេស្វរ.	-ដ-	១៨៧០ (១)

ប្រាសាទថ្មនៅទីអង្គរតាំងប៉ុន្មាន គឺជាស្នាព្រះហស្តព្រះមហាក្សត្រខ្មែរ ព្រះនាម "វរ្ម័នៗ" ទ្រង់សាងទុកជាព្រះកេរ្តិ៍ ដូចសាកលលោកបានឃើញច្បាស់ស្រាប់ហើយ ។

បណ្តាព្រះមហាក្សត្រព្រះនាម "វរ្ម័ន" តាំង ៣២ ព្រះអង្គនោះ សូមស្រង់យកចំពោះតែព្រះពាជប្រវត្តិព្រះបាទជយវរ្ម័នទី ៧ មកវែងដោយសង្ខេប ព្រោះព្រះពាជាអង្គនេះ ជាវីរៈក្សត្រទ្រង់ប្រកបដោយព្រះមហាតេជានុភាពច្រើន ទ្រង់បព្រឹត្តទសពិធពាជធម្ម ទ្រង់ធ្វើឧត្តមប្រយោជន៍ទុកព្រះកេរ្តិ៍ឲ្យខ្មែរជាន់ក្រោយច្រើនជាង ព្រះមហាក្សត្រ ព្រះនាម "វរ្ម័ន" អង្គឯទៀត ។ សឹងមានក្នុងបុល្លិ៍តាំងសាលាបាំងវិសេសនៅចុងបូព៌ាប្រទេស ដែលលោក ល្វី - ហ្វីណូត៍ អតីតចាងហ្វាងសាលានេះ ជាអ្នកស្រាវជ្រាវរកសិលាចារឹកខ្មែរ បានសរសេរចារឹកភាសាសំស្ក្រឹត ១ មានសេចក្តីថា:

"សិលាចារឹកព្រះបាទជយវរ្ម័នទី ៧ ។ ល ។ បញ្ជាក់ពីដំយដំនះពី "អំពើព្រះពាជកុសលរបស់ព្រះអង្គ គឺទ្រង់កសាងមន្ទីរពេទ្យជាដើម ។ ល ។ "សិលាចារឹកតាំងនោះ បានព្រៃលបំភ្លឺពីព្យាវតារប្រទេសកម្ពុជាកន

---

១ តាំងពីរជ្ជកាលទី ១ មកទល់នឹងរជ្ជកាលទី ៣២ រវាង ៨០០ ឆ្នាំ ។

"អតីតកាលឲ្យយើញច្បាស់ថា ព្រះបាទជយវរ្ម័នទី ៧ ជាមហាក្ស-
"ធិកជ ១ ព្រះអង្គខ្មែរប្រកបដោយធម៌ ។ល។ ព្រះពុទ្ធអង្គនេះជា
"ក្សត្រសឹក (ក្សត្រចម្បាំង) មានដំយុដំនះដកប, ជាវដ្ឋប្រុស មាន
"ប្រសាសនោបាយខាងការចម្រើន, ខ្មែរសាងប្រទេសខ្មែរឲ្យរុងរឿង
ឥតមានព្រះពុទ្ធអង្គណាក្នុងសម័យអង្គរស្មើនឹងព្រះអង្គបាន" ។

ចំណែកលោក សឺដែស អតីតចាងហ្វាងសាលាបារាំងសៃសនៅបុង
បូពាំប្រទេស ជាអ្នកស្រាវជ្រាវរកសិលាចារឹកខ្មែរដែរ បានរៀបរៀង
សៀវភៅ ១ ឈ្មោះ "ជយវរ្ម័នទី ៧" មានសេចក្តីដូចស្រង់មកដោយ
បំព្រួញ តទៅនេះថា:

"ព្រះបាទជយវរ្ម័នទី ៧ ខ្មែរប្រសូតក្នុងរវាង គ. ស. ១១២០ ឬបើ
"យ៉ាងក្រោយណាស់ក្នុង គ. ស. ១១២៥ ជាព្រះពុទ្ធបុត្រព្រះបាទធរ-
"ណេន្ទ្រវរ្ម័នទី ២ ក្នុងវដ្ឋកាលព្រះបាទសូរ្យវរ្ម័នទី ២, ត្រូវជាព្រះអនុជ
"រួមព្រះអយ្យិកាទីឆ្ងព្រះបាទសូរ្យវរ្ម័នទី ២ ដែលខ្មែរបានសាងប្រាសាទ
"នគរវត្ត ។ល។ ខ្មែរព្រះទីវង្គតប្រហែលនៅ គ. ស. ១២០១ (១) ។

"ព្រះបាទជយវរ្ម័នទី ៧ ខ្មែរបានសាងប្រទេសកម្ពុជា (ឲ្យជា
"ប្រទេសមហាអំណាចនៅជ្រោយសុវណ្ណភូមិ) ក្នុងវដ្ឋកាលរបស់ខ្មែរ
ជើង្វី គឺមិនយូរហួសកំណត់ ២០ ឆ្នាំ" ។

---

១ ព្រះជន្ម ៨១ ព្រះវស្សា ។

"នៅលើដញ្ជាំងក្រោសាទចាយ័នទឹងបន្ទាយឆ្នារ គេឃើញមាន
"ឆ្លាក់ព្រះរូបព្រះចាទជយវរ្ម័នទី ៧ ត្រង់កាលដែលទ្រង់ចេញធ្វើសង្គ្រាម
"ដើងទឹកតន្ទឹងពួកចាមដោយកងទ័ពទូក ទ្រង់ព្រះសណ្ដិតកាន់អាវុធ
"កណ្ដាលទូកចម្បាំង មានកងពលអុំថែរនឹងកាន់អាវុធហែព្រះអង្គ៧ផង
"ជាចម្បាំងលើកប្រទេសកម្ពុជាឲ្យផុតស្បែរពីខ្មាំងសត្រូវ ។ ចម្លាក់
"នេះសម្រេចក្តីឲ្យឃើញថា ប្រទេសខ្មែរសម័យបុរាណធ្លាប់មានកងទ័ព
"ដើងទឹកដើងគោក ឃ្លាំងដំនាញ" ។

"គេទុកព្រះពាជអង្គនេះ ជាស្តេចធំបំផុតដែលទ្រង់បានពង្រីកព្រះ
"រាជអាណាច័ក្រខ្មែរឲ្យធំទូលាយ (ជាងសព្វថ្ងៃនេះច្រើនភាគ) ។ល។

"សិលាចារឹក ១២ កន្លែង ជាសិលាចារឹកប្រកាសមន្ទីរពេទ្យ មាន
"សេចក្តីដូចគ្នាទាំងអស់ថា: ព្រះចាទជយវរ្ម័នទី៧ទ្រង់មានព្រះរាជប្លង់ទុយ
"ជាបុណ្យទ្រង់ប្រឈួនដោយជម្ងឺបណ្តាកស្តេ ជាងប្រឈួនដោយ ព្រះ
"រោគផ្ទាល់ព្រះអង្គ ។ នេះជាព្រះធម្មៈដ៏សំខាន់ក្នុងអារ្យធម៌ទឹងកងនែន
"ការគ្រប់គ្រងប្រទេសរបស់ព្រះមហាក្សត្រីអគ្គមហេសីរជ្ជខ្មែរ ដែលត្រូវ
"ទទួលខុសត្រូវកងសេចក្តីសុខរបស់ប្រជាកស្តេ ។ ព្រះចាទជយវរ្ម័ន
"ទី ៧ ទ្រង់បានសាងមន្ទីរពេទ្យ ១០២ កន្លែង ក្នុងទិសទាំង ៤ នៃព្រះ
"នគរជាងក្រៅទីក្រុង មានមន្ទីរពេទ្យនៅក្នុងក្រុងធំៗ សំខាន់ជាង
"នេះទៀត គឺនៅទីអង្គរជាដើម" ។

"ព្រះពជធានីខ្មែរសម័យនោះឈ្មោះ "យសោធរបុរៈ" ព្រះបាទ
"ជយវរ្ម័នទី ៧ ទ្រង់រៀបចំដួសដុលជាថ្មីឲ្យល្អជាងដើម ទ្រង់បានសាង
"ទីក្រុងថ្មីៗទៀត មានទាំងប្រាសាទបាយ័នដែលសាងពីមុនៗក្នុងកំពែង
"ក្រុងថ្មីនោះផង, ប៉ុន្តែដែលសំខាន់ជាងគេ គឺទ្រង់សាងនគរធំព្រមទាំង
"កំពែងចំនួន ១២ គង់ម្ដែតែព័ទ្ធជុំវិញ ទឹងប្រាសាទនៅកណ្ដាលគឺប្រាំ-
"សាទបាយ័ន-តាព្រហ្ម-បន្ទាយក្ដី-ព្រះខាន់-នាគព័ទ្ធ-តាសោម-តា-
"នៃបន្ទាយឆ្នារ ជាដើម សុទ្ធតែជាការថ្មីទាំងអស់ ។ ឥតមានស្ដេច
"ស្រុកណាមួយ អាចធ្វើថ្មឲ្យវាញ្ជួយឲ្យកម្រើកដូចព្រះមហាក្សត្រអង្គនេះ
"ឡើយ ។ ល ។ ។ ល ។

សូមស្ទេរព្រះពជប្រវត្តិព្រះមហាក្សត្រ ព្រះនាមវរ្ម័នសម័យអង្គរ
ត្រឹមប៉ុណ្ណេះ, ហើយសូមបរិយាយអំពីព្រះពជប្រវត្តិ នៃព្រះមហាក្សត្រ
ព្រះនាមវរ្ម័នសម័យបច្ចុប្បន្ននេះដោយសង្ខេបតទៅ :

ប្រទេសកម្ពុជាបានប្រាសនិវាសចាកព្រះមហាក្សត្រខ្មែរព្រះនាមវរ្ម័ន
រាវ ៥០០ រយឆ្នាំទៅហើយ, លុះមកដល់សម័យក្នុំពេញ ក្នុងរជ្ជកាល
បច្ចុប្បន្ននេះ ទើបមានឡើងវិញ គឺព្រះករុណាព្រះបាទសម្ដេចព្រះ
នរោត្តម-សីហនុ វរ្ម័ន ព្រះចៅប្រទេសកម្ពុជាជាអម្ចាស់ជីវិតលើត្បូង
របស់យើងសព្វថ្ងៃនេះ ។

ព្រះប្រិយមហាក្សត្រអង្គនេះ គឺជាព្រះមហាក្សត្រតំណព្រះពជវង្ស វ៉ន្នសម័យអង្គរដោយព្រះបរមនាមផង ដោយព្រះគុណសម្បត្តិផង ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ កំពេញ សូមព្រះពជទានព្រះបរមពជវរោកាសបរិយាយអំពីព្រះបរមនាម ទំនឹងព្រះគុណសម្បត្តិនៃព្រះកុណាជាអម្ចាស់ជីវិតលើត្បូង ដូចតទៅនេះ :

ព្រះបរមនាមនៃព្រះប្រិយមហាក្សត្រ ព្រះចៅប្រទេសកម្ពុជាយើងសព្វថ្ងៃនេះចែកជា ៣បទ គឺ ១- ព្រះនរោត្តម ២- ព្រះសីហនុ ៣- ព្រះវរ្ម័ន ។

១ – ព្រះបរមនាម "នរោត្តម" ជាព្រះគោត្តនាម ដែលសន្ធតតាមព្រះនាមព្រះកុណាព្រះចៅទសម្តេចព្រះនរោត្តម (ព្រះសុវណ្ណគោដ្ឋ) ជាព្រះពជអយ្យកោទួតនៃព្រះអង្គ ។

២ – ព្រះបរមនាម "សីហនុ" ជាព្រះនាមដើម ដែលសម្តេចព្រះបរមពជបិតា ទំនឹងសម្តេចព្រះបរមពជជននីនាថ ទ្រង់ព្រះពជទាន កាលព្រះអង្គប្រសូតមក, ដូចទំនឹងព្រះនាមព្រះចៅទ "សីហមុនី" ជាព្រះពជអយ្យកោព្រះសម្មាសម្ពុទ្ធ (សមណគោតម) បរមគ្រូយើង, តែលុបតួ "ហ" ១ចេញ ដើម្បីស្រួលអាន ។

៣ – ព្រះបរមនាម "វ៉ន្ន" ជាព្រះនាមដែលថ្វាយកាលព្រះអង្គទ្បើងសោយពជសម្បត្តិគ្រប់គ្រងព្រះពជអាណាចក្រកម្ពុជា, ដូចទំនឹងព្រះនាមព្រះមហាក្សត្រ ព្រះនាមវ៉ន្នសម័យអង្គរ មានព្រះចៅទជយវ៉ន្នទី ៧ ជាដើម ដែលជាក្សត្រសឹកដ៏ពូកែ ។

ព្រះបរមនាម "ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម-សីហនុ វរ្ម័ន" ប្រែថា "ព្រះពាជាដ៏ឧត្តមជាធំប្រជាជន ទ្រង់គ្រឿងរុះរោយ ជាគ្រឿងសឹក ដ៏មានព្រះមហិទ្ធិរិទ្ធ្ជូចពាជសីហ៍" ។

ព្រះពាជករណីយកិច្ច នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង របស់យើងសព្វថ្ងៃនេះមានបរិយាយជា ២ ប្រការ គឺ

១ - ព្រះអង្គមានព្រះពាជឆន្ទៈស្វាមីភក្តីចំពោះព្រះពុទ្ធសាសនាជា អគ្គពុទ្ធសាសនូបត្ថម្ភក: ដល់ហាន:ខ្ពស់បំផុត គឺទ្រង់ធ្វើតយកព្រះពាជ-តុកាសក្នុងពាជ្យទ្រង់ព្រះជន្ម ១ ព្រះវស្សាជាដើម ជាព្រះពាជាដំឆ្នើម ពិបាករកព្រះពាជាអង្គណាមកប្រៀបផ្ទឹមឲ្យត្រឹមស្មើបាន, ទ្រង់ប្រព្រឹត្ត ទេសពិធពាធ្លៃមិ, ទ្រង់ធ្វើព្រះពាជករណីយកិច្ចអ្វីៗ សុទ្ធតែប្រកបដោយធម៌ ពាំងអស់, ទោះបីព្រះអង្គទ្បត់ព្រះពាជទ្រព្យយ៉ាងណាក៏ពុំទ្រង់វេល ថែម ពាំងទ្រង់លះបង់សិរីពាជសុខក្នុងពាជសម្បត្តិដែលជាសុខុមាលសុខផងទៀត ទ្រង់លះបង់សេចក្តីសប្បាយនានាជាកាមារម្មណ៍ ទ្រង់ស៊ូទ្រាំលំបាក ព្រះអង្គ ដោយទ្រង់ព្រះព្យាយាមធ្វើព្រះពាជបេសកកម្មបម្រើប្រទេសជាតិ មាតុភូមិ ដូចយើងបានដឹងឮឃើញច្បាស់ក្នុងគ្រានេះ ។ ប្រវត្តិសាស្ត្រ ប្រទេសកម្ពុជា បានត្រាទុកព្រះអង្គជាព្រះមហាក្សត្រដ៏ទ្រង់លះបង់ខ្ជាប់ព្រះ ពាជអត្តសុខចំពោះព្រះអង្គ ទ្រង់ជូរយកជាតិសុខចំពោះប្រទេសជាតិពាំង មូល, ពោលដោយសង្ខេប គឺថាព្រះអង្គលះបង់សុខខ្លី, ទ្រង់ជូរយកសុខ

វែងឆ្ងំខ្ញុំលាយ, គួរឲ្យរយើងទាំងឡាយស្ញើចព្រះពាជាកិនិហារបារមីនៃ
ព្រះអង្គពន់ពេក;

២ - ព្រះអង្គមានព្រះពាជធន្ធ:ស្មារម័ភក្តីចំពោះប្រទេសជាតិ, ទ្រង់
ព្រះព្យាយាមកសាងឧត្តមប្រយោជន៍ច្រើនយ៉ាងសម្រាប់ប្រទេស តាម
លំនាំព្រះមហាក្សត្រខ្មែរព្រះនាមវរ្ម័ន ដំនាន់មហានគរ មានទ្រង់ផ្តើមសាង
ទឹងទ្រង់ទំនុកបម្រុងវិទ្យាល័យព្រះសីហនុ នៅក្រុងកំពង់ចាម ព្រមទាំង
ទ្រង់ទំនុកបម្រុងអ្នករៀនសូត្រ ហើយទឹងមន្ទីរពេទ្យព្រះសីហនុ នៅក្រុង
កំពង់ព្រញ ព្រមទាំងទ្រង់ទំនុកបម្រុងអ្នកជម្ងឺជាដើម, ទ្រង់ផ្តើមលះបង់លទ្ធិ-
សម្បូរណាជាសិទ្ធិពាជ, ទ្រង់រៀបចំប្រទេសកម្ពុជាឲ្យជាប្រទេសកាន់លទ្ធិ
ប្រជាធិបតេយ្យ, ទ្រង់ព្រះពាជទានរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាឲ្យប្រជាជនរួម
ជាតិមានសេរីភាពពេញទំហឹង ដូចប្រទេសសេរីទាំងឡាយក្នុងសាកលលោក ទ្រង់
រៀបចំព្រះពាជវាំងកិច្ចការដ៏រៀបរយឲ្យធ្វើការជាប្រយោជន៍ជាតិពិត។ ។

សព្វថ្ងៃនេះទ្រង់ក្សាហានព្យាយាមបំពេញព្រះពាជបេសកកម្មតាមការ
ឯកភាពដ៏សម្បូណ៌ពិតប្រាកដឲ្យខាងតែបាន ដោយសន្តិវិធី ។ ចំណែក
ក្នុងប្រទេសទ្រង់បានរៀបចំផែនការនានា មានផែនការព្រះសីហនុជាដើម
ទ្រង់បង្កើតឲ្យមានកងកម្លាំងហៅថា "កងជីវពល" សម្រាប់ការពារប្រទេស
ឲ្យបានសន្តិសុខ ឲ្យសមជារដ្ឋឯកភាពពិតមែន ។ ប្រវត្តិសាស្ត្រខ្មែរបាន
គាំទ្រព្រះអង្គជាព្រះមហាវីរៈក្សត្រដ៏ឆ្លាសដ៏អង់អាចក្សាហាន ទ្រង់មាន

ប្រសាសនោបាយខាងការចំរើន គឺទ្រង់មានផែនការគ្រប់គ្រងប្រទេស
ស្របទៅតាមផែនការនៃព្រះមហាក្សត្រខ្មែរសម័យអង្គរ ឲ្យប្រទេសកម្ពុជា
រុងរឿងទាំងខាងអាណាចក្រទាំងពុទ្ធចក្រ, គួរឲ្យយើងទាំងឡាយស្ងើច
ព្រះចេស្តាបារមីនៃព្រះអង្គពន់ពេក ទឹងស្រឡាញ់ព្រះអង្គដោយស្មោះ
ទាំងបានថ្វាយខ្លួនថ្វាយជីវិតជាពលរដ្ឋជ្រកក្រោមម្លប់ព្រះពាជសម្ភារបារមី
ដោយសេចក្តីរីករាយជាជាតិ ។

ក្រុមដំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ កំពេញ សូម
ប្តេជ្ញាប្តឹងដល់វត្តសក្តិសិទ្ធិក្នុងលោក សូមប្រសិទ្ធិពរជ័យតែ ថ្វាយ
ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះនរោត្តម-
សីហនុ វរ្ម័ន សូមឲ្យប្រទេសកម្ពុជាបានឯករាជ្យសម្បូណ៌ពិតប្រាកដ ទឹង
បានថ្កើងរុងរឿងទាំងខាងអាណាចក្រ ទាំងខាងពុទ្ធចក្រ សមដូចព្រះ
ពាជបំណងកុំខានឡើយ !

ឯកមាវចនៈ

បទប្រាសាទអង្គរ

ប្រាសាទថ្ម អង្គរខ្មែរ ហែរជេរជាស
បានប្រកាស ពាសពណ៌នា ជាបន្ទាល់
ប្រាប់ដំណឹញ តេញពិតត ឲ្យលោកសាកល
ឲ្យបានស្គាល់ រាល់ប្រទេស ជាតិនានា ។

ថា "ស្រុកខ្មែរ ឯសម័យ អគ្គវរ្ត
ធំប្រាកដ តូរកែកន ចុងបូព៌ា
គឺនៅជ្រោយ សុវណ្ណភូមិ ដ៏សោភា
ដោយវាំង កុ្រតវ័ន ខ្មែរច្រើនអង្គ ។
ដែលទ្រង់សាង ប្រាង្គណ៌ប្រាសាទ ស្អាតសង្ហា
សុទ្ធសិលា ចារឹកកត់ ប្រវត្តិវង្ស
តែមហាកុ្រត នាមវ័ន និពាសបង់
ទៅយូរលង់ ច្រើនរយឆ្នាំ ច្រើនដំនាន់ ។
ទើបផុសបាន មាននាកន្ត ក្រុងភ្នំពេញ
នេះឡើងវិញ ចេញព្រះនាម យ៉ាងជាក់ស្បាន់
គឺព្រះបាទ សីហនុ វ័ន
ដ៏សំខាន់ ជាអម្ចាស់ យើងសព្វថ្ងៃ ។
ជាប្រធាន ចូលប្រទេស និវេសន៍យើង
ថាត្រូវច្បាប់ ឡើងដូចដើម ឆ្នើមពេកក្រៃ
ទាំងពុទ្ធចក្រ អាណាចក្រ ហាក់រីស័យ
ដូចសម័យ នៃអង្គរ បូរាណ ។
ដោយព្រះអង្គ ដ៏ទ្រង់ធម៌ បវរនេះ
ទ្រង់ឋានចេះ ចំណេះឆ្នើម ផ្តើមតវ៉ា

យកឯកភាជ្យ អំណោចពេញ ឲ្យខេមរា
គឺវចនា ខ្មែរឲ្យមាន ជំហានរឹង្គ ។
ដោយសន្តិ - វិធីល្អ ដ៏ប្រសើរ
តាមដំណើរ ដើរប្រៃពៃ នៃបណ្ឌិត
ឲ្យជាតិខ្មែរ ភ្ញាក់ខ្ពស់ រស់ជីវិត
ថ្កើងសក្តិសិទ្ធិ្ធ ដូចវរុំន មុនពុំខាន ។
ចេះត្រែវតែ ខ្មែរស្រីប្រុស ស្រុះព្រមគ្នា
ក្រែកម៉ឺមា លីលាតាម ស្មាមលំអាន
នៃផែនការ ស៊ីហនុ ដ៏ចំណាន
ធ្វើជាហាន ឲ្យបានច្រើន កើនរឹង្គ ។
ឲ្យខ្មែរថ្មី ល្បីដូចចាស់ ជាន់អង្គរ
រឹងដំហរ ពិភពដឹ កម្ពុជា
អាចតតាំង ខ្លាំងក្លា - ក្រៃ ឥតរួញរា
សមនាមា ជាឯកភាជ្យ ពិតមែនអើយ !

ជយោកម្ពុជរដ្ឋ !
ជយោព្រះករុណា !

តំណែងប្រឡងសិស្សសាលាចាស់រង

នៅដែនកូសាំងស៊ីន ភាគខាងត្បូង

ព្រះញោណកោសល ញោណ - ឈឺង

ក្រុមដំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

រៀបរៀង

កាលពីថ្ងៃទី ២០ មេសា ឆ្នាំ ១៩៥៣ នៅដែនកូសាំងស៊ីនភាគខាងត្បូង មានសុកមង្គលដ៏ខ្ពង់ខ្ពស់ គឺពិធីប្រឡងសិស្សសាលាចាស់រង ដែលសិក្សាគ្រប់កំណត់វេលា ៣ ឆ្នាំ តាមប្រកាសរដ្ឋមន្ត្រីក្រសួងធម្មការភ្នំពេញ លេខ ២០៥ ថ្ងៃទី ២ កុម្ភៈ ឆ្នាំ ១៩៥៣ និងប្រកាសរដ្ឋមន្ត្រីក្រសួងសិក្សាធិការយៀកណាមនៃពន្ធនគរ លេខ ៣០៩ ថ្ងៃទី ២៩ មីនា ឆ្នាំ ១៩៥៣, អនុញ្ញាតឲ្យប្រឡងដោយសួស្តី ។ មានសមណៈប្រតិភូពីរក្រុម ចេញដំណើរពីភ្នំពេញ គឺមួយក្រុមទៅកាន់ខេត្តឃ្លាំង, មួយក្រុមទៀតទៅកាន់ខេត្តព្រះត្រពាំង ។

ក) មជ្ឈមប្រឡងនៅសាលាបាលីរងវត្តឃ្លាំង ខេត្តឃ្លាំង

មានគណៈកម្មការ ៦ រូប គឺ

១ – ព្រះគ្រូ បញ្ញាវង្ស ថាច់ - លន់ ចៅអធិការវត្តឃ្លាំង អធិបតី

២ – ព្រះគ្រូ សេខ - នាង សាស្ត្រាចារ្យសាលាចាស់ជាន់ខ្ពស់

សមាជិក

៣- ព្រះមហា ថាច់-ប៊ុច វត្តឃ្លាំង សមាជិក

៤- ព្រះមហា ដេន-វង្ស វត្តតាសិក -

៥- ព្រះមហាឧត្តមវិជ្ជា ថាច់-សាំម វត្តឧណ្ណាលោម -

៦- ព្រះមហាឧត្តមវិជ្ជា ល្ម៉ី-ប៊ូវ លេខាធិការ ។

គណៈកម្មការទាំងនេះបានត្រួតត្រាការប្រឡង រួចហើយពិនិត្យឲ្យពិន្ទុតាមចំណេះវិជ្ជារបស់សិស្សនោះ។ តាមលំដាប់ ។

លទ្ធផលនៃការប្រឡងនៅខែត្រឃ្លាំង

បណ្តាសិស្សចំនួន ៥១ រូប, សិស្សដែលប្រឡងជាប់ពិន្ទុគួរជាបានការគួរឲ្យសញ្ជាប័ត្រ មានចំនួនតែ ៣២ រូប ដូចមានពាយឈ្មោះនឹងសំបុត្ររូបថតជូនទុកនៅមន្ទីរចៅក្រសួងសព្វគ្រប់ស្រាប់ ។

២) មន្ទីរប្រឡងនៅសាលាគណវត្តពោធិសាលរាជ(កំពង់)ខែត្រព្រៃត្រពាំង មានគណៈកម្មការ ៦ រូបគឺ

១- ព្រះញាណកោសល.ញាណ-ឈឺន ក្រុមដំទុំព្រះវិន័យចិដក អធិបតី

២- ព្រះមហាឧត្តមវិជ្ជា ថាច់-លឿក វត្តផ្សោដូង សមាជិក

៣- ព្រះមហាឧត្តមវិជ្ជា វិញ-កឿង វត្តឧណ្ណាលោម -

៤- ព្រះមហាឧត្តមវិជ្ជា សឺន-ត វត្តកង់ស្រុក

៥- ព្រះមហាទត្តមវិជ្ជា ថាប់ ព្រម វត្តកំពង់ស្ពាន សមាជិក

៦- ព្រះមហាទត្តមវិជ្ជា ថាប់ សាប៊ុត វត្តកំពង់ លេខាធិការ ។

គណៈកម្មការទាំងនេះ បានត្រួតត្រាការប្រឡងចាប់តាំងពីម៉ោង ៨ ព្រឹក ថ្ងៃទី ២០ មេសា ឆ្នាំ ១៩៥៣, រួចពិនិត្យឱ្យពិន្ទុតាមចំណេះវិជ្ជារបស់សិស្សតាមលំដាប់ ។

លទ្ធផលនៃការប្រឡងនៅខែត្រព្រះត្រពាំង

ក្នុងបណ្តាសិស្សចំនួន ១០៨ រូប, សិស្សដែលប្រឡងជាប់ពិន្ទុគុកជាបានការគួរឱ្យសញ្ជាំបំផុតមានទំនួនតែ ៧៦ រូប ដូចមានរាយនាមនឹងសំបុត្ររូបថតទុកនៅមន្ទីរចៅក្រសួងសព្វគ្រប់ស្រាប់ ។

ទីរង់ការមុនប្រឡងនៅខែត្រព្រះត្រពាំង

នៅវេលាម៉ោង ១៨ កន្លះល្ងាច ថ្ងៃ ១៨ មេសា ឆ្នាំ ១៩៥៣, ព្រះតេជគុណសុវណ្ណប្បញ្ញោ សឺន-ធន់ មេគណខែត្រព្រះត្រពាំង លោកឱ្យប្រជុំអនុគណនឹងចៅអធិការគ្រប់វត្តកន្លែងខែត្រ ព្រមទាំងពួកពុទ្ធបរិស័ទប្រុសស្រីឱ្យមកជួបជុំ ហើយលោកបញ្ជាឱ្យអធិបតីមេប្រយោគព្រះនាមញាណ-ឈឿន គ្រោកឡើងឈរលើវេទិការធ្វើប្រស័យទៅកាន់ពុទ្ធបរិស័ទពាក់រយនាក់ ដែលស្រែកឃ្លានៅវាលធំចាំស្តាប់ ដោយពាក្យសំឡេងទន្លេសន្ធដែលរាជការយកណាមកបត្តម្ភ ។ ព្រះញាណ-កោសល កំគ្រោកឡើងឈរថ្លែងមាត់ទេសតត្រាងទុកជាមុនអំពីការ

សូមទោស, ជូនសំគួសាធុការពរចំពោះទីប្រជុំ រួចផ្តើមថ្លែងការណ៍សំដៅតែគោលៗ ដូចមានតទៅនេះ ៖

១ — អំពីវិធីប្រឡងភាសាបាលីជាគោលសំខាន់នៃលទ្ធិព្រះពុទ្ធសាសនា, ការសាចាលីមានរបៀបបែបផែនជាលក្ខណៈពិសេសតែមួយគត់ ពុំដាយទឹងសិក្សាតែមរយៈ ៣ ឆ្នាំប៉ុណ្ណោះហើយអាចចេះចាំយកមកប្រឡងបានទេ, តាំងយោបល់ដ៏ប្រណីតសុំតាមការឲ្យបានប្រឡងភាសានេះ តាមផ្លូវរដ្ឋតាំងពីរជាដំបូងនៅខែត្រព្រះត្រពាំងសោត អស់រយៈពេល ៦ ខែទើបសម្រេច ។ សភាពតាំងនេះ អាស្រ័យវិរិយភាពរបស់សាលាគណៈធំធម្មសាសនបណ្ឌិត្យរង់នៅមន្ទីរសមាគមខែត្រឃ្លាំង ខំតស៊ូដោយមុឺងមាត់ពុំបណ្តែតបណ្តោយ, ការកម្រៃដែលបានមកប៉ុណ្ណេះ ទុកជាកត្តាក់ស្នាយ៉ាងខ្លះទី ១ ។

២— អំពីសណ្តាប់ធ្នាប់ កិរិយាមារយាទដ៏ថ្លៃថ្លៃរឹងមាំសេចក្តីឧស្សាហ៍របស់ព្រះសង្ឃ, ព្រះសង្ឃសុះតែចាំនសិក្សារៀនព្រះបរិយត្តិឲ្យចេះដឹងជ្រៅជ្រះ ទើបនឹងអាចយល់សេចក្តីថាធ្វើដូច្នេះខុសដូច្នេះត្រូវ ហើយប្រតិត្តកាន់តាមបែបបទអ្នកបួសដោយខ្ជិលខ្ជួយសព្វគ្រប់បាន, ក្នុងខ្នេះទុកជាកត្តាក់ស្នាជាគំរប់ ២ ។

៣— អំពីគុណបំណាច់សមាគមធំងពុទ្ធសាសនបណ្ឌិត្យរង់នៅខែត្រឃ្លាំង សមាគមនេះមានលោក ឡឹម-ឯម ជាប្រធាន

មួយអន្លើដោយសហការរបស់លោក ចានឆ្លើមទបត្តម្ភសិស្សអ្នករៀនពាំង
ផ្លូវលោកផ្លូវធម៌ដ៏ធំទូលាយយូរឆ្នាំមកហើយ គឺគួតែផ្គត់ផ្គង់នៃនការសព្វចំពូក
ទៅទល់ទឹងធ្វើជំនួយអាហាររូបករណ៍ (ថ្លៃសៀងអាហារ) ដល់
សិស្សពាំងនោះតាមមាន បង្ហូរផលប្រយោជន៍ឲ្យបងប្អូនរួមជាតិអ្នកកូសាំង
ស៊ីនយល់ឃ្លាសនៅបច្ចុប្បន្ន, នេះទុកជាកត្តាក់ស្នាគំរប់ ៣ ។

៤— អំពីការទាក់ទងរវាងព្រះសង្ឃគ្រហស្ថពុទ្ធបរិស័ទ,
ខ្ញុំនេះគឺត្រូវតែរក្សាវិន័យតាមហានៈរៀងខ្លួន, ចំពោះខាងព្រះសង្ឃ ត្រូវរក្សា
អភិសមាចារវត្តមាននៃស្មូកជណ្តប់ត្រៃចីវរ ឲ្យជាបរិមណ្ឌល ប្រតិត្ត
តរិយោបថដេក ដើរ ឈរ អង្គុយឲ្យសមរម្យជាដើម, ចំពោះខាងគ្រហស្ថ
ត្រូវផ្គត់ផ្គង់ដោយបច្ច័យ ៤ តាមកម្លាំងសទ្ធានឹងជឿស្តាប់តាម ធ្វើចិត្ត
ស្មោះស្ម័គ្រឲ្យសមតាមគុណរបស់ទុជ្ឈាសក ត្រង់បទថា សង្ឃៃង
សទ្ធិ សមាធសុខទុក្ខោ ប៉ុណ្ណោះជាអាទិ៍ សេចក្តីថា "ទុជ្ឈាសកទុជ្ឈាសិកា
ត្រូវរួមសុខទុក្ខជាមួយនឹងព្រះសង្ឃសព្វៗកាល" ដោយពិស្តារទៀតគឺ
ត្រូវជាស់តឿនក្រែនរំលឹកទៅវិញទៅមក កុងវេលាដែលមានហេតុឆ្គាំឆ្គង,
នេះជាផ្លែនៃសេចក្តីសាមគ្គីយ៉ាងជ្រាលជ្រៅពិត ជាខសំខាន់គំរប់ ៤ ។

លុះចប់អត្ថបទពាំង ៤ យ៉ាងខាងលើហើយ ព្រះមហាទត្តមរង្សី វិញ
តឿង ត្រាកឈរសូត្រភាក្យប្រកាសអំពាវនាវរបស់សមាគមដដែល
នោះ ដើម្បីឃោសនាកសាងមទ្ទីសមាគមឯកុំពេញ នៅពេលដ៏ខ្លីខាង

មុខឯណោះ ។ ពួកភ្នំទួចវិស័ទក៏ប្រគេនសំពួសាធុការពរថា សាធុ សាធុ ទ្រហឹងអឺងកងឡើងទៅក្រៃយរយៈវេលារាងពីរម៉ោង ។

លុះដល់ម៉ោង ៧,៣០ ថ្ងៃ ២ ៣ ៦ ឆ្នាំម្សាញ់បញ្ចស័ក ព.ស ២៤៩៦, (២០ មេសា ឆ្នាំ ១៩៥៣) លោក "យ៉ ឃុាំងជាញ់" ចៅហ្វាយខែត្រព្រះត្រពាំងជាមួយនឹងមន្ត្រីខែត្រជាច្រើន ដែលយើងសូមអភ័យទោសដោយមិនអាចនឹកចាំនាមនឹងលំដាប់ឋានក្នុងនេះ បានអញ្ជើញមកកាន់មន្ទីរប្រឡងនៅវត្តពោធិសាលភជាផ្លូវការ ។ គណៈសង្ឃមានព្រះមេគណខែត្រជាដើម នាំគ្នារង់ចាំធ្វើបដិសណ្ឋារៈអញ្ជើញនឹងនិមន្តឡើងគាន់មន្ទីរព្រមគ្នា ។ បន្ទាប់មកព្រះមេគណខែត្របង្ហាញរូបគណៈសង្ឃថា នេះសមណប្រតិភូដែលភជការកម្ពុជាចាត់ឲ្យនិមន្តមក, នេះព្រះអនុគណ, នេះចៅអធិការ ។ រួចហើយគណៈសង្ឃសូត្រដយន្តោដូនលោកចៅហ្វាយខែត្រនឹងក្រុមប៉ារិស័ទរបស់លោក ។ តមកទៀតព្រះញាណកោសលតំណាងគណៈសង្ឃធ្វើធម្មទេសនាប្រស័យចំពោះលោកប្រមុខខែត្រនឹងមន្ត្រីធំតូចទាំងនោះដោយរាក់ទាក់នូវថា ៖

អាត្មាភាពបានទទួលកិត្តិយសជាអ្នកតំណាងក្នុងនាម នៃភ្នំទួចវិស័ទក្នុងពិធីប្រជុំនេះ សូមជូនពរត្រឹមត្រូលសួស្តីដល់អស់លោកដូចមានតទៅនេះ

១- សូមអានុភាពយ៉ាងខ្លាំងបំផុតចំពោះដំណើរបស់លោកចៅហ្វាយខែត្រត្រាំញ ន្ទឹងប៉ារិស័ទដែលបានអញ្ជើញមកជាអធិបតីក្នុងពិធីប្រឡងសាលាបាលីវគ្គជាដំបូងនៅពេលនេះ ។

២- សូមអរគុណ យ៉ាងវិសេសចំពោះរដ្ឋាភិបាលប្រទេសយៀក-ណាមទឹងរដ្ឋាភិបាលប្រទេសកម្ពុជា ដែលមានសេចក្តីអនុគ្រោះស្របគ្នាដោយមិត្តភាព ឲ្យានអនុញ្ញាតឲ្យប្រឡងតាមសុំ ។

៣- សូមទទួលឧបការគុណដ៏ថ្លៃថ្លានេះរបស់ពុទ្ធសាសនបណ្ឌិត្យ រង, សមាគមកូសាំងស៊ីនទឹងសាលា គណៈខែត្រព្រះត្រពាំង ដែលអាច ឧបត្ថម្ភកលាណកិច្ចជាកិច្ចដ៏ធ្ងន់លុបកម្ចាំងឲ្យកើតឡើងបាន ដោយឥត មានធុញ្ញទាន់ហុចផលប្រយោជន៍ដល់យើងកល់គ្នា ឧបមាដូចមាតា បង្ហូរទឹកក្បែរចែកឲ្យបុត្រដូច្នោះ អាត្មាភាពទាំងឡាយសូមកត់ចុះក្នុងប្រវត្តិ-សាស្ត្រទុកថា បម្រុងនឹងធ្វើការណ៍យកចិត្តស្នងវិញ ក្នុងចម្ងាយដីវភាព ត្រឹមណានោះរបស់ខ្លួនៗ តទៅ ។

នៅទីបំផុត អាត្មាភាពទាំងឡាយ សូមបួងសួងប្រសិទ្ធិពរដ៏សំខ្ពស់ ជូនចំពោះរដ្ឋាភិបាលទាំងពីរឲ្យមានជោគជ័យសព្វទិសាទុទិស សូម អសន្តិសុខឃ្លាតឆ្ងាត់ទៅ, សន្តិសុខត្រឡប់វិលចូលមកវិញ ដោយរួស ពន់ពាន់បំណងប្រជាកស្ត្រ, សូមពុទ្ធសាសនបណ្ឌិត្យរង. សមាគម កូសាំងស៊ីន ទឹងសាលាគណៈខែត្រព្រះត្រពាំង ឲ្យានតាំងនៅជាសុខ សព្វៗកាល ដោយអំណាចគុណព្រះរត្នត្រ័យ កុំបីឃ្លៀងឃ្លាតឡើយ ។

ជយោ ព្រះពុទ្ធសាសនា !

ជយោ ប្រទេសយៀកណាម !

ជយោ ប្រទេសកម្ពុជា !

ជយោ ចៅហ្វាយខ្ញុំត្រាវិញ !

លុះចប់ហើយ ព្រះមហាឧត្តមវិជ្ជា ថាប់ លឿក ប្រែជាភាសាយៀកណាម ។

តពីនោះមក លោកចៅហ្វាយខ្ញុំត្រយៀកណាមឡើងឈរលើវេទិកាថ្វែងតបជាភាសាយៀកណាម ដោយប្រសាសន៍ដ៏ផ្អែមល្ហែមគួរឲ្យប្រតិព័ទ្ធ ទៅតាន់ពុទ្ធបរិស័ទថា ៖

សូមពិតពុទ្ធដីកាព្រះករុណាគ្រប់ព្រះអង្គ ! សូមជំពាបលោក-អ្នកចាំឯឡាយ ! អំបាញ់មិញខ្ញុំបានស្តាប់ពុទ្ធដីកាព្រះញាណាគោសលអធិបតីសមណប្រតិភូពីក្នុងពេញ លោកបានថ្វែងការណ៍ដោយសេចក្តីបំប្រួញ លុះដឹងចប់ហើយ លោកចំឆ្លៀតយកឧកាសដ៏ខ្វីជូនស័ព្ទសាធុការពរចំពោះប្រទេសយៀកណាម, ប្រទេសកម្ពុជា ចាំឯខ្លួនខ្ញុំនូវមន្ត្រីសញ្ជាតិយៀក ណាម-កម្ពុជា ដែលបានអញ្ជើញមកជាមួយ ខ្ញុំមានបីតិសោមនស្សឥតអ្វីទឹងប្រៀបបានឡើយ ។

លោកចាំឯឡាយ ! កាលខ្ញុំទើបនឹងមកដល់មន្ទីរសាលាគណភ្នំក្រឡែកយើញព្រះសង្ឃច្រើនកុះករធ្វើបដិសណ្ឋារៈជាកិត្តិយសចំពោះខ្ញុំ រំភើបញាប់ញ័រក្នុងចិត្តប្លែកពីធម្មតា, ដោយខ្ញុំពុំបានដឹងពីមុនថាព្រះសង្ឃក្នុងខែត្រនេះរៀនសូត្រភាសាបាលីបានចេះដឹងជ្រៅជ្រះ អាចប្រឡង

យកសញ្ញាប័ត្រ មានប្រមាណជាង ១០០ ជ្វាយម្ដេះទេ ទឹកស្មានថាលោកទាំងនោះគ្រាន់តែរៀនបន្តិចបន្តួចត្រឹមតែចេះមើលអក្សរបុាលីជាច់ សរសេរតាមសូត្របានតាមរបៀបវត្តប៉ុណ្ណោះឯង លុះឃើញហើយក៏ត្រែកអរព្រឺព្រួចសង្ឃឹមថា ការណ៍យកកិច្ចរបស់ព្រះសង្ឃជាបឋមហេតុវិលនេះនឹងធ្លាក់ជាប់ជាជួរស្មាមដក់នៅកងសន្ធានពុទ្ធបរិស័ទមិនថាជាតិណាជាជាតិណាទេ ព្រោះការសាបុាលីនេះជាមូលវិជ្ជាពុទ្ធសាសនាខ្លួនឯងណាស់ ។ ការប្រឡងវិជ្ជាបុាលីនៅខែត្រព្រះត្រពាំងនេះ ជាធម្មសម្បត្តិមួយយ៉ាងពេញលេញសម្រាប់ខែត្រផង, ខ្ញុំសូមប្រគេនពរ សូមឲ្យព្រះគុណជាបេក្ខសមណៈទាំងឡាយ កើតមានបញ្ញាក្ដីស្វាងកងបញ្ញាគ្រប់អន្ទើ ដូចពន្លឺព្រះអាទិត្យថ្ងៃត្រង់, សូមគណៈកម្មការសម្រាប់ប្រឡងធ្វើការឲ្យបានផលសមតាមប្រាថ្នា កុំឲ្យមានរអាក់រអួលដល់ចប់កិច្ចប្រឡង, សូមគណៈសង្ឃក្នុងខែត្របានចម្រើនចំរើនលូតលាស់ដោយចំណេះវិជ្ជាព្រះពុទ្ធសាសនា គ្រាន់ជាប្រទីបគ្រលំភ្លឺប្រទេសទាំងពីរឲ្យបានរុងរឿងទៅឯអនាគត ។

ជយោ ព្រះពុទ្ធសាសនា !

ជយោ ចៅហ្វាយខែត្រត្រាំវិញ !

លុះចប់ហើយលោក ថាច់-យ៉ី អធិការបឋមសិក្សាខែត្រត្រាំវិញបែកខាងខ្មែរប្រែជាកម្មជការ ។

លុះសូប់សំឡេងឲ្យសាធុការពរួចហើយ ទើបលោកអធិបតីវៃត្រ
ព្រះត្រៃពាំងប្រគេនវិញ្ញាសាប្រឡងទៅគណៈកម្មការ ហើយលាត្រឡប់
ទៅវិញ ។ មុននឹងត្រឡប់ អ្នកចាត់ការសម្រាប់គណៈរួមថតបរិស័ទ
ពាំងអស់, ប៉ែកខាងព្រះសង្ឃមានលោកគ្រូមេគណវត្តពោធិសាលកជ
ជាដើម, ប៉ែកខាងគ្រហស្ថមានលោកចៅហ្វាយវៃត្រយៀកណាមជា
ប្រធានទុកជាអនុស្សាវរីយ៍ ។

លំដាប់តពីនោះមក គណៈកម្មការប្រឡងតាំងផ្តើមបើកវិញ្ញាសា
ដែលមានស្រោមបិទភាគល់ខ បង្ហាញនិស្សិតពាំងនោះចំពោះមុខ ។
មេប្រយោគនឹងសិស្ស កំប្រតិបត្តិវិធីប្រឡងតាមកម្មវិធីពាំងពេលព្រឹក
ល្ងាចជាកាលវិភាគ ដូចមានសេចក្តីកត់ហេតុសព្វគ្រប់ស្រាប់ ។

ទំរង់ការក្រោយប្រឡង

លុះដល់ថ្ងៃ ៥ ១ ១ ៦ ឆ្នាំម្សាញ់បញ្ចាស័ក ព ស. ២៤៨៦ (២៣
មេសា ឆ្នាំ ១៩៤៣) ក្រោយថ្ងៃប្រឡងសរសេរួច វេលាម៉ោង ៩ ព្រឹក
មានការប្រជុំសម្រាប់គណៈត្រង់មន្ទីរដដែល ។ ខណៈនោះព្រះមហាថេរ
ជាមេគណ អនុគណ ចៅអធិការវត្តសម្រោងព្រះនាម គង់ ជាព្រះថេរៈ
ចាស់ទុំ ព្រមទាំងមន្ត្រីឃុំ-ស្រុក អាចារ្យវត្តផ្សេងៗ ក្នុងវៃត្រចានមក
កាន់ទីប្រជុំតាមលិខិតនិមន្ត អញ្ជើញរបស់សាលាគណចុះថ្ងៃទី ១៩
មេសា ឆ្នាំ ១៩៤៣ ដើម្បីស្តាប់សន្និសិទក្នុងសំណាក់ព្រះតេជ-គុណព្រះ
ញាណកោសល ។

កាលនោះ ព្រះថេរៈអង្គនេះ ថ្លែងការប្រែស្រ័យទៅគាន់បរិស័ទ សំដៅយកតែគោលសំខាន់ៗ មាន៤មាត្រា តាំងអំពីវិធីប្រឡងភាសាបាលីជាដើមដរចដល់មាត្រាជាគំរប់ ៤ ផ្សេងដោយអធិប្បាយខ្លះ ប្រហែលគ្នានឹងអត្ថបទក្នុងថ្ងៃទី ១៩ មេសាខាងលើខ្លះ; លុះចប់ហើយទើបព្រះមហាវិញ - កឿង ប្រកាស់សេចក្តីអំពាវនាវរបស់សមាគមដូចមុន ។ បញ្ចប់ការធ្វើប្រស្រ័យនោះនៅម៉ោង ១១ ។

លុះដល់ថ្ងៃ ១៤ ៦ ឆ្នាំម្សាញ់ (ទី ២៦ មេសា ឆ្នាំ ១៩៥៣) ម៉ោង ១៥ រសៀល មានរថយន្តវិសេសមួយគូចយ៉ាងស្អាតជារបស់ក្រមរបស់ព្រះតេជព្រះគុណ សឹង វ័ង វិសុទ្ធិបញ្ញោ ចៅអធិការវត្តចេកជុំ អនុគណស្រុកបណ្តា ខែត្តត្រាវិញ ឲ្យមកទទួលព្រះមេគណខែត្តនឹងសមណប្រតិភូពីភ្នំពេញដើម្បីទៅទស្សនាការមនុីរអនុគណ, សាលាបឋមសិក្សាបាកាំង - ខែត្តក្នុងឃុំហ៊ុបហ៊ា ស្រុកបណ្តានោះ ដែលនៅខាងត្បូងសាលាខែត្ត ប្រហែល ៣០ គ.ម. អំពីសាលាខែត្ត ។ លុះរថយន្តដឹកនឹងដល់ ស្រាប់តែឃើញទង់ជ័យ ៣ ប្រភេទគឺទង់ ឃ្លាកណាម, ទង់ជាតិ ទង់ព្រះពុទ្ធសាសនា លើកឡើងត្រួងត្រាងនៅសងខាងផ្លូវដែលមានចម្ងាយ ១ គ.ម. នឹងដល់ទីនោះ ។ បន្តិចទៀត ក្មួសរៀបឡើងស្តារធំដួង រគាំង បន្ទឹមឡើងយ៉ាងអឺកធឺកកង រំពងទទួលជាកិត្តិយសចំពោះព្រះមេគណខែត្ត ព្រះមហាថេរជាអធិបតីខែត្ត ព្រមទាំងសមណប្រតិភូ

ដែលរៀបដំណើរចុះពីលើរថយន្ត ។ វេលានោះគណៈកម្មការអន្តុគណ
ចេកដែលមានព្រះមហាខត្តមវិជ្ជា ឃុត-យឺន ជានាយបញ្ជាការ ចាន
ឲ្យពួកព្រះសង្ឃមានហានៈជាទុបដ្ឋាយ៍ ទៅអធិការនីវាសិស្សសាលា
ចាលីវង្សជាច្រើនចាំទទួលដំណើរ បន្ទាប់មកទុបាសក-សិកា តទៅទៀត
ក្មួនសិស្សសាលាបឋមសិក្សា មានចំនួនប្រហែល ២០០ ជាយរួមទាំង
កុមារកុមារីកាន់ទង់ជាតិ, ទង់សាសនាឈរអមទាំងខាងឆ្វេង-ស្តាំ តាម
សេចក្តីបញ្ជារបស់លោកគ្រូ-អ្នកគ្រូសាលានោះ ។ លំដាប់នោះ ព្រះ
មហា ឃុត-យឺន អាចារ្យសាលាចាលីវង្សវត្តចេកជំ នាំមុខព្រះសង្ឃសូត្រ
ជយមង្គលប្រគេនពរស្វាគមន៍ ហើយនាំចូលទៅកាន់សាលាចាលីវង្សថ្មី,
មន្ទីរសាលាអន្តុគណាបណ្តោះអាសន្នផង, លុះព្រះសង្ឃនីគ្រហស្ថទៅ
ទីនោះស្ងប់ស្ងៀមហើយ ទើបព្រះមហា ឃុត-យឺន តំណាងអន្តុគណ
ក្រោកឈរសូត្រពាក្យទទួលអំណរ ។ បន្ទាប់មក អាចារ្យសម្រាប់វត្ត
នោះតំណាងបែកខាងគ្រហស្ថសូត្រពាក្យទទួលអំណរ ។ លុះចប់ហើយ
ព្រះមហាមឿង-សាន ហៅម៉ុក (សុវណ្ណប្បញ្ញោ) អាចារ្យសាលា
ចាលីវង្សវត្តភោធិសាលភជ តំណាងព្រះមេគណតបវិញដោយថេរដីកា
ដ៏ជ្រាលជ្រៅ ព្រមទាំងពោលជាសង្គ្រឿនក្រើនរំលឹកកិច្ចការខាងគណៈឲ្យ
ខំធ្វើសេចក្តីប្រតិបត្តិ, រៀនសូត្រ, តាំងសាលាចាលី, សាលាធម្មវិន័យ
ឲ្យមានពាស់វាត្ត ដើម្បីឲ្យកុលបុត្រចូលរៀនដោយងាយ ទើបពុទ្ធ-

សាសនាកន្លងមកនៃខែត្រនេះនឹងចំរើនរុងរឿងទៅបាន ។ តពីតំណាងព្រះមេគណមក លោកគ្រូចៅអធិការវត្តចេកដែរ សូមអាងធនានិមន្តព្រះញាណកោសលឲ្យថ្លែងការណ៍ដ៏ថ្លៃក ។ ដែលខេបនឹងកើតឡើងជាដំបូងក្នុងខែត្រនេះ ចែកជូនពុទ្ធបរិស័ទដែលមិនបានទៅកាន់ទីប្រជុំឲ្យបានស្គាប់ផង ។ លោកអធិបតីប្រតិកូលថ្លែងសារសំខ្លះរឿងហេតុផ្សេងៗ តាមដំណើរការជួបកាលសំដែងនៅខែត្រកន្លងថ្ងៃ ១៩ មេសា ១៩៥៣ ដែរ គឺរៀបរាប់អំពីផលនៃការប្រឡងកាសាបាលីគ្រាបច្ចុប្បន្នជាដើម មិនថ្លែកគ្នាអំពីការដេញប្រហែកកាលកន្លងមុន ១៩១៣ ក្នុងវិហារព្រះតែវមែរតែងតែកុំពេញជាន់នោះទេ ផ្សេងតែប្រែថាលើមាត់ទេចំពោះមុខមេប្រយោគប៉ុណ្ណោះ ។ មុននឹងបញ្ចប់ លោកធ្វើតនុតាសង្ឃាកថាវគ្រះសង្ឃនាំងពួង ប្រគេនតុវាទថា សូមព្រះគុណាទាំងឡាយកុំសុំទ្ធស្មាលនឹងការដើរមើលផ្សារតូចធំពេក ល្មមណាតែមានការចាំនពុំបានសិមទៅ សូម្បីជួញ្ចោះ ក៏ត្រូវតែមានតុបាសកជាវេយ្យាវច្ចៈផងដែរគួរ សូមទឹកដល់ទីកន្លែងពុំគួរគ្រាចកុំក្លេចឲ្យសោះ ដើម្បីរក្សាដម្លៃព្រះពុទ្ធសាសនាកុំឲ្យសាបរលាបដោយសារតែយើងភ្លក់រូបឡើយ ។ លុះចប់កិច្ចការប្រស្រ័យគបគហើយ ព្រះមហាវិញ · តឿង ក្រោកឡើងអានសេចក្តីអំពាវនាវរបស់សមាគមជូបមុនៗ ទៀត ។ បញ្ចប់ការធ្វើបដិសណ្ឋារៈនៅម៉ោង ៥, គណៈកម្មការចាំងអស់ត្រឡប់វិលមកវត្តពោធិសាលភវិញ ។

លុះដល់ម៉ោង ១៥ រសៀលថ្ងៃ ៥ ៗ ៦ ឆ្នាំម្សាញ់បញ្ចស័ក ព. ស. ២៤៨៦ (៣០ មេសា ឆ្នាំ ១៩៤៣) ក្រោយថ្ងៃដែលពិនិត្យវិញ្ញាសាប្រឡងរបស់សិស្សបានដឹងជាជាប់លេខមានប៉ុន្មាន, ធ្លាក់អស់ប៉ុន្មានរួចហើយ មានការប្រជុំសូត្រហៅឈ្មោះសិស្សដែលជាប់ពីខ្ទមក្រៃគេនព្រហ្មចានតាំងពីលេខ ១ ដល់ ៧២ តាមលំដាប់ ។ មុនទឹងប្រគេនព្រហ្មចាន លោកអធិបតីមេប្រយោគឲ្យនុវទថា សូមសិស្សតាំងស្តាយកុំភ័ន្តគំនិតយល់ថា: ការប្រឡង ចញពីសាលាបាលីវង់នេះ សិស្សតែងបានរង្វាន់ដូច្នេះតុំមែនទេ រង្វាន់ពេលនេះកើតដោយសទ្ធាព្រះមេគណនឹងគណៈកម្មការរបស់លោក ។ សិស្សប្រឡងជាប់ ត្រូវបានតែសញ្ញាប័ត្រ ១ សន្ធឹកប៉ុណ្ណោះឯង សញ្ញាប័ត្រនោះសោត បើថ្នាក់សាលាវង់ ត្រូវមានសិទ្ធិចូលទៅប្រឡងដណ្តើមកន្ទែងរៀនទៅសាលាបាលីជាន់ខ្ពស់ ឬប្រើការដទៃបានខ្លះ ប៉ែកខាងពុទ្ធសាសនាតាមសមគួរ, សញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ត្រូវមានសិទ្ធិចូលសំឡាយជាងនេះជាទ្វេគុណ ព្រោះហេតុនោះ ត្រូវលោកតាំងស្តាយខំព្យាយាមបន្តវិញ្ញាឲ្យបានចេះដឹងច្រើនឡើងទៀត កុំអាលបន្ធូរបន្ធយសោយចាកព្យាយាមឡើយ ដ្បិតប្រទេសជាតិមាតុភូមិនឹងសាសនា នៅរង់ចន្ទឹងចាំអស់លោកតាំងស្តាយ សង្ឃឹមថាលោកនឹងជួយជ្រោងឲ្យខ្ពង់ខ្ពស់អណ្តែត

ត្រសែតឡើងបានទៅឯអនាគត ។ ខ្ញុំសូមប្រគេនពរសំពួសាធុការ ឲ្យបានចំរុងចំរើនសព្វៗ កាលកុំបីឃ្លាតឡើយ ។

បន្ទាប់អំពីនោះមកទៀត ព្រះមេគណ រួចហើយលោកចៅអុនញោមវត្ត អាចារ្យសម្រាប់វត្តពោធិសាលភជឲ្យសំពួសាធុការពរបន្តគ្នា ។ លុះចប់ហើយ ទើបនិស្សិតទាំងនោះសូត្រទក្ខិណតបដោយសេចក្តីពីរោះក្បោះក្បាយគួរឲ្យចាប់ចិត្តជាកិរ្យាការ ។

ពិធីប្រគេនត្រហ្មានចប់នៅម៉ោង ១៨ ថ្ងៃ ៣០ មេសា ឆ្នាំ ១៩៥៣ ។

អ្នកនិពន្ធ

ព្រះញាណាកោសល

ញាណ - ឈឹង

ភ្នំពេញសុទិយា

ទស្សនាវដ្តី ផ្សាយជំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៥ ខែធ្នូ លេខ ១២

ព.ស. ២៤៩៦ – គ.ស. ១៩៥៣



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— សាធុរត្ថណាថា	ព្រះគ្រូសិរីសោភ័ណ កិម - តូរ ..	៨៨៦
— នានាសារធម៌	លោក ស៊ុន - ឋកិន	៨៩៥
— ទេវតា ... មានមែនឬទេ	លោក ប៊ូ - ប៊ូ	៩០០
ផ្នែកអក្សរសាស្ត្រ		
— ជំបូន្មានរំលឹកដល់រូមជាតិ	លោក អ៊ុង - ស៊ុមន៍	៩១០
— ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៊ម ...	៩២៣
— រឿងសាមកុក (តមក)	ឧកញ៉ា ង៉ូ - កន	៩២៧
— រឿងអាក្សថ្លែងរឿងម្តៃប្រាំ (តចប់)	លោក វ៉ាយ - ប៊ុក	៩៣១
— រឿងចិញ្ចៀនទិព្យ (តមក)	អ្នកស្រីសារីយ៉ាន់	៩៣៩
— រឿងប៉ូលនឹងវីរ៍ស៊ីនី (តមក)	លោក ដេង - ជ្រើរ	៩៤៤
— សកម្មភាពនៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរ បរិយាយពីពាក្យ រ៉ាន	លោកចាប- ឆិន	៩៤៨
កំណត់ទឹនប្រវត្តិការណ៍		
— ព្រះរាជប្រវត្តិនឹងសេចក្តីអស្ចារ្យ នៃព្រះប្រិយមហាក្សត្រ	ព្រះគ្រូអនុគណ កែ - អ៊ឹន	៩៥៧

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដាវ ១៩២រ..០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE

— Sadhurakkhanakatha	Vén. KEM-TO	886
— Nanasaradharna	M. SIM-HEAN	895
— Les dieux	M. BOU-PO	900

PARTIE LITTERAIRE

— Bons conseils	M. OUNG-SOUM	910
— Education morale (suite) . .	Vén. PEUNG-PAM	923
— Histoire de SAMKOK (suite) . .	Oknha NOU-KAN	927
— Les vingt cinq récits du Mauvais Génie (suite et fin)	M. RAY-BUC	931
— La bague magique (suite) . . .	Mme SARIS-YANN	939
— Paul et Virginie (suite)	M. PHÉNG-CHRIEU	944
— Activité de la Commission des Mœurs et Coutumes (Varman)	M. CHAP-PIN	948

NOTES ET CHRONIQUES

— Activité royale	Vén. KER-OEURN	957

Prix d'abonnement annuel (comprenant 12 numéros): 192$00

សូមជូនដំណឹង

អំពីទស្សនាវដ្តី កម្ពុជសុរិយា

ផ្សាយចេញអំពីពុទ្ធសាសនបណ្ឌិត្យ

បងប្អូនរួមជាតិទាំងឡាយ !

ទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំ ១៩៥៣ ដែលបងប្អូនរួមជាតិបានចុះឈ្មោះជាវមកនោះ នឹងចប់ត្រឹមខែ ១២ នេះហើយ ។ យើងសង្ឃឹមថា អស់លោក - អ្នក នឹងចុះឈ្មោះជាវក្នុងឆ្នាំ ១៩៥៤ តទៅទៀត ។ កិច្ចដែលបងប្អូនរួមជាតិស្ម័គ្រចុះឈ្មោះជាវច្រើនឡើងៗនេះ ឈ្មោះថាជាអ្នកឧបត្ថម្ភអក្សរសាស្ត្រខ្មែរ ឲ្យលូតលាស់ចំរើនឡើងទាំងឈ្មោះថាជាអ្នកជួយឲ្យកម្ងាំង នឹងលើកតំកើងខ្លួនពួកអ្នកនិពន្ធខ្មែរយើង ។ ពុទ្ធសាសនបណ្ឌិត្យ សូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះអស់លោក - អ្នកដែលបានចុះឈ្មោះជាវទាំងនោះ ។

មួយទៀត យើងសូមអស់លោក - អ្នកដែលបានចុះឈ្មោះជាវហើយ ជួយផ្សាយដំណឹងអំពីប្រយោជន៍នៃទស្សនាវដ្តីនេះ ដល់បងប្អូនរួមជាតិដែលនៅជិតខាងផង ។

ឯរឿង"វេកន្តផ្នែកសាសនា នឹងផ្នែកអក្សរសាស្ត្រ ដែលយើងត្រូវចោះពុម្ពក្នុងទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំ ១៩៥៤ ដូចមានពាយមាតិកាតទៅនេះ ៖

ផ្នែកសាសនា

១ - ដំណឹងផ្សេងៗ ខាងព្រះពុទ្ធសាសនា ។

២ - ធម្មទេសនា ដែលមានអត្ថរសច្រើនៗ ។

៣ - សីលធម៌របស់ព្រះពុទ្ធសាសនា ។

៤ - ការជ្រើសរើសច្រៀងព្រះសូត្រខ្លះ ដែលមានសេចក្តីគួរដឹងនឹងជាផ្លូវប្រតិបត្តិ ។

ផ្នែកអក្សរសាស្ត្រ

១ - គោលចារឹកខាងផ្នែកអក្សរសាស្ត្រខ្មែរ ព្រមទាំងការពន្យល់ចាស់ៗ ឬថ្មីនៅប ។

២ - ឯកសារ (រឿង"វេសន្តរ ដូចសិលាចារឹកជាដើម) ។

៣ - រឿងសាមកុក នៅតែចោះពុម្ពតទៅទៀត គ្មានដែលចប់ ។

៤ - សុភាសិតផ្សេងៗ របស់ជាតិយើង និងនានាជាតិ ។

៥ - រឿងច្រៀងខ្មែរ ឬរឿងច្រៀងរបស់នានាជាតិ ។

៦ - រឿងទំនៀមទម្លាប់ខ្មែរ របស់គណៈកម្មការទំនៀមទម្លាប់ខ្មែរ ។ ល ។

ដូច្នេះ បងប្អូនរួមជាតិដែលមានបំណងនឹងជាវទស្សនាវដ្តី កម្ពុជ-សុរិយាប្រចាំឆ្នាំ ១៩៥៤ សូមផ្ញើឈ្មោះពីឥឡូវនេះទៅ អគ្គលេខាធិការ នៃពុទ្ធសាសនបណ្ឌិត្យភ្នំពេញ (M. le Secrétaire Général de l'Institut Bouddhique Phnom-Penh) ដោយមានចុះនាមទីលំនៅ ត្រឹមត្រូវដើម្បីជាវប្រចាំឆ្នាំចំនួន ៦០០ រៀលផង (ក្នុង ១ ឆ្នាំ មាន ១២ សៀវភៅ) ។

ពុទ្ធសាសនបណ្ឌិត្យ

ព្រះត្រៃបិដក

ទេសនាដាក់វិទ្យុប្រទេសកម្ពុជា កាលពីថ្ងៃ ៨ ជាច ខែដើម្ប ឆ្នាំឆ្លូវឯកស័ក
ព.ស. ២៤៩២ (១៩-៦-៤៩)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយគោរព) ។

វេលានេះ អាត្មាភាពសូមសម្តែងពុទ្ធភាសិតមួយបទ ត្រង់ថាលីថា

រក្ខេយ្យ អត្តនោ សាធុំ លវិធំ លោណតំ យថា វែចថា *'បុគ្គលគប្បីរក្សាសេចក្តីល្អរបស់ខ្លួនទុក ដូចជាអំបិលរក្សារសជ្រៃរបស់ខ្លួន'' ។*

អាត្មាភាពសូមអធិប្បាយពន្លឹកសេចក្តីនៃពុទ្ធភាសិតនេះ ឲ្យពិស្តារ ល្មមជាទីសង្វេគការនៃអស់លោក-អ្នកជាពុទ្ធសាសនិកជន ដូចតទៅនេះ:

ពាក្យថា 'រក្សាសេចក្តីល្អរបស់ខ្លួនទុក'' នោះ ចាន់ដល់ការរក្សាសេចក្តីល្អដោយមិនធ្វើសេចក្តីអាក្រក់ គឺធ្វើតែសេចក្តីល្អម្យ៉ាងឲ្យកើតចំរើនឡើង យ៉ាងនេះហៅថារក្សាសេចក្តីល្អរបស់ខ្លួនទុក ។ ពាក្យថា "ដូចជាអំបិលរក្សារសជ្រៃរបស់ខ្លួន" នោះ ធម្មតាអំបិលជាធម្មជាតិមានរសជ្រៃ បើទុកជាគេយកទៅទុកឆ្ងាយឆ្ងាំ ច្របូកច្របល់ជាមួយនឹង

វត្តផ្សេង ។ មានសេដ្ឋមល្លីឆ័ជូរចត់ជាដើម អំបិលក៏មិនប្រែក្លាយទៅតាមវត្តទាំងនោះឡើយ នៅតែរក្សារសប្រៃរបស់ខ្លួនដដែល ។ រួមសេចក្តីថា បុគ្គលត្រូវតែរក្សាសេចក្តីល្អរបស់ខ្លួនទុក ឲ្យដូចជាអំបិលដែលរក្សារសប្រៃរបស់ខ្លួនទុក ដូច្នោះឯង ។

ធម្មតាមនុស្សក្នុងលោកសន្និវាសនេះ មិនថាជាន់ខ្ពស់ជាន់កណ្តាលជាន់ទាបទេ គេមនុស្សប្រភេទណាក៏ដោយ សុទ្ធសឹងតែជាអ្នកត្រូវការចង់បានសុខភាពនឹងវឌ្ឍនភាពដូច ។ គ្នាទាំងអស់ ប៉ុន្តែការស្វែងរកសេចក្តីល្អនោះកម្រនឹងជួបប្រទះបានដោយងាយ ច្រើនតែបះពារគ្នាលើរបស់គ្នាផ្សេង ។ ពីគ្នា ។ ការស្វែងរកសេចក្តីល្អនោះ ខ្លះធ្វើដោយប្រាថ្នាយកខ្លួនជាធំ ហៅថា អត្តាធិបតេយ្យក៏មាន, ខ្លះធ្វើដោយប្រាថ្នាយកលោកជាធំ ហៅថា លោកាធិបតេយ្យក៏មាន, ខ្លះធ្វើដោយប្រាថ្នាយកធម៌គឺប្បាប់ជាធំ ហៅថា ធម្មាធិបតេយ្យក៏មាន ។

ដូចម្តេចដែលហៅថា ធ្វើសេចក្តីល្អដោយប្រាថ្នាយកខ្លួនជាធំ? បុគ្គលពួកខ្លះកង់លោកនេះ បើនឹងធ្វើកិច្ចការអ្វីនោះជាផ្លូវលោកក្តី ផ្លូវធម៌ក្តី ដែលខ្លួនសំគាល់យល់ថាជាអំពើល្អហើយក៏ធ្វើទៅ តែការសំគាល់នោះដួនកាលក៏ត្រូវ ដួនកាលក៏ខុស; ព្រោះហេតុអ្វី? ព្រោះធម្មតាគំនិតរបស់មនុស្សម្នាក់ ។ ដែលធ្វើមគតិការអ្វីនីមួយ។ មិនមែនសុទ្ធតែត្រូវគ្រប់យ៉ាងទាំងអស់ទេ គង់មានភ្លាំងភ្លាត់ខ្លះមិនខាន់ ហេតុនោះ

ការតាំងមាន:ប្រកាន់យកខ្លួន ឬលើកខ្លួនជាធំសម្រែចកិច្ចការគ្រប់ដំពូក
មិនវល់អើពើពិភក្សានឹងអ្នកដទៃ មិនអើពើពីច្បាប់ ច្បាប់ខុសត្រូវ យក
ជំនះតែខ្លួនឯង ឯកិច្ចការនោះ ។ រមែងសម្រែចប្រយោជន៍បានល្អខ្លះ
មិនល្អខ្លះ ដូចេ្នះនឹងហៅថាជាអ្នករក្សាសេចក្តីល្អរបស់ខ្លួនទុកដោយ
បរិបូណ៌ពុំបានឡើយ ។

ត្រង់ពាក្យថា "ខ្លះធ្វើការដោយប្រាថ្នាយកលោកជាធំ" ។ លោកី
ក្នុងទីនេះ បានដល់មនុស្សប្រុសស្រីតាំងគ្រហស្ថតាំងបព្វជិត; បុគ្គល
ណាធ្វើមកិច្ចការអ្វីនីមួយ ធ្វើដោយតម្រូវចិត្តរបស់មនុស្ស មិនតម្រូវតាម
ច្បាប់ បុគ្គលនោះនឹងហៅថាជាអ្នករក្សាសេចក្តីល្អរបស់ខ្លួនទុកដោយ
គ្រប់គ្រាន់ពុំបានឡើយ ។

បុគ្គលអ្នកធ្វើសេចក្តីល្អ ត្រូវកុំធ្វើដោយប្រាថ្នាយកខ្លួនជាធំ គឺកុំ
មាន:ធ្វើតាមតែគំនិតខ្លួនម្នាក់ឯង ត្រូវកុំធ្វើដោយប្រាថ្នាយកលោកជាធំ
គឺកុំធ្វើដោយខ្វាចគេនិន្ទា ត្រូវធ្វើដោយប្រាថ្នាយកច្បាប់ជាធំ យកច្បាប់
ជាគោលពិតៗទើបសេចក្តីល្អនោះនឹងអាចតាំងនៅខ្ជាប់ខ្ជួនអស់កាលដ៏យូរ
អង្វែងបាន; ព្រោះបុគ្គលអ្នកធ្វើសេចក្តីល្អដោយប្រាថ្នាយកខ្លួនជាធំនឹង
ប្រាថ្នាយកលោកជាធំ រមែងមិនបានតាំងនៅមាំក្នុងសេចក្តីល្អនោះឡើយ
កាលបើមានអារម្មណ៍គួរប្រាថ្នាចូលមកជន្ទហុចឲ្យ ឬមានភ័យគួរខ្វាចចូល
មកគម្រាមហើយរមែងលះសេចក្តីល្អនោះចោល; ព្រោះហេតុនោះ បុគ្គល

អ្នកប្រាថ្នាសេចក្តីល្អគឺសេចក្តីសុខនឹងសេចក្តីចំរើនឲ្យកើតឡើងដល់ខ្លួននឹងអ្នកដទៃ ត្រូវតែតស៊ូកុំញាំញីតកុំតក់ស្តុតនឹងឧបស័គ្គផ្សេងៗ ។ កាលពេលដែលកំពុងប្រព្រឹត្តធម៌នោះត្រូវដឹងខ្លួនថា បើខុកជាគេយកទ្រព្យនឹងយកស័ក្តិជាដើមមកល្បួងលួងលោមប្រគល់ឲ្យក្តី ឬគេយកអំណាចមកផ្ញើផ្ញាល់គម្រាមជាក់ក្តី បុគ្គលអ្នកប្រាថ្នាសេចក្តីល្អ កុំគប្បីកន្តំនិតទៅត្រេកអរនឹងវត្ថុទាំងនោះ ឬតក់ស្តុតខ្លាចអំណាចនោះឡើយ ត្រូវតែជំនះឈានកន្លងឧបស័គ្គផ្សេង ។ នោះឲ្យបាន ទើបឈ្មោះថាជាអ្នករក្សាសេចក្តីល្អរបស់ខ្លួន បើមិនដូច្នោះទេ នឹងរក្សាសេចក្តីល្អរបស់ខ្លួនខុកឲ្យគ្រប់គ្រាន់ពុំបានឡើយ ។

អស់លោកសប្បុរសអ្នកស្តាប់គួរជ្រាបថា ធម្មតាមនុស្សក្នុងសកលលោកដែលផ្តើមធ្វើការអ្វីនីមួយ ទោះខាងផ្លូវលោកក្តី ខាងផ្លូវធម៌ក្តី រមែងតែមានគំនិតយោលទៅមុខដើម្បីរកសេចក្តីចំរើនរឿង ។ ខ្លួន តែគំនិតរបស់បុគ្គលពួកខ្លះដើរត្រង់ផ្លូវស្អាតល្អ បើនឹងធ្វើអ្វីគឺមានបំណងចង់ឲ្យបានប្រយោជន៍គឺសេចក្តីសុខ នឹងសេចក្តីចំរើនកើតឡើងដល់ខ្លួននឹងអ្នកដទៃផងយកច្បាប់ជាធំជាប្រមាណផង យ៉ាងនេះក៏មាន គំនិតរបស់បុគ្គលពួកខ្លះជាគំនិតវៀចវេរកុងកាប់កោងដូចដងអន្ទាក់ ឬវៀចកួចកួកដូចអន្ទង់អាងរមែងប្រទាំងគ្នារវាល់មកឯលោក បើនឹងធ្វើអ្វីច្រើនតែបៀតបៀនគេឲ្យវិនាស ឬស្វែងរកទោសសង្កត់សង្កិនគេឲ្យរួញរាថយកម្ចាំង ដើម្បីឲ្យកើត

ប្រយោជន៍ដល់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ ដោយអាងទ្រព្យសម្បត្តិ ឬអាងយុសស័ក្តិឬក៏ខ្លាចគេនិន្ទា ពុំនោះចង់ឲ្យគេសរសើរជាដើម យ៉ាងនេះក៏មាន ។

បពិត្រអស់លោកសប្បុរសទាំងឡាយ ! បើលោកអ្នកត្រូវការក្សាសេចក្តីល្អ សូមដំរះកាយវាចាចិត្តឲ្យបរិសុទ្ធស្អាតតាមកុសលកម្មបថ ១០ ហើយដើរតាមផ្លូវត្រង់ បើខុកជាជល់ទង្គិចប៉ះពាល់លើគំនិតខុចរិតរបស់អ្នកដទៃ បណ្តាលឲ្យកើតទៅជាទោសក្តី ជួបប្រទះនឹងលាភៈសក្ការៈជារបស់គួរប្រាថ្នាក្តី ត្រូវញាំងចិត្តកុំឲ្យរំភើបរួញរា ឬត្រេកអរនឹងរបស់ទាំងនោះឡើយ បើមិនដូច្នោះទេ នឹងតាំងខ្លួនជាអ្នករក្សាសេចក្តីល្អ ឬស្វែងរកសេចក្តីល្អដូចម្តេចបាន ប្រៀបដូចអ្នកធ្វើផ្លូវឆ្លងពីភូមិមួយទៅកាន់ភូមិមួយ ពីស្រុកមួយទៅកាន់ស្រុកមួយ បើចង់ឲ្យថ្នល់មានសណ្ឋានត្រង់ស្មើល្អ ថ្នល់នោះឯងកាលបើចាប់ធ្វើទៅហើយ រមែងតែប៉ះពាល់ទៅលើដីខាងនឹងដុះខ្ទះ ប៉ះពាល់លើដើមឈើគូចធំនឹងព្រៃញាតស្បាតខ្លះ ប៉ះពាល់ទៅលើដំណាំដាំដុះនឹងដីភូមិផ្ទះសម្បែងរបស់អ្នកស្រុកជាដើមខ្លះ, ការប៉ះពាល់ទៅលើវត្ថុផ្សេង ។ ដូច្នេះជាធម្មតានៃការធ្វើថ្នល់ ; អ្នកធ្វើថ្នល់បើមានសេចក្តីខ្លាចរួញរា ប្រទះដីខាងមិនលើកបំពេញ ប្រទះដើមឈើគូចធំនឹងព្រៃញាតស្បាតមិនកាប់ឆ្ការំលាយចេញ ប្រទះដីភូមិផ្ទះសម្បែងរបស់អ្នកស្រុកមិនឲ្យគេរុះរើចេញទេ ហើយធ្វើ

ដោយការចៀសវាងដូច្នេះ ថ្នល់នោះឯងមុខតែរៀបកោងកិចក្ងក់មិនត្រង់ស្មើល្អឡើយ, បើចង់ឲ្យថ្នល់នោះមានសណ្ឋានត្រង់ស្មើល្អលុះតែកុំធ្វើទាន់កុំរួញពន្លឺវត្តដែលជាគ្រឿងទើសទាស់ផ្សេង ។ ព័ទ្ធាងមុខ បើទើសទាស់ទង់អ្វីត្រូវតែកំចាត់បង់របស់នោះចេញ ទើបថ្នល់នោះឯងមានសណ្ឋានត្រង់ស្មើល្អទៅបាន: សេចក្តីប្រៀបនេះយ៉ាងណា, បុគ្គលអ្នកស្វែងកេសេចក្តីល្អ គឺប្រយោជន៍ខាងផ្លូវលោកដូចធ្វើស្រែធ្វើចំការបណ្តាំផ្សេង ។ ក្តី ធ្វើជំនួញដូញតាមដើងទឹកនឹងដើងគោកក្តី ឬស្វែងរកវៀនចំណេះអ្វីផ្សេង ។ ក្តី ការស្វែងរកនោះ ។ រមែងមានសេចក្តីព្រួយឧស្សាហ៍លំបាកជាធម្មតា ប៉ុន្តែនឹងគេចចៀសវាងពុំបាន ក្នុងវេលាកំពុងស្វែងរកនោះ ជួនកាលក៏បានសម្រេចប្រយោជន៍សមតាមចិត្តាក៏មាន ជួនកាលជួបប្រទះទៅលើទុបស័គ្គគឺអន្តរាយផ្សេង ។ ចូលមកបៀតបៀនធ្វើឲ្យអាក់ខានឃ្លាតចាកប្រយោជន៍ក៏មាន តែបើយើងខ្ជាប់តក់ស្តុតញញើតរួញពន្លឺទុបស័គ្គនោះ ។ ហើយ ប្រយោជន៍ដែលត្រូវបានក៏បែរទៅជាឃ្លាតក្បាត់សូន្យទទេទៅវិញ; ហេតុនោះបុគ្គលអ្នកស្វែងរកប្រយោជន៍គឺសេចក្តីល្អនឹងសេចក្តីចំរើន ត្រូវតែអធិដ្ឋានតាំងទុកក្នុងចិត្តថា សេចក្តីល្អដែលអាត្មាអញប្រតិត្តធ្វើនេះ បើទុកជាគេយកទ្រព្យឬយសសក្តិមកល្បួងលួងលោមក្តី ឬមានទុបស័គ្គណាមួយចូលមកបៀតបៀនក្តី អាត្មាអញមិនត្រូវកន្តើគំនិតទៅត្រេកអរនឹងវត្តុតាំងនោះ តាំង

មិនត្រូវរួញរាឲ្យខូចសេចក្តីល្អរបស់អាត្មាអញឡើយ ត្រូវតែជំនះឈានទៅ
កន្លងបុថុជ្ជនភូមិនោះ។ ដរាបណាលុះតែបាន ទើបឈ្មោះថាជាអ្នករក្សា
សេចក្តីល្អរបស់ខ្លួនឲ្យតាំងនៅខ្ជាប់ខ្ជួន អស់កាលជាអង្វែងទៅ តំយ៉ាងនោះដែរ ។

ម្យ៉ាងទៀត បុគ្គលអ្នករក្សាសេចក្តីល្អខាងផ្លូវធម៌តីសាសនា គួរជ្រាបដូច្នេះថា គុណធម៌តីសេចក្តីល្អណាមួយដែលខ្លួនបានប្រព្រឹត្តធ្វើមកអស់កាលដ៏យូរហើយក្តី កំពុងប្រព្រឹត្តធ្វើក្តី នឹងត្រូវប្រព្រឹត្តធ្វើតទៅខាងមុខទៀតក្តី តាំងចិត្តប្រព្រឹត្តធ្វើឲ្យខ្ជាប់ខ្ជួនឲ្យរឹងរឹតតែកើនចំរើនឡើង កុំបន្ធូរបន្ធយលះបង់ចោលដោយសារហេតុណាមួយ ចូលមកបៀតបៀននោះឡើយ ពុំនោះសោតបើខុកជាខ្លួនទៅកន្លងចំណោមមនុស្សអន្ធពាលល្ងង់ខ្លៅអាប់ឥតប្រាជ្ញា មានចិត្តលាមកអាក្រក់ប្រកាន់ខុសឃ្លៀងឃ្លាតចាកធម៌និយ៉ាយណា ក៏នៅតែតាំងចិត្តប្រព្រឹត្តសុចរិតល្អត្រឹមត្រូវដោយកាយ វាចា ចិត្ត ជាដរាប មិនអើពើលុះក្នុងអំណាចនៃមនុស្សអន្ធពាលនោះឡើយ; សេចក្តីនេះ លោកប្រៀបដូចផ្កាឈូក ធម្មតាឈូកជាតំណាជាតិមានភក់ទឹកត្រអូបល្អ បើខុកជាដុះកើតនៅត្រង់កន្លែងសំអុយដែលជាកន្លែងគឺមហាជនតែងយកសម្រាម ឬវត្ថុមានក្លិនស្អុយមិនស្អាតគួរខ្ពើមរអើមទៅចាក់ចោលក៏ដោយ ឈូកនោះឯងវេលាមានផ្កាឡើង ឥតបៀតបៀនក្លាយទៅតាមគ្រឿងសំអុយទាំងនោះឡើយ នៅតែរក្សាជាតិរបស់ខ្លួនមាន

ក្នុងត្រកូលដែល រមែងជាទីរាក់ទាក់ស្រឡាញ់ពេញចិត្តនៃជនទាំងឡាយ មានក្សត្រិយ៍នឹងមន្ត្រីជាដើម ជាផ្កាមានលំអគួរគេលើកដំកល់លើក្បាលដំណេកបាន មានឧបមាយ៉ាងណា, បុគ្គលអ្នកស្តាប់សិក្សារៀនសូត្រតាមពុទ្ធវចនៈហើយប្រព្រឹត្តល្អស្អាតដោយកាយ វាចា ចិត្ត ហៅថាជាសាវ័កបស់ព្រះសម្មាសម្ពុទ្ធ សាវ័កនោះឯង បើទុកជាកើតនៅក្នុងចំណោមនៃមហាជនល្ងង់ខ្លៅងងឹតអាប់ឥតប្រាជ្ញា ឬមនុស្សដែលមានគំនិតរបិញរបុញប្រព្រឹត្តអាក្រក់ក្វាក់ដូចជាគំនរសម្រាមក៏ដោយ លោកក៏មិនមែនសម្លឹងមើលដោយសេចក្តីងងឹតល្ងង់ដូចជាមហាជនទាំងនោះឡើយ លោករមែងពិចារណាឃើញនូវទោសក្នុងកាមនិងអានិសង្សក្នុងការចេញចាកកាមហើយទៅបួស លុះបួសហើយមិនព្រមត្រេកអរត្រឹមផ្នួសដែលបានបួសប៉ុណ្ណោះ ខំប្រឹងព្យាយាមសំអិតសំអាតសីលឲ្យបានបរិសុទ្ធហើយធ្វើសមាធិនឹងបញ្ញា ដរាបដល់បានវិមុត្តិនឹងវិមុត្តិញ្ញាណទស្សនៈ ហើយកំចាត់បង់គំនរអវិជ្ជា គឺសេចក្តីងងឹតល្ងង់ខ្លៅឲ្យឃ្លាតចាកសន្តាន ហើយបានធ្វើគុណវិសេសគឺលោកុត្តរធម៌ ឲ្យបិតនៅក្នុងកណ្តាប់ដៃរបស់ខ្លួនបាន ហើយក៏សម្រេចជាអគ្គទក្ខិណេយ្យបុគ្គលដ៏ប្រសើរក្នុងព្រះពុទ្ធសាសនា ជាអ្នកគួរទទួលនូវការគោរពបូជាអំពីទេវតានឹងមនុស្សទាំងឡាយ យ៉ាងប្រពៃក៏មានឧបមេយ្យដូច្នោះឯង ។

ន័យមួយទៀត ការរក្សាសេចក្តីល្អនេះ បើនឹងអធិប្បាយឲ្យដាយ
ស្តាប់កុងធម៌ទេសនានេះ ដូចអស់លោកសប្បុរសជាពុទ្ធមាមកជន ធ្លាប់
មានបរិយោការប្រតិត្តសុចរិតដោយផ្លូវកាយ វាចា ចិត្ត ព្រមទាំងបុក
ពាសុភាពមានសណ្តាប់ធ្នាប់ រៀបរយល្អមកស្រាប់ហើយក្តី ធ្លាប់បាន
ប្រតិត្តធ្វើកុសលណាមួយ មានទានឧបសីលជាដើមមកស្រាប់ហើយក្តី
បើទុកជាខ្លួនមានគ្រោះថ្នាក់គឺសេចក្តីអន្តរាយផ្សេងៗ ចូលមកបៀតបៀន
យ៉ាងណា ក៏នៅតែមិនព្រមលះចរិយានឹងកុសលនោះៗ ឲ្យសាប
រលាបបាត់ទៅវិញឡើយ ប្រៀបដូចជាអំបិលដែលមិនលះបង់ជាតិប្រៃ
របស់ខ្លួនដោយសារតុដទៃដូច្នោះឯង ។

ធម្មទេសនាដែលអាត្មាភាពសម្តែងមកហើយនេះ ល្មមសមគួរ
ដល់វេលាហើយ, សូមបញ្ចប់ដោយសង្ខេបត្រឹមប៉ុណ្ណេះ ។

តេ អត្ថលទ្ធា សុខិតា វិរុឡ្ហា ពុទ្ធសាសនេ
អរោគា សុខិតា ហោថ សហ សព្ពេហិ ញាតិភិ ។

លោកអ្នកទាំងឡាយជាសប្បុរស សូមបាននូវប្រយោជន៍នឹង
សេចក្តីសុខគ្រប់ប្រការ សូមចំរើនលូតលាស់កុងព្រះពុទ្ធសាសនា
សូមកុំឲ្យមានរោគ សូមឲ្យមានតែសេចក្តីសុខម្យ៉ាង ព្រមទាំងញាតិ
ទាំងឡាយគ្រប់ៗគ្នា ! ។

ជាជាសារធម៌

(ស្រង់ចាកប្បាប់ផ្សេង ៗ មានធម្មបទ ខុទ្ទកនិកាយជាដើម)

របស់

លោក សុីន - ប៉ាន ដៅពុទ្ធសាសនបណ្ឌិត្យ

---

១ – មាតាបិតាជាអ្នកមានគុណដ៏ប្រសើរបំផុតក្នុងលោកនេះ ត្រូវដឹងថាគុណលោកនឹងកប់មិនអស់, ដ្បិតលោកជាបុព្វាចារ្យនឹងជាព្រហ្មរបស់យើង ជាបុត្តធីតា ព្រោះដូច្នោះ យើងជាបុត្តធីតាគួរកប់អានធ្វើសក្ការបូជាលោក តាមហ៊ាន:នោះ ។ ទើបឈ្មោះថាកតញ្ញូ កតវេទិបុគ្គល ។

២ – មនុស្សកើតមកហើយ . ត្រូវមានកិច្ចការធ្វើដូចគ្នាទាំងអស់ រៀវលែងតែច្រើនឬតិច សម្រេចឬមិនសម្រេចប៉ុណ្ណោះ ដូច្នោះគួរយើងជ្រើសរើសធ្វើកិច្ចការណាដែលជាប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃ កុំធ្វើខ្លួនឲ្យជាមនុស្សចង្អៀតលោក គឺមនុស្សមិនបានការ ។

៣ – ការប្រជាប់តាក់តែងខាងក្រៅ មិនជារបស់សំខាន់ប៉ុន្មានទេ ព្រោះធ្វើមនុស្សដទៃឲ្យល្អមួយកាលប៉ុណ្ណោះ ស៊ីនឹងសេចក្តីចេះដឹងសេចក្តីប្រព្រឹត្តល្អមិនបានទេ ព្រោះសេចក្តីចេះដឹង - សេចក្តីប្រព្រឹត្តល្អនោះ ជាហេតុធ្វើខ្លួនឲ្យបានចំរើនលឿនទៅមុខជានិច្ច ។

៤ – ធ្វើកម្មដ៏លាមកកំសឹកចំពោះកុំចូលចិត្តថា មិនមានអ្នកណាឃើញមិនមានអ្នកណាដឹង ដូច្នេះមិនត្រូវទេ ព្រោះមនុស្សដទៃមិនឃើញ

មែន តែទៅតាមធម៌យើញ ឬជាគ្រឿងសៅហ្មងដល់ខ្លួនឯង ហេតុនេះ យើងមិនគួរធ្វើបាបទាំងកាយវាចាឡើយ ទាំងកាយវិបត្តិពោះមុខទេ ។

៥ - បើអ្នកណាមានសេចក្តីសួបកាយ-វាចា-ចិត្ត អ្នកនោះនឹងជាទីគាប់ចិត្តរបស់ទៅតានឹងមនុស្សទាំងឡាយ ។

៦ - បញ្ចក្ខន្ធតាំងនៅទីណា ទុក្ខក៏តាំងនៅទីនោះ, បញ្ចក្ខន្ធមានដរាបណា ទុក្ខក៏មានដរាបនោះ ព្រោះបញ្ចក្ខន្ធជាតួទុក្ខ មានទាំងសភាវទុក្ខទាំងបកិណ្ណកទុក្ខ គ្មានអ្នកណានឹងគេចវាងឲ្យផុតបានទេ ទាំងតាំងនៅយូរក៏មិនបាន នឹងត្រូវបែកធ្លាយទៅតាមសភាពរបស់សង្ខារ ។ បុគ្គលកាលបានដឹងដោយដាក់ច្បាស់ដូច្នេះហើយ មិនត្រូវប្រមាទភ្លើងវ័យក្នុងជីវិតនឹងក្នុងសេចក្តីមិនមានរោគ ត្រូវប្រញាប់ប្រញាល់ស្វែងរកសេចក្តីល្អមកជាកំពូន ដើម្បីនឹងបានជាបច្ច័យទុកបំរុងខ្លួន ឲ្យនៅជាសុខក្នុងបច្ចុប្បន្ននឹងអនាគត រឿងនេះគួរមនសិការៈទុកក្នុងចិត្តឲ្យច្រើន ។

៧ - ផលដែលបុគ្គលប្រាថ្នា នឹងសម្រេចដោយអាការតឹមតែតាំងចិត្តប្រាថ្នាប៉ុណ្ណោះមិនបានទេ ដែលពិតត្រូវប្រតបព្រមដោយការធ្វើ កាលបើធ្វើហើយមិនខាន់គ្រប់គ្រាន់ គឺមានខ្វះខាតនៅឡើយ ត្រូវអាស្រ័យគ្រឿងឧបករណ៍ច្រើនយ៉ាងទៀត ដូចជាត្រូវធ្វើឲ្យជាអ្នកមានសត្តិ មានសេចក្តីព្យាយាម ទន់មានសេចក្តីអត់ធន់ជាដើម ទើបនឹងសម្រេចបានដូចចិត្តប្រាថ្នា ។

៨ - មនុស្សគប្បីប្រញាប់ខ្ជិលខ្ជាយធ្វើសេចក្តីល្អ គប្បីហាមចិត្តចេញចាកសេចក្តីអាក្រក់ ព្រោះថាកាលមនុស្សធ្វើសេចក្តីល្អយឺតយូរពេក ចិត្តនឹងត្រេកអរទៅកាន់សេចក្តីអាក្រក់ ។

៩ - សេចក្តីសុខទៅត្រង់សេចក្តីពេញចិត្ត សេចក្តីទុក្ខទៅត្រង់សេចក្តីមិនពេញចិត្ត ឬអាក់អន់ចិត្ត ។

១០ - ជីវិតរបស់ខ្លួនជាទីស្រឡាញ់ដូចម្តេច ជីវិតរបស់អ្នកដទៃក៏ជាទីស្រឡាញ់ដូច្នោះដែរ សប្បុរសយកខ្លួនទៅប្រៀបធៀបយ៉ាងនេះហើយ ទើបធ្វើសេចក្តីមេត្តាករុណាចំពោះសត្វដែលមានជីវិតខ្លួនឯង ។

១១ - ខ្សែទឹកតែងហូរចុះទៅកាន់ទីទាប មិនត្រឡប់ហូរច្រាស់ឡើងវិញដូចម្តេច ថ្ងៃនឹងយប់ដែលកន្លងទៅក៏នាំអាយុរបស់សត្វទៅរឿយៗ សត្វកាលដូច្នោះដែរ ។

១២ - ទឹងធ្វើនឹងនិយាយការអ្វីៗ ត្រូវពិចារណាឲ្យឃើញជាក់ច្បាស់ជាមុនសិន ទើបការធ្វើឬការនិយាយនោះនឹងបានគប់ប្រសប់លទ្ធផលដ៏គាប់ចិត្ត ។

១៣ - ភ្លាហាន រឹងប៉ឹង អត់ធន់ គំនិតហ្មត់ចត់ ជាលក្ខណាការរបស់មហាបុរស ។

១៤ - អ្នកដែលកំណាញ់ណាស់នឹងលោភណាស់ ចាត់ជាមនុស្សគាល់ត្រណាស់, អ្នកដែលមានយុត្តិធម៌ណាស់ ចាត់ជាអ្នកមានព្រហ្មវិហារ ។

១៥ - កើតស្លាប់ជារបស់គួគ្នា អ្នកខ្វាចស្លាប់ចាត់ជាអ្នកខ្វាចកើត អ្នកមិនខ្វាចស្លាប់ ចាត់ជាអ្នកមិនខ្វាចកើត ។

១៦ - កាម ១ លោក ១ ក្រោធ ១ ឫស្យា ១ មាន: ១ ស្រវឹង ១ កាលបើបុគ្គលលះបង់បានហើយ រមែងមានសេចក្តីសុខ ។

១៧ - មនុស្សអាក្រក់ប្រៀបដូចកាដន់ដី បែកធ្លាយងាយ ជួសជុលផ្សាបានដោយកម្រ តែមនុស្សល្អ ប្រៀបដូចកាដន់មាស កម្រនឹងបែកធ្លាយ តែជួសជុលផ្សាបានដោយងាយ ។

១៨ - កាលបុរសសិក្សាគម្ពីរសោស្តេចចប់ហើយ នៅតែជាមនុស្សវង្វេងងល់ក៏មាន លុះកាលគេបានប្រតិបត្តិដោយប្រពៃហើយ ទើបពាក់ថាជាអ្នកចេះដឹង ប្រៀបដូចថ្នាំដែលពេទ្យគិតធ្យូរយ៉ាងល្អ បើមានតែឈ្មោះប៉ុណ្ណោះ ក៏មិនអាចនឹងរក្សាពេគរបស់មនុស្សឈឺឲ្យសះជាបាន ។

១៩ - សេចក្តីរួញរា ភាវៈក ជាអន្តរាយចំពោះការងារទាំងអស់ គួរតែខ្មៃដោយប្រការទាំងពួង ព្រោះដូច្នោះ កាលបើលះសេចក្តីរួញរាហើយ គង់បានកប់ប្រសប់ផលដែលសម្រេចមកពីការងារ ។

២០ - អង្គគុណណា ដែលបុគ្គលបានកង់ផ្លែការចិញ្ចឹមជីវិត ទើងមានសាធុជនសរសើរជាច្រើនក្នុងលោក អង្គគុណនោះគួរថ្នម ទើងគួរព្យាយាមប្រតិត្តឲ្យជាកិរិយាភាពឡើង ។

២១ - មនុស្សពាល ល្ងង់ខ្លៅ តែងគិតតែនឹងប្រកែកសោះសេចក្តីវិនាសមកជាក់ខ្លួន មិនអាចស្គាល់ផ្លូវដែលនឹងនឹងប្រកែកសោះសេចក្តីល្អមកជាក់ខ្លួនបានទេ, ក្នុងកាលមានអ្នកជាទៃជាស់តឿនឲ្យធ្លើសេចក្តីល្អ ជនពាលនោះត្រឹងយើញការជាស់តឿនរបស់អ្នកជាទៃ ក្នុងផ្លូវដែលល្អថាជារបស់ខ្មុសជានិច្ចទៅវិញ ។

២២ - អ្នកណាជាពាល ដឹងខ្លួនថាជាពាល អ្នកនោះនឹងត្រឡប់ជាបណ្ឌិតបានខ្លះ តែថាអ្នកណាជាពាល ត្រឡប់មានសេចក្តីសំគាល់ថាខ្លួនជាបណ្ឌិតវិញ អ្នកនោះឯងលោកហៅថាជាមនុស្សពាលដោយពិត ។

២៣ - កាលលោកសន្ទិដ្ឋ កំពុងនេះរឿងជានិច្ច លោកអ្នកទាំងឡាយ នឹងនាំគ្នាកែកាយត្រែតត្រអាលដល់ណាទៀត លោកអ្នកទាំងឡាយ ដែលត្រូវនឹងគឺអវិជ្ជាគ្របសង្កត់ហើយ ហេតុអ្វីមិនស្វែងរកប្រទីបគឺបញ្ញាទៀង ។

រឿងព្រះបាទបសេនទិកោសលទូលសួរប្រស្នានឹងព្រះសាស្តា

(កណ្ណកត្ថលសូត្រ សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក)

ឃុនបណ្ណាន្ទរក្ឃ ប៊ូ-ប៉ូ ក្រសួងពុទ្ធសាសនបណ្ឌិត្យជាអ្នកប្រែ(១)

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកណ្ណកត្ថលៈប្រទេសជាទីឲ្យអភ័យដល់ហ្វូងម្រឹគ ដ៏ក្រក្ខ ។ ក៏សម័យនោះឯង ព្រះបាទបសេនទិកោសលបានស្តេចមកដល់ទីក្រុងនោះ ដោយកិច្ចនីមួយ, កាលទ្រង់សោយព្រះស្ងោយក្នុងវេលាព្រឹករួចហើយ ស្តេចចូលទៅគាល់ព្រះដ៏មានព្រះភាគ ប៉ុនក្រាបបង្គំទូលសួរថា "បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គបានឮពាក្យថា ព្រះសមណគោតមត្រាស់ថា គ្មានសមណៈឬព្រាហ្មណ៍ណា ដែលជាអ្នកដឹងសព្វ ឃើញសព្វ ប្តេជ្ញាន្ទវញ្ញាណទស្សនៈគឺការឃើញដោយប្រាជ្ញាឥតសេសសល់ ពាក្យដូច្នេះនេះមិនសមហេតុឡើយ អ្នកណានិយាយយ៉ាងនេះ អ្នកនោះនិយាយតាមព្រះពុទ្ធដីការបស់ព្រះអង្គ មិនមែនទិយាយបង្កាច់ព្រះអង្គដោយពាក្យមិនពិតទេ ឈ្មោះថាព្យាករណ៍ន្ទូវធម៌ដ៏សមគួរដល់នវលោកុត្តរធម៌ ទាំងពាក្យតូចពាក្យធំប្រកបដោយធម៌ឯណានីមួយ ក៏មិនដល់នូវទីគួរតិះដៀលទេឬ?" ។

---

១ មិនបានប្រែពេញតាមប្រយោគបាលីទេ ប្រែកាត់ខ្លី ដើម្បីឲ្យងាយស្តាប់ ។

ព្រះ.- បពិត្រមហារាជ! ជនទាំងនេះនិយាយតាមពាក្យដែលតថាគតពោលមែន តែទាំងមិនឈ្មោះថានិយាយបង្កាច់តថាគតដោយពាក្យមិនពិតមិនពិតផងទេ ។

ព្រះបាទបសេនទិកោសល ទ្រង់ត្រាស់ហៅវិឌូឌភសេនាបតីមកសួរថា "ម្នាលសេនាបតី! នរណានឹងអាចនិយាយសំដីនេះកុងព្រះបរមរាជកំឡាំងបាន?" ។ វិឌូឌភសេនាបតីក្រាបបង្គំទូលថា "បពិត្រមហារាជ! មានតែសញ្ជ័យព្រាហ្មណ៍ជាអាកាសគោត្រ" ។

ព្រះបាទបសេនទិកោសល ទ្រង់ត្រាស់ប្រើរាជបុរសឲ្យទៅហៅសញ្ជ័យព្រាហ្មណ៍ ហើយទ្រង់ក្រាបទូលសួរព្រះសាស្តាថា "ព្រះអង្គបានត្រាស់ពាក្យឯទៀតព្រោះសំដៅយកហេតុណាមួយ អ្នកផងគេចូលចិត្តពាក្យនោះដោយប្រការដទៃដែរឬ? ចុះព្រះអង្គជ្រាបនូវពាក្យតាមសមគួរហើយ ទើបពោលវាចាឬ?" ។

ព្រះ - តថាគតដឹងយ៉ាងនេះហើយបានជាពោលវាចាថា គ្មានសមណៈឬព្រាហ្មណ៍ណា ដែលដឹងនូវប្រការទាំងពួង ឃើញនូវប្រការទាំងពួងតែម្តងទេ សេចក្តីនេះមិនសមហេតុឡើយ ។

ប.- ព្រះអង្គសំដែងនូវពាក្យសមហេតុ នូវពាក្យប្រព្រឹត្តទៅមួយអន្ទើដោយហេតុ ថា គ្មានសមណៈឬព្រាហ្មណ៍ណាដឹងឃើញនូវប្រការទាំងពួងតែម្តងទេ រឿងដូច្នេះនេះមិនសមហេតុឡើយ ។ បពិត្រព្រះអង្គ

ដ៏ចំរើន! ចុះវណ្ណៈទាំង ៤ គឺ ក្សត្រ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ នេះមានសេចក្តីវិសេស នឹង មានសេចក្តីផ្សេងគ្នាដែរឬទេ ?

ព្រះ.- បពិត្រមហាភាគ! វណ្ណៈទាំង ៤ នោះ មានតែវណ្ណៈ ២ គឺ ក្សត្រ ១ ព្រាហ្មណ៍ ១ ដែលប្រាកដថាប្រសើរជាងគេ ព្រោះវណ្ណៈទាំង ២ នេះគួរដល់ការថ្វាយបង្គំ ត្រេកទទួល ធ្វើអញ្ជលិកម្មនឹងសាមីចិកម្ម ។

ប.- ខ្ញុំព្រះអង្គមិនទូលសួរនូវគុណវិសេសក្នុងបច្ចុប្បន្ននេះទេ សូមទូលសួរនូវគុណដែលប្រព្រឹត្តទៅក្នុងបរលោកថា វណ្ណៈទាំង ៤ នោះមានសេចក្តីវិសេសផ្សេងគ្នាដែរឬទេ? ។

ព្រះ.- មានសេចក្តីវិសេសផ្សេងគ្នា គឺបើវណ្ណៈទាំង ៤ នោះបានប្រកបដោយអង្គនៃសេចក្តីព្យាយាមទាំង ៥ យ៉ាងហើយ ការប្រកបនោះប្រព្រឹត្តទៅដើម្បីសេចក្តីសុខ សេចក្តីចំរើន អស់កាលជាយូរអង្វែងដល់វណ្ណៈទាំងនោះ ។ ឯអង្គនៃសេចក្តីព្យាយាមទាំង ៥ យ៉ាងនោះ គឺ

១.- ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធាជឿនូវការត្រាស់ដឹងរបស់ព្រះតថាគត ។

២.- ជាអ្នកគ្មានអាពាធ គ្មានទុក្ខ ប្រកបដោយការចាប់បដិសន្ធិមានវិបាកដ៏ស្មើគ្នា គឺមិនត្រជាក់ពេក មិនក្តៅពេក ជាកណ្តាលអត់ត្រាំនូវសេចក្តីព្យាយាមបាន ។

៣.- ជាអ្នកមិនអួតអាង គ្មានមាយា ធ្វើនូវខ្លួនឲ្យជាក់ច្បាស់តាមសេចក្តីពិតក្នុងព្រះសាស្តាផង ក្នុងសព្រហ្មចារីជាអ្នកប្រាជ្ញទាំងឡាយផង ។

៤.- ជាអ្នកប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ដើម្បីបំពេញនូវកុសលធម៌ទាំងឡាយ មានកម្លាំងចិត្ត មានព្យាយាមដ៏មាំមួន មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយឡើយ ។

៥ - ជាអ្នកមានប្រាជ្ញា ប្រកបដោយបញ្ញាដ៏ប្រសើរ ស្គាល់សេចក្តីកើតឡើងនិងវិនាសទៅ ជាបញ្ញាដល់នូវសេចក្តីអស់ទៅនៃទុក្ខដែលជាគ្រឿងនឿយណាយ ។

ប.- ចុះវណ្ណៈទាំង ៤ នោះប្រកបដោយអង្គនៃសេចក្តីព្យាយាមទាំង ៥ យ៉ាងនេះហើយ តើមានសេចក្តីវិសេសជាងគ្នាផ្សេងគ្នាក្នុងហេតុនេះដែរឬទេ? ។

ព្រះ. បពិត្រមហាពាជ! ទុសគ្នា ប្រៀបដូចសត្វ ២ ពួក គឺដំរីឬសេះ គោ ដែលគេចូរនាន ១ ពួក ដែលគេមិនបានចូរនាន ១ ពួក ។ ពួកដំរី សេះ គោ ដែលគេបានចូរនានប្រឹនប្រដៅល្អហើយ តើបានដល់នូវហេតុដែលគួរចូរនាន ដល់នូវទីដែលគួរចូរនានដែរឬទេ? ។

ប.- បានដល់នូវហេតុដែលគួរចូរនាន ដល់នូវទីដែលគួរចូរនានមែនហើយ ព្រះអង្គ! ។

ព្រះ - ចុះពួកដំរីឬសេះគោដែលគួរចូរនាន ប៉ុន្តែគេមិនបានចូរនានប្រឹនប្រដៅទេ តើបានដល់នូវហេតុដែលគួរចូរនាន ដល់នូវទីគួរចូរនានដូចជាដំរីឬសេះគោដែលគេបានចូរនានប្រឹនប្រដៅល្អហើយដែរឬទេ? ។

ป.- มิនปานเท [พระอัคฺค!] ฯ

[พระ.-] ปุคฺคลมานสทฺธา คฺานอาพาธ ชาอฺกมินอฺตอาง คฺาน มายา [ปาวฺจนูวเสจกฺกิพฺยายาม] มาน[ปาชา] วเมง์ชล่นูวเหตุ ฉณา ปุคฺคลคฺานสทฺธา มานอาพาธเปฺรน ชาอฺกอฺตอาง มานมายา ฉฺลเปฺรอฺส ฅตปาชา นิง์ชล่นูวเหตุโนะชูจคา พากฺยชูเปฺรนนี้ มินสมเหตุเอฺย กัย์ง์นโนะแว ฯ

ป.- [พระ]ง์มานพระภาค พายพากฺยง์สมคูวชล่เหตุ [ปพฺรึกฺต] เอฺมยอเนฺงีชายเหตุ วณฺณ:คำง์ ๔ โนะปฺรกปชายอคฺคนิเสจกฺกี พฺยายาม ๕ ย์ง์นี้ เฌฺนาะชามานเสจกฺกีพฺยายามชายพิต วณฺณ: คำง์โนะมานเสจกฺกีวิเสสชาง์คา เผฺรง์คากง์เหตุนี้ฉง์ ฯ

[พระ.-] ตถาคตมิน พายนูวอำเพิเผฺรง ฯ ปน์ถิจปน์ถจกง์เหตุ นี้คือวิมุตฺถิชายวิมุตฺถิเท ฯ ชูจปุรสยกอุสชเลสูตมกปง์กาต์เกฺง์ กำเกิตเกฺง์เอฺง์ ฯ มานปุรสม์กเอียกยกอุสสฺวายชเลสูตมก ปง์กาต์เกฺง์ กำเกิตเกฺง์เอฺง์แว ฯ ปุรสม์กเอียกยกอุสลฺวา ชเลสูตมกปง์กาต์เกฺง์ กำเกิตเกฺง์เอฺง์แว ฯ [พระ]อัคฺคสำคาลนูว เสจกฺกีโนะชาชูจเมฺตช อำเพิปน์ถิจปน์ถจเผฺรง ฯ รชสเกฺง์คำง์โนะ ชเลเกิตอำพิอุสเผฺรง ฯ คือณฺณาตเกฺง์ชายอณฺณาตเกฺง์กี พณิ ชายพณิกี พฺยนฺชายพฺยนฺชกี ขุสคาแวปฺรเท? ฯ

ប.- មិនទុសគ្នាទេ ព្រះអង្គ! ។

ព្រះ.- តេជៈឯណាដែលបុគ្គលមិនបានញ៉ាំញ៉ី ដោយព្យាយាម ដែលកើតអំពីព្យាយាម តថាគតមិនពោលនូវអំពើបន្តិចបន្តួចថាផ្សេងគ្នាក្នុងតេជៈនោះ គឺរឹមត្តិដោយរឹមត្តិយ៉ាងនេះទេ ។

ប.- ព្រះដ៏មានព្រះភាគពោលពាក្យប្រឌិតមួយអន្ទើដោយហេតុ; ចុះទេវតាមានដែរឬទេ? ។

ព្រះ- ចុះហេតុដូចម្តេចបានជាទ្រង់តម្កល់សួរយ៉ាងនេះវិញ? ។

ប.- ប្រសិនបើទេវតាមានមែន ទេវតាទាំងនោះមុខជានឹងមកកាន់អត្តភាពជាមនុស្សនេះពុំខាន, បើគ្មានទេ ទេវតាទាំងនោះនឹងមិនមកកាន់អត្តភាពជាមនុស្សនេះឡើយ ។

ព្រះ- ពួកទេវតាឯណាមានសេចក្តីព្យាបាទ ទេវតាទាំងនោះទើបមកកាន់អត្តភាពជាមនុស្សនេះ ពួកទេវតាឯណាគ្មានសេចក្តីព្យាបាទ ទេវតាទាំងនោះមិនមកកាន់អត្តភាពជាមនុស្សនេះទេ ។

កាលបើព្រះដ៏មានព្រះភាគមានព្រះពុទ្ធដីកាយ៉ាងនេះហើយ វិឌូឌុកសេនាបតីទូលសួរព្រះដ៏មានព្រះភាគថា "បពិត្រព្រះអង្គដ៏ចំរើន! ពួកទេវតាឯណាមានសេចក្តីព្យាបាទ ទេវតាទាំងនោះទើបមកកាន់អត្តភាពជាមនុស្សនេះ, ពួកទេវតាឯណាគ្មានសេចក្តីព្យាបាទ ទេវតាទាំងនោះមិនមកកាន់អត្តភាពជាមនុស្សនេះទេ ហើយញ៉ាំងទេវតាដែលមានព្យាបាទទាំងនោះឲ្យកន្ត្រាក់កន្ត្រកចាកទីនោះ ប្តូរបណ្តេញចេញបានឬទេ!" ។

លំដាប់នោះ ព្រះអានន្ទត្ថេរត្រិះរិះថា វិឌូឌុភសេនាបតីនេះជាបុត្រ
របស់ព្រះបាទបសេនទិកោសល ឯអាត្មាអញជាបុត្ររបស់ព្រះដ៏មាន
ព្រះភាគ, កាលនេះជាកាលឲ្យបុត្រប្រកួតជាមួយនឹងបុត្រ ។ ទើបព្រះ
អានន្ទដ៏មានអាយុហៅវិឌូឌុភសេនាបតីមកសួរថា "បពិត្រសេនាបតី!
ដើរដូច្នោះអាត្មាភាពនឹងសួរប្រស្នាចំពោះទ្រង់ក្នុងដំណើរនេះវិញ, ប្រស្នា
គួរដល់ទ្រង់យ៉ាងណា សូមទ្រង់ដោះស្រាយយ៉ាងនោះចុះ, បពិត្រសេនា-
បតី! ចុះទ្រង់សំគាល់សេចក្តីនោះថាដូចម្តេច ដែនរបស់ព្រះបាទបសេន-
ទិកោសលត្រឹមណា មួយទៀតព្រះបាទបសេនទិកោសលសោយរាជ-
សម្បត្តិជាឥស្សរាធិបតីក្នុងដែនណា ព្រះអង្គអាចធ្វើឲ្យកន្ត្រើកឬបណ្តើញ
ខ្លួវសមណៈឬព្រាហ្មណ៍ដែលមានបុណ្យក្តី តតបុណ្យក្តី ប្រព្រឹត្តល្អក្តី
អាក្រក់ក្តី ឲ្យចេញចាកតំណែងនោះក្នុងទីដែននោះបានដែរឬទេ? ។

វិ.- ព្រះអង្គអាចធ្វើឲ្យកន្ត្រើកឬបណ្តើញចេញបាន ។

អា.- ចុះទីដែលមិនមែនជាដែនរបស់ព្រះបាទបសេនទិកោសល
ត្រឹមណា មួយទៀត ព្រះបាទបសេនទិកោសលមិនបានសោយរាជ-
សម្បត្តិជាឥស្សរាធិបតីក្នុងដែនណា ព្រះអង្គអាចធ្វើឲ្យកន្ត្រើកឬបណ្តើញ
ចេញនូវសមណៈឬព្រាហ្មណ៍ដែលមានបុណ្យឬតបុណ្យ ប្រព្រឹត្តល្អឬ
អាក្រក់ឲ្យចេញចាកតំណែងនោះបានដែរឬទេ? ។

វិ.- បពិត្រលោកម្ចាស់ដ៏ចំរើន! ធ្វើដូច្នោះមិនបានទេ ។

អា.- ចុះទ្រង់បានឮថា ពួកទេវតាជាន់តាវត្តឹង្សមានដែរឬទេ? ។

វិ.– កុណា ខ្ញុំបានឮថាមាន តែឥឡូវនេះព្រះបាទបរសេនទិកោសលក៏ទ្រង់ឮថា ពួកទេវតាជាន់តាវតឹង្សមានដែរ ។

អា – ព្រះបាទបរសេនទិកោសលអាចធ្វើឲ្យកកើតឬបណ្តេញពួកទេវតាជាន់តាវតឹង្ស ឲ្យចេញចាកទីនោះបានដែរឬទេ? ។

វិ.– ព្រះបាទបរសេនទិកោសលមើលពួកទេវតាជាន់តាវតឹង្សមិនឃើញទេ ទ្រង់ទៅបំបរបង់បណ្តេញទេវតាទាំងនោះឲ្យចេញចាកទីនោះឯណាក៏បាន ។

អា.– មែនដូច្នោះហើយ ពួកទេវតាឯណាមានសេចក្តីព្យាបាទទេវតាទាំងនោះមកកាន់អត្តភាពជាមនុស្សនេះ, ពួកទេវតាឯណា គ្មានសេចក្តីព្យាបាទ ទេវតាទាំងនោះមិនមកកាន់អត្តភាពជាមនុស្សនេះទេ ទេវតាទាំងនោះមើលពួកទេវតាទាំងនោះមិនឃើញទេ ទ្រង់ទៅបំបរបង់ឬបណ្តេញទេវតាទាំងនោះឲ្យចេញចាកទីឯណាក៏បាន ។

គ្រានោះ ព្រះបាទបរសេនទិកោសលទូលសួរព្រះដ៏មានបុណ្យថា កិកុនេះឈ្មោះអ្វី? ។

ព្រះ.– ឈ្មោះអានន្ទ ។

ព្រះពជាមានព្រះភាគទ្រង់ភ្ញាក់ថា "អើហ្ន៎ ព្រះអានន្ទទេតើ! អើហ្ន៎ រូបព្រះអានន្ទទេតើ! បពិត្រលោកម្ចាស់ដ៏ចំរើន! ព្រះអានន្ទដ៏មានអាយុ

ចេះសំដែងពាក្យសមគួរដល់ហេតុ ប្រតិត្តទៅមួយអន្លើដោយហេតុ, ចុះព្រហ្មមានដែរឬទេ? ។

អ. - ហេតុអ្វីបានជាទ្រង់សួរយ៉ាងនេះ? ។

ប. - បើព្រហ្មនោះមានមែន មុខជានឹងមកកាន់អត្តភាពជាមនុស្សនេះមិនខានទេ បើគ្មានព្រហ្មទេ មិនបានមកកាន់អត្តភាពជាមនុស្សនេះឡើយ ។

អ. - បើព្រហ្មឯណាមានសេចក្តីព្យាបាទ ព្រហ្មនោះទើបមកកាន់អត្តភាពជាមនុស្សនេះ, បើព្រហ្មឯណាគ្មានសេចក្តីព្យាបាទទេ ព្រហ្មនោះមិនបានមកកាន់អត្តភាពជាមនុស្សនេះទេ ។

លំដាប់នោះ មានបុរសម្នាក់ក្រាបទូលព្រះបាទបសេនទិកោសលថា "បពិត្រមហាភាព! សញ្ជយព្រាហ្មណ៍ជាអាកាសគោត្រមកដល់ហើយ"។ ទើបព្រះបាទបសេនទិកោសល មានព្រះរាជឫទ្ធារៀនឹងសញ្ជយព្រាហ្មណ៍ជាអាកាសគោត្រថា "ម្នាលព្រាហ្មណ៍! នរណាហ្ន៎អាចពោលកថាវត្ថុនេះក្នុងព្រះរាជវាំងបាន?" ។ សញ្ជយព្រាហ្មណ៍ទូលថា "បពិត្រមហាភាព! មានតែវិឌូឌុភសេនាបតី"។ ឯវិឌូឌុភសេនាបតីទូលថា "បពិត្រមហាភាព! មានតែសញ្ជយព្រាហ្មណ៍" ។ គ្រានោះ មានបុរសម្នាក់ទៀត បានមកក្រាបបង្គំទូលព្រះបាទបសេនទិកោសលថា "បពិត្រមហាភាព! កាលនេះគួរស្តេចយាងហើយ" ។

លំដាប់នោះ ព្រះបាទបសេនទិកោសលក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា "បពិត្រព្រះអង្គដ៏ចំរើន! យើងខ្ញុំតាំងឡាយមិនទូលសួរនូវសព្វញ្ញុតញ្ញាណ, មិនទូលសួរនូវណៈតាំង ៤ ដ៏ស្អាត, មិនទូលសួរនូវពួកទេវតាជាធំ, មិនទូលសួរនូវព្រហ្មជាធំ, មិនទូលសួរនូវហេតុឯណាៗ ទើបព្រះដ៏មានព្រះភាគទេ ស្រាប់តែព្រះដ៏មានព្រះភាគព្យាករណ៍នូវសព្វញ្ញុតញ្ញាណជាដើម ដរាបដល់ហេតុនោះៗ ព្យាករណ៍នោះក៏គាប់ចិត្ត គួរដល់យើងខ្ញុំតាំងឡាយ ក៏ត្រេកអរនឹងព្យាករណ៍នោះៗ បពិត្រព្រះអង្គដ៏ចំរើន! ឥឡូវនេះ យើងខ្ញុំតាំងឡាយមានកិច្ចច្រើន មានការងារដែលត្រូវធ្វើច្រើន សូមថ្វាយបង្គំលាត្រឡប់ទៅវិញ" ។ ព្រះសាស្តាត្រាស់ថា "បពិត្រមហារាជ! សូមព្រះអង្គសំគាល់នូវកាលដ៏គួរក្នុងកាលឥឡូវនេះចុះ" ។

ព្រះបាទបសេនទិកោសល ទ្រង់សព្វព្រះរាជហឫទ័យរីករាយចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគហើយ ក៏ទ្រង់ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគដោយគោរព ធ្វើប្រទក្សិណរួចហើយស្តេចចេញទៅ ។

ចប់តែប៉ុណ្ណេះ ។

លោក អ៊ុង - សុមន អនុរក្ស អនុរ៉ឺទ្យាល័យ
ព្រះសុីហនុ កំពង់ចាម

តែង

ខ្ញុំជាជាតិខ្មែរ ពូជពង្សអ្នកស្រែ នៅច្រែនលង់ទៅ
រៀនចេះតិចតួច ប្រដូចប្រៀបទៅ ទឹងច្រាំជ្រលងជ្រៅ
ពុំបានឡើយណា ។ ទឹកត្រីយចំបែង ខិតខំស្ទុះស្ទែង
រួចបែងចែចា ចង់ជាក្បួនច្បាប់ ចែកដួនខេមក
ចិត្តខ្ញុំច្រាំថ្នា ឲ្យបានសម័យ ។ កុំរួញកុំពុក
ទោះក្តៅរងារ កុំថាយប់ថ្ងៃ កុំតួញកុំតែរ
ខ្មែរត្រូវពួតដៃ ស្រុកស៊ីវិល្យៃ ទើបថ្ងៃជាតិយើង ។
ខេមរៈអ្នកគិត រំពឹងឆ្ងាយជិត ភ្ញាក់បើកភ្នែកឡើង
មើលអស់សព្វសត្វ ពាងតួចស្ទួចស្តើង ចេះលើកតំកើង
គ្មានអស្ចារ្យ ។ សត្វនោះគឺឃុំ ហិចហើរទៅទំ
បង្កាបត្រីក្បាច រៀបចំសំបុក ផុតកូនចៅរាក
ពួនពាក់លើគ្នា ច្រែនវែកកន្ទុង ។ មើលធ្នុំជុំជិត
មើរខ្មៅងងឹត លើមែកបង្គង់ ពួនពាក់លើគ្នា

ក់សួត្រសង៍ មិនចេះស្ងៀមម្តង៍ មានការជាន់ច្ចុ ។
ឃ្មុំសត្វទុស្សាហ៍ ក្រែបលំអង៍ផ្កា ទោះបីច្រើនតិច
ហើរត្រង់សំបុក ខ្ចាក់មួយរំពេច រួចច្រឹងហើរហិច
ចូលត្រៃទៅទៀត ។ សត្វឃ្មុំមានមេ ក្រមជាង៍ពលរេហ៍
ចាត់ការចង្អៀត គ្មានខ្វះខាតពេល តែង់ឈ្លាសទំឈ្លៀត
សត្រូវណាចៀត នាំគ្នាទិចក្តាម ។ ឃ្មុំទិចចុកណាស់
ទោះក្លែង៍ទោះចាស់ ទឹកក្តែតរហាម ស្ទើរយំស្ទើរស្រែក
ហាក់ដូចចុកឈាម រកផ្លាវរួចក្តាម ទើបបាន់សាយ ។
រីទឹកឃ្មុំសោត ឈួយលើសស្ករគ្នាត លើសស្ករទាំង៍ឡាយ
អស់ពួកអ្នកស្រុក តែង់ចំរូលខ្លាយ ដណ្តើមប្រញាយ
ក្រែបរសទឹកឃ្មុំ ។ គួរយើង៍ត្រាប់តុត ឃ្មុំសត្វល្អិតសុទ្ធ
ចេះនៅជួបជុំ ឯង៍ជនសាមញ្ញា ហ៊ានទៅច្រឹមក្តៀ
គេប្រមូលផ្តុំ ភូមិខ្វះមិនរើ ។ យើង៍ត្រូវតែរុះ
មិនត្រូវឲ្យខ្ទុស រាជការខាង៍លើ បើយើង៍ទទឹង
រឹង៍មិនត្រមធ្មើ តាមច្បាប់ប្រសើរ វិនាសមិនខាន ។
លោកធំលោកដឹង៍ ចាន់ជាលោកច្រឹង៍ គ្មានដែលស្រាកស្រាន្ត
ចង់ឲ្យរាស្ត្រសុខ សប្បាយក្សេមក្សាន្ត ស៊ូទ្រាំយ ហត់ច្រណា
ដើរវៃស្រែកដើរហៅ ។ រាស្ត្រអើយអ្នកគិត គួរលះគំនិត

កំណើតលូងខ្ចៅ ត្រូវយើងចេះដឹង ដំណឹងក្នុងត្រកៅ
ម្តេចលោកឲ្យទៅ នៅផ្ទះជុំគ្នា ។ នៅបែកខ្ញាត់ខ្ញាយ
នៅដោយពាយបាំយ នាំទុក្ខវេទនា គ្មានពាជការជួយ
ខាងាំងការពារ ចោរចិត្តមោហា ប្រមាថរបជាន់ ។
ចោរចិត្តអាក្រក់ ចោរប្លន់លួចឆក់ ក្រែបីគោមាន់
ចាប់ចងតាំងមនុស្ស បង្ខាប់ប្លាក់ពាន់ យើងរកមិនបាន់
ជីវិតស្ងាប់ចង់ ។ ចោរខ្មែរងាំងខ្មែរ ងាំងគេលុកដែរ
ឯងធ្វើគង្វង់ ប្រឹងប្រមូលប្លាក់ ទុកជាក់ច្រកថង់
រួចរត់តំរង់ ទៅពឹងងាំងគេ ។ គំនិតពាយមាយ
គិតមិនឲ្យឆ្ងាយ ស៊ីនៅទំនេរ មិនអានរឿងព្រាវ
ប្រវត្តិបុព្វេ មិនចារសរសេរ ចែកចាយកូនចៅ ។
បណ្តែតបណ្តោយ គំនិតថ្មោះឆ្មោយ នាំឲ្យលូងខ្ចៅ
បើយើងអាណិត គិតញាតិក្នុងត្រកៅ ត្រូវខំឆ្លាស្ងួរ
ឲ្យគ្នាស្រួលដើរ ។ មានតែផ្លូវមួយ ដែលយើងអាចជួយ
ឲ្យបានប្រសើរ រួមសាមគ្គីគ្នា រួចយើងចាប់ធ្វើ
កំចាត់លូងលើ ឲ្យចាកចេញឆ្ងាយ ។ គឺសង់សាលា
សុំគ្រូពាជការ មកអធិប្បាយ មកប្រៀនប្រដៅ
កូនចៅតាំងឡាយ សង់ភូមិភាគ់ពាយ ក្មេងរៀនឆ្ងាយដើរ ។

លោកពីជាន់មុន លោកអ្នកមានគុណ ស័យយឺតដំណើរ
ស្រឡាញ់កូនពេក ថ្នមកូនខុសប្រើ ថាខ្លាចគេធ្វើ
ទុក្ខគោសដល់កូន ។ ម្ល៉ោះហើយអប់រំ ស្រឡាញ់ជាប់ធំ
កៀកកើយនឹងខ្លួន ខ្លាចឈឺចុកចាប់ គ្មានអ្នកថែធួន
ចំលាក់បំពួន ឲ្យកូនទៅផ្ទះ ។ ពេជការដើរសួរ
លោកមីងលោកពូ មានកូនអ្វីខ្លះ ប្រឹងធ្វើយ ច្បាប់គេ
ជាប់ខាតស្រឡះ ន! ព្រះគុណម្ចាស់ ខ្ញុំគ្មានកូនមួយ ។
កូនស្រីកូនប្រុស រត់ពួនពីសព្រួស ទៅខ្ចីកូយ
ថប់ស្ទើរនឹងស្លាប់ មិនហ៊ានរំដួយ ដល់ពេលបកកួយ
ញើសជាបឆ្អឹងខ្នង ។ ប្រឹងលាក់បំពួន ឲ្យកូនរួចខ្លួន
គ្រាន់ចាប់ក្តាមខ្នង កូនត្រីតូច។ កែពិសបង្កង
ដើរជួសដើរជន កសាងផ្លូវព្រួយ ។ លង់អូលង់ម្ល៉ោះ
ខ្លួនមិនសូវចេះ កូនមិនគិតជួយ ឲ្យគ្នាវៀនសូត្រ
គ្រាន់ដោះទុក្ខព្រួយ នេះទំប្រឹងស្ងួយ ឲ្យលូតគ្នាទៀត ។
ខេមរៈសម័យ យើងស៊ីវិល្ហៃ ស្រុកឡើងចម្រើត
ម្តេចធ្វើព្រងើយ គ្មានចិត្តទំនៀត រកដីជូតជៀត
ទំសាងសាលា ។ សង់ស្ពឹកប្តូរឈើ ពួតដៃគ្នាធ្វើ
សុំច្បាប់ពេជការ កុំសង់ឯកឯង ក្រែងខុសមាត្រា

ចាន់ចាប់កាលណា សង់កុបអ្នង់ ។ ចំណែកច្រាក់កាស
ទាំគ្នាអង្គាស នៃតាមចំណង់ ទោះតិចទោះច្រើន
ច្រមូលគ្នាចង់ រួចគួរវាសឫង់ សង់ឲ្យខាង់ចាន ។
ៗលវដ្តទាំង ឡាយ អ្នកគិតឲ្យឆ្ងាយ ការបូតច្រប់ច្រាណ
យើងចាស់ណាស់ហើយ រស់នៅប៉ុន្មាន តង់នឹងចែកស្មាន
ថ្ងៃស្អែកៗ នេះ ។ ស្ងាប់ដោយគ្មានឈ្មោះ កេរ្តិ៍ពុំពីពោះ
ស្ងាច់នោះឆ្អាបឆ្អែះ បើមុននឹងស្ងាប់ បង់ៗជាផេះ
បញ្ចេញតម្រែះ ចែកចាយកូនចៅ ។ កុំលាក់កូនខ្ទុក
ក្នុងស្រវាងែក ឲ្យកូនល្ងង់ខ្លៅ ត្រូវឲ្យរៀនសូត្រ
វិជ្ជាពាក់ជ្រៅ តាន់ជាសំពៅ ពឹងពាក់អ្នកផង ។
សូវឲ្យឃ្លាតគា ៗយហេបចោះឡូ លេងលែ្បងស៊ីសង
យើញពាក់មួកស កែងជាប់ឆ្នឹង ១ង មកពីរំលង
មិនរៀនវិជ្ជា ។ ចាស់ខ្ទះច្រកាន់ ថាអញមិនបាន
រៀនសូត្រឯណា គង់ចិញ្ចឹមវា រស់មានរូបា .
ឥឡូវបែរថា អញលូងៅវិញ ។ មើលដាយអ្វីម្ល៉ះ
ថ្មីបើឯងចេះ ម្តេចមកជ្រក់ជ្រៃញ ដល់អញជាចាស់
នាំគ្នាគោម្នេញ នេះចំហៅពេញ អកត្តញ្ញ ។
មិនស្គាល់ចាស់ទុំ មិនដឹងតូចធំ មិនចេះគិតគូរ

ក៏តើតគ្រែយអញ ក៏ចង់ផ្ទៃគ្រូ មានតែសត្វញ៉ូ
សម្ពុន្ធមួយទេ ។ ដែលអញត្រូវថ្ងាយ វន្ទាខុនកាយ
គ្មានល្អែទំនេរ ចុះឯងជាអ្វី គ្រាន់បើលើសគេ
ជាន់គ្រែយសោះទេ អាកុំអាលអួត ។ ក្មេងគ្រាន់ពន្យល់
ដីរលមូលវល់ ពោលថាគ្មានឆ្ងួត អញចាស់ម្ល៉ះហើយ
ឯងកុំចេះត្រួត កុំទាំអញឆ្ងួត ដើរតាមជានឯង ។
សម័យដ៏ខ្លាន ចាស់ស្តាប់មិនបាន ថាអស្ចារ្យស្រែង
បុកណាជាន់មុន ចេះហោះខ្វួនឯង មិនបាច់តុបតែង
ទៅដោយគ្រឿងយន្ត ។ ផ្ទុយគ្នាជានិច្ច បើគិតការកិច្ច
ច្រែនជាន់លើសលន់ មិនសូវសំរេច ដូចចិត្តយើងចង់
ការគិតមិនទាន់ នាំឲ្យវិនាស ។ ដដែកប្រណាំង
លាន់ឮសូរខ្ទាំង កើតហេតុផ្តេសផ្តាស មកពីព្រោះអ្វី
ព្រោះមិនអៀនខ្មាស ចេះស្មើរមិនប្រាស់ ក្បួនច្បាប់កងលោក ។
យើងចេះត្រើល ។ នាំឲ្យគេមើល- ងាយយើងលើគោក
ត្រូវចេះឲ្យស្ងាត់ ចាំមាត់ប្រាជ្ញព្រោក ដឹកនាំសត្វលោក
ជាក់ដល់ត្រីយនាយ ។ បើមិនគិតដួយ ឲ្យមូលមាត់មួយ
មុខជាបែកខ្ញាយ ខ្លះធម៌សាមគ្គី គ្មានឃើញសប្បាយ
កើតបែកខ្ញាត់ខ្ញាយ ខ្មែរគ្មុជា ។ ពលរដ្ឋអកដួយ

នគរតូចមួយ
ហាក្យត្រែសាសនា
នគរថ្កើងបាន
ស្រុកច្រើនអ្នកច្បាជ្រ
គ្រាន់សណ្តោងជាតិ ។
កុំបីយល់ញាតិ
បំភ្លឺឲ្យស្អាត
យកមកវាំងវ៉ែន
នាំស្រុកវាលត់
ទើបបានសប្បាយ
ព្រោះពាល់ពស្ត្រធំ
ព្រះបរមក្សត្រៃថ្ងៃ ។
ពួតដើរពួតដៃ
ទើបមានតម្លៃ
សាច់ញាតិកន្លះក្រៃ
ក្រៃបីសែះលា
ខ្ញុំសូមនុនកាយ
មិនថាអង្គណា

ត្រូវនាំគ្នាគ្នា
ពង្រីកកម្ពុជា
ប្រើចិត្តក្លាហាន
បណ្ឌិតកវី
ត្រូវប្រើក្បាច់
ច្បាប់លោកធម៌
ដល់ពួកពលរដ្ឋ ។
ឲ្យច្បាស់ច្បាស់
រៀនឲ្យហ្មត់ចត់
រឹតពាយកន្លះកាយ
ពស្ត្រត្រូវពុនរែក
ពស្ត្រត្រូវតែធំ
រដ្ឋយើងពស្ត្រធំ
ចំរើនសេដ្ឋកិច្ច
ដល់កម្ពុជា ។
ត្រូវបណ្តុះគ្នា
នាំថោកកម្ពុជា
បង្គំថ្វាត់ថ្វាយ
នេនកិក្ខុសង្ឃរាជ

តំកើងព្រះមេ-
ឲ្យមានវាស្នឹ ។
ចាំងប្រុសចាំងស្រី
ពូកែសំដី
ឲ្យមានសណ្តាប់
កុំបំឲ្យឃ្លាត
ពស្ត្រត្រូវតែដឹង
កុំចេះស្ទើរស្ទាក់
ក្លឹថ្ងាននឹងក្អែក ។
គ្មានការដាច់ដែក
រួចពីឆ័ប៉ង្អែក
ចេះត្រូវចិតចំ
ឲ្យទាន់សម័យ
មានកូនមានចៅ
កុំឲ្យឃ្លាលគោ
ប្រទេសឯករាជ្យ ។
ព្រះសង្ឃអង់អាច
លោកមានអំណាច

លើពុទ្ធបរិស័ទ ។ លោកតែងទ្រទ្រង់ ទិមន្តស្រោចស្រង់
ដល់ពួកពលរដ្ឋ ទេសនាប្រដៅ ធម៌ព្រះចមមកុដ
ប្រសើរលើសធុត កពលោកទាំងបី ។ សូមទ្រង់ពន្យល់
កុំឲ្យសត្វឆ្គល់ គម្ពីរបាលី សីលទានភាវនា
ជាអាលដ្ឋី សង្ឃមត្តន្ទ្រិយ ឲ្យបានសំរេច ។
ព្រះអង្គពោលថា ចង់បានបញ្ញា- ញាណសារពេជ្ឈ
ត្រូវរំរៀនសូត្រ កុំបីមានក្តេច មិនត្រូវរៀនគេច
ឆ្ងាយចាកប្បាប់ក្បួន ។ សូមអង្គព្រះគុណ ទានប្រាសនិមន្ត
ទេសនាចែកជូន ដល់ពស្ត្រកង់ក្រែង ក្រៃក្រែងសត្វខ្លួន
គិតឲ្យឆ្ងាប់ខ្លួន ដល់កម្ពុជា ។ ពស្ត្រជឿព្រះសង្ឃ
ដូច្នេះសូមអង្គ ប្រទានធម៌អាថ៌ ប្រដៅដល់សត្វ
ផ្សះលោកសាសនា ឲ្យបានគួរថ្លា ប្រាជ្ញាក៏ឆ្លៀវ ។
គ្រាន់ជួយសន្ធោស ជនជាតិស្រីប្រុស ឲ្យមានតម្លៃ
ចេះអក្សរខ្មែរ ខ្លះជាតិដទៃ ការពារទឹកដី
ពជរដ្ឋធានី ។ កុមារនៅវត្ត ព្រះគុណកុំឃាត់
ទុកប្រើតែពី ឲ្យគ្នារៀនសូត្រ ចេះដឹងពេញទី
កុំឲ្យដេកស៊ី ប្រាយលេងសប្បាយ ។ ព្រះគុណអាណិត
សូមមេត្តាចិត្ត ចិតចំខ្លួនឯង តឿនក្មេងវត្តនោះ

ឲ្យទំនៃត្រសត្រាយ វិជ្ជាទាំងឡាយ ឲ្យបានចេះច្បាស់ ។
ច្រាប់ដើងវត្តថា ញោមត្រូវដឹងការណ៍ កូមិយើងនៅខ្វះ
សាលាសម័យ មិនទាន់កើតរះ នាំគ្នាក្មេងចាស់
ទំឲ្យមានៈឡើង ។ រៀនសូត្រសព្វថៃ្ង រហ័សពេកកៃ្រ
ខុសពីជាន់យើង ជាន់ចាស់រៀនយឺត ព្រោះខ្វះគ្រប់គ្រឿង
មិនសូវដឹងរឿង ច្រវត្តិរបស់ខ្មែរ ។ ក្មេងជាន់ឥឡូវ
ដល់រៀនយូរៗ ច្រាជ្រុះយូរកៃ ខ្វះធ្វើដំណើរ
តាត់រៀនស្រុកគេ បន្តគ្នាំហែ រៀងតែពាល់ធ្នាំ ។
មិនមែនសុទ្ធប្រុស ស្រីលាយចំរុះ អាចក្តីបានចាំ
ទៅរៀនវិជ្ជា ខាងឆ្មបថៃពាំ ទឹងខាងសូដាំ
រៀបចំទុកជាក់ ។ ចុះមនុស្សកូមិយើង ម្តេចទឹងច្បាន់ថ្លើង
បើសុទ្ធតែខ្វាក់ មកពព្រោះអ្វី សូមឲ្យដឿជាក់
ព្រោះគ្មានចិត្តស្ម័គ្រ កសាងសាលា ។ ព្រះសង្ឃគ្រែនភ្លាម
ដើងវត្តធ្វើតាម សង្ឃដីកា មិនហ៊ានទទឹង
ទឹងគ្រូអាចារ្យ សម្រេចកិច្ចការ កើតបានឆុតឆាប់ ។
សត្វខ្លាចព្រះសង្ឃ ដូច្នេះសូមទ្រង់ ព្រះគុណបង្គាប់
ឲ្យសាងសាលា ជាបញ្ញាទ្រព្យ ប្រសើរមានតំលៃ
ជាងទានដទៃ ។ ព្រះពុទ្ធយល់ច្បាស់ រួចទ្រង់បានត្រាស់

ព្រះធម៌ថ្លាថ្លៃ ប្រាសប្រាណសត្វលោក ឲ្យរួចចាកភ័យ
តើព្រះប្រើអ្វី? គឺបញ្ញាញាណ ។ ព្រះបានតីណា
ពីអតិនិហារ កសាងសីលទាន មិនមែនមួយជាតិ
អស្ចារ្យលាន ឆ្នាំខើបព្រះបាន បែកសម្ពិភាញាណ ។
ញោមញាតិគាំងឡាយ ជ្រាបច្បាស់ក្នុងកាយ ចំណែកសីលទាន
ផ្គត់ផ្គង់ព្រះសង្ឃ ឲ្យបានវស្សាទាន កុំឲ្យសង្ឃមាន
ទុកខានរៀនសូត្រ ។ រៀនចេះពេលណា បញ្ញាក្តីថ្លា
សត្វចេះកាចសូត្រ កាចត្រូវនឹងច្បាប់ គេខ្លាចរហូត
គេមិនសូវត្រូត កិច្ចការយើងធ្វើ ។ សូត្រយើងសូត្រចេះ
សូត្រប្រើចំណេះ សូត្រគាប់ប្រសើរ សូត្រមានប្រាជ្ញប្រាយ
សូត្រកាយការធ្វើ ការពារបំរើ ដល់មាតុភូមិ ។
ញោមនោះតភាយ ដាច់ដោចឃ្លាតឆ្ងាយ ត្រូវមកនៅរួម
ចង់សាមគ្គីសុខ ក្នុងស្រុកក្នុងភូមិ ឲ្យឃុំយើងចោម
ជុំជិតសប្បាយ ។ ញោមប្រុសស្រីកា សូមពិចារណា
គិតឲ្យវែងឆ្ងាយ បួសនេនពីតូច មិនសង្ឃឹមកាយ
បួសនោះរឹតក្លាយ កើតជាបាបទៅវិញ ។ សង្ឃប្រៀបសំពៅ
បើកបរចេញទៅ ចង់ចាន់ចំណេញ បើប៉ះខ្សាច់ព្រុះ
រលកពាសពេញ នាំទុក្ខទោម្នេញ លិចលង់អន្តរាយ ។

សង្ឃឹមវិសុទ្ធ　　សង្ឃឹមស់ខ្ពង់ផុត　　ចាកផ្លូវអំបាយ
ត្រូវបាកជិត　　សង្ឃឹមមុខបែកឆ្ងាយ　　បាបបួលលុកកាយ
ឆ្ងាយចាកព្រះផ្លូស ។　　អាត្មាទឹកស្តាយ　　អស់ញោមតាំងឆ្ងាយ
មិនសូវពិគ្រោះ　　បង្ខំកូនតូច　　ឲ្យបានបួលបួស
កូនប្រពិត្តហួស　　បាបនោះស្តែងជាក់ ។　　បន្តិចអង្វរកូន
ថាឧលោកនេម　　ញោមមានធុរៈ　　ដូរវិស្សា
ភ្លៀងធំហូរធ្លាក់　　សូមនេនលាចាក　　សិក្ខាបទទៅ ។
មើលគោក្របី　　ដួយញោមប្រុសស្រី　　កុងការងាំស្រូវ
ដល់ត្រង់អាយុ　　ម្លៃធ្នាំត្រឹមត្រូវ　　ចាំកូនទៅនៅ
បំពេញកិច្ចខ្មែត ។　　បួសសឹក។　　ពីនេនទៅកិច្ច
ខ្លួចកូនចោលម្សៀត　　កាលកូននៅតូច　　មិនគិតឲ្យឆ្ងៀត
ស៊ីឲ្យហាលងៀត　　កណ្តាលភ្លៀងថ្ងៃ ។　　កូនសឹកពីបួស
ចង់ឲ្យមានយស　　សក្តិល្អប្រពៃ　　កែបញ្ជីជាតិ
ឲ្យគេលក់ដៃ　　អាយុជិតម្លៃ　　ទើបនឹកចង់រៀន ។
ទៅអង្វរគ្រូ　　ឲ្យជួយគិតគូរ　　តាំងខ្មាសតាំងអៀន
ជិតការប្រពន្ធ　　ទើបនឹកចង់រៀន　　ធ្វើម្តេចនឹងប្រែន
រៀនចេះនឹងគេ ។　　គេស្រកថ្នាំង　　អាមេរិកាំង
ឯងរៀនអាបេ (AB)　　គេច្រំដួចណ្តិត　　ឯងចេះសរសេរ

ជាង់ទៅទំនេរ សុំធ្វើបង់តុង ។ រួចបន្ទោសថា
អ្នកមេអ្នកបា មិនគិតឆ្ពើមផ្ទុង ឲ្យខ្ញុំរៀនសូត្រ
ឲ្យបានជាខ្ញុំផុង ទៅជាលិចលង់ ខ្លួនដល់ប៉ុណ្ណឹង ។
ស្តាយណាស់សព្វថ្ងៃ ទឹកគិតរំពៃ កើតការកំហឹង
ដល់ខ្ញុំមានកូន ខ្ញុំឲ្យវាច្រឹង បង្ខឹបខ្ពង់
ឲ្យវាបានការ ។ គ្រាន់តែចេះស្តី មិនបាច់ជំអី
គួរវាសន្ធឹងក្តារ អាយុប្លន់ឆ្នាំ កាន់ដង្កាបកា
ឲ្យទំសិក្សា វិជ្ជាចាំងឡាយ ។ កូនធំពិបាក
ក្រឹក្រែតោកយ៉ាក ទោសខុតុកម្តាយ ឥឡូវយើងដឹង
ត្រូវច្រឹងខ្លាំងខ្លាយ កូនរៀនបានឆ្ងាយ សប្បាយចិត្តបា ។
កូនបានធ្វើជំ រៀបប្រកបមុខម្ចាស់ កង្វល់ការពជការ
ក្តៅឈ្មោះលេចឮ ទៅសព្វទិសា អ្នកមេអ្នកបា
ជំដោយសារកូន ។ ញោមបង់ពន្ធដារ ជាក់ឃ្លាំងពជការ
តាមក្រឹត្យក្រមក្បួន មានប្រយោជន៍ក្រៃ កុំបីគុំគួន
គឺឲ្យថែជួន ពួកកូនចៅយើង ។ ចែកពួកគ្នាក់ងារ
ចិតចំនួនសាហ៍ អស់ពីដៃដើង ការពារប្រយោជន៍
ពជជានីយើង ឲ្យបានថ្កុំថ្កើង មានតេជៈជ័យ ។
យើងបង់ពន្ធដារ ជួយដល់ការ កិច្ចល្អប្រពៃ

ប្រាក់ពន្ធទាំងនោះ ពដការលក់លៃ ឲ្យមានតម្លៃ
នៅកន្លែងផ្សារ ។ ធំផុតលុយកាក់ ខ្វះហើយពិបាក
លៃលកចាត់ការ ចេះតែរកតែយើង កុំបីរួញរា
ពីរឿងពន្ធដារ តាមធនធានតិច ។ យើងត្រូវតែបង
មិនត្រូវបង្អង់ បង់ពន្ធជាកិច្ច គ្រប់ជាតិទាំងអស់
គេគ្មានរៀរគេច ស្រុកគេមិនលិច ព្រោះពន្ធពាល់ធ្នាំ ។
ខ្ញុំបាទសូមលា. ញាតិទាំងអស់គ្នា ប៉ុន្តែសូមផ្តាំ
ពាក្យខាងលើនេះ បងប្អូនជួយចាំ រួចសូមផ្សាយផ្សាំ
ប្រាប់កូនចៅផង ។ សូមកុំបណ្តោយ កេងខ្វែរជាន់ត្រោយ
គួរឲ្យត្រាប់តែង ខំរៀនវិជ្ជា នានាជាតិផង
កុំឲ្យគ្នាដង ជួតតវិជ្ជា ។ អាណិតកុមារណាស់
ស្តាយខ្លួនឆាប់ចាស់ ព្រោះហេតុដូច បើហេតុដូច្នេះ
ត្រូវអស់កុមារ ខំរៀនថែរ" ខាន់ខ្លួនកេងហោង ។

អ៊ុង - ស៊ុមន

ព្រះមហាឧត្តមរាជ ធិលញ្ញាណោ ប៊ុង-ប៉ម
អាចារ្យសាលាជាតិវរធ វត្តបទុមវតី ក្រុងកំពត រៀបរៀង
ឃ្លូនបណ្ណាគារកែប ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

ឧទាយបណ្តុះនិស្ស័យទី ៧

និស្ស័យរាប់អានខ្លួនឯង

លោក - អ្នកស្រឡាញ់ខ្លួនគាំងឡាយ ! ខ្លួនរបស់យើងហ្នឹងឯង ជាបុគ្គល ១ រូបដែលយើងគួរតែរាប់អានឲ្យមុនជាងនរណា គាំងអស់ តែដើម្បីរក្សាកិត្តិយសនៃគ្នានឹងគ្នានោះ កាលបើយើងរាប់អានខ្លួនយើងយ៉ាងណា ក៏ត្រូវរាប់អានមនុស្សដទៃយ៉ាងនោះផង ។ បើយើងរាប់អានតែខ្លួនយើង ១ ចំណែក ក៏នឹងទៅជាមនុស្សអាក្រក់ចំពោះមនុស្សដទៃ សូម្បីយើងរាប់អានតែមនុស្សដទៃ ១ ចំណែកក្រោត ក៏នឹងទៅជាមនុស្សលប់គុណនឹងមើលងាយខ្លួនឯង ។ ហេតុនេះ ដើម្បីលើកតំកើងកិត្តិយសរបស់ខ្លួននឹងមនុស្សដទៃឲ្យស្មើគ្នា ក្នុងខណៈដែលយើងរាប់អានខ្លួនឯង យើងគួររាប់អានមនុស្សដទៃផងឲ្យត្រមគ្នា ។

មនុស្សដែលមាននិស្ស័យមិនរាប់អានខ្លួនឯង ច្រើនចូលចិត្តបន្ទាបនឹងមើលងាយខ្លួនឯង ដោយសំគាល់ថាខ្លួនឯងជាមនុស្សថោកទាប ។ កាល

បើដូច្នោះ ខ្ញុំឯងក៏នឹងភ្ញាក់ផ្អាកនៅកាន់ថ្នាក់ខាប តាមសេចក្តីគិតយើញ
នោះឯង ។ ព្រោះបើតាមពិត សេចក្តីគិតយើញមានសភាពយ៉ាងណា
ការធ្វើនឹងនិយាយ ក៏សម្តែងលំនាំចេញមកជាយ៉ាងនោះ ដូចជាយើង
បន្ទាបខ្លួនយើងឲ្យជាមនុស្សតូចខាបទៅជាងគេ យើងក៏តែងតែសម្តែង
ខ្លួនរបស់យើងជាមនុស្សតូចខាប ឲ្យមនុស្សដទៃយើញ ។ បើយើង
បន្ទាបខ្លួនឲ្យចុះមកកាន់ថ្នាក់ជាមនុស្សតូចខាបដូច្នេះហើយ ក៏បាននឹងថា
ខាបណ្តាយខ្លួនឲ្យធ្វើការអាក្រក់ថោកខាប ។ មនុស្សដើរធ្វើចោរកម្ម,
ដើរប្លាកប្លែស, ដើរសេពសុភ រហូតដល់ធ្វើចិត្តឲ្យអណ្តែតអណ្តូង
មិនមានស្មារតី, ដើរប្រែឡែប្រែកោនៅតាមថ្នល់ ឬមនុស្សដែលធ្វើខ្លួន
ឲ្យស្មោកគ្រោក មិនដំរេរាងកាយ, មិនរក្សាសំពត់ស្លៀកពាក់ឲ្យស្អាត
សូម្បីផ្ទះសំបែងក៏បណ្តាយចោលឲ្យស្មុកស្មាញ ក៏សំបុកកណ្តុរ នេះជា
មនុស្សបណ្តាយខ្លួនឯង ឲ្យភ្ញាក់ផ្អើលដែរនៃសេចក្តីអាក្រក់ថោក
ខាប មិនឈ្មោះថារាប់អានខ្លួនឯង ឬរក្សាកិត្តិយសរបស់ខ្លួនឡើយ ។

ការរាប់អានខ្លួនឯង សំដៅយកការទំនុកបំរុងខ្លួនឯងឲ្យល្មមចូល
ទៅសមាគមជាមួយមនុស្សដទៃគួរទៅបាន ទើង សំដៅយកការធ្វើខ្លួនឲ្យ
ឈានដើរឆ្ពោះមុខទៅក្នុងការសិក្សា ការធ្វើការងារទើងការប្រព្រឹត្តដោយ
វិធីចេះគ្រប់គ្រងខ្លួនឯង, ចេះពឹងខ្លួនឯង ចេះជឿខ្លួនឯង, ចេះពិចារណា
ខ្លួនឯង ទើង ចេះយកជ័យជំនះខ្លួនឯង ។ មនុស្សដែលមាននិស្ស័យរាប់

អានខ្លួនឯង រមែងគោរពខ្លួនទើបលើកតំកើងខ្លួន ចេះគ្រប់គ្រងខ្លួនឯង, ពឹងខ្លួនឯង, ដឿខ្លួនឯង, តិចារណាខ្លួនឯង នឹង យកឈ្នះខ្លួនឯង ដើម្បីឲ្យខ្លួនបានទៅជាមនុស្សល្អ មានសេចក្តីសុខផុតទុក្ខភ័យ, ធ្វើល្អវៀរចាកអាក្រក់, វៀរបស់ដែលមិនល្អ ទើបគ្រឿងស្រវឹងគ្រប់បែបយ៉ាង ធ្លាយបំផុត ធ្វើរបស់ដែលល្អឲ្យល្អជាទីបំផុត ។ ហេតុនេះ ការចេះគ្រប់គ្រងខ្លួនឯង, ចេះពឹងខ្លួនឯង, ចេះដឿខ្លួនឯង ចេះតិចារណាខ្លួនឯង នឹង ចេះយកជ័យដំនះខ្លួនឯង ទាំង ៥ ប្រការនេះ ចាត់ជាលក្ខណៈនៃការរាប់អានខ្លួនឯង ។

១— ចេះគ្រប់គ្រងខ្លួនឯង — ការស្រឡាញ់ខ្លួនឬជីវិតរបស់ខ្លួន រមែងខ្ពង់ខ្ពស់ជាងសេចក្តីស្រឡាញ់របស់ជនដៃទាំងអស់ ។ មនុស្សគ្រប់គ្នា មានគោលបំណងដែលខ្ពស់បំផុត នៅត្រង់ការស្រឡាញ់ខ្លួន ឬជីវិតរបស់ខ្លួនជាទី ១ ស្រឡាញ់មនុស្សជនដៃ ឬវត្តុជនដៃជាទី ២, ចង់ឲ្យខ្លួនជាមនុស្សល្អ មានសុខមុនជាងនរណា។ ទាំងអស់ នឹងមិនប្រាថ្នាឲ្យខ្លួនទៅជាមនុស្សថោកទាបលំបាកគាកយ៉ាក ក្តៅក្រហាយ ឬកើតអន្តរាយយ៉ាងណា។ ឡើយ ។ សូម្បីប្រាថ្នាយ៉ាងនោះក៏ដោយ ក៏មនុស្សនៅតែចាប់យកសេចក្តីល្អឲ្យសមបំណងគ្រប់គ្នាមិនបាន ។ ព្រោះមនុស្សចេះគ្រប់គ្រងខ្លួនឯង លើកខ្លួនឡើងដម្កល់ទុកឲ្យនៅក្នុងអំណាចយ៉ាងខ្ពស់ អាចរៀបចំខ្លួន ឲ្យទៅជាមនុស្សល្អឬខ្ពស់ឡើងជាលំដាប់បាន ។

មនុស្សខ្លះ មិនចេះគ្រប់គ្រងខ្លួន បណ្តោយខ្លួនឲ្យធ្លាក់ទៅនៅក្នុងអំណាចថោកទាប បំផ្លាញខ្លួនឯងឲ្យវិនាសដោយគ្រាច់ប្រកបអំពើអាក្រក់ផ្សេងៗ កាលបើយ៉ាងនេះ ខ្លួនក៏មុខជានឹងធ្លាក់ចុះទៅកាន់សេចក្តីលំបាកគោកយ៉ាកក្តៅក្រហាយដែលខ្លួនមិនគប្បីធ្វើថ្នាំពុំខាន ។

មនុស្សល្អប្រៀបដូចជាឆ្នាំងមាស ដែលកម្រនឹងបែក សូម្បីបែកក៏ងាយនឹងផ្សារ ។ មនុស្សអាក្រក់ប្រៀបដូចឆ្នាំងដី ដែលងាយនឹងបែក ហើយមិនងាយនឹងផ្សារភ្ជាប់វិញទេ ។ បើលោក-អ្នកចង់ឲ្យខ្លួនក្លាយទៅជាមនុស្សល្អ មានសេចក្តីសុខ សេចក្តីចំរើនក្នុងលោកនេះ ក៏គួរគ្រប់គ្រងខ្លួនឯងឲ្យល្អ ។ សិល្បៈដ៏ឆ្ងាយ ក៏គឺការរៀនឲ្យស្គាល់ដើម្បីគ្រប់គ្រងខ្លួនឯងឲ្យផុតចាកសេចក្តីអាក្រក់ដែលជាសឹកសត្រូវ ចំពោះសន្តិសុខនឹងសម្រេចបាន ។ លោក-អ្នកកុំបណ្តោយខ្លួនឲ្យធ្លាក់ទៅជាទាសៈនៃអំណាចទាបថោក ឬជាមនុស្សទោសរបស់និស្ស័យអាក្រក់ឡើយ គប្បីព្យាយាមធ្វើខ្លួនឲ្យជានាយទៅហ្វាយលើនិស្ស័យអាក្រក់ រុញខ្លួនឯងឲ្យឡើងទៅនៅក្នុងអំណាចទាន់ខ្ពស់ នឹងឃុំគ្រងខ្លួនឲ្យមានចិត្តប៉ុនប៉ងតែក្នុងរបស់ដែលល្អ ជំនួសការប៉ុនប៉ងក្នុងរបស់ដែលអាក្រក់ ដែលគួរស្អប់គួរខ្ពើម, ឲ្យប៉ុនប៉ងតែក្នុងសេចក្តីសុខ-សប្បាយជំនួសការប៉ុនប៉ងដែលជាទុក្ខក្តៅក្រហាយ, ឲ្យធ្វើថ្នាំតែការស្ងប់ស្ងៀមរៀបរយ ជំនួសសេចក្តីខ្មោមនស្សខើសខែងចង្អៀតចង្អល់លំបាកចិត្ត ។ (អាឥត)

កណ្ឌទី ១៧

ឧកញ៉ាវិបុលរាជសេនា ន្ធូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
ធឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

គោស៊ុន, តៀវលៀវដំរាបថា តាន់តេង៑ជាបុត្រតាន់គុយទៅច្បាប់ខ្ញុំបាទថា ចូរធ្វើមព័ន្ធលោកជាប់ ហើយឲ្យខ្ញុំបាទប្រញាប់លើកទ័ពទៅជួយ ដែលខ្ញុំបាទចេញចេលស្រុកមកដូច្នេះ គោសខ្ញុំបាទខុសជាទម្ងន់ណាស់។ តាន់កុង៑ក៏និយាយនឹងលីចោ៉ាថា ដែលតាន់តេង៑ឥតប្រឆូសព័យដល់លោកគ្រានេះ លោកនឹងគិតដូចម្តេច? ។ លីចោ៉ឆ្លើយថា "អ្នកកុំរិតក្តីឡើយ ដែលតាន់តេង៑ឥតឆូសដល់យើង៑ដូច្នេះ យើង៑ត្រូវតាមសង សឹកកាត់ក្បាលវាឲ្យបាន" ហើយនាំគោស៊ុន, តៀវលៀវនឹងសេនាពាហាន ទាំងពួង លើកចូលទៅស្រុកសៀវផាយ ឃើញពាហាននៅត្រួតត្រាក្បា-

សើនបន្ទាយមាំមួនណាស់ មានទង់ជ័យដោតនៅមុខបន្ទាយជាទង់ជ័យ
របស់ចូតូ លីហ្គោ"ទឹងណាស់ក៏បំផាយសេះចូលទៅដល់ដើងកំពែង ហើយ
ស្រែកដេរតានតែងថា អាចោរអាពុកនឹងកូន ២ នាក់ អញស្រឡាញ់ពាប់
អានដំកើងឲ្យធ្ងៃធំ គួរឬអាឯងមកឲ្យយើសក្បត់ចិត្តអញ ។ នឹងកាត់ក្បាល
អាឯងឲ្យបាន ។

តាន់តេងឈរនៅលើសើនលើកដៃចង្អុលមុខលីហ្គោ"ហើយស្រែកតប
មកថា ខ្ញុនកុំព្រហើនចរចា យើងនេះជាខ្ញុំរាជការព្រះចៅហៀនតេផ្សេងទេ
កាលគ្រាអ្ញុនសុតលើកទ័ពមកវាយយកស្រុកឈើជីវនោះ មិនពីព្រោះគំនិត
អញនឹងបិតាទេតើ បានជាខ្ញុនឯងរួចចាកសេចក្តីស្លាប់ ឥឡូវម្តេចត្រឡប់
ថាអញប្រឆូសវ"យនឹងឯងវិញ ? ។ លីហ្គោ"ទឹងណាស់ក៏បរពលចូល
នឹងហែកបន្ទាយចំលាយកំពែងស្រុកសៀវផាយ ។ ទ្ហូលតៀវហ៊ុយ
ដែលបែកទ័ពទៅតាំងហ្វឹកហាត់ពាហាននៅក្នុងន"ងនោះ បានដឹងសេច-
ក្តីថា លីហ្គោ"បែកខ្វែកទ័ពដោយកលឧបាយរបស់តាន់តេងហើយក៏ស្រូត
រួតប្រញាប់លើកទ័ពតម្រង់ទៅស្រុកសៀវផាយ ។ លីហ្គោ"ឃើញក៏ចយ
ពាហានចេញមក ហើយប្រើកោស៊ុនចេញតយុទ្ធនឹងតៀវហ៊ុយបាន
៥ក្ងេង លីហ្គោ"ឃើញកម្លាំងកោស៊ុនតស៊ូនឹងតៀវហ៊ុយមិនបាន ក៏បរសេះ
ចូលដួយកោស៊ុនប្រយុទ្ធគ្នានឹងតៀវហ៊ុយ ។

ខណៈនោះចូតូដឹងថា លីហ្គោ"ខូចស្រុកនឹងបុត្តក, តាន់តុយហើយក៏
លើកកងទ័ពតម្រង់ទៅស្រុកសៀវផាយ ឃើញលីហ្គោ"នឹងតៀវហុយច្បាំង

ជាប់ដៃ ចូរធ្វើកិច្ចការចោមព័ទ្ធដុំវិញ ។ លីចោ"ឃើញដូច្នោះក៏ដោះខ្លួនចេញពីតៀវហ៊ុយ បំផ្លាយសេះទម្លាយកងទ័ពចូរចេញទៅបាន ។ តៀវហ៊ុយក៏បំផ្លាយសេះទន្ទ្រានទៅទៀត ។

ឯគួនអ៊ូកាលបែកទ័ពទៅ បានទៅតាំងហាត់សមសេនាភាហានទៅស្រុកហៃដីវ លុះក្រោនដឹងថា លី ចា"ចាញ់ទុបាយកលតាន់តេង ក៏ស្រួតលើកភាហានតម្រង់ទៅស្រុកសៀវផាយ ប្រទះទឹងលីចោ"កណ្តាលផ្លូវ គួនអ៊ូក៏ស្រែកសួរថា អាលីចោ" អាឯងរត់ទៅណា ? ។ លីចោ"ខឹងណាស់ក៏បរសេះចូលប្រយុទ្ធគ្នាទឹងគួនអ៊ូ ខ្លួលតៀវហ៊ុយតាមមកទាន់ លីចោ"ភ័យតក់ស្លុតក៏បំផ្លាយសេះរត់ចូលទៅកងស្រុកហៃហ្វី ហើយចាត់ចែងភាហានឲ្យឡើងយាមល្បាតដុំវិញសេនាបន្ទាយ ។

តៀវហ៊ុយដេញលីចោ"មកប្រទះទឹងគួនអ៊ូ ។ ក្រោប់តៀវហ៊ុយថា កាលយើង ២ នាក់បងប្អូនបែកគ្រាត់គ្នានៅច្រកភ្នំនោះ បងបានទៅនៅហ្វឹកហាត់ភាហានទៅស្រុកហៃដីវ ។ តៀវហ៊ុយក្រោប់ថា កាលខ្ញុំគ្រាត់គ្នានៅច្រកភ្នំនោះ ខ្ញុំបានទៅហ្វឹកហាត់ភាហានទៅក្តុបងយ៉ុង លុះដឹងថាលីចោ"បែកខ្ញែកកងទ័ព ខ្ញុំក៏លើកត្រឡប់មកស្វាក់ចាំងទឹងលីចោ", ខ្លៅពីបងយើងឥឡូវបានទៅចូលនោទឹងចូរួហើយ ។ គួនអ៊ូបានស្តាប់ដូច្នោះក៏មានចិត្តសោមនស្សត្រេកអរពន់ប្រមាណ ទើបនាំតៀវហ៊ុយចូលទៅរកខ្លៅពីក្នុងកងទ័ពចូរួ ។ ខ្លៅពីឃើញគួនអ៊ូ តៀវហ៊ុយទៅដល់ក៏

សប្បាយចិត្តណាស់ សុះចេញមកទទួល ហើយអធិប្បាយពាយរឿងកំ-
សត់ពិបាក កាលបែកបាក់ព្រាត់គ្នាទៅនោះ ឲ្យគួនអ៊ូតៀវហ៊ុយស្តាប់
ហើយក៏នាំគ្នាចូលទៅគំនាប់ចូតួ ។ ក៏នាំឡៅពី, ចោយិន, តាន់តេង
លើកទាហានចូលទៅកាន់ស្រុកឈីជីវ ។ ប៊ុតុកដឹងថាចូតួលើកទ័ពមក
ក៏ចេញទៅទទួលនាំចូលទៅក្នុងស្រុក ហើយប៊ុតុកទៅគំនាប់ឡៅពី
ពណិនារឿងឲ្យឡៅពីស្តាប់ ឡៅពីដឹងថាមិនមានសេចក្តីអន្តរាយក៏
ត្រេកអរណាស់ ។

ឯតាន់តេងកាលចូលទៅដល់ស្រុកឈីជីវហើយ ក៏ចូលទៅជួបនឹង
តាន់គុយជាបិតាដំណាលរឿងហេតុឲ្យបិតាស្តាប់ ហើយនាំគ្នាទៅគំនាប់
ចូតួ ។ ក៏ឲ្យរៀបតុលៀងអាហារ អញ្ជើញតាន់គុយ, តាន់តេង នឹងបណ្តា
នាម៉ឺនសេនាទាហានទាំងពួងឲ្យបរិភោគ ហើយចូតួក៏សួរប្រស្រ័យនឹងតាន់
គុយ, តាន់តេងថា "អ្នកធ្វើការបានសម្រេចដូចគំនិតដែលបានគិតទុកមក
នោះ ឃើញថាបានសេចក្តីគាប់ប្រសើរដល់យើងជាអនេកណាស់" ថា
ហើយ ក៏លើកអាណាខ្វែត្រខាងបុព្វាទិស ១០ មណ្ឌល ឲ្យនាំសួយសា
អាករឡើងតាន់គុយគ្រប់ដូរ ហើយតាំងតាន់តេងជាហុកគោរៀងគុន
គឺនាយទាហានធំ ។

(មានត)

រឿងអាក្បែរនៃរឿងក្អែកត្រាំ

លោក រ៉ាយ-ប៊ុក ក្រមការ

ប្រែពីជាភាសាមកជាខ្មែរ

(ត - ចប់)

រឿងទីប្រាំបួន

បពិត្រមហាកដ! នៅប្រទេសកលិង្គ (Kaling) មានព្រាហ្មណ៍ម្នាក់ឈ្មោះយគ្យសម៌: (Yagyasharma) មានភរិយាឈ្មោះនាង៍សោមទត្តា (Sômdatta) ប្រកបដោយរូបនោមលោមតណ៌ស្អាតប្រមំប្រិយ។ ព្រាហ្មណ៍នេះបានធ្វើពលិកម្មមួយ ហើយភរិយាគាត់ក៏ប្រសូតិបុត្រមួយល្អប្លែក ។ ដល់បុត្រនោះអាយុបាន ៥ ឆ្នាំ បិតាបានបង្រៀនទូវៃស្ក្រា ។ អាយុ ១២ ឆ្នាំ កូនប្រុសនោះបានរៀនចេះចាំសស្ក្រាគាំង៍អស់, ជាបណ្ឌិត ហើយនៅបម្រើម៉ែពុកម្ដាយមិនឲ្យឆ្គាំឆ្គង ។ តែបន្ដិចទៀត កូនប្រុសនោះក៏អនិច្ចកម្មទៅ ។ បិតាមាតាក៏សោកសង្រែង៍អាឡោះអាល័យបុត្រនោះពន់ពេក ។ គ្រួសារគាំង៍អស់ ដល់ឮថាកូនប្រុសនោះទទួលមរណភាព ក៏មកយកសពកូនប្រុសនោះដាក់លើប្រដាប់សែង៍នាំគ្នាសែង៍ទៅឯចូបដ្ឋាន ហើយអ្នកគាំង៍អស់ក៏បើកសពនោះមើល ស្រែកថា: "កូនប្រុសនេះល្អ ដល់ស្លាប់ទៅ ក៏នៅតែល្អ" ។ កាលក្រុមញាតិសន្ដានបានពោលយ៉ាង៍នេះ

ហើយ កំចានយកអុសមកតរបង្កាត់ភ្លើងដើម្បីនឹងបូជាសពនោះ, តែមាន យោគីម្នាក់កំពុងស្ងឹងស្ងាធិនៅក្រៃស្មសានចាន់ពាក់ចានេះ កំពោលខ្លួនឯង ថា: "រូបកាយអញចាស់ជរាហើយ, បើអញចូលទៅស្ថិតនៅក្នុងរូប កាយកូនក្មេងនេះ, អញអាចធ្វើមគ្គកិលមជ្ឈានខ្លះយោគរបស់អញយ៉ាងស្រួល" ។ យោគីនោះពោលរួចក៏ចូលទៅស្ថិតនៅក្នុងរូបកូនប្រុសនោះ ហើយក៏បៃរមុខទៅខាងម្ខាងពោលថា: "រាមកិស្ណ" (Râm-Krishna) ហើយក៏ក្រោកអង្គុយ ដូចជាមនុស្សទើបនឹងក្រោកពីដេក ។ អ្នកចាំង អស់ដល់ចានឃើញអច្ឆរិយភាពដូចនោះ ក៏មានចិត្តងឿងឆ្ងល់ពន់ពេក, ហើយក៏វិលត្រឡប់ទៅកាន់គេហដ្ឋានសព្ទ ។ ខ្លួនវិញ ។ បិតានៃកូន ប្រុសនោះ លុះចានជ្រាបនូវអច្ឆរិយភាពបែបនេះ ក៏ឲ្យពរសព្វសាធុការ ដល់តាបស រួចសើច បន្តិចទៀតយំ ។

គារក្យកាលចានក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ នូវរឿងរ៉ាវចាំង នេះហើយ ក៏ទូលសួរថា: "បពិត្រព្រះចាទពិក្រម: ! ហេតុម្តេចក៏បិតា នៃកូនប្រុសនោះសើច រួចទើបយំជាក្រោយ? ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលថា: "បិតានៃកូនប្រុសនោះ សើច ដោយឃើញព្រះយោគចូលទៅស្ថិតនៅក្នុងរូបសពដោយអានុភាព នៃសិល្បសាស្ត្រ, ហើយយំក្រោយនោះ ដោយគិតថាខ្លួនគាត់ក៏មុខជា នឹងត្រូវចេញចាករូបគាត់ថ្ងៃណាមួយមិនខាន ។

អាវ័ក្សដល់បានស្តាប់ន្ទូវព្រះបន្ទូលនៃព្រះនរបតី ក៏រីលទៅកាន់រុក្ខជាតិវិញ ។ ព្រះពុទ្ធទ្រង់ក៏ចាប់អាវ័ក្សនោះចងភ្ជាប់ លើលើព្រះអង្សានាំយកទៅ ។

ចប់រឿងទី ២៤

រឿងទីម្ភៃប្រាំ

អាវ័ក្សក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ថា: "បពិត្រមហាពាជ! នៅប្រទេសទេឌិន (DèKhin) មានពាជធានីឈ្មោះធម៌បុរៈ (Dharmapur) ។ ព្រះមហាក្សត្រិយ៍នៃនគរនោះ ទ្រង់ព្រះនាមព្រះបាទមហាពល (Mahà-bal) ។ មានកាលមួយថ្ងៃ ព្រះមហាក្សត្រិយ៍មួយអង្គទៅគង់បរទេស ទ្រង់បាននាំកងទ័ពមកវាយព្រះពាជធានី របស់ព្រះបាទមហាពល ។ ការតយុទ្ធអស់រយៈវេលាច្រើនថ្ងៃ តែកងទ័ពខាងព្រះបាទមហាពលបរាជ័យ ហើយធ្លាក់ដល់សេចក្តីវិនាសជាងពាក់កណ្តាល ។ ព្រះបាទមហាពលទ្រង់ចេញពីព្រះពាជធានី ភ្លោះទៅកាន់ព្រៃកន្លងពេលយប់នាំយកព្រះអគ្គមហេសីនឹងព្រះពាជបុត្រីរបស់ព្រះអង្គទៅផង ដោយគ្មានព្រះពាជទ្រព្យអ្វីជាប់នឹងព្រះអង្គសោះឡើយ ។ ដល់ទ្រង់ធ្វើព្រះពាជដំណើរជារាច្រើនយោជន៍ទៅកន្លងព្រៃផ្សៃ ទ្រង់ស្តេចយាងទៅដល់ភូមិមួយកន្លងពេលត្រឹក ។ ទ្រង់បានចាត់ឲ្យព្រះអគ្គមហេសីនឹងព្រះពាជបុត្រី គង់នៅក្រោមដើមឈើ

ទ្រង់ក៏យាងតែមួយព្រះអង្គទៅកាន់កូមិនោះ ដើម្បីនឹងស្វែងរកព្រះស្ងួយ
សោយ ។ តែមានពួកកិល (Bhils) មកដល់ចាមព័ទ្ធព្រះអង្គ ហើយ
ស្រែកថា "ទម្លាក់គ្រឿងអាវុធឲ្យឆាប់" ។

ដល់ទ្រង់ព្រះសណ្តាប់ពាក្យរបស់ពួកកិលនេះ ទ្រង់ក៏តម្រង់ធ្នូបាញ់,
ឯពួកនោះក៏បាញ់តមកព្រះអង្គវិញ ។ ការតស៊ូទៅវិញទៅមកធ្វើឲ្យពួក
កិលអន្ទិចកម្ចាច្រើន ។ តែទន្លួលព្រួញមួយនោះស៊ុះមកចំព្រះសិរព្រះ
មហាក្សត្រិយ៍ ។ ក៏ដួល ហើយមានកិលម្នាក់ ស៊ុះមកកាត់ព្រះស្ងួរធ ។
ព្រះអគ្គមហេសីនឹងព្រះពាជបុត្រី ដល់ទ្រង់ឃើញស្តេចទិវង្គត ទ្រង់ក៏
សោយព្រះកន្សែងគក់ព្រះឧរ ហើយក៏រលែតឡប់ទៅចូលព្រៃវិញ ។
ទាំង ២ ព្រះអង្គ លុះទ្រង់យាងចម្ងាយប្រហែលពីរយោជន៍ ទ្រង់ក៏អស់
ព្រះកាយពលពន់ពេក ហើយក៏គង់សម្រាកក្រោមដើមឈើ ទ្រង់ព្រះ
តម្រិះសព្វគ្រប់ ។

តែក្នុងពេលនោះ ព្រះចាទចន្ទ្រសេន (Chandrasên) ទ្រង់ស្តេច
កំពុងក្រសាលបរបាញ់សត្វជាមួយព្រះពាជបុត្រនៅក្នុងព្រៃនោះ. ទ្រង់
ចាន់ទតទៅឃើញស្នាមដើងស្ត្រីពីរនាក់ ទ្រង់មានព្រះបន្ទូលទៅកាន់
ព្រះពាជបុត្រថា: "ស្នាមដើងដែលយើងឃើញនៅក្នុងព្រៃធំនេះ តើជា
ស្នាមដើងស្ត្រីឬបុរស?" ។ ព្រះអង្គម្ចាស់ក្រាបបង្គំទូលថា: "ស្នាម
ដើងនេះ គឺស្នាមដើងស្ត្រី. ស្នាមដើងបុរសមិនមែនតូចដូចនេះទេ" ។

ព្រះបិតាមានព្រះបន្ទូលថា "មែន មនុស្សប្រុសមិនមែនដើងតូចដូចនេះទេ" ។ ព្រះអង្គម្ចាស់មានព្រះបន្ទូលថា: "ស្ត្រីនេះទើបនឹងកាត់ធ្មេងទីនេះអម្បាញ់មេញ!" ។ ព្រះមហាក្សត្រិយ៍មានព្រះពាជបន្ទូលថា "ត្រូវតែយើងទៅរកស្ត្រីទាំងពីរនេះ ។ បើយើងបានដួប, អញឲ្យនូវស្ត្រីដែលមានស្នាមដើងធំមកឯង ហើយអញយកស្ត្រីដែលមានស្នាមដើងតូចវិញ" ។

កាលព្រះពាជានឹងព្រះពាជបុត្រត្រមត្រៃងគ្នាហើយ, ក៏ស្តេចយាងទៅស្វែងរកស្ត្រីទាំងពីរនោះ, ទ្រង់ក៏បានដួបប្រទះនូវនារីទាំងពីរនាក់កំពុងអង្គុយក្រោមដើមឈើ ១ ដើម ។ ព្រះមហាក្សត្រិយ៍ត្រមទាំងព្រះពាជបុត្រមានព្រះពាជហ្ឫទ័យសោមនស្សពន់ពេក ទ្រង់នាំយកស្ត្រីនោះដាក់លើសេះ, ព្រះពាជបុត្រទ្រង់យកព្រះអគ្គមហេសី, ព្រះមហាក្សត្រិយ៍ជាព្រះវរបិតាទ្រង់យកព្រះពាជបុត្រី ។

ដល់អាវ៌ក្សក្រាបបង្គំទូលព្រះពាជាដូចនេះហើយ, ក៏ទូលសួរថា: "បពិត្រព្រះបាទពិក្រម: តើព្រះពាជបុត្រព្រះមហាក្សត្រិយ៍ នឹងព្រះពាជបុត្រព្រះអគ្គម្ចាស់យ៉ាងណាទៅ?" ។

ព្រះមហាក្សត្រិយ៍ទ្រង់មិនជ្រាបថា តើនឹងត្រូវឆ្លើយបែបណាទេ ទ្រង់ក៏គង់នៅស្ងៀម ។ អាវ៌ក្សសប្បាយចិត្តទើបសួរទៀតថា "ទុមហាពាជ! ទូលបង្គំជាអ្នកសាក្សី ដែលធ្លាប់បានស្គាល់ព្រះពាជហ្ឫទ័យព្រះអង្គថាជាអ្នកក្សាហាន, អាចអាច, ហើយទូលបង្គំមានសេចក្តីពេញចិត្តជាខ្លាំង ។ តែទូល

បង្គំសូមក្រាបទូលទ្រង់ដូចតទៅនេះ សូមទ្រង់ព្រះសណ្ដាប់: មានមនុស្ស
ប្រុសម្នាក់មានសក់ដូចជាបន្ទា ហើយរូបដូចជាឈើឈ្មោះសន្ត-សិល
(Shant-Shil ។ បុរសនោះបានចូលទៅកន្លែងតែ្រង, បង្គាប់ឲ្យទ្រង់ស្តេច
យាងមករកទូលបង្គំ. តែបុរសនោះនៅថូបជ្ឈនមួយ ហើយកំពុងប្រតិត្ត
ន្ធវិស្សាស្ត្រហើយមានបំណងចង់ពិឃាដព្រះអង្គ ។ ទូលបង្គំសូម
ក្រាបទូលព្រះអង្គឲ្យទ្រង់ជ្រាបជាមុន ។ ដល់បុរសនោះសូត្រធម្មចប,
មុខជាបង្គាប់ព្រះអង្គឲ្យធ្វើការកោតមានច្រាំមួយអរិ:យ៍ (គោរពដោយ
ក្បាលជង្គង់ ដើង, តែងដៃប៉ះដល់ដី) ទ្រង់ត្រូវតបទៅបុរសនោះវិញថា:
' យើងជាស្តេចធំលើស្តេចទាំងឡាយ ហើយអ្នកទាំងអស់ត្រូវគោរព
យើង ។ មកដល់ឥឡូវនេះ, យើងមិនដែលគោរពអ្នកណាសោះឡើយ ។
លោកជាគ្រូរបស់យើង, ចូរអាណិតយើង, ហើយសូមឲ្យលោកបង្ហាញ
អាការដែលត្រូវគោរពនោះយ៉ាងណាខ្លះ ។ ដល់បុរសនេះនូនក្បាល,
ត្រូវព្រះអង្គកាត់ក្បាលរាមួយរំពេចនឹងព្រះខ័នច្បាំ, ហើយព្រះអង្គមុខជានឹង
សោយរាជសម្បត្តិជាសុខ, បើមិនដូចនោះទេ, មុខជាកំពុងពិឃាដព្រះអង្គ
ហើយត្រូតត្រាប្រទេសនេះតែរ៉ា" ។

អាវ៉ាត្រូវដល់ក្រាបបង្គំទូលព្រះមហាក្សត្រិយ៍អំពីរឿងនេះ, ក៏ចេញពី
ពុទ្ធសាកសពហើយត្រាច់ទៅ ។ ពេលនោះយប់, ព្រះបាទពិ្រមៈទ្រង់
បាននាំសាកសពនោះទៅប្រគល់ឲ្យព្រះយោគីជាកំចិតមុខ ។ សន្តសិល

ចានយើញសប្បាយចិត្តខាន់ពេក ចំពោះព្រះមហាក្សត្រិយ៍ ហើយសរសើរ
ព្រះអង្គជាអនេកប្បការ ។ បុរសនោះក៏សូត្រអាគមធ្វើឲ្យសាកសពនោះ
មានជីវិតឡើងវិញហើយក៏ធ្វើពលិកម្ម ។ ដល់អង្គ៌ុយស្រួលបួល, មុខបែរ
ទៅខាងត្បូង, បុរសនោះក៏ចានបូជាទៅនាងទេវធីតានូវម្ហូ, បុប្ផា, គ្រឿង
ក្រអូប, ចង្កៀង, អាហារសព្វគ្រប់ ។ ដល់សូត្រធម៌រួច, បុរសនោះ
ក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ថា "សូមព្រះអង្គសំដែងគារវភាព, ព្រះ
អង្គចានកិត្តិយស, កិត្តិនាមហើយនឹងអរិយទ្រព្យទាំងប្រាំប្លែក ព្រមទាំង
សិទ្ធិទាំងប្រាំបីស្តេចទៅកន្លងមហាប្រាសាទរបស់ព្រះអង្គ" ។ តែព្រះពជា
ទ្រង់ចាមព្រះសណ្តាប់ទូរបណ្តាំអាក្រក់, ក៏លើកព្រះហត្ថាសំពះហើយ
មានព្រះបន្ទូលជាសុភាពថា "លោកគ្រូ ! យើងមិនដឹងធ្វើគារវភាពយ៉ាង
ម្តេចទេ, តែលោកជាគ្រូយើង, ចូរលោកគ្រូអាណិតមកយើង, សូម
លោកគ្រូបង្ហាញនូវអាការគេរពនោះឲ្យយើងឃើញសិន យើងនឹងធ្វើ
តាមគ្រោយ" ។ ដល់យោគីនោះឧទ្ទាលធ្វើគារវភាព, ព្រះមហា-
ក្សត្រិយ៍ក៏កាត់ក្បាលយោគីកន្លងពេលនោះទៅ, ហើយអាក់ក្បមកដល់
កំចាប់បុប្ផាដូចក្បៀង ។

មានគម្ពីរពោលថា "មិនមែនក្បត់សាសនាទេ ត្រង់ការពិយាដ
អ្នកដែលប្រឹងនឹងសម្លាប់ខ្លួនអ្នក" ។

ព្រះឥន្ទ្រទឹងទេវតាទាំងអស់គង់នៅលើទេវរថ ចានយើញនូវសេចក្តី
អង់អាចុនៃព្រះពជា, ក៏មានព្រះសូរសៀងឲ្យពរជោគជ័យ ហើយព្រះឥន្ទ្រ

ពេញ ព្រះហ្ឫទ័យទើង ព្រះរាជា ក៏មានព្រះទេវបញ្ជាទៅកាន់ទ្រង់ថា: " ចូរ ព្រះអង្គសុំសេចក្តីអនុគ្រោះពីយើង។ ទើងថ្វាយតាមសព្វព្រះរាជហ្ឫទ័យ "។ ព្រះបាទពិក្រម:បង្គំទូលតបថា: " សូមឲ្យព្រះរាជឥស្សរិយរបស់យើង ល្បីល្បាញទូទៅក្នុងពិភពលោក។ ព្រះឥន្ទ្រាធិរាជទ្រង់មានព្រះបន្ទូលថា: " ព្រះរាជឥស្សរិយរបស់ព្រះអង្គ សូមឲ្យស្ថិតនៅដោយជោគជ័យលើស ព្រះចន្ទ ព្រះអាទិត្យ ព្រះធរណី មេឃនោះទៅទៀត ហើយព្រះអង្គ ជាព្រះមហាក្សត្រិយ៍សោយរាជ្យនៅក្នុងពិភពលោក "។

ព្រះឥន្ទ្រាធិរាជទ្រង់មានព្រះរាជបន្ទូលរួចហើយ ទ្រង់ក៏វិលទៅកាន់ទេវលោកវិញ។ ព្រះមហាក្សត្រិយ៍ទ្រង់ចាប់សាកសពទាំងពីរចោលទៅក្នុងតុងប្រែងមួយ ហើយវិញ្ញាណក្ខន្ធអាក្បែនឹងយោគីបានចេញពីក្នុងទីនោះមក ក្រាបបង្គំទូលព្រះបាទពិក្រម:ថា: " តើព្រះអង្គទ្រង់គ្រាស់បង្គាប់ឲ្យយើងទាំងពីរនាក់ធ្វើយ៉ាងណា "។ ព្រះបាទពិក្រម:មានព្រះបន្ទូលថា " បើយើងនឹកដល់អ្នក ចូរអ្នកមកឯយើងមួយរំពេច "។ ដល់អ្នកទាំងពីរ ក៏បាត់ឆង្ហួយឆកអាសាព្រះអង្គរួចហើយ ព្រះបាទពិក្រម:ទ្រង់ក៏វិលទៅកាន់រាជ្យរបស់ព្រះអង្គ ហើយទ្រង់ក៏សោយរាជសម្បត្តិដោយសុខតមក។ មានគម្ពីរខ្លះពោលថា: អ្នកណាបានដល់ជ្រាជ្រា ចេះកំដោយ លង្ឃកំដោយ តារក ប្ញទំទង់ តែងតែមានជោគជ័យជាដរាប។

(ចប់)

រឿងចិញ្ចៀនដ៏ឥត

អ្នកស្រីសារីយ៉ាន់ ប្រែពីបារាំងមកជាខ្មែរ

(តមក)

នៅក្នុងភូមិកប៉ាល់នោះមានស្រីចាស់ម្នាក់មានកូនស្រី១ផង ។ ស្រីនោះនិយាយថា "ក្រែកឡើងមើល! យើងនឹងគិតធ្វើទុបាយកលជាប្រយោជន៍យើងផង ជាប្រយោជន៍ដល់ពាផង" ។ លោកវានាវឯកក្រែកឡើងហើយបញ្ចេញមនុស្សដែលស្តេចត្រូវពិនិត្យម្នាក់ម្តង ។ ចំណែកឯយាយចាស់គាត់រើបង្ខិចសំពត់អាវនឹងប្រអប់ជាក់គ្រឿងប្រដាប់ សម្រាប់ស្រែតែងខ្លួនឲ្យស្តេចអាលីស្ងើកធ្ងន់សេទជាស្រី ហើយយកសំពត់១រុំមុខ ឲ្យរង្គុយនៅជិតគាត់ ។

លុះពិនិត្យគ្រប់មនុស្សប្រុសអស់ហើយ នាយតម្រួតនិយាយថា "នៅតែស្រីបីនាក់ទេ" ហើយក៏ឡើងចូលទៅរើរកក្នុងភូមិកប៉ាល់ទៀត ។ ព្រះអង្គម្ចាស់អាលី កាលឃើញពួកផែកឆេរទៅដល់ ទ្រង់តក់ស្លុត តែទ្រង់គេចព្រះភ័ក្ត្រចេញផ្លែកន្តើយ ។ ក្រោយពីបានពិនិត្យសព្វគ្រប់ក្នុងភូមិកប៉ាល់ហើយ ពួកអ្នកផែកឆេរក៏ដើរចេញពីភូមិកប៉ាល់ទៅ ។ ឈ្មួញទាំងប៉ុន្មានត្រេកអរណាស់ នាំគ្នាសរសើរលោនន្ទូកិច្ចកលរបស់យាយចាស់នោះឯង ។

ឃូរថៃគ្រោយមក កប៉ាល់នោះបានដល់កោះ អែល ហិន្ទូ, លោក
វេនាវីឯក និយាយទៅកាន់ពួកឈ្មួញថា: "ឈ្មួញទាំងឡាយ! ខ្ញុំមាន
សេចក្តីសរសើរអំពីការផ្គត់គ្រោះថ្នាក់របស់អ្នកណាស់ គ្រោយនេះយើង
ទើបបានដល់កោះអែល-កាហ្ស្រះហើយ" ។ លោកវេនាវីឯកឃើញមនុស្ស
កុះករឈរនៅកំពង់ចំណត លោកលាន់មាត់ថា: "ពុទ្ធោអើយ! ដូច
នៅឯកោះអែលអង់ប៉ារទៀតហើយ" ។ យាយចាស់ឆ្លើយថាមិនអ៊ីទេ
"យើងស្គាល់ការហើយ" ។ លុះកប៉ាល់ចូលដឹតដល់ច្រាំងការណា
ស្តេចកោះនោះមានព្រះបន្ទូលថា: "ឯងដឹងទេ ព្រះមហាក្សត្រី
យ៉ាគូតាហ៍ បានផ្តាំនឹងយើងថា: សូមពិនិត្យកប៉ាល់ដែលមកពីស្រុក
អៀរ៉ាក់ បើឃើញបុរសរូបភាពយ៉ាងនេះ។ សូមទ្រង់សម្លាប់ចោលព្រម
ទាំងមនុស្សនៅក្នុងកប៉ាល់ទាំងប៉ុន្មាន" ។ លោកវេនាវីឯកឆ្លើយតបថា:
"សូមទ្រង់ព្រះមេត្តាប្រោស! យើងគ្មានបុរសណាមានរូបបែបនោះ
ទេ" ។ ពួកតម្រួតឡើងឆែកឆេរកប៉ាល់ ប៉ុន្តែហាក់ដូចជាព្រះជា
ម្ចាស់ជួយទ្រទ្រង់អ្នកមានគ្រោះ ។

គ្រោយនោះ ព្រះអង្គម្ចាស់អាលី ក៏បានដល់កោះអែល-កាហ្ស្រះ ។
យាយចាស់នោះក៏តាក់តែងខ្លួនព្រះអង្គម្ចាស់ជាស្រី ។ ព្រលឹមឡើងគេ
ឃើញមានក្បួនខ្ចីបើ ១ ពាន់នាក់ ជាមួយនឹងពួកមនុស្សគ្រៀវ ៥០ នាក់,
នៅតណ្តាលចំណោមមនុស្សនេះ គេឃើញព្រះវរាជិនី យ៉ាគូតាហ៍

ឧដ៏ព្រះស្នំមាដ៏នានៅនៃបព្រះនាង ។ ស្តេចទ្រង់ប្រថាប់នៅលើមាត់ច្រាំងចាំទតកប៉ាល់ទាំងឡាយ ។

ព្រះនាងក្រឡេកឃើញនាវា ហើយទ្រង់បង្គាប់ទៅរឿនហ្វូងថា: "ចូរឯងទៅមើលកប៉ាល់នោះ តើឃើញបក្ខាមិត្តរបស់អញឬទេ ព្រោះឯងស្គាល់វាច្បាស់ជាងអ្នកដទៃ បើឃើញវាកាលណា ចូរឯងចាប់វាចងភ្ជាប់នៅក្បាលកប៉ាល់ រួចចូរយកទ្រព្យសម្បត្តិរបស់វាទាំងអស់ ហើយចូរឯងសម្លាប់ពួកដែលនៅក្នុងកប៉ាល់នោះផងកុំឲ្យនៅសល់" ។ រឿនហ្វូងទទួលព្រះឱង្ការដោយគោរព ហើយស្រែកហៅពួកពាណិជថា: "ពាណិជទាំងឡាយទាំងស្រីទាំងប្រុស! ចូរអ្នកឡើងមកទាំងអស់គ្នា" ។ ពួកពាណិជក៏ធ្វើតាម. ព្រះអង្គម្ចាស់អាលីនឹងយាងចូលជាមួយនឹងពួកស្រី ។ រឿនហ្វូងពិនិត្យពួកប្រុសៗឆែកនេរហិបឡុំទាំងប៉ុន្មានយ៉ាងហ្មត់ចត់ តែពុំឃើញអ្វីសោះ ហើយក៏ឡើងទៅទូលព្រះនាងថា: "ក្រាបទូលព្រះអង្គម្ចាស់ក្សត្រី! ទូលព្រះបង្គំជាខ្ញុំពុំមានឃើញអ្វីទេ" ។ ព្រះមហាក្សត្រីក៏បង្ខិលមុខត្រឡប់ចូលព្រះបរមរាជវាំងវិញ ។ មាដ៏នាជាស្នំរបស់ព្រះនាងសួរទៅរឿនហ្វូងថា: "ឯងបានពិនិត្យមើលពួកស្រីៗឬទេ?" ។ រឿនហ្វូងឆ្លើយថា: "ព្រះអង្គម្ចាស់អាលីនឹងស្លៀកពាក់ក្លាយជាស្រីម្តេចបាន ព្រះអើយ!" ។

កាលណោះមាដិនាក៏ចូលទៅជិតប្រាំ (tente) ដែលពួកស្រីៗនៅ ។ ព្រះអង្គម្ចាស់អាលីលុះបានឃើញនាងមាដិនា ទ្រង់នឹកដល់គុណបុណ្យព្រះជាម្ចាស់សួគ៌ ។ យាយចាស់កាលបានឃើញនាងស្ទុះដើរមកដល់ក៏ក្រោកឡើងនិយាយថា: "អ្នកស្រី! ខ្ញុំជូនកូនស្រីខ្ញុំនេះជាបំរើអ្នក" ។ នាងនោះស្រាប់ព្រះអង្គម្ចាស់អាលីម្ដងម្កាក់ៗ ។ ព្រះអង្គម្ចាស់អាលីទ្រង់ជ្រាបថា: សេចក្ដីវិនាសនឹងតាមទាន់ព្រះអង្គពិត ទ្រង់ឡើងព្រះកំភ្លុងស្ទាំងមួយរំពេច ហើយទ្រង់នឹកបួងសួងថា: "ឧ! តេជៈព្រះដ៏មានបុណ្យអើយសូមជួយខ្ញុំ!" ។ នាងមាដិនានិយាយថា: "កុំខ្លាចកូន! ដូចជាឋានឯងដូច្នោះដែរ" ។ ព្រះអង្គម្ចាស់អាលីទ្រង់ជាក់ព្រះភ័ក្ត្រចុះហើយប្រថុយយាងចូលទៅជិតស្នំៗ កាន់ព្រះអង្គហើយបង្គាប់ថា: "ខិតចូលមកទៀត" ទើបវាបកសំពត់ទូរក្បាលចេញ ។ នាងឃើញព្រះភ័ក្ត្រព្រះអង្គចេញមកយ៉ាងប្រិមប្រិយ ក៏លាន់មាត់ថា: "ព្រះអង្គអើយ! ម៉ុខអ្វីក៏ល្អម្ល៉េះ បើប្រសិនឯងជាស្រី អញសរសើរដល់អ្នកដែលបង្កើតឯងមក ឲ្យដូចគ្នានឹងមនុស្សដែលអញរកដូចជាទឹក ១ ដំណក់" ។ ក៏ប៉ុន្តែនាងស្គាល់ជាព្រះអង្គម្ចាស់អាលីហើយ ទើបទូលទ្រង់ថា: "ព្រះអើយ! នៅលើដីនេះគ្មាននរណាមួយហៅហ៊ានដូចព្រះអង្គម្ចាស់អាលីទេ ប៉ុន្តែម្ដងនេះខ្ញុំម្ចាស់មានចិត្តមេត្តាដល់ទ្រង់ណាស់" ។ ព្រះអង្គម្ចាស់អាលីរកតែមានព្រះបន្ទូល ១ មាត់ពុំបាន ។ នាងស្ទុះនិយាយតទៅទៀតថា

"សូមទ្រង់មានព្រះបន្ទូលមក ម្តេចក៏ទ្រង់ខ្ជាចខ្ញុំម្ចាស់ទៅវិញ?" ។
ព្រះអង្គម្ចាស់អាលីមានព្រះបន្ទូលថា: "មាដ៏នា! ពេលនេះគឺជាពេលដែលនាងត្រូវធ្វើអំពើល្អ" ។ នាងមាដ៏នាក្រាបទូលថា: ព្រះពរម្ចាស់! សូមទ្រង់កុំក្បត់ចិត្តខ្ញុំម្ចាស់ បើកាលណាទ្រង់ចានសំរេចកិច្ចហើយ សូមទ្រង់កុំបោលខ្ញុំម្ចាស់ឲ្យសោះ" ។ ព្រះអង្គម្ចាស់ទ្រង់ស្បថឲ្យនាងស្តាប់ដឿ ហើយទ្រង់ចង់ចាប់ដៃនាងថើប ប៉ុន្តែនាងពុំព្រមថ្វាយ. នាងទូលទ្រង់ថែមទៀតថា: "ទូលព្រះអង្គម្ចាស់! ខ្ញុំម្ចាស់ពុំដែលឃើញចិញ្ចៀននោះសោះតាំងតែពីព្រះនាងចានលួចយកមកកាលណា, ព្រះនាងគ្មានពេលអាក្បែបំរើទេ បើប្រសិនជាមាននោះព្រះនាងនឹងរកឧបាយសម្ងាប់ទ្រង់ចានទៅហើយ មួយទៀតក្នុងពេលនេះ បើខ្ញុំម្ចាស់ដឹងថាចិញ្ចៀននោះនៅកន្លែងណា ខ្ញុំម្ចាស់នឹងលួចយកមកថ្វាយទ្រង់ភ្លាម ទ្រង់ជ្រាបស្រាប់ហើយថាខ្ញុំម្ចាស់នឹងព្រះនាងក៏មិនមែនកំចាំងទេ" ។

ថាដូច្នោះហើយ នាងស្ទុះដើរចេញទៅ ព្រះអង្គម្ចាស់អាលីនៅតែមិនទុកព្រះទ័យដល់ពាក្យល្អរបស់ទ្រង់ទៀត ហើយទ្រង់ព្រះដំរិះថា: "អញគ្មានទីពឹងផ្នែងណាក្រៅអំពីផ្នែងយាយចាស់មុននោះឡើយ" រួចទ្រង់ក៏យាងគាត់តម្រង់ទៅដល់ហើយក៏គោះទ្វារ ។ ស្រីបំរើម្នាក់ចេញមកសួរទ្រង់ថា: "អ្នកមានការអ្វី?" ។ ទ្រង់តបថា: 'ខ្ញុំជាសាវឡៃកនៅក្នុងព្រះបរមរាជវាំង" ។

(មានត)

លោកធើង-ជ្រើរ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តពីសៀវភៅលេខ ១០)

លោកគ្រូពេទ្យដែលលោកចៅហ្វាយបញ្ជូនមក ឲ្យជួយមើលថែរក្សាអ្នកទាំងឡាយនោះពោលថា បើចង់ឲ្យអាប៉ូលឈប់ស្រងូតស្រងាត់ ត្រូវតែបណ្តាយតាមចិត្តវា វាចង់ធ្វើអ្វីឲ្យធ្វើចុះ កុំយល់ខាស់ប្តូរទំនងវាឡើយ ទុយហ្នឹងទើបធ្វើឲ្យវាជាត់ព្រួយបាន ។

ខ្ញុំសម្រេចចិត្តធ្វើតាមលោកគ្រូពេទ្យ ។ កាលណាអាប៉ូលត្រឡប់មានកំឡាំងដូចដើមវិញ វាគិតតែដើរចេញពីផ្ទះ ។ ខ្ញុំមិនហ៊ានឲ្យជាត់ជានឡើយ ខ្ញុំដើរតាមតែពីក្រោយទៀត ហើយខ្ញុំប្រាប់ឲ្ញុំម៉ាំងឲ្យយកស្បៀងអាហារតាមយើងមក ។ លុះណាអ្នកកំឡោះប៉ូលដើរកន្ទុយផុតខ្ទុះហើយ (តាចាស់ចង្អុលក្តុំ) សេចក្តីរីករាយនឹងកំឡាំងកាយរបស់វាដូចជាមានកាន់តែច្រើនឡើង ។ វាដើរតាមផ្លូវ ប៉ុន្តែមុះ លុះដើរដល់តែរវិហារ ត្រង់ផ្លូវទៅគុម្ពឫស្សី វាឈរឆ្ងល់នោះត្រង់កន្លែងដែលគ្រឡប់មើលឃើញអាចម៍ដីនៅចុង ។ វាគាំងលុតជង្គង់នៅទីនោះ ក្អែកបើកសំឡឹងមើយហើយសូត្រធម្មយូរអើយូរ ។ ខំនេះ មើលទៅដូចជាវាត្រឡប់មានសតិឡើងវិញ ព្រោះការដែលមានចិត្តឆ្ងល់ដល់ព្រះជាម្ចាស់ ធ្វើឲ្យ

យើញថាត្រលឹងរបស់ពាលមកធ្វើការនៅកន្លែងចាស់ដូចដើម ។ ខ្ញុំនឹងប្ញមុាង លុតជង្គង់តាមពាក្យសូត្រធម៌ដែរ ។ រួចហើយ ក៏ត្រាក់ឡើងដើរតាមផ្លូវសំដៅកោះខ្សាច់ដើង គ្មានរវល់នឹកនាអ្វីពីយើង ។ ខ្ញុំយល់ថាកំមិនដឹងគេកប៉ះខ្លាច រីស៊ីនី ត្រង់ណាឡើយ តាំងពីចេញពីសមុទ្រមក ។ ខ្ញុំសួរថា ចុះហេតុអីក៏ឯងនៅថ្ងាយបង្គំសូត្រធម៌នោះស្បែរគុម្ពឫស្សី? ។ ពាឆ្លើយថា យើងពីដើមធ្លាប់មកទីហ្នឹងញឹកញាប់! ។

អាប៉ូលចេះតែដើរៗ ទៅរហូតដល់មាត់ព្រៃ ស្រាប់តែយប់មកដល់ ។ នៅទីនោះ ខ្ញុំបង្ខំពាឲ្យស៊ីឆ្ងាយតាមខ្ញុំបានបន្តិច ។ រួចយើងដេកលើស្មៅក្រោមឈើមួយដើម ។ ពឹកឡើង ខ្ញុំស្មានថាមុខជាពាសាជានមកវិញមិនខាន ។ មិនដូច្នោះ ពាឈរសំឡឹងវិហារ ប៉ុប្លែមុះ មួយស្របក់ក្រឡេកមើលទៅតាមផ្លូវគុម្ពឫស្សី នៅកណ្តាលក់ល ហើយធ្វើទំនងដូចជានឹងវិលមកវិញ ស្រាប់តែសុះចូលព្រៃជ្រៅក ដើរទៅតែទិសខាងដើង ។ ខ្ញុំដឹងច្បាស់ទូវបំណងពា ហើយខ្ញុំនិយាយបញ្ឆោតបន្ទប់ដូចម្តេចក៏ឥតអំពើ ។ ថ្ងៃត្រង់យើងទៅដល់ភូមិពូត - ឧរ . ។ ពាសុះវត់ទៅមាត់សមុទ្រ ដំរង់តន្លែងដែលនាវាសាំងសេរ៉ដ៏លិច ។ កាលពាក្រឡេកឃើញគោះដំនឹងច្រកព្រៃពាសដីតរលាយចូលគ្នាតែមួយដូចកញ្ចក់ ពាលោតស្រែកថា: "រីស៊ីនី! ឯ រីស៊ីនី មាសត្រលឹងបង!" ហើយស្រាប់តែដួលបាត់ស្មារតី ។

ដូម្ប៉ាង នឹងខ្ញុំរំលើកសែងវាទៅកណ្តាលព្រៃ ហើយវាគត់ច្រចាប់ទំពាំបានដងខ្លួនឡើងវិញ ។ ភ្លាវឡើងដងខ្លួនបានស្រួល វាចង់វិលទៅមាត់សមុទ្រទៀត តែយើងរំអង្វរថាកុំឲ្យធ្វើសេចក្តីខ្ជុលរបស់វានឹងរបស់យើងឲ្យចំរើនឡើង ដោយការលឹកឥតប្រយោជន៍ ។ វាក៏ត្រឡប់ទៅកាន់ទីដដែលទៀត ។ ក្នុងរយៈវេលាប៉ុន្មានថ្ងៃ អាប៉ូលចេះតែដើរទៅគ្រប់កន្លែងដែលវាធ្លាប់ទៅជាមួយនឹងប្អូនសំឡាញ់វាកាលពីដើម ដែលជាកុមារ ។ វាដើរតាមផ្លូវដែលវ៉ែស៊ីនីទៅសុំទោសឲ្យស្រីពួងម្នាក់នាស្ទឹងទឹកឡើ រួចវាទៅមើលមាត់ស្ទឹងក្តុងដោះបីជាកន្លែងដែលនាងដើរមិនបានហើយអង្គុយនៅទីនោះ ទៅមើលត្រង់កន្លែងដែលនាងវង្វេងផ្លូវ ។ វាដើរមើលគ្រប់កន្លែងទាំងអស់ ដូចជាត្រង់ដែលមានព្រួយ , ត្រង់លេនល្បែង, ត្រង់ស៊ីចាយ, កន្លែងដែលប្អូនសំឡាញ់វាធ្លើតាន, ស្ទឹងក្តុងវែង, ផ្ទះខ្ញុំ (តាចាស់), ទឹកជ្រោះនៅជិតខាងដើមល្វាងដែលនាងដាំ, វាលស្មៅដែលនាងចូលចិត្តរត់លេង ផ្លូវបំបែកដែលនាងចូលចិត្តទៅច្រៀងលេង; ទីស្ថានប៉ុន្មាននេះធ្វើឲ្យអាប៉ូលស្រក់ទឹកភ្នែកគ្រប់កន្លែង ហើយពីដើមធ្លាប់តែរំពងក្តុងនៃសំឡេងនឹងសម្រែកដ៏សប្បាយជាមួយគ្នា តឡូវតែស្ងាត់ឈឹងវេទនា: "វ៉ែស៊ីនី ? ឧ វ៉ែស៊ីនិ មាសថ្លៃបងអើយ ! ម្តេចអូនឃ្លាតបាត់ទៅណា !" ។

ក្នុងកាលដែលអាប៉ូលប្រព្រឹត្តដូចសត្វតិរច្ឆាន មិនចេះមានទីមួយកន្លែង វាមានក្អែកស្លាត់ ពណិស្លេក សេចក្តីសុខកាយកាន់តែបុះ ។ ការ

យល់ឃើញថាសេចក្តីទុក្ខព្រួយរបស់យើងកើតឡើងជាទ្វេគុណ ដោយសារតែការលើកនូវសេចក្តីរីករាយដែលមានហើយក្នុងកាលមុន នឹងកាមគុណភាំងឡាយចេះតែចំរើនឡើងក្នុងទីស្ងាត់ ខ្ញុំក៏សម្រេចចិត្តនឹងបញ្ឈប់សំឡាញ់កំសត់នេះ ពីទីកន្លែងដែលនាំឲ្យរាចេះតែលើកនូវការបាត់បង់ ទៅទុកនៅកន្លែងមួយក្នុងកោះ ជាកន្លែងដែលរាមិនយល់នូវអនុស្សាវរីយ៍នាំបណ្តាលឲ្យមានការស្រេងេះស្រេងោច ។

បើដូច្នេះ ខ្ញុំនាំរាទៅនៅលើឯងកុំ ក្នុងភូមិមួយឈ្មោះ វីល្យាំ ជាកន្លែងដែលរាមិនដែលទៅម្តងសោះ ។ នៅកន្លែងកោះត្រង់ហ្នឹងបរិបូណ៌ទឹងចំរើនដោយផលព្រះឥណាទឹងជំនួញគ្រប់យ៉ាង ។ គេឃើញពួកជាងជាច្រើន ខ្លះចាំង ខ្លះអារឈើ ។ រនេះចាំងឡាយបរទៅមកតាមថ្នល់ ហូងសត្វពាហនៈចាំងឡាយស៊ីស្មៅរនោកនារាលស្មៅ នៅទីរាលសុទ្ធតែផ្ទះអ្នកស្រុកដ៏ខ្លួល បើកអំណាចជាច្រើនកន្លែងដល់ពួជដំណាំចាំងឡាយមកពីប្រទេសនុប ។ ក្រឡេកទៅខាងណោះសំឡឹងទៅខាងណោះ នៅទីរាលគេឃើញស្រែរសាលីចាំងឡាយដុះពាសពេញ ពោតសណ្តែកនៅត្បែរមាត់ព្រៃ ដើមផ្លាកូឡាបជាច្រើនដុះហែជួចរបងតាមផ្លូវ ។ អាកាសត្រជាក់ជ្រួតជ្រាបដល់សរសៃ គួរជាទីអាស្រ័យនៅដោយសេចក្តីរីករាយនៃពួកក្រែកស ។ (មានត)

អំពីការប្រឡងក្នុងធម្មាសនៈទី ១ ឆ្នាំ ១៩៥៣

នៅធម្មាសនៈទី ១ ឆ្នាំ ១៩៥៣ ក្រុមដំណុំបានបើកនូវការប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ ២ រឿង គឺទី ១ អំពីភ្ជាប់ពាក្យសុីស្លា, ទី ២ អំពីភ្លេីង ។ ក្នុងករណីយ៍នេះក្រុមដំណុំបានទទួលឯកសារប្រឡងជាច្រើនអំពីចេកូជនដែលស្នុំគ្រប្រឡង បានជួបជុំពិនិត្យនូវឯកសារទាំងនោះដោយហ្មត់ចត់ ឃីញបានលទ្ធផល ដូចដូនដំណឹងតទៅនេះ :

ទី ១ រឿងភ្ជាប់ពាក្យសុីស្លា បានជាប់ ៥ រូប គឺ

ក) លោក ឌួង - អ៊ូច រមយុំអង្គាញ់ ស្រុកវៃពកប្បាស (តាកែវ) ជាប់លេខ ១ ត្រូវបានរង្វាន់ ៣០០រ,០០ ;

ខ) លោក ឆួរ - អ៊ុក ឫងឺតុងសាលាខែត្រតាកែវ ជាប់លេខ ២ ត្រូវបានរង្វាន់ ២៥០រ,០០ ;

គ) លោក ម៉ម - សាក់ ក្រសួងនេសាទ្រនៅកំពង់ឆ្នាំ ជាប់លេខ ៣ ត្រូវបានរង្វាន់ ២០០រ,០០ ;

ឃ) លោក អេង - លី នៅឃុំ-ស្រុក - ខែត្រក្រចេះ ជាប់លេខ ៣ ត្រូវបានរង្វាន់ ២០០រ,០០ ;

ង) លោក ធន - ផាត់ (បណ្ណាគារ, ធន - ផាត់)-នៅផ្សារស្វាយ-រៀង ស្វាយរៀង) ជាន់ជាប់លេខ ៤ ត្រូវបានរង្វាន់ ១៥០រ ០០ ។

ទី ២ រឿងភ្លើងបានជាប់ ២ រូប គឺ

ក) លោក ជូរ-អ៊ុក ប្រធានតុនសាលាខេត្តតាកែវ ជាន់ជាប់លេខ ៣ ត្រូវបានរង្វាន់ ២០០រ,០០;

ខ) លោក កែវ - ហង្ស ចាងហ្វាងរ៉ឺស្តែត នៅឃុំសួង ស្រុកត្បូងឃុំ (កំពង់ចាម) ជាន់ជាប់លេខ ៤ ត្រូវបានរង្វាន់ ១៥០រ,០០ ។

អាស្រ័យដោយអស់លោកបេក្ខជនទាំងនេះ ជាបច្ចាស់នូវខ្លួនគតិរបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ព្រមទាំងយកចិត្តទុកដាក់ចំពោះខ្លួនគតិនេះណាស់ហើយ ជាន់ជាសរសេរឯកសារប្រឡងទំនៀមទម្លាប់ខ្មែរទាំងអស់នេះក្នុងធម្មាសនទី ១ ឆ្នាំ ១៩៥៣ នេះបាន, ក្រុមជំនុំមានអំណរគុណជាច្រើន ។ សូមប្រកាសឈ្មោះអស់លោកទាំងនេះទុកជាទីរលឹកតទៅ ។

អំពីការប្រឡងជាប្តីក្នុងធម្មាសទី ២ ឆ្នាំ ១៩៥៣

នៅធម្មាសទី ២ ឆ្នាំ ១៩៥៣ ក្រុមជំនុំបានបើកឧកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ ២ រឿងជាថ្មីទៀត គឺ

ទី ១ រឿងហោរាសាស្ត្រ: សួរអំពីដំណើរ-ទំនាយ នឹងត្រណមចំពោះព្រះអាទិត្យព្រះចន្ទ នឹងផ្កាយទាំងឡាយ ដូចសុរិយគ្រាស ចន្ទគ្រាស

ថ្ងៃចាំឆន័ត្រ ខែចាំឆន័ត្រ ឆ្នាំយដុសកន្ទុយ ឆ្នាំយហោះ ខេពជ្យុត ដើឆក្កាយ ទឹងរឿងព្រែងចាក់ទង់ដោយវត្តនោះ ។ ល ។

ទី ២ រឿងទីក: ស្ទរអំពីទំនៀម - ជំនឿនឹងត្រណម ចំពោះទឹកទន្លេ សមុទ្រ ស្ទឹង បឹង - ត្រពាំង - អណ្តូង - ស្រះ, ការដឹកអណ្តូង ស្រះ - ប្រជាប់សួន - រវៃ - ចាច - ឋង្ហរ - ស្រូបទឹក - ទេវតារក្សាទឹក ទឹងរឿងព្រែងចាក់ទង់ដោយទឹកចាំងនោះ ។ ល ។

គោលនៃការប្រឡងនេះ ក្រុមដំទុំបានបោះពុម្ពចែកផ្សាយតាមរយៈ សាលាខែត្រ សាលាស្រុក សាលាឃុំ សាលាគណ អនុគណ ហើយទឹងដំកល់ទុកក្នុងមន្ទីរក្រុមដំទុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ សម្រាប់ចែកលោកអ្នកត្រូវការ ។

ការប្រឡងជាប់លើកនេះ ត្រូវបានរង្វាន់ច្រើនជាងលើកមុន ។ គឺ

រង្វាន់លេខ ១	ត្រូវបាន	៤០០រ,០០
- ដ - ២	- ដ -	៣០០,០០
- ដ - ៣	- ដ -	២០០,០០
- ដ - ៤	- ដ -	១០០,០០

ដូច្នេះ, ព្រះតេជព្រះគុណ, លោកអ្នកចាំងឡាយ ទោះជាស្ត្រី ឬបុរស - គ្រហស្ថ ឬបព្វជិត ដែលស្ម័គ្រចិត្តជួយលើកស្ទួយអារ្យធម៌ខ្មែរ

សូមតែងរឿងដូចពាយឈ្មោះខាងដើមយកទៅជូន ប្តូរផ្ញើតាមប៉ុស្តិ៍ផ្ទាល់ក៏បាន, ជូនសាលាខេត្ត សាលាស្រុក - សាលាឃុំផ្ញើឲ្យក៏បាន ឲ្យបានទៅដល់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរនៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ មុនដាច់ខែធ្នូ ឆ្នាំ ១៩៥៣ ។

អំពីឈ្មោះនឹងឯកសារដែលសមាជិកធ្វើយឆ្លងបានជូនក្នុងធម្មាសទី ១ ទី ២ ឆ្នាំ ១៩៥២ នឹងធម្មាសទី ១ ឆ្នាំ ១៩៥៣

ពួកសមាជិកធ្វើយឆ្លង នឹងឯកសារដែលសមាជិកទាំងនេះបានឲ្យការណ៍ក្នុងធម្មាសទី ១ ទី ២ ឆ្នាំ ១៩៥២ នឹងធម្មាសទី ១ ឆ្នាំ ១៩៥៣ ដូចពាយឈ្មោះតទៅនេះ គឺ

- លោក សាំង - លិន នៅឃុំល្វេ ស្រុកស៊ីធរកណ្តាល (ត្រៃវែង) បានជូនរឿងចម្លាក់ក្បាលជណ្តើរ, ការសាស្ត្រ, ការធ្វើជំណើរ, មហោស្រព នឹងចម្រៀងបុរាណ;

- លោក គ្រូ ចាប ចន្ទ វត្តក្តីក្រៅ ឃុំខ្នាវស ស្រុកស្រីសន្ធរ (កំពង់ចាម) បានជូនដើមកំណើតស្តេចក្រុងចិនដែលទៅពីស្រុកខ្មែរទៅកើត, ដើមកំណើតក្រុងភ្នំពេញ ពង្សាវតារខ្មែរ, ត្រកូលសង្ឃាន្ត, ទំនៀមធ្លប់ខ្មែរ, ជំពាក្យខ្មែរ, ភ្ជាប់ពាក្យស៊ីស្ងា, ទំនៀមភ្ជើង នឹងប្រវត្តិគ្រូឃ្លាំងនៅស្រុកត្រើង (កំពង់ចាម);

លោក ប៊ុន ប៊ូរ ប៊ូលិស ស្រុកជាំក្សាន្ត (កំពង់ធំ) បានជូនរឿង ទំនៀមផ្សេងៗ, ទំនៀមធ្វើបុណ្យខ្មោច នឹងភ្ជាប់ពាក្យសុំស្លា;

លោក អុង - គឹមហ៊ាន ស្មៀនប៊ុយរ៉ូកូមិចាល ស្រុកមង្គលបូរី (ប៉ាត់ដំបង) បានជូនកំរួនសង់ផ្ទះ;

អ្នកអង្គម្ចាស់ក្សត្រី នរោត្តម - សុខានារី លេខាធិការិនី នៅមន្ទីរយោសនាការអាម៉េរិកាំង ក្រុងភ្នំពេញ, បានជូនរឿងសម្រែកចំពាក់ខ្មែរ;

លោក កូ - តាកែ, ស្មៀនឃុំអន្ទង់គ្នោត ស្រុកក្រគរ ខោធិសាត់ បានជូនរឿងធ្នូរខ្មែរ, ទំនៀមធ្វើទន្ទេ, ប្រវត្តិភូមិខ្មែរ, របៀបធ្វើសំពត់ហូល, រឿងកុំស្រវ, ចម្រៀងខ្មែរ នឹងមហាស្រព;

លោក ចៅ គង់ នៅឃុំស្វាយជូនកែវ ស្រុកបាកាន ខោធិសាត់ បានជូនរឿងមហាស្រព នឹងចម្រៀង;

លោក ឡុង សាន់ នៅឃុំស្វាយចាំ ស្រុកសង្កែ (ប៉ាត់ដំបង) បានជូនរឿងធ្នូរទន្ទេ នឹងដំមា្បញខ្មែរ;

លោក ជួរ អ៊ុក ឫទ្ធិតុង សាលាខែត្រតាកែវ បានជូនរឿងដម្បាញខ្មែរ របៀបធ្វើសំពត់ហូល, រឿងភ្ជើង នឹងភ្ជាប់ពាក្យសុំស្លា;

លោក ឃួង - អ៊ីច មេឃុំអន្លាញ ស្រុកត្រែកបា្លស (តាកែវ) បានជូនរឿងធ្នូរទន្ទេ នឹងចម្រៀងខ្មែរ;

នាង ទេព - សាធឿម ឃុំលំចន៍ស្រុកសំពេង តាកែវ ចានដូន រឿងធ្លងទេន្ទ ;

លោក កែវ ហង្ស ចាងហ្វាងរុំត្រែត នៅឃុំសួង ស្រុកត្បូងឃ្មុំ (កំពង់ចាម) ចានដូនរឿងជម្បាញខ្មែរ, ពង្សាវតារខ្មែរ, ចម្រៀងខ្មែរ, រឿងកូវ ទំងរឿងភ្លាបពាក្យស៊ីស្ង ;

លោក គង់-ចណ្ឌន: នៅឃុំជ្រៃវៀន ស្រុកកៃពៃឈរ (កំពង់ចាម) ចានដូនរឿងជម្បាញខ្មែរ, ប្រវត្តិកូមិស្រុក, ទំនៀមធ្លងទេន្ទ ទំង ចម្រៀងខ្មែរ;

លោក អាចារ្យ សួង វង្ស នៅឃុំត្រែកញ្ជៅ ស្រុកពញាលី (កណ្តាល), ចានដូនរឿងធ្លងទេន្ទ, ជម្បាញខ្មែរ, រឿងកូមិ, រឿងត្រែង, ចម្រៀងខ្មែរ, របៀបធ្វើសំពត់ហូល-ច្របុច, អាពាហ៍ពិពាហ៍, បញ្ចេញ ម្ជុលកូនស្រី, ធ្វើធ្មេញ, មហោស្រព, ចម្រៀងខ្មែរ ទំងក្បួនចាយ លក្ខ-ណៈមនុស្ស;

លោក សោម ហុម ត្រឡាបញ្ជីរុំត្រែត នៅឃុំលេខ ៤ កំពង់ញ ចានដូនរឿងប្រវត្តិកូមិ, រឿងធ្លងទេន្ទ, មហោស្រព, ចម្រៀង ទំង របៀបធ្វើសំពត់ហូល,

លោក ធន់ - សៅ នៅឃុំលេខ ៥ កំពង់ញ ចានដូនរឿងតម្បាញ ទំងរឿងភ្លាបពាក្យស៊ីស្ង;

លោក ស៊ុន - សាំង មេឃុំចាស់ ឃុំគោកត្រឹង ស្រុក - ខេត្តស្វាយរៀង បានជូនរឿងធ្វើទន្ទេ នឹងចម្រៀង;

លោក អៀង - សឿង. មេជាងរចនា នៅឃុំលេខ ១ ភ្នំពេញ បានជូនរឿងពង្សាវតារ នឹងធ្វើទន្ទេ;

លោក ន ន្ធូ - នៅ នៅឃុំលេខ ៤ ភ្នំពេញ បានជូនរឿងធ្វើសំពត់ហូល;

លោក ឌឿ - ភ័ន្ត នៅឃុំភ្នំកុង ស្រុកបន្ទាយមាស (កំពត) បានជូនរឿងភ្លេង នឹងភ្ជាប់ពាក្យស៊ីស្វា, បម្ងាក់ក្បាច់ដណ្តើរ នឹងតម្បាញ;

លោក គ្រូ ព្រហ្ម - គង់ មេគណខេត្តកំពង់ធំ បានជូនរឿងមហោស្រព នឹងចម្រៀង;

លោក អេង លី នៅឃុំ ស្រុក ខេត្តក្រចេះ បានជូនរឿងភ្ជាប់ពាក្យស៊ីស្វា នឹងរឿងភ្លេង;

លោក តេង - ងី នៅឃុំកំពង់ពពិល ស្រុកពារាំង (ខៃត្រវែង) បានជូនរឿងភ្លេង នឹងភ្ជាប់ពាក្យស៊ីស្វា

លោក ខេព វស់ នៅឃុំលំចង ស្រុកសំរោង (តាកែវ) បានជូនរឿងភ្លេង នឹងរឿងមង្គលការ;

លោក ម៉ម - សាត់ នៅក្រសួងនេសាទ ត្រី (កំពង់ឆ្នាំង) បានជូនរឿងភ្ជាប់ពាក្យស៊ីស្វា;

លោក ធន់ - ផាត់ នៅផ្សារស្វាយរៀង ស្រុក ខែត្រស្វាយរៀង បានជូនរឿងភ្ជាប់ពាក្យស៊ីស្វា ;

ឧកញ៉ាកត្តីសាខេត កែ - នេត្រ រ៉ុំត្រែត នៅឃុំលេខ ១ ភ្នំពេញ បានជូនរឿងក្បួនមើលលក្ខណៈរបស់មនុស្ស ទំនងរឿងបណ្តាំពាលី ។ អំពីឈ្មោះជនមិនមែនសមាជិកធ្លើយធ្លង ដែលបានជូនឯកសារ

លោក នួន - ផាន់ នៅប៉ុស្ត៍ G.V.F. ស្ថានីបំណាក់ បានជូនរឿងព្រៃឆ្ន ទំនងចម្រៀងខ្មែរ ;

លោក រ័ត - ជូរ នៅផ្សារស្វាយរៀង ស្រុក ខែត្រស្វាយរៀង បានជូនរឿងចម្រៀងខ្មែរ ;

លោក គាំ - ភួង នៅឃុំលំចង់ ស្រុកសំរោង (តាកែវ) បានជូនរឿងភ្ជាប់ពាក្យស៊ីស្វា ;

លោក ឡុញ - ទុយ ប៉ូលិសស្រុកស្រីសន្ធរ (កំពង់ចាម) បានជូនរឿងពង្សាវតារ ។

ក្រុមដំនុំទំនៀមទម្លាប់ខ្មែរ សូមសរសើរគុណជាថ្មីថែមទៀត ចំពោះអស់លោកចំណសមាជិកធ្លើយធ្លង ចំណមិនមែនសមាជិកធ្លើយធ្លង ព្រមចំណអស់លោកជាបេក្ខជន ដែលបានផ្ញើឯកសារទៅប្រឡងក្នុងឆមាសទី ១ ឆ្នាំ ១៩៥៣ នេះ ដោយមានសេចក្តីរាប់អានតាមគតិរបស់ក្រុមដំនុំ

ទំនៀមទម្លាប់ខ្មែរ ដែលបានឈាមថាបានជួយបំពេញការណ៍យកចិត្តនៃក្រុមជំនុំនេះ ឲ្យចំរើនជាកិយ្យាភាពឡើង ។

មួយទៀត ក្រុមជំនុំសូមអំពាវនាវដល់ព្រះតេជព្រះគុណ លោកអ្នករួមជាតិទាំងឡាយ ទូទៅទាំងព្រះរាជអាណាចក្រទាំងមូល សូមជួយជ្រោមជ្រែងការណ៍យកចិត្តរបស់ក្រុមជំនុំនេះ ដោយចុះនាមធ្វើជាសមាជិកធ្វើយ៉ាងធំ ទឹងជាបេក្ខជន ហើយសរសេរឯកសារទំនៀមទម្លាប់ផ្សេងៗទៀតការណ៍ ទឹងទៅប្រឡងរៀងរាល់ឆមាសតទៅ ។ បើប្រសិនជាមានអស់លោកណា មិនបានចុះនាមជាសមាជិក ឬជាបេក្ខជនទេ តែមានសទ្ធាអាចសរសេរឯកសារឿងទំនៀមទម្លាប់ណាមួយ ទៅឲ្យក្រុមជំនុំបាននោះ វិតវែងជាការគាប់ប្រសើរណាស់ទៅទៀត ។

ក្រុមជំនុំ សូមទទួលអំណរគុណយ៉ាងខ្ពស់ខ្ពុកជាមុន ។

ព្រះរាជប្រវត្តិ

ទំនឹងសេចក្តីអស្ចារ្យ នៃព្រះបិយមហាក្សត្រ

ព្រះគ្រូបាសាទរដ៏ឫអ្នគុណា កែ - អឿន (វីរិយប្បញ្ញោ)

វត្តព្រះពុទ្ធវត្តន៍ ខែត្រសៀមរាប ឋានថ្កែង ក្នុងថ្ងៃផ្តុំបិណ្ឌធំ

ឆ្នាំ ៣ ស. ២៤៨៦ ក្នុងប្រជុំបរិស័ទពាន់នាក់

បៅអធិការវត្តនានា បានសុំចម្លងយកទៅសូត្រជូនគ្នា ។

ព្រះបាទសម្តេចព្រះនរោត្តម ស៊ីហនុវរ្ម័ន ភាជហរិវង្ស ខ្មែរគោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះបៅអាណាចក្រកម្ពុជា ព្រះអង្គទ្រង់ឋានសោយរាជសម្បត្តិពី ព.ស ២៤៨៤ គ ស.១៩៤២ ក្នុងព្រះជន្មវស្សាគំរប់ ២០ ឆ្នាំ ព្រះអង្គជាក្សត្រខ្មែរគោសុជាត ទ្រង់ប្រកបដោយទសពិធរាជធម៌ ទ្រង់មានព្រះអធ្យាស្រ័យទៀងត្រង់សុភាពទន់ភ្លន់ស្រគត់ស្រគំសមរម្យឥតគ្នាំគ្នង ទ្រង់ពេញព្រះរាជហ្ឫទ័យចំពោះការសិក្សាទាំងផ្លូវលោកផ្លូវធម៌ មានព្រះរាជទស្សាហ៍ព្យាយាមដ៏មុតមាំ ជាក្សត្រទ្រង់សីលមានធម៌ជាកុសល ទ្រង់រក្សានូវប្បដិបត្តិយធម៌ គឺគោរពកោតក្រែងដល់ចាស់ព្រឹទ្ធាចារ្យទាំងព្រះសង្ឃដែលទ្រង់ត្រៃសិក្ខា ជាទីស្រឡាញ់ពេញចិត្តនៃប្រជាជនក្នុងកម្ពុជរដ្ឋទាំងមូល ។ តាំងអំពីព្រះអង្គបានសោយរាជ្យឡើងវេលាណាទ្រង់ទំបំពេញព្រះរាជករណីយកិច្ច ក្នុង

ព្រះពុទ្ធអាណាចក្រ ឲ្យមានរបៀបរៀបរយ ហើយទ្រង់ប្រទានច្បាប់
រដ្ឋធម្មនុញ្ញ នឹងប្រជាធិបតេយ្យដល់ពលរដ្ឋរបស់ព្រះអង្គ ។ ច្បាប់រដ្ឋធម្ម-
នុញ្ញនឹងប្រជាធិបតេយ្យនេះ ទើបតែនឹងកើតមានក្នុងរជ្ជកាលព្រះអង្គនេះ,
ព្រះកិត្តិគុណនេះហើយ ដែលអាចធ្លាក់ទុកក្នុងប្រវត្តិសាស្ត្រតទៅក្នុងអនា-
គតកាល មិនតែប៉ុណ្ណោះសោតទេ ព្រះអង្គទ្រង់គោរពព្រះពុទ្ធសាសនា
ដែលជាសាសនារបស់រដ្ឋយ៉ាងក្រៃលែង ហើយទ្រង់ជាអគ្គសាសនូបត្ថម្ភ
ជាពុទ្ធបរិស័ទដ៏ឧត្តម ទ្រង់ឡាយព្រះហស្តលេខាធិការ ព្រះពាន្ធុញ្ញាត
ព្រះពុទ្ធគ្រិត្យ បង្កើតឲ្យមានសាលារៀនធម្មវិន័យ គ្រប់វត្តទូទៅក្នុង
ព្រះពុទ្ធអាណាចក្រ, ហើយព្រះអង្គបានទ្រង់ព្រះផ្ទៃជាកិត្តិការៈក្នុងព្រះ
ពុទ្ធសាសនាពីថ្ងៃទី ១៤ កើត ខែទុតិយាសាធ ឆ្នាំកុរនពស័ក ព. ស.
២៤៩០ គឺថ្ងៃទី ៣១ កក្កដា គ ស. ១៩៤៧ ។ កាលទ្រង់ព្រះផ្ទៃរួច
ហើយទ្រង់ទំប៊ីនសិក្សាធម្មវិន័យចេះគ្រប់គ្រាន់ អាចសំដែងធម៌ទេសនា
ទូន្មានដល់ពុទ្ធបរិស័ទជាច្រើនកន្លែងបាន, ទ្រង់ព្រះផ្ទៃបាន ១ ព្រះ
វស្សាអស់រយៈកាលដ៏ខ្លីប៉ុណ្ណោះ ព្រះអង្គមានព្រះប្រាជ្ញាឆ្លៀវឆ្លាសវាង
វៃ ចេះធម៌វិន័យសព្វគ្រប់ ប្រហែលដូចជាព្រះថេរមានវស្សា ៦០ ។
កាលព្រះអង្គទ្រង់លាចាកសិក្ខាបទមកវិញ ទ្រង់ទំបំពេញព្រះពុទ្ធករ-
ណីយកិច្ច ក្នុងព្រះពុទ្ធអាណាចក្រ គឺទ្រង់ទំតាមការយកឯកភាពឲ្យមាន
សិទ្ធិបរិបូណ៌ ឲ្យពលរដ្ឋរបស់ព្រះអង្គ ឲ្យរួចអំពីសហភាពចាំងសែស

ដែលចង់ក្រែកដាត ១ សតវត្សមកហើយ សហគាពនោះបាក់ឆ័សែស
មិនត្រមថ្វាយតាមព្រះពជបំណង់សោះឡើយ ទ្រង់ក៏ទំាមការបានបន្តិច
ម្តង ។ រហូតដល់ទ្រង់លះបង់ព្រះពជកំង់ទឹង់មហាប្រាសាទចេញចាកព្រះ
ពជធានីយាង់ទៅកាន់នានាប្រទេស ដើម្បីតាមការយកឯកភាជ្យឲ្យបាន
បរិបូណ៌ ។ ទោះបីទំាប្រឹង់ដល់ម្ល៉ះនេះ ក៏បាក់ឆ័សែសមិនត្រមថ្វាយ នៅ
តែកាន់ខ្ជុកជាប់ស្អិតដាប ។ ទោះបីយ៉ាង់ដូច្នេះទ្រង់នៅតែទំាការមិន
ឈប់ មិនគង់នៅកង់ព្រះពជកំង់ទឹង់មហាប្រាសាទ មកគង់កង់ខែត្រ
បាត់ដំបង ទឹង់សៀមរាប ជាខែត្រស្រុយភាជ្យ ទ្រង់មិនត្រមប្រាស្រ័យ
ការទឹង់បាក់ឆ័ មានព្រះរុង្ការថា: ''បើបាក់ឆ័មិនថ្វាយឲ្យបរិបូណ៌ដាប
ណា មិនយាង់ទៅគង់កង់ព្រះពជកំង់ទឹង់មហាប្រាសាទដាបនោះ'' ។
ពលរដ្ឋកង់ខែត្រទំាង ១៤ ទំាងព្រះសង្ឃទឹង់ត្រហ្ម កាលបើបានដឹង
ដំណឹង់ដូច្នោះហើយ ក៏មានចិត្តរអាក់រអួលក្តួលក្តង់កង់ហឫទ័យវត្ត ស្រ-
ណោះដល់ព្រះបិយមហាក្សត្រ នាំដង្វាយសួយវៃមកអំពីទិសទំាង ៤
មានហិរញ្ញវត្ថុជាដើម មកថ្វាយព្រះអង្គនៅខែត្របាត់ដំបង សៀមរាប
រកចន្លោះថ្ងៃគ្មាន ហើយក្រាបទូលថា ' ដើម្បីសម្រេចឯកភាជ្យឲ្យបាន
បរិបូណ៌ យើង់ខ្ញុំព្រះអង្គជាពលរដ្ឋទឹង់ដើរតាមក្រោយព្រះបិយមហា-
ក្សត្រ'' ។ ហេតុដែលនាំទឹកចិត្តពលរដ្ឋឲ្យមានសមានឆន្ទៈ នាំដង្វាយ
មកថ្វាយព្រះអង្គអំពីទិសនានានេះ មិនមានលោកអ្នកណាមួយបង្គាប់

បញ្ហាការដម្រែវដ្ដនេះក៏ទេ គឺទឹកឃើញតែគ្រប់ ៗ ខែតែម្តង, នេះជា
ហេតុអស្ចារ្យយ៉ាងក្រៃលែង ។ ព្រះអង្គនេះហើយ ជាព្រះបាទធម្មិក
មិនមែនមានអង្គឯណាទៀតទេ, លោកអ្នកចាំងឡាយតែងនិយាយសង្ឃឹម
រកព្រះបាទធម្មិកជាយូរណាស់មកហើយ មិនចេះឃើញសោះ, ការស្មានំ
ពីដើមមកនោះខុសទេ គ្មានព្រះបាទធម្មិកឯណាក្រៅពីព្រះបាទសម្តេច
ព្រះនរោត្តម-សុីហនុវរ្ម័ននេះទេ ព្រះអង្គពិតជា "ព្រះបាទធម្មិក" ។
ចូរលោកអ្នកចាំងឡាយ គោរពបូជាដើរតាមក្រោយព្រះអង្គនេះចុះ ។

ដោយគុណានុភាពនៃព្រះរតនត្រ័យ នឹងវត្ថុដ៏សក្តិសិទ្ធិកង់លោក
ព្រមចាំងកុសលដ៏ប្រសើរក្នុងពេលនេះ យើងខ្ញុំព្រះអង្គសូមទទួលបង្អោន
ថ្វាយព្រះពជកុសលចំពោះព្រះប្រិយមហាក្សត្រ ព្រមចាំងព្រះពជវង្ស-
នុវង្ស សូមឲ្យទ្រង់គង់នៅក្នុងសិរីពជសម្បត្តិ ខ្ជាត់កយាជៈសុខសាន្ត
សម្រាន្តក្នុងព្រះកាយពល ដើម្បីសម្រេចព្រះធាវ គឺព្រះមេត្តាព្រហ្ម-
ហារ គ្រប់ដណ្តប់លើប្រជាជនក្នុងកម្ពុជវដ្ឋ កុំបីមានទុបស័គ្គមកពាំង
ព្រះពជប្អូនឡើយទ្រង់បានឡើយ ។

ម្យ៉ាងទៀតព្រះពជបំណងឯណា ដែលព្រះអង្គទ្រង់ទំពាមតាតាំ
យកឯកពជឲ្យបានបរិបូណ៌ដល់ប្រទេសកម្ពុជា ព្រះពជបំណងនោះ សូម
ឲ្យបានសម្រេចកុំបីអាក់ខានឡើយ ទឹងសូមឲ្យអស្ចារ្យសុខដែលកើតមាន
ក្នុងប្រទេសស្ងប់ផៅ ដោយគេជះនៃព្រះរតនត្រ័យ នឹងកុសលដ៏ប្រសើរ
ក្នុងពេលនេះ ។